ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

## ឆ្នាំគំរប់ ១៤ ភាគទី ១

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៦

គ.ស. ១៩៤២

# បញ្ជីរឿង

ទំព័រ


១ — ព្រះរាជពិធីអភិសេក នៃព្រះបាទសម្តេចព្រះនរោត្តម-សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី . . . . . . . . . . . . . . . . . . . . ៥

២ — ប្រវត្តិអក្សរសាស្ត្រខ្មែរ (សង្ខេប) លោកសឺដែសចាងហ្វាងសាលាបារាំងសែស នៅចុងបូព៌ាប្រទេសរៀបរៀង . . . . . . . . . . . . . . . . . . ៣១

៣ — ពង្សាវតារប្រទេសភេម ស្រង់យកអំពីគោលចារឹកផ្សេងៗ ក្នុងពង្សាវតារលោក (គឺពីឆ្នាំ ១៩៤១ មក) . . . . . . . . . . . . . . . . . . . . ៣៥

៤ — ប្រវត្តិពួកឧបាសក - ឧបាសិកា ជាសាវក - សាវិការបស់ព្រះពុទ្ធជាម្ចាស់ៈ ទី ១ ប្រវត្តិតបុស្សៈនិងភល្លិកៈ . . . . . . . . . . . . . . . . . . . . ៣៨

៥ — ច្បាប់ពាក្យចាស់ . . . . . . . . . . . . . . . . . . . . ៤១

៦ — ភូមិសាស្ត្រសង្ខេប នៃក្រុងម៉ានីល . . . . . . . . . . . . . . . . ៤៤

៧ — រឿងព្រេងខ្មែរៈ រឿងស្រីពីរនាក់ជិះល្ពៅមក្នុងគ្នា . . . . . . . . . . . . . ៤៩


## រូបក្រៅរឿង


ព្រះបរមឆាយាល័ក្ខណ៍ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម - សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី . . . . . . . . . . . . . . . . . . . . ១

# TABLE DES MATIÈRES


Pages

1. Cérémonies du Couronnement de S. M. Préas Bat Samdach Préas Norodom-Sihanouk Varman, Roi du Cambodge.. 5
2. Littérature cambodgienne, par Monsieur G. Cœdès, Directeur de l'École française d'Extrême-Orient............ 31
3. Histoire de Rome. Extrait de divers documents de l'histoire universelle (suite de 1941)...................... 35
4. Vies des disciples laïques du Bouddha: La vie de Tapussa-Bhallika.................................... 38
5. Chbab Péakchas (Bons conseils en vers)................ 41
6. Géographie sommaire de Manille........................ 44
7. Conte populaire cambodgien inédit: " Deux femmes se disputent un enfant "................ 49

HORS TEXTE

Portrait du S. M. Préas Bat Samdach Préas Norodom-Sihanouk Varman.................................... 1


Cl. B.T.

ក្រុងកម្ពុជាធិបតី

# ព្រះរាជកំណាត់បុណ្យរាជាភិសេក

## ព្រះបាទសម្តេចព្រះនរោត្តម - សីហនុ វរ្មន

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី ជាម្ចាស់ជីវិតលើត្បូង

*ទ្រង់ប្រសូតក្នុងក្រុងភ្នំពេញ*

*នៅថ្ងៃអង្គារ ១១ កើតខែកត្តិក ឆ្នាំចត្វាស័ក ពុទ្ធសករាជ ២៤៦៦*

*ត្រូវនឹងថ្ងៃ ៣១ ខែឧកតូប្រ៍ ឆ្នាំ ១៩២២ ។*

ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម - សីហនុ ព្រះរាជនត្តានៃព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្សព្រះបរមទត្តិយកោដ្ឋបានឡើងសោយរាជសម្បត្តិតពីព្រះបរមរាជអយ្យកោ នៅថ្ងៃពុធ ១២ រោចខែចេត្រ ឆ្នាំម្សាញ់ត្រីស័ក ពុទ្ធសករាជ ២៤៨៤ ត្រូវនឹងថ្ងៃ ២៣ ខែអាវ្រីល គ្រិស្តសករាជ ១៩៤១ ។

១

# របៀបតាក់តែង

ក្នុងព្រះទីន័ងទេវាវិនិច្ឆ័យ ដែលនឹងរៀបព្រះរាជពិធីពេញអក្ខរៈនឹង តាំងព្រះរាជមណ្ឌលធំ មានគ្រែពិធីជាទីដាក់ព្រះពុទ្ធរូបព្រះទេវរូបនឹង គ្រឿងបញ្ចកកុធភណ្ឌ នឹងវិប្រជុំបុណ្យធំខាងមុខព្រះមហាស្វេតច្ឆត្រព្រះ បល្ល័ង្ក ។ មានករទេព្ដា ៣ ថ្នាក់ ៨ ទិសជុំវិញព្រះទីន័ងទេវាវិនិច្ឆ័យនឹង ករទេព្ដាធំ ៧ ថ្នាក់ ១ ទៀតតាំងខាងមុខព្រះទីន័ងទេវាវិនិច្ឆ័យ ។ តាំងព្រះ បល្ល័ង្ក ៩ជាន់ មានព្រះមហាបុស្សបុកមាសសម្រាប់ថ្វាយទឹកស្រង់ខាង ទិសបូព៌ានៃព្រះទីន័ងទេវាវិនិច្ឆ័យ ។ សង់រោងមណ្ឌល ៤ ទិសជុំវិញតាម ព្រះទ្វារក្រៅកំពែងព្រះបរមរាជវាំង រោងមណ្ឌលមួយៗទំហំ ៤ ម៉ែត្រ ៤ ជ្រុងស្មើ លើករានក្រាលក្ដារមានរបៀងនឹងព្រះរាជវ័តជុំវិញ មានករទេព្ដា ៣ ថ្នាក់ ១ នឹងជង់គោមលាបថ្នាំ ១ មានគោម ១ អុជគ្រប់រោងមណ្ឌល ។

ព្រះសង្ឃខាងគណៈតាំងពីគណៈ នឹងសេនាបតីនាហ្មឺនសព្វមុខមន្ត្រី ទៅក្រមក្នុងក្រុងនឹងក្នុងខេត្តនៃព្រះនគរ តាំងគ្រឿងសក្ការបូជាគោរព ទេវតាក្នុងថៃក្នុងកំពែងសីមានៃព្រះបរមរាជវាំង ។

ត្រូវក្រុមរាជបណ្ឌិត ព័ទ្ធអារម្ភសីមាគ្រប់ព្រះទីនាំង ព្រះដំណាក់ទាំងអស់ មកប្រជុំនៅត្រពិធីសូត្រមន្តក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ:

១ – ព្រះកេនមណ្ឌលធំគឺព្រះទីនាំងទេវាវិនិច្ឆ័យ ត្រូវសម្តេចព្រះឥស័កត្វាធិបតី ១, ព្រះព្រហ្មាធិរាជ ១, ព្រះមុន្ទូរ ១, ព្រះជយាធិបតី ១, ព្រះធម្មរាជ ១, ព្រះបរមាចារ្យ ១, ព្រះទេពាចារ្យ ១, ព្រះឥន្ទ្រកោរព្ក-ការ ១ ជា ៨ នាក់ កាន់ព្រឹតតាំងព្រះរាជពិធីចំរើនព្រះសិទ្ធសេក្តស់ស័ន្ធ ។

២ – កេនមណ្ឌលទិសបូព៌ ត្រូវព្រះអារ្យសាល ១ និងបាគូ ៣ នាក់ កាន់ព្រឹតតាំងព្រះរាជពិធីចំរើនព្រះសិទ្ធសេក្តស់ស័ន្ធ ។

៣ – កេនមណ្ឌលទិសទក្សិណ ត្រូវព្រះធម្មរតន៍ ១ និងបាគូ ៣ នាក់ កាន់ព្រឹតតាំងព្រះរាជពិធីចំរើនព្រះសិទ្ធសេក្តស់ស័ន្ធ ។

៤ – កេនមណ្ឌលទិសបស្ចិម ត្រូវព្រះធម្មាចារ្យ ១ និងបាគូ ៣ នាក់ កាន់ព្រឹតតាំងព្រះរាជពិធីចំរើនព្រះសិទ្ធសេក្តស់ស័ន្ធ ។

៥ – កេនមណ្ឌលទិសឧត្តរ ត្រូវព្រះឥន្ទ្រសរជ័យ ១ និងបាគូ ៣ នាក់កាន់ព្រឹតតាំងព្រះរាជពិធីចំរើនព្រះសិទ្ធសេក្តស់ស័ន្ធ ។

---

## ២

## ទី ១ ថ្ងៃសៅរ៍ ៦ កើតខែកត្តិកគឺថ្ងៃ ២៥ ឧកតូប្រ៍

វេលាម៉ោង ១២ ដល់ម៉ោង ៤ រសៀល — រៀបពិធីឡើងព្រះទីនាំងព្រះមហា-មន្ទីរជាទីប្រថាប់ នឹងក្រឡាព្រះបន្ទំព្រះករុណាជាម្ចាស់ជីវិតលើត្បូង ជាប់

នឹងព្រះទីនាំងទេវាវិនិច្ឆ័យ មានព្រះបល្ល័ង្កស្វេតច្ឆត្រ ខាងក្នុងសម្រាប់ទទួលក្រុមស្ត្រីត្រង់ព្រះមហាមន្ទីរ មានព្រះទីនាំងចក្រពត្តិជាទីក្រឡាព្រះបន្ទំព្រះករុណា នៅខាងត្បូង នឹងព្រះទីនាំងនារីរត្នសោភាជាទីក្រឡាបន្ទំសម្រាប់ព្រះមហេសីឬព្រះស្នំ នឹងហោគ្រឿងជាទីសោយឬទុកគ្រឿងទ្រង់នៅខាងលិច ។

ព្រះករុណាទ្រង់ព្រះពស្ត្រសារបាប់ ស្ដេចយាងព្រះបាទលើមាគ៌ាក្រាលសំពត់សលើកទ្រូល តាមក្បួនហែពីព្រះមហាប្រាសាទខេមរិន្ទ ចូលទៅឡើងព្រះទីនាំងព្រះមហាមន្ទីរតាមទំនៀម ។ ឧកញ៉ាវាំង សេនាបតីព្រះបរមរាជវាំង ត្រូវចាំទទួលព្រះករុណាក្នុងព្រះទីនាំងព្រះមហាមន្ទីរ ។

ទីស្ដេចក្សត្រីនឹងព្រះស្នំក្រមការនឹងជំទាវខុនណាង ក្រាបបង្គំគាល់ក្នុងព្រះទីនាំងមហាមន្ទីរនឹងក្នុងព្រះទីនាំង ចក្រពត្តិ / នារីរត្នសោភា ។

ទីស្ដេចក្រោមនឹងសេនាបតី នាហ្មឺនសព្វមុខមន្ត្រី ក្រាបបង្គំគាល់ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យមុខព្រះមហាបល្ល័ង្កស្វេតច្ឆត្រ ។

ម៉ោង ១៧ នឹង ៣០ មីនុត គឺម៉ោង ៥ កន្លះល្ងាច — ព្រះករុណាថ្វាយបង្គំថ្វាយព្រះបិតរក្នុងហោព្រះអដ្ឋិ ។

ម៉ោង ១៨ គឺម៉ោង ៦ ល្ងាច — ឧកញ៉ាហោរាធិបតី តាងហ្វាង សូត្រ ប្រកាសទេវតា ចូលបុណ្យរាជាភិសេកនៅក្នុងរោងធំខាងមុខព្រះទីនាំង ទេវាវិនិច្ឆ័យ ។

ម៉ោង ១៨ និង ៣០ មីនុតគឺម៉ោង ៦ កន្លះល្ងាច — អ្នកនាទីប្រចាំត្រៀមសក្ការបូជាក្នុងព្រះបរមរាជពិធីទាំងពីរ ខាងក្នុង ខាងមុខព្រះទីនាំងទេវាវិនិច្ឆ័យ និងត្រៀមតាំងតុ ។

ព្រះករុណាទ្រង់ព្រះពស្ត្រាសាបាច់ ទីងព្រះភូសាសាបាច់ ព្រមទាំងគ្រឿងព្រះកដកសេរ្តយសយស ស្តេចយាងព្រះបាទតាមក្បួនហែ មានមហាតលិកកាន់ផ្កាមាស ៤ ផ្កាប្រាក់ ៤ ប្រណម្យហែមុខនិងបុរសជំទង់កញ្ញាញគ្រឿង ១៦ នាក់ហែក្រោយ ។ ហែពីក្នុងព្រះទីនាំងព្រះមហាមន្ទីរ ចេញតាមព្រះជាយគ្រៀមមកគង់នៅព្រះទីនាំងទេវាវិនិច្ឆ័យ មានសម្តេចព្រះអស្សិកត្តាធិបតីអញ្ជើញព្រះទាកយណ៍ហែមុខ ។

ទ្រង់ប្រថាប់លើព្រះទីនាំងរាជអាសន៍ អុជគ្រឿងពុទ្ធបូជាថ្វាយបង្គំព្រះរតនត្រ័យ ហើយស្តេចយាងទៅអុជទៀនជ័យជាមួយនឹងព្រះសង្ឃនាយកក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ហើយទ្រង់ប្រគេនត្រៃចីវរដល់ព្រះសង្ឃ ១៦ អង្គគ្រង់ រួចក្រុមសង្ឃការ៉ូនតាំងអាការនមាសីល និមន្តព្រះសង្ឃចំរើនព្រះពុទ្ធមន្តក្នុងពិធីសៀនព្រះទីនាំងមហាមន្ទីរនិងផ្ចិតព្រះស្វ័ស្ដិ៍ស្រេបព្រះពុទ្ធមន្តរក្សាប្រេងក្នុងពិធីរាជាភិសេក ។

ព្រះរាជវង្សានុវង្សគ្រប់អង្គទាំងសេនាបតី នាហ្មឺនសព្វមុខមន្ត្រី ទៅក្រុមក្នុងក្រុងទាំងក្នុងខែត្រ ស្លៀកសំពត់ទាំងពាក់អាវសារបាប់ពណ៌ ល្បៀកប្តូរជាមួយនឹងគ្រឿងឥស្សរិយយស ជួបជុំក្រាបថ្វាយបង្គំគាល់តាមដំណែងក្នុងព្រះទីន័ងទេវាវិនិច្ឆ័យ ។ ព្រះសង្ឃចំរើនព្រះពុទ្ធមន្តរួចព្រះករុណាស្តេចយាងចូលតាមក្លោងទ្វារហៅទៅប្រថាប់ក្នុងព្រះទីន័ងចក្រពត្តិ ទ្រង់គ្រឿងពណ៌ស ទទួលសមាទានសីលក្នុងព្រះទីន័ងទ្រង់ធម៌ជាបរិសុទ្ធក្នុងព្រះអង្គ ។

ម៉ោង ២០ គឺម៉ោង ៨ យប់ — លៀងភោជនាហារព្រះរាជវង្សានុវង្សសេនាបតី នាហ្មឺនសព្វមុខមន្ត្រី ។

ពីម៉ោង ២១ ដល់ម៉ោង ២៤ គឺពីម៉ោង ៩ យប់ ទៅដល់អធ្រាត្រ — រាំល្ខោនក្នុងរោងព្រះទីន័ងពិធីបុណ្យ និងល្បែងមហោស្រពខាងមុខព្រះលាន អុជកាំជ្រួចរន្ទាក្បៀទៀន ។

## គំរប់ ២ ថ្ងៃអាទិត្យ ៧ កើតខែកត្តិក គឺ ២៦ ឧក្តូប្រ៍

ម៉ោង ៨ ព្រឹក — ព្រះករុណាទ្រង់ព្រះពស្ត្រពណ៌ហានក្រហម ស្តេចយាងតាមក្លោងទ្វារហោងដែល បញ្ចូនមន្តព្រះសង្ឃដែលបានចំរើនព្រះពុទ្ធ-មន្តពីល្ងាច សូត្រគាថាហុំថ្វាយ វេរព្រះភោជនាហារ ព្រះសង្ឃឆាន់ក្នុងព្រះទីន័ងទេវាវិនិច្ឆ័យ មានតន្ត្រីមហោរីលេងថ្វាយ រួចទ្រង់ប្រគេនទេយ្យទាន ។

ព្រះករវរក្សត្រី សេនាបតី នាហ្មឺនសព្វមុខមន្ត្រីក្នុងក្រុងទាំងក្នុងខែត្រ ស្លៀកពាក់ដូចផ្ដែងទាំងគ្រឿងឥស្សរិយយស ដូចជាក្រាបថ្វាយបង្គំគាល់ ។

លេងល្បែងមហោស្រពខាងមុខព្រះបរមរាជវាំងដល់ម៉ោង ១០ ព្រឹក ។

ព្រះករុណាព្រះរាជទានគ្រឿងឥស្សរិយយសដល់ខ្ញុំរាជការខ្មែរ ។

ពីម៉ោង ១៥ ដល់ម៉ោង ១៨ គឺពីម៉ោង ៣ រសៀលដល់ម៉ោង ៦ ល្ងាច — កាល្ខោន ក្នុងព្រះទីនាំងពិធីបុណ្យទាំងល្បែងមហោស្រពមុខព្រះលាន ។

ពីម៉ោង ១៨ ដល់ម៉ោង ២៤ គឺពីម៉ោង ៦ ល្ងាចដល់អធ្រាត្រ — របៀបបុណ្យដូចថ្ងៃទី ១ ។

## គំរប់ ៣ ថ្ងៃចន្ទ ៨ កើតខែកត្តិក គឺ ២៧ ឧកតូប្រ៍

របៀបបុណ្យដូចថ្ងៃគំរប់ ២ ។

## គំរប់ ៤ ថ្ងៃអង្គារ ៩ កើតខែកត្តិក គឺ ២៨ ឧកតូប្រ៍

ថ្ងៃអង្គារនេះថ្ងៃទ្រង់ប្រសូត ។

ម៉ោង ៧ ព្រឹក — ជាមហាវិជយមង្គលបុត្យ ព្រះករុណាទ្រង់គ្រឿងព័ណរិស ព្រះភូសាជាយស ស្តេចយាងតាមក្បួនហែដូចដែលមកក្នុងព្រះ

ទីន័ងទេពវិនិច្ឆ័យ ពារគ្គុំស័ទ្ធគ្រៃលែងពីងពាំងទឹងប្រគំតូរ្យតន្ត្រីថ្វាយ
តាមទំនៀម ព្រះករុណាថ្វាយបង្គំព្រះពុទ្ធរូបព្រះទេវរូប និមន្តព្រះសង្ឃ
ដែលសូត្រព្រះពុទ្ធមន្តពីល្ងាចសូត្រជយន្តោថ្វាយជ័យស្រេច ហើយព្រះ
ករុណាទទួលលោកឡើងតូវៃរណើរហៀរលោកល់ដីឡាំងដូស៊ីនទីនលោក
ឡើរស៊ីដងត៍សុរប៉ារយ៉ាក្រឹនក្រែងកម្មផាផាំមួយទីងសម្តេចព្រះសង្ឃនាយក
ទាំងពីរគណៈទីងសេនាបតីទីងសម្តេចព្រះឥសីភក្តាធិបតី ហែះស្តេចយាង
ឡើងលើព្រះបល្ល័ង្កក្រោមព្រះមហាបុស្សបុក គាំងទាងមុខព្រះទីន័ង
ទេពវិនិច្ឆ័យ ព្រះករុណាគង់លើផែនសុវណ្ណដារដ៏រចនាទីនដាក់ហ៊ុំល
ជាភាគកជសីហ៍ ក្រាលលើស្លឹកឧទុម្ពព្រឹក្ស សម្តេចព្រះឥសីភក្តាធិបតី
ថ្វាយស័ព្ទជ័យព្រឹក្ស[១] ព្រះករុណាទ្រង់ទទួលកាន់ដោយព្រះហស្តស្តាំផា
ព្រះគេជះបេស្តាហើយទ្រង់ឈមព្រះភក្ត្រៈទៅបូព្វទិស ។

ចៅញ៉ាហោកធិបតីបានហ្លួងក្រុមហោរ សូត្រប្រកាសអញ្ជើញ
ទេវតាសូមចំរើនសិរីសួស្តីជយមង្គលថ្វាយព្រះករុណា នៅវិកទទេត្តាហើយ
សក្ខណាគាំគ្រើនធំ ២១ ណាត[២] ។

ព្រះសង្ឃនាយកទាំងពីរគណៈថ្វាយព្រះឧទកធារាពុទ្ធមន្តស្រេច
សម្តេចព្រះឥសីភក្តាធិបតីថ្វាយព្រះសិទ្ធរសក្នុងស័ព្ទទ្រង់ស្រង់យោងព្រះ
កេសាតាមទំនៀម សម្តេចព្រះឥសីភក្តាធិបតីថ្វាយស្លឹកញ៉ោះសៀតព្រះ
កាណកិច្ចេន ។

---

១ ស្លឹកជ័យព្រឹក្ស ។ ២ បាញ់កាំភ្លើងធំបាជ័យឬក្ស ២១ ណាត ។

លោកឡឺគូវែរណ័រហ្សេណេរ៉ាល់ លោកឡឺរេស៊ីដង់ស៊ុបេរីយ៉ើរ ទាំងសេនាបតី ក៏ជួយថ្វាយព្រះសព្ទរស ទ្រង់ស្រង់រួចហើយស្តេចយាងចុះមក ត្រូវព្រះកមាភផាធំបតីចាងហ្វាងក្រុមព្រះវង្ស ស្រង់ព្រះបាទព្រះករុណា ទឹងទឹកជូនទឹកអប់លាយជាសមាសជាសប្រាក់ រួចស្តេចយាងទៅសណ្ឋិតលើព្រះវែនផ្លាស់ព្រះពស្ត្រព្រះភូសា ហើយស្តេចយាងចូលទៅក្នុងព្រះទីន័ងទេវាវិនិច្ឆ័យតាមក្បួនហែ យាងទៅប្រថាប់ក្នុងព្រះទីន័ងចក្រពត្តិវិញ ទ្រង់គ្រឿងព្រះពស្ត្រព្រះភូសាជាយវត្តកម្ពលតាមប្រវេណីមហាក្សត្រពីបុរាណពេញព្រះកដយស ។

ម៉ោង ៨ព្រឹក— ព្រះករុណាទ្រង់គ្រឿងសម្រាប់ព្រះមហាក្សត្រាធិរាជតាមក្បួនបែបធំដដែល ចេញមកក្នុងព្រះទីន័ងទេវាវិនិច្ឆ័យ សម្តេចព្រះឥស័កត្តាធិបតីទូលហែមុខ ទ្រង់ទទួលគំនាប់លោកឡឺគូវែរណ័រហ្សេណេរ៉ាល់ដឺឡាំងដូស៊ីន លោកឡឺរេស៊ីដង់ស៊ុបេរីយ៉ើរទាំងអស់អ្នកការអ្នកធំខ្ពង់ញុងថ្នាក់វិសេស ដែលមកជួបជុំជួយបុណ្យ រួចទ្រង់ថ្វាយបង្គំព្រះពុទ្ធរូបនឹងព្រះទេវរូប ទទួលសីលថ្វាយព្រះអង្គជាពុទ្ធឧបដ្ឋាក ជាធម្មឧបដ្ឋាក ជាសង្ឃឧបដ្ឋាក ហើយប្រកាសនាហារទឹងគ្រឿងទេយ្យទានប្រគេនព្រះភិក្ខុសង្ឃៗថ្វាយព្រះរាជមន្ទុទៅតាមឯកុដិ ។

ព្រះករុណាស្តេចយាងទៅប្រថាប់លើព្រះទីន័ងកៅអីក្រាលសបរិសុទ្ធ ឈមព្រះភក្ត្រទៅទិសបូព៌ា មានព្រះរាជគ្រូបាគ្រូបុរោហិតអន្ទ័យ

គាល់ជុំវិញទាំង៨ទិស មានបារគូគ្រែលែងពិណពាំង៨នាក់នឹងបារគូផ្លុំស័ង្ខ ទើបសម្តេចព្រះឥសីកម្ពុជាធិបតីថ្វាយព្រះឥស្សូរទ្រង់ឧបព្រះហស្តស្តាំ ថ្វាយព្រះនារាយណ៍ទ្រង់ឧបព្រះហស្តឆ្វេង ហើយព្រះរាជគ្រូអគ្គិយខាងទិសបូពិ សូត្រថ្វាយព្រះគាថាតាមទិស រួចទ្រង់បង្វិលព្រះអង្គជាទក្ខិណាព័ត៌ ឆ្ពោះព្រះភក្ត្រទៅទិសអគ្នេយ៍ ទិសទក្សិណ ទិសនិរតី ទិសបស្ចិម ទិសពាយ័ព្យ ទិសឧត្តរនឹងទិសឦសាន ត្រូវឲ្យបុរោហិតដែលអគ្គិយប្រចាំទិសសូត្រថ្វាយព្រះគាថាតាមទិសគ្រប់ៗទិសតាមចំនៀមព្រាហ្មណ៍ រួចទ្រង់ឆ្ពោះព្រះភក្ត្រទៅទិសបូពិវិញ ព្រះរាជគ្រូប្រចាំទិសទាំង៨ថ្វាយសិរីសួស្តីមហាជ័យមង្គលព្រមៗគ្នា រួចសម្តេចព្រះឥសីកម្ពុធិបតីថ្វាយព្រះសិទ្ធរសព្រះរាជស័ង្ខទ្រង់ស្រោយ ។

ឧកញ៉ាមហាទេពចាងហ្វាងក្រុមព្រះអាល័ក្ខណ៍ សូត្រព្រះសុវណ្ណបត្រថ្វាយព្រះនាម ។

ឧកញ៉ាមហាមន្ត្រីចាងហ្វាងក្រុមរឿនហ្លួង សូត្រថ្វាយព្រះមហាមកុដរាជនឹងរាជសម្បត្តិ សួយសារអាករ ក្នុងកម្ពុជរដ្ឋ នឹងព្រះរាជវង្សានុវង្សក្សត្រានឹងអគ្គមហាសេនា សេនាបតី នាហ្មឺនសព្វមុខមន្ត្រីរាជការគ្រប់ដំណែងគ្រប់ក្រុមទាំងខាងក្នុងខាងក្រៅ នឹងស្រែចំការចម្ការដំណាំទឹកដីព្រៃភ្នំក្នុងខេត្រខណ្ឌសីមានៃកម្ពុជរដ្ឋទាំងថ្វាយសព្វសារពើ រួច

ព្រះរាជវង្សានុវង្ស អគ្គមហាសេនា សេនាបតី នាហ្មឺនសព្វមុខមន្ត្រី ខ្ញុំរាជការទាំងអស់ ដែលមកជួបជុំនៅទីនោះ មានពានមានតុដាក់ដំកល់ គ្រឿងសម្រាប់យសស័ក្តិទីផ្កាទីងទៀនទឹកអប់ តាមយសស័ក្តិ ក្រាបថ្វាយបង្គំម្ដង ។

ព្រះករុណាទ្រង់មានព្រះរាជឱង្ការ ទូវព្រះបន្ទូលសួរសុខ នាំព្រះរាជទានសាធុការពរ ហើយទ្រង់ព្រះរាជទានគ្រឿងសម្រាប់យសស័ក្តិមុខងារ គ្រប់ដំណែង ឲ្យអស់ព្រះរាជវង្សានុវង្ស អគ្គមហាសេនា សេនាបតី នាហ្មឺនសព្វមុខមន្ត្រីទទួលធ្វើរាជការតាមដំណែងទូលព្រះតេជព្រះគុណ និងព្រះរាជទានស្រែចម្ការចក្រដំណាំទឹកដីព្រៃភ្នំ ឲ្យអស់ខ្ញុំរាជការប្រជានុរាស្ត្រនៅធ្វើបរកស៊ីដោយសុខក្សេមក្សាន្តជាធម្មតាដូចដែលវិញ ។

ខ្ញុំរាជការទាំងអស់ទទួលក្រាបថ្វាយបង្គំម្ដង ។

ព្រះករុណា គង់លើព្រះទីនាំងកៅអីមាស ។

លោកឡឺគូវែរណឺរហ្សេណេរ៉ាល់ទីនៈ លោកឡឺរេស៊ីដង់ស៊ុប៉េរីយើរ ចូលថ្វាយគំនាប់ជួបជុំប្រជុំធំ នាំពាណិជ្ជ៍ខាងថ្វាយសព្ទសាធុការពរពីរាជ-ការគូវែរណឺម៉ង់ត៍បារាំងសែស ដែលទំនុកបំរុងក្រុងកម្ពុជាធិបតី ហើយអញ្ជើញទីនោះស្ដេចឡើងប្រថាប់លើព្រះបល្ល័ង្ករត្ន ក្រោមព្រះមហា-សេ្វតច្ឆត្រ ៩ ជាន់ សក្ដុណកាំភ្លើងធំ ២១ ណាត់ ហើយសម្ដេចព្រះ

ឥសិកម្មាធិបតីអញ្ជើញព្រះមហាមកុដរាជ ជូនទៅលោកឡឺគូវែរណ័រហ្សេណេរ៉ាល់ៗថ្វាយព្រះករុណា តាងនាមរាជការក្រុងបារាំងសែស ។

អញ្ជើញព្រះខាន់រាជ ជូនទៅលោករេស៊ីដង់ស៊ុបេរីយើរៗថ្វាយទៅព្រះករុណា ៗទ្រង់ទទួលកាន់ដោយព្រះហស្តស្ដាំ ហើយសេនាបតីឌឹងទៅក្រសួងថ្វាយហានព្រះករ ព្រះសុព័ណ៌បាទុកទឹងគ្រឿងសម្រាប់កជ្យតាមទំនៀម ។

ខ្ញុំរាជការក្រាបថ្វាយបង្គំម្ដងទៀតជាគំរប់ ៣ ដងស្រេច ។

លោកឡឺគូវែរណ័រហ្សេណេរ៉ាល់ថ្លែងអធិប្បាយថ្វាយសព្ទសាធុ-ការពរ ។

ព្រះរាជគ្រូហោរស្ដេចយាងចុះមកគំនាប់លោកឡឺគូវែរណ័រហ្សេណេ-រ៉ាល់និងលោករេស៊ីដង់ស៊ុបេរីយើរ ហើយទ្រង់សូត្រព្រះរាជសក្ការតបព្រះតេជព្រះគុណក្រុងបារាំងសែសដែលជួយការពារព្រះនគរ និងរាជការក្រុងកម្ពុជាធិបតី និងជួយជាអធិបតីក្នុងការបុណ្យរាជាភិសេកព្រះអង្គ ។

លោកឡឺគូវែរណ័រហ្សេណេរ៉ាល់និងលោករេស៊ីដង់ស៊ុបេរីយើរ និងមហាជនបារាំងសែស ដែលមកជួបជុំទាំងអស់ថ្វាយគំនាប់លាព្រះករុណាចេញទៅវិញ ។

ម៉ោង ១០ ព្រឹក — ព្រះករុណាស្ដេចយាងតាមក្បួនហែចូលទៅវិញ ដល់ព្រះទីនាំងទក្សិណ ប្រថាប់លើព្រះថែន ។ ទើបអ្នកអគ្គរាជទូតនិស្ស

ក្រាបបង្គំទូលជូនថ្វាយអស់ព្រះរាជវង្សានុវង្សក្សត្រី និងព្រះស្នំក្រមការ ព្រះស្រីស្គារទាំងសព្វសាធុការពរ ។

ករិយាបានហៅក្រុមរឿងហ្លួងក្រាបបង្គំទូលជូនថ្វាយជំទាវខុន-ណាងនឹងខ្ញុំរាជការស្ត្រីគ្រប់ក្រុម ហើយថ្វាយសាធុការពរ ។

អស់ព្រះរាជវង្សានុវង្សស្ត្រីនិងព្រះស្នំក្រមការព្រះស្រីស្គារជំទាវខុនណាងនឹងខ្ញុំរាជការស្ត្រីគ្រប់ក្រុម មានផ្កាទំនេះទៀតទឹកអប់ដំកល់លើពានទលិតតាមយសស័ក្តិគ្រប់គ្នាក្រាបថ្វាយបង្គំម្ដង ។

ព្រះករុណាទ្រង់មានព្រះរាជឱង្ការព្រះរាជទានសព្វសាធុការវិញ អស់ខ្ញុំរាជការស្ត្រីក្រាបថ្វាយបង្គំម្ដង ។

ព្រះករុណាទ្រង់យាងចូលទៅក្នុងព្រះទីនាំងចក្រពត្តិ អស់ខ្ញុំរាជការស្ត្រីក្រាបថ្វាយបង្គំម្ដងទៀតជាគំរប់ ៣ ដងស្រេច ។

ម៉ោង ១០ និង ៣០ មីនុតព្រឹក — ព្រះករុណាទ្រង់គ្រឿងព័ណ៌ជាផលស្ដេចព្រះរាជដំណើរយាងចេញតាមក្បួនហែមកក្នុងព្រះទីនាំងទេវាវិនិច្ឆ័យជួបជុំព្រះរាជវង្សានុវង្ស អគ្គមហាសេនា សេនាបតី នាហ្មឺនសព្វមុខមន្ត្រី ថ្វាយព្រះទក្ខិណាបង្វិលព្រះពពិល ១៩ ជុំ ។

លែងមនុស្សទោសគ្រប់គុកក្នុងព្រះនគរ តាមព្រះរាជប្រកាស តាមសេចក្ដីសុំពីក្រសួងយ៉ុសេនាបតី ។

ម៉ោង ២០ គឺម៉ោង ៨ យប់ - ព្រះករុណា ទ្រង់ទទួលលៀងភោជនាហារ លោកឡឺគូវែរណឺរហ្សេណេរ៉ាល់និងលោកឡឺរេស៊ីដង់ស៊ុប៉េរីយ៉ើរ ។

ម៉ោង ២២ គឺម៉ោង ១០ យប់ — រាំល្ខោនព្រះរាជទ្រព្យនឹងកំសាន្តក្នុង ព្រះពន្លាច័ន្ទឆាយា ។

## គំរប់ ៥ ថ្ងៃពុធ ១០ កើតខែកត្តិក គឺ ២៩ ឧកតូប្រ៍

ម៉ោង ៧ ព្រឹក — ព្រះករុណា ទ្រង់គ្រឿងព្រះពស្ត្រព្រះភូសាសំរប់ ព្រះមហាក្សត្រាធិរាជ ទ្រង់ព្រះមហាមកុដពេញព្រះរាជយស ស្តេចយាងតាមក្បួនហែចេញពីព្រះទីនាំងទេវាវិនិច្ឆ័យ សក្ខណាកាំភ្លើងធំ២១ ណាក់ ស្តេចយាងឡើងគង់ព្រះរាជយានមាសព្រមដោយក្បួនហែធំ ទីនព្រះរាជវង្សានុវង្សទ្រង់ព្រះពស្ត្រសារបាប់ព្រះភូសាដោយពណ៌ ឬព្រះភូសាស័ក្តិព្រះមាលាកាស សេនាបតីយោធាសេនាបតីតួយៀង ចេញប្រទក្សិណព្រះនគរតាំងពីមុខព្រះលានទៅទិសបូព៌ បត់តាមថ្នល់ទៅទក្សិណ កេស៊ីស៊ុវត្ថិ ផ្លូវសុទ្ធាវង្ស ដល់ថ្នល់ទទឹងបត់ទៅទិសបស្ចិមតាមផ្លូវឡេង ស៊ីសុវត្ថិ បបត់តាមផ្លូវឧដារដេឡាក្រែ ដល់កន្លែងស្ពានទាគចាស់ ចូល ព្រះពន្លាគាក់ ១ ។

លោកឡឺរេស៊ីដង់ស៊ុប៉េរីយ៉ើរនឹងសម្តេចព្រះឥសិកត្ថាធិបតីចាំទទួល ព្រះករុណា ស្តេចចូលប្រថាប់ ព្រាហ្មណ៍ផ្លុំស័ង្ខថ្វាយជ័យថ្វាយព្រះសិរ្ទ-

សេក្តស់ស័ទ្ធយានព្រះកេសា ហើយទ្រង់ព្រះមហាផជាបញ្ចក្ជូដ ឡើងគង់លើព្រះកជវថេរឹមអស្សត្រា ៦ តាមក្បួនហោរាតាមផ្ទុះក្រោយវត្តកុ ចត់ទៅឯកើតទៅដល់កន្លែងស្ពានទន្ទុផទួតាស់ ចូលព្រះពន្លាគាក់ ១ ។

លោកឡឺរស៊ីដង់ស៊ុបេរីយើរទើនសម្ដេចព្រះឥសរក្តុងនិបតីចាំទទួលព្រះករុណា ព្រាហ្មណ៍ផ្ទុំស័ង្ខថ្វាយជ័យ ថ្វាយព្រះស័ង្ខសេក្តស់ស័ទ្ធយានព្រះកេសា រួចទ្រង់ព្រះមហាមាលា ឡើងគង់ព្រះវិទ័ងអស្សត្រាតាមញ្ញាំ មកដល់មុខមន្ទីរប្រឹក្សាក់ស្ដេចចូលប្រថាប់ មានក្រុមយុទ្ធនាថ្វាយគំនាប់ ។

មានលោកឡឺគូវែរណើរហៅ្រណេកល់ទើនលោកឡឺរស៊ីដង់ស៊ុបេរីយើរ ទទួលថ្វាយសាធុការ ព្រាហ្មណ៍ផ្ទុំស័ង្ខថ្វាយជ័យ ថ្វាយព្រះទកក្តុស់ស័ទ្ធយានព្រះកេសា រួចស្ដេចទ្រង់ព្រះមហាមាលាទ្រង់ប្រពាត ឡើងគង់លើព្រះវិទ័ងគជេន្ទ្រព្រះកជដំណើរតាមក្បួនហោរចូលក្នុងព្រះបរមកជាំង ដល់កើយភាំងមុខព្រះទីនាំងសម្រាន្តកិរេ្យ ទ្រង់យាងតាមព្រះទីនាំងសម្រាន្តកិរេ្យ សក្ខណាតាំងកើងផ ២៩ ណាក់ ។

លោកឡឺរស៊ីដង់ស៊ុបេរីយើរទើនសម្ដេចព្រះឥសរក្តុងនិបតីទទួលហែព្រះករុណាទៅក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ព្រាហ្មណ៍ផ្ទុំស័ង្ខថ្វាយជ័យ ថ្វាយព្រះស័ង្ខសេក្តស់ស័ទ្ធ រួចហែស្ដេចយាងតាមក្បួនហោចូលទៅប្រថាប់ក្នុងព្រះទីនាំងព្រះមហាមន្ទីរ ។

*ល្បែងមហោស្រពលេង ទីងល្ខោនកំដរដល់ម៉ោង ១៨ គឺម៉ោង ៦ រសៀលលើក ។ មុខពន្លាប្រាំបួនកំពូលអញ្ចែង ។*

ម៉ោង ២០ ដល់ម៉ោង ៨ យប់ – *លោកឡៅឌូវែណៅហៀរណាក់ទីងលោក ឡីសេស៊ីដង់សុប៉េរ្យើរ រៀបលៀងថ្វាយព្រះករុណាទ្រង់សោយ ឯមន្ទីរប្រតិភូកំពត ។*

## គំរប់ ៦ ថ្ងៃព្រហស្បតិ៍ ១១ កើតខែកត្តិក គឺ ៣០ ឧកតូប្រ៍

ម៉ោង ៦ ព្រឹក – *សាធុផលតាំងគ្រឿងសក្ការបូជា ។*

ម៉ោង ៨ ព្រឹក – *ពិធីទឹកព្រះវិស្សុទ្ធា ។*

ម៉ោង ១៣ ដល់ម៉ោង ៤ រសៀល – *ព្រះករុណាទ្រង់គ្រឿងឧក្កា ស្ដេចចេញលក់ទៀនជ័យ និងប្រគេនទេយ្យធម៌ដល់ព្រះសង្ឃក្នុងព្រះទីន ទៅវិជ្ជ័យ ។*

ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម- សីហនុ វរ្ម័ន
ព្រះចៅក្រុងកម្ពុជាធិបតីជាម្ចាស់ជីវិតលើត្បូង
ទ្រង់ព្រះរាជឧញ្ញាត
*ន. សីហនុ*

*ទទួលព្រះរាជឧត្តរទៅព្រះបន្ទូល*
*សូមសំពះនាទដាក់លើត្បូង*
ឧកញ៉ាភិនព្រៀងជ័យសេនាបតី
ព្រះបរមរាជវាំង, ធិលធារាធិការ,
ព្រះឃ្លាំងនិងរបោង ។

# របៀបក្បួនហែប្រទក្សិណ

ឯក្បួនហែក្នុងព្រះរាជពិធីពឹកជាតិលោក ព្រះករុណា ព្រះបាទសម្ដេច ព្រះនរោត្តម-សីហនុ វរ្ម័ន ជាម្ចាស់ជីវិតលើត្បូង កាលពីថ្ងៃ២៩ ខែឧត្តុបប្រ ឆ្នាំ១៩៦១ ដូចមានរបៀបក្បួនហែខាងក្រោមនេះ:

## ១– ក្រុមលោក ប៉ុក-ឃួន

| លេខរៀង | ជួរលេខ ១ | ជួរលេខ ២ | ជួរលេខ ៣ (កណ្ដាល) | ជួរលេខ ៤ | ជួរលេខ ៥ |
|---|---|---|---|---|---|
| ១ | | | ទង់មហាភជ | | |
| ២ | | ទង់សេនាសេះ | | ទង់ប្រាសាទ | |
| ៣ | | | ភ្លេងពិណពាទ្យ | | |
| ៤ | | | ភ្លេងបារាំងព្រះរាជទ្រព្យ | | |
| ៥ | | | ក្រុមទាហានជើងគោកជាតិឱរុប ព្រមទាំងភ្លេងត្រែ | | |
| ៦ | | | ក្រុមទាហានជើងទឹក ព្រមទាំងភ្លេងត្រែ | | |
| ៧ | | | ក្រុមទាហានពិជ័យស-ង្គ្រាម ព្រមទាំងភ្លេងត្រែ | | |
| ៨ | | | ក្រុមទាហានរក្សាស្រុក ព្រមទាំងភ្លេងត្រែ | | |

| លេខរៀង | ជួរលេខ ១ | ជួរលេខ ២ | ជួរលេខ ៣ (កណ្ដាល) | ជួរលេខ ៤ | ជួរលេខ ៥ |
|---|---|---|---|---|---|
| ៩ | | | ក្រុមទាហានរក្សាព្រះ ក្រុមទាំងភ្លេងត្រែ | | |
| ១០ | | | ភ្លេងក្លងខែក | | |
| ១១ | សេនាសេះ ស្ពាយក្របី ចំនួន ២៥ នាក់ | មាននាយសេ-នាសេះម្នាក់ | | មាននាយសេ-នាសេះម្នាក់ | សេនាសេះ ស្ពាយក្របី ចំនួន ២៥ នាក់ |
| ១២ | | | ភ្លេងដៃយ៉ាំ | | |

## ២— ក្រុមលោក ទង់-អួន-ម៉ម

| លេខរៀង | ជួរលេខ ១ | ជួរលេខ ២ | ជួរលេខ ៣ (កណ្ដាល) | ជួរលេខ ៤ | ជួរលេខ ៥ |
|---|---|---|---|---|---|
| ១៣ | | | ក្រុមតំណាងកូនសិស្សលីសេស៊ីសុវត្ថិ | | |
| ១៤ | តម្រួតកាន់បាច់ផ្កាចំនួន ៣០ នាក់ | មន្ត្រីចាម | | មន្ត្រីចាម | តម្រួតកាន់បាច់ផ្កាចំនួន ៣០ នាក់ |
| ១៥ | អ្នកកាន់ទង់ជាតិ ៣០ នាក់ | | ក្រុមភ្លេងពិណពាទ្យ | | អ្នកកាន់ទង់ជាតិ ៣០ នាក់ |

## ៣— ក្រុមលោក អ៊ុក-ធុប

| លេខរៀង | ជួរលេខ ១ | ជួរលេខ ២ | ជួរលេខ ៣ (កណ្ដាល) | ជួរលេខ ៤ | ជួរលេខ ៥ |
|---|---|---|---|---|---|
| ១៦ | ទកញ្ញាភគីភា-ត្កូលជិះសេះ | មន្ត្រីយួន | ក្រុមភ្លេងចាម | មន្ត្រីយួន | ទកញ្ញាទេពវរ-ដ្ឋណាជិះសេះ |

| លេខរៀង | ផ្លូវលេខ ១ | ផ្លូវលេខ ២ | ផ្លូវលេខ ៣ (កណ្ដាល) | ផ្លូវលេខ ៤ | ផ្លូវលេខ ៥ |
|---|---|---|---|---|---|
| ១៧ | អ្នកកាន់ទង់ ក្លែប ៣០ នាក់ | មន្ត្រីបិទ | ក្មេងកូនខែក | មន្ត្រីបិទ | អ្នកកាន់ទង់ ក្លែប ៣០ នាក់ |
| ១៨ | | មន្ត្រីកិត្តិយសខ្មែរ | ក្មេងចាម | មន្ត្រីកិត្តិយសខ្មែរ | |
| ១៩ | | ក្រុមដំណាងភស្ត្រីខ្មែរស្រុកកូសាំងស៊ីន | | ក្រុមដំណាងភស្ត្រីខ្មែរស្រុកកូសាំងស៊ីន | |
| ២០ | | ក្រុមដំណាងក្រសួងភាគការផ្សេងៗ | | ក្រុមដំណាងក្រសួងភាគការផ្សេងៗ | |

## ៤– ក្រុមលោក ជូ-ឡុង និងលោកពីឡូដ៍ម៉ុងតេរ៉ូ

| | | | | | |
|---|---|---|---|---|---|
| ២១ | សេនា ៤០ នាក់ កាន់ខែលនិងដាវ | មន្ត្រីខ្មែរដើរហែជាតិរដ្ឋ: មន្ត្រីនៅក្រុងថ្នាក់កណ្ដាល | មាសស្ដួរជ័យ ១ | មន្ត្រីខ្មែរដើរហែជាតិរដ្ឋ: មន្ត្រីនៅក្រុងថ្នាក់កណ្ដាល | សេនា ៤០ នាក់ កាន់ខែលនិងដាវ |
| ២២ | | មន្ត្រីនៅខេត្តស្ទឹងត្រែងនិងពោធិ៍សាត់ | | មន្ត្រីនៅខេត្តកំពង់ស្ពឺ | |
| ២៣ | | ក្រចេះ | | តាកែវ | |
| ២៤ | | សៀមរាប | | ស្វាយរៀង | |
| ២៥ | | ព្រៃវែង | | កំពង់ធំ | |

| លេខរៀង | ជួរលេខ ១ | ជួរលេខ ២ | ជួរលេខ ៣ (កណ្ដាល) | ជួរលេខ ៤ | ជួរលេខ ៥ |
|---|---|---|---|---|---|
| ២៦ | | កំពង់ឆ្នាំង | | កំពង់ចាម | |
| ២៧ | | កណ្ដាល | | កំពត | |
| ២៨ | | មន្ត្រីជាន់ខ្ពស់ នៅក្រុង ខាង ក្រសួងរដ្ឋបាល | មានគនជ័យ ១ | មន្ត្រីជាន់ខ្ពស់ នៅក្រុងខាងក្រ សួងតុលាការ | |

## ៥— ក្រុមលោក មាស-សាអែម

| លេខរៀង | ជួរលេខ ១ | ជួរលេខ ២ | ជួរលេខ ៣ (កណ្ដាល) | ជួរលេខ ៤ | ជួរលេខ ៥ |
|---|---|---|---|---|---|
| ២៩ | អ្នកកាន់ទង់ មករ ៣០ នាក់ | | ក្រុមភ្លេងខ្មែរ | | អ្នកកាន់ទង់ មករ ៣០ នាក់ |
| ៣០ | អ្នកកាន់ទង់ ឆ្មារ ៥ នាក់ | ព្រាហ្មណ៍ ៤ នាក់ត្រីពីង ពាំង | | ព្រាហ្មណ៍ ៤ នាក់ត្រីពីង ពាំង | អ្នកកាន់ទង់ ឆ្មារ ៥ នាក់ |
| ៣១ | | ព្រាហ្មណ៍ ៤ នាក់ផ្លុំស័ង្ខ | ស្គរខហោរធិត ១ | ព្រាហ្មណ៍ ៤ នាក់ផ្លុំស័ង្ខ | |
| ៣២ | | ហោរាម្នាក់ | | ហោរាម្នាក់ | |
| ៣៣ | អ្នកកាន់ផ្តិត ភ្ញាន ៤ នាក់ | | | | អ្នកកាន់ផ្តិត ភ្ញាន ៤ នាក់ |
| ៣៤ | | ព្រះវង្ស ២ | | ព្រះវង្ស ២ | |

| លេខរៀង | ជួរលេខ ១ | ជួរលេខ ២ | ជួរលេខ៣ (កណ្តាល) | ជួរលេខ ៤ | ជួរលេខ ៥ |
|---|---|---|---|---|---|
| | | | **៦—ក្រុមលោក ឱត-ស្រេន** | | |
| ៣៥ | | មន្ត្រីពីរនាក់ ស័ក្តិ ៩ ហ៊ូពាន់ ជិះសេះ គឺ លោកភា-សាន និងលោក ភិ-កាម៉ុល | លោកយោយភង ប៊ែន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជិះអង្រឹងស្នែង | មន្ត្រីពីរនាក់ ស័ក្តិ ៩ ហ៊ូពាន់ ជិះសេះ គឺ លោក ប៉ុក-ហៃល និង លោក គិន | |
| ៣៦ | | ឧកញ៉ាមហាទេពជិះសេះ | | ឧកញ៉ាមហាមន្ត្រី ជិះសេះ | |
| ៣៧ | | អ្នកអង្គម្ចាស់ ម៉ុងពណណាទ្រង់ គង់អង្រឹងស្នែង | | លោកអ៊ឹង-អ៊ីវផ្តី មន្ត្រីក្រសួងវាំង ជិះអង្រឹងស្នែង | |
| ៣៨ | | មន្ត្រីម្នាក់កាន់ ព្រះភិលវ័ជនី | | មន្ត្រីម្នាក់កាន់ ព្រះភិលវ័ជនី | |
| ៣៩ | អ្នកកាន់ដំព្រួត «អភិរម្យ» ៤ នាក់ | មន្ត្រីពីរនាក់ ថ្វាយព្រះក្រុត | ព្រះយានុមាសព្រះទីន័ង មានមនុស្សសែង ៨ នាក់ | មន្ត្រីពីរនាក់ ថ្វាយព្រះក្រុត | អ្នកកាន់ដំព្រួត «អភិរម្យ» ៤ នាក់ |
| ៤០ | | មន្ត្រីម្នាក់កាន់ ផ្ចិត «បាំង សែង» | មន្ត្រីម្នាក់កាន់ផ្ចិត «បាំងសែង» | មន្ត្រីម្នាក់កាន់ ផ្ចិត «បាំង សែង» | |

| លេខរៀង | ជួរលេខ ១ | ជួរលេខ ២ | ជួរលេខ ៣ (កណ្ដាល) | ជួរលេខ ៤ | ជួរលេខ ៥ |
|---|---|---|---|---|---|
| ៤១ | | លោក ចាន់-ណាក រដ្ឋមន្ត្រីអធិបតីសាលាវិនិច្ឆ័យ និងអង្រឹងស្នែង | | លោក មាស-ណាល់ រដ្ឋមន្ត្រីក្រសួងរដ្ឋា-ធិការ និងអង្រឹងស្នែង | |
| ៤២ | | | ចហាតលិកអញ្ជើញគ្រឿង ៨ នាក់ | | |
| ៤៣ | | មន្ត្រីក្រុមភូសាមាលាអញ្ជើញគ្រឿង ៥ នាក់ | | មន្ត្រីក្រុមភូសា-មាលាអញ្ជើញគ្រឿង ៥ នាក់ | |

## ៣— ក្រុមលោក ឡេង-ង៉ែត

| លេខរៀង | ជួរលេខ ១ | ជួរលេខ ២ | ជួរលេខ ៣ (កណ្ដាល) | ជួរលេខ ៤ | ជួរលេខ ៥ |
|---|---|---|---|---|---|
| ៤៤ | | ព្រះអង្គម្ចាស់ ១ អង្គកាន់ព្រះស-លៀង (ព្រះអង្គម្ចាស់ គីយ៉ែរ) | | អ្នកអង្គម្ចាស់ ១ អង្គកាន់ព្រះស-លៀង (អ្នកអង្គម្ចាស់កេតណា) | |
| ៤៥ | | ព្រះអង្គម្ចាស់ ២ អង្គទ្រង់កាន់អស្សុតរ | | ព្រះអង្គម្ចាស់ ២ អង្គទ្រង់កាន់អស្សុតរ | |
| ៤៦ | | | ព្រះមហាភិរបិទ័ម លេះ ៦ | | |

| លេខរៀង | ជួរលេខ ១ | ជួរលេខ ២ | ជួរលេខ ៣ (កណ្តាល) | ជួរលេខ ៤ | ជួរលេខ ៥ |
|---|---|---|---|---|---|
| ៤៧ | | មន្ត្រីម្នាក់ជិះសេះ (លោក ហៀង) | | មន្ត្រីម្នាក់ជិះសេះ (លោក ស៊ុខ-ហ៊ាង) | |
| ៤៨ | | ព្រះអង្គម្ចាស់ វឌ្ឍឍាយារង្ស គង់អង្រឹងស្នែង | | លោក ជួន-ហ៊ល ជិះអង្រឹងស្នែង | |
| ៤៩ | អ្នកកាន់ទង់ ជន្ត្រី ៣០ នាក់ | តម្រួតកាន់លំពែង ១៥ នាក់ | | តម្រួតកាន់លំពែង ១៥ នាក់ | អ្នកកាន់ទង់ ជន្ត្រី ៣០ នាក់ |
| ៥០ | | មហាតលិកព្រះ សែងជូន ៥ នាក់ | ព្រះទីន័ងអស្សតរ សម្រាប់ឡើងគង់ទី ១ | មហាតលិកព្រះ សែងជូន ៥ នាក់ | |
| ៥១ | | | ព្រះទីន័ងអស្សតរ សម្រាប់ឡើងគង់ទី ២ | | |

## ៨ — ក្រុមលោក អ៊ុក-លង់

| | | | | | |
|---|---|---|---|---|---|
| ៥២ | | គជេន្ទ្របម្លង សឹកកាំភ្លើងធំ ១ | ដំរីទីន័ងព្រះ ១ | គជេន្ទ្របម្លង សឹកកាំភ្លើងធំ ១ | |
| ៥៣ | | ដំរីបញ្ជិះពួក ភ្លេង ១ | | ដំរីបញ្ជិះពួក ភ្លេង ១ | |
| ៥៤ | អ្នកកាន់ដំបង ២៥ នាក់ | គជេន្ទ្រយោង ២ | ដំរី១ ទ្រមាក់២ ដើរជិ | គងជេន្ទ្រ យោង ២ | អ្នកកាន់ដំបង ២៥ នាក់ |

| លេខរៀង | ជួរលេខ ១ | ជួរលេខ ២ | ជួរលេខ ៣ (កណ្ដាល) | ជួរលេខ ៤ | ជួរលេខ ៥ |
|---|---|---|---|---|---|
| ៥៥ | | ដំរី ១ | | ដំរី ១ | |
| ៥៦ | | ទ្រមាក់ ១ កាន់ ចេកអំពៅ | ដំរីសេះតែងគ្រឿងមាសប្រាក់ ១ | ទ្រមាក់ ១ កាន់ ចេកនិងអំពៅ | |
| ៥៧ | | មន្ត្រីក្រុមដំរី ១ | | មន្ត្រីក្រុមដំរី ១ | |
| ៥៨ | | ដំរី ១ | | ដំរី ១ | |
| ៥៩ | អ្នកកាន់ដំបង ២៥ នាក់ | មន្ត្រីក្រុមវាំង ៥ នាក់ | ដំរីសឹកព្រះទីនាំង ១ | មន្ត្រីក្រុមវាំង ៥ នាក់ | អ្នកកាន់ដំបង ២៥ នាក់ |
| ៦០ | | | គជេន្ទ្រព្រះទីនាំងទី ១ | | |
| ៦១ | អ្នកកាន់ខ្សែ ២៥ នាក់ | មន្ត្រីក្រុមវាំង ៥ នាក់ | គជេន្ទ្រព្រះទីនាំងទី ២ | មន្ត្រីក្រុមវាំង ៥ នាក់ | អ្នកកាន់ខ្សែ ២៥ នាក់ |

# ដំណើរក្បួនហែ

*ចេញពីផ្លូវព្រះបរមរាជវាំង ផ្លូវអាវីទុយ ពញាយ៉ាត- កេស៊ីសុវត្ថិ- ផ្លូវសុធារស- ផ្លូវប៉ូលីការ ឡេនស៊ីសុវត្ថិ- ផ្លូវប៉ូលីការ ឌូដាដឺឡាក្រេ (ឈប់នៅចុងផ្លូវប៉ូលីការ ខានដើង) ផ្លូវក្ដី- ផ្លូវស្ដេចសឹក សូហ្វ ខានមុរប៉ុយរ៉ូ ជេស៊ីផន្សែស្សុប៉ារីយ៉េរ ប៉ូលីការ ម៉ុស ប៉ូលីការ ដីសម្បូ (ឈប់ត្រង់ផ្លូវបែកប៉ូលីការ ដីសម្បូ និងប៉ូលីការ ដំសុង) កេឡាត្រង់ទីរ៉ៃយ៉េរ (ឈប់នៅហោ-តិលឈេស៊ីផនីតស្សុប៉េរីយ៉េរ) កេនរកុម កេស៊ីសុវត្ថិ អាទិទុយពញាយ៉ាត ចូលមកព្រះបរមរាជវាំងវិញ ។*

## ព្រះរាជពិធីរាជាភិសេក

ព្រះបាទសម្តេចព្រះនរោត្តម-សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី

ព្រះរាជពិធីរាជាភិសេកនិងចំរើនព្រះជន្មវស្សាព្រះករុណាជាម្ចាស់ជីវិតលើត្បូង បានធ្វើតាមព្រះរាជកំណត់តាំងពីថ្ងៃ ២៨ ដល់ថ្ងៃ ៣០ ឧកតូប្រ៍ ឆ្នាំ ១៩៤១ ពុទ្ធសករាជ ២៤៨៤ ដូចមានសេចក្តីរាយការក្នុងព្រះរាជកំណត់ស្រាប់ ៗ

ក្នុងឱកាសប៉ុន្មានថ្ងៃនេះ មានមនុស្សម្នាមហាជនបានចូលមកមើលព្រះរាជពិធីនេះណែនណាន់តាន់តាប់ ៗ ថ្ងៃដែលមានមនុស្សច្រើនជាងគេ គឺថ្ងៃដែលហែប្រទក្សិណទីក្រុងភ្នំពេញ ៗ

កាលថ្ងៃដែលស្រង់ព្រះឧទកធារនោះ ព្រះករុណាជាម្ចាស់ជីវិតលើត្បូងទ្រង់ថ្លែងព្រះសុន្ទររាជបន្ទូល ដូចមានតទៅនេះ :

## សុន្ទររាជបន្ទូលក្នុងឱកាសរាជាភិសេក

### លោកអាមីរ៉ាល់ !

តាមពង្សាវតារនានាប្រទេសក្តី តាមទំនៀមទម្លាប់ផងទាំងឡាយក្តី រមែងតែងតែមានកិច្ចការសើរើធ្វើដូចដើមឡើងវិញដោយវេរគ្រា ៗ ជាដរាប ៗ

ដូចយ៉ាងព្រះបរមអយ្យកោទួតនៃទ្រង់ គឺព្រះបាទសម្តេចព្រះនរោត្តម កាលពីដើមក៏ទ្រង់បានទទួលគ្រឿងសម្រាប់រាជ្យពីលោកកាពីតេនដឺប្រៀ-

ភាគដេសមួយឡាំងក្នុងក្រុមជលធាធិការ ជាទៅក្រសួងអេកាមាំហ្ស៊ីរបស់លោកអាមីកាល់ដឹកឡាត្រង់ឱ្យនោះដែរ ឥឡូវនេះទៀត ក៏ជាពួកក្នុងក្រុមជលធាធិការទៀត ដែលទើបនឹងថ្វាយគ្រឿងសម្រាប់កង្សមកខ្ញុំអម្បាញ់មិញនេះ ។

ខ្ញុំសូមត្រេកអរសោមនស្សដល់ហេតុដែលបណ្ដាលឲ្យមានឱកាសមហាជ័យមង្គលក្នុងកង្ស អនុលោមស្របគ្នានឹងក្រុមជលធាធិការជាថ្មីទៀត ញ៉ាំងឲ្យពួកឃើញអំពីសេចក្ដីមេត្រីស្មោះសរជាដរាបរៀងមក មិនដែលមានផុយរលាស់អ្វីឡើយ ដែលជាប្រផ្នូលល្អចំពោះដល់រាជសម្បត្តិរបស់ខ្ញុំ ។

មួយវិញទៀត ខ្ញុំសូមថ្លែងសេចក្ដីអរគុណដល់លោក ដោយលោកបានខំឆ្លៀតក្នុងខណៈកាលដែលកំពុងមានព្រួយបារម្ភនេះ អញ្ជើញមកជួយក្នុងមហាពិធីដោយផ្ទាល់ខ្លួន ។ កាលប៉ុន្មានអាទិត្យមុននេះ លោកបានអញ្ជើញមកទទួលកាន់ទុក្ខថ្វាយព្រះករុណាព្រះបរមខត្តិយកោដ្ឋនៅប្របខ្ញុំម្ដងហើយ ឥឡូវនេះដែលលោកបានអញ្ជើញមកម្ដងទៀតជាគំរប់ ២ លើកនេះ គឺលោកមានសេចក្ដីមេត្រីរាប់អានដល់ព្រះករុណាព្រះបរមខត្តិយកោដ្ឋផង មានសេចក្ដីទុកចិត្តចំពោះដល់ខ្ញុំផង ។

សូមលោកអាមីកាល់ជ្រាប អំពីដែលលោកមេត្តាមានសទ្ធាទុកចិត្តដល់ខ្ញុំដូច្នេះ ខ្ញុំឥតមានបំណងអ្វីនឹងធ្វើឲ្យលោកបង់ចិត្តសោះឡើយ ។

គឺទ្រង់គោរពតាមក្រមាប់សុចរិតស្មោះត្រង់ ដែលជាដំណគរៀងៗ មកអំពីព្រះវង្សរបស់ទ្រង់ ហើយដោយទ្រង់បានរៀនសូត្រចេះដឹងមក ហើយ ទ្រង់ទើបមានព្រះទ័យកោតសរសើរដល់នគរដែលទ្រង់បានរៀន តាមវិជ្ជាសិល្បសាស្ត្រនោះជាដើម ទ្រង់មានព្រះរាជហឫទ័យប្តេជ្ញាមកថា នឹងជួយនគរបារាំងសែសយ៉ាងស្មោះនឹងយ៉ាងមាំមួន ដូចកាលដែលព្រះករុណាមុនៗ លោកបានជួយរៀងរាប់មកជិតចំនួន ៨០ ឆ្នាំហើយ ។

មួយទៀត ទ្រង់ក៏មានព្រះរាជហឫទ័យប៉ុនប៉ងនឹងជួយឧបត្ថម្ភដោយស្មោះសរក្នុងកិច្ចការលើកប់ស្រុកឱ្យបានដូចកាលដែលព្រះករុណាមុនៗ លោកបានយកព្រះទ័យទុកដាក់រៀងមកដូច្នោះដែរ ។

រាជសម្បត្តិនៃព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស ដែលទ្រង់ចាប់គ្រងមកដោយសុខសប្បាយជាបំផុតបានកំណត់ ១៩ ឆ្នាំនោះទើបនឹងកន្លងផុតទៅក្នុងខណៈដែលកំពុងមានហេតុជាទម្ងន់ដោយខ្សែកក្នុងព្រះនគរ ហើយនគរកម្ពុជាដែលធ្លាប់សុចរិតស្មោះត្រង់ចំពោះដល់នគរបារាំង-សែសរៀងមក ទុកណាជានគរបារាំងសែសមានទុក្ខរំពុកក្តី មានជ័យជំនះក្តី នោះក៏បានជួយរំលែកទុក្ខជាទម្ងន់ក្នុងអក័ក្ខដែលបណ្តាលកើតឡើងដោយអយុត្តិធម៌ដល់នគរបារាំងសែសនេះ ជាប៉ុន្មានដងមកហើយដែរ ។

(នៅមានត)

# អំពីអក្សរសាស្ត្រខ្មែរ

លោកសឺដែស រៀបរៀង

រឿងនេះមានសេចក្ដីពោលទុកក្នុងសៀវភៅមួយ និយាយអំពីប្រទេសឥណ្ឌូស៊ីន យើងមានសង្ឃឹមថា រឿងនេះនឹងមានប្រយោជន៍ដល់អ្នកមើលទស្សនាវដ្ដីរបស់យើងជាប្រាកដ ។

ប្រសិនបើលើកយកសព្ទថា "អក្សរសាស្ត្រ" តាមន័យដ៏ធំទូលាយនោះ គេគួរយកសិលាចារឹកខ្មែរជាន់ចាស់ៗ ទុកដូចជាចារឹកជាន់ដំបូងបំផុតនៃក្បួនអក្សរសាស្ត្រខ្មែរបាន ។

ចារឹកអក្សរខ្មែររបស់ស្រុកខ្មែរ ដែលជាគោលចារឹកជាងចាស់បំផុតឡើងទៅ កាលពីពុទ្ធសករាជ ១១៤០ នោះ សំដែងឲ្យឃើញថា តាំងអំពីដើមហូតមក មានការប្រើភាសាពីរបែបលាយចម្រុះគ្នាក្នុងសម័យជាមួយគ្នា គឺភាសាអ្នកប្រាជ្ញ ជាភាសាសំស្ក្រឹត សម្រាប់ប្រើកត់ត្រាធ្វើបញ្ជីព្រះរាជវង្សានុវង្ស ឬមហាក្សត្រ និងតែងសេចក្ដីសរសើរដល់ក្សត្រដែលទ្រង់កសាងប្រាសាទ ឬអស់លោកដែលមានចិត្តសទ្ធាជ្រះថ្លាធ្វើអំណោយទាន, ភាសាមួយទៀត ជាភាសាខ្មែរធម្មតា សម្រាប់កត់ត្រារាយរឿងការកសាងនិងសេចក្ដីរៀបរាប់ពួកមនុស្សបំរើ និងគ្រឿងប្រដាប់ប្រដា ដែលគេថ្វាយព្រះវិហារ ។

សេចក្ដីតែងជាភាសាសំស្រ្កឹត សុទ្ធតែរៀបរៀងជាពាក្យកាព្យសុទ្ធតែជាសេចក្ដីចងក្រងឲ្យមានចុងចួន ដែលពួកអ្នកសិក្សាអក្សរសាស្រ្តឥណ្ឌៀហៅថា គាវ្យៈ ។ ក្នុងរឿងនេះយើងមិនមានប្រស្នានឹងលើកពាក្យឃ្លោងនោះឡើងពិចារណាទេ ព្រោះពាក្យឃ្លោងទាំងនោះដែលពួកបណ្ឌិតនៅប្រទេសឥណ្ឌៀសុទ្ធ អាចនឹងមានសេចក្ដីពេញចិត្តបាន ចំពោះអ្នកប្រាជ្ញស្រុកគាយ ប្រសិនបើជាយើងដឹងប្រាកដថា អ្នកប្រាជ្ញទាំងនេះបានតែងដែរ យើងក៏ពុំអាចកប់ពាក្យឃ្លោងទាំងនោះបញ្ចូលក្នុងអក្សរសាស្រ្តខ្មែរយើងសុទ្ធសាតបានឡើយ ។

ប្រយោជន៍នៃសិលាចារឹកខ្មែរមានច្រើនជាអនេកប្រការណាស់ ព្រោះសិលាចារឹកនោះធ្វើឲ្យយើងដឹងរបៀបកិច្ចការជាន់ចាស់ផ្សេងៗ ក្នុងស្រុកទេសបានច្បាស់លាស់ល្អ តែតាមយោបល់យល់ឃើញអំពីអក្សរសាស្រ្តវិញ ឃើញថាអក្សរចារឹកអស់នោះសឹងមានដំឡៃត្រឹមតែធ្វើឲ្យស្គាល់សំដីភាសាជាន់ចាស់ប៉ុណ្ណោះឯង ។

បើដូច្នេះ នឹងថាខ្មែរបុរាណមិនបានបណ្ដុះបណ្ដាំទុកយើងទៀងពាក់អំពីរបៀបអក្សរសាស្រ្តនោះបានឬទេ ? សេចក្ដីនេះយកជាការពិតពុំបានឡើយ ។ ក្រៅអំពីចម្រៀងរបស់អ្នកស្រុក ដូចយើងនឹងពោលទៅខាងមុខនេះ ដែលជាទីចាប់ចិត្តណាស់របស់បណ្ដាកវីខ្មែរសព្វថ្ងៃនេះ ក្នុង

សម័យអង្គរនៅមានរឿងព្រេងធំៗរបស់ឥណ្ឌា ដូចជារឿងព្រះរាម ព្រះក្រឹស្ណៈ វិស្ណុ និងរឿងព្រះពុទ្ធជាម្ចាស់ដែលគេនិយមធ្វើចេញជារូបភាពរូបចម្លាក់នឹងក្បាច់ចំឡាក់ស្អេកស្អះទុកគង់ ៗ មកនោះ នាំឲ្យយើងយល់ឃើញថា ក្នុងសម័យនោះមុខជាគេបានប្រែរឿងក៏ពុកណាអស់នោះចេញមកជាភាសាអ្នកស្រុកដែរ ៗ មានសិលាចារឹកជាច្រើននិយាយពាក់ព័ន្ធដោយប្រវត្តិរបស់ក្សត្រទាំងឡាយ ព្រមទាំងការត្រួតត្រាពជអាណាចក្រខ្មែរសម័យនោះ មិនមែនជាមិនមានច្បាប់សម្រាប់ស្រុកទេ សឹងមានដល់ទៅស័ព្ទសម្រាប់តុលាការដោយឡែកថែមទៀត ព្រមទាំងវិជ្ជាផ្សេងៗ ដោយមុខៗរបស់ខ្មែរ មិនបាច់ពោលថាជាវិជ្ជាវិទ្យាសាស្ត្រក៏ដោយ ក៏គេបានចំឡងទុកជាក្បួនតូចៗ ដូចយើងឃើញមាននៅហូតដល់មកសព្វថ្ងៃនេះ ៗ នៅទីបំផុត ពួកអាមាត្យាធិបតេយ្យ ដែលធ្វើឲ្យអង្គររុងរឿងយ៉ាងពន្លឺកដូច្នោះ មិនមែនគ្មានវប្បធម៌ទេ ឯវប្បធម៌នោះសោតទៀត ក៏ប្រហែលជាមិនមែនផ្សាយចេញតែដោយសារភាសាសំស្ក្រឹតដែរ ៗ អក្សរសាស្ត្រអស់នេះ មានកើតឡើងជាពិតប្រាកដ ប៉ុន្តែមិនមានសេសសល់ដល់មកយើងបានសោះឡើយ . ដោយហេតុសម័យនោះគេប្រើសរសេរក្រមាផ្សេងៗ ដោយដិតពងលើស្បែកសត្វដែលធ្វើឲ្យមានពណ៌ខ្មៅ ម៉្លោះហើយក្រមាអស់នោះក៏ត្រូវបាត់បង់អស់ឥតសល់ គឺ

អន្តរាយដោយអំណាចសត្វល្អិតទាំងធាតុអាកាស មានតែជាតិថ្មទើបរង់ទល់គង់នៅបាន ។

អក្សរសាស្ត្រទំនើបថ្មី ខុសគ្នាស្រឡះនឹងអក្សរធម៌ខ្មែរសម័យបុរាណ ឯទីប្រាសាទដែលមានឆ្លាក់សេចក្តីជាន់ចាស់ជាភាសាខ្មែរនោះ មើលទៅក៏ហាក់ដូចជាថាវត្ថុដ៏អស្ចារ្យដែលកើតឡើងដោយឫទ្ធានុភាពរបស់ព្រះឥន្ទ្រនឹងព្រះវិស្សុកម្មជាជាងកសាងនៅស្ថានសួគ៌ ។ វត្ថុដែលគង់ទ្រង់នៅជាបែបអក្សរធម៌សម័យបុរាណខាងសាសនាព្រាហ្មណ៍គឺ ១ ក- រឿនកមកេរ្ត៍ ដែលជាសេចក្តីប្រែចេញអំពីរឿងរាមាយណៈ ថែមទាំងប្រែមិនបានចប់សព្វគ្រប់ផង ហើយថែមទាំងបំប្រួញជារឿងខ្លីៗដែលគេតែងនិ-យមលេងជាញឹកញយ ១២ – គម្ពីរត្រៃភេទត្រៃភូមិ ដែលមានដោច់ដោចពេកណាស់ គោលអំពីចក្រឡោក ។ វប្បធម៌ខ្មែរសម័យបុរាណដែលមានសេសសល់នៅជាដំណតមកក្នុងអក្សរសាស្ត្រខ្មែរទំនើបថ្មីនេះប្រហែលជាត្រឡប់មកតាមស្រុកសៀមនឹងតាមស្រុកលាវវិញទេ ។

(នៅមានត)

# ពង្សាវតារក្រុងរោម

(តទៅ)

## វគ្គទី ៣

### អំពីកំឡាំងទាហានខាងជ័យជំនះនៃក្រុងរោម

ក្រុងរោមបានធ្វើជាចៅហ្វាយលោកមុន ឯការដែលបានធ្វើជាចៅហ្វាយលោកនោះគឺបានដោយសារកំឡាំងទាហាន ហេតុដូច្នេះគួរតែយើងរៀនឲ្យស្គាល់លក្ខណៈកងទ័ពរបស់ពួករ៉ូម៉ាំងខ្លះ ជាគ្រឿងប្រដាប់សតិបញ្ញារបស់យើង ។

កិច្ចការពាររបស់រោមបានកែប្រែផ្លាស់ប្តូរមកជាច្រើនប្រការ ទើបក្លាយទៅជាកងទ័ពដែលខ្លាំងពូកែបំផុតក្នុងសម័យ ស៊ីល·សេសារ ។ ដំបូងនោះ កងទ័ពរបស់ក្រុងរោមស្ទើរតែមិនមានលក្ខណៈដែលគួរហៅថាជាកងទ័ពសោះឡើយ ដោយហេតុត្រូវការយុត្តិធម៌ ឬមិនទុកចិត្តយ៉ាងណាមិនប្រាកដ មនុស្សដែលទទួលក្រមិនបាច់ធ្វើទាហានទេ ទាំងមិនព្រមអនុញ្ញាតឲ្យធ្វើផង ។ ទាហានមិនបានរួបរួមតាំងឡើងជាពួកក្រុមទេ ទាំងកិច្ចការក៏មិនបានចាត់ធ្វើបន្ទាយទាហានបំរុងទុកដោយឡែកដូចសព្វថ្ងៃនេះ ។ លុះកាលណាត្រូវការកងទ័ពទើបហៅមនុស្សគ្រប់ត្រកូលហើយទៀតផងខ្លួនកាន់អាវុធតាមតែខ្លួនស្វែងរកបាន ពួកអ្នកមានគ្រាន់បើក៏នាំគ្នាជិះសេះចេញទៅច្បាំង នេះជាដើមកំណើតនៃទាហានសេះ ។ ឯអ្នក

ទិទ័លក្រគ៏ះដីរជើងៈ៧ នេះជាដើមកំណើតនៃទាហានថ្មើរជើង ៗ ពួកទាហានក៏កេណហាប៉ោកោតដោយខ្លួនឯង ទាំងមិនមានបៀវត្សប្រាក់ខែអ្វីឡើយ តែពួកទាហានអស់នេះក៏អាចរកផលប្រយោជន៍បាន កាលបើបានច្បាំងឈ្នះស្រុកណា ក៏ប្លន់ដណ្តើមយកទ្រព្យសម្បត្តិរបស់ស្រុកដែលចាញ់ រែកពុនស្ពាយផ្ទាន់យកមកតាមកំឡាំងរបស់ខ្លួន នេះជាផលប្រ-យោជន៍ដែលពួកទាហានបានទទួលក្នុងវេលាឈ្នះសង្គ្រាម ៗ លុះដល់ពេលឈប់ច្បាំងហើយ ពួកទាហានក៏ផុតអំណាចធ្វើជាទាហាន ត្រវិលមករកធ្វើការដាំដំណាំចិញ្ចឹមសត្វ ទៅតាមដើមវិញ ៗ មួយវិញទៀតសង្គ្រាមក្នុងសម័យដើម ៗ នៃក្រុងរោម ជាសង្គ្រាមបន្តិចបន្តួច ច្បាំងតស៊ូគ្នាតែក្នុងរង្វង់ប្រទេសជិតខាងរបស់ខ្លួន ៗ

សម័យក្សត្រសេរវិយុស — លុះមកដល់សម័យស្តេចសេរវិយុស ទើបមានចំនួនទាហានទំនងតាក់របៀបប្រែអាវុធឡើង ឯវិធីបន្ថែមកំឡាំងទាហាននោះ ព្រះបាទសេរវិយុសទ្រង់ញែកបែងប្រជាជនចេញជា ៧ ជាន់ តាមមានតាមក្រ ៗ ឯប្រជាជននៅក្នុងជាន់ទី ៧ នោះ ជាពួកដែលទាល់ក្រណាស់ នោះមិនបាច់ធ្វើជាទាហានទេ ពួកដែលត្រូវធ្វើជាទាហាន មានតែ ៦ ជាន់ គឺពួកជាន់ទី ១ ជាពួកមានសម្បត្តិស្តុកស្តម្ភបំផុត នោះមានសេះជិះ តាំងជាទាហានសេះ ពួកទី ២ មានសម្បត្តិតិចជាងពួកទី ១ មិនមានសេះជិះ តែមានគ្រឿងពាក់គ្រប់គ្រឿង កាន់ខ្ទួនទំរដារ ពួកទី ៣

ទី ៤ និងពួកទី ៥ ក៏មានអាវុធសំភាន់គប់ចុះទៅរហូតដល់ពួកទី ៦ មានតែផ្ទាអាវុធ ហើយពួកពាហនអស់នេះ គេនឹងកាត់រកគ្រឿងតែងខ្លួនឯង អាហារបរិភោគដោយខ្លួនឯងជានិច្ច ។ លុះមកដល់សម័យក្រោយពុក ក្នុងខណៈការម៉ារុសធ្វើជាកុងស៊ុល ពួកកេម៉ាំងត្រូវតែបង្ហាំងទីងពួកគោល្ល៉ា ដែលជាពួកពាហនមានរបៀបទីងអាវុធពូកែជាង ៗ របៀបពាហនរបស់ក្រុងរោមក៏គេងតែផ្លាស់ប្តូរកែប្រែទៅផង ពោលគឺសង្គ្រាមគ្រានេះគេងខូចពេលវេលាជាយូរ ពួកពាហនមិនអាចធៀតទៅរកស្បៀងសម្រាប់បរិភោគដូចជាកាលមុនៗ ទើបមានវិធីចែករបៀបឲ្យពួកពាហនទៀងមកមានប្រាក់ដម៉ាំមួនក្នុងសម័យសេសារ ហើយថែមទាំងពួកពាហនក៏មិនត្រូវកាត់លំដាប់តាមថ្នាក់ដូចជាន់ដើមនោះទេ តែបានញែកចែងចែកជាក្រុមៗតាមលក្ខណៈរបស់អាវុធ លុះមកដល់ម៉ារីយុស ពួកអ្នកទទួលក្រប់ផុតក៏មានឱកាសចូលធ្វើពាហនបាន ហើយតាំងអំពីការនោះមកការធ្វើជាពាហនក៏ក្លាយទៅជារបរចិញ្ចឹមជីវិតមួយផ្លូវ ដោយពួកពាហនមិនបាច់ទៅធ្វើការរកស៊ីខាងក្រៅៗ ពីទទួលប្រាក់ខែបៀវត្ស ទាំងមិនមានមុខក្រសួងដទៃទៀតក្រៅពីធ្វើសង្គ្រាម ។ បណ្ដាអាវុធទាំងឡាយក៏ចាត់ឲ្យមានប្រើស្មើគ្នាទាំងអស់ កងពាហនសេះដែលធ្លាប់តែអ្នកមានទ្រព្យជិះបាន ក៏ក្លាយទៅជារបស់សាធារណៈ ស្រេចតែកងការរើសមនុស្សមកប្រើការក្នុងដំណែងនេះ ។

(នៅមាន)

# ប្រវត្តិឧបាសក

## ជាសាវករបស់ព្រះពុទ្ធជាម្ចាស់

១—តបុស្សៈ-និងភល្លិកៈ — នេះជាឈ្មោះពាណិជពីរនាក់ជាបងប្អូនគ្នា នៅអសិតញ្ជនគរ កើតក្នុងត្រកូលកុដុម្ពិក ។ បងឈ្មោះតបុស្សៈ ប្អូនឈ្មោះភល្លិកៈ ពាណិជពីរនាក់ជាឈ្មួញរទេះ ។ កាលព្រះបរមសាស្តានៃយើងទាំងឡាយបានត្រាស់ដឹងហើយ គ្រានោះព្រះអង្គគង់នៅក្រោមដើមរាជាយតនៈ (ដើមកែះ) ពាណិជទាំងពីរបររទេះមកដល់ទីនោះប្រទះនឹងព្រះបរមសាស្តា ទើបថ្វាយបឋមបិណ្ឌបាត គឺយកសដូវផង់ សដូវដុំ ដែលជាស្បៀងដើរផ្លូវចូលទៅថ្វាយ រួចឈរនៅទីដ៏សមគួរមួយ ។ ព្រះបរមសាស្តាទ្រង់ទទួលសោយស្រេចហើយ ពាណិជទាំងពីរក៏ក្រាបទូលសំដែងខ្លួនជាឧបាសកដោយអាងព្រះអង្គនឹងព្រះធម៌ជាទីពឹងទីរឭក ចាត់ជា ឧបាសកទ្វេវាចិកៈ មុនដំបូងបំផុតក្នុងលោក ព្រោះវេលានោះមិនទាន់មានព្រះសង្ឃនៅឡើយ ។

ព្រះអដ្ឋកថាចារ្យបានពោលពង្រីកសេចក្តីត្រង់ដែលពាណិជទាំងពីរនាក់ទៅជួបនឹងព្រះដ៏មានព្រះភាគឲ្យពិស្តារបន្តិចទៅទៀតថា ទេវតាដែលធ្លាប់ជាមាតារបស់ពាណិជទាំងពីរក្នុងជាតិជាតំបូងនោះគិតថា ឥឡូវកូនអញទាំងពីរមកតាមផ្លូវនេះ គួរតែថ្វាយចង្ហាន់បិណ្ឌបាតដល់ព្រះពុទ្ធជា

ម្ចាស់ ទើបបណ្ដាលឲ្យគោអស់នោះឈប់នៅស្ងៀម ទុកជាពាណិជទាំងពីរគិតកែខៃយ៉ាងណាក៏មិនសម្រេច ទើបទេវតាចូលជ្រែកក្នុងរូបបុរសម្នាក់ និយាយពន្យល់អំពីបំណងរបស់ខ្លួនឲ្យស្ដាប់ ៗ នាយពាណិជទាំងពីរក៏មានចិត្តត្រេកអរ ទើបយកសត្តូវផង់សត្តូវដុំទៅថ្វាយព្រះដ៏មានព្រះភាគ ៗ ក្នុងវេលានោះ ព្រះអង្គឥតបាត្រទេ ព្រោះបាត់ទៅតាំងអំពីគ្រាដែលទ្រង់ទទួលមធុបាយាសរបស់នាងសុជាតាហើយ ទើបទ្រង់ព្រះតម្រិះថា ព្រះតថាគតទាំងឡាយមិនដែលទទួលបិណ្ឌបាតផ្ទាល់ព្រះហស្ដទេ ចុះតថាគតត្រូវធ្វើដូចម្ដេចហ្ន៎? គ្រានោះ ស្ដេចចតុលោកបាលទាំង ៤ អង្គទ្រង់ជ្រាបព្រះពុទ្ធតម្រិះ ទើបនាំបាត្រសិលាមួយអង្គបាត្រមួយៗមកថ្វាយ ទ្រង់ទទួលហើយទ្រង់អធិដ្ឋានឲ្យរួមចូលគ្នាជាបាត្រតែមួយ ទើបទ្រង់យកបាត្រនោះទទួលសត្តូវរបស់ពាណិជទាំងពីរនាក់នោះៗ

មួយវិញទៀត មានសេចក្ដីដំណាលទុកថា ពាណិជទាំងពីរចេញដើរមកពីឧក្កលជនបទហើយបានមកជួបនឹងព្រះបរមសាស្ដាដែលទ្រង់គង់សោយវិមុត្តិសុខក្រោមដើមកែះ ទើបនាំយកសត្តូវទាំងពីរបែបនោះថ្វាយព្រះអង្គ ៗ លុះទ្រង់សោយស្រេចហើយ ពាណិជទាំងពីរនាក់បានស្ដាប់ព្រះធម្មទេសនារបស់ព្រះអង្គហើយ ទើបថ្វាយខ្លួនជា ទ្វេវាចិកឧបា-សក ៗ ដល់វេលាត្រឡប់ទៅស្រុករបស់ខ្លួនវិញ ពាណិជទាំងពីរក៏ក្រាប

ទូលសុំវត្ថុជាទីរឭក ទើបព្រះបរមសាស្ដាទ្រង់ស្ទាបព្រះកេសាដោយព្រះហស្តស្តាំបានព្រះកេសា ៨ សរសៃ ហើយទ្រង់ប្រទានទៅពាណិជទាំងពីរ។ក៏យកព្រះកេសធាតុទៅដំកល់ទុកក្នុងស្គតមាស ហើយនាំទៅស្រុករបស់ខ្លួន ប្រតិស្ឋានព្រះជីវកេសធាតុទុកក្នុងចេតិយក្បែរទ្វារនគរអសិតញ្ជនៈ លុះដល់ថ្ងៃសីល ឬថ្ងៃឧបោសថ រស្មីពណ៌ខៀវក៏ផុះពន្លឺចេញពីព្រះចេតិយនោះ ។

កាលព្រះបរមសាស្ដាទ្រង់គង់ក្នុងព្រៃវេឡុវ័ន ទ្រង់តាំងនាយពាណិជទាំងពីរនាក់ក្នុងដំណែងឯតទគ្គដ្ឋាន ថាជាកំពូលនៃពួកឧបាសកដល់សរណៈមុនដំបូងបង្អស់ ។

**ចប់ប្រវត្តិសង្ខេប នៃ តបុស្ស:- ភល្លិកឧបាសកតែប៉ុណ្ណេះ ។**

# ច្បាប់ពាក្យចាស់

## បទព្រហ្មគីត

១ ពាក្យចាស់ពាក្យពីព្រេង ទោសខ្លួនឯងមើលពុំយល់ ទោសគេតូចសោតសល់ មើលយល់ប៉ុនទាំងភ្នំ ។ ចូលព្រៃសត្វសាហាវ រកអំពារ[១]គ្នាមកជុំ ដល់បានស្អាតទឹកឃ្មុំ ពួនក្នុងផ្ទះស៊ីម្នាក់ឯង ។ បានហើយចង់បានទៀត ធ្វៀតហើយធ្វៀតពុំគិតឈ្វេង មើលយល់តែខ្លួនឯង មិនយល់គេឯទៀតផង ។ ទីងស៊ីចង់ពិសា ខ្ជិលទំពាឲ្យម៉ដ្ឋហ្មង យល់នាមថាជាមង យល់ឯងផងថាជាគួយ ។ យល់តាថាជីដូន យល់ឯកូនថាជាក្មួយ យល់ពីរថាជាមួយ យល់ឯព្រួយថាជាសុខ ។ យល់ទោសថាជាគុណ យល់ឯបុណ្យថានរក យល់ល្អថាអាក្រក់ យល់លាមកថាជាផ្កា ។ ស្បៀកស្បង់មិនគោរសក់ ផ្ទះកញ្ចក់ធ្មេចនេត្រា យល់សេះថាជាលា យល់គជាថាកណ្ដុរ ។ នេះពាក្យលោកពីព្រេង អ្នកណាឈ្វេងប្រាជ្ញយល់ ឃើញថ្មកកុំថាថ្នល់ ក្រែងកំហល់កំហុសមាន ។ អ្នកប្រាជ្ញកាន់ពាក្យទៀង កុំលំអៀងពាក្យបុរាណ កុំដើរផ្លូវបំពាន ពាក្យអ្នកចាស់លោកដៀលថា ។ ពាក្យនេះពីព្រេងព្រឹទ្ធ គួរឲ្យគិតពិចារណា កុំអួតអង្គអាត្មា ថាចំណេះចំណាំមាន ។ ដេកយប់កុំដេកយូរ ខ្លាចក្ដីទុក្ខដិនដល់ប្រាណ បើស៊ីកុំតាមឃ្លាន គិត

---

១ ច្បាប់ខ្លះថារកបំព្រាវ ។

ប្រមាណត្រប់គ្នា ។ លើកដាក់តាមកំឡាំង កុំកើបខ្លាំងឈើដល់ស្មា
បើគេប្រើឲ្យត្រា កុំសាំសិទនទៅពើ ។ ទោះគិតកុំស្រពន់ គិតឲ្យ
ត្រាន់ទើបដើរទៅ កុំឲ្យមានអាស្រូវ កើតជំទៀលដល់អាត្មា ។ កុំ
យកឆ្អិនជាឆៅ កិច្ចការក្រៅមានតម្រា[1] កុំអាងឯងប្រាជ្ញ ពោល
ច្បាប់ក្បួនលោកព្រេងនាយ ។ ស្រដីឲ្យស្រួលស្រេច គិតសេចក្រេច
កុំគិតងាយ រំពឹងឲ្យវែងឆ្ងាយ យល់លំអិតពាក្យលោកថា ។ ពាក្យ
ព្រេងលោកស្រដី ថាកុំបីចិញ្ចឹមខ្លា ពាក្យព្រេងលោកឧបមា គិតត្រង់
ណាក្ដើឲ្យបាន ។ កាន់កពស់ឲ្យខ្ជាប់ ខ្លាចក្រឡាប់ទាំងប្រាណ អូស
ទូកកុំឲ្យល្អាន ទឹកថ្លាសោតកុំឲ្យល្អក់ ។ ស្ទូកឈើឥតកម្រើក បើ
ករើកផ្សិតខ្យល់បក់ ទឹកថ្លាល្អក់បើល្អក់ ផ្សិតលេកខ្លាំងសោះសា ។
យល់តូចកុំខឹងខំ គួរសន្សំយកជាគ្នា បានច្រើនកុំខំពារ សន្សំមកឲ្យណា
គិបរទៅ ។ អ្នកមានក្បាលខ្សត់ ដូចសំពត់ព័ទ្ធតាក្រៅ អ្នកប្រាជ្ញក្បាល
ខ្លៅ ដូចសំពៅទូលសំប៉ាន ។ អ្នកខ្ពស់ក្បាលទាប ដោយសភាពធម៌
បុរាណ អ្នកខ្ពួតក្បាលឃ្លាន នាអ្នកប្រឹងក្បាលឆ្លា[2] ។ ក្បាលទៅមុខវឹង ឥត
កំដឹងអស់អម្បាល ចំណោះចៃកាន់កាល ដូចរបងស្រាស់បន្ទា ។ កុំខ្ពួត
ពេកតែឯង មិនគិតក្រែងអស់គ្នីគ្នា គេឃ្លាទាំងផ្ទៃផ្សា ឲ្យស៊ីក៏បានខ្ពួត

---

១ ច្បាប់ខ្លះថា ញាតតម្រា ។ ២ ច្បាប់ខ្លះថា នាអ្នកមានក្បាលឆ្លា ។

ផង ។ កុំមានចិត្តលលើ ពឹងក្រពើឲ្យចម្លង កុំកាច់ៗសរបង កាំងចំ-
ណាឯអាត្មា ។ មានទូកហើយមានថ្នោល មានបង្គោលមានយុថ្កា
ចាំងតួរចាំងប្រាំ ក្រដីងចាប់ដោយនូវគ្រប់ ។ ប្រយ័ត្នក្រែងព្យុះឡល់
បក់បោកដល់ទឹងទល់ទប់ ប្រយ័ត្នប្រយោជន៍គ្រប់ ទើបហៅជាតិជាក-
ណើត ។ ពាក្យព្រេងគិតគួរចាំ ជាបណ្តាំប្រដៅនែប់ ពាក្យព្រេង
ពាក្យព្រេងព្រឹទ្ធ មុខគួរគិតៗឲ្យគ្រាន់ ។ ពាក្យនេះជាសណ្តាប់ ទុក
ជាច្បាប់ទៀងជាក់ស្បាន់ ពាក្យនេះជាកំណាន់ កំណត់នៅឥតឃ្លាតឃ្លា ។
សូមបទូវទិតាន ពាក្យទូន្មានដោយប្រការ អម្បាលនេះឯងណា ចាំទុក
កាយគ្រប់គ្រាន់ហោង ។

## អំពីក្រុងម៉ានីល

អស់លោកអ្នកមើលទស្សនាវដ្ដីរបស់យើង តែងស្គាល់ឈ្មោះក្រុងរបស់ហ្វីលីពីននោះ ហើយមានអ្នកខ្លះដឹងថា ព្រះបាទសម្ដេចព្រះនរោត្ដមព្រះចៅក្រុងកម្ពុជាស្ដេចធ្លាប់ទៅប្រពាសប្រទេសនោះម្ដង ហើយទ្រង់នាំយកបេបក្លូងមួយយ៉ាងដែលអ្នកស្រុកហៅថា ក្លូងម៉ានីល ជាក្លូងព្រះរាជទ្រព្យជាប់រហូតមកដល់សព្វថ្ងៃនេះ យើងតែងបានឮសូរក្លូងកល់ដង នៅឱកាសដែលមានព្រះរាជពិធីបុណ្យហោមផ្សេងៗ ។ អ្នកខ្លះបានដឹងថា គោខ្មែរគេតែងធ្វើទៅលក់នៅស្រុកម៉ានីលជាចំនួនច្រើនកល់ៗឆ្នាំ ហើយគេដឹងច្បាស់ថា ហ្វីលីពីនជាកោះនៅក្នុងសមុទ្រប៉ាស៊ីហ្វិក ជាពង់កោះស៊ុងដ៏ទីងល្វឹងសមុទ្រចិនខាងត្បូង មិនឆ្ងាយពីប្រទេសឥណ្ឌូចិនប៉ុន្មានទេ ។

ឥឡូវនេះយើងមានបំណងនឹងបង្ហាញអ្នកមើលទស្សនាវដ្ដីរបស់យើងឲ្យបានស្គាល់ច្បាស់នូវទីក្រុងម៉ានីលនេះ ដែលជាទីក្រុងដ៏សំខាន់មួយ ។

កាលពីពុទ្ធសករាជ ២៤៤១ ពួកកោះហ្វីលីពីននោះជារបស់អេស្ប៉ាញ៉ុល តមក ក៏កើតចម្បាំងដណ្ដើមកោះនឹងកងទ័ពជើងទឹករបស់ជាតិអាមេរិកាំង ទើបកោះហ្វីលីពីនរបូតពីដៃអេស្ប៉ាញ៉ុល បានទៅជាតិអាមេរិកាំង ។ ឯទីក្រុងចាស់របស់ម៉ានីលមានប៉មចាស់ៗព័ទ្ធជុំវិញ នៅទីនេះ

គេបានឃើញព្រះពដកំងចាស់ៗ វត្តចាស់ៗ និងវិហារកាតូលិកចាស់ៗមាន មហាវិទ្យាល័យជាងចាស់បំផុតមួយរបស់លោកសាំងថូម៉ាស ដែលមាន សំណង់វិចិត្រផ្សេងៗនៅក្នុងស្រុកជង ៗ ឥឡូវនេះទីក្រុងថ្មីរបស់ម៉ានីល តាំងនៅក្រៅក្រុងចាស់ មានចំនួនអ្នកស្រុកប្រមាណ ៦២៤.០០០ នាក់ ក្នុងផ្លូវធំតាមបណ្ដោយថ្នល់ក្បែរៗទីក្រុងចាស់នុះឯង តែកាលពីដើមមក នោះជាទីស្រែចម្ការរបស់អ្នកស្រុក មានព្រៃស្វាយដុះនៅទ្រុបទ្រុល ឥឡូវនេះ ទីអស់នោះក្លាយទៅជាផ្ទះសំបែងកាសពេញទូទៅ ។

មានអនុស្សាវរីយ៍ល្អៗ ធ្វើពីថ្មកែវពណ៌ស គេហៅស្ពានទំនើបថ្មី ដែលគេបានកសាងយ៉ាងម៉ាំមួន ថ្នល់ធំៗនៅក្នុងក្រុងមានម្លប់ឈើត្រជាក់ គួរដើរលេងកំសាន្តចិត្ត បត់បេញទៅមាត់សមុទ្រសម្រាប់យកខ្យល់អាកាស ។ មានយានជំនិះគ្រប់ប្រភេទសម្រាប់ផ្លូវគឺ រថយន្ត, រថរ៉ៃ, រទេះគោ, រទេះសេះ, ចក្រយាន និងយន្តហោះ ។ មានប៉ុស្តិ៍វិទ្យុ១ផ្សាយដំណឹងនានាជាភាសាអង់គ្លេស ភាសាអ្នកស្រុកនិងភាសាចិន ។ គេនិយមប្រើភាសាអង់គ្លេសជាភាសាធម្មតា មានក្មេងច្រើនចំនួន ១.៧០០.០០០នាក់ ដែលចូលសាលារៀន ដោយច្រើនពួកនេះនិយមរៀនអង់គ្លេស ។ មានសារពត៌មានទស្សនាវដ្ដី, សៀវភៅបោះពុម្ពជាចំនួនច្រើននៅកោះហ្វីលីពីនសុទ្ធតែជាភាសាអង់គ្លេស ហើយមានទស្សនាវដ្ដីមួយផ្នែកទៀត

ដើមកពីប្រទេសអាមេរិកចូលមកក្នុងកោះនេះ មានចំនួនច្រើនជាង ៥០០.០០០ ច្បាប់ ។ ឯរឿងផ្សេងៗ ដែលគេបានបោះពុម្ពផ្សាយចំនួន ៦៧០ រឿង គិតជាសៀវភៅ ១.៥០០.០០០ ក្បាល ដែលគេតែងជាភាសាអង់គ្លេសមានចំនួនច្រើនជាងពាក់កណ្តាល ។

កាលពីឆ្នាំ ១៨៩៨ នោះ ចំនួនប្រជាជននៅកោះនេះប្រមាណ ៦.០០០.០០១ នាក់ ដល់មកសព្វថ្ងៃនេះ ចំនួនមនុស្សចំរើនឡើងដល់ ១៦ លាន (១៦.០០០.០០០) ។ កាលមុនសម័យជនជាតិអេស្ប៉ាញ៉ុលនឹងអាមេរិកាំងនោះ ចំណោមកោះអស់នេះក៏មានអារ្យធម៌ជាន់ចាស់របស់ខ្លួនដូចយ៉ាងប្រទេសដទៃខាងដែរ ទើបគេឃើញមានវត្ថុបុរាណជាចំនួនច្រើនដែលគេបានរូបរួមទុកក្នុងសារមន្ទីរសព្វថ្ងៃនេះ ។

ក្នុងឆ្នាំក្រោយៗមកនេះ ការសិក្សារបស់ស្ត្រីមានសេចក្តីចំរើនរុងរឿងឡើងណាស់ច្រើន សព្វថ្ងៃនេះ មានចំនួន ៩០ ភាគក្នុង ១០០ ភាគ នៃពួកសិស្សសិក្សាថ្នាក់ឧត្តម សុទ្ធតែជាស្រីគ្រូ ឯក្រសួងសិក្សាធិការមានចំនួនសិស្សស្រីដល់ ៩៣ ក្នុង ១០០ ហើយមានចំនួន ៥៥ ក្នុង ១០០ នៃស្ត្រីដែលសិក្សាថ្នាក់ជាន់ខ្ពស់ក្នុងមហាវិទ្យាល័យ ។ ឯចំនួនអាំងហ្សីនីញ៉េរប្រុសមានតិចណាស់ ពួកអ្នកព្យាបាលជម្ងឺស្ទើរតែជាអាំងហ្សេនីញ៉េរស្រីទាំងអស់ ។ មានស្រីគ្រូម្នាក់ធ្វើត្រូតពិនិត្យគ្រូពេទ្យ ចំពោះតែថែគ្រូពេទ្យក្នុងគេឯងប៉ុណ្ណោះ ។

ក្រសួងសាធារណសុខបានធ្វើការជាច្រើន ដើម្បីឲ្យបានសេចក្ដីសុខសប្បាយក្នុងទីក្រុងទាំងមូល ព្រមទាំងបានកំចាត់អស់ទាំងសត្វកណ្ដុរ ហើយទាំងចាក់ដីបំពេញអស់ទាំងថ្លុកត្រពាំងផង ។ ល្បែងហាត់ប្រាណជាល្បែងដែលគេនិយមណាស់ ហើយនាំឲ្យបានចំរើនកំឡាំងនឹងសាច់ឈាមរបស់ជនជាតិហ្វីលីពីនជាអនេក គេមិនហាមឃាត់អ្នកឧស្សាហ៍ទៅមើលកុនជានិច្ចទេ ។ ឯគ្រឿងសាប៊ូគ្រប់យ៉ាង ដែលគេប្រើក្នុងប្រទេសអាមេរិកនោះ សុទ្ធតែធ្វើពីប្រេងដូង ដែលបញ្ជូនទៅពីកោះហ្វីលីពីននេះទាំងអស់ ហើយគេបានបញ្ជូនជាតិឈើរឹង, ស្ករ, ដូងទុំ នឹងផលានុផលដទៃទៀតជាច្រើន ទៅលក់ឯទ្វីបអាមេរិក ។ កោះនេះមានកើតលោហធាតុមាស ដែលគេធ្វើប្រើការជានិច្ច ។ មានមន្ទីរមើលផ្កាយ ១ ជាមន្ទីរល្បីល្បាញណាស់ ហើយមានប្រយោជន៍ជាពន់ពេកណាស់ ព្រោះទីនេះអាចដូនដំណឹងអំពីខ្យល់ព្យុះសមុទ្រ ជាហេតុឲ្យទូកកប៉ាល់ចៀសវាងពីការលិចលង់ក្នុងសមុទ្រផុតពីសេចក្ដីអន្តរាយបាន ។ ឯការសិក្សានៅកោះអស់នេះ ពិតមែនតែចំរើនឡើងច្រើនពាសពេញកោះ ការប្រកាន់ប្រផ្នូលក៏បាត់បន្តិចៗទៅ តែនៅចំណែកខាងស្រុកស្រែនៅជឿប្រផ្នូលនៅឡើយ ដូចសត្វស្វា គេថាជាឫក្សអាក្រក់ ប្រសិនបើមានបក្ខីយរត់កាត់បំពីមុខផ្លូវ គេមិនត្រូវដើរទៅមុខទៀតទេ ត្រូវត្រឡប់ថយក្រោយវិញ

កូនក្មេងមិនត្រូវឲ្យលេងសត្វអណ្តើកទេ ពីព្រោះដល់ធំឡើងកន់ទីងទៅជា មនុស្សល្ងង់ខ្លៅអាប់អោនប្រាជ្ញា ប្រសិនបើមានមេអំបៅហើរចូលទៅក្នុងផ្ទះ ទីងមានសេចក្តីព្រួយបារម្ភសោកមិនខាន ។ គេជឿថា មិនត្រូវដាស់ ពញ្ញាក់អ្នកណាមួយយ៉ាងរហ័សឡើយ ការធ្វើដូច្នេះ ព្រលឹងមិនអាចចូល មកក្នុងខ្លួនអ្នកនោះបានទេ បើកាលណាគេបោះអុំបោលទៅ ត្រូវពោល ពាក្យសុំទោសជាដរាប ក្រែងបោលទៅត្រូវខ្មោចបិសាចណាមួយ ៗ មាន រឿងមួយនិយាយពីជំនឿកសាងកោះអស់នេះថា មានថ្ងៃមួយ មានយក្ខ ១ លីដីមកលើស្មាទាំងពីរ ហើយទឹកក្រើរក្រោធយ៉ាងណាមិនប្រាកដ ក៏ ទម្លាក់ដីចុះពីលើស្មា ។ ឯដីនោះក៏ធ្លាក់ចុះមកបែកជាបំណែក ៗ ចំនួន ៧.០៥៣ ដុំ មានបំណែកដីខ្លះកើតជាកោះហ្វីលីពីននេះ ។

តែកាលណាអាកាសក្តៅខ្លាំង ប្រជាជនដែលល្មមដោះខ្លួនចេញពី ការងារបាន គេតែងទៅកន្លែងខ្ពស់ៗ ដែលមានអាកាសធាតុត្រជាក់ល់តែ គេងអាំងភ្លើង ដើម្បីធ្វើកាយឲ្យក្តៅអ៊ុនៗទៅវិញ ហើយគេតែងនាំ គ្នាទៅលេងហាត់ប្រាណនៅលើកំពូលភ្នំខ្ពស់ៗជាចំនួនច្រើន ។ ដូចជំនួញ កំពង់របស់ម៉ានីល ជាកំពង់មួយសំខាន់ណាស់ ព្រោះមិនមែនត្រឹមតែជា កំពង់ចេញចូលរបស់កប៉ាល់តូច-ធំ នៅក្នុងសមុទ្រចិនប៉ុណ្ណោះទេ គឺភ្ជាប់ ក្រសួងដឹកជញ្ជូនពីប្រទេសនានាមកកាន់កោះហ្វីលីពីនឲ្យប្រព្រឹត្តទៅបាន ស្រួលផង ។

ចប់រឿងក្រុងម៉ានីលដោយសង្ខេបតែប៉ុណ្ណេះ ។

# រឿងស្រ្តីពីរនាក់ដណ្ដើមកូនគ្នា

មាននិទានមួយដំណាលថា មានស្រីពីរនាក់មានកូនដូចគ្នា មេមួយកូនស្លាប់ ឯមេមួយទៀតកូននៅរស់ មេនោះពកូនទៅងូតទឹក ឯមេកូនស្លាប់នោះដើរមកជួបហើយស្រដីថា កូននាងដូចកូនអញ នាងអើយអញសូមថើបកូននាងបន្តិច ៗ ឯម្ដាយក៏ឲ្យកូននោះទៅ មេនោះទ-ទួលយកមកថើបបំបៅហើយដើរទៅយកទាំងកូននោះទៅកាន់លំនៅរបស់វាផង ៗ ឯមេម្ដាយរៃស្រែកថា នាងអើយ នាងយកកូនអញទៅណា មេនោះថាកូនអញទេតើម្ដេចមេថាកូនមេ ស្រីទាំងពីរឈ្លោះប្រកែកគ្នាទៅវិញទៅមករួចនាំគ្នាទៅប្ដឹងចៅក្រម ៗ ឯមេដណ្ដើមកូនគេនោះប្ដឹងថា សូមបាទនាងខ្ញុំពកូនមក មេនោះយល់កូននាងខ្ញុំហើយក៏ដើរតាមមកថាជាកូនរបស់វា ៗ ឯមេម្ដាយប្ដឹងថា នាងខ្ញុំពកូនមកងូតទឹក មេនេះដើរមកអំពីឯណាមិនដឹងយល់កូននាងខ្ញុំហើយថាដូចកូនវាស្រដីសុំអំពីនាងខ្ញុំយកទៅថើបលាដៃយកអំពីខ្ញុំៗក៏ឲ្យកូនទៅមេនេះថើបហើយពបំបៅនាំកូននាងខ្ញុំរត់ទៅ សូមឲ្យលោកម្ចាស់ពិចារណាឲ្យខ្ញុំហាន ៗ ឯចៅក្រមជំនុំពិចារណាអស់ត្រិះរិះក៏ពុំយល់ប្រាកដជាកូននាងណា ៗ ឡើយ នឹងកាត់សេចក្ដីនេះពុំបាន ទើបនាំមេទាំងពីរឡើងទៅក្រាបទូលសម្ដេចព្រះមហាក្សត្រាធិរាជដោយនូវដំណើរនោះ ៗ ព្រះអង្គបានជ្រាបសព្វគ្រប់ដោយដំណើរនោះ

ហើយ ទើបព្រះអង្គទ្រង់ព្រះចិន្ដាពិចារណាដោយនូវព្រះប្រាជ្ញាពិសេស ឈ្វេងយល់ក្នុងមេចាំងពីរហើយ ទើបព្រះអង្គត្រាស់ឲ្យយកកូននោះទៅដាក់ជាកណ្ដាល ឲ្យមេចាំងពីរដណ្ដើមគ្នា បើនរណាដណ្ដើមបាន ឲ្យអ្នកនោះយកកូននោះ កាលបើដូច្នោះក្ដីមេចាំងពីរចូលដណ្ដើមគ្នា ឯមេកូនស្ទាបចាប់ចាំងធ្មេញយូរយកពុំគិតបាក់បែករហែកដៃជើងឥតចិត្តមេត្តាករុណាប្រណីក្មេងឡើយ ឯមេម្ដាយស្ដាយកូនចូលទៅដណ្ដើមហើយបបក់ព្រលឹងរងារមានសេចក្ដីកំហឹងខឹងខឹងមេនោះណាស់ តែមានចិត្តអាសូរករុណាមេត្តាកូននោះក្រពេក ចូលជួយទប់ក្រសោបយកកូន យល់មេនោះសាំចំពុះការប្រាប់ចាប់ពុំគិតបាក់បែកធ្អឹងធ្មេញដូច្នោះ ក៏លែងកូននោះចេញបានកូនទៅមេមួយនោះ ។ ទើបព្រះអង្គមានព្រះបន្ទូលថា នាងដែលលែងកូនឲ្យបានទៅគេនោះ ហេតុដ្បិតមានចិត្តអាសូរករុណាកូនគឺនាងនេះឯងជាតិជាម្ដាយមែន ឯនាងដែលដណ្ដើមកូនបានទៅនោះហេតុតែកូននោះពុំមែនកូនឯងពិតៗ ទើបឥតចិត្តអាសូរករុណាកូននោះទាំងដណ្ដើមយកតែឈ្នះដៃ ។ ព្រះអង្គមានព្រះបន្ទូលដូច្នោះហើយ ទើបទ្រង់កាត់សេចក្ដីឲ្យបានកូននេះទៅម្ដាយវិញ ។ រីឯមេដណ្ដើមកូនគេនោះ ព្រះអង្គឲ្យផ្ដន្ទាទោសផ្ចាលជាស្បូវទៅប្រការអំពាលពណាះហោង ។

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

## ឆ្នាំគំរប់ ១៤ ភាគទី ២

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨៤

គ. ស. ១៩៤២

# បញ្ជីរឿង

ទំព័រ


១ — ព្រះរាជពិធីរាជាភិសេក នៃព្រះបាទសម្តេចព្រះនរោត្តម-សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី (តមកនឹងចប់) . . . . . . . . . . . . . . . . . . . . ៣

២ — ប្រវត្តិទង់ប្រចាំជាតិខ្មែរ . . . . . . . . . . . . . . . . . . . . ២៩

៣ — ប្រវត្តិអក្សរសាស្ត្រខ្មែរ (សង្ខេប) លោកសឺដែសចាងហ្វាងសាលាបារាំងសែសចុងបូព៌ាប្រទេសរៀបរៀង (តមក) . . . . . . . . . . . . . . . . . . ៣៧

៤ — ច្បាប់វិធុរបណ្ឌិត (ពាក្យកាព្យ) . . . . . . . . . . . . . . . . . . ៤២

៥ — ប្រវត្តិពួកឧបាសក-ឧបាសិកា ជាសាវកសាវិការបស់ព្រះពុទ្ធជាម្ចាស់ (តមក) : ទី ២ ប្រវត្តិសុទត្តគហបតី . . . . . . . . . . . . . . . . . . ៤៥

៦ — ពង្សាវតារភូមា ស្រង់យកអំពីគោលចារឹកផ្សេងៗក្នុងពង្សាវតារលោក (តមក) . ៤៧

៧ — រឿងព្រេងខ្មែរ «រឿងជីងសងជីង អំបែងសងអំបែង» . . . . . . . . . . . . ៥១


## រូបក្រៅរឿង


រូបប្រាសាទបន្ទាយស្រី - កសាងក្នុងសម័យនៃការរបតាក់ពុងចំរើនបរិបូណ៌ កាលពីសតវត្សរ៍ទី ១៦ នៃពុទ្ធសករាជ . . . . . . . . . . . . . . . . . . ១

# TABLE DES MATIÈRES

Pagese

1. Cérémonies du Couronnement de S. M. Préas Bat Samdach Préas NORODOM-SIHANOUK VARMAN, Roi du Cambodge (suite et fin) .......... 3

2. Histoire du drapeau Khmèr .......... 29

3. Littérature cambodgienne, par Monsieur G. CŒDÈS, Directeur de l'École française d'Extrême-Orient (suite). .......... 37

4. Chbab-Vidhurapandit (poème) .......... 42

5. Vies des disciples laïcs du Buddha. La vie de SUDATTA-GAHAPITI .......... 45

6. Histoire de Rome. Extrait de divers documents de l'histoire universelle (suite) .......... 47

7. Conte populaire cambodgien inédit :

"Tesson pour tesson, herminette pour herminette" .......... 51

HORS TEXTE.

Banteai Srei — Exemple caractéristique de l'art Khmèr à son apogée (Xe siècle) .......... I



រូបប្រាសាទបន្ទាយស្រី កសាងក្នុងសម័យនៃការរចនាកំពុងចំរើនបរិបូណ៌
កាលពីសតវត្សរ៍ទី ១៦ នៃពុទ្ធសករាជ

# ព្រះរាជពិធីរាជាភិសេក

## ព្រះបាទសម្តេចព្រះនរោត្តម-សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី

(តមក និងចប់)

តែសេចក្តីទុក្ខលំបាកនេះ មិនអាចរម្ងាប់នូវសេចក្តីយកចិត្តទុកដាក់ខ្នះខ្នែងរបស់យើងបាន ទឹងបណ្តាលឲ្យយើងភ្លេចអំពីកិច្ចធុរៈរបស់យើង ដែលត្រូវតែលាងរុំរបួសដំបៅរបស់ស្រុកឲ្យបានសះជាឆាប់ កុំបីបណ្តែតបណ្តោយធ្វេសទុកឲ្យយូរតទៅឥតអត្ថិមាន ត្រូវតែប្រជុំប្រជាជនឲ្យបានចំរើនទៅខាងអនាគត ដើម្បីជាទីអាចឲ្យយើងមានសេចក្តីកក់ក្តៅសង្ឃឹមទុកចិត្តបានគ្រប់រូប ។

ទ្រង់មានព្រះតំរិះយល់ថា នឹងយកព្រះរាជហឫទ័យទុកដាក់ក្នុងការនេះឲ្យអស់ពីព្រះរាជហឫទ័យ ហើយទ្រង់ប្រកាសពេញឥទ្ធិរិទ្ធិដល់អាណាប្រជារាស្ត្ររបស់ទ្រង់ក្នុងវេលាថ្ងៃនេះ ដើម្បីឲ្យសម្រេចតាមការដ៏ប្រពៃនេះ អំពីដែលទ្រង់មានព្រះរាជឧត្ការតម្រូវឲ្យធ្វើដូច្នេះ គឺទ្រង់សំរេចតាមព្រះរាជបំណងដ៏ខ្លាំងរបស់ព្រះករុណាព្រះបរមខត្តិយកោដ្ឋ ។

អំពីប្រទេសនានា ដែលធ្លាក់ចុះអន្តរាយទៅយ៉ាងណា ដោយច្រើនអាស្រ័យហេតុមកអំពីគំនិតគិតចំពោះតែការផ្ទាល់រូបនីមួយៗ ខ្លាំងពេក មកអំពីគ្មានសេចក្តីស្មោះត្រង់ចំពោះដល់ការជាប្រយោជន៍ទូទៅទាំងអស់

គ្នាប្រមូលអំពីប្រាថ្នារកតែប្រយោជន៍ផ្ទាល់ខ្លួនលើសលុបពេកនោះ ប្រទេសទាំងនោះដែលទើបងើបទៅកាន់សេចក្ដីចំរើនថ្កុំថ្កើងឡើងវិញដោយរហ័សឆាប់បាន    ចួនណាក៏អាស្រ័យហេតុទៅតាមតែរបៀបដែលរៀបចំការប្រព្រឹត្តិសាសនានិងការប្រព្រឹត្តិកាន់ចិត្តគំនិតឲ្យបានមានដម្លៃស្រួលបួលដូចដើមឡើងវិញដូច្នោះតែប៉ុណ្ណោះដែរ ៗ

តាមពង្សាវតាររៀងមក    ធ្លាប់ឃើញបណ្ដាលឲ្យរើខ្លួនរួចទៅកាន់សេចក្ដីថ្កុំថ្កើងឡើងវិញតាមន័យដូច្នោះក៏ច្រើន    ហើយកាលពេលប៉ុន្មានឆ្នាំតមកអំពីជ័យជំនះក្នុងឆ្នាំ ១៩១៨   ក៏មានបណ្ដាលហេតុកើតឡើងជាគួរយ៉ាងដ៏វេទនាដូច្នោះនៅប្រទេសឧរុបស្រាប់ហើយ ៗ តែការរើខ្លួនរួចយ៉ាងប្រពៃ ដែលត្រង់ពិនិត្យឃើញក្នុងព្រះរាជតំរិះសព្វថ្ងៃទុកយ៉ាងមហាវិសេសនោះ គឺការគ្រប់គ្រងរៀបចំឲ្យបានចំរើនឡើងវិញរបស់លោកសេនាប្រមុខ ប៉េតាំង នៅនគរបារាំងសែស   ដែលបានទទួលរង[illegible]យ៉ាងទម្ងន់ពេញ ១ ឆ្នាំមកហើយ ៗ បេះរើរៀបរបៀបកិច្ចការនានា   ដាក់ឡើងសម្រាប់ស្រុកឲ្យបានស្រួលឡើងវិញ   ហើយសព្វថ្ងៃនេះកំពុងសើរើបន្តិចម្ដង ៗ ទៅកាន់វិជ័យក្នុងលោកដូចកាលអំពីដើមឡើងវិញហើយ ៗ

ខ្ញុំមិនអាចនឹងជ្រើសរើសគំរូឯណាឲ្យប្រពៃលើសជាងពីគំរូរបស់លោកសេនាប្រមុខ ប៉េតាំង ដែលលោកធ្វើឲ្យបានកើតការស្រួលឡើង

វិញដោយអស្ចារ្យដូច្នេះឡើយ  សេចក្ដីនេះ  សូមលោកអាមីរ៉ាល់ជ្រាប ថាខ្ញុំមានសេចក្ដីគោរពចំពោះដល់ប្រាជ្ញាគំនិតរបស់លោកព្រឹទ្ធាចារ្យ ដែលជាអ្នកកាន់កាប់ភ័ព្វសំណាងនៃនគររបស់លោក  ហើយខ្ញុំនឹង អធិប្បាយឲ្យអាណាប្រជារាស្ត្ររបស់ខ្ញុំ  នឹងរបៀបកិច្ចការដែលអាច នាំឲ្យបានសេចក្ដីឧត្ដុង្គឧត្ដមដល់ព្រះនគរតទៅ ។

ឯកិច្ចធំក្នុងរបៀបដូច្នោះ  គោរពតាមការឲ្យមានអំណាច  លុះមាន អំណាចដូច្នោះហើយគេនឹងត្រូវឲ្យទទួលការខុសត្រូវដូច្នោះផង ។

## លោកមេទ័ពជើងទឹកដឹកគ្រប់ទាយកសហរដ្ឋឥណ្ឌូស៊ីន

បំពាក់មកុដថ្វាយព្រះករុណាព្រះបាទសម្ដេចព្រះនរោត្ដម-សីហនុ វរ្ម័ន

លុះបានបំពេញព្រះរាជពិធីតាមទំនៀម  ក្នុងព្រះទីន័ងទេវាវិនិច្ឆ័យ គំរប់ ៣ ថ្ងៃហើយ  ដល់ថ្ងៃអង្គារ ៩ កើតខែកត្ដិក (២៨ ឧកតូប្រ ១៩៤១) ជាថ្ងៃចំរើនព្រះជន្មវស្សា  គឺថ្ងៃដែលព្រះករុណាទ្រង់ប្រសូត  នោះតាំង ពីព្រលឹម  ព្រះករុណាទ្រង់ស្ដេចចេញមកកាន់ព្រះទីន័ងទេវាវិនិច្ឆ័យ ថ្វាយបង្គំព្រះពុទ្ធរូប  ហើយព្រះសង្ឃសូត្រជយន្តោថ្វាយជ័យមង្គលរួច ព្រះករុណាទ្រង់ទទួលលោកអធិបតីនៃរាជការអាណាព្យាបាលក្រុងកម្ពុជា ព្រះសង្ឃនាយកទាំង ២ គណៈ  រដ្ឋមន្ត្រីទាំង ៥ នឹងសម្ដេចស័ក្ដិត្រាធិបតី តាន់ហ្វានធាតុ  ហែព្រះករុណាទៅយាងឡើងលើព្រះបល្ល័ង្កក្រោមព្រះ

មហាបុស្សបុកគាំងនៅមុខព្រះទីន័ងទេវា ។ ព្រះករុណា ទ្រង់ប្រតិស្ឋាន លើផែនមាស ក្រាលលើស្លឹកឧទុម្ពរព្រឹក្ស សម្តេចឥសីកទ្ធាធិបតីថ្វាយ ស័ទ្ធជយព្រឹក្ស ព្រះករុណា ទ្រង់ទទួលកាន់ដោយព្រះហស្តស្តាំជាព្រះ តេជះបេស្តា ហើយទ្រង់ឈមព្រះភក្រ្តទៅទិសបូព៌ា ឲកញ៉ាហោរាធិបតី បានហ្វានក្រុមហោរាសូត្រប្រកាសអញ្ជើញទេវតា សូមចំរើនសិរីសួស្តី ជ័យមង្គលថ្វាយព្រះករុណា នៅទីកនទេព្តា ហើយបាញ់កាំភ្លើង ២១ ណាត់ថ្វាយជាព្រះកិត្តិយស នៅវេលាដែលលោកឡឺរេស៊ីដង់ស៊ុប៉េរីយើរ ព្រះចៅហ្វូងព្រះបាទ សម្តេចព្រះបរមរាជបិតាសុក្រមឹត សម្តេចព្រះ មាតុលាមុទ្ររេត ព្រះសង្ឃនាយកទាំងពីរគណ: សម្តេចព្រះឥសីកទ្ធថ្វាយ ព្រះសិទ្ធរស ទ្រង់ស្រង់រួចហើយស្តេចចុះមកឈានព្រះបាទាដោយទឹកដូង ទឹកអប់ក្នុងថាសមាស ។

ព្រះករុណា ទ្រង់គ្រឿងព្រះពស្ត្រព្រះភូសាផាយរត្តកម្ពលពេញព្រះ រាជបេស តាមលំអានព្រះមហាក្សត្រពីបុរាណ សម្តេចឥសីកទ្ធាធិបតី ហែមុខ ទ្រង់យាងចេញមកក្នុងព្រះទីន័ងទេវាវិនិច្ឆ័យទទួលលោកឡឺរេ-ស៊ីដង់ស៊ុប៉េរីយើរនៃប្រទេសកម្ពុជា ` ព្រះសង្ឃនាយកទាំង ២ គណ: ព្រះរាជវង្សានុវង្ស សេនាបតី នាហ្មឺនសព្វមុខមន្ត្រីក្នុងព្រះរាជាណាចក្រ និងមន្ត្រីរាជការប្រតិភូក៏ត៍ ហើយទ្រង់ទទួលព្រះបាទសម្តេចព្រះស៊ីស-ក៏នវង្ស ព្រះចៅហ្វូងព្រះបាទ លោករត្ស រេស៊ីដង់ស៊ុប៉េរីយើរនៅ

រៀនចន្ទន៍នឹងព្រះរាជវង្សានុវង្សដែលតាមហែមក     លោកហ្លួងកំហាយ សេនាបតីក្រសួងព្រះឃ្លាំងនៃក្រុងហ្វេនីងតូនគីនជាព្រះរាជបំរើនៃព្រះចៅ ប្រទេសអណ្ណាម លោករីវល់តួវ៉ែរណេរីនៃប្រទេសកូសាំងស៊ីន ។

លោកឡឺតូវ៉ែរណេរហ្សេណេរ៉ាល់ដែលចំស្រុកដំណើរតាមផ្លូវគោ-កាសពីហាណូយតាំងពីពេលព្រឹកមក     ទើបបានមកដល់ក្រុងភ្នំពេញ នៅវេលាម៉ោង ១០ ព្រឹកមិនទាន់ព្រះរាជពិធីស្រង់ព្រះសពឡើយ ។

លុះទៅភ្នាក់ងារសម្រេចកិច្ចតាមចំនៀមថ្វាយព្រះករុណាសព្វគ្រប់ ហើយ   ទើបលោកអធិបតីនៃប្រទេសឥណ្ឌូស៊ីន   លោកឡឺរេស៊ីដង់ស៊ុ-ពេរីយើរក្រុងកម្ពុជា ចូលថ្វាយបង្គំព្រះករុណាជួបជុំប្រជុំធំ នាំពណាដ៏មាន ថ្វាយសព្វសាធុការពេរពីរដ្ឋបាលបារាំងសែស ដែលចំនុកបំរុងក្រុងបារាំង-សែស ហើយអញ្ជើញនឹងហែស្តេចឡើងប្រថាប់លើព្រះបល្ល័ង្កតែង ក្រោមព្រះមហាស្វេតច្ឆត្រ ៩ ជាន់ មានបាញ់កាំភ្លើង ២១ ណាត់ថ្វាយជា ព្រះកិត្តិយស ជាទីសំគាល់ថាព្រះករុណាចូលទ្រង់សោយរាជសម្បត្តិក្រោម ព្រះមហាស្វេតច្ឆត្រហើយ ។ គ្រានោះ សម្តេចព្រះឥសីកាធិបតីអញ្ជើញ ព្រះមកុដកង្សផូនទៅលោកឡឺតូវ៉ែរណេរហ្សេណេរ៉ាល់ ចំពាក់ថ្វាយព្រះ ករុណាតាមទំនៀមរដ្ឋបាលបារាំងសែស ។ លោកឡឺរេស៊ីដង់ស៊ុពេរីយើរ អញ្ជើញព្រះខាន់រាជ្យថ្វាយព្រះករុណា ។ ទ្រង់ទទួលដោយព្រះហស្តស្តាំ

ហើយសេនាបតីទីទៅក្រសួង ថ្វាយគ្រឿងសម្រាប់កង្សាតាមទំនៀម ។ ទុកផ្កាក្រាបថ្វាយបង្គំព្រះករុណា ។

លោកអធិបតីសភារដ្ឋសភាក៏ថ្លែងសុន្ទរកថាថ្វាយសព្ទសាធុការ ការ ។

ព្រះរាជគ្រូហោរាស្ដេចចុះមកគង់ទាប់លោកឡើងតូវវណ៌ហើយលោកក៏ល់ ទឹងលោកឡើងប្រឹងដំណើរស្រប៉ើតហើយ វេលានោះមានពិធីបង្វិលពពិលថ្វាយ ។

ដល់ថ្ងៃពុធ ១០ កើតខែកត្តិក (២៩ឧកតូប្រ៍ ១៩៦១) មានពិធីហែប្រទក្សិណទីក្រុងភ្នំពេញ ព្រះករុណាទ្រង់ព្រះមកុដកេវប្រថាប់លើព្រះរាជយានមាស ហែចេញពីក្នុងព្រះបរមរាជវាំងតាមទ្វារធំខាងមុខ ដល់មាត់ទន្លេ ព្រះករុណាទ្រង់ទទួលព្រះពរជ័យអំពីកុមារកុមារីកូនសិស្សនៅក្រុងភ្នំពេញ ដែលកាន់ទង់ជាតិខ្មែរ-បាក់ទង់ទីងកាន់ផ្កាចាំថ្វាយព្រះពរជ័យ-មង្គល រួចទើបចូលក្នុងក្បួនធំដែលរៀបត្រៀមចាំស្រាប់ ។ លុះក្បួនព័ទ្ធដល់ទៅវត្តភ្នំ ព្រះករុណាទ្រង់ឡើងទៅលើព្រះពន្លាក៏ហើយឡើងគង់លើព្រះរាជរថមាស ក៏ព្រះរាជដំណើរទៅទៀត ដល់មុខអនុស្សាវរីយ៍មហា-សង្គ្រាម ទើបចូលឈប់លើព្រះពន្លាក៏ផ្លាស់ព្រះមកុដចេញ ទ្រង់ព្រះមាលាវិញ ហើយឡើងគង់លើព្រះទីន័ងអស្សរថ ក៏ព្រះរាជដំណើរទៅដល់មុខមន្ទីរពេទ្យការុណព្យាបាលទើបទ្រង់ចូលឈប់នៅទីនោះ ដែល

លោកឡឺគូវែរណឺរហ្សេណេរ៉ាល់ លោកឡឺរេស៊ីដង់ស៊ុបេរីយ៉េរព្រមទាំងខ្លួន ហើយទ្រង់ផ្លាស់ព្រះមាលាចេញ ទ្រង់ព្រះមាលាប្រពាតហើយទើបឡើងគង់លើព្រះទីនាំងគជេន្ទ្របន្ទ្រ ព្រះកដដំណើរប្រទក្សិណព្រះនគរមកដល់ព្រះបរមរាជវាំង ដែលមានបាញ់កាំភ្លើង ២១ ណាត់ថ្វាយជាព្រះកិត្តិយស ហើយទ្រង់យាងឡើងទៅលើព្រះពន្លាកកសម្រាន្តកម្សៀ ដែលលោកអធិបតីនៃប្រទេសឥណ្ឌូស៊ីននិងលោកឡឺរេស៊ីដង់ស៊ុបេរីយ៉េរ សម្ដេចព្រះបរមរាជបិតាហែចុះមកកាន់ទេពវិនិច្ឆ័យវិញ ។

## សុន្ទររាជបន្ទូលក្នុងឱកាសរាជាភិសេក

ឯដោយពិតនោះ ដែលនិងសន្មតថាមនុស្សត្រូវសំគាល់តាមត្រកូល តាមក្រុមសន្និកសនិងតាមប្រទេសដែលខ្លួនកើតនិងរស់នៅ គឺតាមសេចក្ដីសាមគ្គីជាតិដូច្នេះហើយ ដែលទ្រង់ប្រាញ្ញស៊ុំពួកយើងនៅវេលាថ្ងៃនេះ ជាប្រយោជន៍ដើម្បីនឹងកែរៀបនគរកម្ពុជាជាថ្មីឲ្យបានស្រួលឡើង ។

ឯការរំឭកនេះ គឺបំណងឲ្យបណ្ដាជនក្នុងព្រះនគរមានគំនិតគិតដល់អាណាប្រយោជន៍សាធារណៈ បើពោលឲ្យចំពោះទៀតគឺថាត្រូវឲ្យមានសេចក្ដីស្មោះត្រង់ចំពោះដល់ប្រយោជន៍សាធារណៈ ត្រូវឲ្យយកចិត្តទុកដាក់ធ្វើការទាំងពួង ឲ្យស្រឡាញ់នូវសេចក្ដីសុចរិត ។ ឯកិច្ចធ្វើការ

នេះជាមតិសំរាប់ជនកម្មករ ហើយជនកម្មករត្រូវតែធ្វើទីងជៀសវាងពុំបាន តែមានទេសជាតិជាច្រើនដែលមានចេតនាចង់ជៀសវាងពីកិច្ចធុរៈធ្វើការនេះឯង ហើយផ្ទុកលើអ្នកដទៃឲ្យធ្វើការជាជំនួសខ្លួន ត្រូវកំចាត់បង់កុំឲ្យមានគំនិតខុសដូច្នោះទៀតឡើយ ត្រូវខិតខំតាំងខ្លួនឲ្យមានកើតឡើងជាអ្នកមានប្រយោជន៍ដល់ស្រុកឲ្យមានចំនួនច្រើនឡើងក្នុងព្រះនគរ ដូចកាលក្នុងនានាពង្សក្សត្រក្នុងនគរបុរាណវិសេស ដែលមានពួកជនដូច្នោះជាច្រើនខិតខំយកចិត្តទុកដាក់រៀងរាល់ថ្ងៃ ធ្វើឲ្យបានសិរីជយមង្គលដល់មហាក្សត្ររបស់គេ ដូច្នេះអំពើគេនៅត្រូវតែខំភពការគ្រប់ដំណែងដែលទទួលអំណាចអំពីទ្រង់ប្រោសព្រះរាជទានទៅឲ្យសព្វរៀងខ្លួននោះខំខ្នះខ្នែងធ្វើការឲ្យហ្មត់ចត់ដោយសុចរិតទៀងត្រង់ ហើយខិតខំឃ្លាតឲ្យអស់ពីកំឡាំងកាយនិងចិត្តរបស់ខ្លួន កុំឲ្យប្រាថ្នាយកតែសុខ ហើយនឹងធ្វើការមុខអាគេចវេះមិនឲ្យមានការទទួលខុសត្រូវលើខ្លួន ហើយឥតមានប្រយោជន៍អ្វីដូចកាលមុនទៀត តែត្រូវឲ្យមានដើមគំនិតរបស់ខ្លួនជាមេនាយក ត្រូវសង្វាតធ្វើការឲ្យបានសំរេចហើយឲ្យបានល្អផង ។

សុំឲ្យពួកយុវជនដែលមានចំណេះវិជ្ជាក្នុងព្រះនគរទាំងប៉ុន្មានយល់តាមព្រះរាជតម្រិះនេះ ហើយលុះបានប្រកបកិច្ចការអ្វីឯណា ត្រូវឲ្យទទួលប្រតិបត្តិតាមរបៀបដែលទ្រង់បានរើសត្រូវមកលើខ្លួន គឺ “ធ្វើការជាប្រយោជន៍ស្រុក” ។

សេចក្ដីស្រឡាញ់ជាតិរបស់ខ្លួន ដែលទ្រង់ទុកជាប្រយោជន៍ដើម្បីឲ្យបានមាំមួនខ្លាំងឡើងនេះ មិនត្រូវបណ្ដាលឲ្យអស់អាណាប្រជាកស្ត្រក្តួចឡើយ ជា នៅក្រៅពីដែនស្រុកយើងទៅ មាននានាប្រទេសឯទៀតដែលព្រះនគរបានរួបរួមចងមិត្រមេត្រីនឹងគ្នា ជាប្រយោជន៍ធំផ្ទាល់ដ៏រឹតលើសលុបអំពីកិច្ចការលក្ខណៈដែលចុះខសញ្ញាជាត្រឹមត្រូវមាំមួនទឹងគ្នាតាមរបៀបច្បាប់នោះទៅទៀត ។

រឿងនេះ ប្រការ ១ គឺទ្រង់អធិប្បាយអំពីប្រទេសឥណ្ឌូស៊ីនដែលដើមឡើយគ្រាន់តែជាទីរួមដែននគរជាមួយគ្នាជានាមប៉ុណ្ណោះទេ តែដល់មកក្នុងរង់ប៉ុន្មានឆ្នាំមុននេះ បានរួបរួមគំនិតគ្នាចំរើនឡើងរឿងៗមកលុះត្រាតែកើតឡើងជាក្រុមសហរដ្ឋ១យ៉ាងមាំមួន កាលដើមគិតស្មានថាជាការរួបរួមគ្នាតែដោយគំនិតបន្តិចបន្តួចប៉ុណ្ណោះទេ តែដោយបានប្រស្រ័យគ្នាទៅវិញទៅមកជាចិតថេរមាំមួនឡើង មានមេត្រីកប់ភានគ្នាដោយដឹងស្គាល់ផ្លៃគ្នាទៅវិញទៅមករឹតតែផ្គុតជាបន្ទាំងឡើងហើយបានស្រុះចិត្តខ្ទួលបង់ខាតជាមួយគ្នាក្នុងការៈការពារប្រទេសឥណ្ឌូស៊ីនកាលលើកមុនមិញនេះទៀតនោះ ទើបបណ្ដាលរួបរួមជាសហរដ្ឋនេះឡើង ។

គំនិតដែលប្រួបប្រួមបង្កើតឡើងនៅសហរដ្ឋនេះ ទើបបានបញ្ញត្តត្រូវឲ្យជួបជុំជុំនុំការប្រួបប្រួមគ្នាក្នុងក្រុមមហាសន្និបាតដែលទើបបង្កើតថ្មី ។

គួរតែកម្ពុជរដ្ឋជួយឧបត្ថម្ភដល់ក្រុមសហរដ្ឋថ្មីនេះហើយ ដោយក្រុមនេះអាចនឹងបណ្ដាលឲ្យមានប្រយោជន៍ចំពោះខ្លួន នោះកម្ពុជរដ្ឋដែលនឹងមានមេត្រីជួយឈឺឆ្អាលឬជួយឧបត្ថម្ភដល់ក្រុមនោះ កុំបីមើលបំណាំក្នុងកិច្ចការឯណាដែលមិនគួរមើលបំណាំនោះឡើយ ។

ឯប្រទេសឥណ្ឌូស៊ីនេះនេះគ្រាន់តែជាភាគ ១ នៃប្រទេសកដរបស់នគរហុកំងីសែសប៉ុណ្ណោះទេ ហើយកម្ពុជរដ្ឋដែលទៅក្នុងដែនប្រទេសឥណ្ឌូ-ស៊ីន ក៏កប់ចូលក្នុងវង្សប្រទេសកដរបស់បាកំងីសែសដែលជាទីរួមប្រទេសព្រេនោះដែរ ក្នុងប្រទេសកដរបស់បាកំងីសែសទាំងអស់មានមនុស្សចំនួន ១០០ លាននាក់ មានទំហំដីធំជាងកម្ពុជរដ្ឋចំនួន ៥០ ដង ។

គួររំពុកឲ្យឃើញឡើងថា ដោយសារមកអំពីមានប្រទេសដយ៉ាងធំលក់លៀបដូច្នេះ បានជាខគរយើងមិនអាចលោយទៅបាន ហើយមួយវិញទៀត ដោយមានរាត់វែងធ្វើការក្នុងប្រទេសជនោះបានចំរើនឡើងរៀងរាបដកបមកនោះ គង់មានថ្ងៃណាយើងនឹងមានសិរីជយមង្គលដូចកាលបុកណដើមឡើងវិញជាមិនខាន ។

ដូច្នេះ ក្រៅអំពីសេចក្ដីសាមគ្គីដែលត្រូវជួយឈឺឆ្អាលដល់ក្រុមសហរដ្ឋដែលខ្ញុំទើបអធិប្បាយឲ្យដឹងហេតុមកខាងលើនេះ ខ្ញុំសុំឲ្យ

គាណាប្រជាកស្ត្រមានគំនិតដឹងយល់តាមរបៀបដែលអធិប្បាយអំពីប្រ-ទេសកម្ពុជានោះផង ។

កម្ពុជរដ្ឋ សព្វថ្ងៃនេះគេមិនមែនបដិសេធឲ្យនៅតែឯកឯងក្នុងលោកនោះទេ ដែលមានកំឡាំងអន់ថយបន្តិចនេះគឺដោយមានគ្រោះកាល គ្រោះខគអាណាព្យាបាលមានទុក្ខលំបាកនៅប្រទេសនុះ លុះកាលណាសម័យហេតុត្រឡប់មកជាស្រួលដូចធម្មតាឡើងវិញ ទ្រង់មានព្រះកដកម្រើះយល់ជាក់ច្បាស់ណាស់ថា នឹងបានរុងរឿងឡើងវិញជាប្រាកដ តែត្រូវឲ្យនគរនីមួយៗក្នុងប្រទេសកម្ពុជមានសេចក្ដីប្រាម្ភយកចិត្តទុកដាក់ សំរេចតាមការៈដែលខ្លួនត្រូវធ្វើចំពោះដល់ប្រទេសកម្ពុជផងទើបបាន ត្រូវឲ្យជឿទុកចិត្តយ៉ាងខ្ពស់ប្រពៃដូចទ្រង់ធ្វើចំពោះដល់នគរបុរាណវិសេសនិងកិច្ចការដែលលោកសេនាប្រមុខសើរើធ្វើឲ្យបានចំរើនឡើងវិញ ។

ទ្រង់មិនមែនមានបំណងអធិប្បាយចំពោះតែអំពីរបៀបគំនិតធំៗ ដែលមានប្រយោជន៍ក្នុងការធ្វើឲ្យបានចំរើនឡើងវិញដល់នគរប៉ុណ្ណោះ ហើយឥតអធិប្បាយអំពីរបៀបទំនៀមទម្លាប់របស់ជាតិនោះទេ គឺថាបើកាលណាទំនៀមទម្លាប់នោះល្អស្រួលហើយ ត្រូវតែប្រតិបត្តិឲ្យមានឋិតថេរតទៅ ប្រសិនបើទំនៀមទម្លាប់នោះមិនសូវស្រួលល្អទេ ត្រូវតែកែតម្រូវឲ្យបានស្រួលឡើង ។

វត្ថុដែលជាទីគោរពយ៉ាងធំសំខាន់បំផុតរបស់ជាតិយើងគឺព្រះពុទ្ធសាសនា ជាមត៌កពីដូនតារបស់យើងតកមក ដែលលោកប្រដៅទូន្មានញុំាងចិត្តមនុស្សលោកឲ្យបានបរិសុទ្ធសុចរិតស្អូតត្រង់ជាបំផុតតាមតម្រានៃព្រះសម្មាសម្ពុទ្ធគោតម ។ ឯសេចក្ដីប៉ុនប៉ងយ៉ាងធំរបស់ទ្រង់ គឺប៉ងឲ្យអាណាប្រជារាស្ត្រមានសេចក្ដីព្យាយាមខំស្វាហាប់ប្រតិបត្តិតាមសាសនាដែលបរិសុទ្ធវិសេសជ្រះ ។

ធម្មតាចិត្តមនុស្សមិនដែលបរិសុទ្ធល្អឯង ធម្មតាចំណង់មនុស្សមិនដែលមានព្យាយាមមាំមួនឯង ឬលុះទៅដោយការលះបង់ឯងៗ ដែលនឹងធ្វើចិត្តឲ្យបរិសុទ្ធបាន ធ្វើចំណង់ឲ្យមានព្យាយាមមាំមួនឡើងបាន ឬឲ្យលុះទៅតាមការលះបង់បាននោះ ត្រូវឲ្យមានរបៀបទូន្មានឲ្យប្រតិបត្តិជាទូលាយស្រួល តែកុំបីឲ្យឃ្លាតពីសេចក្ដីព្យាយាមសោះឡើយ ។ ឯរបៀបទូន្មានឲ្យប្រតិបត្តិនោះ គ្មានអ្នកណាអាចនឹងធ្វើឲ្យបានប្រសើរលើសអំពីរបៀបដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងក្រោមដើមអជបាលនិគ្រោធពោធិរាង២៥០០ ឆ្នាំមកហើយនោះទេ ដែលព្រះអង្គទ្រង់ប្រកបដោយមហាករុណាដល់មនុស្សលោក ក៏ទ្រង់បានសំដែងទូន្មានប្រៀនប្រដៅឲ្យបានរេះដឹងឡើង ។ សេចក្ដីនេះ គឺទ្រង់រំឭកដល់អាណាប្រជារាស្ត្រទាំងឡាយ បំពោះឲ្យប្រតិបត្តិតាមទូន្មានរបស់ព្រះសម្មាសម្ពុទ្ធឲ្យបានត្រឹមត្រូវហ្មត់ចត់មាំមួនឡើង ។

សុំលោកអាយ៉ក៏ល់ជ្រាប! គឺតាមន័យដូចមានអធិប្បាយខាងអម្បាលម៉ាន់ខាងលើនេះហើយ ដែលទ្រង់ខ្ញុំខរំពុកដាស់តឿនអាណាប្រជារាស្ត្ររបស់ទ្រង់ឲ្យប្រតិបត្តិតាម ។

ទ្រង់មានព្រះរាជហឫទ័យគិតជួយអាណាប្រជារាស្ត្រ ដើម្បីឲ្យបានសំរេចតាមន័យដែលទ្រង់បានអធិប្បាយរំពុកមកនេះ ដោយទ្រង់ត្រូវប្រតិបត្តិឲ្យទៀងទាត់ត្រឹមត្រូវតាមការៈដែលទ្រង់ខ្ញុំនាំមកដូច្នេះផង ។

ចំណែកខាងទ្រង់ដែលបានឡើងគ្រងរាជសម្បត្តិនេះ គឺទ្រង់ទទួលការខុសត្រូវពេញទីតាំងអស់តាមនាទីរបស់ទ្រង់ ហើយទ្រង់បានប្ដេជ្ញានឹងសំរេចឲ្យបានស្រួលតាមកិច្ចមុខក្រសួងដែលត្រូវមកលើទ្រង់ជាអ្នកណែនាំឲ្យបានចំរើនតទៅ ។

ទ្រង់មានសង្ឃឹមជាក់ថា មុខជានឹងមានទេវតាលើមេឃជួយជាកម្លាំងដល់ទ្រង់ ដើម្បីឲ្យទ្រង់ពាត់ការរបស់ទ្រង់បានសំរេចដូចសេចក្ដីប្រាថ្នា ហើយថាអំពីដែលទ្រង់គិតខំរៀបចំនេះ នឹងបានសំរេចឲ្យកម្ពុជរដ្ឋបានរៀបចំស្រួលឡើងទៅថ្ងៃមុខជាមិនខាន តាមព្រះរាជបំណងនៃព្រះករុណាព្រះបរមខត្តិយកោដ្ឋ ដែលទ្រង់បានគិតរៀបចំដូច្នោះមកកាលនៅក្នុងបច្ឆិមវ័យរបស់ទ្រង់ ។

ទ្រង់រំពុកដោយពេញឥន្ទ្រិយ៍ដល់អស់ជនានុជនខេមរជាតិ ឲ្យជឿទុកចិត្តលើគំពូសំណាក់ព្រះនគរតាមន័យដូច្នេះឯង ។

# ព្រះរាជឱង្ការនូវព្រះបន្ទូលស្នូរសីហនាទ

ខ្លួនខ្ញុំឯងនេះគឺ:

ព្រះបាទសម្ដេចព្រះនរោត្ដម - សីហនុ វរ្ម័ន រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរ័តន៍ និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី ជាម្ចាស់ជីវិតលើត្បូង

ខណៈនេះខ្ញុំត្រូវការថ្លែងពណ៌នាដ៏មានខ្លួចមានខាងក្រោយចំពោះ

ដល់ព្រះរាជវង្សានុវង្ស

ដល់សេនាបតី

ដល់អស់នាហ៊ឺនសព្វមុខមន្ត្រី ក្រសួងរដ្ឋបាលទាំងក្រសួងតុលាការ ក្នុងក្រុងទាំងក្រៅខេត្ត

ដល់ជនានុជនក្នុងក្រុងកណ្ដាលទីប្រជុំទាំងស្រុកស្រែចំការទាំងអស់ ចូរបានដឹងការប្រៀនកល់ចំណែក ។

ដ្បិតព្រះរាជពិធីបុណ្យព្រះមេរុ នៃព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ-មុនីវង្ស ជាព្រះរាជអយ្យកោនៃខ្ញុំ ព្រមទាំងពិធីរាជាភិសេកផ្ទាល់ខ្លួនខ្ញុំនេះ ក៏បានរៀបគាត់តែងស្ទើរសម្រេចដោយរុងរឿងយ៉ាងប្រសើរ តាមរបៀបទម្លាប់នឹងទំនៀមពីបុរាណរៀងមកហើយ ។

ហេតុនេះ ខ្ញុំត្រូវការថ្លែងសេចក្ដីសោមនស្សអរគុណដល់សប្បុរសទាំងឡាយ ពោះព្រះរាជវង្សានុវង្សក្ដី សេនាបតីក្ដី នាហ្មឺនសព្វមុខមន្ត្រីក្ដី ដែលបានទទួលនឿយហត់ជួយទំនុកបំរុងដោយស្មោះ ធ្វើឲ្យបានពិធីបុណ្យល្អរុងរឿងដល់ម្ល៉េះ ។

ខ្ញុំសូមអរគុណដល់ចំណែកព្រះសង្ឃ ដែលបានយកព្រះទ័យទុកដាក់ជ្រះថ្លានិមន្តមកជួយធ្វើឲ្យបានរុងរឿង ជាទីលើកសិរីសួស្ដីក្នុងពិធីបុណ្យនេះផង ។

មួយយ៉ាងទៀត ខ្ញុំមានសេចក្ដីសោមនស្សរីករាយដោយបានឃើញអាណាប្រជាជននាំគ្នាចូលមកក្នុងឱកាសបុណ្យនេះជាច្រើន ហើយឃើញប្រកបទៅរបៀបយ៉ាងសុភាពល្អ អាចជាបន្ទាល់ឲ្យឃើញថាមានចិត្តស្រឡាញ់ដល់ព្រះករុណាព្រះបរមរតនកោដ្ឋនោះផង ទាំងមានសេចក្ដីសប្បុរសស្មោះត្រង់ចំពោះដល់រូបខ្ញុំនេះថែមទៀត ។

មួយយ៉ាងទៀត ខ្ញុំមានអំណរណាស់ដោយមានឱកាសនេះដាល់-អានឲ្យខ្ញុំបានមកសន្ទនាផ្ទាល់ដល់អស់ជនានុជនទាំងឡាយឲ្យបានយល់ភ្លឺ អំពីកិច្ចកម្មវិបាកដែលមានមកតាមសកកដក្នុងសម័យនេះ ហើយទាំងបានឲ្យសេចក្ដីទូន្មានខ្លះដល់អាណាប្រជានុរាស្ត្រផង ។

ខ្ញុំមានចិត្តជឿច្បាស់ថា អាណាប្រជានុរាស្ត្រមុខជានឹងប្រតិបត្តិតាមសេចក្ដីទូន្មាននេះ ហើយមុខជានឹងមានសេចក្ដីបារម្ភ យកចិត្តទុកដាក់

ដល់ព្រះនគរទៅខាងអនាគត ស្មើដូចជាប្រយោជន៍ផ្ទាល់ខ្លួន តាមសេចក្តី ខ្ញាននេះជាមិនខាន ។

ក – អំពីកិច្ចការឲ្យកាន់កាប់អំណាចស្តុកដការ

អំពីកិច្ចដែលត្រូវឲ្យហ៊ានទទួលការខុសត្រូវលើគ្នា

អំពីក្រិត្យគោរពប្រតិបត្តិ

សេចក្តីខ្ញាចទី ១ អធិប្បាយអំពីរបៀបអំណាចនិងរបៀបកិច្ចការ ដែលត្រូវទទួលខុសត្រូវលើខ្លួន ។ មានមន្ត្រីជាច្រើនរូបដែលតែងតែ បណ្តែតបណ្តោយទៅតាមសេចក្តីងាយងាយ ព្រោះតែមានគំនិតគិតតែពឹង ផ្អែកទៅលើអ្នកដំណាងនគរបាលពិសេសឲ្យសម្រេចសេចក្តីផ្សេងៗជួសខ្លួន ទៅវិញ ។ គំនិតដែលគិតខុសបែបនេះ អាចនាំបណ្តាលឲ្យមន្ត្រីពួកនោះ ឯងមានគំនិតខុសគិតតែអែនខ្លាចមិនហ៊ានទទួលកំហុសត្រូវលើខ្លួនដោយ ស្មោះពេញចិត្តបណ្តាលឲ្យបែកនាទទួលស្គាល់សម្រេចកិច្ចការរដ្ឋការបាន ល្អិតល្អពេញមុខក្រសួងដែលនោះឡើយ ។

ឯអំពើទាស់នេះ នាំឲ្យខូចខាតការណាប្រយោជន៍នៃព្រះនគរ ហើយនាំឲ្យខាសខុសនីរបៀបលទ្ធិស្សតាតរបស់រដ្ឋការណាព្យា-បាលចាក់ពិសេសនោះផង ឯរដ្ឋការណាព្យាបាលចាក់ពិសេសមាន ប្រាថ្នាចង់ឲ្យមន្ត្រីខេមរជាតិ បេះមានគំនិតដណ្តើម បេះភាគពែងការរដ្ឋការ ឲ្យបានកើតមាំមួនឡើង ។

ខ្ញុំមានសេចក្តីសង្ឃឹមថា អំណេះតទៅអ្នកទាំងអស់ជាជំនាន់ កដការផែនដីមុខជានឹងយកចិត្តទុកដាក់បំបាត់អំពើប្រព្រឹត្តខុសផ្លូវនេះ ពោលចេញហើយៗថា អ្នកកដការគ្រប់ជំនាន់ មុខជានឹងចេញមុខ សំរេចកិច្ចការពេញអំណាច ដែលខ្ញុំបានប្រគល់ទៅឲ្យគាត់គាប់រៀងកល់ ចំណែកតទៅ ដោយនូវបានពិគ្រោះព្រមព្រៀងជាមួយនឹងអ្នកស៊ុធនិក ផាតិបាកំងសែសផងជាមិនខាន ។

មួយយ៉ាងទៀត ខ្ញុំសង្ឃឹមថា អាណាប្រជានុរាស្ត្រដែលជាទីគាប់ចិត្ត របស់ខ្ញុំ មុខជានឹងដឹងស្គាល់នូវប្រយោជន៍ដែលគប្បីឲ្យគោរពកោតខ្លាច តាមក្រិត្យច្បាប់ដោយអហង្ការ ហើយមុខជានឹងនាំគ្នាយកចិត្តទុកដាក់ធ្វើ កិច្ចគោរពច្បាប់នឹងទទួលស្តាប់បង្គាប់ជាបំផុតក្នុងពេលសម័យនេះ អាច ទុកជាគម្រាប់ល្អតទៅ ។

១ – <u>អំពីត្រូវឲ្យមានចេតនាយកចិត្តទុកដាក់ធ្វើការដោយឥតប្រាថ្នា យកប្រយោជន៍ចំពោះខ្លួន នឹងអំពីសេចក្តីយកចិត្តទុកដាក់ស្មោះត្រង់ចំពោះ ព្រះនគរ ។</u>

គំនិតគិតខុសមួយយ៉ាងទៀតរបស់ជាតិយើង គឺគ្មានចេតនានឹងយក ចិត្តទុកដាក់ខិតខំប្រើកំឡាំងសោះ បើធ្វើការរបស់ៗ បំណងចង់តែឲ្យបាន បំរើនតែតាមសេចក្តីត្រូវការជាប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ ឥតមាន សង្ឃឹមចង់ឲ្យបានលើសទៅទៀតឡើយ ។

នៅស្រុកយើង មានមនុស្សពំពួកខ្លះមិនសូវជាគិតការផ្ទាល់ខ្លួនពេកណាស់ទេ តែយកចិត្តទុកដាក់ចំពោះតែគន្ធវង្សត្រកូលរបស់ខ្លួន កាលបើមានខេមរជាតិនីមួយៗប្រកបនូវសេចក្ដីស្រឡាញ់នគររបស់ខ្លួនជាទីបំផុតចិត្ត ហើយមានបំណងប៉ងនឹងប្រឹងដើរតែរបស់ខ្លួនស្វែងជាប្រយោជន៍នគរឋាន ប៉ុន្តែតាមធម្មតាអ្នកដែលមានសេចក្ដីស្រឡាញ់នឹងស្មោះត្រង់ដូច្នោះ ហើយខំយកចិត្តទុកដាក់ប្រឹងប្រែងធ្វើការជាដរាបទៅ ឥតមានប្រាថ្នាយកប្រយោជន៍ផ្ទាល់ខ្លួនដូច្នោះ ក៏សោតសឹងមានតិចតួចណាស់ ។

ឯដោយពិតនោះ គឺមនុស្សទាំងត្រកូលត្រូវសំគាល់ថាយកកំណើតអាស្រ័យដោយខានស្រុកកំណើតដែលជាទីតាំងឲ្យខ្លួនមានរបររកស៊ីចង់ឲ្យបានសេចក្ដីសុខក្នុងការចិញ្ចឹមជីវិតរបស់ខ្លួន ។

សេចក្ដីនេះ ខ្ញុំសុំកុំឲ្យខេមរជាតិភ្លេចឡើយ ហើយសុំឲ្យដឹងថាសិរីសួស្ដីជ័យមង្គលថ្កើងថ្កានរបស់ប្រទេសនីមួយៗ មិនសូវមានបណ្ដាលកើតឡើងមកពីសេចក្ដីក្លាហានរបស់មនុស្សត្រឹមតែប៉ុន្មាននាក់នោះទេ គឺច្រើនកើតមកពីសេចក្ដីព្យាយាមព្រមទាំងការអត់ធន់របស់មនុស្សដែលរួបរួមច្រើនគ្នាទៅ ។

គ - អំពីសេចក្ដីរួបរួមសាមគ្គីនៃកម្ពុជរដ្ឋ នឹងប្រទេសឥណ្ឌូស៊ីន ។

ព្រំប្រទល់នៃប្រទេសរបស់យើង មិនមែនជាទីបាំងរាំងមិនឲ្យយើងសំរេចកិច្ចការបានហួសទៅក្រៅនោះទេ គឺហួសពីទីព្រំប្រទល់នោះទៅ

មានប្រទេសធំៗទៅទៀត ដែលកម្ពុជរដ្ឋបានរួបរួមសាមគ្គីជាប្រយោជន៍ផ្ទាល់ជីវិត ហើយមានចុះខសញ្ញាល័ក្ខខ័ណ្ឌជាត្រឹមត្រូវតាមច្បាប់នោះផង ។

រឿងនេះគឺខ្ញុំចង់អធិប្បាយអំពីប្រទេសកណ្ដូស៊ុនជាដើមហេតុ ដែលដើមឡើយគ្រាន់តែជាទីប្រជុំអាណាចក្រមួយដែនជាមួយគ្នាប៉ុណ្ណោះទេ តែក្នុងរវាងប៉ុន្មានឆ្នាំមុននេះបានចំរើនឡើងរួបរួមគ្នាជាសហរដ្ឋមួយយ៉ាងមាំមួន ។

គឺសេចក្ដីចំរើនក្នុងការផ្ញើដំនួញទៅវិញទៅមកច្រើនៗឡើងរាល់ថ្ងៃ សេចក្ដីមេត្រីរាប់អានគ្នាដោយដឹងស្គាល់ដម្លៃគ្នាទៅវិញទៅមក រឹងរឹតតែជ្រួតជ្រាបខ្លាំងឡើង ព្រមទាំងការទទួលបន្ទុកជាទម្ងន់ក្នុងកិច្ចការការពារទឹកដីជាមួយគ្នាកាលមុនម៉ិញនេះទៀត នេះហើយដែលជាហេតុនាំឲ្យខេមរជាតិជាតិលាវនឹងជាតិយួនបានរួបរួមគ្នាតទៅ ។

ខ្ញុំមានចិត្តចង់ឲ្យអាណាប្រជានុរាស្ត្របំភ្លេចសេចក្ដីដែលធ្លាប់មានអធិករណៈនឹងគ្នាពីដើមមកនោះចោលទៅ ដើម្បីឲ្យរពឹកឃើញតែអំពីសេចក្ដីដែលទើបចងមិត្រមេត្រីនឹងគ្នាថ្មីៗនេះតទៅ ហើយត្រូវឲ្យជួយឧបត្ថម្ភដល់សហរដ្ឋកណ្ដូស៊ុនតាមកំឡាំងរបស់ខ្លួនផង កុំបីប្រចាំនឹងប្រទេសជិតខាងឡើយ ។

ឃ – អំពីការញុំាងកម្ពុជរដ្ឋឲ្យបានចំរើនឡើង និងអំពីការធ្វើប្រទេសបារាំងសែសឲ្យបានប្រែទៅការសេចក្ដីរុងរឿងឡើងវិញ ។

ប្រទេសឥណ្ឌូស៊ីននេះគ្រាន់តែជាភាគ ១ នៃប្រទេសកជបារាំងសែសប៉ុណ្ណោះទេ ហើយដែនកម្ពុជាដែលនៅក្នុងប្រជុំប្រទេសឥណ្ឌូស៊ីន ក៏ចប់ចូលក្នុងវង់ប្រទេសកជរបស់បារាំងសែស ដែលមានទំហំដីធំរួមប្រទេសជាច្រើននោះដែរ ក្នុងប្រទេសកជរបស់បារាំងសែសទាំងមូលមានមនុស្សចំនួន ១០០ លាននាក់ មានទំហំដីធំជាងដែនកម្ពុជាចំនួន ៥០ ដង ។

ខ្ញុំត្រូវពោលឲ្យឃើញឡើងថា ដោយសារមានប្រទេសកជជាកំឡាំងដំនោយជាកំពាំងដូច្នោះហើយ បានជាប្រទេសយើងមិនអាចរលាយទៅបានហើយមួយវិញទៀត ដោយមានចាត់ការក្នុងប្រទេសកជនោះរឹតតែចំរើនឡើងៗ នោះគង់មានថ្ងៃណាមួយ ប្រទេសយើងនឹងមានសិរីសួស្ដីជ័យមង្គលប្រែបានជារុងរឿងដូចកាលអំពីបុរាណឡើងវិញពុំខាន ។

ដូច្នេះ គ្រាន់អំពីសេចក្ដីសាមគ្គីដែលត្រូវជួយឈឺឆ្អាលដល់សហរដ្ឋឥណ្ឌូស៊ីន ដែលខ្ញុំទើបនឹងអធិប្បាយខាងលើនេះ ខ្ញុំសុំឲ្យអាណាប្រជាជនដឹងយល់ន័យតាមកិច្ចការនៃប្រទេសកជនោះផង ។

សេចក្ដីនេះ គួរអធិប្បាយឲ្យឃើញឡើងថា មេត្រីភាពដែលកម្ពុជរដ្ឋត្រូវសំដែងកតញ្ញុតាឲ្យឃើញជាក់ស្ដែងចំពោះប្រទេសបារាំងសែសក្នុង

បច្ចុប្បន្ននេះ មិនមែនគ្រាន់តែប្រកបតាមទំនៀមទម្លាប់សុចរិតស្មោះត្រង់របស់ជាតិខេមរៈប៉ុណ្ណោះទេ គឺប្រកបតាមយោបល់ប្រាជ្ញដែលឈ្វេងយល់ដល់ការណាប្រយោជន៍ជិតឆ្ងាយរបស់ប្រទេសនេះផង ។

កម្ពុជរដ្ឋសព្វថ្ងៃ បើទុកជាស្រពោនស្រពាប់ស្ងប់ស្ងាត់ដូចម្ដេចក្ដី ដោយហេតុដែលទើបមានបណ្ដាលមកថ្មីៗនេះ ក៏គេមិនមែនបដិសេធទុកឲ្យនៅតែឯកឯងក្នុងលោកនេះទេ គឺថាបើប្រទេសបារាំងសែសនៅជួយទំនុកបំរុងតទៅទៀត នេះមុខជានឹងបានគង់វង្សជាអង្វែងមិនខាន ។ មានតែហេតុដោយខ្សែកប៉ុណ្ណោះទេ ដែលបណ្ដាលនាំឲ្យប្រទេសបារាំងសែសអស់ថយកំឡាំងក្នុង ១ ខណៈនេះ តែត្រូវសង្ឃឹមថាក្នុងពេលទៅមុខគង់នឹងបានស្រួលឡើងវិញ នាំឲ្យប្រទេសអាណាព្យាបាលបានរើបទៅកាន់សេចក្ដីរុងរឿង ហើយប្រទេសយើងក៏នឹងបានរៀបចំល្អឡើងវិញដែរ ។

## ង - អំពីសេចក្ដីគោរពព្រះពុទ្ធសាសនា

ខ្ញុំមិនមែនមានបំណងអធិប្បាយតែអំពីកិច្ចការដែលមានប្រយោជន៍ចំពោះភ័ព្វសំណាងនៃប្រទេសយើងប៉ុណ្ណោះ ហើយឥតអធិប្បាយអំពីទំនៀមទម្លាប់របស់ជាតិនោះទេ គឺថាបើកាលណាទំនៀមទម្លាប់នោះល្អ ត្រូវតែប្រតិបត្តិឲ្យគង់នៅឋិតថេរតទៅ ។

វត្ថុដែលជាទីគោរពយ៉ាងធំសំខាន់បំផុតរបស់ជាតិយើងគឺព្រះពុទ្ធ-សាសនា ជាមរតកពីដូនតារបស់យើងទុកមក ដែលលោកគាបប្រដៅ

ខ្លួនញ៉ាំងចិត្តមនុស្សលោកឲ្យបានបរិសុទ្ធ សុចរិតស្អាតត្រង់ជាបំផុត តាមតម្រាប់នៃព្រះគោតមបរមសម្មាសម្ពុទ្ធ ។

ឯបំណងយ៉ាងមាំរបស់ខ្ញុំ ចង់ឲ្យអាណាប្រជានុរាស្ត្រមានសេចក្តីព្យាយាមឧស្សាហ៍បដិបត្តិតាមសាសនាដ៏បរិសុទ្ធដ៏វិសេសនេះ ។

ខ្ញុំចង់ឲ្យអាណាប្រជាជនទាំងអស់ ទោះជាបព្វជិតក្តី គ្រហស្ថក្តី បដិបត្តិឲ្យទៀងទាត់ត្រឹមត្រូវតាមពុទ្ធបញ្ញត្តិ ដើម្បីឲ្យកម្ពុជរដ្ឋយើងដែលបានត្រាប់ត្រងរក្សាបែបបទនៃសាសនាដ៏បរិសុទ្ធឲ្យឋិតថេរគង់វង្សជាច្រើនសតវត្សមកហើយនោះ បាននៅជាគំរូប្រសើរលើសជាងនានាប្រទេសដែលកាន់ព្រះពុទ្ធសាសនាដូចគ្នានៅចុងបូព៌ាប្រទេស ។

ច – <u>អំពីការដែលត្រូវសិក្សា</u>

អំពីការដែលឲ្យប្រព្រឹត្តកាន់សាសនាឲ្យទៀងទាត់នោះ មិនមែនជាហេតុបណ្តាលឲ្យពួកអ្នកមានសតិបញ្ញាអាក់ខានក្នុងការរៀនសូត្រវិជ្ជាទំនើបនោះឡើយ ខ្ញុំចង់ឲ្យពួកខេមរជនដែលមានសតិបញ្ញាច្រើនខំប្រឹងប្រែងរៀនក្នុងដំនួរនៀវណា យទំនងការរៀនសូត្រវិជ្ជាបែបខាងបច្ចិមប្រទេសឡើយ គឺឲ្យយកចិត្តទុកដាក់ខិតខំរៀនសូត្រសិល្បសាស្ត្រសម័យថ្មីៗមាំមួនឡើង ។

ការដែលរៀនសូត្រសិល្បសាស្ត្រសម័យថ្មីនេះ ពុំមែនគ្រាន់តែបានចំណេះវិជ្ជាផ្ទាល់ប្រយោជន៍ក្នុងការទៀយហាត់ប៉ុណ្ណោះទេ គឺជាបច្ច័យឲ្យបានគ្រឿងមុខក្នុងការធ្វើប្រយោជន៍ឲ្យប្រទេសរបស់ខ្លួនថែមទៀតផង ។

សព្វថ្ងៃនេះ មានទីតំណែងដ៏សំខាន់ៗជាច្រើនកន្លែងនៅលើផែនដីគ្រប់ប្រទេស ឯកន្លែងទាំងនោះគួរនឹងប្រគល់ទុកដាក់ឲ្យខ្មែរជាតិកាន់កាប់បាន ដូចយ៉ាងមុខក្រសួងវិស្វកម្ម គ្រូបង្រៀនជាន់ខ្ពស់ និងគ្រូពេទ្យជាដើម ។

ឯការដែលខ្លះមនុស្សជាតិខ្មែរកាន់កាប់ទីតំណែងដ៏សំខាន់ៗដូច្នោះ ពិតមែនតែក្នុងតំណែងខ្លះមិនសូវជាបណ្ដាលឲ្យបង្កាតប្រយោជន៍ប៉ុន្មានទេ ប៉ុន្តែមានតំណែងខ្លះបណ្ដាលឲ្យខូចខាតប្រយោជន៍យ៉ាងធំបំផុត ។

សេចក្ដីនេះ ខ្ញុំចង់លើកតួយ៉ាងឲ្យឃើញឡើងអំពីការដែលខ្លះត្រូវអោយខ្មែរជាតិធ្វើការ បណ្ដាលឲ្យខូចរបៀបចាត់ការនៃក្រសួងព្យាបាលរោគដែលការពារមនុស្សមិនឲ្យមានឈឺចាប់ស្លាប់ច្រើន ហើយមិនអាចនឹងជួយសង្គ្រោះឲ្យមានមនុស្សកើតច្រើនតាមសេចក្ដីត្រូវការជាប្រយោជន៍ប្រទេសនោះផង ។

ខ្ញុំមានសង្ឃឹមថា ពួកយុវជនក្នុងប្រទេសយើងមុខជានឹងប្រតិបត្តិតាមដំបូន្មានរបស់ខ្ញុំមិនខាន ហើយអំណើះតទៅមុខជានឹងខិតខំប្រឹងប្រែងរៀនសូត្រដណ្ដើមយកថ្វីដៃក្នុងសាលាជាប្រាកដ ។

ពួកយុវជនទាំងនោះមុខជានឹងខំរៀនប្រឡងយកសញ្ញាប័ត្រឲ្យបាន ដើម្បីឲ្យឃើញថាខ្មែរជាតិមិនមែនគ្រាន់តែមានដំឡៃខ្ពស់លើសគេ

ដោយសារតែមានសេចក្តីសុភាពសុចរិតស្លូតត្រង់ប៉ុណ្ណោះទេ ទាំងសេចក្តីវៃឆ្លាតក៏ខ្ពស់ជាងកបដូច្នោះដែរ ។

៥-ជំបូន្មានដោយប្រប្រម ។

ខ្ញុំទើបនឹងអធិប្បាយរឿងធំៗមកអម្បាញ់មិញនេះ ដោយមានបំណងចង់ឲ្យអាណាប្រជាជនរបស់ខ្ញុំយកចិត្តទុកដាក់ប្រតិបត្តិតាម ។ ក្រៅពីរឿងទាំងនោះនៅមានរឿង១ទៀតដែលខ្ញុំមិនចង់បំភ្លេចចោលឡើយ គឺបរិយាល្អសព្វថ្ងៃនេះឯង ដែលនាំឲ្យជនានុជនអាចប្រស្រ័យគ្នាបានដោយងាយ ហើយជួយឲ្យមានសាមគ្គីធម៌ដល់គ្នានឹងគ្នា ជាប្រយោជន៍ឲ្យបានសុខក្សេមក្សាន្តកល់រូប ។

គាថាបាលីមានស័ព្ទបែកច្រើន សំរាប់សំគាល់បរិយាផ្សេងៗហើយពួកខេមរបុត្រទាំងឡាយក៏បានរៀនចេះដឹងតាមស័ព្ទតាំងពីនៅជាកុមារតូចៗនៅឡើយ បរិយា ៤ យ៉ាង គឺ:

មេត្តា សេចក្តីរាប់អានស្រឡាញ់គ្នា ករុណា សេចក្តីអាណិតអាសូរគ្នា មុទិតា សេចក្តីរីករាយចំពោះសេចក្តីសុខ-ចំរើនរបស់អ្នកដទៃ ឧបេក្ខា សេចក្តីតាំងចិត្តជាកណ្តាល មិនលំអៀងទៅខាងណា ។

ព្រហ្មចរិយាទាំងនេះជាគតិដែលខេមរជាតិតែងនិយមរាប់អាន ហើយនាំឲ្យជនជាតិដទៃយកមកប្រារព្ធដំណាលសរសើរជាការគោរពល្អនឹងស្លូតត្រង់ស្មុខ ។

បំណងដ៏ស្មោះរបស់ខ្ញុំ ។ ចង់ឲ្យជនានុជនក្នុងកម្ពុជរដ្ឋនៅតែប្រព្រឹត្ត តាមធម្មចរិយាព្រហ្មវិហារទាំងនេះ ឲ្យបានទៀងទាត់ត្រឹមត្រូវតាមប្រវេណីតទៅ ដូចកាលដូនតាពីដើមរៀងមក ហើយឲ្យវៀរកុំឲ្យមានគំនិតគិតពិរុទ្ធដល់គ្នានឹងគ្នា ។

វិធានទាំងនេះហើយដែលខ្ញុំប៉ុនប៉ងថ្លែងឲ្យបានឮដល់អាណាប្រជានុរាស្ត្ររបស់ខ្ញុំ ។ ដំបូន្មាននេះជាពាក្យថ្លែងប្រដៅចំពោះអាណាប្រជានុរាស្ត្រដែលជាទីគាប់ព្រះរាជហឫទ័យនៃក្រៃពេក សុំឲ្យអស់អាណាប្រជាជនយល់តាមពាក្យទូន្មានទាំងនេះឲ្យជាក់ច្បាស់ ហើយឲ្យយល់ថាមកពីខ្ញុំមានមេត្រីយ៉ាងស្មោះ ទើបបណ្តាលឲ្យខ្ញុំថ្លែងទុកដូច្នេះ ។ តែធម្មតាក្សត្រិយ៍មួយៗមិនមែនគ្រាន់តែត្រូវឲ្យទុកដល់ប្រជាជនប៉ុណ្ណោះទេ គឺត្រូវប្រតិបត្តិព្រះអង្គឯងធ្វើឲ្យអាណាប្រជានុរាស្ត្រនឹងព្រះរាជអាណាចក្របានសម្រេចប្រយោជន៍នោះផង ។ ចំណែកខាងខ្ញុំ ។ ក៏នឹងប្រតិបត្តិឲ្យត្រឹមត្រូវតាមកិច្ចការរបស់ខ្ញុំជាក្សត្រដោយទូរស្មោះត្រង់ តាមព្រះពុទ្ធសាសនាផងគោរពតាមទំនៀមទម្លាប់ដ៏ប្រពៃរបស់ជាតិយើងផង ។

កាលបើខ្ញុំព្រមទាំងប្រជាជនបានប្រព្រឹត្តត្រឹមត្រូវដូច្នេះ ពពួកទេវតាគ្រប់ទិសទី គង់នឹងជួយអភិបាលរក្សារាជសម្បត្តិរបស់ខ្ញុំ ឲ្យមាន

សិរីសួស្តីជ័យមង្គល ព្រមទាំងជួយបីបាច់រក្សាកម្ពុជរដ្ឋឲ្យបានចំរើនរុង-រឿង ជួយទំនុកបំរុងផ្ដុងផ្ដើមប្រជាជនអ្នកមានផ្ទៃរបស់ខ្ញុំឲ្យបានប្រកបដោយសេចក្ដីសុខក្សេមក្សាន្តនិងសេចក្ដីចំរើនឥតអាក់តរៀងទៅ ។

ព្រះរាជឱង្ការឲ្យព្រះបន្ទូលសួរសីហនាទ ធ្វើក្នុងព្រះបរមរាជវាំងក្រុងភ្នំពេញចតុមុខ នៅថ្ងៃសៅរ៍ ១២ កេតខែកត្តិកឆ្នាំម្សាញ់ត្រីស័ក ព្រះពុទ្ធសករាជ ២៤៨៤ ត្រូវនឹងថ្ងៃ ១ ខែណូវែម្ប្រឹឆ្នាំ ១៩៤១ ។

នរោត្តម-សីហនុ វរ្ម័ន

ចប់ព្រះរាជពិធីរាជាភិសេកតែប៉ុណ្ណេះ ។

# ប្រវត្តិទង់ប្រចាំជាតិខ្មែរ

ឧកញ៉ា ទេពពិទូរ ក្រសេម

រាល់ៗ ជាតិក្នុងលោកនេះ ដែលមានសេចក្ដីចំរើនរុងរឿងហើយ រមែងមានទង់ប្រចាំជាតិទាំងអស់ ប្លែកតែប្រើពណ៌ផ្សេងៗផ្លាស់គ្នាប៉ុណ្ណោះ ដោយជាគ្រឿងសំគាល់ជាតិ សាសនា មហាក្សត្រិយ៍ និងអធិបតេយ្យ (ភាពជាធំ) ជាដើមរបស់គេ, ក្នុងពណ៌នីមួយៗដែលយកមកប្រកបជាអង្គទង់ឡើង សុទ្ធតែមានប្រវត្តិរបស់គេ អធិប្បាយហេតុផលទុកឲ្យយល់ផង មិនមែនចេះតែចាប់ដាក់ៗទៅតាមទំនើងចិត្តនោះទេ តែនឹងកំណត់ឲ្យជាការទៀងទាត់ថា ពណ៌បែបនេះ ជាគ្រឿងសំគាល់យ៉ាងនោះ ឲ្យត្រូវត្រង់គ្នាទាំងអស់ពុំបាន ព្រោះស្រេចហើយតែសេចក្ដីត្រូវការ គោលគឺប្រព្រឹត្តទៅតាមសេចក្ដីនិយមរបស់អ្នកដើមការបញ្ញត្តឡើង ឬដោយអាស្រ័យមានហេតុភេទឯណានីមួយជាសំខាន់ដ៏ទាក់ទាមដោយពណ៌នោះកើតឡើងក្នុងស្រុកទេសរបស់នោះ គេក៏សន្មតយកពណ៌នោះទុកជាពណ៌ទង់ជាតិរបស់គេមួយយ៉ាង តែតោងរៀងផ្លាស់គ្នាដោយពណ៌ផ្សេងៗខ្លះទៀត យ៉ាងតិចត្រឹម ៣ ពណ៌ ៗ តាមសេចក្ដីនិយមដោយច្រើន ពណ៌សជាគ្រឿងសំគាល់សាសនា, ពណ៌ក្រហមជាគ្រឿងសំគាល់ជាតិមហាក្សត្រ, ពណ៌ខៀវផ្ទៃមេឃ ជាគ្រឿងសំគាល់អធិបតេយ្យ ។

តែសម្រាប់ប្រទេសឥណ្ឌាក្នុងសម័យបុរាណ ការកំណត់ប្រើពណ៌ទង់ ឬពណ៌គ្រឿងសំលៀកបំពាក់របស់គេ ឃើញដូចជាមានរបៀបបែបផែនទៀងទាត់ណាស់ ព្រោះគេមានគ្រូ ឬមានគម្រាតែមួយបែប គួរយ៉ាងដូចវណ្ណៈ (ប្រភេទមនុស្ស) ៤ ចំពួកក្នុងប្រទេសឥណ្ឌា គេបញ្ញត្តពណ៌សម្រាប់វណ្ណៈនោះៗ ជាការទៀងទាត់ហូតមក គឺក្សត្រជាតិអ្នកបម្រាំងពណ៌ក្រហម, ព្រាហ្មណ៍អ្នកកាន់សាសនាពណ៌ស, វេសៈ ពួកអ្នកធ្វើការកេសុំជាធម្មតាពណ៌លឿង, សូទ្រៈពួកកម្មករពណ៌ខ្មៅ ។

ចំណែកខ្មែរយើង ក៏ជាមនុស្សជាតិដែលមានអារ្យធម៌សឹងទាក់ទាមដោយអារ្យធម៌ឥណ្ឌាយ៉ាងច្រើន ហេតុនោះការដែលប្រើពណ៌ទង់ ឬពណ៌គ្រឿងសំលៀកបំពាក់ទាំងពួងច្រើននិយមទៅតាមបែបឥណ្ឌា គួរយ៉ាងដូចពណ៌ទង់ជាតិនិងពណ៌សម្រាប់ព្រះមហាក្សត្រជាដើម ។

ឯទង់ជាតិខ្មែរតាំងពីដើមតាមផ្លូវសន្និដ្ឋានឃើញថាជាពណ៌ត្រៃរង្គ (៣ ពណ៌ ) គឺ

១ ពណ៌ស ជាផ្ទៃ កង ៤ ជ្រុងទ្រវែង

២ ពណ៌ក្រហម អមជុំវិញពណ៌ស ទីង-

៣ ពណ៌ផ្ទៃមេឃ អមជុំវិញពណ៌ក្រហម បែបជាជាយ ។

អធិប្បាយៈ តាមវណ្ណបថក្នុងសាសនាព្រាហ្មណ៍ ដែលជាសាសនាចាស់ជាងគេក្នុងលោក ហើយដែលខ្មែរយើងធ្លាប់កាន់មកក្នុងសម័យព្រេង

នាយនោះ និយមពណ៌ស ដែលជាពណ៌បរិសុទ្ធ ថាជាពណ៌សម្រាប់សាសនា ចូរមើលពួកព្រាហ្មណ៍អ្នកកាន់សាសនា វែងស្លៀកពាក់សជាគ្រឿងសំគាល់ ។ ចំណែកខាងព្រះពុទ្ធសាសនា ឃើញដូចជានិយមពណ៌សតាមទំនងនេះខ្លះដែរ ចូរមើលពួកឧបាសកឧបាសិកាអ្នកដែលកាន់ម៉ឹងម៉ាត់ ក៏និយមស្លៀកសពាក់សដោយច្រើន វៀរលែងតែពួកបព្វជិតគេនឹងប្រើពណ៌លឿង ដោយអំណាចពុទ្ធប្បញ្ញត្តិៈណ្ហដោយឡែកផ្សេង ។ ដោយហេតុនេះខ្មែរយើងកាលនឹងផ្ដើមធ្វើទង់សម្រាប់ជាតិឡើង ក៏បានខៃលកបញ្ញត្តយកតាមទំនងនេះ គឺទង់បែបដើមមុនសម័យនគរធំដាក់ពណ៌សជាឋាន ជាគ្រឿងប្រកាសថាជាអ្នកកាន់សាសនា ដែលប្រៀបដោយដួងចិត្តដ៏បរិសុទ្ធ សឹងតាំងនៅកណ្ដាលរូបកាយ តែលុះមកដល់សម័យក្រុងយសោធរបុរៈ (នគរធំ) ក្នុងរវាងពុទ្ធសករាជ ១.៤០០ ដល់ ១.៧០០ ដែលកើតប្រាសាទថ្មធំៗសឹងល្អអស្ចារ្យក្នុងលោកនេះឡើង ក៏កែប្រែទង់ជាតិដើម្បីទទួលកិត្តិយសថ្មីនោះ ដោយដកពណ៌សចេញ ទុកតែពណ៌ក្រហមនិងពណ៌ខៀវផ្ទៃមេឃ ហើយរៀបដាក់ពណ៌ក្រហមជាផ្ទៃពណ៌ខៀវផ្ទៃមេឃជាជាយជុំវិញ ហើយដាក់រូបប្រាសាទ (កំពូល ៣) ពណ៌សជាជំនួសត្រង់កណ្ដាល គឺដាក់សង្កត់លើផ្ទៃក្រហមនោះ កាលមើលទៅក៏ឃើញហាក់ដូចជាពណ៌ត្រៃរង្គដូចដើម ។

ឯពណ៌ក្រហមជាគ្រឿងសំគាល់ព្រះមហាក្សត្រដែលជាអ្នកសុះជាតិ ទឹងជាអ្នកចម្បាំង សឹងមានអាការប្រៀបដូចសុរិយារង្សី ឬប្រៀបដូចលោហិតរបស់ប៉ុរសអ្នកក្លាហាន ។ តាមគតិស្តេចសៀមក្នុងចក្រីវង្សនេះ មានព្រះពុទ្ធយ៉តហ្វា ជាដើម បានកំណត់យកពណ៌លឿងជាពណ៌ប្រចាំព្រះបរមកដវង្ស(១) (ខ្មែរយើងមានកាន់យកតាមបែបនេះខ្លះដែរ) ។

ចំណែកឯពណ៌ផ្ទៃមេឃ ជាគ្រឿងសំគាល់អធិបតេយ្យដែលធំខ្ពស់គ្របលើពិភពផែនដី ។ តែមកដល់សម័យមួយក្នុងរជ្ជកាលព្រះបាទសិទ្ធតអមរិន្ទ្រ បានកែប្រែទង់ជាតិម្តងដោយផ្លាស់រូបប្រាសាទចេញ ដាក់រូបសេះសជំនួស ព្រោះក្នុងរជ្ជកាលនោះ ទ្រង់និយមសេះសណាស់ លុះផុតរជ្ជកាលនោះហើយ រជ្ជកាលក្រោយមក បានត្រឡប់ផ្លាស់រូបសេះសចេញ ដាក់រូបប្រាសាទដូចដើមវិញ នៅរហូតមកដល់សព្វថ្ងៃនេះ ។ ពណ៌ទង់ខ្មែរនេះរាប់ថាត្រូវតាមលក្ខណៈពណ៌ដែលលោកនិយមល្អណាស់ ។

## ឆដ័មហាភដ

### ជាទង់សម្រាប់អង្គព្រះមហាក្សត្រម្ចាស់ផែនដី

ទង់សម្រាប់មហាក្សត្រម្ចាស់ផែនដី ហៅថា "ទង់មហាកដ"

---

(១) ចូរមើលសៀវភៅសិល្បាករភាគ ១ ផ្ទាំទី ២ ព.ស. ២៤៨១ ក្នុងរឿង "គ្រឿងសំគាល់អាយ៍ណាឃោស" ។

ទង់នេះមានលក្ខណៈខុសគ្នានឹងទង់ជាតិដែលពោលហើយ គឺផ្ទៃជាពណ៌ផ្ទៃមេឃ ជាយជុំវិញជាពណ៌ក្រហម ស្ទឹងដូចគ្នានឹងពណ៌ទង់ជាតិ, ត្រង់វេនកណ្ដាលផ្ទៃប៉ាក់ពណ៌មាស ជារូបព្រះខ័នដំកល់លើជើងពាន រូបព្រះមហាមកុដដាក់ពីលើព្រះខ័ន ហើយមានរូបឆត្រ ១ គូ អមសងខាង ។ បើនឹងរួមរាប់ពណ៌ទាំងអស់ទៅ ឃើញថាមានពណ៌ ៣ ដែរ គឺពណ៌មាស ពណ៌ផ្ទៃមេឃ ពណ៌ក្រហម ទុកជាត្រដ្ឋដូចដើម គ្រាន់តែផ្លាស់ពណ៌ខុសគ្នាប៉ុណ្ណោះ ។

ទង់មហារាជនេះ ប្រើបានចំពោះតែព្រះមហាក្សត្រម្ចាស់ផែនដី, តាមប្រក្រតី ត្រូវបង្ហូតនៅជង់ទង់ធំនៅមុខព្រះបរមរាជវាំង នឹងប្រាសាទដែលស្ដេចគង់ជាធម្មតានៅក្នុងព្រះបរមរាជវាំង, បើមានការត្រូវស្ដេចទៅគង់នៅដំណាក់-វាំងឯណាមួយក្រៅពីព្រះបរមរាជវាំង តាំងពី ២៤ ម៉ោងទៅ ត្រូវបង្ហូតទង់មហារាជនៅដំណាក់ឬវាំងនោះដែរ ជាគ្រឿងសំគាល់ថាស្ដេចគង់នៅទីនោះៗ ។ ឬមួយកាលស្ដេចគង់ព្រះរាជរថទៅកាន់ទីជិតឬឆ្ងាយក៏ដោយ ត្រូវប្រដាប់ទង់មហារាជខ្នាតតូចនៅព្រះរាជរថនោះ ជាគ្រឿងសំគាល់ថា ស្ដេចគង់នៅក្នុងព្រះរាជរថនោះ ឬថា អ្នកដែលអង្គុយនៅក្នុងព្រះរាជរថនោះគឺព្រះរាជាម្ចាស់ផែនដី អ្នកនៅជិតខាងត្រូវសំដែងសេចក្ដីគោរពតាមសមគួរ ។

# ទង់ជ័យ

## ជាទង់សម្រាប់ទាហានសឹក

ទង់សម្រាប់ស្តេចសឹក មេទ័ព មេកង ប្រើក្នុងកងការសង្គ្រាម ហៅថា "ទង់ជ័យ" មានលក្ខណៈផ្សេងពីទង់ពីរបែបខាងលើនេះខ្លះ ដូចអធិប្បាយតទៅនេះ:

តាមបែបបុរាណ បើជាទង់ជ័យសម្រាប់ព្រះមហាក្សត្រម្ចាស់ផែនដី សឹងទ្រង់ដំណែងជាស្តេចសឹក (ចមពល) ដោយព្រះអង្គឯង នោះរូបទង់ក៏ដូចជាទង់មហាកដែលពោលហើយ ប៉ុន្តែនៅចុងដងទង់ធ្លាក់ជារូបព្រះនារាយណ៍ទ្រង់គ្រុឌ, (គឺព្រះនារាយណ៍គង់លើគ្រុឌ) ពុំនោះសោត នៅត្រង់កណ្តាលផ្ទៃទង់ ប៉ាក់ដោយសូត្រពណ៌មាសជារូបព្រះនារាយណ៍ទ្រង់គ្រុឌ ជាជំនួសរូបព្រះខ័ន ព្រះមហាមកុដ, តាមគែមជាយជុំវិញប្រដាប់ដោយព្រយរំយោលដែលធ្វើអំពីសូត្រពណ៌ដ៏វិចិត្រ ។

ម្យ៉ាងទៀត (ក្រៅអំពីព្រះរាជា) ដូចយ៉ាងសម្តេចព្រះមហាឧបរាជជាដើម បើទទួលដំណែងជាស្តេចសឹកធំ កាន់កាប់ទ័ពហ្លួង (ទ័ពធំ) ជំនួសព្រះរាជាម្ចាស់ផែនដី នោះទើបប្រើទង់បែបនេះបាន, ក្រៅអំពីស្តេចសឹក ចមទ័ពប្រើមិនបានទេ ។

ចំណែកទង់ជ័យសម្រាប់មេទ័ព មេកង រឺស្តេចសឹកចុះមក មានលក្ខណៈប្រហែលនឹងទង់ជាតិនោះឯង ប៉ុន្តែនៅចុងដងទង់ធ្លាក់ជារូប

ហង្សមាសហោះ ពុំនោះសោតនៅកណ្ដាលផ្ទៃទង់ ប៉ាក់ដោយសូត្រពណ៌ស ជារូបហង្សមាសហោះ (គ្មានរូបប្រាសាទ) នៅរឹមជាយជុំវិញប្រដាប់ដោយព្រយរំយោលយ៉ាងវិចិត្រ ។

តែបើសង្កេតមើលទង់ជ័យក្នុងគង់ទ័ពរបស់ព្រះបាទសូរ្យវរ្ម័ន មហា-កដទី ២ ដែលឆ្លាក់ទុកនៅព្រះរបៀងប្រាសាទអង្គរវត្ត ឃើញថាទង់ជ័យគ្រានោះគ្មានក្បួនទង់មានតែដង ហើយទឹងរូបព្រះនារាយណ៍ទ្រង់គ្រុឌ រូបហង្សមាសហោះនៅចុងដងទង់ប៉ុណ្ណោះ ក្នុងសៀវភៅទិកសង្គរវត្តរបស់សម្ដេចព្រះយ៉ាជាំរង្សក់ជានុគាត ហៅទង់នេះថា កប៉ធ្វជ, គ្រុឌពាហ៍ គឺទង់រូបហង្សមាន ហៅថា កប៉ធ្វជ, ទង់រូបព្រះនារាយណ៍ទ្រង់គ្រុឌ ហៅថា គ្រុឌពាហ៍ សម្រាប់ប្រើនាំទ័ពក្នុងកិច្ចការសង្គ្រាម គឺជាទង់ជ័យនាំទ័ពនោះឯង ។

## ការគោរពទង់ជាតិ

ជាតិដែលមានអារ្យធម៌ មានសីលធម៌ សូម្បីជាជាតិតូច មិនសូវមានឥទ្ធិពល ក៏តែងមានទង់ជាតិជាគ្រឿងសំគាល់ជាតិរបស់ខ្លួន កាលបើដូច្នេះ ទង់ជាតិក៏ទៅជារបស់ស័ក្ដិសិទ្ធិមួយយ៉ាង ក្នុងបទដ្ឋានយោមថា ប្រជាជនអ្នកនៅក្រោមម្លប់ទង់ជាតិនោះ ត្រូវសំដែងសេចក្ដីគោរពតាម

សមគួរដល់ឋានៈរបស់ខ្លួន គឺជាទាហានត្រូវគោរពតាមបែបទាហាន គ្រស្ថសាមញ្ញត្រូវគោរពតាមបែបគ្រស្ថសាមញ្ញ, មិនត្រូវបោះបង់ពេលផ្តេសផ្តាស មិនត្រូវដើរគន្ធង ដើរដាច់ញីញក់ មិនត្រូវយកទៅផ្ទុកឬខ្ចប់អ្វីៗ ល។ កាលចាស់មិនត្រូវការប្រើហើយ ត្រូវទំលាយចោល ដោយដុតភ្លើងចោលជាដើម មិនត្រូវចោលកក់កយក្នុងទីទីមួយឡើយ ។ អាការដែលរាលមកនេះឈ្មោះថាគោរពទង់ជាតិ, អ្នកដែលមិនគោរពទង់ជាតិ ទុកជាមនុស្សមិនស្រឡាញ់ជាតិ, អាការដែលធ្វើឲ្យឃើញជាក់ស្តែងនៅទីមុខប្រជុំជន ត្រូវមានទោសក្នុងស្ថានណាមួយ ។

ប្រវត្តិទង់ប្រចាំជាតិខ្មែរចប់តែប៉ុណ្ណេះ ។

# អំពីអក្សរសាស្ត្រខ្មែរ

លោកសឺដែសរៀបរៀង (តមកនិងចប់)

តាមដោយពិត ហេតុដែលនាំឲ្យប្រែប្រួលចំពោះអក្សរសាស្ត្រខ្មែរ មានដូចគ្នានឹងហេតុដែលនាំឲ្យប្រែប្រួលនៃអារ្យធម៌ខ្មែរនោះដែរ អារ្យធម៌ខ្មែរដែលមានឥទ្ធិពលក្នុងសតវត្សរ៍ទី ១៣ នឹង ១៤ (ព.ស. ១៧៥០ ដល់ ១៩៥០) ទៅគ្របលើជាតិថៃនៅប្រទេសសៀមនឹងប្រទេសលាវយ៉ាងមាំមួន ៗ ក្នុងខណៈនោះ អក្សរសាស្ត្រខ្មែរឈប់ចំរើននៅប្រទេសខ្មែរ អក្សរសាស្ត្រនោះទៅចំរើនខ្លាំងបំផុតនៅប្រទេសសៀមវិញ ។ ក្នុងសម័យថ្មីនេះ គឺក្នុងដើមសតវត្សរ៍ទី ១៩ (ព.ស. ២៣៩៣) អំណាចរបស់សៀមគ្របលើប្រទេសខ្មែរ សៀមក៏សងមកប្រទេសខ្មែរវិញ ដោយកែប្រែផ្លាស់ប្តូរចេញចំពោះការងារដែលប្រទេសសៀមបានទទួលយកទៅកាលពីសតវត្សរ៍ទី ១៣ ដោយហេតុនេះ ទើបលំបាកនឹងពិនិត្យមើលក្នុងអក្សរសាស្ត្រខ្មែរ ថែកចេញឲ្យឃើញថានេះជាប្រពៃណីរបស់ខ្មែរតៗមកដោយត្រង់ៗ នេះជាទំនៀមប្រពៃណីដែលប្រែប្រួលហើយត្រឡប់មកអំពីប្រទេសសៀមមកវិញ នេះជាបែបផែនដែលមកអំពីឥទ្ធិពលរបស់ការប្រទេសដ៏ទៃ ៗ ការរុករកយ៉ាងនេះ ពិបាកនឹងរកឲ្យបានច្បាស់ល្អ ហើយថែមទាំងពេលដោយពិត ឃើញថាមិនជាមានប្រយោជន៍ដ៏ធំដុំទេ ទាំងសាច់រឿងសោតទៀតក៏មិនជាការសំខាន់ប៉ុន្មាន ៗ ការកសាងអក្សរសាស្ត្រខ្មែរ

ក្នុងសម័យថ្មីនេះ ប្រសិនបើលើកយកចម្រៀងអ្នកស្រុកនិងរឿងព្រេង ដែលនិយាយមាត់ទទេនោះចេញ ឃើញថាអក្សរសាស្ត្ររបស់ស្រុក សម័យថ្មីនេះ មិនមានរសជាតិដើមនិងដំឡៃថ្លៃថ្លាជាធំដុំឡើយ ។

ចុះហេតុអ្វីបានជាអក្សរសាស្ត្រខ្មែរមិនបានចំរើនដោយខ្លួនមានរសជាតិដើម ដែលអាចនឹងឆ្លុះឲ្យឃើញបានខ្លះ រស្មីរបស់ជនជាតិមួយដែលធ្លាប់មានថ្វីដៃជាងគេ ត្រង់ជនជាតិសៀមដែលមានវប្បធម៌សឹងដូចគ្នានឹងជនជាតិជិតខាងនៅទិសខាងកើតនោះ ហើយបានធ្វើការកសាងអក្សរ-សាស្ត្រដូចគ្នានោះដែរ ម្តេចក៏គេបង្កបង្កើតបានក្បួនខ្នាតរឿងរ៉ាវខ្លះមានដំឡៃដ៏ពិតៗនោះបាន? ពិនិត្យរកហេតុផលនេះទៅ ឃើញថាប្រហែលជាមកអំពីប្រទេសខ្មែរបេះតែមានគ្រោះថ្នាក់ឥតស្រាកស្រាន្តតាំងអំពីសតវត្សរ៍ទី ១៥ មក ។ ហើយៈក្រោយដែលអង្គរអន្តរាយធ្លាក់ចុះទៅនោះ ពង្សាវតាររបស់ប្រទេសខ្មែរស្ទើរមានតែការរ៉ាប់រៀបអំពី រឿងចម្បាំងកំង ដល់បរាជ័យនោះឯង ។ ព្រោះជាមានការដទៃៗទៀតដែលត្រូវធ្វើ មិនអាចនឹងគិតគូរបណ្តុះបណ្តាលអក្សរសាស្ត្រនិងរចនារបស់ជាតិឲ្យចំរើនបាន ប្រជារាស្ត្រដែលមានសេចក្តីសប្បាយក្នុងការចិញ្ចឹមជីវិត ។ មួយវិញទៀត យើងត្រូវលើកយកហេតុដែលព្រះពុទ្ធសាសនាមកផ្សាយឥទ្ធិពលលើអារ្យធម៌ជាន់ចាស់របស់ខ្មែរ ខុសឆ្ងាយអំពីការផ្សាយនិងនាំអារ្យធម៌ចូលទៅក្នុងប្រទេសថៃ កាលពីសតវត្សរ៍ទី ១៣-១៤ ដែលថៃបានវប្បធម៌

នៅជារបៀបមនុស្សជាន់ដើមច្រើនជាងខ្មែរនៅឡើយ  កិច្ចការទាំងនោះ ហើយដែលគួរនាំយកមកពោលជាហេតុដែលធ្វើឲ្យអក្សរសាស្ត្រខ្មែរមិនមានសេចក្ដីចំរើនតៗមកដល់សម័យក្រោយនេះ  ក្នុងខណៈដែលជនជាតិសៀមបានបង្កើតជាវត្ថុ ១ ជាដំបូង  គឺសិលាចារឹកយ៉ាងល្អចំណានរបស់ព្រះបាទរាមកំហែង  ដែលជាសម្រែកសំដែងជ័យជំនះនិងឫទ្ធានុភាពនាំឲ្យឃើញថា  អាណាចក្រខ្មែរបុកណាចាប់ផ្ដើមទ្រុឌទ្រោមចុះតាំងតែអំពីនោះមក  (ចុងសតវត្សរ៍ទី ១៣) ។

មុននឹងពិនិត្យមើលប្រភេទអក្សរសាស្ត្រផ្សេងៗ ក្នុងចំណោមអក្សរសាស្ត្រខ្មែរទំនើបថ្មីនោះ  យើងត្រូវតែបញ្ជាក់ជាមុនថា  ក្បួនខ្នាតនិងសាស្ត្ររឿងផ្សេងៗរបស់ខ្មែរ  ច្រើនតែគ្មានឈ្មោះអ្នកតែងនិងគ្មានថ្ងៃខែឆ្នាំជាប្រាកដ ។ កាលពីសតវត្សរ៍ទី ១៩ គេបានដឹងថា  អ្នកតែងរឿងអស់នោះគឺព្រះបាទព្រះអង្គដួង (ព. ស. ២៣៨៦-២៤០២) ពួកបណ្ឌិតខ្លះនៅក្នុងព្រះរាជសំណាក់  ពួកលោកសង្ឃខ្លះក្នុងចំណោមលោកសង្ឃនេះ មានសម្ដេចព្រះមហាសង្ឃរាជដែលសុគតក្នុង ព. ស. ២៤៥៧ ។

ពាក្យកាព្យឃ្លោង — ភាសាដែលបណ្ឌិតរចនាក្រងឡើងជាពាក្យកាព្យសឹងមានទំនងខុសគ្នាឆ្ងាយពីរបៀបនិយាយឬរបៀបសរសេរធម្មតា ភាសា

ចិត្តកវីនោះ សំរេចដោយភាសាសំដីបុរាណនិងពាក្យពេចន៍ដែលខ្ចីយកមកពីភាសាសំស្ក្រឹតនិងភាសាបាឡី ៗ ចំពោះពួកបណ្ឌិត គេទុកការចេះដឹង ការរុករកឬរៀនសូត្ររបស់អ្នកតែងរឿង ជាការគាប់ប្រសើរនៃការតែងកាព្យឃ្លោង ច្រើនជាងការសម្រើបចិត្តឬក៏បាយនាំឲ្យសម្រើបចិត្ត ។ ដោយហេតុនោះហើយបានជាពួកកាព្យឃ្លោងដែលមានរបៀបបែបផែនជាក្បួនខ្នាតសម្រាប់ក្មេងរៀនមើលនៅតាមវត្តនោះ ក្មេងមើលដាច់អស់ ប៉ុន្តែមិនអាចយល់សេចក្ដីថាដូចម្ដេចឡើយ ហើយមនុស្សចាស់ក៏មិនងាយនឹងពន្យល់ឲ្យច្បាស់លាស់បានដែរ ។

ក៏វិធីតែងកាព្យឃ្លោងខ្មែរនេះ អាស្រ័យនៅលើចំនួនព្យាង្គនិងសម្ពស្សឃ្លោង តែសម្ពស្សឃ្លោងមិនចេះតែចាប់ចុងចួននៅចុងឃ្លាជានិច្ចទេ គឺចុងឃ្លាអាចមានចុងចួននឹងព្យាង្គណាមួយនៅក្នុងឃ្លាពាក្យមួយដទៃទៀតក៏បាន ស្រេចតែច្បាប់សម្រាប់វិធីតែងកាព្យនីមួយៗ ។ ការប្រើព្យាង្គដដែលៗក៏ជាវិធីមួយក្នុងការតែងកាព្យឃ្លោងនោះដែរ កាលបើតែងជារឿងល្ខោនឬកាព្យនីមួយ ៗ ច្រើនតែប្រកបដោយការតម្រូវទៅតាមចិត្តគំនិតនឹងទៅតាមដំណើររឿង ។ ក្រៅអំពីឃ្លាល្បះដែលគេធ្លាប់ប្រើជាធម្មតាដែលមានចំនួនប្រហែលជា ១៦ បែបនោះ នៅមានឃ្លាល្បះបែបគេរចនាឡើងដោយខ្លួនឯង ដែលជាការសមហាក់ឃ្លាល្បះលេងពិតៗ ឥតមានសំដែងឲ្យ

ឃើញគំនិតឬទឹកចិត្តរបស់អ្នកតែងនោះទេ ។ ពាក្យកាព្យដែលមានរបៀបបែបផែន ហើយគេទុកជាក្បួនខ្នាតដ៏ពិតប្រាកដនោះ សឹងសុទ្ធតែជាក្បួនរួមប្រមូលកាព្យឃ្លោងសំដែងអំពីឱវាទដម្បូន្មានដែលច្រើនតែជារបស់បុរាណ ។ មានជាតិខ្មែរតិចទេដែលមិនចេះចាំមាត់នូវច្បាប់ក្រមជាតម្រាស៊ីវិល ច្បាប់ប្រុសជាតម្រាសម្រាប់កូនប្រុស ច្បាប់ស្រីជាឱវាទដំបូន្មានសម្រាប់កូនស្រី (ដែលគេនិយមថាជាស្នាព្រះហស្តព្រះអង្គដួង) សាស្ត្រាកេរ្តិ៍កាល កូនចៅ និងពពួកច្បាប់សាស្ត្រដទៃ ៗទៀត ដែលមានលក្ខណៈដូចគ្នានេះ ខ្មែរដែលធ្លាប់រៀនទន្ទេញចេះចាំច្បាប់ទាំងនោះ ដែលមានលាយឡំនូវព្រះពុទ្ធបញ្ញត្តិព្រមទាំងរបៀបទំនៀមទំលាប់របស់ខ្មែរក៏ចេះរើសយកច្បាប់ទាំងនោះមកប្រើជាច្បាប់សម្រាប់ខ្លួនតម្រូវតាមឱកាសផ្សេង ៗ ក្នុងកិច្ចចិញ្ចឹមជីវិត ។

ពពួកអក្សរសាស្ត្រដែលជាពាក្យកាព្យ ច្រើនតែជាសាស្ត្រល្បែងដែលដកស្រង់យកពីរឿងរាមកេរ្តិ៍ ឬរឿងក្នុងគម្ពីរបញ្ញាសជាតក ដែលតមកជាន់ក្រោយ លោកសង្ឃរាជបានបញ្ចូលរឿងព្រេងផ្សេង ៗរបស់ប្រទេសឥណ្ឌូស៊ុនទៅក្នុងនោះថែមទៀត ។ ក្នុងសាស្ត្រល្បែងទាំងនោះ អ្នកតែងតួនីមួយ ៗ សឹងនិយមធ្វើតាមដំណើររឿងឥណ្ឌៀ ដែលតែងជាកាព្យឃ្លោង ។

# ច្បាប់វិធុរបណ្ឌិត

## បទព្រហ្មគីត

១ ព្រះពាន់ហើយឥតស្រាម នាផ្ទះក្រោមឥតមន្ត្រី ក្សត្រិយ៍ពុំបេះ
គន្លើរ ប្រើឥតតម្លៃក្រឡា ។ កើតមកជាបុត្រក្សត្រិយ៍ ពុំប្រយ័ត្នរៀន
សាស្ត្រា ពុំរៀនពិចារណា ពុំដឹងក្រែងទុក្ខស្ត្រ ។ ពុំដំកើងពាក្យ
ពិត បញ្ចូរផលវិនាស យកតលោយកបញ្ហាស កុំយកមាសលាយ
ទឹកប្រាក់ ។ ប្រើត្រាប់ឯត្រាជូ កុំបង់ផ្លូវដោយតម្រាស់ កុំជិះរទេះ
ចាស់ ធាចសាចខ្សាច់កំបុកត្បូង ។ ជាក្សត្រិយ៍ពុំរៀនធម៌ ពុំដោះសា
ជម្ងឺទ្រូង ពស្ត្រតាសទឹងចំគោង អាក់ចិត្តខឹងសត្វបោមពេម ។ ទឹង
កើតក្តៅក្រហាយ ទុក្ខអន្តរាយគងផ្ទៃក្រោម ពស្ត្រផងទឹងទឹងបោម
ជ្រោមខ្លាត់ខ្លាយទីទៃណា ។ រិមិត្រសង្សារស្នេហ៍ កុំបីប្រែពាក្យ
ថា ស្រឡាញ់ខ្លួនសត្យា កុំបីស្អប់ឲ្យសាមាន្យ ។ អ្នកកាចសារពើក្តី សឹង
អប្រិយផ្តួលប្រាណ កើតទោសអាត្មាមាន គំនូរខុសជាអសារ ។ ទោះ
ធ្វើព្រះគន្ធា សាត់អាត្មាកណ្តាលហ៊ល ពារសឹកដេញប្រហារ តែបេញ
ទៅប្រះខ្មា ។ ប្រទះតាំងពាក់ឈើង សឹងជាប់ឡើងទាំអាត្មា ចំរុងប្រែង
បទ្មា ជាប់ដោយដើងជាន់ជិតដី ។ ខ្មោចកេក្រគ្រឹស្តាន តោសរ៉ង់មាន
ក្នុងលំនោ បិតខ្វែប្រែក្តាត់ក្តៅ សឹងហ្មងសៅធ្វើទោសណា ។ តាំងនាយ

កុំរក្សា បៀនបិណ្ឌាពុំឲ្យច្រើន អស់ញាតិពុំបន្ទុន សីលតែបៀសចេញ
ទៅឆ្ងាយ ៗ ពឹងថ្កោលៗសោកបាក់ ខូកពំនាក់ក្នុកព្រាត់ព្រាយ ពឹង
បុណ្យប្រាបកំចាយ សាត់គយ្ហាយដោយខ្យល់នាំ ៗ កុំឲ្យចង្វាចក សូវចុះ
ទឹកក្រពើខាំ អភ័ព្វនៅសាំចាំ ជាទុក្ខសោកនៅស្មុកស្មុក ៗ ខូវកើតឯ
ហោចហិន ត្រះមាចក្សោណរឹងកាក្រក់ អំពើដ៏លាមក នូវកើតទោស
ជាសាមាន្យ ៗ ដូចពាក្យនៃមនុស្សផង ស្រដ័ត្ថង់ឥតប្រមាណ ពោល
ពាក្យពារបំពាន ពុំរំពឹងឯក្រោយក្នុក ៗ ពានពុំដែលស្ទ័ត្រ ស្រី
សាធស័ក្ដិពុំដែលស្រែក រឹងមៀមទឹងក្អក ពុំដែលរួមគ្រេងគ្នា ៗ ទោះ
អ្នកជាតិព្រេងព្រឹទ្ធ ចាំរិះរិតបុកណា គួរចង់ចិត្តស្នេហា សរពើគិតកេរ្តិ៍
សព្វស្ថាន ៗ យកខាលជង់សំណ ដោយចិត្តធត់តឲ្យបាន រលាយឯខាល
កាណ សីងពុំបានចង់ខាលសោក ៗ ប្រទះបោះកាំបិត ចង់សុចរិតនៃ
អ្នកធោត ចង់ពីរប្រការសោក ត្រូវជំនៀលលោកទិន្ន ៗ កុំកាន់ពាក្យ
អស័ត្យ ប្រុងប្រយ័ត្នអត្ថកាត្មា ដ៏លោកបរលោកា បរិបូណ៌បានសុខ
សួស្តី ៗ កុំពោលពាក្យមុសា ក់ទក់ចាឲ្យមាទហ្វង់ ចំពួកសត្រូវផង
កែងយកទោសនៃអាត្មា ៗ កុំពោលពាក្យចំពាន តែងទឹងមានជំនៀលថា
ទុយ៌សពិតពុំជា ទូវត្វាសមុខឯងសព្វថ្ងៃ ៗ យកទ្វោចគេមកយំ មើល
ផ្សំថ្នាំពព្រាជហិនវៃ ពុំនីរពុំប្រពៃ ពុំបានជាប្រយោជន៍អង្គ ៗ ដេគុណ

កើតជាទោស យកឈើងព្រោសក្នុងអន្ទង់ យកប៉ុយទៅគ្របកើង គុណប្រខ្សែអម្បោះផ្កាយ ។ អណ្តើកអម្ចាស់មាន ហ៊ានក្បួនពានយកស្មោះងាយ ក្របផ្ទូរពុំផ្ទូរក្លាយ ពុំប្រយ័ត្នគេយកបាន ។ ហេតុចិត្តកើតខ្ជៃអំពីក្រែពន់ប្រមាណ អ្នកច្រស់យសពីប្រាណ ចិត្តពុំក្សាន្តពុំសោយ ។ អ្នកខ្ជិលចង់តែស៊ី អ្នកអប្រិយមើលងាយគេ គេក្សាច្រើនផាផាយ ទ្រព្យភ្លាត់ភ្លាយរង្គោះឡើង ។ ដំរីសោរចូលទៅ ក្នុងអំពៅនោះរលីង ទាំងគុម្ពល្អិតដោយដើង នៃដំរីសោរចូលហោង ។ អំពៅអំពល់អស់ រលីងឫសទាំងគុម្ពផង ទាំងស្រែចំការស្រែង ហានលំនៅឥតអស្រ័យ ។ អ្នកខ្លាចអ្នកអាងហ៊ាន ស្រដីកនព្ធតដើងដៃ កំឡាំងមានស្មើខែ ទើងបើអ្នកអាងសាធារណ៍ ។ អ្នកជាពាហាន ស្ងៀមនៅហានពុំចរចា សន្សើមកេស៊ីស្វា លុះសឹកដល់បន្ទឹមាត់ ។ ដូចស្បែកខ្លាទន្សែ សឹងសាយគ្មានគង់ពុំបាត់ កាលស្លាប់គេលះលាត់ លាយយល់ស្លាកដូចដែលហោង ។ ដូចពុតកាលពុំជា ក្តីឆ្នាទោសទណ្ឌផង ថង់តបងាល់ក់យចង់ ពុំបេះពាលពុតបាត់បង់ ។

(នៅមានត)

## ប្រវត្តិពួកឧបាសក-ឧបាសិកា

### ជាសាវកសាវិការបស់ព្រះពុទ្ធជាម្ចាស់

២– សុទត្ត-គហបតី- នេះជាឈ្មោះដើមរបស់អនាថបិណ្ឌិកសេដ្ឋី ទុះឯង លោកជាបុត្ររបស់សុមនសេដ្ឋីក្នុងនគរសាវត្ថី កាលចំរើនវ័យធំឡើងហើយ ក៏បានគ្រប់គ្រងផ្ទះសំបែងតាមយកកសវិស័យ ជាអ្នកមានចិត្តជាកុសល តែងទំនុកបំរុងសមណព្រាហ្មណ៍ហូតដល់មនុស្សអនាថា ទើបមាននាមបញ្ញត្តិឡើងថ្មីថា អនាថបិណ្ឌិកៈ ប្រែថាអ្នកមានដុំបាយសម្រាប់ទំនុកបំរុងមនុស្សអនាថា ។ មានសេចក្តីដំណាលថា សម័យមួយលោកបានផ្ទុករបស់ដោយរទេះចំនួន ៥០០ ទៅកាន់ផ្ទះរបស់សំឡាញ់ក្នុងក្រុងរាជគ្រឹះ ហើយលោកបានស្គាល់ព្រះបរមសាស្តានៅទីនោះ បានស្តាប់ព្រះធម្មទេសនា បានសម្រេចសោតាបត្តិផល ។ ក្នុងថ្ងៃជាតំរប់ពីរ លោកអនាថបិណ្ឌិកសេដ្ឋីបានថ្វាយមហាទាន ហើយក្រាបទូលនិមន្តសម្តេចព្រះបរមសាស្តាឲ្យស្តេចទៅកាន់ក្រុងសាវត្ថីផង ទើបលោកកសាងព្រះជេតវនមហាវិហារថ្វាយ ដោយការបរិច្ចាគទ្រព្យ៥៤កោដិកហាបណៈ ហើយបានថ្វាយភត្តផ្សេងៗ ជានិច្ច ជាមហាឧបាសកដែលមានសទ្ធាជ្រះថ្លាយ៉ាំងក្រៃលែងក្នុងព្រះពុទ្ធសាសនា ដោយអាស្រ័យហេតុនេះ ទើបព្រះបរមសាស្តាទ្រង់តាំងលោកក្នុងដំណែងដែលប្រសើរលើសលែងជាងឧបាសកទាំងឡាយអ្នកថ្វាយទាន ។

លោកអនាថបិណ្ឌិកសេដ្ឋីនេះ ល្បីថាជាអ្នកបរិច្ចាគទានក្នុងព្រះពុទ្ធ-សាសនា ដរាបដល់អស់ទ្រព្យសម្បត្តិលើងតែតមក ក្រោយទៀតបានតែ

កូនមានទ្រព្យសម្បត្តិស្តុកស្តម្ភឡើងវិញ ។ លោកមានកូនប្រុស ១ ឈ្មោះ ខេមកៈ ជាទីដំបូងជាមនុស្សស្រវឹងនឹងរូបសម្បត្តិ ដល់ទៅបិតាគាត់ជួល ឲ្យទៅស្តាប់ធម៌ទេសនាទើបព្រមទៅតាម ក៏ត្រឡប់ជាអ្នកប្រព្រឹត្តល្អ ។ ឯកូនស្រីលោកមាន ៣ នាក់ ទី ១ ឈ្មោះមហាសុភទ្ទា ទី ២ ឈ្មោះ ចុល្លសុភទ្ទា ទី ៣ ឈ្មោះសុមនា ។ សេដ្ឋីជាបិតាជាអ្នកមានសទ្ធាជ្រះថ្លា ខ្ជាប់ខ្ជួនក្នុងព្រះពុទ្ធសាសនា តែងថ្វាយទាននៅក្នុងផ្ទះរបស់ខ្លួនជានិច្ច តែខ្លួន លោកជាទានបតី អ្នកស្រុកកប់អានថាជាមង្គល បើអ្នកណាទីងធ្វើបុណ្យ ទានអ្វី ច្រើនតែអញ្ជើញលោកមិនសូវដែលខាន ទើបមិនមានឱកាសចាត់ ការអង្គាសព្រះភិក្ខុសង្ឃដោយខ្លួនលោកនៅផ្ទះរបស់ខ្លួន ទើបសេដ្ឋីតាំង នាងមហាសុភទ្ទាឲ្យជាអ្នកចាត់ចែងធ្វើទានជំនួសខ្លួន ។ លុះនាងបាន សម្រេចសោតា ទៅកាន់ត្រកូលស្វាមីហើយ ទើបតាំងនាងចុល្លសុភទ្ទាធ្វើ ការនោះជំនួស លុះនាងបានសម្រេចសោតារួចទៅកាន់ត្រកូលស្វាមីហើយ ទើបសេដ្ឋីតាំងនាងសុមនាជាប្អូនពៅជំនួស តមកនាងបានសម្រេចអនា គាមិផល តែជាស្ត្រីមានរោគច្រើន ទើបអនិច្ចកម្មទៅតាំងពីនៅក្មេង ធ្វើឲ្យ សេដ្ឋីបិតាសៅសោកជាខ្លាំង ទើបទៅក្រាបទូលអំពីបុគ្គលវិយោគដល់ព្រះ សាស្តា ៗទ្រង់សំដែងធម៌រម្ងាប់សេចក្តីសៅសោកបាន ។ ឯខ្លួនលោកកាល មានអាយុសង្ខារសមគួរនឹងកាលវេលាហើយ ក៏អនិច្ចកម្មទៅ ។

ចប់ប្រវត្តិសង្ខេប របស់អនាថបិណ្ឌិកសេដ្ឋីតែប៉ុណ្ណេះ ។

# ពជ័ក្ររ៍តាររ៉ូម

(តមក)

កាលបើបានចាត់របៀបអនុញ្ញាតឲ្យប្រជាជនធ្វើទាហានបានហើយ កងការទាហានក៏ចាត់ជាកិច្ចមួយ ដែលកងការត្រូវចាត់របៀបឲ្យមានឡើង ៗ សភាសេណាក៏ជាអ្នកកំណត់ថាត្រូវចាត់ឲ្យមានទាហានប៉ុន្មានក្រុម កុងស៊ុលជាអ្នកកំណត់ថ្ងៃហៅប្រជុំពួកដំណាងកស្រុក ៗ វិធីរើសមនុស្សមកធ្វើទាហានប្រើវិធីចាប់ស្លាកជាមុន រួចទើបគេជ្រើសរូបទីមួយ ៗ ជាក្រោយ កស្រុកណាដែលមិនបានមកចូលប្រជុំត្រូវធ្វើទោសជាទម្ងន់ដូចជាលក់ពិន័យ, រាយ, ដាក់គុកឬចាប់ខ្លួនធ្វើជាខ្ញុំក៏មាន កាលបើរើសបានគ្រប់ចំនួនតាមសេចក្តីត្រូវការហើយ ទើបឈប់ហៅ ៗ

ទាហានរ៉ូមជាចំនួនច្រើន សុទ្ធតែជាសែស្រឡាយជាតិឡាតាំង តាមធម្មតាជាអ្នកមានរូបរាងមិនធំស្រាងទេ ច្រើនតែមានរាងកាយធាត់ធំខ្ទង់ខ្ទែង ធ្លាប់ធ្វើការងារនៅទីវាលស្រែមកជាច្រើន ទើបមានអំណត់អត់ធ្មត់មិនសូវនឿយហត់ណាយ ៗ ឯសេចក្តីអត់ធន់នេះ ជាគុណសម្បត្តិដ៏សំខាន់មួយដែលទាហានរ៉ូម៉ាំងបានទទួលសេចក្តីសរសើរមកច្រើនបំផុត ដូចជាទាហានថ្មើរជើង អាចចេញដើរតែមួយជើងក្នុងចម្ងាយផ្លូវតាំងអំពី ២៨ ដល់ ៣៦ គីឡូម៉ែត្រ ព្រមទាំងរបស់យកទៅផង មានទម្ងន់ ២០ គីឡូក្រាម ព្រោះក្រៅពីគ្រឿងក្រោះនិងគ្រឿងការពារក្នុងរូបខ្លួនមនុស្ស

ម្នាក់ៗ នៅត្រូវមានពូថៅនិងចបប៉ែល សម្រាប់ប្រើធ្វើនាទីជាទាហានជាងផង ហើយគាត់ផ្ទុកគ្រឿងអាហារភោជនសម្រាប់បរិភោគឲ្យល្មមគ្រប់គ្រាន់ក្នុងវេលា ១៨ ថ្ងៃផង ៗ កាលបើដល់ដំណាក់ផ្លូវនីមួយៗ ក៏ត្រូវតែកសាងបន្ទាយគ្រប់អន្លើ ដោយហេតុនេះទាហានកម្ពុជគ្រប់គ្នាទើបត្រូវតែមានលក្ខណៈ៣ប្រការ គឺជាអ្នកដើរមិនសូវនឿយហត់ ជាអ្នកច្បាំងដ៏ក្លាហានហើយជាជាងដែលមានថ្វីដៃពូកែផង ៗ

ចំណែកខាងចិត្តថ្លើម ពួកកម្ពុជជាជាតិដែលស្លាប់ងាយទៅហ្វាយជាទីបំផុត ខនេះហើយជាមូលហេតុដ៏សំខាន់ ដែលធ្វើឲ្យជាតិកម្ពុជជាម្ចាស់លោក ៗ ជនជាតិកម្ពុជជាប្រជាជនដែលមានសេចក្តីព្យាយាមនឹងស្ម័គ្រចិត្តលះបង់អ្វីៗដើម្បីប្រទេសជាតិរបស់ខ្លួន មិនចេះធុញថប់អស់សេចក្តីមានះ កាលបើទៅច្បាំងចាញ់គេឬធ្វើការមិនសម្រេច ៗ ខនេះទុកជាពួកស្ត្រីកម្ពុជក៏មានសេចក្តីសរសើរ ក្រៅពីនេះ ក្រុមទាហានកម្ពុជគោង ធ្វើពិធីស្បថ ដែលមានសេចក្តីសំខាន់ គឺការត្រូវជឿស្តាប់ពាក្យបង្គាប់របស់មេទ័ព ហើយត្រូវទៅតាមមេទ័ពរបស់ខ្លួនគ្រប់ច្រកគ្រប់អន្លើ ស្រេចតែមេទ័ពនាំទៅ ហើយត្រូវនៅក្រោមម្លប់ទង់ជ័យរបស់ទាហាន ទម្រាំតែដល់ផុតកំណត់ពាក្យសំបថនោះ ៗ វិធីធ្វើពាក្យសត្យសំបថនេះ ពួកមេទាហានគាត់ផ្តើមធ្វើជាមុន រួចយកពាក្យសំបថនោះទៅមើលក្នុងកងទាហាន កាលបើមើលចប់ហើយ យកបញ្ជីឈ្មោះ

ទាហានមកហៅឈ្មោះគ្រប់ៗគ្នា អ្នកដែលត្រូវហៅឈ្មោះខ្លួនគេនឹងឆ្លើយ
ថា "ខ្ញុំបាទ" ផង ៗ

ពួកទាហានរ៉ូម៉ាំងគេនឹងកាន់ច្បាប់វិន័យទាហានយ៉ាងម៉ឺងម៉ាត់បំផុត ពួកមេទ័ពបង្គាប់ឲ្យកូនទាហានដើរផ្លូវឆ្ងាយៗធ្វើការយ៉ាងធ្ងន់ ទាំងធ្វើទោសជាទម្ងន់ ៗ ការទទឹងរឹងរូសមិនស្តាប់បង្គាប់មេទ័ព មិនថាក្នុងកិច្ចការណានីមួយទេ គេនឹងត្រូវទោសដល់ប្រហារជីវិត មុននឹងប្រហារជីវិតត្រូវចាប់វាយគ្រាតែទ្រមគ្រាំគ្រា ហើយការធ្វើទោសបែបនេះ មិនកំណត់ថាជាមនុស្សជាន់ណាទេ គេនឹងត្រូវទោសដូចគ្នាទាំងអស់ ៗ កូនប្រុសម្នាក់របស់ ម៉ុនលីយុស ធ្វើជាកុងស៊ុលក៏នៅតែត្រូវទោសដល់ប្រហារដែរ ជីវិតមិនមែនដោយហេតុទៅធ្វើខុសច្បាប់ឬមិនធ្វើតាមបង្គាប់មេទ័ពទេ គឺដោយហេតុខ្លួនច្បាំងចាញ់ទាហានគេល្ហ៊ុក្នុងការតទល់គ្នាតែម្នាក់ទឹងម្នាក់ ផ្សិតតាមគំនិតពួករ៉ូម៉ាំងក្នុងសម័យនោះ ប្រកាន់ថា ជាការអាម៉ះមុះណាស់គួរតែស៊ូស្លាប់ទៅវិញប្រសើរជាង ៗ

បើបែរជាកំហុសរបស់ទាហានទាំងក្រុមឬទាំងកង ច្រើនតែធ្វើទោសដោយវិធីចាប់ស្លាក គឺចាប់យកម្នាក់ក្នុងចំនួន ១០ នាក់ ឬ ២០ នាក់ហើយយកគ្រូថៅកាប់កាត់កពោល ៗ តាមធម្មតា ពួកទាហានរ៉ូម៉ាំងដែលធ្លោយឲ្យពួកសត្រូវចាប់ខ្លួនធ្វើជាឈ្លើយនោះ មានសង្ឃឹមតិចណាស់ក្នុងការដែលឲ្យរដ្ឋបាលខ្លួនជួយដោះខ្លួនឲ្យបានត្រឡប់មកស្រុកទេសវិញ ៗ ធ្លាប់

មានចម្បាំងមួយ ក្នុងវេលាក្រុងរោមនឹងការថាស៍ ពួកទាហាន ៨០០០ នាក់ ត្រូវពួកទាហានការថាស៍ចាប់យកទៅធ្វើជាឈ្លើយ ។ រឿងនេះ តាមធម្មតា រដ្ឋបាលតែងសុំទិញដោះខ្លួនទាហានមកស្រុកវិញ តែក្នុងសម័យនោះ សភាសេណាត់មិនព្រមទិញ ទើបពួកទាហានកម្លាំងទាំង ៨០០០ នាក់ ត្រូវគេចាប់ខ្លួនលក់ជាខ្ញុំអស់ទៅ ដែលជាការធ្វើទោសយ៉ាងធ្ងន់មួយយ៉ាង ។

ឯបំណាច់រង្វាន់ដែលត្រូវចែកដល់ពួកទាហាន ដែលមានជ័យជំនះវិញក៏សំបើមណាស់ដែរ មានការឲ្យជូនត្រាឲ្យមកុដ ហើយមានជូនការឲ្យប្រាក់ជាច្រើនផង ។ មេទ័ពណាដែលទៅច្បាំងឈ្នះ ដល់ត្រឡប់មកវិញមានការទទួលរាប់រងជាពិធីដ៏ធំក្រៃលែង ខ្លួនមេទ័ពនេះចូលកាន់ក្រុងរោមដោយរថទឹមសេះ ៤ នៅខាងមុខរថមេទ័ពនេះ មានពួកឈ្លើយនឹងទ្រព្យសម្បត្តិដែលប្លន់យកមកបាន ឬដែលរឹបជាន់មកពីពួកសឹកសត្រូវ ។ បើមានចម្បាំងធំទើងមានជ័យជំនះយ៉ាងធំហើយ ការធ្វើពិធីទទួលមេទ័ពដែលមានជ័យ ដើរចូលកាន់ក្រុងរោមនេះជាក្បួនដ៏មហិមា ដូចជាកាលត្រាច្បាំងឈ្នះពួកម៉ាសេដ្ឋាន នោះគេធ្វើពិធីដើរទ័ពចូលកាន់ក្រុងរោមជាវេលា ៣ ថ្ងៃទើបផុតក្បួនដើរទ័ព ។ មេទ័ពដែលមានជ័យជំនះ ក៏ហែមកោមទៅដោយពួកទាហានដែលកាន់ភួងផ្កានឹងស្លឹកព្រៀងក្នុងជ័យ ។ កាលចូលដល់ក្រុងហើយ ក៏ចាប់យកពួកមេទ័ពមេកងខាងសត្រូវដែលចាប់ឃុំខ្លួនបានមកនោះ ទៅដាក់គុកហើយច្របាច់កសម្លាប់ ។

(នៅមានត)

# រឿងដឹងសងដឹង-អំបែងសងអំបែង

មាននិទានមួយដំណាលថា មានបុរសប្តីប្រពន្ធមានកូនប្រុសម្នាក់ ។ បុរសជាប្តីនោះទៅខ្ចីដឹងអំពីសេដ្ឋីម្នាក់យកទៅកាប់ឫស លុះលើកឡើងនឹងសំពន់កាប់ ស្រាប់តែដឹងនោះរបោះផ្លោះធ្លាក់ទៅត្រូវប្រើសមួយកប់បាត់ក្នុងខ្លួនប្រើសនោះ ក៏បោលចូលព្រៃតាមរកពុំឃើញឡើយ បុរសនោះក៏វិលមកផ្ទះអាត្មា ប្រាប់ប្រពន្ធកូនរួចហើយទើបទៅប្រាប់សេដ្ឋីដោយនូវដំណើរដឹងបាត់នោះ ។ សេដ្ឋីថា ដឹងនោះជារបស់កំសត់កម្រពីមេបាអញ បើឥតអំពីដឹងនេះហើយ អញគ្មានអ្វីប្រើការឡើយ ។ បុរសនោះអង្វរសុំសងជាដឹងមួយថ្មីវិញ សេដ្ឋីពុំព្រមនិយាយថាឲ្យបានដឹងដើមទើបយក ទុកជាបុរសនោះអង្វរសុំសងមួយជាពីរក៏សេដ្ឋីពុំព្រមយកឡើយ ។ បុរសនោះក៏វិលទៅគិតនឹងប្រពន្ធរួចត្រឡប់ទៅរកសេដ្ឋីទៀត អង្វរសុំសងមួយជាបួន សេដ្ឋីនៅតែពុំព្រមយក សងមួយជាដប់សេដ្ឋីក៏ពុំយកទៀត នៅតែនិយាយដូចថាឲ្យបានដឹងដើមនោះទើបយក ។ បុរសនោះលាសេដ្ឋីវិលទៅគិតនឹងប្រពន្ធព្រមព្រៀងគ្នាថា ត្រូវយកកូនកំឡោះធ្វើជាសំណងវិញ ។

លុះគិតដូច្នោះហើយ បុរសនោះក៏នាំកូនកំឡោះទៅប្រគល់សេដ្ឋីជាសំណងដឹងនោះ សេដ្ឋីក៏ព្រមទទួលយក ។ ឯបុរសនោះក៏វិលទៅ

ផ្ទះអាត្មាវិញ ហើយទៅកុះសក្កនៃព្រៃទៀត ស្រាប់តែឃើញប្រើសនោះផិត ល្វយទៅហើយ ៗ ឃើញទាំងដីនោះផង មានសេចក្ដីត្រេកអរតេត្ងបមា នាំយកមកផ្ទះ ស្គាល់ជាក់ជាដីរបស់មហាសេដ្ឋី ផុសលាងស្អាតហើយ យកទៅជូនសេដ្ឋី ប្រាប់ដោយដំណើរនោះសព្វគ្រប់ហើយសុំយកកូនមកវិញ ៗ ឯសេដ្ឋីស្គាល់ដីនោះជាក់ក៏ទទួលយកហើយឲ្យកូនកំឡោះទៅបុរសនោះ ៗ នាំកូនទៅកាន់លំនៅរបស់ខ្លួន ៗ ចំណេរកាលតមក ដល់ជួរស្រូវទុំ បុរសប្ដីប្រពន្ធដាល់អំបុកស៊ី ៗ កូនស្រីសេដ្ឋីនោះផ្ចិត អំបុកក៏នឹកចង់ស៊ីហើយអង្វរម្ដាយអាពុកឲ្យរកអម្បែងឲ្យ សេដ្ឋីរកខ្ចី អម្បែងគេពុំបានសោះ ក៏ចូលទៅខ្ចីអម្បែងបុរសនោះ លុះដាល់អំបុករួចហើយ ជួនជាមានខ្លែងមកប្រខាំគ្នាការលើអម្បែងនោះបែកល្អិតអស់ ៗ សេដ្ឋីឲ្យទៅប្រាប់បុរសនោះ ៗ យំតក់ខ្លួនថា អម្បែងនេះជារបស់កំសត់កម្រពីមេបាមក ត្រូវតែរកអម្បែងដើមមកសងវិញ ទុកជាសេដ្ឋីស្រដីថានឹងសងមួយជាមួយក្ដីជាពីរក្ដី បុរសនោះពុំព្រមយកឡើយ គឺទទូចយកឲ្យបានតែអម្បែងដើមនោះឯង បើមិនបានអម្បែងនោះមិនព្រមទេ ៗ ទើបសេដ្ឋីឲ្យទៅស្រដីថានឹងសងមួយជាបួនក្ដី មួយជាដប់វិញក្ដី បុរសនោះក៏នៅតែពុំព្រមយកឡើយ ៗ សេដ្ឋីខឹងក៏ទៅប្ដឹងដល់ចៅក្រម ៗ ឲ្យហៅបុរសនោះមកជណ្ដឹងសួរដោយដំណើរហើយ ទើបចៅក្រមបង្គាប់ឲ្យសេដ្ឋី

នោះសងអម្បែងតែមួយ បុរសនោះពុំព្រមយកឡើយ ទៅក្រមក៏និយាយថា ទៅបុរសនេះល្មើសនឹងបង្គាប់អញ ៗ ឯសេដ្ឋីយល់បុរសនោះពុំសុខចិត្ត ក៏នាំសេចក្ដីឡើងទៅក្រាបបង្គំទូលសម្ដេចព្រះមហាក្សត្រាធិរាជដោយដំ-ណើរនោះ ទើបព្រះអង្គឲ្យហៅបុរសនោះមកហើយមានព្រះបន្ទូលដណ្ដឹងសួរថា ដំណើរនេះទៅក្រមបង្គាប់ក្ដីហើយម៉េចក៏ព្រះស្លូនពុំសុខចិត្ត ៗ បុរសនោះក្រាបទូលថា ដ្បិតសេដ្ឋីខ្ចីអម្បែងខ្ញុំព្រះអង្គទៅដាល់អំបុក ទុកឲ្យវត្តប្រទាំគ្នាពារលើវែករបស់ខ្ញុំព្រះអង្គ ឯអម្បែងនោះជាកេរ្ដិ៍ពីមេពីបាមក តែងនឹងចិញ្ចឹមជីវិតដោយសារអម្បែងនោះ ដូច្នេះលុះតែបានអម្បែងដើមទើបខ្ញុំព្រះអង្គយក បើរកពុំបានទេខ្ញុំព្រះអង្គពុំយកឡើយ ៗ ទើបព្រះមហាក្សត្រទ្រង់ព្រះចិន្ដាពិចារណាថា ការអស់នេះសមមានហេតុនឹងគ្នាអំពីមុនបានជាក្ដួចកាន់ខ្ជាំងណាស់ ទើបត្រាស់ដណ្ដឹងសួរថា ព្រះស្លូនមានដំណើរហេតុដូចម្ដេចអំពីដើមបានជាក្ដួចកាន់គ្នាខ្ជាំងម៉េះ ៗ បុរសនោះក្រាបទូលថា ដំណើរដើមនោះគឺខ្ញុំព្រះអង្គខ្ចីដីងសេដ្ឋីទៅកាប់ឫសហើយរន្ទះផ្ទុះខ្ចូតទៅត្រូវប្រើសមុតជាប់នឹងខ្លួនកាំបោលបាត់ទៅ ខ្ញុំព្រះអង្គរកពុំឃើញ បានទៅប្រាប់សេដ្ឋីថាដីងនេះជាដីងកសត់កម្រពីមេពីបា ខ្ញុំព្រះអង្គសុខចិត្តសងមួយជាពីរមួយជា ១០ ក្ដី សេដ្ឋីក៏ពុំយកឡើយ ឲ្យបានតែដីងដើមទើបយក បើពុំបានដីងដើមពុំយកឡើយ ៗ សេដ្ឋីក្ដួចកាន់ដូច្នោះ

ទើបខ្ញុំព្រះអង្គយកកូនឲ្យទៅនៅបំរើជាជំនួស ។ សេដ្ឋីក៏ទទួលយក លុះខ្ញុំព្រះអង្គទៅរកស្នៅព្រៃនាថ្ងៃក្រោយ ស្រាប់តែឃើញប្រើសនោះជាប់ជិតល្អះទៅហើយ ។ ឃើញដីនៅក្នុងស្រុកនោះផង ខ្ញុំព្រះអង្គស្គាល់ជាក់ជាដីងសេដ្ឋីហើយ មានចិត្តត្រេកអរណាស់ យកទៅឲ្យសេដ្ឋី ។ ស្គាល់ជាក់ជារបស់ខ្លួនហើយ ក៏ទទួលយកហើយឲ្យកូនមកខ្ញុំព្រះអង្គវិញ ។ ព្រះមហាក្សត្រាធិរាជទ្រង់ព្រះសណ្ដាប់ហើយ ទើបដណ្ដឹងសួរសេដ្ឋីថា ដំណើរនុះដូច្នេះមែនឬទេ ។ សេដ្ឋីក្រាបទូលថា ដូច្នេះមែន ។ ទើបព្រះអង្គមានព្រះបន្ទូលថា បើដូច្នោះសេដ្ឋីត្រូវឲ្យកូនខ្លួនទៅនៅបំរើគេវិញ ទើបគាប់ដោយគន្លងធម៌ ។ សេដ្ឋីនឹងបុរសនោះក៏ក្រាបថ្វាយបង្គំទទួលព្រះបន្ទូលពិសេសតាំងអស់គ្នា ។ សេចក្ដីដែលសម្ដេចព្រះមហាក្សត្រាធិរាជទ្រង់បង្គាប់ដូច្នេះ សេដ្ឋីនឹងទៅបុរសនោះចូលចិត្តស្ដាប់បាន ហើយក្រាបលាទៅកាន់លំនៅរៀងៗហោង ។

រឿងនឹងសងដឹង - អំបែងសងអំបែង ចប់តែប៉ុណ្ណោះ

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

## ឆ្នាំគំរប់ ១៤ ភាគទី ៣

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃទាំងពីរគណៈ

បានអនុញ្ញាតហើយ


ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨៤

គ. ស. ១៩៤២

# បញ្ជីរឿង

ទំព័រ


១ — មហាភារតៈ (សង្ខេប) . . . . . . . . . . . . . . . . . . . . ៣

២ — ប្រវត្តិពួកឧបាសក-ឧបាសិកា ជាសាវ័ករបស់ព្រះពុទ្ធជាម្ចាស់ៈ ទី៣ ប្រវត្តិចិត្ត-គហបតី . . . . . . . . . . . . . . . . . . . . . ៧

៣ — ច្បាប់វិធុរបណ្ឌិត (តមកនឹងចប់) . . . . . . . . . . . . . . . . ១០

៤ — ភូមិសាស្ត្រសង្ខេបនៃប្រទេសផ្សេងៗៈ អំពីប្រទេសអល្លឺម៉ាញ . . . . . . . ១៣

៥ — ពង្សាវតាររោម, ស្រង់យកអំពីពោលបារាំងផ្សេងៗក្នុងពង្សាវតារលោក (តមក) . . . . . . . . . . . . . . . . . . . . . ១៧

៦ — សេចក្ដីប្លែកៗ . . . . . . . . . . . . . . . . . . . . . . ២១

៧ — រឿងព្រេងខ្មែរៈ "រឿងសេដ្ឋីបីនាក់" . . . . . . . . . . . . . . . ២៦


## រូបក្រៅរឿង


រូបគជសីហ៍អង្គុយ សក់គេឆ្លាក់ជាក្បាច់ រចនាបែបប្រាសាទបាខែង ព.ស. ១៤៤៣ ១

# TABLE DES MATIÈRES


| | Pages |
|---|---|
| 1. Mahābhārata (sommaire) ...................... | 3 |
| 2. Vie des disciples laïcs du Buddha. — III. La vie de Citta-Gahapati ...................... | 7 |
| 3. Chbab-Vidhurapaṇḍit (suite et fin) ...................... | 10 |
| 4. Géographie sommaire de divers pays: L'Allemagne ...................... | 13 |
| 5. Histoire de Rome. Extrait de divers documents de l'histoire universelle (suite) ...................... | 17 |
| 6. Notes variées ...................... | 21 |
| 7. Conte populaire cambodgien inédit: "Légende de trois richards" ...................... | 26 |


HORS-TEXTE


| | |
|---|---|
| Phnom-Bakheng — Lion assis. Crinière à stylisation décorative (début du X^e siècle) ...................... | 1 |

# សេចក្តីជូនដំណឹង

## អំពីព្រះរាជបណ្ណាល័យ កម្ពុជា

គម្ពីរមង្គលត្ថទីបនីបាលី ព្រះរាជបណ្ណាល័យបានបោះពុម្ពចប់សព្វគ្រប់ហើយ ចែកចេញជា ៤ ភាគ គឺ ភាគទី ១ ដំឡៃ ១ ក្បាល ២រ.០០ ភាគទី ២ ដំឡៃ ១ ក្បាល ២រ.៥០ ភាគទី ៣ ដំឡៃ ១ ក្បាល ៣រ.០០ ភាគទី ៤ ដំឡៃ ១ ក្បាល ២រ.៧០ ។ អស់លោក-អ្នកសិក្សាគម្ពីរបាលីដល់ថ្នាក់មង្គលត្ថទីបនីហើយ សឹងមានសេចក្តីត្រូវការគម្ពីរនេះទាំងអស់គ្នា ដូច្នេះ សូមចូលទៅជាវនៅព្រះរាជបណ្ណាល័យទីឯកន្លែងលក់សៀវភៅរបស់ព្រះរាជបណ្ណាល័យតាមត្រូវការចុះ ។

អស់លោក - អ្នកចុះឈ្មោះជាវព្រះត្រៃបិដកគង់មានសេចក្តីទន្ទឹងចាំបើកព្រះត្រៃបិដកឲ្យបានឆាប់ៗកល់គ្នា ចំពោះភាគថ្មីៗ តទៅ ដូច្នេះ ព្រះរាជបណ្ណាល័យសូមជូនដំណឹងថា ព្រះត្រៃបិដកភាគទី ៣២ (សុត្តន្តបិដក) បានបោះពុម្ពសម្រេចហើយ សូមអញ្ជើញទៅបើកយកចុះ ។ ឯភាគទី ៣៣ - ៣៤ ទាំងតទៅនោះកំពុងពុម្ពកំពុងរៀបកាត់ចងក្រងនឹងបោះពុម្ព ជាលំដាប់តទៅឥតឈប់ឈរទេ ។

*

* *

ព្រះរាជបណ្ណាល័យបានបោះពុម្ពផ្សាយរឿងថ្មី ១ រឿងទៀតហើយ គឺមគ្គុទ្ទេសក៍ទេសចរ ជាសៀវភៅនាំផ្លូវទៅមើលបុរាណស្ថាននគរវត្ត នគរធំ នៅខេត្តសៀមរាប ។ មគ្គុទ្ទេសក៍នេះមាន ២ ភាគ ភាគទី ១ និយាយពី

ពង្សាវតារសម័យបុរាណនៃស្រុកកម្ពុជា ទាំងពេលព្រះមហាក្សត្រសម័យនគរ មានសេចក្ដីរៀបរៀងតាមគោលការណ៍ផ្សេងៗដែលអ្នកប្រាជ្ញបានស្រាវជ្រាវរកឃើញ ភាគទី ១ នេះ ១ ក្បាលថ្លៃ ០ ៛.៦០ ។

ភាគទី ២ មានសេចក្ដីពន្យល់ពីផ្លូវដែលត្រូវទៅមើលប្រាសាទអស់នោះ និងបង្ហាញឲ្យដឹងច្បាស់ថា ប្រាសាទណាកសាងឡើងក្នុងសម័យណា? ព្រះមហាក្សត្រអង្គណាទ្រង់កសាង? កសាងឡើងដើម្បីជាប្រយោជន៍អ្វី? ហើយបានបង្ហាញឲ្យយើងស្គាល់បែបផែនប្រាសាទឬក្បាច់រចនាដែលកើតឡើងដោយស្នាដៃខាងពួកសាសនាព្រាហ្មណ៍ឬខាងពួកពុទ្ធសាសនាមហាយានទាំងហីនយានដោយឡែកថែមទៀតផង ។

នៅខាងក្នុងផ្ទៃសៀវភៅមគ្គុទ្ទេសក៍ភាគទី ២ នេះ មានរូបប្រាសាទនិងរូបផ្សេងៗ ជាចំនួនច្រើន ហើយមានផែនទីសម្រាប់នាំផ្លូវទៅមើលបុរាណស្ថានផ្សេងៗ ជាអក្សរខ្មែរយ៉ាងច្បាស់លាស់ផង ទុកជាលោក-អ្នកមិនដែលអញ្ជើញទៅនគរវត្តសោះ គ្រាន់តែមានផែនទីដែលខ្ចាស់ជាប់មកនិងមគ្គុទ្ទេសក៍ភាគទី ២ នេះ ក៏លោក-អ្នកអាចអញ្ជើញទៅមើលនគរវត្តនគរធំ ដោយខ្លួនឯងបាន មិនបាច់វង្វេងផ្លូវឬភាន់ច្រឡំឡើយ ។ សៀវភៅមគ្គុទ្ទេសក៍ភាគទី២ នេះថ្លៃ ១ ក្បាល ១៛.២០ ។

សៀវភៅអស់នេះ មានលក់នៅព្រះរាជបណ្ណាល័យនិងកន្លែងលក់សៀវភៅរបស់ព្រះរាជបណ្ណាល័យទូទៅ ។



រូបភាពសីហ៍អង្គុយ សក់គេធ្លាក់ជាក្បាច់រចនាបែបប្រាសាទបាខែង ព. ស. ១៤៤៣

# មហាភារតៈ

មានជនជាតិខ្មែរជាចំនួនច្រើន ដែលមិនទាន់ស្គាល់ឈ្មោះកំណាព្យធំ ១ នេះរបស់ប្រទេសឥណ្ឌា តែជនជាតិខ្មែរបុរាណគេស្គាល់ច្បាស់ណាស់ ហើយរឿងនេះស្ទើរតែមានចម្លាក់នៅគ្រប់អគារ និងប្រាសាទបុរាណ ក្នុងមហាអាណាចក្រខ្មែរសម័យបុរាណ ដែលគេបានស្រង់យករឿងរ៉ាវមកអំពីកាព្យនេះ ហើយឆ្លាក់ជារឿងរ៉ាវទុកនឹងជញ្ជាំងប្រាសាទ និងខាងលើខ្លោងទ្វារនៅតាមប្រាសាទផ្សេងៗ ហេតុនេះហើយបានជាយើងគិតឃើញថា ការនាំយករឿងនេះមកចុះផ្សាយក្នុងទស្សនាវដ្ដីជាការគាប់ប្រសើរមួយ ទុកជាទីរឭកនៃមហាកាព្យនេះ ដែលមានរឿងរ៉ាវជាទីចាប់ចិត្តនៃវិស្វករខ្មែរអំពីបុរាណ ហើយនាំឲ្យកំណាព្យធំនេះមានជីវិតរស់ឡើងវិញផង ។

ឯកំណាព្យធំនេះមានសេចក្ដីរៀបរៀងជាគាថា ចំនួន ៤០០.០០០ គាថា ក្នុងគាថានីមួយៗមាន ៤ បាទ ក្នុង ១ បាទៗមានអក្សរ ៨ និង ១១ ហៅថាស្លោក និងត្រិស្ដុភ(១) អស់នេះជួនកាលមានសេចក្ដីរៀបរៀងជារបៀបសីលធម៌, ជារបៀបប្រសាសនោបាយ, ជារបៀបសាសនា, ជារបៀបព្រះអភិធម្ម ។

---

១ ពាក្យថាស្លោក បានដល់គាថានីមួយៗមាន ៤ បាទ ៨ អក្សរ ក្នុងបាទនីមួយៗក្នុង ១ គាថាមាន ៣២ អក្សរ ។ ឯត្រិស្ដុភៈបានដល់គាថាមាន ៤ បាទដែរ តែក្នុង ១ បាទៗមាន ១១ អក្សរ មួយគាថា ៤៤ អក្សរ ។

កាព្យមហាភារតៈនេះជាពង្សាវតារយ៉ាងធំ ហើយចាស់ជាងរឿងរាមាយណៈផង ។ កាព្យនេះលើកដំកើងក្រិស្ណៈថាជាតួព្រះវិស្ណុបែងភាគចុះមកក្នុងលោក ។ គេមិនអាចនឹងកំណត់អំពីកំណើតរបស់កាព្យនេះយ៉ាងប្រាកដបានទេ តែកាព្យនេះដែលគេបានរៀបរៀង ហើយកែចំរើនឡើងនោះរាប់ជាពេលច្រើនឆ្នាំដែរ នៅក្នុងរវាងពុទ្ធសករាជ ១០០ នឹង ៩០០ ឆ្នាំ ។ គេឃើញមានសេចក្ដីសរសើរនេះ នៅក្នុងរឿងរ៉ាវជាន់ដើមខាងពុទ្ធសាសនាដែរ ។ ឯប្រទេសឥណ្ឌាក្នុងសម័យដែលតែងកាព្យនេះឡើង គង់បានស្គាល់នានាប្រទេសខ្លះហើយ ការតែងកាព្យនេះទើបនាំឲ្យទឹកដល់រឿងរ៉ាវក្នុងប្រទេសឯទៀតៗ គឺក្រិក, ប៉ែរ្ស, ចិន នឹងចំណែកៗរបស់ឥណ្ឌាដោយឡែក ។ ឯពួកវណ្ណៈដែលជារបៀបឥណ្ឌូ គង់មានបរិបូណ៌ហើយ ( ក្នុងសម័យនោះ ) ទើបគេឃើញមានសេចក្ដីនិយាយប៉ះពាល់ដល់បុរាណស្ថានពុទ្ធសាសនានឹងហិណ្ឌូ ។ ឯព្រះត្រៃបិដករបស់ឥណ្ឌាក៏មាននិយាយក្នុងរឿងនេះទាំងអស់ ។

រឿងមហាភារតៈនេះមានសាម្កកថា ១ និយាយអំពីរឿងរ៉ាវរបស់ពួកភារតនឹងពួកមនុស្ស ដែលជារឿងសំខាន់ក្នុងពង្សាវតារ ដូចមានសេចក្ដីសង្ខេបដូច្នេះ:

មានបងប្អូន ២ នាក់ ឈ្មោះធ្រិតរាស្ត្រៈ ១ នឹងបាណ្ឌុ ១ ដែលអាយុករីឈ្មោះគឺប្អូនបានខឹងចិត្តមិនចាប់ថៃក្រោ ។ ដូច្នេះ ធ្រិតរាស្ត្រមានប្រពន្ធ

ឈ្មោះគន្ធារី មានបុត្រ ១០០ នាក់ ហៅថាកុរុ ។ ឯបាណ្ឌុមានប្រពន្ធ ២ នាក់ ប្រពន្ធមួយឈ្មោះម៉ាទ្រី កាលបូជាសពប្ដីលើគំនរឧសនោះ នាងក៏ធ្វើពិធីសាតី (គឺលោតសម្លាប់ខ្លួនឯងក្នុងគំនរភ្លើងនោះ) ទៅ ។ ប្រពន្ធមួយទៀតឈ្មោះនាងប្រីថា ចិញ្ចឹមកូនទាំង៥ ប្រុសដែលហៅថាបាណ្ឌុ ដែលតាមពិតនោះ ពួកបាណ្ឌុជាកូនទេព្ដា ហៅថា យុធិស្ឋិរៈ (កូនព្រះធម៌) អជុនៈ (កូនព្រះឥន្ទ្រ) នកុលៈនិងសហទេវ (កូនព្រះអស្វិន) ។

ឯក្រុងហស្តិនាបុរៈ ពួកកុរុប្រជុំគ្នាហើយសម្រេចថាទៅអញ្ជើញពួកបាណ្ឌុឲ្យមកលេងល្បែងស្កាភ្នាល់គ្នា ដោយល្បិចឆបោកដោយយកស្រុកទេសជាដើមភ្នាល់ ហើយត្រូវបន្លំយកអស់ទាំងព្រះរាជអំណាច ។ ដំបូងព្រះបាទយុធិស្ឋិរៈទ្រង់លេងល្បែងនោះទោ ក៏ទ្រង់ចាញ់អស់ទាំងព្រះរាជទ្រព្យរបស់ខ្លួនស្រុកទេសនិងប្អូន ៗ របស់ទ្រង់ហើយនិងខ្លួនទ្រង់ ។ នៅទីបំផុតទ្រង់លេងហើយខូចមហេសីដែលមានបងប្អូន ៥ នាក់ ឈ្មោះនាងក្រិស្ណា ជារាជធីតារបស់ក្សត្រទ្រុបទ ។ ទ្រង់នៅលេងតទៅទៀតដកបដល់គេនិរទេសទ្រង់ ហើយនៅទីបំផុតត្រូវបំបរបង់បងប្អូនទាំង៥និងមហេសីរបស់ទ្រង់ឲ្យទៅនៅក្នុងព្រៃជាវេលា ១២ ឆ្នាំ ។ ក្នុងសៀវភៅ១ហៅថា "វន" និយាយរៀបរាប់អំពីជីវិតដែលនៅក្នុងព្រៃ ហើយមានរឿងកាំយ៉ាងឆ្ងាយ និងរឿងកំដែលជួយឲ្យពួកដែលត្រូវគេនិរទេសអត់ធន់ទ្រាំទ្រសេចក្ដីព្រួយលំបាកក្នុងជីវិតដែលនៅក្នុងព្រៃផង ។

លុះដល់១២ឆ្នាំក្រោយកន្លងមក ទើបបងប្អូនទាំង៥នាក់ទាំងមហេសី ចេញទៅស្នងកេវតំនាក់ទីងស្តេចវិរាដៈ ហើយប្រួបប្រួមជាពួកសម្ពន្ធមិត្តជួយស្តេចនោះក្នុងការច្បាំងតវ៉ាប់នឹងពួកកុរុ ៗ ឯព្រះបាទក្រិស្ណៈ ជាតួវិស្ណុបែងភាគចុះមក ក៏បានចេញទៅច្បាំងនៅខាងពួកបាណ្ឌុ អជ៉ុនបានប្អូនស្រីធ្វើជាប្រពន្ធ ៗ

នៅខាងដើមនៃសេចក្តីពន្យល់ ដែលនិយាយអំពីចម្បាំងក្នុងពាក្យកាព្យដែលហៅថា ភគវទ្គីតៈនោះ មានសេចក្តីពីរោះណាស់ រឿងនេះគេបានប្រែចេញជាច្រើនគ្រប់ៗភាសាក្នុងទ្វីបអឺរ៉ុប កាព្យនេះហើយដែលយើងនឹកស្មានថា យើងនឹងប្រែចេញជាខ្មែរក្នុងថ្ងៃខាងមុខមិនខាន ៗ

ចម្បាំងនេះចប់ចុះដោយកិស្ណៈបានជ័យ ទើបគេផ្លាស់ឲ្យទ្រោណៈឡើងគ្រងក្រុងស្រុកកុរុ ៗ មានសៀវភៅ១ និយាយពន្យល់អំពីពួកដែលមានជីវិតរស់នៅ ខាងពួកកុរុបានចេញច្បាំងក្នុងវេលាយប់ បានសម្លាប់គស់ទាំងពួកទាហាន លើកលែងតែពួកបាណ្ឌុចេញ ឯកិស្ណៈត្រឡប់មានជីវិតរស់ឡើងវិញយ៉ាងអស្ចារ្យ ហើយទេសនាតាមផ្លូវសាសនា និយាយអំពីលលខមិទីងដំណើររបស់ជីវិត ៗ ឯរឿងក៏រ៉ាំងពួងដែលនិយាយអំពីចម្បាំង សឹងមានចម្លាក់ជាក្បាច់នៅថ្នាក់ក្រោមនៃប្រាសាទនគរវត្ត ៗ

(នៅមានត)

ជាសាវកសាវិការបស់ព្រះពុទ្ធជាម្ចាស់

៣ — ចិត្តគហបតី កើតក្នុងត្រកូលសេដ្ឋី ក្នុងស្រុកមច្ឆិកាសណ្ឌៈ ដែនមគធៈ ។ មានរឿងដំណាលថា កាលពេលលោកប្រសូតនោះមានភ្លៀងជាផ្កាឈូក ៤ យ៉ាង ធ្លាក់ចុះមកគរពេញស្រុកត្រឹមជង្គង់ ទើបមាតាបិតាតាំងនាមកូនថា ចិត្តកុមារ ព្រោះស្ថានទីទូទៅវិចិត្រត្រកាលដោយផ្កាឈូក ។ លុះធាត់ធំចំរើនឡើង ក៏បានទទួលមុខក្រសួងសេដ្ឋីជាជំនួសបិតា ។ ក្នុងសម័យនោះ ព្រះមហានាមត្ថេរដែលនៅក្នុងពួកបញ្ចវគ្គិយបានទៅកាន់ស្រុកមច្ឆិកាសណ្ឌៈ ចិត្តគហបតីបានជួប ក៏មានចិត្តជ្រះថ្លា ទើបបវារណាលោកសុំឲ្យនៅ ហើយរៀបចំទីកន្លែងឲ្យលោកស្នាក់នៅអម្ពាតការាម ។ ព្រះថេរៈឃើញឧបនិស្ស័យធម៌របស់ចិត្តគហបតី ទើបសំដែងធម៌ចែកអាយតនៈទាំង ៦ ប្រការ ចិត្តគហបតីបានស្តាប់ព្រះធម្មទេសនារបស់លោក ក៏បានសម្រេចអនាគាមិផល ។ តមកថ្ងៃ ១ ព្រះឥសិទត្តត្ថេរទៅនៅក្នុងទីនោះ បានពោលឆ្លើយដោះប្រស្នាគ្នាទៅវិញទៅមករួចហើយចៀសចេញទៅ ។ ក្នុងថ្ងៃមួយនោះ សេដ្ឋីបាននិមន្តសុំឲ្យព្រះមហកត្ថេរសំដែងឥទ្ធិបាដិហារ្យ លោកក៏បានសំដែងបាដិហារ្យប្រកបដោយតេជោសមាបត្តិរួចហើយចៀសចេញទៅ ។ តមកសម័យក្រោយ

ទៀត ព្រះអគ្គសាវកមានភិក្ខុ ១ ពាន់រូបជាបរិវារ បានត្រេចចារិកទៅកាន់វ៏
នោះ ឯចិត្តគហបតីបានចាត់ការទទួលយ៉ាងអឹកធឹក ព្រះសុធម្មត្ថេរជាចៅ
អាវាសនៅវ៏នោះកើតចិត្តច្រណែនឫស្យា ដោយការហេតុថាចិត្តគហបតី
រំលងមុខលោក ព្រោះទៅនិមន្តព្រះអគ្គសាវកមុន ទើបមកនិមន្តលោក
ជាក្រោយ ធ្វើឲ្យលោកអន់ចិត្តមិនព្រមទទួលនិមន្តរបស់ចិត្តគហបតី ៗ ទទូច
អង្វរយ៉ាងណាក៏លោកនៅតែមិនព្រមទទួលនិមន្ត ព្រឹកឡើងជាថ្ងៃថ្វាយ
ទានដល់ព្រះអគ្គសាវកព្រមទាំងភិក្ខុសង្ឃ ព្រះសុធម្មត្ថេរចេញទៅបិណ្ឌ-
បាត ហើយបានចៀងទៅអែបមើលលាភសក្ការៈដែលគហបតីចាត់ថ្វាយ
ដល់ព្រះអគ្គសាវក ។ ចិត្តគហបតីបានឃើញក៏និមន្តឲ្យលោកគង់ លោក
មិនព្រមគង់ ហើយថែមទាំងពោលពាក្យដៀមដាមដល់ជាតិកំណើត
របស់គហបតីផង ហើយលោកត្រឡប់មកគាល់ព្រះបរមសាស្តា ក្រាប
បង្គំទូលឲ្យទ្រង់ជ្រាប ។ ព្រះអង្គទ្រង់លើកទោសហើយឲ្យទៅសុំខមា
ទោសនឹងចិត្តគហបតី ព្រះសុធម្មត្ថេរក៏ធ្វើតាមព្រះពុទ្ធដីកា បានសុំខមា
ទោសនឹងចិត្តគហបតីហើយ បំពេញព្យាយាមចំរើនសមណធម៌នៅអម្ពាត
កាមនោះឯង ក៏បានសម្រេចព្រះអរហត្តជាព្រះខីណាស្រព ។

ប៉ែកខាងចិត្តគហបតីបានចូលទៅគាល់ព្រះបរមសាស្តា បានស្តាប់
ព្រះធម្មទេសនាដែលទ្រង់សំដែងអំពីអាយតនៈ ៦ ប្រការ កើតចិត្តជ្រះថ្លា

យ៉ាងក្រៀវក្រា បានបំពេញទានបរិច្ចាគ មានមហាជននាំគ្នាមកជួយជាច្រើន ។ តមកសម័យមួយ ព្រះបរមសាស្ដាទ្រង់សំដែងចិត្តសំយុត្តឲ្យជាហេតុ ទើបទ្រង់តាំងក្នុងដំណែងឯតទគ្គៈក្នុងពួកឧបាសកដែលជាធម្មកថិក ។

ចប់ប្រវត្តិរបស់ចិត្តគហបតីតែប៉ុណ្ណោះ ។

# ច្បាប់វិធុរបណ្ឌិត

( [illegible] )

ដូចទៀនគន្ធយក្ខ នោះនូវប្រែតក់ពុំត្រង់ យកប្រេងទូរគេចង់ គេល ក្មេងតក់ពុំត្រង់បាន ។ ដូចពុកពាលសក់ឡក់ ចិត្តអាក្រក់ធ្វើលើកលាន យល់ធម៌ផ្សន្ទាន ចិត្តពុំវូលពុំចង់ស្តាប់ ។ ទឹកហូរចេញចូលណា ដោយច្បាប់ជាលោកប្រើគ្រាប់ ជាញាតិសន្ដានស្រាប់ ត្រូវគ្រាប់អំពើរាជ្យ ។ អ្នកតូចឥតមេត្រី ចង់ជាក្តីមែនគ្នាចង់ ទ្រព្យធននាយពុំគង់ បទបំណាច់ឯងឲ្យបាត់ ។ នោះបើយល់គេខុស កុំប្រទូស្តប្រទះមាត់ យល់ថ្ងៃកប្រើប្រយ័ត្ន ត្រូវលែងសាធុសបក្ខធម៌ ។ នោះបើជាតិអ្នកបេះ មានបំណោះអាងជីងអាថ៌ ប្រើធ្ងន់ប្រើដោះសា ដោយសណ្ដាប់ព្រះធម៌ស្រាយ ។ វាក្យពាលកះឡាំ ពុំដឹងប្រើដោយបរិយាយ នាំពាក្យទៅនិយាយ ដើរប្រាប់ប្រាយឲ្យអប្រិយ ។ អម្ចាស់អ្នកប្រើទៅ វែងវល់នៅពុំខាងក្តី ស្វែងទ្រព្យសរពើរ្ជ អង់អាលស៊ីទ្រព្យសាធារណ៍ ។ ប្រើទៅជាកផ្ទួត ចិត្តពុំស្ងួតធ្វើក្រៅសារ បេះតាំងនូវអស់អាថ៌ ជាកផសារទូកតម ។ ជាកផបុរោហិត កផបណ្ឌិតត្រូវហោរធំ ពុំមានប្រព្រឹត្តក្រម លោកក្រៃលែងអ្នកសាមន្ត ។ នោះគេស្រឡាញ់ហោង ប្រើបេះស្នងស្រ-ឡាញ់ថ្កាន បណ្ដាលហឫទ័យក្សត្រ សមស្នេហាមិត្រមេត្រី ។ នោះទេវក្តីកុក្កល ប្រើបេះយល់អាថ៌នោះមិញ អប្រិយប្រើចៀសចេញ

ទូរចិត្តឆ្ងាយឲ្យបាត់ដាន ។ ពុំគួរយកខ្លួនគប់ គួរតែស្តាប់ហេតុសាមាន្យ កុំ សេពអាស្រវប្រាណ ពាក្យដំទៀលតែឯក្នុង ។ កុំយកពងមាន់ផ្ញើ ឮដី លើសំបុកក្អែក អ្នកដំកុំផ្ញើដែក អ្នកប្រមឹកកុំផ្ញើស្រា ។ កុំបីយកសំរិទ្ធិ ផ្ញើអ្នកស្មិតនោះពុំជា រីឯអ្នកចំការ កុំយកត្រាប់ត្រសក់ផ្ញើ ។ ពោះស្រូវ គោដសាលី ទុកកុំផ្ញើក៏នោះឃាត់បើ កុំមានចិត្តសើរើ យកមកផ្ញើនៅ ផលស័យ ។ បញ្ញើប្អូនប្រការ ពិចារណាឲ្យអស់ក្តី កុំមានពាក្យអប្រិយ ខ្លាចចំណោរដំទៀលថា ។ កាលក្អែកចេញស៊ីលុះ កត្រីនោះមៀមកោក្តា មានសឹកកេកសា ទៀបអាត្មាកុំឃ្លាតឆ្ងាយ ។ ទឹកឡើងស្រមោចលង់ លុះចំណង់ត្រីសប្បាយ ស្រមោចក៏អន្តរាយ លុះចំណោរចំណាប់ល្អ ។ លុះទឹករីងស្ងួតទៅ ត្រីផងនៅអាត្មាមរណ៍ អានកអនន្តរ លុះចំណោរ ស្រមោចស្អួន ។ នេះមានពៀរវេរា ពីបុកបុកណាហោង សព្វហានពុំ ករុណ ហេតុចំណងពីព្រេងព្រឹទ្ធ ។ បានទុកបទទក់ទី បានជាក្តីបទចិត្តឯង ហេតុចិត្តវៀចវេរុន បង់ទ្រព្យឯងបទចិត្តស្រាល ។ រីអ្នកខ្ញញខ្ជិល ខ្ជាយ កុំបីឲ្យកាន់នូវការ ពាលាអន្ធពាល កុំឲ្យធម៌ឥតចិត្តបង់ ។ ពោះបានសត្វបក្សី ប្រកតីតិចស្លាប់បង់ រីក្តីដឹងសព្វអង្គ បើគិតផ្សង គំនិតបញ្ជាប់ ។ បើត្រាប់ឯតាំងយូ ត្រងត្រូពុំគួរត្រាប់ កុំយល់មួយ កណ្តាប់ ជាមួយទីងកំបង់ដៃ ។ កុំយល់សសោភា កុំបីថាជាខ្មៅក្រ បន្តិចនេះប្រពៃ គួរត្រាប់កុំបីភ្លេចឡើយ ។ ពោះបើដីបាត់ លោកបើ

:

ស្អាកក៏ជាត្រើយ តាមទឹងដំរីហើយ កុំបីដើរទឹងដើងលា ។ តោះខ្លួកដាច់
សាត់សោះ យកខ្លួកស្មោះទៅតាមគ្នា នេះពាក្យព្រេងលោកថា ទុកជា
ច្បាប់តម្រាប់កេរ្តិ៍ ។ រីអ្នកមានប្រាជ្ញា សង្រាកយល់ពុំថេរ ទុក្ខសោក
ក័យចំណោរ ប្រើផ្តាច់ផ្តិលទិកសស្ថាន ។ ស្រុកមានសឹកកុំបី ទៅជួញខ្ញី
រកធនធាន រីខ្លួនកំព្រាប្រាណ ក្រកក្សាខ្លួមាសប្រាក់ ។ ហោរយ៉េយ
តាំបែបូន ឥតតំបន់ណាទីងលាក់ ខ្លួនឯងឥតបើជាក់ សរពើទ្រព្យបាត់
អស់ឯង ។ តំបន់ទព័ព្រៃ កុំជ្ជិតនៅម្នាក់ឯងលេង ទឹកហូរពេងព្រែង
កុំបីអាលចុះខ្លួកផ្ងង ។ ក្រពើក្រពេញពាំ សាហាវចាំសព្វព្រែកផង
តាំតាប់ដោយបំណង បីដូចខ្យល់ទឹងភ្លៀងព្រៃ ។ ដរតែជសារធំ តុតារជុំ
ជាញដល់ទៃ ប្រែរត់បៀសពេញវៃ កុំយកខ្លួនទៅទប់ទល់ ។ កំឡាំង
តំបពិតអស្ត ឯងជាអ្នកឯណាយល់ ទើបបានខ្លួនទុំពិល លុះនៅដូលអាត្មា
មរណ៍ ។ ព្រះធម៌នេះជាច្បាប់ ប្រសើរគាប់ឲ្យអស់នរ អ្នកផងចាំបានបរិ-
បូណ៌ដល់ត្រៃពិធសួគ៌ហោង ។

ច្បាប់វិធុរបណ្ឌិតចប់តែប៉ុណ្ណេះ

ភូមិសាស្ត្រសង្ខេប

នៃនានាប្រទេស

# អំពីភូមិសាស្ត្រសង្ខេប នៃប្រទេសអល្លឺម៉ាញ

**ទីតាំងនិងអាណាខេត្ត** — ប្រទេសអល្លឺម៉ាញតាំងនៅចន្លោះប្រទេសបារាំងសែសនិងប៉ូឡូញ ។

**ទំហំដី** — ៤៧២.០៣៤ គីឡូម៉ែត្រក្រឡា ក្រោយមហាយុទ្ធសង្គ្រាម គឺសម្រេចតាំងអំពីឆ្នាំ ១៩១៩ មក តែក្នុងឆ្នាំ ១៩៤១ នេះ មហាយុទ្ធសង្គ្រាមនៅទ្វីបអឺរ៉ុបមិនទាន់ស្រេច កាលបើស្រេចហើយមុខជាមានការប្រែប្រួលយ៉ាងសំបើមមិនខាន ។

**ផ្ទៃផែនដី** — ប្រទេសអល្លឺម៉ាញមានផ្ទៃផែនដីមិនស្មើគ្នា តំបន់ខ្លះជាទីរាបខ្ពស់ តំបន់ខ្លះជាទីរាបទំនាប តំបន់ខ្លះជាទីមានភ្នំគ្របដោយព្រៃឈើធំៗ មានផ្ទៃផែនដីចែកជា ៤ ភាគគឺៈ

១ — ទីរាបខ្ពស់ក្នុងស្រុកបាវីយ៉ែរ, វ៉ឺតេមបែរគ៍និងបាដេន ។ ទីរាបខ្ពស់នេះចេញមកពីតំបន់ភ្នំអាល្ប៍ ហើយលាតចុះតាមទៅខាងជើងទន្លេដានូប ។

២ — ទីទំនាបជើងទន្លេរ៉ាំងត្រង់កណ្ដាលៗ ផ្ទៃផែនដីចំណែកនេះគ្របដោយភ្នំនិងទំនាបជើងភ្នំ មានដីដ៏ជាតិល្អ ។

៣ – ភាគកណ្ដាលរបស់ប្រទេសអល្លឺម៉ាញ ផ្ទៃដីភាគនេះប្រកបដោយជួរភ្នំវែងៗដូចភ្នំហារ៍សជាដើម តាមចង្កេះភ្នំដេរដាសដោយព្រៃឈើយ៉ាងស្ដុក ។

៤ – ទំនាបភាគខាងជើង ផ្ទៃដីភាគនេះជាចំណែកមួយនៃទំនាបធំរបស់ទ្វីបអឺរ៉ុប មានការណាខេត្តតាំងអំពីហុល្លង់រហូតដល់ប្រទេសប៉ូឡូញ មានដងទន្លេវែងៗ ហើយមានខ្ទេសាបធំៗជាច្រើននៅក្នុងទំនាបនេះ ផ្ទៃដីទិសខាងលិចដែលជាប់ព្រំប្រទល់នឹងប្រទេសបែលហ្ស៊ិក នឹងប៉េអី-បាស់ ជាទីមានដីជាតិល្អតែនៅខាងសមុទ្របាល់ទិក នឹងនៅខាងប្រទេសប៉ូឡូញជាដីល្បាយខ្សាច់ ។

៥ – ផ្ទៃដីភាគខាងជើងរបស់ប្រទេសអល្លឺម៉ាញមិនសូវមានដីជាតិទេ ពួកអ្នកស្រែគេប្រើជីដាក់ផងជាជីកប នៅទីដីមិនមានជីជាតិដូច្នេះគេប្រើដាំស្មៅ, ស្រូវនឹងដំឡូងបារាំង ។

៦ – ទន្លេសំខាន់របស់ប្រទេសអល្លឺម៉ាញមាន ៤ គឺទន្លេរ៉ាំង (១២៣៦ គ.ម.) ទន្លេអែលប៍ (១១០៤ គ.ម.) អូដែរ (៨៨០. គ.ម) វែស៊ែរ (៦០៨ គ.ម.) នឹងដានូប ជាទន្លេនៅប្រទេសអល្លឺម៉ាញ មានលក្ខណៈដូចទន្លេក្នុងប្រទេសបារាំងដែរ គឺមានទឹកហូរយឺតៗ ស្រួលដល់ការធ្វើដំណើរតាមទូក ហើយមានព្រែកជីកច្រើនហូរភ្ជាប់ទៅក្នុងសមុទ្រទិសខាងលិចទៀតខាងជើង ។

**ខ្យល់អាកាស** — នៅភាគខាងលិច, ខាងត្បូងនិងខាងជើងមានអាកាសមធ្យម នៅភាគខាងកើតមានអាកាសត្រជាក់ខ្លាំងក្តៅខ្លាំង មានភ្លៀងធ្លាក់តែល្មមសមគួរ នៅក្រុងវែលឡាំងមានភ្លៀងធ្លាក់ប្រមាណក្នុង ១ ឆ្នាំ ៥៨០ មិល្លីម៉ែត្រ នៅព្រៃព្រឹក្សានិងភ្នំមានភ្លៀងធ្លាក់ជាច្រើន ។

**ការដាំដំណាំ** — ប្រទេសអល្លឺម៉ាញមានការដាំដំណាំយ៉ាងសំបើម តែដំណាំដែលគេដាំជាច្រើនបំផុតនោះ គឺស្មៅសត្វ ស្រូវអូក្ស និងដំឡូងបារាំង បន្ទាប់មក គឺស្រូវប៊្លេ បែត្តរ៉ាវសម្រាប់ធ្វើស្ករ ដំឡូងបារាំងសម្រាប់ធ្វើស្រា ហូប្លុងសម្រាប់ធ្វើប៊ីយែរ និងស្រូវផ្សេងៗទៀតមានដាំជាច្រើននៅភាគខាងជើង ។ ស្ពៃដាំច្រើននៅភាគកណ្តាលនិងភាគខាងលិច ហូប្លុងដាំច្រើននៅក្នុងរដ្ឋបាវីយែរ ទំពាំងជូរដាំច្រើននៅត្រើយទិសខាងកើតនៃទន្លេរ៉ាំង ។

**លោហធាតុ** — ប្រទេសអល្លឺម៉ាញមានលោហធាតុជាច្រើន លោហធាតុសំខាន់បំផុតគឺធ្យូងថ្ម ដែលមាននៅទីទំនាបជិតទន្លេក្នុងខេត្តវេស្តហ្វាលី និងជិតទន្លេសារ៍ជិតប្រទល់ដែនបារាំងសែស ដែកមានច្រើនក្នុងខេត្តវេស្តហ្វាលី ក្នុងស៊ីលេស៊ីនិងស័ក្ស ស័ង្កសី (ច្រើនបំផុតក្នុងលោក) មានច្រើននៅក្នុងស៊ីលេស៊ី ជាតំបន់ព្រៃឈើនិងភ្នំហាស អំបិលមានច្រើននៅក្នុងស័ក្ស ប៉ូតាស្យូមមានច្រើនបំផុតក្នុងលោក នៅតំបន់

ស្ពាសហ្វ្រក៍ នៅទិសខាងលិចនៃខាងត្បូង ស្រុកម៉ុកដីប្លក៍ មាន លោហធាតុអស់នេះគឺ សំណកក់, សំណប៉ាហាំង, ទង់ដែង, ប្រាក់ នីន នីកែល ។

លោហធាតុសំខាន់បំផុតដែលដឹកបានក្នុង ព.ស. ២៤៨៣ មាន ចំនួនដូច្នេះ គឺធ្យូងថ្ម ២៨៩ លានតោន រ៉ែដែក ៤,៧៤១,២០៤ តោន (បានសាច់ដែក ១,៨៣៤,៣៣៨ តោន) រ៉ែស័ង្កសី ២៧៣,២៧៤ តោន (បានស័ង្កសី ១៣៨,៦៥៣ តោន) រ៉ែទង់ដែង ៨៤៤,៦១៩ តោន, ប៉ូ-តាសស្យូម ១,៣៥១,៤២០ តោន សំណ ១៨២,១៤០ តោន ទឹកប្រេង កាត ១៧៤,៣២៨ តោន ។

សត្វចិញ្ចឹម — ក្នុង ព.ស. ២៤៧៤ មានចំនួនដូច្នេះ ជ្រូក ២៣, ៧៨៣, ៤០០, គោ ១៩, ០៩០, ៩០០, កែះ ៧, ៤៩៥, ០០០ សេះ ៣.៤៧៧,៧០០ ពពែ ២,៥១៤,៤០០ ។

(នៅមានត)

# ពង្សាវតាររោម

(តទៅ)

ពិធីដែលគេនិយមធ្វើជានិច្ចនោះ គឺកាលបើបានជ័យជំនះហើយ ទាហានក៏ប្លន់ដណ្តើមយកទ្រព្យសម្បត្តិរបស់ប្រជាជនក្នុងស្រុកនោះៗ ទ្រព្យសម្បត្តិទាំងពួកឈ្លើយត្រូវនាំមកកាន់ក្រុងរោមហើយដាក់លក់ រឿងនេះរដ្ឋបាលជាអ្នកចាត់ការលក់ដូរ ហើយចែកយកចំណែកទុកជាចំនួនច្រើន សល់ពីនោះក៏ចែករំលែកទៅក្នុងពួកក្រុមទាហាន ហេតុនេះបានជាឃ្លាំងរបស់រដ្ឋបាលមិនសូវមានការខ្វះខាតៗ ជួនកាលកងការត្រូវបានទ្រព្យសម្បត្តិជាចំនួនច្រើនៗក៏មាន ដូចកាលក្រុងរោមច្បាំងឈ្នះពួកម៉ាសេដូន ទ្រព្យសម្បត្តិរបស់ឈ្លើយលក់បានចំនួនប្រហែល ៣០.០០០.០០០ ត្រណោក ឯរាស្ត្រប្រជាដែលមិនបានទៅច្បាំងក៏បានរួចខ្លួនមិនបាច់បង់ពន្ធដារ ពោលគឺកាលបើរដ្ឋបាលបានទ្រព្យសម្បត្តិរបស់ឈ្លើយមកជាច្រើនក្នុងវេលាណា រាស្ត្រប្រជាទាំងពួងត្រូវលើកលែងមិនបាច់បង់ពន្ធដារ១ឆ្នាំក្នុងវេលានោះៗ

ពួករោមមានពិធីប្លែកជាងជនជាតិបុរាណឯទៀតៗ ក្នុងការរក្សាអំណាចស្រុកចំណុះដែលខ្លួនវាយបាននោះឲ្យនៅជាប់ខ្លួនជានិច្ច ពោលគឺកាលបើទៅវាយស្រុកណាបាន ក៏រៀបចំដាក់ទាហានសាងបន្ទាយ ហើយក្រុម

ទាហានក៏មានគ្រួសារនៅប្រចាំក្នុងទីនោះ ប៉ុន្តែចែកទីដីសម្រាប់ធ្វើការរកស៊ីកាលតែក្លាយទៅជាប្រជាជនរបស់ស្រុកនោះ តែគង់នៅជាជាតិរ៉ូម៉ាំងដដែល ៗ ក្រៅពីនេះពួករ៉ូម៉ាំងនៅតែយកចិត្តទុកដាក់ធ្វើថ្នល់ ថ្នល់ដែលពួករ៉ូម៉ាំងកសាងទុកនោះ នៅតែប្រើការបានរហូតមកដល់សម័យនេះ ហើយអារ្យធម៌របស់ពួករ៉ូម៉ាំងក៏ផ្សាយចេញទៅគ្រប់ច្រកគ្រប់អន្លើនៅតាមខេត្រដែនដែលពួករ៉ូម៉ាំងធ្លាប់ធ្វើជានាយចៅហ្វាយត្រួតត្រាមកនោះ ៗ

## អំពីជ័យជំនះនៃក្រុងរោម

យើងបានដឹងហើយថា រោម នៅត្រង់ពាក់កណ្ដាលនៃប្រទេសអ៊ីតាលី ៗ ឯប្រទេសអ៊ីតាលីនេះ ជាប្រទេសសំខាន់បំផុត ក្នុងសមុទ្រមេឌីទែរ៉ាណេ ៗ ការដែលក្រុងរោមធ្វើចម្បាំងហើយមានជ័យជំនះ ត្រាតែបានធ្វើជាម្ចាស់លោកក្នុងសម័យនោះ គឺដំបូងចាប់ធ្វើការច្បាំងក្នុងប្រទេសអ៊ីតាលីខ្លួនជាមុនសិន ហើយក៏យកអាណាខេត្តឲ្យកាន់តែរីកធំចេញតទៅទៀត សរុបរួមជ័យជំនះរបស់ក្រុងរោមមាន ៣ ភាគគឺៈ

ក- ជ័យជំនះក្នុងប្រទេសអ៊ីតាលី ៗ

ខ- ជ័យជំនះនៅចំណែកទិសខាងលិច ខាងសមុទ្រមេឌីទែរ៉ាណេ

គ- ជ័យជំនះនៅចំណែកទិសខាងកើត ៗ

ក- ជ័យជំនះក្នុងប្រទេសឥតាលី. ចាប់ផ្តើមតាំងអំពីក្រុងរោមកសាងឡើងរហូតមកដល់ពុទ្ធសករាជ ២៧៧ ។ ពង្សាវតារមានហេតុសំខាន់ ២ ប្រការកើតឡើងក្នុងស្រុក គឺការដណ្តើមអំណាចគ្នារវាងពួកប្លេបេអ៊ីយាងនឹងពួកប៉ាទ្រីស្យាំង ។ ឯការខាងក្រៅស្រុកនោះ ពួករ៉ុ-ម៉ាំងមានជ័យជំនះប្រទេសឥតាលី តាំងអំពីជួរភ្នំអាប៉ែនណាំង (Apennins) រហូតដល់កោះស៊ីស៊ីល (Sicile) ។ ហេតុកេខសំខាន់ទាំងពីរប្រការនេះមានតគ្នាមករហូតរវាងវេលា ៤ សតវត្សរ៍ ហេតុនេះហើយបានជាបើកឱកាសឲ្យពួកប្លេបេអ៊ីយាងមានសេចក្តីស្មើភាគគ្នានឹងពួកប៉ាទ្រីស្យាំង ។

សង្គ្រាមដែលក្រុងរោមចាប់ផ្តើមធ្វើឡើងក្នុងជាន់ដំបូង ៗ នោះ គ្រាន់តែជាការពោមយកប្រទេសជិតខាង ជាភារកិច្ចរបស់ក្សត្រក្រុងរោមដែលទ្រង់ធ្វើសង្គ្រាមដើម្បីពង្រីកអាណាខេត្ត តាមដោយពិតនោះ ក្រុងរោមជាស្រុកតូចមានរូបរាង ៤ ជ្រុង មានទំហំដ៏មិនប៉ុន្មានគីឡូម៉ែត្រទេ ។ ព្រះបាទទុល្លុស,ហុស្ទីលិយុស (Tullus,Hostilius) ក្សត្រអង្គទី ៣ នៃក្រុងរោម បានរាតអាណាខេត្តចេញទៅផុតដែនឡាស្យូម (Latium) ។ ព្រះបាទអង្កុស (Ancus) ក្សត្រអង្គទី ៤ ទ្រង់ពង្រីកតទៅទៀតរហូតដល់ទន្លេទីប្រ៍(Tibre) ។ លុះដល់ក្សត្រអង្គនេះក្ស័យព្រះជន្មទៅ ក្រុងរោមក៏បានជាប្រមុខនៃស្រុកផ្សេងៗដែលបានមករួបរួមគ្នាមានចំនួនដល់៣០ ស្រុកៗ

# អំពីការប្រឆាំងតទល់នឹងអេទ្រុស្គ

គ្រាវេលាដែលក្រុងរោមបំបរបង់ក្សត្រ ចេញពីរាជសម្បត្តិនោះ ជាវេលាកើតចលាចលវឹកវរក្នុងនគរ ទើបពួកអេទ្រុស្គចូលមកវាយប្លន់ក្រុងរោម ដោយមានមេនាយកជាតិអេទ្រុស្គម្នាក់ឈ្មោះ ពរសេន្នា ត្រាតែពួករោម៉ាំងបរាជ័យ ហើយតាំងអំពីកាលណោះមក ក្រុងរោមក៏មិនបានធ្វើជាប្រមុខពួកឡាតាំងដូចកាលជាន់ដើម ប៉ុន្តែតមកវេលាក្រោយ ពួកក្រិកនឹកខ្លាចក្រែងពួកអេទ្រុស្គមានកំឡាំងអំណាចច្រើនហួសពេកទៅ ទើបរួមកំឡាំងគ្នាច្បាំងនឹងពួកអេទ្រុស្គ ហើយក្រុងរោមក៏របួតរួចពីកណ្តាប់ដៃពួកអេទ្រុស្គមកបាន ។ សង្គ្រាមគ្រានោះជាសង្គ្រាមដែលក្រុងរោមចាញ់ទេ តែជម្នាមនុស្សប្រាជ្ញគេនាំកលឧបាយបំបិទបំបាំងកេរ្តិ៍ឈ្មោះរបស់ខ្លួន វិធីដែលពួករោម៉ាំងលាក់បំពួនសេចក្តីអៀនខ្មាសក្នុងការចាញ់ចម្បាំងគ្រានេះ គឺគេតែងជានិទានចំលងរឿងព្រេងនិយាយពីសេចក្តីក្លាហានរបស់ជាតិរោម៉ាំងជាអនេកប្រការ ហួសវិស័យនឹងជឿបាន ។

(នៅមានត)

## សេចក្ដីប្លែកៗ

**ព្រះអវលោកិតេស្វរៈ** — អស់លោក-អ្នកមើលទស្សនាវដ្ដី ហើយធ្លាប់បានមើលសៀវភៅមគ្គុទ្ទេសក៍នគរ គង់បានជ្រាបរឿងរ៉ាវរបស់ព្រះពោធិសត្វអវលោកិតេស្វរៈ ឬព្រះលោកេស្វរៈ ដែលគេបានកសាងឡើងក្នុងអាណាចក្រខ្មែរកាលពីសម័យបុរាណ ៗ តាមដោយពិត រូបនេះជារូបទេវតាថែរក្សាប្រាសាទអង្គរ ទើបយើងឃើញរូបនេះនៅគ្រប់ខ្លោងទ្វារ នៅបរិវេណស្ថានបុរាណខ្មែរ ដូច្នេះជនជាតិខ្មែរត្រូវតែស្គាល់ឈ្មោះព្រះពោធិសត្វនេះ ដែលបុព្វបុរសរបស់ខ្លួនធ្លាប់គោរពបូជាមក ៗ ចុះឈ្មោះនេះតើបានសេចក្ដីដូចម្ដេច? សព្ទនេះបែកចេញជា ៣ បទគឺ អវ ១ បទ, លោក ១ បទ, ឥស្វរៈ ១ បទ, ប្រែថា ព្រះជាម្ចាស់តែងទ្រង់ពិនិត្យមើលសកលលោក ៗ តាមយោបល់របស់ពួកអ្នកកាន់ពុទ្ធសាសនាបែបមហាយានថា ព្រះជាម្ចាស់នេះតែងទ្រង់ទតមើលសត្វលោកដែលរងទុក្ខវេទនានៅលើដី ដែលនាំជីវិតឲ្យប្រឡូកប្រឡល់ដោយអកុសលកម្ម ព្រះភក្ត្រតែងងាកបែរទៅជុំវិញទិស ដើម្បីទតមើលសព្វសារពើទាំងពួងនឹងជួយសង្គ្រោះលោក ហេតុនេះហើយ បានជាគេធ្វើព្រះភក្ត្រ ៤ សម្រាប់ទិសទាំង ៤ ហើយប្រតិស្ឋានទុកគ្រប់ប្រាសាទនឹងតាមខ្លោងទ្វារប្រា-

សារអត្ថ ៗ មួយវិញទៀត គេហៅព្រះពោធិសត្វនេះថា "លោកនាថ" ប្រែថា ជាទីពឹងនៃលោក ជាព្រះធម្មទេសរបស់ព្រះពុទ្ធ ៗ តាមជំនឿរបស់ពួកមហាយាន ព្រះដែលមាននាមថា "អមិតាភៈ" ប្រែថា ព្រះពុទ្ធដែលមានរស្មីទ្រង់គិតគណនាពុំបាន ហេតុនេះហើយបានជាព្រះពោធិសត្វអវលោកិតេស្វរៈ មានរូបព្រះពុទ្ធស្ថិតនៅទីផ្នួងសក់ជានិច្ច ៗ

**អំពីខេត្តបេង្គលនៅប្រទេសឥណ្ឌា** - ខេត្តនេះនៅក្នុងចន្លោះទន្លេធំៗពីរ គឺទន្លេគង្គា និងទន្លេព្រហ្មបុត្រ ៗ នៅទិសខាងជើងខេត្តនេះមានព្រំប្រទល់នឹងខណ្ឌសីមាប្រទេសនេប៉ាល់ ដែលជាតំបន់ជាទីកើតនៃពុទ្ធសាសនា ទិសខាងលិចមានព្រំប្រទល់នឹងខេត្តនានានៅឥណ្ឌាកណ្តាល នៅទិសខាងត្បូងទល់នឹងសមុទ្រ ដែលជាឈូងសមុទ្របេង្គល ទិសខាងកើតជាប់នឹងខេត្តដែនភូមា ដែលជាប្រទេសកាន់ព្រះពុទ្ធសាសនា ៗ ក្នុងខេត្តបេង្គលសព្វថ្ងៃនេះ មានចំនួនអ្នកកាន់ពុទ្ធសាសនាតិចទេ ក្នុងចំពួកសាសនាផ្សេងៗនោះ ព្រះពុទ្ធសាសនានៅក្នុងជួរទី ៤ នៅចំណែកទិសខាងលិចនៃខេត្តនេះ បានទទួលលទ្ធិពុទ្ធសាសនាដែលជាពុសតល់ដើមរបស់សាសនា តែពួកពុទ្ធសាសនាសព្វថ្ងៃនេះជាពួកមហាយាន ហើយមានតែពួកមនុស្សដែលមកពីនេប៉ាល់ (ស្រុកដែលព្រះពុទ្ធកើត) និងមកពីប្រទេសទីបេតជាចំនួនច្រើន ៗ

លទ្ធិសាសនាហិណ្ឌូអ៊ីស្លាមបានបំបាត់ពុទ្ធសាសនាក្នុងតំបន់នេះឯង តំបន់នេះហើយដែលគេនាំវិធីគ្រប់គ្រងវណ្ណៈចូលមកផ្សាយ ហើយថែមទាំងមហាក្សត្របានជួយទំនុកបំរុងបីបាច់ទៀត ក៏ការប្រកាន់វណ្ណៈនេះ ហើយ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់បដិសេធៈពាលជាដំបូង ហើយទេវរូបផ្សេងៗក្នុងសាសនាព្រាហ្មណ៍ក៏បានមកនៅជិតខាងគ្នានឹងព្រះពុទ្ធរូបនៅជាមួយគ្នាទាំងពីរសាសនា ហើយសាសនិកជន (ទាំងពីរពួក) បាននាំគ្នាទៅគោរពពិធីបូជាយញ្ញទៀតវិញ ។

ឥឡូវនេះ ពុទ្ធិកសមាគមហៅថា "មហាពោធិ" បានចាត់បញ្ជូនគណៈធម្មទូតទៅទិសខាងកើតខេត្តបេង្គ៉ល (ដែលជាប់នឹងដីប្រទេសភូមា) ហើយចាត់ចែងដឹកនាំប្រជាជនមួយចំណែកឲ្យចូលក្នុងលទ្ធិសាសនាដ៏បរិសុទ្ធ ហើយគណៈធម្មទូតនេះបានធ្វើការប្រសើរណាស់ ទើបនាំឲ្យគណៈសង្ឃហីនយានចំរើនឡើងច្រើន ។

## ក្នុងព្រះពុទ្ធសាសនាមានព្រះជាម្ចាស់ឬគ្មានទេ?

មានអ្នកប្រាជ្ញម្នាក់ជាតិបែលស៊ិ ដែលបានខំទ្វិសជីវិតក្នុងការសិក្សាព្រះពុទ្ធសាសនាទាំងប៉ែកខាងមហាយានទាំងប៉ែកខាងហីនយាន លោកបានពិនិត្យមើលអំពីពាក្យចោទសួរខាងលើនេះ ហើយលោកបានគោលទុកថា ប្រសិនបើគេទុកពុទ្ធសាសនាតាមយោបល់ខាងបរមត្ថវិជ្ជា

វិញ លទ្ធិសាសនានេះមែនតែងទំនាស់នឹងគំនិតយោបល់និយាយអំពីទេព-វិសេសជាទន្ទឹមឬព្រះម្ចាស់សួគ៌ាតាមដែលពួកគេប្រកាន់យល់មកនោះ ។ ពួកពុទ្ធសាសនិកជនតែងជឿថា អំពើល្អអាចមានអំពើអាក្រក់មកចូលផង ហើយដណ្ដើមគ្នាឲ្យផលល្អ - អាក្រក់តែរៀងខ្លួន ពុទ្ធសាសនិកជនតែងសរសើរអំពីកិរិយាឈើចិត្តស្ដាយក្រោយ ត្រង់ការដែលខ្លួនធ្វើខុស ហើយលើកចិត្តគំនិតឲ្យប្រព្រឹត្តទៅតាមអំណាចនៃកម្ម ដែលគេទុកជាកំឡាំងខាងសតិបញ្ញា (ពាក់ព័ន្ធកិច្ចការទាំងពួង) ។

កាលបើមើលគម្ពីរបាលីជាច្រើនគម្ពីរទៅ គេយល់ច្បាស់ថា ទេវតាទាំងឡាយតែងគោរពព្រះព្រហ្ម ហើយព្រះព្រហ្មនៅក្រោមព្រះពុទ្ធទេ ។ ក្នុងគម្ពីរក្រោយ ៗ មករបស់ព្រះពុទ្ធសាសនា មានលក្ខណៈឃើញដាច់ស្រេចថាមិនមានព្រះម្ចាស់សួគ៌ ដែលទ្រង់កសាងនឹងតាក់តែងលោកនេះទេ ហើយលោកអ្នកប្រាជ្ញបានពោលអាងដល់រឿងមួយ ក្នុងគម្ពីរមួយជាភាសាសំស្ក្រឹតប៉ែកខាងមហាយាន ដែលព្រះថេរៈ ១ អង្គឈ្មោះសន្តិទេវៈបានតែងឡើងក្នុង ព. ស. ១១៩១ ។ សេចក្ដីនេះលោកបានដកស្រង់យកអំពីគម្ពីរហៅថា "ពោធិចរិយាវតារៈ" ឬដំណើរទៅកាន់ពោធិញ្ញាណដ៏សេចក្ដីក្រាស់ជើង ។ "ទេវតាជាវត្ថុហួសនឹងជឿតាមបាន សូម្បីតែគុណសម្បត្តិរបស់ទេវតាជាអ្នកកសាងលោកក៏ជាការជឿពុំបានដែរ . . .

ប្រសិនបើទេវតាធ្វើការៈដោយឥតចំណង់ទេ ក៏នៅតែប្រាកដថា ទេវតានេះជាពាសានៃលោក ប្រសិនបើទេវតានេះមានប្រាថ្នាផង ទេវតានេះក៏ទៅជាពាសានៃតណ្ហាដូច្នេះ នេះឬជាគុណសម្បត្តិរបស់ទេវតាជាអ្នកកសាងលោក" ។

## អំពីអាវុធកាំភ្លើងក្នុងសង្គ្រាមបុរាណ

### របស់ប្រទេសឥណ្ឌូស៊ីន

តាំងអំពី គ.ស. ១៩៣៦ ដែលកើតសង្គ្រាមរវាងខ្មែរនិងសៀម គេបេះប្រើអាវុធកាំភ្លើងក្នុងចម្បាំង ហើយនៅក្នុង គ.ស. ១៨៩៧ ពួកភូមាមានកាំភ្លើងធំប្រើហើយ ។ គ្រឿងអាវុធកាំភ្លើងនេះពួកអារ៉ាប់បាននាំចូលមកក្នុងជ្រោយប្រទេសមលេស៍ តាមផ្លូវស្រុកកុដ្ឋ ។ នៅក្នុងស្រុកចិនគេក៏បេះប្រើកាំភ្លើងធំនិងអាវុធកាំភ្លើងតាំងពី គ.ស. ១៩៤០ ។ ពាក្យខ្មែរថា "ម៉ារៀន" និងពាក្យសៀមថា "បារៀម" នោះសំដៅយកកាំភ្លើងធំ កំណើតពាក្យនេះមកពីពាក្យអារ៉ាប់ ផ្សាយចូលមកតាមប្រទេសមលេស ។ កំណើតដើមពាក្យមកពីពាក្យថា ម៉ារី, ម៉ារីយ៉ា (Marie, maria) ជាពាក្យអារ៉ាប់ប្រើហៅកាំភ្លើងធំ ព្រោះកាំភ្លើងធំដំបូងដែលពួកអារ៉ាប់ស្គាល់នោះជារបស់ដែលពួកគ្រិស្តប្រើការក្នុងទ្វីបអឺរ៉ុប ឯពាក្យថា ម៉ារី ទើបក្លាយជាឈ្មោះម្ដាយរបស់ព្រះគ្រិស្ត ។

# រឿងសេដ្ឋីបីនាក់

មាននិទានមួយដំណាលថា នៅក្នុងស្រុកមួយ មានសេដ្ឋីបីនាក់ សេដ្ឋីមួយនៅទិសខាងកើត សេដ្ឋីមួយនៅកណ្តាល សេដ្ឋីមួយទៀតនៅទិសខាងលិច ឯសេដ្ឋីនៅកណ្តាលមានកូនក្រមុំមួយរូបឆោមល្អ ទើបសេដ្ឋីនៅទិសខាងលិចចាត់ចែងបណ្តាការឲ្យគេទៅដណ្តឹងកូនក្រមុំសេដ្ឋីនោះ ជូនជាថ្ងៃដែលទៅដណ្តឹងនោះ សេដ្ឋីជាឪពុកមិននៅ តែម្តាយៗក៏ស្រុះស្រួលឲ្យកូនទៅសេដ្ឋីនៅទិសខាងលិច ៗ តមក សេដ្ឋីនៅទិសខាងកើតបានចាត់ចែងបណ្តាការឲ្យមនុស្សទៅនិយាយដណ្តឹងកូនក្រមុំសេដ្ឋីនោះដែរ តែគាប់ជួនថ្ងៃនោះនៅតែឪពុក ម្តាយទៅកាន់ទីដទៃ ឪពុកក៏យល់ព្រមឲ្យកូនទៅសេដ្ឋីទិសខាងកើត ឯប្រពន្ធពុំដឹងជាប្តីលើកកូនក្រមុំឲ្យទៅសេដ្ឋីនៅទិសខាងកើតឡើយ លុះដណ្តឹងស្រេចហើយក៏កំណត់ថ្ងៃរៀបមង្គលការជាមួយគ្នា ហើយសេដ្ឋីទាំងពីរនាក់ ចាត់អ្នកផ្ទះទៅមហារៀបគ្រឿងបណ្តាការក្រយាសំពះ នាំទៅជូនឪពុកក្មេកម្តាយក្មេក ស្រាប់តែទៅជួបប្រទះគ្នានៅផ្ទះឪពុកក្មេកម្តាយក្មេក ហើយតាំងដណ្តើមគ្នា មួយថាស្រីនេះជាប្រពន្ធអញ ម្តាយលើកឲ្យអញ ៗ សេដ្ឋីមួយទៀតថាស្រីនេះប្រពន្ធអញ ឪពុកលើកឲ្យអញ ៗ សេដ្ឋីទាំងពីរដណ្តើមគ្នាផ្ទុះហើយ ក៏នាំគ្នាទៅប្តឹងចៅក្រមសុំឲ្យចៅក្រមកាត់សេចក្តីនេះតើត្រូវបាន

នៅទាំងណា ឯអស់ពៅក្រុមអារកាត់សេចក្ដីនោះពុំបានឡើយ ទើបសេដ្ឋីទាំងពីរនាំគ្នាឡើងទៅក្រាបបង្គំទូលសេចក្ដីនោះ ដល់សម្ដេចព្រះមហាក្សត្រ ទើបព្រះអង្គមានព្រះបន្ទូលថា ហៃសេដ្ឋីទាំងពីរអើយ ហេតុដំណើរអ្វីក៏ប្រស្ដែងនាំគ្នាមកប្ដឹងប្ដល់? ទើបសេដ្ឋីនៅទិសខាងកើតក្រាបបង្គំទូលថា ខ្ញុំព្រះអង្គឲ្យគេទៅដណ្ដឹងកូនក្រមុំសេដ្ឋីម្នាក់ដល់ម្ដាយអាពុក តែជួនជាពុំជួបនឹងម្ដាយឡើយ ឃើញតែអាពុកៗក៏ព្រមឲ្យកូនមកខ្ញុំព្រះអង្គដាច់ស្រឡះហើយ ទើបខ្ញុំព្រះអង្គរៀបគ្រឿងបណ្ណាការក្រយាសំពះទៅប្រទះគ្នានៅមុខផ្ទះម្ដាយអាពុកនោះ ទើបដណ្ដើមគ្នាកើតជាក្ដី ហើយនាំគ្នាមកក្រាបទូលឲ្យទ្រង់ជ្រាបក្រោមលួងធូលីព្រះបាទនេះតែប៉ុណ្ណោះឯង ។ ទើបព្រះអង្គបន្ទូលដណ្ដឹងទៅសេដ្ឋីមួយទៀត ។ សេដ្ឋីនៅទិសខាងលិចក៏ក្រាបទូលថា ខ្ញុំព្រះអង្គឲ្យគេទៅដណ្ដឹងម្ដាយអាពុក តែជួនជាពុំឃើញអាពុកឡើយ ឃើញតែម្ដាយៗលើកឲ្យខ្ញុំព្រះអង្គជាស្រឡះហើយ ទើបខ្ញុំព្រះអង្គរៀបរណ្ដាប់ទៅសំពះ ស្រាប់តែប្រទះគ្នានៅមុខផ្ទះម្ដាយអាពុក ទើបដណ្ដើមគ្នាកើតជាក្ដី នាំគ្នាមកក្រាបទូលឲ្យទ្រង់ជ្រាបក្រោមលួងធូលីព្រះបាទដោយដំណើរអស់តែប៉ុណ្ណោះឯង ។ ទើបព្រះអង្គទ្រង់ព្រះចិន្ដាពិចារណាថាគួរឲ្យសេដ្ឋីដែលម្ដាយលើកប្រគល់ឲ្យ ដ្បិតម្ដាយបានបីថ្នមនឿយហត់លើសក្រៃលែងជាងអាពុក ហេតុដំណើរដូច្នោះ

ហោង ទើបទ្រង់វិនិច្ឆ័យថា ត្រូវឲ្យកូនក្រមុំទៅជាប្រពន្ធសេដ្ឋីនៅទិសខាងលិច ឯសេដ្ឋីនៅទិសខាងកើតដែលអាពុកលើកឲ្យនោះ មិនត្រូវបានទេ ព្រោះកូនស្រីអាពុកមិនសូវបានថែទាំដូចជាម្ដាយ ហើយព្រះអង្គមានបន្ទូលផ្សះផ្សាឲ្យសេដ្ឋីទាំងពីរចងមេត្រីនឹងគ្នាតរៀងទៅ ឯសេដ្ឋីទាំងពីរនាក់ក្រាបបង្គំទូលលាទៅកាន់លំនៅរៀងខ្លួនហោង ។

ចប់រឿងសេដ្ឋីបីនាក់តែប៉ុណ្ណោះ ។

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

ឆ្នាំគំរប់ ១៤ ភាគទី ៤

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ


ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨៤

គ. ស. ១៩៤២

# បញ្ជីរឿង

ទំព័រ


១ — រឿងព្រះបាទអសោកមហារាជ, អ្នកអាចារ្យ គិម-អាន ប្រែចេញពីភាសាបារាំង-
សែសមកជាភាសាខ្មែរ (នៅមានត) . . . . . . . . . . . . . . . . ៣

២ — ច្បាប់ទូន្មានខ្លួន . . . . . . . . . . . . . . . . . . . . ១០

៣ — ភូមិសាស្ត្រសង្ខេប នៃប្រទេសផ្សេងៗ: អំពីប្រទេសអាល្លឺម៉ាញ (តមក) . . ១២

៤ — ពង្សាវតារភេទ, ស្រង់យកអំពីពោសតារីកផ្សេងៗក្នុងពង្សាវតារលោក (តមក) ១៥

៥ — ប្រវត្តិពួកឧបាសក-ឧបាសិកា ជាសាវករបស់ព្រះពុទ្ធជាម្ចាស់: ទី៤ ប្រវត្តិរបស់
ហត្ថក-អាឡវក . . . . . . . . . . . . . . . . . . . . ១៧

៦ — រឿងមហាការតៈ (តមក) . . . . . . . . . . . . . . . . . ២១

៧ — រឿងព្រេងខ្មែរ: រឿងស្វាលួចមកុដស្ដេច . . . . . . . . . . . . . ២៤


## រូបក្រៅរឿង


រូបគជសីហ៍ខ្មែរ, រចនាបែបភ្នំគូលែន (ក្នុង ព. ស. ១៣៦៨) . . . . . . . . ១

# TABLE DES MATIÈRES

Pages

1. Légende de l'empereur Açoka de l'Inde antique. Traduit du français en Cambodgien par feu l'Achar KIM-ANN (à suivre)........................................ 3

2. Chbab Tounmean Khluon (bons conseils en vers)............ 10

3. Géographie sommaire de divers pays : L'Allemagne (suite).... 12

4. Histoire de Rome. Extraits de divers documents de l'histoire universelle (suite)........................................ 15

5. Vie des disciples laïcs du Bouddha. IV. La vie de HATTHAKA-ALVAKA........................................ 18

6. MAHĀBHĀRATA (sommaire. Suite)........................ 21

7. Conte populaire cambodgien inédit :

"Le singe voleur de la couronne du roi"...................... 24


HORS-TEXTE

Lions Khmèrs. Art du Kulên (1368 E. B.)................ 1

# សេចក្ដីជូនដំណឹង

## អំពីព្រះរាជបណ្ណាល័យ កម្ពុជា

គម្ពីរមន្តលក្ខទីបនីបាលី ព្រះរាជបណ្ណាល័យបានចាត់ចែងបោះពុម្ពចប់សព្វគ្រប់ហើយ ចែកចេញជា ៤ ភាគ គឺ ភាគទី ១ ដំឡៃ ១ ក្បាល ២រ.០០ ភាគទី ២ ដំឡៃ ១ ក្បាល ២រ.៥០ ភាគទី ៣ ដំឡៃ ១ ក្បាល ៣រ.០០ ភាគទី ៤ ដំឡៃ ១ ក្បាល ២រ.៧០ ។ អស់លោក-អ្នកសិក្សាគម្ពីរបាលីដល់ថ្នាក់មន្តលក្ខទីបនីហើយ សឹងមានសេចក្ដីត្រូវការគម្ពីរនេះទាំងអស់គ្នា ដូច្នេះ សូមចូលទៅជាវនៅព្រះរាជបណ្ណាល័យទីកន្លែងលក់សៀវភៅរបស់ព្រះរាជបណ្ណាល័យតាមត្រូវការចុះ ។

អស់លោក-អ្នកចុះឈ្មោះជាវព្រះត្រៃបិដកគង់មានសេចក្ដីទន្ទឹងចង់បើកព្រះត្រៃបិដកឲ្យបានឆាប់ៗរាល់គ្នា ចំពោះភាគថ្មីៗ តៗទៅ ដូច្នេះ ព្រះរាជបណ្ណាល័យសូមជូនដំណឹងថា ព្រះត្រៃបិដកភាគទី ៣២ (សុត្តន្តបិ-ដក) បានបោះពុម្ពសម្រេចហើយ សូមអញ្ជើញទៅបើកយកចុះ ។ ឯភាគទី ៣៣ - ៣៤ ទឹងតៗទៅនោះរោងពុម្ពកំពុងដេរកាត់ចងក្រងនឹងបោះពុម្ពជាលំដាប់តៗទៅឥតឈប់ខានទេ ។

✻

✻ ✻

ព្រះរាជបណ្ណាល័យបានបោះពុម្ពផ្សាយរឿងថ្មី ១ រឿងទៀតហើយ គឺមគ្គុទ្ទេសក៍នគរ ជាសៀវភៅនាំផ្លូវទៅមើលបុរាណស្ថាននគរវត្ត នគរធំ នៅខែត្រសៀមរាប ។ មគ្គុទ្ទេសក៍នេះមាន ២ ភាគ ភាគទី ១ និយាយពី

ពង្សាវតារសម័យបុរាណនៃក្រុងកម្ពុជា ទីក្រុងព្រះមហាក្សត្រសម័យនគរ មានសេចក្ដីរៀបរៀងតាមគោលហេតុផ្សេងៗដែលអ្នកប្រាជ្ញបានស្រាវជ្រាវកើតឃើញ ភាគទី ១ នេះ ១ ក្បាលដំឡៃ ០ រ.៦០ ។

ភាគទី ២ មានសេចក្ដីពន្យល់ពីផ្លូវដែលត្រូវទៅមើលប្រាសាទអស់នោះ ទីនិងចង្អុលបង្ហាញឲ្យដឹងច្បាស់ថា ប្រាសាទណាកសាងឡើងក្នុងសម័យណា ? ព្រះមហាក្សត្រអង្គណាទ្រង់កសាង? កសាងឡើងដើម្បីជាប្រយោជន៍អ្វី? ហើយបានចង្អុលបង្ហាញឲ្យយើងស្គាល់របបផែនប្រាសាទ ឬក្បាច់ចនាដែលកើតឡើងដោយស្នាដៃខាងពុទ្ធសាសនាព្រាហ្មណ៍ឬខាងពុទ្ធសាសនាមហាយាននិងហីនយានដោយឡែកថែមទៀតផង ។

ទៅខាងក្នុងសៀវភៅមគ្គុទ្ទេសក៍ភាគទី ២ នេះ មានរូបប្រាសាទនិងរូបផ្សេងៗ ជាច្រើន ហើយមានផែនទីសម្រាប់នាំផ្លូវទៅមើលបុរាណស្ថានផ្សេងៗ ជាអក្សរខ្មែរយ៉ាងច្បាស់លាស់ផង ទុកជាលោក-អ្នកមិនដែលអញ្ជើញទៅទស្សនាសោះ គ្រាន់តែមានផែនទីដែលខ្ជាស់ជាប់មកនិងមគ្គុទ្ទេសក៍ភាគទី ២ នេះ ក៏លោក-អ្នកអាចអញ្ជើញទៅមើលនគរវត្តនគរធំ ដោយខ្លួនឯងបាន មិនបាច់ផ្ទួនផ្លូវឬកាន់ច្រឡំឡើយ ។ សៀវភៅមគ្គុទ្ទេសក៍ភាគទី២ នេះដំឡៃ ១ ក្បាល ១ រ.២០ ។

សៀវភៅអស់នេះ មានលក់នៅព្រះពុទ្ធបណ្ណាល័យនិងកន្លែងលក់សៀវភៅរបស់ព្រះពុទ្ធបណ្ណាល័យទូទៅ ។



## រឿងព្រះបាទអសោក

## សេចក្ដីផ្ដើម

រឿងព្រះបាទអសោកមហារាជនេះ ជាសេចក្ដីរៀបរៀងនិងប្រែចេញមកពីភាសាបារាំងវិសេស របស់អ្នកអាចារ្យ គិម-អាន ដែលអនិច្ចកម្មទៅកាលពីថ្ងៃ ២៦ ដេសេម្ប្រ៍ ១៩៣៧ ដូចមានប្រវត្តិពិស្ដារនៅក្នុងសៀវភៅ "សាសនកិច្ចានុក្រមលេខ ២ ឆ្នាំ ១៩៣៨ នោះស្រាប់" ។

រឿងព្រះបាទអសោកនេះ អ្នកអាចារ្យ គិម-អាន បានរៀបរៀងប្រែកាលដែលខ្លួននៅបួសនៅឡើយ ប្រហែលនៅក្នុងរវាងឆ្នាំ ១៩៣៥ ជាឆ្នាំដែលខ្លួនបានចូលមកធ្វើការជាក្រុមជំនុំប្រែព្រះត្រៃបិដក ក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យ ។ លុះរៀបរៀងប្រែបានចប់ហើយបានយកសំណៅទៅប្រគល់ឲ្យក្រសួងពុទ្ធសាសនបណ្ឌិត្យ ដើម្បីឲ្យចាត់ការបោះពុម្ពផ្សាយតទៅ ។

លោកគ្រូអាចារ្យ គិម-អាន ធ្វើការជាក្រុមជំនុំព្រះត្រៃបិដកបាន ១ ឆ្នាំក៏លាចាកសិក្ខាបទដោយមានកើតរោគរបេងរ៉ាំរ៉ៃ តមក រោគនេះកាន់តែបណ្ដាលខ្លាំងឡើងៗ ក៏លាចេញពីមុខក្រសួងនេះទៀត ខ្លួនទៅនៅឯលំនៅដើមរបស់ខ្លួន ហើយដាក់អនិច្ចកម្មក្នុងឆ្នាំ ១៩៣៧ នៅភូមិវត្ត ព្រះទ្វារ ឃុំពង្រ ខេត្តកំពង់ចាំ ។

ក្រសួងពុទ្ធសាសនបណ្ឌិត្យសូមអរគុណដល់អ្នកអាចារ្យ គិម - អាន ដែលបានព្យាយាមប្រែរឿងព្រះបាទអសោកនេះ ហើយប្រគល់ឲ្យជាសម្បត្តិរបស់ក្រសួងពុទ្ធសាសនបណ្ឌិត្យ ។ សូមឧទ្ទិសជូនកុសលដែលជាផលនៃការបោះពុម្ពផ្សាយរឿងនេះ ចំពោះវិញ្ញាណក្ខន្ធរបស់អ្នកអាចារ្យ គិម-អាន សូមឲ្យបានទទួលឥដ្ឋមនុញ្ញផលតាមគាប់ចិត្តចុះ ។

## អារម្ភកថា

រឿងព្រះបាទអសោកនេះ អ្នកប្រាជ្ញទាំងឡាយបានតែងពីត្រឹមតតិយ-សង្គាយនាដរាបមក មានស្ទើរតែគ្រប់គម្ពីរដែលសំដែងអំពីព្រះពុទ្ធសាស-នាក្នុងភាសាបាលី, ភាសាសំស្ក្រឹតនិងភាសាឯទៀតៗជាច្រើន ហើយជារឿងមានឡាក់ហាន ដោយមានសិលាចារឹកជាគ្រឿងសំគាល់ច្រើនបំផុត ដ៏ដេរដាសក្នុងមជ្ឈិមប្រទេស នៅមានរហូតដល់មកសព្វថ្ងៃនេះ ។ ហេតុនោះបានជាពួកអ្នកប្រាជ្ញទៅទាំងលោកក្នុងប្រទេសធំៗ មានទ្វីបអឺ-រុបជាដើម ច្រើនតែចេះរឿងដំណាលព្រះបាទអសោកនេះគ្រប់ៗគ្នា អ្នកខ្លះបានឃើញតាមគម្ពីរបាលីឬសំស្ក្រឹត អ្នកខ្លះបានព្យាយាមស្ទុះស្វែងទៅដល់សិលាចារឹក ត្រង់ទីសំវេជនីយស្ថាននោះៗ ហើយថតផ្ដិតយកមកសរសេរជារឿងទុកក្នុងសៀវភៅទាំងឡាយជាច្រើន ដើម្បីជាប្រយោជន៍ដល់អ្នកអានមើល, សូម្បីគម្ពីរបឋមសម្ពោធិជាភាសាខ្មែររបស់យើងនេះ

ដែលធ្លាប់មានយូរណាស់មកហើយ  ក៏មានសេចក្ដីជំណាលដល់រឿងអ-សោកនោះខ្លះ  នៅត្រង់ខ្សែរាពេទ្ធដែលលោកអ្នកអានមើលធ្លាប់បានឃើញជាញឹកញយណាស់មកហើយ  ប៉ុន្តែមានសេចក្ដីមិនប្រហែលដល់ចប់សព្វគ្រប់ ។

ព្រោះហេតុដូច្នោះបានជាខ្ញុំប្រែរឿងព្រះបាទអសោកនេះ  អំពីសៀវភៅជាភាសាបារាំងសែសឈ្មោះ  ឡាឡេសង់ដឺឡាំប៉ឺរ័អសោក (La Légende de l'empereur Açoka, par J.Przyluski)  មកជាភាសាខ្មែរយើង  ព្រមទាំងបានផ្ទៀងផ្ទាត់ធៀបគ្នាតាមគម្ពីរបាលីនិងសំស្ក្រឹតថែមទៀត  ដើម្បីនឹងឲ្យបានត្រឹមត្រូវហើយជាប្រយោជន៍ដល់លោក-អ្នកមានប្រាថ្នាចង់ដឹងរឿងនេះឲ្យបានច្បាស់លាស់  ព្រោះព្រះបាទអសោកអង្គនោះ  ទ្រង់មានមហាករុណាដ៏ធំដល់លោកទាំងមូល  ទ្រង់បានធ្វើតតិយសង្គាយនាហើយផ្សាយព្រះពុទ្ធសាសនាដោយកំឡាំងព្យាយាមរបស់ព្រះអង្គ  ឲ្យតាំងនៅគប់ប្រទេស  រហូតដល់សុវណ្ណភូមិ (គឺប្រ-ទេសឥណ្ឌូចិនយើងនេះ)  ចំណែកខាងដែនកម្ពុជាយើងសោត  បើនឹងសង្កេតមើលទៅ  គង់ឃើញថា  កាលជាន់ដើមពួកអ្នកស្រុកកាន់សាសនាព្រាហ្មណ៍តមកកាន់ពុទ្ធសាសនាប៉ែកខាងមហាយាន  លាយឡំគ្នាដោយមានគ្រឿងសំគាល់នៅក្រុងនគរធំ  ដែលគេសាងឡើងជាន់ដំបូងនោះ  គេធ្វើសិលាចារិកជារូបពោធិសត្វខ្លះជាព្រះសិវព្រហ្មនឹងទេវរូបឯទៀតៗខ្លះ

នៅគ្រប់កន្លែងជាគ្រឿងសំគាល់ថា គេសាងឡើងដើម្បីបូជាដល់សាសនាទាំងពីរនោះពិត ៗ, ដល់មកខាងក្រោយគេកាន់របៀបតាមហីនយានវិញនេះហើយសំដែងឲ្យឃើញថាពុទ្ធសាសនាក្នុងប្រទេសយើងនេះ ក៏មានសាសនាជាប់តមកអំពីការឧបត្ថម្ភរបស់ព្រះបាទអសោកមហារាជនោះដែរ ព្រោះព្រះពុទ្ធសាសនាផ្សាយចូលមកប្រទេសឥណ្ឌូចិន (ឥណ្ឌូស៊ីននេះ) ដំបូងចូលមកប្រទេសភូមានិងមន ដោយព្រះថេរៈពីរអង្គ គឺព្រះសោណត្ថេរនិងព្រះឧត្តរត្ថេរ ដែលជាពួកព្រះថេរៈទាំងមួយពាន់ជាអ្នកធ្វើសង្គាយនាគ្រាទី ៣ ក្នុងក្រុងបាដលិបុត្រ កាលពីពុទ្ធសករាជ ៣០១ នៅក្នុងសេចក្ដីឧបត្ថម្ភរបស់ព្រះបាទអសោកអង្គនោះ តែប្រទេសឥណ្ឌូចិនជាន់នោះ ព្រះពុទ្ធសាសនាមិនបានចំរើនរុងរឿងប៉ុន្មានទេ ព្រោះពួកមនុស្សជាន់នោះនៅជឿសាសនាព្រាហ្មណ៍តាមទំលាប់ដើមរបស់ខ្លួនច្រើនណាស់នៅឡើយ លុះដល់ព្រះមហិន្ទត្ថេរជារាជបុត្រនិងនាងសង្ឃមិត្តាថេរីជារាជធីតានៃព្រះបាទអសោកអង្គនោះ ដែលបានទទួលភារៈមកប្រតិស្ឋានព្រះពុទ្ធសាសនានៅលង្កាទ្វីប (Ceylan) ក៏ពួកស្ដេចនិងមហាជននៅកោះលង្កានោះចុះបួសជាច្រើនហើយ បាននាំគ្នាប្រឹងជួយផ្សាយព្រះពុទ្ធសាសនាថែមទៀត ទើបព្រះពុទ្ធសាសនានៅប្រទេសឥណ្ឌូចិនយើងនេះរុងរឿងឡើងពេញបន្ទុកតាំងតែពីគ្រានោះមក មិនតែប៉ុណ្ណោះ ព្រះបាទអសោកអង្គនោះបានសាងព្រះស្តូប ៨៤.០០០ ទុកជាទីបូជនីយស្ថាន ព្រោះហេតុ

នោះ ពួកអ្នកប្រាជ្ញក្នុងទ្វីបឥរុបសព្វថ្ងៃនេះ បើគេចង់ដឹងរឿងព្រះពុទ្ធសាសនាឲ្យច្បាស់លាស់ ដែលជាសាសនាមានតឹកតាងនៅមានពិតនោះ គេច្រើនមើលសៀវភៅដំណាលអសោកគុលចក្រពត្តិ ដែលអ្នកប្រាជ្ញជាន់មុនបានចំឡងមកពីស្រុកឥណ្ឌ ឬពីស្រុកចិន ជួនកាលមានទាំងផ្ដិតយកអក្សរថ្មរបស់ព្រះបាទអសោកនៅទីសំវេជនីយស្ថានគ្រប់កន្លែងមកជាគ្រឿងសំគាល់ថែមទៀត ប៉ុន្តែអ្នកប្រាជ្ញទាំងឡាយដែលបានតែងគម្ពីរដីកា ឬសៀវភៅឡើងនោះ សឹងមានរបៀបពាក្យបានសរសេរទៅតាមសេចក្ដីយល់ផ្សេងៗគ្នាខ្លះ ដូចយ៉ាងរឿងព្រះបាទអសោកជារបស់ប៉ែកខាងឧត្តរនិកាយ ដែលយើងធ្លាប់ដឹងតាមគម្ពីរមហាវង្ស ដែលពួកព្រះ-ថេរៈនៅលង្កាទ្វីបបានចារឹកមកជាភាសាបាលីនោះ មានដំណើរសេចក្ដីប្លែកគ្នាខ្លះដោយអន្លើៗ អំពីរឿងព្រះបាទអសោក ដែលពួកខាងឧត្តរ-និកាយបានចារឹកទុកមកជាភាសាសំស្ក្រឹតនោះ តែបើទុកជាយ៉ាងនោះក៏ដោយ សូមលោក-អ្នកអានមើលកុំគប្បីសង្ស័យនឹងដំណើរសេចក្ដីប្លែកគ្នានោះ ត្រូវកំណត់យកតែសំណុំរឿងព្រះបាទអសោកមកជាប្រមាណ បើនៅតែមិនទាន់ចូលចិត្តស៊ប់ក្នុងរឿងនេះទេ ត្រូវសង្កេតឲ្យហ្មត់ចត់ ធៀបមើលតាមសិលាចារឹករបស់ព្រះបាទអសោក ដែលខ្ញុំបានដាក់មកក្នុងទំព័រក ៗ ទៅខាងមុខ គង់តែចូលចិត្តរឿងនេះច្បាស់លាស់ល្អឡើងមិនខាន ។

ក្នុងសៀវភៅនេះ ខ្ញុំមិនចង់ឲ្យឃ្លាតឆ្ងាយពីប្រយោគជាភាសាបារាំង

ច្បាប់ដើមនោះ បានជានៅត្រង់កន្លែងខ្លះ មានពាក្យផ្ទុយគ្នាលំបាកស្តាប់ ព្រោះភាសាបារាំងនឹងភាសាខ្មែរយើងមានដំឡើងពាក្យមិនស្មើគ្នា លំ-បាកនឹងរកពាក្យដាក់ឲ្យត្រូវចំគ្នាផង ហើយខ្លួនខ្ញុំសោតក៏បានរៀនសូត្រភាសាបារាំងនោះតិចតួចពេក មិនសមនឹងហ៊ានធ្វើការធំយ៉ាងនេះ ប៉ុន្តែដោយសេចក្តីប្រាថ្នាចង់ឲ្យពួកពុទ្ធសាសនិកជនជ្រាបរឿងនេះណាស់ បានជាខ្ញុំខំព្យាយាមរហូតដល់កើតជាសៀវភៅនេះឡើង តែក្នុងសៀវភៅបារាំងច្បាប់ដើមនោះ មានរឿងដ៏ឯទៀតៗ ចម្រុះជាច្រើន ដែលខ្ញុំមិនបានប្រែដាក់មក ខ្ញុំប្រែដកយកចំពោះតែរឿងអសោកមួយប៉ុណ្ណោះ ។

ក្នុងសៀវភៅនេះចែកជាពីរចំណែក ខាងដើមហៅថា (បកិណ្ណកនិ-ទាន) គឺនិទានរាយរាយដែលជាប់ទាក់ទងដល់រឿងព្រះបាទអសោកនោះដែរ ប៉ុន្តែមិនមានសេចក្តីហួរហែដោយសព្វគ្រប់ គ្រាន់តែដកយករឿងដែលខុសគ្នាមកជាត្រៀងសំគាល់ហើយវិនិច្ឆ័យសេចក្តីនោះៗខ្លះ ខាងចុងហៅថា "រឿងព្រះបាទអសោក" គឺជាផ្លូវរឿងនៃស្តេចអង្គនោះ មានតាំងពីកាលកសាងជម្រុងឡើងរហូតដល់បានជាស្តេចចុល្លចក្រ ហើយនឹងស្តេចដ៏ណាខាងក្រោយព្រះបាទអសោកនោះមកខ្លះ ខ្ញុំប្រមូលទាំងពីរចំ-ណែកឲ្យឈ្មោះសៀវភៅនេះថា "រឿងព្រះបាទអសោក" នៅតាមច្បាប់ដើមដដែល ប៉ុន្តែនៅមិនទាន់ខ្ចុកចិត្ត ក្រែងមិនត្រឹមត្រូវ ខ្ញុំបានយកសៀវភៅនេះទៅប្រគេនព្រះមហា ហ. ហ្វូត ក្រុមជំនុំប្រែព្រះត្រៃបិដក

ក្នុងពុទ្ធសាសនបណ្ឌិត្យ នៅព្រះរាជបណ្ណាល័យ សូមឲ្យលោកជួយពិនិត្យសម្រួលពាក្យខ្មែរជាមួយនឹងខ្លួនខ្ញុំថែមទៀត ដើម្បីជម្រះមន្ទិលគឺសេចក្ដីឃ្លៀងឃ្លាតអំពីច្បាប់ដើម ។

លោកអ្នកអានមើល "រឿងព្រះបាទអសោក" នេះ គង់នឹងបានប្រទះសេចក្ដីខ្លះដែលខុសគតិរបស់ព្រះពុទ្ធសាសនា ដូចរឿងយក្សចូលបួសជាដើម ដែលខ្ញុំរក្សាទុកតាមច្បាប់ដើម តែបើតាមរឿងនេះគួរនឹងសន្និដ្ឋានថា យក្សមិនមែនជាអ្វី គឺមនុស្សជំពូកមួយដែលមានឈ្មោះយ៉ាងនោះ ឬជានាមសម្រាប់ហៅអ្នកដែលគួរគោរព ព្រោះពាក្យថា យក្ខ ឬ យក្ស នេះ មកពីរូបធាតុថា (យជ) ប្រែថា "បូជា" ហេតុនេះបានជាហៅបានហូតដល់ពួកមនុស្សទេវតា, អ្នកតាជាដើម ។

ម្យ៉ាងទៀត ជាធម្មតារបស់អ្នកតែងសៀវភៅដែលជាប់ទាក់ទងដល់វិជ្ជាការឬប្រវត្តិព្រះពុទ្ធសាសនា តែងតែឧទ្ទិសសៀវភៅដែលខ្លួនតែងបូជាដល់បុព្វការីបុគ្គលឬជូនដល់ញាតិមិត្រដែលខ្លួនស្រឡាញ់រាប់អានជាទីបំផុត ដែលមានជីវិតរស់នៅឬសូម្បីធ្វើមរណកាលកន្លងហួសទៅហើយក៏បាន ទើបខ្ញុំប្រគេនសៀវភៅនេះជាសក្ការបូជាចំពោះព្រះតេជព្រះគុណព្រះឧត្តមមុនី (អ៊ុំ-ស៊ូរ) ដែលលោកមានឧបការៈដល់ខ្ញុំជាអនេកប្រការសមគួរដែលខ្ញុំនឹងលើកបូជាដល់លោកមុនបុគ្គលដទៃ ៗ ។ (មានត)

អាចារ្យ គិម-អាន

# ច្បាប់ទូន្មានខ្លួន

## បទព្រហ្មគីត

១ មនុស្សកាចកុំប្រែសព្វ កុំទៅកប់ទីងហោះឃើយ គេចាប់ចងទៅក្រោយ វាយបណ្ដើរយល់អប្រិយ ។ កុំគប់ទីងខ្ញុំគេ កុំបៀតខ្សែខ្វល់ទីងស្រី កុំដួញទីងមន្ត្រី ទីងខាតខុនធនឯងហោង ។ កូនអើយអាពុកបា ទីង១បមាមួយទៀតហោង បាស្ដាប់ត្រាប់ត្រងរង ទុកទូន្មានអង្គឥន្ទ្រិយ ។ គេដើរកុំអាលបាញ់ បើស្រឡាញ់កុំឲ្យខ្ចី សូវឲ្យស្មោះពៅថៃ ទៅគន់ជាគ្នាយើនយូរ ។ សូវចូលកុំឲ្យចេញ សូវឲ្យទិញកុំឲ្យដូរ សាច់ញាតិឲ្យប្រមូល កុំស្រដីពាក្យសល់រលៃ ។ មនុស្សកាចកុំបីប្រើ ការក្រៅធ្វើកុំឲ្យសល់ ខែកខានកុំឲ្យយល់ ពាក្យបញ្ឆោះកុំឲ្យមាន ។ ពាក្យខុសកុំឲ្យស្ដាប់ សេចក្ដីគាប់ឲ្យគិតឲ្យាន អំពើបាបកុំឲ្យមាន សីលទីងទានឲ្យរះគិត ។ សីលសោតខ្នួរកេរ្តិ៍ ខំប្រាជ្ញាឲ្យបានជិត ពិបាកឲ្យគន់គិត កេន់និតគិតឲ្យដល់ ។ ស្អប់គេកុំអាលថា មានប្រាជ្ញាឲ្យចេះយល់ ពាក្យកួតស្ដាប់គួរឆ្ងល់ មានកន្ទល់កុំអាលថែង ។ ពាក្យក្រកុំអាលប្រាប់ ពាក្យឥតសព្វកុំអាលថ្លែង ពាក្យពិតកុំឲ្យថែង ពាក្យពិតស្មែងពុំគួរលោក ។ គេប្រាប់កុំអាលក្រោធ គេបញ្ចោតកុំអាលភ្ញាក់ សឹកដេញកុំអាលបាក់ គ្នាជំពាក់ប្រែដោះសា ។ គេតេកុំអាលដេញ គេ-លើកចេញកុំអាលថា សឹកដល់កុំអាលធ្លា ពួកពាកុំអាលយក ។

គេប្រើកុំអាលទៅ គេឲ្យហៅកុំអាលមក គេឲ្យកុំអាលយក គេសង្ស័ក កុំអាលថយ ។ ខ្លួនតូចកុំទំពារ ខ្លួនអ្នកជាកុំគិតល្មោភ ឲ្យគិតក្រែង ក្រក្រោយ ខ្លួនខ្វះខ្សោយទ្រព្យាម្ក ។ ទំនៀមទំនងព្រេង ច្បាប់ ថ្លាថ្លែងដោយក្រឹត្យក្រម ពាក្យនេះជាឧត្តម ចូរចាំ ៗ ត្រងត្រាប់ ។ សង្កាត់គេស្រុក ដូញលលក់ទិញតាមច្បាប់ ខ្សត់ភ្លនឃ្លានស៊ីស្លាប់ កុំខុសច្បាប់ព្រះធម្ម ។ មានទ្រព្យផ្សិតសំណាង ជាតិមុនសាង ទានសីលា ទើបកើតជាតិនេះណា មានទ្រព្យធនផ្សំគាំទ្រគេ ។ បើខ្លួន មានស័ក្តិបុណ្យ បានទ្រព្យធនខ្ញុំពលរេហ៍ ត្រូវចិត្តឲ្យត្រង់ត្រែ ជាតិទៅ មុខទើបបានទៀត ។ ស៊ីបានវនឹងខំ លោភលន់យងគេបៀនបៀត បំបាត់ទ្រព្យគេធ្វៀត ខុសច្បាប់ផងមិនទេឡើយ ។ ល្អតែនៅលោកិយ លុះផុតក្ស័យជីវិតហើយ ទល់ទុក្ខពុំផុតស្បើយ រូបវិនាសកម្មវេទនា ។ ព្រះទ្រង់ទេសនាមក គួរតែយកទុកសិរសា មនុស្សសត្វផងក្ដីណា ពុំដែលរៀរពីក្ដីស្លាប់ ។ គួរតែសាងសីលទាន នោះនឹងបានបុណ្យ លាភបាប គេប្រស័លដកប នោះប្រសើរពេកកូនអើយ ។ អស់ទ្រព្យ សម្បត្តិនៅ មិនបានទៅតាមខ្លួនឡើយ មានតែសីលទានហើយ ទៅ កិដរហូតលោកខាយ ។ អស់ទាំងគ្រឿងរបស់ ខ្ញុំស្រីប្រុសផងទាំងឡាយ គេនឹងទានចោលនៅកាយ ជារបស់គេសល់នៅ ។

(នៅមានត)

# ភូមិសាស្ត្រសង្ខេប

## នៃនានាប្រទេសក្នុងលោក

### អំពីភូមិសាស្ត្រសង្ខេបប្រទេសអាល្លឺម៉ាញ (តទៅ)

ហត្ថកម្ម— ប្រទេសអាល្លឺម៉ាញមានរោងហត្ថកម្មច្រើនជាងប្រទេសទាំងអស់ក្នុងទ្វីបអឺរ៉ុប លើកលែងតែប្រទេសអង់គ្លេសចេញ ព្រោះប្រទេសអាល្លឺម៉ាញបរិបូណ៌ដោយលោហធាតុផ្សេងៗជាច្រើន ទាំងការសិក្សារបស់ប្រជាជនសោតទៀតក៏ចំរើនឡើងច្រើនដែរ ។ កេរ្ត្រកម្មរបស់អាល្លឺម៉ង់ក៏ចំរើនកើនជាងនានាប្រទេសជាច្រើន ជនជាតិអាល្លឺម៉ង់ដាំបែត្តិកវែសម្រាប់ធ្វើស្ករច្រើនបំផុតក្នុងលោក ដាំស្រូវសេកជាទី ២ ស្រូវប៊ីជាទី ៣ ស្រូវអូតជាទី ៤ ។

រោងម៉ាស៊ីនឧស្សាហកម្មមានចំនួនដូចនេះគឺ រោងតម្បាញសំពត់ ១៦៦.៩៨៧ រោងឧស្សាហកម្មធ្វើដែក ១៥០.៦៩៩ ដោយច្រើនតាំងនៅក្នុងតំបន់ទន្លេរ៉ែយហ៍ទឹងទន្លេរ៉ូងក្នុងរដ្ឋព្រុស្ស៊ី, រោងធ្វើក្រដាសនិងគ្រឿងបោះពុម្ពចំនួន ៣៤.៧៦៤, រោងការឈើចំនួន ៦១៩.៣៣៤ រោងធ្វើគ្រឿងកែវនិងចានចំនួន ៣៤.៨៩៨ បរិស័ទសមាគមជីកលោហធាតុចំនួន ៦.៩៦៦ សមាគម. រោងធ្វើស្ករ ៦៣៣, រោងធ្វើស្រា ៣៨.១៨៦ ។

**ការធ្វើជំនួញនឹងនានាប្រទេស**— ប្រទេសអល្លឺម៉ាញធ្វើជំនួញលក់ដូរនឹងប្រទេសផ្សេងៗ ទូទៅក្នុងលោក ប្រទេសដែលលក់ដូរជាមួយនឹងអល្លឺម៉ង់ជាច្រើនគឺ អង់គ្លេស សហរដ្ឋអាមេរិក, ហុល្លង់, បារាំង-សែស, ទួរគី, ដាណឺម៉ាក, ស៊ុយអែត, ជប៉ុន, អាសង្ទីន, ប្រាស៊ីល នឹងចិន ។

**ជំនួញដែលលក់ចេញគឺ**— គ្រឿងដែក, គ្រឿងចក្រយន្ត, ស្ករ (ច្រើនបំផុតក្នុងលោក), ធ្យូងថ្ម, ក្រដាស, ល័ក្ខជ្រលក់សំពត់នឹងថ្នាំលាបឈើ, គ្រឿងសំលៀកបំពាក់ធ្វើដោយសូត្រ-អំបោះ, រោមសត្វ, ទង់ដែង, កញ្ចក់, គ្រឿងកែវ, គ្រឿងគីមី, ប្រដាប់ធ្វើដោយស្បែកសត្វ, ប្រដាប់សរសេរ នឹងឡាប៊ីយ៉ែរ ។

**ជំនួញដែលនាំចូលមកលក់គឺ**— កប្បាស, ជ័រ, សូត្រ, ថ្មៃ, ឈើ, រោមកែះ, ស្បែកសត្វ, កាហ្វេ, ទង់ដែង, ធ្យូងថ្ម, ស្រូវ ។

**ផ្លូវគមនាគម**— ប្រទេសអល្លឺម៉ាញមានផ្លូវគមនាគមល្អបំផុតក្នុងទ្វីបអឺរ៉ុប មានផ្លូវរថភ្លើងប្រវែង ៦៧.៨៦០ គីឡូម៉ែត្រ ផ្លូវរថអគ្គិសនី (រថអៃ) ៦.៤១៤ គីឡូម៉ែត្រ (រថអៃនេះស្រុកខ្មែរយើងមិនទាន់មានប្រើទេ) ផ្លូវថ្នល់មានច្រើន មានប៉ុស្តិ៍ទូរលេខ, ទូរសព្ទ, វិទ្យុទូរលេខ នឹងការហោះហើរតាមផ្លូវអាកាសមានគ្រប់គ្រាន់បរិបូណ៌ទាំងអស់ ។ មានព្រែកជីក

សំខាន់មួយសម្រាប់ភ្ជាប់សមុទ្រខាងជើងនឹងសមុទ្របាល់ទិកក្នុងខេត្តហូ-ស្តាំង ហៅថាព្រែកជីកគីយែល បណ្ដោយ ៩៨ គីឡូម៉ែត្រ ទទឹង ៦៤ ម៉ែត្រ មាននាវានានាជាតិចេញចូលតាមព្រែកជីកនេះចំនួន ៥៣.៥៤១ ក្នុង ព.ស. ២៤៧៣ ។

ប្រជាជន — បណ្ដាជនអាល្លឺម៉ង់មានចំនួន ៦៦ លាន (ព.ស. ២៤៧៦) គិតបែងចែកក្នុង ១ គីឡូម៉ែត្រក្រឡាមានចំនួនមនុស្ស ១៤១ នាក់ ។

សាសនា — ប្រជាជនអាល្លឺម៉ង់នៅភាគខាងជើងកាន់សាសនាគ្រិស្តនិកាយប្រូតេស្តង់ជាចំនួនច្រើន ។ ឯពួកអាល្លឺម៉ង់នៅភាគខាងត្បូងកាន់និកាយរ៉ូម៉ាំងកាតូលិក ។ ចំនួនមនុស្សកាន់និកាយប្រូតេស្តង់ជាង ៤០ លាន ក្រៅពីនេះជាពួករ៉ូម៉ាំងកាតូលិក ។

ស្រុកកំពង់: ហាំបួគ - ជាស្រុកកំពង់ធំបំផុតរបស់អាល្លឺម៉ង់ ។

ប្រេម — ជាស្រុកកំពង់សំខាន់ទី ២ ។

គីនិក្សប៊ែក - ជាកំពង់សំខាន់របស់រដ្ឋព្រុស្សទិសខាងកើត ។

គីយែល — ជាស្រុកកំពង់នៃទាហានជើងទឹក ។

ស្តេតាំងនិងលុយប៊ិក - ជាស្រុកកំពង់បន្ទាប់ ។

ទីក្រុងសំខាន់ៗ: ប៊ែរឡាំង-(ចំនួនមនុស្ស ៤ លាន) ជាទីក្រុងធំ ។

(នៅមានទៀត)

កាលបើក្រុងរ៉ូមតាំងខ្លួនប្រាណបានឡើងវិញហើយ ក៏ចាប់ផ្តើមធ្វើសង្គ្រាមនឹងប្រទេសជិតខាងជាវេលាយូរតទៅទៀត ទើបក្រុងរ៉ូមបានចាប់ផ្តើមគិតគូរឲ្យប្រាក់ខែដល់ពួកទាហាន ព្រោះទាហានត្រូវទៅធ្វើចម្បាំងប្រចាំនៅក្នុងកងទ័ពជាវេលាយូរ មិនអាចបែងពេលវេលាទៅរកអាហារចិញ្ចឹមជីវិតដោយខ្លួនឯងបាន ។

## អំពីការសង្គ្រាមតទល់នឹងពួកគោល្វ៉ាស៍ (Gaulois)

ជ័យជំនះរបស់ក្រុងរ៉ូមគាំងតែឈប់បន្តិចទៅវិញ ដោយមានពួកគោល្វ៉ាស៍លើកទ័ពទន្ទ្រានចូលមកលុកលុយក្រុងរ៉ូម នៅថ្ងៃ១៨ ស៊ីយេត មុនគ្រិស្តសករាជ ៣៩០ (ព.ស.១៥៣) ជាថ្ងៃដែលពួកទាហានរ៉ូម៉ាំងត្រូវទាហានគោល្វ៉ាស៍សម្លាប់អស់ជាចំនួនច្រើន ថ្ងៃនេះហើយជាថ្ងៃដែលពួករ៉ូម៉ាំងប្រកាន់ថាជាថ្ងៃមានគ្រោះថ្នាក់ដោយពួកទាហានគោល្វ៉ាស៍លុកលុយចូលមកកាន់យកបានទីក្រុងរ៉ូម ហើយដុតផ្ទះសំបែងអ្នកស្រុកនិងសម្លាប់មនុស្ស [illegible] ក្រុងរ៉ូមគាំងបរាជ័យចម្បាំង ១ គ្រាទៀត [illegible] តែនៅរៀងព្រែនយ៉ាងអស្ចារ្យ ដើម្បី [illegible] ចម្បាំង ។

កាលដែលពួករ៉ូម៉ាំងចាញ់ចំបាំងពួកគោល្វ៉ាស៍គ្រានេះ ត្រូវពិន័យជាមាសចំនួន ១ ពាន់លីវ្រ៍ លុះពួកគោល្វ៉ាស៍ទៅផុតហើយ រ៉ូម៉ាំងជាអ្នកមានលក្ខណៈខ្លាំងពូកែជានិច្ច ក៏ត្រឡប់តាំងខ្លួនបានឡើងវិញយ៉ាងស្រួល ហើយផ្ដើមច្បាំងលុកលុយប្រទេសឥតាលីតទៅទៀត បានច្បាំងឈ្នះពួកក្រិកដែលមកតាំងភូមិលំនៅប្រទេសឥតាលី ១ ពួក មានក្សត្រគ្រីកផ្សេងទ្រង់ព្រះនាមពីរុស (Pyrrhus) ។ សង្គ្រាមគ្រានេះក៏ចាត់ជាសង្គ្រាមធំមួយដែរ យើងគួរដឹងថា ក្នុងគ្រានោះជាគ្រាដែលពួកទាហានប្រើដំរីធ្វើចម្បាំងក្នុងទ័ពទាហាន ព្រះបាទពីរុសមានពល ២៥.០០០ នឹងពលដំរី ២០ ។ គ្រានោះ ពួករ៉ូម៉ាំងមិនទាន់ចេះវិជ្ជាស្ទុះដំរី ទើបច្បាំងយកជ័យជំនះព្រះបាទពីរុសមិនសម្រេច គ្រាន់តែខំការពារយ៉ាងរឹងមាំ ព្រះបាទពីរុសក៏ទ្រង់យល់ថា មុខគួរស្ងប់ស្ងៀមណាស់ដែរ ហើយទ្រង់យល់ថា ការច្បាំងឲ្យឈ្នះពួករ៉ូម៉ាំងគង់មិនសម្រេចជាក្រាកដ ទើបបញ្ជូនរាជទូតឲ្យទៅនិយាយសុំសន្តិភាពនឹងរដ្ឋមន្ត្រី តែសភាសេណាត់នៅក្រុងរ៉ូមមិនព្រមទទួលស្ពានមេត្រីរបស់ព្រះបាទពីរុស ដោយបានពោលតបថា បើព្រះបាទពីរុសនៅតែមានកងទាហានប្រចាំនៅក្នុងដែនដីឥតាលីដរាបណា ក្រុងរ៉ូមមិនព្រមទទួលមេត្រីជាដាច់ខាត ។ លុះព្រះបាទពីរុសទ្រង់ជ្រាបសេចក្ដីនេះហើយ ទើបទ្រង់លើកទ័ពទៅវាយកោះស៊ីស៊ីល ហើយទ្រង់វាយយកកោះនោះបាន ។

ក្នុងខណៈដែលព្រះបាទពីរុសគង់នៅកោះស៊ីស៊ីលនោះ ពួករ៉ូម៉ាំងខំប្រឹងប្រែងសមហាត់វិធីតស៊ូដីរ ។ លុះព្រះបាទពីរុសលើកទ័ពត្រឡប់មកចូលក្នុងខែត្រឥតាលី ក៏ត្រូវពួករ៉ូម៉ាំងវាយខ្ទេចខ្ទីបាក់បែកអស់ទៅ ក្នុង ព.ស. ២៦៨ (មុន គ.ស. ២៧៥) ព្រះបាទពីរុសក៏ទិវង្គតទៅ តែមិនមែនដោយហេតុត្រូវអាវុធក្នុងចម្បាំងទេ ដោយដូនជាមានស្ត្រីចាស់ម្នាក់ ចាប់ក្បឿងគ្រវែងចុះមកពីដំបូលត្រូវព្រះបាទពីរុសត្រង់ទីដំណាំក៏ក្ស័យព្រះជន្មទៅ ។

## ១ — អំពីជ័យជំនះនៅទិសខាងកើតសមុទ្រមេឌីតេរ៉ាណេរ

កាលបើក្រុងរ៉ូមបានប្រាបប្រាមព្រះបាទពីរុសស្រេចហើយឈ្មោះថាអស់សឹកសត្រូវហើយនៅប្រទេសឥតាលី ទើបក្រុងរ៉ូមមានអំណាចខ្លាំងខ្ពស់ឡើង តែនៅមានប្រទេស ១ ទៀតជាគូប្រណាំងប្រជែងយ៉ាងសំខាន់នឹងក្រុងរ៉ូម គឺប្រទេសកាថាស៍ ហេតុនេះបានជាក្រុងរ៉ូមនឹងកាថាស៍ត្រឡប់ទៅជាសត្រូវនឹងគ្នាយ៉ាងធំឡើង ក្រុងរ៉ូមមិនធ្លាប់មានសត្រូវនឹងជាតិណាឲ្យសាហាវស្មើនឹងកាថាស៍នេះឡើយ ។ ឯសង្គ្រាមរវាងក្រុងរ៉ូមនឹងកាថាស៍នេះ មានឈ្មោះហៅក្នុងពង្សាវតារម្យ៉ាងទៀតថា សង្គ្រាមពុយនិក (Les guerres puniques) សង្គ្រាមនេះតោងធ្វើជាវេលាយូរអង្វែងដល់ទៅ ១១៩ ឆ្នាំ គឺតាំងអំពីពុទ្ធសករាជ ២៧៩ ដល់ពុទ្ធសករាជ ៣៩៧ ។

(នៅមានត)

៤ — ហត្ថក - អាឡវក - លោកនេះតាមប្រវត្តិមានសេចក្តីដំណាលថា លោកកើតក្នុងស្រុកអាឡវី ដែនអាឡវី ចាប់ប្រតិសន្ធិក្នុងរាជត្រកូល ដូចមានរឿងដំណាលថា ថ្ងៃមួយ ព្រះបាទអាឡវកៈ (ជាជនករបស់ហត្ថក-អាឡវកៈនេះ) ស្តេចចេញទៅប្រពាតព្រៃ សម្លាប់ធ្វាន ម្រឹគសមដូចព្រះរាជបំណងហើយ ទ្រង់កាត់វះស្រេចហើយទ្រង់យកដងព្នងមក ស្តេចទ្រង់ព្រះរាជដំណើរមក រួយស្រពន់អស់ព្រះកំឡាំងណាស់ ទើបស្តេចចូលផ្ទកក្រោមម្លប់ឈើ ១ ដើមធំ មានស្លឹកដ៏ល្អត្រឈឹងត្រឈៃ ដោយទ្រង់ព្រះចិន្តាថា គ្រាន់តែសម្រាកឲ្យបាត់នឿយហត់ប៉ុណ្ណោះ ។

ក្នុងមួយស្របក់នុះ យក្សដែលអាស្រ័យនៅទីនោះមិនប្រែស្រាប់តែមកចាប់ព្រះហស្តព្រះមហាក្សត្រជាប់ហើយគម្រាមថា នឹងស៊ីទ្រង់ជាអាហារ ។ ព្រះរាជាទ្រង់តក់ស្លុតខ្លាំងក្រៃណា មិនទ្រង់បរល់ឧបាយដែរ ទើបទ្រង់សន្យានឹងយក្សថា សូមឲ្យតែយក្សដោះលែងទ្រង់ចុះ ទ្រង់នឹងបញ្ជូនមនុស្សមកឲ្យយក្សបរិភោគមួយថ្ងៃម្នាក់ព្រមទាំងថាស ១ ជាស

ផង ៗ យក្ខក៏លែងទ្រង់ទៅ លុះស្ដេចត្រឡប់មកវិញហើយ ទ្រង់ចាត់បញ្ជូនអ្នកទោសម្នាក់ព្រមទាំងបាយ ១ ថាសផងផ្ញើទៅឲ្យយក្ខរាល់ ៗ ថ្ងៃ ទ្រង់ធ្វើតែដូច្នេះត្រាតែអស់អ្នកទោសក្នុងគុក ។ ស្រុកទេសវេលានោះកើតវរើក បណ្ដារាស្ត្របានគេចរត់ទៅក្នុងដែនដទៃទៀតអស់ទៅជាចំនួនច្រើន ៗ លុះពួករាជបុរសចាត់រកមនុស្សផ្ញើឲ្យទៅយក្ខមិនបាន ទើបក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាប ទ្រង់មានព្រះបន្ទូលឲ្យយកអាឡវកកុមារដែលទើបប្រសូតបានមួយថ្ងៃនោះទៅឲ្យយក្ខ ។

នៅវេលាព្រឹកព្រហាមក្នុងថ្ងៃនោះ ព្រះបរមសាស្ដាទ្រង់ពិចារណាមើលសត្វលោក បានទ្រង់ជ្រាបហេតុការណ៍នោះបានហើយ ទើបស្ដេចទៅទូន្មានអាឡវកយក្ខ ត្រាតែយក្ខនោះបានសម្រេចសោតាបត្តិផល ។ នៅពេលនោះរាជបុរសក៏នាំអាឡវកកុមារ នឹងបាយ ១ ថាសយកទៅឲ្យអាឡវកយក្ខ ៗ មានសេចក្ដីអៀនខ្មាសពុំហានទទួល ទើបព្រះអង្គមានព្រះពុទ្ធដីកាថាទទួលចុះ អាឡវកយក្ខក៏ទទួលពីដៃរាជបុរសទៅ ហើយដាក់ថ្វាយលើព្រះហស្តព្រះបរមសាស្ដា ៗ ទ្រង់ទទួលហើយ ទ្រង់ប្រទានទៅអាឡវកយក្ខ ៗ ក៏ប្រគល់ឲ្យទៅរាជបុរសវិញ ។ អាស្រ័យហេតុដែលផ្លាស់ប្ដូរដៃគ្នាយ៉ាងនេះ ទើបព្រះរាជកុមារមាននាមថា ហត្ថក-អាឡវកៈ ។

កាលព្រះសាស្តាទ្រង់នាំអាឡវកយក្សចូលទៅក្នុងស្រុកអាឡវីនោះ ព្រះបាទអាឡវីកទ្រង់ចេញទៅទទួលព្រះអង្គ មហាជនក៏ភ្ញាក់ផ្អើលមកមើលជាច្រើន ។ ឯហត្ថក-អាឡវកកុមារកាលចំរើនវ័យឡើងបានសម្រេចមគ្គផលដល់ថ្នាក់អនាគាមិ បានឃុំគ្រងបរិស័ទជាច្រើន ។ ព្រះសាស្តាត្រាស់សួរអំពីហេតុដែលកៀរចិត្តបរិស័ទ បានក្រាបទូលស្នងព្រះពុទ្ធដីកាថា សង្គ្រោះបរិស័ទដោយសង្គហវត្ថុ ៤ យ៉ាង អាស្រ័យហេតុនេះទើបព្រះបរមសាស្តាទ្រង់តាំងលោកក្នុងដំណែងឯតទគ្គៈខាងការកៀរទឹកចិត្តបរិស័ទដោយសង្គហវត្ថុ ៤ ប្រការ ។

ចប់ប្រវត្តិសង្ខេប របស់ហត្ថក-អាឡវក តែប៉ុណ្ណេះ ។

មហាភារតៈ

( តមក )

យុធិស្ឋិរៈបានគ្រងរាជសម្បត្តិឡើងវិញ ។ ក្នុងសៀវភៅទី ១០ និយាយអំពីសេចក្តីស្លាប់របស់ក្រិស្ណៈ ហើយគេពោលសារស័ព្ទអំពីដំណើរពួកបាណ្ឌុលះបង់រាជធានីលើផែនដី ដើម្បីឡើងទៅកាន់ស្ថានសួគ៌ ។ តមកទៀត ពាក្យកាព្យនេះគេបានបន្ថែមសៀវភៅ១ទៀតហៅថា ហរិវង្សៈ ឬវង្សត្រកូលរបស់ព្រះវិស្ណុ-ហរិ ឯសេចក្តីបន្ថែមនេះកើតឡើងប្រហែលក្នុង ព.ស. ៦៥០ ។

សេចក្តីសំខាន់នៃរឿងមហាភារតៈនេះ ជារបស់ធំសំបើមណាស់សម្រាប់ពង្សាវតារនៃបរមត្ថវិជ្ជា-សាសនា-ចំណេះចេះដឹងតាមពង្សាវតារ-ភូមិសាស្ត្រក្នុងសម័យនោះ ព្រមទាំងចំណេះចេះដឹងខាងកិច្ចការចិញ្ចឹមជីវិតក្នុងប្រទេសឥណ្ឌាសម័យបុរាណ ។

ក្នុងទីនេះ យើងលើកយកតែពាក្យកាព្យ ១ វគ្គក្នុងពួកកាព្យអស់នោះ ដែលមានក្នុងរឿងមហាភារតៈហៅថា ភគវទ្គីតា យើងសូមស្រង់យកពាក្យកាព្យដែលជាសេចក្តីប្រែជាភាសាបារាំងសែស ដែលមានសារសព្វក្នុងអារម្ភកថា ដែលលោកអ្នកប្រែបានសរសេរទុក ដើម្បីបង្ហាញពាក្យកាព្យដ៏សំខាន់នេះ ដល់អស់ពួកអ្នកមើលរឿងមហាភារតយុទ្ធ

កាលពីពុទ្ធសករាជ ២៤៩០ ឯសេចក្តីសរសេរក្នុងអារម្ភកថានោះ ដូចមានសេចក្តីប្រែខាងក្រោមនេះ៖

"សៀវភៅនេះមានប្រយោជន៍សំខាន់បំផុត ដែលកើតឡើងដោយស្នាដៃរបស់មនុស្សលោក ។ គ្មានរណាមួយបានពោលទុកដោយពិស្តារ អំពីគោលសំខាន់ៗនៃធម្មជាតិចិត្ត សឹងមានអាការដ៏ធំទូលាយនិងខ្ពង់ខ្ពស់ថ្កុំថ្កើងស្មើនឹងបរមត្ថដ៏ឥតស្មើឡើយ ។ សីលធម៌ដែលហូរចេញពីសៀវភៅនេះ ជារបស់ល្អវិសេសរកអ្វីប្រៀបពុំបាន មិនមែនត្រឹមសីលធម៌ទទេ គឺគេបានប្រតិបត្តិតាមសីលធម៌ហ្នឹងម៉ឺងម៉ាត់ផង សីលធម៌នេះហើយដែលនាំឲ្យមនុស្សស្រឡាញ់ជាប់ចិត្ត តាមធម្មជាតិរបស់មនុស្ស ហើយជាខន្តិធម៌របស់មនុស្សផង ។

ដូច្នេះយើងត្រូវតែមើលសៀវភៅនេះ និងចិញ្ចឹមជីវិតដោយសៀវភៅនេះៗ ហើយដែលយើងត្រូវការយ៉ាងធំបំផុត ។

សមាគមចំណោះជនទាំងនេះថ្មី ដែលយើងគង់ចាំងរៀបចំតាមក្រិត្យសាសនានោះ ស្រួតែតាំងទៅលើការគិតតែប្រយោជន៍ផ្ទាល់ខ្លួន ឬប្រយោជន៍ផ្ទាល់ខ្លួននៃសាគរទៀត ក៏រៀវត្ថុបស្តុះស្តើងណាស់ ។ ការដែលនាំឲ្យមនុស្សលោកសព្វថ្ងៃមានអាការក្រហួលនេះ គឺមនុស្សទាស់ដំណើរខ្លួនគ្នានឹងគ្នា ពួកនេះទាស់នឹងពួកនោះ មកតែពីការគិតប្រយោជន៍

ផ្ទាល់ខ្លួនជាប្រមាណ ។ កម្រមានណាស់ អ្នកដែលគិតលះបង់ប្រយោជន៍ខ្លួន ដើម្បីជាប្រយោជន៍ដល់អ្នកដទៃ (គ្រាន់តែធ្វើឲ្យបានសម្រេចប្រយោជន៍ខ្លួន តែកុំឲ្យខូចប្រយោជន៍អ្នកដទៃក៏រកបានក្រដែរ) ។

មនុស្សយើង·ច្រើនតែត្រូវការសេចក្ដីសប្បាយភ្លើតភ្លើនក្នុងជីវិត ហើយមិនត្រូវការឲ្យការសប្បាយនេះខូចបង់ទៅផងជាធម្មតា ឯការធ្វើអំណោយអំពីមួយដល់អ្នកទីទាល់ក្រនោះ គ្រាន់តែជួយបន្ធូរសេចក្ដីក្រតោកយ៉ាក មិនមែនជួយស្រោចស្រង់ឲ្យមានឋានៈខ្ពស់ឡើងឡើយ ។

ឯការបះបោរចលាចលធំៗក្នុងលោកនោះ បណ្ដាជននាំគ្នាបះបោរឡើង ដើម្បីបំបាត់លទ្ធិដែលគិតតែប្រយោជន៍ខ្លួន ដែលកន្លងមកហើយនោះឯង ។ ការបះបោរនេះ លើកយកមនុស្សចំនួនច្រើនគ្របសង្កត់ចំនួនតិច ហើយផ្ដាក់ផ្ដិលរំលោភគ្រប់ប្រការរបស់មនុស្សចំនួនតិច ។ ឯការបះបោរចលាចលនេះមិនមែនដឹកនាំឲ្យកើតគោលសំខាន់នៃសីលធម៌ថ្មី សម្រាប់សាធារណជននិងកុសលធម៌ផ្ទាល់ខ្លួនឡើងទេ ។

(នៅមានត)

# រឿងពានរលួចព្រះមកុដ

មាននិទានមួយដំណាលថា មានព្រះមហាក្សត្រាធិរាជមួយព្រះអង្គ តែងស្ដេចទៅប្រពាតព្រៃទេព្រាន ហើយដោះព្រះមកុដទុកក្នុងប្រអប់មាស ឲ្យស្ត្រីម្នាក់ថែរក្សានៅនាព្រះពន្លាភាគ ហើយព្រះអង្គស្ដេចចេញទៅបរបាញ់ជាមួយនឹងអស់សេនាយោធាពលផង ស្ត្រីចាំរក្សាព្រះមកុដនោះងុយដេកក៏ដេកលក់ទៅ ។ កាលនោះមានពានរមួយចុះពីដើមឈើមក ឃើញស្ត្រីនោះដេកលក់ពុំដឹងខ្លួនប្រាណ ក៏បើកប្រអប់លួចព្រះមកុដយកទៅពាក់បង្អួតគ្នាលេងលើមែកឈើ រួចលាក់ទុកទៅ ។ ស្ត្រីនោះភ្ញាក់ឡើងឃើញប្រអប់បើក បាត់តាំងមកុដផង ក៏គិតភ័យក្រៃលែង គិតថាខ្លួនមុខជាស្លាប់ដោយព្រះរាជអាជ្ញាជាប្រាកដ ។ រត់រកព្រះមកុដពុំឃើញឡើយ ហើយស្រែកទ្រហោយំ លុះមហាក្សត្រស្ដេចមកអំពីបរបាញ់ ស្ត្រីនោះក៏ក្រាបទូលដោយដំណើរអំពីងងុយដេកៗលក់ទៅមានចោរលួចព្រះមកុដបាត់ ។ ព្រះអង្គឲ្យសេនាយោធាមាត្យដើររកសព្វអន្លើ ស្រាប់តែប្រទះឃើញទៅនេសាទម្នាក់កាន់ស្នាដើរបរបាញ់សត្វយកទៅលក់ចិញ្ចឹមជីវិត ។ សេនាយោធាមាត្យចាប់ទៅនេសាទនាំបណ្ដើរមកក្រាបទូលព្រះរាជាថា អានេះឯងជាចោរលួចព្រះមកុដ ហើយដាក់ឲ្យក្រសួងតុលាការជំនុំជំរះ ។ ចៅក្រមពិចារណាសួរទៅនេសាទនោះ វាឆ្លើយថា ខ្ញុំពុំបានលួចព្រះមកុដទេ ខ្ញុំស្ទង់រកបរបាញ់សត្វក្នុងព្រៃទេតើ ខ្ញុំពុំបាន

មកជិតព្រះពន្លានេះទេ ។ ទៅក្រមក្រាបទូលព្រះមហាក្សត្រថាក៏នេះ ឯងជាចោរកំណាច ឥតនរណាមួយមកជាន់ព្រៃនេះឡើយ មិនបាច់ជំនុំអ្វីទេ គ្រាន់តែចាប់សួររកព្រះមកុដឲ្យឃើញប៉ុណ្ណោះបានហើយ ។ ទើបព្រះអង្គបង្គាប់ឲ្យចាប់ទៅទេសាចនោះ ទៅទេសាចនោះពុំមែនជាចោរលួចទេ តែឈឺណាស់ទីងអត់ទ្រាំពុំបាន ក៏ស្រែកថា ម្ចាស់ខ្ញុំអើយ ខ្ញុំជាចោរលួចព្រះមកុដមែន ខ្ញុំយកទៅឲ្យមហាសេដ្ឋី ដ្បិតមហាសេដ្ឋីប្រើខ្ញុំឲ្យមកលួចគាត់ទីងឲ្យគ្នាន់ខ្ញុំ ។ ព្រះមហាក្សត្របានជ្រាបហើយ ឲ្យទៅចាប់មហាសេដ្ឋីយកមកពិចារណា មហាសេដ្ឋីឆ្លើយថា ទូលព្រះបង្គំជាខ្ញុំពុំបានប្រើទៅទេសាចនេះឲ្យលួចព្រះមកុដទេ ។ ទើបពួកទៅក្រមក្រាបបង្គំទូលថា ត្រូវឲ្យចាប់មហាសេដ្ឋីៗត្រូវតែនាបឈឺខ្លាំងណាស់ទីងអត់ទ្រាំតទៅទៀតពុំបាន ក៏ឆ្លើយថា ម្ចាស់ខ្ញុំអើយ ខ្ញុំប្រើទៅទេសាចនេះឲ្យលួចព្រះមកុដមែន តែខ្ញុំយកទៅឲ្យផ្ញើខាន់ទៅបុរោហិតទៅហើយ ។ ទើបទៅក្រមក្រាបបង្គំទូលឲ្យចាប់បុរោហិតនោះមកពិចារណាទៀត ។ ឯបុរោហិតឆ្លើយថា ម្ចាស់ខ្ញុំអើយ មហាសេដ្ឋីនេះពុំបានយកព្រះមកុដមកឲ្យខ្ញុំឡើយ ។ ទើបពួកទៅក្រមក្រាបបង្គំទូលឲ្យចាប់បុរោហិតនោះទៀត បុរោហិតពុំដឹងខ្លួនពិតមែន តែត្រូវតែនាបឈឺខ្លាំងណាស់ទីងអត់ពុំបាន ក៏ស្រែកថា សូមឲ្យម្ចាស់បន្ធូរតែនាបបន្តិចហើយឆ្លើយថា ម្ចាស់ខ្ញុំអើយ មហាសេដ្ឋីយកព្រះមកុដមកឲ្យខ្ញុំមែន តែខ្ញុំយកទៅទុកឯព្រៃខ្មោចទៅ

ហើយ ទើបត្រាស់បង្គាប់ឲ្យរកកែងនៃព្រៃខ្សាន ក៏ឥតមានគេរកឃើញ ឡើយ ហើយត្រាស់បង្គាប់ឲ្យតាមទៀត ៗ

គ្រានោះ ព្រះពលសេនាឡើងទៅក្រាបថ្វាយបង្គំគាល់ ទូលសព្វ សាំតែបុរោហិត, មហាសេដ្ឋី និងចៅនេសាទ ទៅស្រែកយំពេញផ្លូវ មិញ ក៏កើតគិតដោយព្រួយថា បើព្រះអង្គនៅតែឲ្យតាមដល់ផ្ទះ បុរោហិត មហាសេដ្ឋីនិងចៅនេសាទ នេះមុខជាស្លាប់មិនខាន ឯព្រះមកុដក៏បាត់ ពុំឃើញ ទើបក្រាបបង្គំទូលសូមយកសេចក្ដីនេះទៅពិចារណា ៗ ព្រះអង្គទ្រង់ព្រះកជានុញ្ញាត បើកឲ្យព្រះពលសេនា យករឿងនេះទៅជំនុំ ពិចារណាជាមួយនឹងពួកសេនាបតី ព្រះពលសេនានូវសេនាបតីក៏នាំជន ទាំង ៣ នាក់ទៅឃុំក្នុងរោងមួយមានជញ្ជាំងជិត ៗ លុះវេលាយប់ ឲ្យ ស៊ើបទៅលបលាក់ខ្លួនពួនចាំស្ដាប់ពីក្រៅជញ្ជាំងកុំឲ្យអ្នកទាំងបីដឹងខ្លួន ៗ គ្រានោះមហាសេដ្ឋីស្រដីថា ហេតុដែលអញត្រូវគេនាំចាប់ឃុំដល់ម្ល៉េះព្រោះ តែចៅនេសាទនេះឯង អើចៅនេសាទ ចុះអញប្រើទៅឲ្យលួចព្រះមកុដ ពីអង្កាល់ ទាំឲ្យលោកធ្វើក្ដីលំបាកដល់អញយ៉ាងនេះ? ឯចៅនេសាទ ឆ្លើយថា លោកអើយ ខ្ញុំពុំបានលួចព្រះមកុដមកឲ្យលោកទេ តែគេតាប ខ្ញុំលើណាស់ទឹងអត់ទ្រាំពុំបាន ទើបខ្ញុំឆ្លើយដាក់លោកឲ្យបានរួចខ្លួនមួយ គ្រាសិន ៗ ឯបុរោហិតក៏ស្រដីទៅនឹងមហាសេដ្ឋីថា អើអ្នកឯងសោត បានយកព្រះមកុដទៅឲ្យអញពីអង្កាល់?- មហាសេដ្ឋីឆ្លើយថា ម្ចាស់ខ្ញុំ

អើយ គេគាបខ្ញុំឈឺណាស់ទីងអត់ទ្រាំពុំបាន ទើបខ្ញុំឆ្លើយដាក់អ្នក ហើយ សេដ្ឋីសួរទៅបុរោហិតវិញថា ចុះបំណែកខាងអ្នកខ្ញុំពុំបានឲ្យព្រះមកុដទេ ម្ដេចក៏អ្នកថាឲ្យ ហើយថាយកទៅទុកឯព្រៃឧទ្យាន ឲ្យគេទៅរកពុំឃើញ ដូច្នេះៗ បុរោហិតឆ្លើយថា អ្នកអើយ លោកពុំដំទុំពិចារណាឲ្យអស់សេចក្ដី ស្រាប់តែឲ្យគាបឈឺណាស់ ខ្ញុំបះតែថាឲ្យរួចតែពីមាត់ទៅឲ្យលោកបន្ធូរ ផ្ទើមបន្តិចប៉ុណ្ណោះទេ ។

ឯសៀននោះស្ដាប់ឮជាក់ហើយ ក៏កត់ពាក្យចៅនេសាទ មហាសេដ្ឋី នូវបុរោហិត យកទៅជូនព្រះពលសេនានូវសេនាបតីៗដំទុំពិចារណា យល់ថាចៅនេសាទមហាសេដ្ឋីនូវបុរោហិតនោះពុំមែនជាចោរទេឡើយ ហើយ ព្រះពលសេនាឲ្យជាងធ្វើព្រះមកុដកែវមាសមួយដូចព្រះមកុដពីមុនយក ទៅថ្វាយព្រះមហាក្សត្រ ទ្រង់អញ្ជើញស្ដេចទៅប្រពាតព្រៃឧទ្យានម្ដង ទៀត ទុកព្រះមកុដដូចដែលហើយឲ្យស្ត្រីដែលនោះថែរក្សា ផ្ដាំថាឲ្យ ធ្វើជាដេកលក់ហើយមើលបំណាំ ថាបើមានចោរមកលួចព្រះមកុដម្ដង ទៀត ឲ្យស្រែកអាក្រោស ៗ លុះទ្រង់ផ្ដាំស្ត្រីនោះស្រេចហើយ ព្រះពលសេនាក៏ឲ្យសេនាយោធាមាត្យពួនឃ្លាំល្បាតមើលជុំវិញ ហើយ ព្រះអង្គស្ដេចចេញទៅបញ្ចាញ់ ។

ពានរនៅដែលនោះចុះមកអំពីចុងឈើ ទៅគន់មើលស្ត្រីនោះយល់ថា ដេកលក់ពុំកំរើកខ្លួនឡើយ ក៏បើកប្រអប់លួចព្រះមកុដយកទៅពាក់កំបន្ទិត គ្នាតោះលើចុងឈើ ទើបស្ត្រីនោះស្រែកថា ពះអាស្វាលួចព្រះមកុដ ៗ ឯអស់សេនាយោធាមាត្យដែលចាំល្បាតក៏រត់មកជាញាប់គ្រប់គ្នា ស្រែកថាស្វាលួចព្រះមកុដទម្លាក់ក្នុងទ្រូឈើ លុះព្រះមហាក្សត្រមកដល់ព្រះពន្លា ហើយស្ត្រីនូវអស់សេនាយោធាមាត្យក្រាបបង្គំទូលតាមដំណើរនុះសព្វគ្រប់ ព្រះមហាក្សត្រទ្រង់បង្គាប់ឲ្យឡើងទៅមើលនៅទ្រូឈើនោះ ឃើញព្រះមកុដទាំងចាស់ទាំងថ្មី យកមកថ្វាយព្រះអង្គ ៗ ព្រះអង្គមានព្រះបន្ទូលថា ស្វានេះទេតើ សេចក្តីនេះ បើព្រះពលសេនាពុំបានមកដំនុំពិចារណាទេ សមទៅក្រុមផងទាំងនេះគេពុំឃើញឡើយ មុខជាឲ្យគាបបុរោហិតនូវមហាសេដ្ឋី នឹងទៅនេសាទត្រាតែស្លាប់បង់ទៀត ឯព្រះមកុដអញក៏នឹងបាត់អសារ ៗ

ព្រះអង្គមានបន្ទូលដូច្នោះហើយ ទ្រង់ប្រទានពរសព្វសាធុការដល់ព្រះពលសេនាជាអស្ចារ្យនានាកណ្តាលដំនុំធំនោះហោង ៗ

ចប់រឿងពានរលួចព្រះមកុដតែប៉ុណ្ណេះ ។

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

ឆ្នាំគំរប់ ១៤ ភាគទី ៥

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៦

គ.ស. ១៩៤២

# បញ្ជីរឿង

*ទំព័រ*


១ – រឿងព្រះបាទធម្មាសោករាជ អ្នកអាចារ្យ ជិម – អាន ប្រែចេញពីភាសាបា-
រាំងសែសមកជាខេមរភាសា (តមក)................ ៣

២ – ច្បាប់ទូន្មានខ្លួន (តមកនឹងចប់)................ ៨

៣ – ប្រស្នាចំរើនសតិបញ្ញា: ប្រស្នាទី ១ សួរនិងឆ្លើយអំពីរផ្លូវទាំង ៣ ..... ១១

៤ – ភូមិសាស្ត្រសង្ខេប នៃនានាប្រទេស: អំពីប្រទេសអល្លឺម៉ាញ (តមកនឹងចប់) ១៤

៥ – អំពីពង្សាវតារនៃប្រទេសភេម, ដកស្រង់យកមកអំពីគោលបារីកផ្សេងៗក្នុង
ពង្សាវតារលោក (តមក)................ ១៨

៦ – ប្រវត្តិពួកឧបាសក-ឧបាសិកា ជាសាវកសាវិការបស់ព្រះពុទ្ធជាម្ចាស់: ទី៥-៦
ប្រវត្តិរបស់ មហានាម-សក្យរាជ និងឧគ្គគហបតី........... ២៤


## *រូបក្រៅរឿង*


រូបទ្វារបាល នៅនឹងតួប្រាសាទកណ្ដាល នៃប្រាសាទបន្ទាយស្រី ។ រចនាបែប
ប្រាសាទបន្ទាយស្រី សតវត្សរ៍ទី ១៦ នៃពុទ្ធសករាជ................ ១

# TABLE DES MATIÈRES


Pages

1. Légende de l'Empereur Açoka de l'Inde antique, traduit du texte français en cambodgien par feu l'Achar Kim-Ann (suite) . . . . . . . . . . . 3

2. Chbab Tounméan Khluon (bons conseils en vers) (suite et fin) . . . . . . . . . . . 8

3. Réflexions sur les phénomènes naturels. I. Dialogue sur les trois saisons . . . . . . . . . . . 11

4. Géographie sommaire de divers pays: L'Allemagne (suite et fin) . . . . . . . . . . . 14

5. Histoire de Rome. Extraits de divers documents de l'histoire universelle (suite) . . . . . . . . . . . 18

6. Vie des disciples laïcs du Bouddha. V. VI. Les vies de Mahānāma et de Ugga-Gahapati . . . . . . . . . . . 24


HORS-TEXTE


Statue de dvārapāla à Bantéay-Srei . . . . . . . . . . . 1



រូបទ្វារបាល នៅខាងត្បូងប្រាសាទកណ្តាល នៃប្រាសាទបន្ទាយស្រី
រចនាបែបប្រាសាទបន្ទាយស្រី សតវត្សរ៍ទី ១៦ នៃពុទ្ធសករាជ ។

# រឿងព្រះបាទអសោក

(តមក)

## បកិណ្ណកនិបាត

## (ក្រុងបាដលិបុត្រនឹងមោរិយវង្ស)

ព្រះរាជវង្សដែលព្រះបាទចន្ទ្រគុប្តបានតាំងឡើងជាដំបូងនោះ មាននាមថា មោរិយវង្ស បានគ្រប់គ្រងក្រុងបាដលិបុត្រក្នុងដែនមគធៈបានចំនួន ៨៥ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ១២៨ ដល់ពុទ្ធសករាជ ២១២ ។ ស្ដេចទី ២ ទ្រង់ព្រះនាមព្រះបាទពិន្ទុសារៈ ដែលជាឱរសរបស់ព្រះបាទចន្ទ្រគុប្ត ព្រះអង្គបានសោយរាជ្យក្នុងដែនមគធៈបាន ១៩ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ២៥២ ដល់ពុទ្ធសករាជ ២៧០ ព្រះបាទពិន្ទុសារៈអង្គនេះបានវាយយកខែត្រដែនតូច ៗ ជាច្រើនរហូតដល់ដែនមទ្រាស (Madras) ឲ្យតាំងនៅក្រោមអំណាចព្រះអង្គ ក្នុងគ្រានេះ ឥណ្ឌៀនឹងក្រិកបានជាប់ទាក់ទងគ្នាទៅវិញទៅមកកាន់តែចំរើនមាំមួនឡើង រហូតដល់មកស្ដេចសោយរាជ្យជាន់ក្រោយ ៗ ក្នុងក្រុងម៉ាសេដូន ក៏ទ្រង់នៅតែបញ្ជូនទូតមកក្រុងបាដលិបុត្រ ។

ព្រះបាទពិន្ទុសារៈមានរាជឱរសច្រើនព្រះអង្គ តែទ្រង់ឃើញថា អសោកមានសេចក្ដីអង់អាចតាំងតែពីនៅជាកុមារតូចមក ទើបព្រះបិតាតាំងដំណែងឲ្យជាឧបរាជ ដម្បូងទ្រង់ឲ្យទៅគ្រប់គ្រងក្រុងតក្កសិលា

តែខាងក្រោយមក ទ្រង់ឲ្យទៅគប់គ្រងស្រុកមាលវៈ ។ គ្រាកាលព្រះបាទពិន្ទុសារៈអស់ព្រះជន្ម អសោកកុមារក៏បានជាស្តេចសោយរាជ្យស្នងព្រះអង្គឡើងក្នុងពុទ្ធសករាជ ២៧៤ គឺបួនឆ្នាំខាងក្រោយព្រះបាទពិន្ទុសារៈអស់ព្រះជន្ម បានជាយឺតយូរដូច្នេះ ន័យខ្លះថា ព្រោះកើតចម្បាំងដណ្តើមរាជសម្បត្តិនឹងព្រះអនុជាឬព្រះជេដ្ឋា តាមគម្ពីរមហាវង្សសំដែងថា ព្រះបាទអសោកបានជ័យជំនះទ្រង់ធ្វើគុតព្រះជេដ្ឋានិងព្រះអនុជាអស់ ឲ្យទុកតែព្រះអនុជព្រះនាមតិស្សៈមួយអង្គដែលរួមព្រះមាតាជាមួយ តែតាមប្រវត្តិសាស្ត្រសម័យនេះ ដែលរកឃើញនោះត្រឡប់ជាប្រាកដថា ព្រះបាទអសោកបានទំនុកបម្រុងព្រះជេដ្ឋានិងព្រះអនុជាយ៉ាងល្អបំផុត មិនបានប្រទូសរ៉ាយគ្នាឡើយ ។ ព្រះបាទអសោកមានលក្ខណៈដ៏រឹងប៉ឹងពូកែប្រកាន់ការងារតាមច្បាប់ជាដាច់ខាត តែមិនមែនជាក្សត្រិយ៍កាចអាក្រក់ប្រកបដោយមោហចរិតដូចយ៉ាងធ្លាប់ចូលចិត្តមកក្នុងជាន់ដើមនោះទេ ។ សេចក្តីពិតថា ព្រះបាទអសោកបានធ្វើសង្គ្រាមជាច្រើនដង តាមធម្មតារបស់ក្សត្រិយ៍គប់ព្រះអង្គ ដែលត្រូវតែផ្សាយអំណាចតេជានុភាពរបស់ព្រះអង្គចេញទៅ ព្រះអង្គជាស្តេចមានបុណ្យធំបំផុតក្រៃលែងជាងស្តេចឯទៀតដែលមានក្នុងប្រវត្តិការណ៍របស់លោក ។ ដែនអាណាចក្ររបស់ព្រះបាទអសោកនោះ ផ្សាយចេញទៅគប់ប្រទេសក្នុងឥណ្ឌាទាំងមូល មិន

តែផែនរបស់ពួកអរិយកៈប៉ុណ្ណោះទេ ព្រះអង្គយកបានចុះមកខាងក្រោម ហេតុដល់ទល់នឹងខ្ទេចខ្ទាំទៀតផង ។

ព្រះបាទអសោកទ្រង់បង្កើតច្បាប់សម្រាប់អាណាចក្ររបស់ព្រះអង្គ ជាអាជ្ញាដាច់ខាត តែជាន់ដំបូងទ្រង់ច្រើនតែសម្រេចកិច្ចពិឃាតផ្ទាល់នឹងព្រះហស្តព្រះអង្គ លុះគ្រាខាងក្រោយមកទើបអនុញ្ញាតឲ្យធ្វើគុកសម្រាប់ផ្ចាញ់ផ្ចាលពួកមនុស្សទុច្ចរិតហើយទ្រង់តាក់តែងឃាតម្នាក់ឈ្មោះគិរិកៈឲ្យជាអ្នកទទួលភារៈនោះ ។

កាលដែលអ្នកប្រាជ្ញចិនឈ្មោះ ហ្វា-ហៀន ចូលមកក្នុងឥណ្ឌាពី ព.ស. ៩៤២, ត្រឡប់ទៅស្រុកចិនវិញព.ស. ៩៥៦, ដល់មកខាងក្រោយមានចិនម្នាក់មកទៀតឈ្មោះ ហ្វួន-ត្សង់ អ្នកប្រាជ្ញទាំងពីរនាក់នេះ ជាអ្នកស្វែងរកការពិតរបស់ព្រះពុទ្ធសាសនា បានទៅឃើញក្រុងបាដលិបុត្រដែលជាក្រុងបាក់បែកគ្រាំគ្រាទៅហើយ ពេលនោះថាមានអ្នកស្រុកបង្ហាញ "នរករបស់ព្រះបាទអសោក" គឺជាគុកដែលស្តេចអង្គនោះធ្វើក្នុងគ្រាខាងក្រោយបានកផសម្បត្តិ តាមរឿងក៏នេះថា គុកនោះគេធ្វើសំរាប់ផ្ចាញ់ផ្ចាលពួកមនុស្សដែលប្រព្រឹត្តអំពើទុច្ចរិត ។ តាមដំណាលរបស់ហ្វា-ហៀន និយាយថា ស្តេចអសោកបានយាងទៅដល់ទីបំផុតនៃកណ្តាប់ចក្រវាឡ ទ្រង់បានទស្សនាការស្ថានព្រះយមរាជហើយមានព្រះរាជ-ហឫទ័យប្រាថ្នានឹងសាងស្ថាននរកនៅទីជិតក្រុងរបស់ព្រះអង្គឲ្យបានដូចជា

នរករបស់ព្រះយមរាជនោះ ។ ក្នុងអសោកាវទានថា គុកនោះសាងឡើងដោយពេជ្ឈឃាតរបស់ព្រះបាទអសោកឈ្មោះគិរិកៈទូលសូមឲ្យសាងសម្រាប់ពិឃាតមនុស្ស ខាងក្រោយមក ពេជ្ឈឃាតនោះបានចូលទៅស្តាប់ភិក្ខុកំពុងស្វាធ្យាយពាលបណ្ឌិតសូត្រដែលសំដែងអំពីស្ថាននរកក្នុងវត្តកុក្កុដារាម ទើបទូលសូមអនុញ្ញាតឲ្យធ្វើនរកនោះម៉ាំមួនឡើងទៀត ។

ក្នុងរឿងក៏ព្រះបាទអសោកមានដំណាលថា នរកដែលទ្រង់អនុញ្ញាតឲ្យគិរិកៈធ្វើនោះមានកំពែងតែមួយជាន់ឥតមានជញ្ជាំងខណ្ឌ ដាក់ពួកមនុស្សទោសជាច្រើនទៅប្របូកប្រចល់គ្នាក្នុងទីនោះ ។

ក្នុងទេវទូតសូត្រមជ្ឈិមនិកាយ មានសេចក្តីប្លែកគ្នាថា "នរក (របស់ព្រះយមរាជ) នោះ ចែកជាច្រើនពួកច្រើនជាន់ នៅត្រង់កណ្តាលហៅថាមហានរក មហានរកនោះបួនជ្រុង បែងចែកជាទ្វារគ្រប់ជ្រុងទាំងបួន មានកំពែងដែកព័ទ្ធជុំវិញ ផែនដីមហានរកនោះសុទ្ធសឹងតែដែក មានភ្លើងឆេះក្តៅក្តីប្រាលឆ្អៅជានិច្ច ផ្សព្វផ្សាយកំដៅទៅចំនួនមួយយោជន៍ ។ ទ្វារទាំងបួនរបស់មហានរកនោះ ត្រង់ទៅចំនរកទាំង ៤ ជាបន្ទាប់គ្នា គឺ គូថនរក, កុក្កុឡនរក, សិម្ពលិវន និងអសិបត្តវន មានទន្លេឈ្មោះវេតរណីជាព្រំប្រទល់ ។ ពាលបណ្ឌិតសូត្រសំស្តែងថា មានពួកសត្វទៅកើតក្នុងនរក ពួកនិរយបាលចាប់បានហើយផ្តួលសត្វនោះសន្ធឹងលើ

ផែនដីដែកដែលភ្លើងកំពុងឆេះសន្ធោសន្ធៅ មានសុទ្ធតែអណ្ដាតភ្លើងក្រាលទៀងតែម្យ៉ាង,..." ។

អសោកាវទានថា "ក្នុងនរកមានតែសេចក្ដីទុក្ខនិងការឈឺចាប់ដោយភ្លើងឆេះឆួលឆាបខ្ទួន; ពពួកសត្វតិរច្ឆានសឹងតែមានសេចក្ដីស្អប់ស្អើងខ្លាចការប្រទូស្ដដល់គ្នានិងគ្នាទៅវិញទៅមកគ្រប់ដង្ហើមចេញចូល; ពួកប្រេតសឹងតែក្ដៅក្រហាយដោយសេចក្ដីស្រេកឃ្លាន; ពួកមនុស្សសឹងតែមានសេចក្ដីព្រួយថប់ក្នុងការចិញ្ចឹមជីវិត; ពួកទេវតាសឹងតែមានសេចក្ដីភ័យខ្លាចនឹងការច្យុតធ្លាក់ចុះមកហើយនឹងការអស់បុណ្យ ហេតុជាវិបាកកម្មទាំងប្រាំប្រការនុ៎ះឯងហើយដែលជាគ្រឿងចាក់ចងសត្វក្នុងភពទាំងបី" ។

សង្កិច្ចជាតកថា "នរកមានប្រាំបីរណ្ដៅ គឺ សញ្ជីវ, កាឡសុត្ត, សង្ឃាត, រោរុវៈមានពីររណ្ដៅ, មហាវីចិ, តាបន, បតាបន, ។ តាបននរក ជារណ្ដៅមួយដែលភ្លើងឆេះជានិច្ច; បតាបននរក ជារណ្ដៅដែលភ្លើងឆេះក្រៃលែង ។

(នៅមានត)

# ច្បាប់ទូន្មានខ្លួន

(តមកទីងចប់)

គួរដើររិះគិតឲ្យបាន គួរឲ្យខានធ្វើបុណ្យទៅ ទាន់ខ្លួនជីវិតនៅ នោះប្រសើរពេកណាកូន ៗ បើបាធ្វើតែបាប មិនសុភាពចិត្តកាចលន់ ធ្វើបាបមិនធ្វើបុណ្យ លែងជាតិទៅនៅនរក ៗ បើបាបានធ្វើបុណ្យ បានសងគុណម្តាយឪពុក ឲ្យបានចាំស័លសុខ នោះទឹងបានឋានសួគ៌ា ៗ ខ្លួនធំខំរកស៊ី ចាស់ព្រឹទ្ធគួរអនិច្ចា កើតជាមនុស្សនេះណា មានលោកពុំដែលរួច ៗ មួយសោតកុំស្នេហ៍ស្និទ្ធ កុំមានចិត្តគិតកាន់កួច កិរិយាគេកុំល្មួច នៅលោកិយក្តីនិន្ទា ៗ ដល់ខ្លួនលែងជាតិនោះ ទឹងចូលចុះនរកណា ទឹងឡើងដើមរកា ដែកនោះធំៗខ្ពស់ក្រៃ ៗ យមបាលតែទៅជ្រោម កាន់គ្រឿងពោមបាក់ទាវៃ ក្អែកត្មាតទន់ជើងដៃ ចចឹកស៊ីជាអាហារ ៗ មានខ្លួននោះដាចដាច់ អស់ទាំងសាច់ឈាមខ្លោចផ្សា ក្រៀវទឹងបន្លា សឹងជាដែកមុតឆ្ងាយធ្ងុះ ៗ ហើយធ្លាក់ពីបន្លា ដើមរកាដែកធំនោះ ធ្លាក់ចុះក្នុងទឹកខ្ទុះប្រែផ្សាក្តៅឥតសម្រាន្ត ៗ ហើយហែលក្នុងទឹកនោះ ស្លាប់ហើយរស់លំបាកប្រាណ ពីពាន់ឆ្នាំទើបបាន រួចមកកើតជាមនុស្ស ៗ រួចនោះបានមកកើត យកកំណើតមនុស្សនេះណា ហេតុកម្មពៀរវេរា កើតជាស្រីប្រាំយេជាតិ ៗ រួចនោះជាខ្វាក់ខ្វើយ កូនចៅអើយកុំប្រមាថ កិរិយាគេមិនឃាត

ពីនរកនោះឡើយណា ។ មួយសោតអាពុកផ្តាំ ចូរចាំកុំផឹកស្រា វានាំ
ចិត្តពាលា ពាលោលទន់ពេកក្រៃ ។ ផឹកស្រាជាអ្នកកាច ពុំក្រែង
ខ្លាចអ្នកដទៃ វានាំបាត់ស្មារតី ទីនរកស៊ីបាត់ប្រាជ្ញា ។ នៅនាលោកិយ
ហោង អស់អ្នកផងគេនិន្ទា លុះខ្លួនជួនមរណា ទៅនរកវេទុក្ខទោ ។
នៅតែរងវិបាក ខ្លួនលោកទីងដែកក្តៅ អស់ថ្លើមប្រមាត់ទៅ ក្នុង
ពុងពោះឈឺពន្លឹក ។ ដែកក្តៅឆេះជាភ្លើង ផ្សែងផ្សព្វឡើងព្រុតតឹក
យមបាលសោតបំផឹក ទឹកទង់ដែងឆេះព្រោងព្រាយ ។ ទាក់កញ្ចាញ
ផ្តេកផ្តួល ទំងបង្គោលដែកទាំងឡាយ មាត់នោះឆេះព្រោងព្រាយ ហេតុ
បាបបានផឹកសុរា ។ ពាក្យនេះមិនជាឯង មានតាំព្រេងព្រះទេសនា អ្នក
ណាបរទារការ សេពសុរាជួបប្ចះទៃ ។ គិតគួរគួរឲ្យចាំ សីលនានាំឲ្យ
ល្អនៃ រៀនធម៌គម្ពីរថៃ បានរៀបបាបផងនានា ។ ហៃអស់កូនចៅអើយ
ចាំឲ្យហើយធម៌ទេសនា អ្នកមិនផឹកសុរា អ្នកនោះបានឋានសួគ៌ហោង ។
គេស៊ីគិតពិត្តី គិតលោកិយបរលោកផង ក្រែងខ្លួនជួនមកហោង ផល
ជួយជូនបានសុខា ។ ច្បាប់នេះព្រះបន្ទូល គួរតែចូលចិត្តគប់គ្នា ខ្ចួល
ទុកលើសិរសា កុំបីភ្លេចដល់មួយថ្ងៃ ។ ថ្ងៃសីលកក្តាកិ រៀនធូបក្តិ
ផ្កាំម្រាមដៃ ថ្វាត់ថ្វាយព្រះរត្នត្រ័យ កុំបីដាច់ថ្ងៃមួយឡើយ ។ អ្នកណា
អាចបានស្តាប់ ត្រេកត្រងត្រាប់ធម៌ជាត្រើយ លុះលែងជាតិទៅហើយ
នោះនឹងបានឋានសួគ៌ ។ ពោះបីបានមកកើត យកកំណើតជាតិនេះ

ណា ប្រកបដោយប្រាជ្ញា អគ្គការយាល្អប្រិមប្រិយ ៗ កើតកបទ្រព្យ របស់ ខ្ញុំស្រីប្រុសគោត្រពី មាសប្រាក់ឥតខ្វះអ្វី មានទូកក្តារប្រាំ ហោង ៗ មានគេក្រើកកោះស្រែស្រូវ បេកអំពៅដូងស្លាផង នោះច្រើនៗ ពេកហោង សឹងលើសលន់ពន់ប្រមាណ ៗ ពាក្យនេះស្មើខ្ទួនហើយ កូនទៅអើយចូរចាំប្រាណ អស់អាចិន្តកំខាន ជាសូត្របណ្តាំ ហោង ៗ ចូររៀនចូររៀនយក ជាគុណូកចិត្តតាំងចង់ ស្មើស្ពានចាំចំឡង ទៅដាក់ដល់ ថ្នល់និព្វាន ៗ

ច្បាប់ទូន្មានខ្លួនចប់តែប៉ុណ្ណោះ

# ប្រស្នាចំរើនសតិបញ្ញា

## ប្រស្នាទី ១

សួរថា រដូវភ្លៀង រដូវក្តៅ រដូវរងា រដូវទាំង ៣ នេះ ចុះរដូវណា ស្រួលជាងគេ ?

## សេចក្តីឆ្លើយទី ១

ក្នុងរដូវទាំង ៣ នេះ នឹងពោលថារដូវណាស្រួលសប្បាយជាង រដូវណាថាមិនទាន់បានទេ បើនិយាយពីដេកស្រួល-ស្រណុកវិញ គេនឹងពោលថារដូវភ្លៀងស្រួល, បើធ្វើការងារស្រួលមិនលំបាក គេនឹងពោលថា រដូវក្តៅស្រួលជាង តែឯរដូវរងានោះមិនបានការសោះ ព្រោះទោះធ្វើការ ឬទោះដេកក៏មិនស្រួលទាំងអស់ គេនឹងស្លៀកពាក់សំពត់អាវក្រាស់ៗឬទោះ ដេកក៏គេនឹងដណ្តប់ភួយក្រាស់ៗ ទើបកក់ក្តៅសំងំដេកទៅបាន ដូចមនុស្ស ឈឺគ្រុន បើតាំងពីកផង រងាខ្លាំងនាំឲ្យវេទនាជាអនេក ។ មួយវិញទៀត រដូវនេះ នាំឲ្យមនុស្សខ្ជិលច្រអូសមិនចង់ធ្វើការងារអ្វីឡើយ នេះពោល តាមអធ្យាស្រ័យរបស់ពួកយើង ដែលធ្លាប់នៅក្នុងប្រទេសក្តៅដូចប្រ- ទេសយើងសព្វថ្ងៃនេះ សម្ពស្សនឹងធាតុធ្លាប់ស៊ាំនឹងអាកាសបែបនេះជា ប្រក្រតី តែជនដែលគេធ្លាប់នៅក្នុងប្រទេសត្រជាក់ សម្ពស្សនឹងធាតុ របស់គេធ្លាប់មកដូច្នោះ គេគង់ចូលចិត្តរដូវរងាជាងជាធម្មតា ។ ហើយ

ចុះ យើងកុំបាច់និយាយពីជាតិដទៃដែលធ្លាប់នៅតែក្នុងទឹកដីត្រជាក់នោះ ឡើយ យើងត្រូវនិយាយតែអំពីចិត្តគំនិតរបស់យើងវិញចុះ តើយើង គាប់ចិត្តរដូវណាជាង? ចំពោះរដូវរងាត្រូវបដិសេធចោលហើយថាមិន ល្អ នៅសល់តែរដូវពីរគឺ រដូវភ្លៀងនិងរដូវក្ដៅ ត្រូវលើកឡើងថ្លឹង ហើយអធិប្បាយថាខាងណាមានទម្ងន់ជាង ៗ តាមយោបល់ខ្ញុំបាទយល់ ថា រដូវក្ដៅស្រួលសប្បាយជាងរដូវដទៃទាំងអស់ ព្រោះនឹងធ្វើការរក ចិញ្ចឹមជីវិតបានដោយស្រួល ឬមួយនឹងធ្វើការកុសលឬមង្គលអ្វីមួយក៏ បានស្រួលមិនលំបាកដូចរដូវឯទៀត ដ្បិតរដូវនេះទុកជាមានភ្លៀងធ្លាក់មក ខ្លះ ក៏មិនសូវជាគាំងដល់ទៅធ្វើការអ្វីមិនកើតទុះទេ ៗ រដូវភ្លៀងតែងមាន ភ្លៀងធ្លាក់ជោកជាំខ្លាំង នឹងធ្វើការចិញ្ចឹមជីវិតអ្វីក៏មិនស្រួល ឬនឹងធ្វើបុណ្យ ទាន-កាមង្គល-អវមង្គល ៗ ល ៗ តែមានភ្លៀងធ្លាក់មកហើយ បណ្ដា ពួកភ្ញៀវដែលត្រូវអញ្ជើញទាំងប៉ុន្មានច្រើនតែឈប់ខានមិនបានទៅកាន់ទី ប្រជុំឲ្យបានគ្រប់ចំនួន បើជួនមានភ្លៀងខ្លាំងទាំងយប់ទាំងថ្ងៃ ក៏កាន់តែ លំបាកណាស់ទៅទៀត ហេតុដូច្នោះហើយបានជាខ្ញុំបាទយល់ថា រដូវក្ដៅ ឬគិម្ហរដូវស្រួលជាងរដូវឯទៀត ៗ ពិតមែនតែរដូវក្ដៅ តោងតែមាន សេចក្ដីក្រវល់ក្រវាយរហាប់រសល់ដោយកំដៅថ្ងៃបន្តិច ដោយមានញើស ចេញច្រើនធាប់អស់កំឡាំង តែមានរបស់សម្រាប់ដោះទុក្ខនេះបានខ្លះ ដែរ គឺថាបើក្ដៅខ្លាំងនឹងនិងច្រើនកណាប់ស្រឡាបខ្លួនហើយព្រោះព្រំដោយ

ម្សៅទឹកអប់ រួចយកផ្លិតស្លឹកត្នោតឬផ្លិតរោមសត្វបក់ឲ្យរហើយៗ ក៏ត្រជាក់ស្រួលដែរ ។ មួយវិញទៀត រដូវក្តៅនេះ ទុកជាក្តៅយ៉ាងណាក៏មិនធ្វើឲ្យខូចខាតការងារអ្វីឡើយ ។

ដូច្នេះខ្ញុំបាទសូមសរសេរសេចក្តីថា គិម្ហរដូវប្រសើរជាងរដូវទាំងពីរគឺវស្សានរដូវនឹងហេមន្តរដូវ ។

## នាយគិម្ហរដូវ

(នៅមានត)

សូមលោកអ្នកមើល ចាំមើលចំឡើយរបស់នាយវស្សានរដូវនឹងនាយហេមន្តរដូវតទៅទៀត។

# ភូមិសាស្ត្រសង្ខេប

## របស់នានាប្រទេស

### អំពីប្រទេសអាល្លឺម៉ាញ ( តមកនិងចប់ )

មុយនិក — ជាទីក្រុងរបស់រដ្ឋបាវីយែរ ។

ឡៃបស៊ិក — ជាស្រុកដែលមានការបោះពុម្ពសៀវភៅ, លក់សៀវភៅ, សិតមេពុម្ព ទីធ្វើគ្រឿងតន្ត្រីច្រើនបំផុតក្នុងលោក ។

ដ្រែសដ៍ — ជាទីក្រុងរបស់រដ្ឋស័ក្ស ។

កូឡូញ — ជាស្រុកដែលមានរោងតម្បាញជាច្រើន ទឹកអប់ដឺកូឡូញ ក៏ធ្វើនៅស្រុកនេះជាច្រើនដែរ ។

ម៉ុកដឺបែក — ជាទីប្រជុំធ្វើស្ករអំពីបែត្តរ៉ាវអល្លឺម៉ង់ ជាប្រទេសដែលលក់ស្ករបែត្តរ៉ាវច្រើនបំផុតក្នុងលោក ចំណាយចេញក្នុង ១ ឆ្នាំៗ ប្រមាណ ១ លានតោន ។

ប្រេស្យូណោ — មានរោងម៉ាស៊ីនធ្វើគ្រឿងដែកជាច្រើន ។

ស្តេត្តាំង — ជាទីប្រជុំធ្វើកប៉ាល់

ស្តុតការ — ជាទីក្រុងរបស់វ៉ឺរតេមបែក

នុយរ៉េមបែក — ជាស្រុកដែលមានរោងធ្វើរបស់លេង, ធ្វើខ្មៅដៃ និងគ្រឿងសរសេរ ។

អេស្សង់ — ជាទីប្រជុំធ្វើគ្រឿងអាវុធ, គ្រឿងយន្តសម្រាប់ភ្ជួរស្រែ នឹងគ្រឿងគិតបញ្ជី ។

មិស្សៀន — ជាទីប្រជុំធ្វើគ្រឿងចាននឹងគ្រឿងបញ្ចាគ្គ ។

មុនស្តែរ — ជាទីតាំងសាលារដ្ឋបាលនៃរដ្ឋវេស្តហ្វាលី មានធ្វើគ្រឿងហត្ថកម្មជាច្រើន ។

ហ្វ្រង់ហ្វួត — ជាស្រុកសំខាន់ខាងធនស្ថាន ( ផ្ទះបាំគ្គ ) បន្ទាប់ពីក្រុងបែរឡាំងមក ។

របៀបគ្រប់គ្រង — ប្រទេសអល្លឺម៉ង់ជាប្រទេសសហរដ្ឋដូចជាសហរដ្ឋអាមេរិក, សហរដ្ឋស្វ៊ីស នឹងសហរដ្ឋស្សូវៀត ដោយមានអាណាចក្រផ្សេងៗ រួមគ្នាដល់ ១៧ រដ្ឋផងគ្នា ជាមហាអាណាចក្រអល្លឺម៉ង់ តែអាណាចក្រព្រុស្ស៊ីមានផែនដីធំជាងរដ្ឋឯទៀតៗ ទាំងអស់ គឺទំហំដីដល់ ២៩២.៧៦៣ គីឡូម៉ែត្រក្រឡា គឺធំជាងទាំង ១៦ រដ្ឋរួមគ្នា ។

កាលពីថ្ងៃទី ៨ ខែអាព្រិលឆ្នាំ ១៩៣៣ ព.ស. ២៤៧៦ នោះ មានការប្រកាសចេញច្បាប់រួមរដ្ឋផ្សេងៗ មកជាអាណាចក្រតែមួយ ដោយមិនព្រមបើកអំណាចឲ្យរដ្ឋអស់នោះគ្រប់គ្រងខ្លួនឯងដូចពីដើម គឺឲ្យគ្រប់ៗ រដ្ឋគោងនៅក្រោមអំណាចរបស់មន្ត្រីប្រចាំរដ្ឋ ដែលបានទទួលខុស-ត្រូវដោយត្រង់ចំពោះលោកប្រធានាធិបតីហ៊ីត្លែរ ។ មន្ត្រីប្រចាំរដ្ឋនីមួយៗ នេះ មានអំណាចតាំងនឹងដកនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីនឹងចៅក្រមរបស់រដ្ឋ

រស់នៅបាន ហើយមានអំណាចចេញច្បាប់បានផង ៗ តមកមានប្រ-
កាសច្បាប់ថ្មី ១ ទៀត កាលពីថ្ងៃទី ១ ហ្វេវ្រិយេក្នុងឆ្នាំដដែលនោះ ឲ្យ
ដកអំណាចអធិបតីដែលមានសម្រាប់រដ្ឋផ្សេងៗនោះទៅទុកនៅនឹងរដ្ឋបាល
កណ្ដាលតែមួយ ហើយបណ្ដាមន្ត្រីប្រចាំរដ្ឋតោងឡើងត្រង់ទៅរករដ្ឋមន្ត្រី
ស្ដីការក្រសួងរដ្ឋាធិការតែមួយ ធ្វើដូច្នេះ ប្រទេសអាល្លឺម៉ាញក៏ក្លាយទៅ
ជារដ្ឋតែមួយ រដ្ឋបាលកណ្ដាលមានអំណាចទូទៅទាំងអស់ ៗ

រដ្ឋសភាមានឈ្មោះក្នុងភាសាអាល្លឺម៉ង់ថា រេចស្តាក មានសមាជិក
៤៧៧ នាក់ សមាជិកម្នាក់តំណាងមនុស្ស ៦០.០០០នាក់ មានតែរដ្ឋស-
ភានេះមួយប៉ុណ្ណោះដែលមានអំណាចចេញច្បាប់បាន, ឯសមាជិកក្នុងរដ្ឋ-
សភានេះ សុទ្ធតែជាពួកគណៈណាស៊ីទាំងអស់ មនុស្សក្នុងពួកគណៈ
ឯទៀតៗ ចូលធ្វើជាសមាជិកពុំបានឡើយ, តាំងអំពីលោកហ៊ីត្លែរធ្វើជា
ប្រមុខគណៈណាស៊ីហើយបានជានាយករដ្ឋមន្ត្រី ហើយតមកធ្វើតាំង
ប្រធានាធិបតីតាំងនាយករដ្ឋមន្ត្រីអស់មួយជីវិត រដ្ឋមន្ត្រីអាល្លឺម៉ង់មាន
អំណាចចេញច្បាប់កាន់តែច្រើនឡើង អំណាចរបស់រដ្ឋសភាកាន់តែថយ
តិចទៅ ទើបរដ្ឋសភាអាល្លឺម៉ង់ប្រគល់អំណាចដាច់ស្រេចដល់រដ្ឋបាល
ជាវេលា ៤ ឆ្នាំ តាំងអំពីថ្ងៃទី ១ អាវ្រិល ពុទ្ធសករាជ ២៤៨០ រដ្ឋបាលនឹង
កែខៃច្បាប់អ្វីមួយឬនឹងប្រកាសចេញច្បាប់អ្វី ក៏មានអំណាចធ្វើបានទាំង
អស់ តែរដ្ឋបាលអាល្លឺម៉ង់ធ្លាប់ឲ្យបណ្ដារាស្ត្រទាំងប្រុសទាំងស្រីនូវទៅក្នុង

ប្រទេស ដែលមានអាយុតាំងពី ២០ ឆ្នាំឡើង ឲ្យបោះឆ្នោតយល់ព្រមឬមិនយល់ព្រមនឹងកិច្ចការដ៏សំខាន់នេះ ក្នុងការដែលរដ្ឋបាលតាក់តែងមកកែម្ដងនោះដល់ ៣ ដងហើយ គឺកាលរដ្ឋបាលគណៈហាក់ត្រូវដកខ្លួនចេញអំពីសន្និបាតនានាជាតិម្ដង កាលដកខ្លួនចេញពីការប្រជុំបន្ថយអាវុធព្រោះឃើញថាចាញ់ប្រៀបមហាប្រទេសឯទៀតៗម្ដង កាលលោកហាក់ត្រូវសុំឲ្យយល់ព្រមក្នុងកិច្ចការដែលទាក់ទងនឹងនយោបាយការប្រទេសដែលបានតាក់តែងទៅទៀតម្ដង ។ ប្រសិនបើមានមនុស្សមិនគាប់ចិត្តជាចំនួនច្រើនហើយ គណៈរដ្ឋបាលហាក់ត្រូវតោងលាចេញទាំងអស់ តែបណ្ដាក្រស្ដជាចំនួនច្រើនៗពេញចិត្តនឹងការដែលរដ្ឋបាលបានតាក់តែងទៅគ្រប់ៗគ្រា ដូចជាគ្រាក្រោយបង្អស់ កាលពុងព្រះពុទ្ធសករាជ ២៤៧៨ មានអ្នកបោះឆ្នោតជិត ៤៥ លាន យល់ព្រមជាមួយនឹងរដ្ឋបាលមានចំនួនជាង ៤៤ លាននាក់ ។

ពង្សាវតារភេម

(តមក)

យើងបានមើលពីខាងដើមមកហើយ ការថាស៍នេះជាស្រុកដែលពួកហ្វេនីស៊ាំងបានតាក់តាំងឡើង ជាស្រុកចំណុះហ្វេនីស៊ាំងមកអំពីដើម ។ លុះតមក អំណាចរបស់ហ្វេនីស៊ាំងសាបសូន្យអស់ទៅ ការថាស៍ក៏ក្លាយទៅជាស្រុកសំខាន់ ១ ឡើង ស្រុកនេះនៅក្នុងទ្វីបអហ្វ្រិកខាងត្រើយសមុទ្រខាងនាយចំពីមុខប្រទេសឥតាលី ។ ក្នុងប្រទេសមានដីជាតិល្អ ឯប្រជាជនច្រើនតែកាចសាហាវណាស់ ទាំងខាងផ្លូវសាសនាក៏ប្រដៅឲ្យកាចសាហាវជាងមនុស្សទៅទៀត គឺគេគោរពរាប់អានព្រះដែលស៊ីមនុស្សជាព្រះអង្គធំសំបើម មានភ្នក់ភ្លើងធំនៅក្នុងពោះ ការធ្វើពិធីគឺចាប់មនុស្សដាក់ទៅក្នុងរណ្ដៅភ្នក់ភ្លើងឲ្យឆេះស៊ុសទៅ គេសន្មតថាជាអាហាររបស់ព្រះគេ ។ បើស្រុកទេសកំពុងមានទុក្ខធុរៈខ្លាំងផង ទើបត្រូវតែធ្វើពិធីយ៉ាងសំខាន់ ដើម្បីឲ្យព្រះទ្រង់ប្រោសប្រណីជួយទុក្ខធុរៈឈឺឆ្អាលនឹងស្រុកទេស ក៏ត្រូវតែចាប់យកក្មេង ៗ ទៅបោះឲ្យចូលទៅក្នុងមាត់ព្រះជាចំនួនច្រើន ។

ពួកការថាស៍មាននិស្ស័យជាអ្នកជំនួញដូចជាពួកហ្វេនីស៊ាំង កាលបើពួកហ្វេនីស៊ាំងអស់អំណាចហើយ ទើបពួកការថាស៍បានអំណាចខាងផ្លូវសមុទ្រមេឌីតេរ៉ាណេទុកក្នុងកណ្ដាប់ដៃទាំងអស់ ហើយទាំងភូមិ

ប្រទេសក៏លៀនលយចេញទៅក្នុងសមុទ្រមានសណ្ឋានជាជ្រុង ត្រូវទំនងល្មមធ្វើជាម្ចាស់សមុទ្របានផង ។ ជនពួកនេះពិតមែនតែមានទ្រព្យសម្បត្តិមាសប្រាក់ស្តុកស្តម្ភច្រើន តែមិនសូវមានកំឡាំងខាងសេនាពហាន ហើយមិនសូវមានសីលធម៌និងបរិយាមារយាទល្អទេ ។ ការគ្រប់គ្រងស្រុកទេសនៅក្នុងកណ្ដាប់ដៃរបស់អ្នកជំនួញដែលមានសម្បត្តិស្តុកស្តម្ភ ដែលច្រើនតែគិតប្រយោជន៍ខ្លួន ។ ឯប្រជាជនអ្នកស្រុកធម្មតាសាមញ្ញ មិនមានការទាក់ទងដឹងឮខាងកិច្ចការស្រុកទេសទេ ទើបជនជាតិនេះមិនចេះស្រឡាញ់ជាតិរបស់ខ្លួន ហើយថែមទាំងស្រុកការថាស៍មិនមានគំនិតហានសម្រាប់ការពារជាតិរបស់ខ្លួនផង អាស្រ័យតែពួកទាហានឈ្នួលដែលជាជាតិអេស្ប៉ាញ៉ុលឬជាតិគោល៉ ហើយពួកការថាស៍នេះ តាមធម្មតាច្រើនតែគិតអំពីប្រយោជន៍ខ្លួនច្រើនជាងប្រយោជន៍របស់ស្រុកទេស ហេតុនេះទំនងនេះបង្អួលឲ្យឃើញថា ការថាស៍និងក្រុងរោមមានលក្ខណៈខុសគ្នាឆ្ងាយ ព្រោះរោមនៅឱកាសដែលជាគូវៃរ អរិនឹងការថាស៍នេះ មានសាមគ្គីរៀបរយល្អណាស់ កិច្ចការខាងក្នុងស្រុកក៏មានរបៀបរៀបរយល្អដែរ អំណាចស្រុកទេសនៅក្រោមអំណាចសភាសេនាត៍ ដែលជាសភារៀបចំស្រុកទេស ចាត់ចែងទំនុកនិងថែរក្សាច្បាប់សម្រាប់ស្រុក ។

តាមដោយពិតនោះ ប្រទេសទាំងពីរមិនគួរជាគូវិវាទនឹងគ្នាទេ ព្រោះក្រុងរ៉ូមជាប្រទេសមានអំណាចនៅលើផ្ទៃដី ហើយជាជាតិឥរុប ។ ឯពួកការថាស៍ជាប្រទេសមានអំណាចខាងផ្លូវសមុទ្រ ហើយជាជាតិអព្រិ-កាំង ។ ក្រុងរ៉ូមមិនមានកងទ័ពជើងទឹក ការថាស៍មិនមានកងទ័ពជើងគោក ហេតុនេះទើបគួរតែជាមិត្តមេត្រីជាមួយគ្នា ។ ក្នុងជាន់ដំបូងប្រទេសទាំងពីរបានស្រុះស្រួលមូលមិត្តជាមួយគ្នាល្អណាស់ មានខសន្យាជាមួយគ្នាយ៉ាងមាំមួន ក្នុងសម័យដែលក្រុងរ៉ូមធ្វើសង្គ្រាមនឹងព្រះបាទពីរុស, ទាំងក្រុងរ៉ូមបានទទួលជំនួយមកអំពីការថាស៍ផង តែលុះកាលក្រុងរ៉ូមក៏យបានអាណាខេត្តរបស់ក្រិក ហើយមានបំណងចង់បានកោះស៊ីស៊ីល ដែលជាកោះស្តុកស្តម្ភបំផុតមួយ ហេតុនេះបានជាកើតប៉ះពាល់ទាស់ទែងនឹងប្រទេសការថាស៍ឡើង ដោយហេតុពួកការថាស៍ធ្វើជំនួញនៅកោះនោះជាច្រើន សូម្បីព្រះបាទពីរុសក៏ទ្រង់ទំនាយហេតុភេទអស់នេះទុកមកមុនហើយ ដោយទ្រង់មានព្រះតម្រាស់ក្នុងវេលាស្តេចចេញពីកោះស៊ីស៊ីលថា "យើងបានបោលស្នាមចម្បាំងជាទីយុទ្ធភូមិយ៉ាងល្អ ទុកឲ្យពួកការថាស៍នឹងពួករ៉ូមាំងច្បាំងគ្នា" ។

ឱកាសនៃសង្គ្រាមកើតឡើង កាលពួកស៊ីរ៉ាគុស (Syra Cuse) នឹងពួកមេស្ស៊ីន (Messine) កើតទាស់ទែងខ្វែងគំនិតគ្នាឡើង ទើបក្រុងរ៉ូមកាន់ជើងពួកមេស្ស៊ីន ខាងស្រុកការថាស៍កាន់ជើងខាងស៊ីរ៉ាគុស ក្រុង

រោមរៀបចំធ្វើប៉ងនឹងបណ្ដេញពួកការថាស៍ឲ្យចេញចាកកោះស៊ីស៊ីលឲ្យអស់ ។ ឯការដែលនឹងធ្វើឲ្យបានសម្រេចតាមប៉ងនោះ ត្រូវតែពួករោម៉ាំងមានកំឡាំងទ័ពជើងទឹកពូកែរឹងប៉ឹង ល្មមតទល់នឹងពួកការថាស៍ខាងផ្លូវសមុទ្រ ទើបក្រុងរោមរៀបចំកសាងទូកចម្បាំងតាមបែបការថាស៍ ចំនួន ១៣០ អស់វេលា ២ ខែ តែទាហានជើងទឹករបស់ក្រុងរោមមិនបានហាត់ឲ្យស្ទាត់ជំនាញខាងជើងទឹកច្រើនតែថ្នឹកស្ទាត់ខាងជើងគោក តែបើទុកជាខាងជើងទឹកមិនទាន់ពូកែក៏ដោយ កំឡាំងទ័ពរោមនៅតែទៅច្បាំងវាយកងទ័ពជើងទឹកការថាស៍ឲ្យបរាជ័យទៅបានដែរ កាលពីពុទ្ធសករាជ ២៨៣ (មុនគ.ស. ២៦០) ។

ពួករោម៉ាំងមានសេចក្ដីត្រេកអរសោមនស្សក្នុងជ័យជំនះរបស់ទាហានដែលមានចិត្តក្លាហាន ទើបលើកកងទ័ពធំសំបើមសំដៅទៅក្រុងការថាស៍ តែគ្រានេះធ្វើការមិនសម្រេច ដោយហេតុត្រូវដកកងទ័ព ១ ផ្នែកត្រឡប់មកក្រុងរោមវិញ ។ ក្នុងគ្រានោះ ខាងពួកការថាស៍បានមេទ័ពពូកែម្នាក់ជាពួកស្ប៉ាត (យើងធ្លាប់មើលឃើញរឿងរ៉ាវក្នុងពង្សាវតារក្រិកមកហើយ) បានវាយទ័ពក្រុងរោមបែក ហើយមេទ័ពរោមក៏អនិច្ចកម្មក្នុងទីចម្បាំង កាលពីពុទ្ធសករាជ ២៨៨ (មុនគ.ស. ២៥៥) ។ លុះតមក បានធ្វើសង្គ្រាមនៅកោះស៊ីស៊ីលទៀត ទ័ពជើងទឹករោមដែលមិនធ្លាប់មានកេរ្តិ៍ឈ្មោះមកពីដើម ក៏បែរជាមានជ័យជំនះមួយដងទៀត ទាល់តែការថាស៍

ព្រមចុះចាញ់ កាលពីពុទ្ធសករាជ ៣០៦ (មុនគ.ស. ២៤១) ។ គ្រានេះ គូកែងទាំងសងខាងស្រុះស្រួលនឹងគ្នា តែការថាសនឹកភ័យ ក្រែងផ្ទៃដីខ្លួនរបស់ខ្លួនបាត់សាបសូន្យទៅ ទើបសុំធ្វើសញ្ញាស្ងប់សង្គ្រាម ហើយព្រមប្រគល់អំណាចការត្រួតត្រាកោះស៊ីស៊ីលឲ្យរោម និងព្រមចេញសោហ៊ុយបង្អាតក្នុងចម្បាំងចំនួនប្រាក់ប្រហែល ២០ លានត្រណោត និងសងឲ្យស្រេចក្នុងរវាង ២០ ឆ្នាំ (កាលមុនគ្រិស្តសករាជ២៤១) ។

## អំពីការបាសនឹងរោមក្នុងខណៈសម្រាកសង្គ្រាម

ការធ្វើសន្តិភាពគ្រានេះ គ្រាន់តែឈប់សម្រាកចម្បាំងមួយគ្រាសិនប៉ុណ្ណោះ ក្នុងរវាងនេះត្រូវកងទាំងសងខាងសឹងនាំគ្នាបន្ថែមកំឡាំង រីតតែរៀងខ្លួនឡើងយ៉ាងខ្លាំង ។ លុះតមកមិនយូរប៉ុន្មាន ពួកក្រិកដែលផ្គត់ផ្គង់មកធ្វើទាហាននោះ បានបង្កការចលាចលឡើង ។ ក្រុងរោមចាប់យកឱកាសនេះ ទៅកាន់យកកោះកាស៊ក (La Corse) បាន ដែលជាអ្នកធ្វើល្មើសខុសសន្យា ហើយក្នុងខណៈនេះឯង ពួកគោលគំនិតនាំខ្លួនជាសត្រូវនឹងក្រុងរោមម្នាក់មួយទៀត ក្រុងរោមមុខជានឹងត្រូវសត្រូវកាយតាមតាំងសងខាងឡើង ទើបមានសេចក្ដីតក់ស្លុតភ័យភ្ញាក់ផ្អើលយ៉ាងធំទៅក្រុងរោម ។ បន្ទាប់ពីនោះមក រកការប្រកាសកេណ្ឌមនុស្សដែលមានកងកាយមាំមួនចូលធ្វើជាទាហានគ្រប់គ្នា ។ ដល់ចាប់ច្បាំងគ្នាឡើង ពួករោមមុំងមានជ័យ

ជំនះឈ្នះគោល្វ៉ ដោយហេតុពួករ៉ូម៉ាំងមានអាវុធល្អជាងពួកគោល្វ៉ ។ មានតែដាវខ្លី ទើបកងទ័ពរ៉ូម៉ាំងលើកចូលទន្លេប៉ូ (Pô) ក៏យកស្រុកមីឡង់ (Milan) បាន ទាំងយកផែនដីស៊ីស័លពីន របស់គោលបានទៀត កាលពីពុទ្ធសករាជ ៣២១ (មុន គ.ស. ២២២) ។

ចំណែកខាងស្រុកការថាស ក្នុងវេលានោះមិនបានធ្វើសង្គ្រាមតស៊ូនឹងក្រុងរ៉ូមទេ ពីព្រោះពួកទាហានឈ្នួលដែលមិនបានប្រាក់ខែមកជាវេលាយូរនោះនាំគ្នាប្តឹងសុំប្រាក់ខែរករដ្ឋការ កាលរដ្ឋការមិនមានប្រាក់នឹងចំណាយឲ្យ ទើបនាំគ្នាបះបោរជាក្បត់ឡើង ទើបមានសង្គ្រាមខាងក្នុងស្រុកជាវេលា ៣ ឆ្នាំ ។ មានមនុស្សសំខាន់របស់ស្រុកការថាសម្នាក់ឈ្មោះអាមិលការ (Amilcar) ជាមនុស្សមានបញ្ញាឈ្លាសវៃ បានតាំងចិត្តធ្វើឲ្យពួកទាហានឈ្នួលអស់នោះអត់ឃ្លានព្រមចុះចាញ់ ហើយចាប់ប្រហារជីវិតអស់ជាច្រើន មានពួកទាហានដែលត្រូវសម្លាប់ក្នុងគ្រានេះចំនួនដល់ ៤០.០០០ នាក់ ។ ការក្បត់នេះគាំងប្រាបប្រាមជាវេលាយូរដល់ ៤ ឆ្នាំទើបស្ងប់ គឺតាំងពី ព.ស. ៣០៣ ដល់ ព.ស. ៣០៦ (មុន គ.ស. ២៤១ – ២៣៧) ។

(នៅមានត)

## ប្រវត្តិឧបាសកឧបាសិកា

ជាសាវកសាវិការបស់ព្រះពុទ្ធជាម្ចាស់

៥- មហានាម-សក្យរាជ- ឧបត្តិក្នុងក្សត្រកូលនៅក្រុងកបិលពស្តុ លុះចំរើនវ័យឡើងទើបបានសម្រេចសោតាបត្តិផល នៅឱកាសដែលបានជួបនិងបានស្តាប់ព្រះធម្មទេសនាក្នុងគ្រាដំបូង ដូចមានសេចក្តីដំណាលថា សម័យ ១ ព្រះបរមសាស្តាទ្រង់គង់ចាំវស្សានៅក្រុងវេរញ្ជា ហើយស្តេចទៅដល់ក្រុងកបិលពស្តុដោយលំដាប់ ហើយស្តេចប្រថាប់នៅនិគ្រោធារាម លោកមហានាមសក្យរាជបានឮដំណឹងថា ព្រះបរមសាស្តាស្តេចមកដល់ក៏ចូលទៅគាល់ ក្រាបទូលអំពីការដែលភិក្ខុសង្ឃគង់លំបាកវេទនាដោយអាហារបិណ្ឌបាតក្នុងក្រុងវេរញ្ជា ហើយទ្រង់អារាធនាថ្វាយអាហារបិណ្ឌបាតយ៉ាងផ្ចិតផ្ចង់ ។ ព្រះបរមសាស្តាក៏ទ្រង់ទទួលនិមន្ត ទើបមហានាមសក្យរាជទៅចាត់ចែងទេយ្យទានយ៉ាងផ្ចិតផ្ចង់គ្រប់យ៉ាងថ្វាយព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រមុខ ទ្រង់បានប្រតិបត្តិព្រះភិក្ខុសង្ឃដោយចង្ហាន់យ៉ាងផ្ចិតផ្ចង់ទាល់តែគ្រប់ ១ ឆ្នាំ ។ តអំពីនោះទៅព្រះបរមសាស្តាមិនទ្រង់ទទួលរះប្តញ់ តែកាលណាមានឱកាស ទ្រង់តែងប្រគេនចង្ហាន់យ៉ាងផ្ចិតផ្ចង់ដល់ព្រះភិក្ខុសង្ឃជាដរាបមក ។ គុណធម៌នេះមាន

ល្បីឮទៅជាហេតុឲ្យព្រះបរមសាស្តាទ្រង់តាំងលោកក្នុងឯតទគ្គដ្ឋាន គឺជាកំពូលនៃបណ្ដាឧបាសកដែលថ្វាយទានយ៉ាងផ្ចិតផ្ចង់ ។

ចប់ប្រវត្តិសង្ខេប របស់មហានាមសក្យរាជតែប៉ុណ្ណោះ ។

៦ — ឧគ្គ-គហបតី — កើតក្នុងត្រកូលសេដ្ឋី ក្នុងក្រុងសាវត្ថី ។ កាលដើមឡើយមានឈ្មោះមិនទាន់ប្រាកដទេ តមក លោកមានកាយខ្ពស់ធាត់ធំសមល្អណាស់ អាស្រ័យហេតុនេះ ទើបមាននាមប្រាកដថា ឧគ្គសេដ្ឋីតាំងអំពីនោះមក ៗ ដំបូង ឧគ្គសេដ្ឋីនេះបានសម្រេចត្រឹមសោ-តាបត្តិផល តមកទៀតទើបបានសម្រេចអនាគាមី ។

លុះចំណេរកាលតមក ឧគ្គសេដ្ឋីក៏កាន់តែចាស់ជរាមានអាយុច្រើន សម្ងំនៅទីស្ងាត់កើតសេចក្ដីត្រិះរិះថា ព្រះបរមសាស្ដាទ្រង់ទូន្មានថា "មនា-បទាយី លភតេ មនាបំ" អ្នកឲ្យរបស់គាប់ចិត្ត តែងបានរបស់គាប់ចិត្តមកវិញ ហេតុដូច្នេះរបស់ណាមួយជាទីគាប់ចិត្តរបស់អញ ៗ គួរថ្វាយរបស់នោះដល់ព្រះទសពល ៗ លុះគិតដូច្នេះហើយ ក៏នឹកគិតតទៅទៀតថា សូមឲ្យព្រះបរមសាស្ដាទ្រង់ជ្រាបចារៈចិត្តរបស់អាត្មាអញ ហើយសូមព្រះអង្គស្ដេចមកកាន់គេហស្ថានរបស់អាត្មាអញផងចុះ ។

ចំណែកឯព្រះបរមសាស្ដាបានទ្រង់ជ្រាបចារៈចិត្តរបស់គេហើយ ដល់វេលាទើបស្ដេចយាងទៅកាន់គេហស្ថានរបស់គេព្រមដោយព្រះភិក្ខុ-

សន្សៀ ៗ ឧគ្គសេដ្ឋីបានដឹងថាព្រះបរមសាស្តាស្តេចមក ក៏ក្រោកឡើង ទ្ធឃ្មាត ទៅកាន់សំណាក់ព្រះអង្គ ក្រាបថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋ ហើយទទួលយកបាត្រនិមន្តឲ្យស្តេចចូលទៅក្នុងផ្ទះ ហើយក្រាបបង្គំទូល សេចក្តីដែលខ្លួនបានគិតទឹកនោះឲ្យទ្រង់ជ្រាបគ្រប់ប្រការ រួចថ្វាយទាន ដល់ព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រមុខ របស់ណាដែលគាប់ចិត្តក៏អង្គាស ដោយរបស់នោះ អាស្រ័យហេតុនេះ ទើបព្រះបរមសាស្តាកាលទ្រង់គង់ នៅព្រះជេតវនមហាវិហារ ទ្រង់តាំងឧគ្គសេដ្ឋីក្នុងដំណែងឯតទគ្គដ្ឋាន ជា កំពូលនៃពួកឧបាសកដែលថ្វាយរបស់ជាទីគាប់ចិត្ត ។ រឿងឧគ្គសេដ្ឋីនេះ មានសេចក្តីពិស្តារក្នុងឧគ្គសូត្រ បញ្ចកនិបាតអង្គុត្តរនិកាយ ។

ចប់ប្រវត្តិសង្ខេប របស់ឧគ្គសេដ្ឋីតែប៉ុណ្ណោះ ។

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្តីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

ឆ្នាំគំរប់ ១៤ ភាគទី ៦

គណៈរដ្ឋមន្ត្រីនិងសម្តេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៦

គ.ស. ១៩៤២

# សេចក្ដីជូនដំណឹង

## អំពីព្រះរាជបណ្ណាល័យកម្ពុជា

ភាណវារៈបាលី រួបរួមព្រះបរិត្ត ព្រះសូត្រផ្សេងៗ និងព្រះអភិធម្ម ព្រមទាំងភិក្ខុបាតិមោក្ខ ជាធម៌សម្រាប់សូត្រគ្រប់វត្តអារាមទូទៅ ដែលព្រះរាជបណ្ណាល័យបានបោះពុម្ពផ្សាយចំណាយអស់តាំងពីយូរមកហើយនោះ ឥឡូវនេះ ព្រះរាជបណ្ណាល័យបានបោះពុម្ពឡើងវិញហើយ ហេតុនេះបើលោកគ្រូម្ចាស់អង្គណាត្រូវការជាវ សូមនិមន្តទៅជាវនៅមន្ទីរព្រះរាជបណ្ណាល័យ និងកន្លែងលក់សៀវភៅរបស់ព្រះរាជបណ្ណាល័យទូទៅ ។

សៀវភៅនេះថ្លៃ ១ ក្បាល ១៤.៨០ ៛

# បញ្ជីរឿង


ទំព័រ

១ — អក្សរសាស្ត្រខ្មែរ លោកសីដែលជាងហ្វាងសាលាបារាំងសែសនៅចុងបូព៌ាប្រទេសរៀបរៀង (តមកនឹងចប់) . . . . . . . . . . . . . . . . . . ៣

២ — មហាភារត (សង្ខេប តមក) . . . . . . . . . . . . . . . . . . . . ១០

៣ — ភូមិសាស្ត្រសង្ខេបរបស់នានាប្រទេស; អំពីភូមិសាស្ត្រប្រទេសអង់គ្លេស . . . . ១៤

៤ — ពង្សាវតារប្រទេសភេម ស្រង់យកអំពីគោលបារីកផ្សេងៗក្នុងពង្សាវតារលោក (តមក) . . . . . . . . . . . . . . . . . . . . . . . ១៧

៥ — ប្រស្នាចំរើនសតិបញ្ញា: ១១ និយាយអំពីរង្វង់ទាំង ៣ (តមក) . . . . . ២១

៦ — រឿងព្រេងខ្មែរ: "រឿងព្រះរាជវិនិច្ឆ័យក្តីទាំង ៤" . . . . . . . . . . ២៤


## *រូបក្រៅរឿង*


រូបទ្វារបាល នៅប្រាសាទព្រះគោ ការរចនាសម័យប្រាសាទព្រះគោ កាលពីសតវត្សរ៍ ទី ១៨ នៃព្រះពុទ្ធសករាជ . . . . . . . . . . . . . . . . . . . . . ១

# TABLE DES MATIÈRES

Pages

1. Littérature cambodgienne, par Monsieur G. Cœdès, Directeur de l'École Française d'Extrême-Orient (suite et fin)....... 3

2. Mahābhārata (sommaire) (suite).......................... 10

3. Géographie sommaire de divers pays : l'Angleterre......... 14

4. Histoire de Rome. Extraits de divers documents de l'histoire universelle (suite)....................................... 17

5. Réflexions sur les phénomènes naturels. I. Dialogue sur les trois saisons (suite).................................... 21

6. Conte populaire cambodgien inédit :

"La procédure d'un roi au cours de quatre procès"...... 24


## Hors-Texte

Statue de dvārapāla provenant de Préas Kô................. I

# អក្សរសាស្ត្រខ្មែរ

លោកសឺដេស រៀបរៀង (តមកនឹគពប់)

រឿងល្ខោនគេក៏តែងជាពាក្យកាព្យដូចសាស្ត្រល្បែងដែរ ហើយសាច់រឿងក៏ស្រង់យកមកពីក្នុងរឿងអណ្ដៀដដែលនោះដែរ ៗ ក្នុងរឿងល្ខោនទាំងមួយៗពួកអ្នកតែងក៏មិនសូវមានកិច្ចឆ្លើយឆ្លងដល់គ្នាជាពាក្យសំដីទេ ដោយហេតុតួល្ខោនទាំងមួយៗមិនប្រើសំដីឆ្លើយឆ្លង វៀរលែងតែរឿងខ្លះដែលមានតួកំប្លែងច្រើន ទើបមានពាក្យឆ្លើយឆ្លងដល់គ្នាទីងគ្នា ដោយពួកតួល្ខោនបញ្ចេញពាក្យសំដីដោយខ្លួនឯង ៗ រឿងល្ខោនមួយៗជាកម្រាប់កំតាមភ្លេង ឯសាច់រឿងដែលជាសេចក្ដីពន្យល់បង្ហាញអំពីអាការកិរិយារបស់ពួកស្ត្រីអ្នករាំ ឬពាក្យសំដីដែលអ្នកកំប្រុងនឹងពោលរឿងនោះ មានអ្នកបើកបទចាំពោលបើកបទបង្ហាញ មានពួកអ្នកច្រៀងចាំច្រៀងពន្យល់ ៗ របៀបតែងរឿងល្ខោនខុសគ្នាអំពីរឿងល្បែង តែត្រង់រឿងល្ខោនរៀបរៀងជាមួយឈុតៗ ព្រមទាំងមានភ្លេងលេងជាមួយផងប៉ុណ្ណោះ ៗ

អំពីរបៀបល្ខោន ខ្មែរលេងតាមរបៀបល្ខោនសៀមទាំងអស់ លើកលែងតែរឿងកម្មាយណៈ ដែលមានលេងបន្តិចបន្តួចនៅក្នុងស្រុកតាមរបៀបខ្មែរ តែសេចក្ដីនេះមិនមែនជាហេតុនាំឲ្យយល់ថា ពួកខ្មែរពុំណាមិនបានស្គាល់បែបសិល្បៈរបស់ល្ខោននោះទេ ព្រោះខ្មែរមានធ្លាក់ប្រល្ខោនក៏

ទុកយ៉ាងសមរម្យ ដែលជាបទៅតាមកំពែងផ្ទៃប្រាសាទបុរាណខ្មែរ ជា
បញ្ជាល់សាក្សីស្រាប់ ៗ រឿងរ៉ាវដែលគេស្រង់យកមកអំពីរឿងជាតក គឺ
រឿងសជាតិរបស់ព្រះពុទ្ធជាម្ចាស់ក្នុងអតីតកាលក្តី យកមកលេងជារឿង
ល្ខោន ក៏សឹងមានពោលទុកយ៉ាងច្បាស់លាស់ក្នុងសិលាចារឹក ១ ដែល
កសាងឡើងក្នុងសតវត្សរ៍ទី ១២ (ព.ស. ១៦៨០) ៗ រឿងសំលៀកបំពាក់
ល្ខោនទីងរបៀបបែបផែនរបស់ល្ខោន ដែលគេពិនិត្យទៅឃើញត្រូវតាម
ក្បាច់ចំឡាក់នៅប្រាសាទអង្គរកាលបរម្យៀក ជាគ្រឿងសំគាល់មួយទៀត
ឲ្យឃើញឃើញថា ពួកសៀមចាប់ផ្តើមចូលរៀនក្នុងសាលារបស់ខ្មែរសិន
ទេ គឺថាចាប់ផ្តើមឡើង សៀមមកខ្ចីយកសិល្បសាស្ត្រនោះពីស្រុកខ្មែរ
ទៅ រួចត្រឡប់នាំមកចូលស្រុកខ្មែរវិញ ៗ ប៉ុន្តែរឿងរ៉ាវផ្សេងៗដែលតែង
សម្រាប់ឲ្យល្ខោនលេង ហើយលេងក្នុងស្រុកខ្មែរនោះ ច្រើនតែជារឿង
ដែលសៀមរៀបរៀងនៅស្រុកសៀម ដូចជារឿងឥណាវ ដើមដែល
ល្បីល្បាញជាងគេទាំងអស់ ៗ រឿងនេះសោតទៀតក៏ជារឿងនិយាយ
អំពីពង្សាវតារជ្វាទេ គឺរឿងដែលនបីនយីដែលពួកចិត្តក្នុងកងសំណាក់
របៀបបានតែងឡើងក្នុងដើមសតវត្សរ៍ទី១២ (ព.ស. ២២៤០) ៗ

ចម្រៀងខ្មែរជាប្រភេទកាព្យឃ្លោង តាមគេមើលទៅកាន់ទីងឃើញ
គំនិតនឹងចិត្តរបស់ខ្មែរបាន តាមធម្មតាច្រើនតែស្រងេះស្រងោចលន្ទន់
លន្ទោច ៗ ខ្មែរមានអ្នកចេះរៀបពាក្យសំដី ហើយចាប់តាំងច្រៀងឡើង

ដោយខ្លួនឯងបាននោះមានចំនួនច្រើន ដោយហេតុចម្រៀងខ្មែរជាពាក្យ
កាព្យឃ្លោងមានឃ្លាល្បះ មិនជាប្រឹតប្រៀនពេក ងាយនឹងតែងរៀបរៀង
ដូចជាស្លោកសំស្រ្កឹត គេតែងជាបទពាក្យ ៦ ឬបទពាក្យ ១២ ហើយថែម
ទាំងកាព្យចម្រៀងនោះមិនមែនមានត្រឹមតែអ្នកប្រាជ្ញទេ ដែលជាអ្នកស្មូង
គេតែងលេងនោះ សូម្បីតែកស្រ្តធម្មតាក៏និយមច្រៀងលេងដល់ទៅមាន
គ្រូឈ្មោះល្បីល្បាញក៏មានដែរ ៗ តាំងតែអំពីបុរាណកាលមក ក្នុង
ឱកាសចូលឆ្នាំ ពួកកុមារកុមារីខ្មែរតែងតែចូលជុំគ្នាលេងពេលល្ងាចជា
ទំនៀម ដោយមានច្រៀងចន្ទួលទៅវិញទៅមកជាពាក្យកាព្យមួយឃ្លា ៗ
ដែលពួកអ្នកលេងបញ្ចេញច្រៀងដោយខ្លួនឯង ៗ ពាក្យអស់នេះមានឃ្លា
ល្បះយ៉ាងងាយ ៗ ទៅតាមធម្មតាមិនជាពិបាកតែងទេ របៀបបែបផែនក៏មិន
មានច្រើន ហើយទំនុកច្រៀងសោកទៀត តាមធម្មតាច្រើនតែប្រើរបៀប
សំដែងសេចក្តីស្នេហាគ្នា ៗ សេចក្តីទុក្ខព្រួយដែលកើតឡើងអំពីចិត្ត
ស្នេហានោះមានច្រើនជាងសេចក្តីរីករាយសប្បាយ ដែលគេច្រើនតែ
សំដែងពន្យល់យ៉ាងជ្រៅជ្រះដោយប្រើពាក្យសំដីប្រៀបធៀបយ៉ាងមោះ
មុត ៗ ពោះបើក្នុងក្បួនអក្សរសាស្រ្តឬក្នុងចំណាក់រចនាក្តី ខ្មែរមានចិត្ត
ស្អប់ខ្ពើមរឿងឬរូបដែលគាត់តែងឡើងជារបៀបលោកស្រោកអគ្គមានបុណ្យ
ចាំង ៗ ទំនុកច្រៀងរបស់ខ្មែរ មានសំដែងទឹកចិត្តនឹងសេចក្តីប្រាថ្នាប្រាយ

របស់ជាតិច្រើនជាងក្បួនកាព្យឃ្លោងដែលគេតែងឡើងដោយបញ្ចេញ បញ្ចេញតាមចំណង់ចិត្តដូចមានរៀបរាប់ពីខាងលើមកនោះ ។

ពាក្យពេយ - គឺប្រភេទអក្សរសាស្ត្ររៀបរៀងជាពាក្យពេយ គេច្រើនអនុលោមរៀបរៀងទំនងប្រៀងដែលមាននៅក្នុងគម្ពីរសាសនា ការប្រែគម្ពីរក្បួនច្បាប់ខាងពុទ្ធសាសនាជារបៀប ១ ដែលគេធ្វើប្រែឲ្យត្រូវតាមកិច្ចដែលមនុស្សត្រូវការ ឧយ៉ាងដូចជាក្នុង ១ ខែៗមាន ៤ ថ្ងៃ ពួកឧបាសកឧបាសិកាតែងទៅប្រជុំគ្នាឯវត្ត ដើម្បីខំសុំសីលរក្សាឧបោសថទំនងស្ដាប់ធម៌ទេសនា ក្រៅអំពីការប្រជុំគ្នាតាមកាលសម័យនោះៗ តាមទំនៀមទម្លាប់របស់ពុទ្ធសាសនា ពួកឧបាសកឧបាសិកានៅមាននិមន្តព្រះសង្ឃទៅឯផ្ទះប្រគេនចង្ហាន់ រួចហើយព្រះសង្ឃក៏សំដែងធម៌ទេសនាផង ។ ក្នុងឱកាសអស់នេះ ធម្មកថិកយកគម្ពីរបាលីមកសំដែងរួចហើយទើបប្រែពន្យល់មួយឃ្លាម្ដងៗ ។ ព្រះសង្ឃដែលរបេះសំដែងសេចក្ដីប្រែអំពីគម្ពីរដីកាមាតិកាទេ នោះមានចំនួនតិចណាស់ តាមធម្មតាលោកច្រើនតែសំដែងតាមសេចក្ដីប្រែដែលបានរៀបរៀងទុកជាមុន ។

ក្រៅពីធម៌ទេសនា គម្ពីរពុទ្ធសាសនាជាគ្រឿងនាំឲ្យកើតអក្សរសាស្ត្រថែមទៀត ដូចជាសេចក្ដីអធិប្បាយពន្យល់តាមអដ្ឋកថា អំពីផលប្រយោជន៍ដែលពួកឧបាសកឧបាសិកាបានធ្វើនូវការកុសលផ្សេងៗ ហើយមានសំដែងក្នុងគម្ពីរនោះៗ ។ រឿងជាតកដូចជាទសជាតកជាដើម

ជាគ្រឿងដឹកនាំឲ្យគេរៀបរៀងចេញជារឿងផ្សេងៗ ដែលជាទីពឹងអាងរបស់ប្រជាជនតទៅ ។ នៅទីបំផុត ច្បាប់វេយ្យាករណ៍ និងក្បួននៃគម្ពីរក៏មានគេចងទុកជាក្រាំងសៀវភៅផងសំខាន់ៗដែរ ។

ទុកជាអក្សរសាស្ត្របែកខាងសាសនា ចាក់ឫសមាំនៅលើព្រះត្រៃ-បិដកបាលីក៏ដោយ សព្ទដែលប្រើក្នុងសេចក្ដីប្រែនិងសំដីដែលប្រើខ្លួនទៅជាភាសាពុទ្ធសាសនាខ្មែរ នៅតែមានប្រើជាដរាប សពាសពេញទៅដោយភាសាសំស្ក្រឹត ឃ្លាល្បះដ៏សំខាន់ក្នុងក្បួនពុទ្ធសាសនា ក៏ឃើញតែងជាភាសាសំស្ក្រឹតមិនមែនជាសព្ទបាលីឡើយ ។ ចុះជាលទ្ធិពុទ្ធសាសនាផ្សាយជាភាសាបាលីជ្រាបចូលទៅចាក់ឫសមាំមួនក្នុងទំនៀមទំលាប់ស្រុកយ៉ាងណាក៏ដោយ ពុទ្ធសាសនាភាសាបាលីក៏នៅតែត្រូវប៉ះទង្គិចនឹងភាសាសំដីជាន់ចាស់ ដែលអ្នកស្រុកធ្លាប់ប្រើតៗមកតាំងអំពីសម័យដែលលទ្ធិពុទ្ធសាសនាភាសាសំស្ក្រឹត និងលទ្ធិសាសនាព្រាហ្មណ៍ដែលជាទីប្រោសប្រាណនៃក្សត្រសម័យអង្គរ និងជាទីពឹងអាងរបស់ប្រជាជនជាន់បុរាណដែលនៅក្នុងស្រុក ។

ឯអក្សរសាស្ត្រដែលជាពាក្យពេចន៍សុទ្ធសាតសម្រាប់ប្រើដោយខ្មែរនោះ សឹងមានសរសេរទុកក្នុងក្បួនមាត្រាច្បាប់សម្រាប់ស្រុកដែលគេទើបតែរើប្រមូលក្នុងលើកក្រោយបង្អស់ កាល ព.ស. ២៤១៩ (គ.ស. ១៨៧៦) ក្នុងក្បួនមាត្រាទាំងនោះនៅបានសព្ទភាសាជាន់ចាស់ជាច្រើនៗ

ប្រវត្តិនៃក្រិត្យក្រមមាត្រារបស់ខ្មែរ ជាការមួយដែលត្រូវតែរៀបចំធ្វើឡើង ៗ នៅវេលានេះយើងមិនអាចនឹងយកមកពោល ផ្សេងជាការក្រៅអំពីសេចក្តីអធិប្បាយអក្សរសាស្ត្រនេះ ៗ ឯវិជ្ជាឯទៀតដូចជាវោហារសាស្ត្រ, ក្បួនព្យាករណ៍, គម្ពីរពេទ្យ, គម្ពីរផ្សំថ្នាំ, គម្ពីរអាគមគាថា, គម្ពីរពិធីបុណ្យ អស់នេះគេបានសរសេរជាក្បួនតូច ៗ ផ្សាយចេញជាជាសពាសពេញ ៗ តាមរបៀបបែបផែននៃក្បួនវិជ្ជាអស់នោះ គេនឹងទុកជាក្បួនអក្សរសាស្ត្រស៊ើរតែពុំបាន ប៉ុន្តែការដែលពិនិត្យស្រាវជ្រាវរកវិជ្ជាអស់នោះ ជាការដ៏សំខាន់មួយអាចនឹងនាំឲ្យស្គាល់ដួងចិត្តគំនិតរបស់ខ្មែរៗ

ឯរឿងល្បែងដែលតែងជាពាក្យរាយ និង រឿងល្បែងដែលតែងជាពាក្យកាព្យ គ្រាន់តែមានស្ពានខុសគ្នាប៉ុណ្ណោះ ៗ ឯនិទានរឿងព្រេងនិងនិទានសុភាសិត ដែលមានគេសរសេរចេញនោះមានតិចណាស់ កាលមុនដែលពួកខ្មែរបានចាត់ចែងឲ្យមានការបោះពុម្ពឡើង ៗ រឿងអស់នេះហើយដែលជាគ្រឿងជួយឲ្យឃើញជាក់ច្បាស់អំពីរបៀបបែបផែននិងសំដីនិយាយរបស់ខ្មែរ ព្រមទាំងអារម្មណ៍រីករាយស្រស់ស្រាយរបស់ប្រជាជន ៗ សាច់រឿងទាំងនេះ ពិនិត្យសង្កេតមែនទែនទៅ ឃើញថាប្រហែលជាមិនមែនជារបស់ខ្មែរទាំងអស់ទេ ដ្បិតយករឿងអស់នេះទៅផ្ទៀបគ្នាមើលនឹងរឿងព្រេងរបស់ប្រទេសជិតខាង ឃើញថាគេស្រង់យកមកអំពីនិទានឥណ្ឌា គម្ពីរបញ្ចតន្ត្រ ឯនិទានរឿងខ្មោចបិសាច

ប៉ុន្តែរឿងធ្មេញជ័យ, រឿងសុភាទន្សាយ និងរឿងទំពែកទាំង ៤ ដែលកើតឡើងក្នុងប្រទេសខ្មែរជារបស់ខ្មែរសុទ្ធៗ ហើយជាគ្រឿងសំដែងយ៉ាងជាក់ច្បាស់អំពីចិត្តគំនិតរបស់រាស្ត្រ ។

ក្នុងការបញ្ចប់សេចក្ដីយល់អំពីរបៀបអក្សរសាស្ត្រខ្មែរនេះ គួរពោលអំពីប្រជុំក្បួនព្រះរាជនិពន្ធនិងសេចក្ដីរាយការរបស់មហាក្សត្រ ដែលមានចំនួនជាច្រើននិងក្រាស់ក្រែលគ្រាន់បើដែរ តែមិនមានច្បាប់សាស្ត្រណាមួយឲ្យសមតាមរបៀបសិល្បកម្ម ដើម្បីជាការគួរលើកមកពោល ។

បើពោលដោយសរុបទៅ អក្សរសាស្ត្រខ្មែរមិនបានកើតផលចំរើនធំទូលាយនិងមានដំឡៃថ្លៃថ្នូរយ៉ាងឧត្ដមទេ សូម្បីតែក្នុងសម័យអង្គរដែលចំរុងចំរើនរុងរឿងយ៉ាងឯកនោះ អក្សរសាស្ត្រខ្មែរក៏មិនចំរើនឲ្យសមនឹងរចនាខ្មែរឡើយ ។ ឯការរចនារបស់ជាតិមិនមានចំរើនត្រឹមតែត្រង់ការស្វែងរកបែបផែនថ្មីៗនោះទេ នៅមានធ្វើឲ្យបានសំរេចសេចក្ដីចំរើនយ៉ាងប្លែកៗបានថែមទៀតផង ។

ចប់

(តមក)

ច្បាប់នេះហើយដែលហៅថា "ច្បាប់នៃការលះបង់" មិនទាន់មាននរណាប្រតិបត្តិតាមសោះ គ្មាននរណាចង់លះបង់សោះ គេគិតតែប្រមូលមកឲ្យបានច្រើនបំផុតទឹងកេក្រពុកឲ្យបានទាំងអស់ ។

ដោយការបាត់បង់ខាងគោលសំខាន់ៗ របស់សីលធម៌ ទើបប្រជាគមសមាគមមនុស្សលោករបស់យើងខូចច្បាប់សំខាន់ៗទៅអស់ មិនមែនវិទ្យាសាស្ត្រ មិនមែនឧស្សាហកម្ម មិនមែនពាណិជ្ជកម្មទេ ដែលជួយទំនុកបំរុងច្បាប់សីលធម៌អស់នោះ ។ សីលធម៌មិនបានជួយស្រោចស្រង់សមាគមចំណោមមនុស្សឲ្យចំរើនឡើងឡើយ ។

យើងត្រូវតែមើលក្នុងសៀវភៅតូចនេះគង់នឹងបានឃើញថា មនុស្សទាំងឡាយដែលគិតរកសេចក្ដីចំរើនថ្លៃថ្លាបានគ្រាន់បើជាងយើង (សព្វថ្ងៃនេះ) ដែលនាំដើរទៅតាមផ្លូវនៃសេចក្ដីសុខក្សេមក្សាន្ត ។

ឯព្រះភគវទ្គីតៈ (ដែលយើងចេញឈ្មោះមកហើយ) នោះ ជាសេចក្ដីសន្ទនាគ្នា រវាងព្រះបាទក្រិស្ណៈនឹងអជ៌ុនៈ ។ មុននឹងច្បាំងតទល់គ្នានឹងពួកញាតិសាលោហិតខាងពួកកុរុនោះ អជ៌ុនៈមានសេចក្ដីព្រួយបារម្ភទើបមានចិត្តស្ទាក់ស្ទើរ ក្នុងការច្បាំងតទល់នឹងពួកញាតិកាវង្សជាមួយគ្នាបើដូច្នេះ អជ៌ុនៈត្រូវធ្វើដូចម្ដេច? ព្រះបាទក្រិស្ណៈបានដាស់តឿនអជ៌ុនៈឲ្យ

មានសេចក្ដីក្លាហាន ហើយត្រាស់ថា ត្រូវតែធ្វើការតាមមុខក្រសួងរបស់ខ្លួន ដែលធ្វើជានាយទាហាន ហើយទ្រង់ពន្យល់អជ្ជុនៈតាមហេតុផលដែលត្រូវអជ្ជុនៈធ្វើការលះបង់នេះ ។ នេះហើយជាច្បាប់ទេពតាមួយ ហើយយើងត្រូវធ្វើជាមនុស្សព្រងើយកន្តើយចំពោះវត្ថុទាំងពួងកុំបីមានលោភ តែត្រូវធ្វើជានាយទាហានលើកិច្ចការរបស់ខ្លួន ។

គាថា ៩-១០ តទៅនេះ ស្រង់យកមកអំពីសេចក្ដីសន្ទនាគ្នា (នៃអជ្ជុនៈនិងក្រិស្ណៈ) សឹងមានបែបបទជាគាថាដូចខាងក្រោមនេះ:

— លោកអជ្ជុនៈបានឃើញពួកមនុស្សដែលឈរនៅចំពោះមុខខ្លួនដែលកាលពីដើមមកសុទ្ធតែជាមិត្តភក្ដិ, ជាញាតិសាលោហិត, ជាបុត្របុរស, ជាគ្រូអាចារ្យ, ជាអាពុកធំ, ជាបងប្អូនជីដូនមួយ, ជាបងថ្លៃប្អូនថ្លៃ, ធ្លាប់ជាគូកន, ជាសំឡាញ់ ហើយបំបែកគ្នាជា ២ កងទ័ព ។

— ជើងខ្ញុំញ័ររំព្រើប, ដៃខ្ញុំក៏ញ័រទន់ល្វន់, សាច់ស្បែកទៅជាខ្លោចផ្សា, ខ្ញុំឥតគំនិត (គិតបញ្ហាំង) ខ្ញុំឈរមិនជាប់ទេ ។

— ខ្លួនខ្ញុំគិតតែសំឡឹងមើលជោគកម្មអាក្រក់ ដែលកើតឡើងចំពោះមុខនេះ គង់ការច្បាំងកាប់សម្លាប់តែបងប្អូនឯង ។

— កាលបើខ្លួនខ្ញុំនឹងកាប់សម្លាប់ពួកជនអស់នេះ តើនឹងនាំឲ្យខ្លួនខ្ញុំមានសេចក្ដីសុខបន្តិចបន្តួចឡើងទៀតឬអ្វី ?

— ចុះមានប្រយោជន៍អ្វី យើងគិតតែថែរក្សាសម្បត្តិរបស់យើង សូម្បីជីវិតរបស់យើងក៏ដោយ គង់តែមកជួបជុំលេងល្ខោនតែបែបមួយនេះ? យើងនាំគ្នាមកច្បាំងតទល់គ្នានឹងពួកមនុស្សអស់នេះ ដើម្បីសម្រេចប្រ-យោជន៍ជាដាច់ស្រេច ថាខាងណាត្រូវបានធ្វើជាម្ចាស់ស្រុកប៉ុណ្ណោះ ។

— ខ្លួនខ្ញុំមិនអាចតាំងខ្លួនជាអ្នកពិឃាតជាតិរបស់ខ្ញុំបានឡើយ ។

— ប្រសិនបើគូសត្រូវរបស់យើងមានចិត្តសាហាវឃោរឃៅ តាំងមិនស្គាល់ទោសកំហុសដែលខ្លួនកាប់សម្លាប់គេ នេះជាហេតុផលមួយសម្រាប់យើង តើយើងគួរយកតម្រាប់ជនអស់នេះឬអ្វី ?

— ខ្ញុំនឹងមានសេចក្ដីសប្បាយចិត្តដូចម្ដេចកើត ប្រសិនបើកាប់សម្លាប់ជនអស់នេះ មួយវិញទៀត ខ្ញុំនឹងមានចិត្តក្សេមក្សាន្តឯណាកើត បើខ្ញុំបំផ្លាញញាតិវង្សរបស់ខ្លួនឯង ។

— នេះហើយជាទោសកំហុសមួយយ៉ាងធ្ងន់ គឺការបំផ្លាញវង្សត្រកូលរបស់ខ្លួន ៗ តាមដោយពិត យើងផ្ដើមនឹងធ្វើអំពើអកុសលយ៉ាងធំណាស់ ដោយចង់បានជ័យជំនះនឹងប្រាថ្នាកិត្តិយសប៉ុណ្ណោះ ដែលយើងនាំគ្នាមកច្បាំងគ្នានេះ ។

— ខ្លួនខ្ញុំមានគ្រោះកាចអ្វីម្ល៉េះ ក៏មិនមានដំឡៃថ្លៃជាងនេះឬអ្វី សម្រាប់ខ្លួនខ្ញុំដែលត្រូវគេកាប់ដោយឥតការពារនឹងឥតអាវុធ ហើយខ្ញុំសុំឱ្យត្រូវគេអារកសម្លាប់ដោយដាវដ៏មុតរបស់ខ្មាំងនៅលើទីរណភូមិនេះចុះ!

លុះអដ្ឋិនៈនិយាយដូច្នេះហើយ ក៏ទំលាក់ដងធ្នូនឹងសររបស់ខ្លួន ហើយដាក់ខ្លួនអង្គុយលើអាសនៈ ប្រកបដោយចិត្តគំនិតក្តៅផ្សាហើយនិយាយដូច្នេះថា “ខ្ញុំនឹងមិនចូលបព្វជ្ជាទេ” ។

— បពិត្រព្រះក្រិស្ណៈ បេះដូងរបស់ខ្ញុំស្ទើរតែរលួយដោយមេត្តាចិត្ត ខ្ញុំសូមទូលសួរទ្រង់អំពីការខ្លាចបាប ខ្ញុំមើលមិនឃើញថា ការកិច្ចរបស់ខ្ញុំនេះដែលខ្ញុំត្រូវធ្វើតើនៅឯណា ចំណែកណាដែលប្រសើរថ្លៃថ្លា សូមទ្រង់មានព្រះបន្ទូលមកចុះ ខ្លួនខ្ញុំព្រមធ្វើជាសាវករបស់ទ្រង់ ។ តើទ្រង់យល់ថាខ្លួនខ្ញុំត្រូវធ្វើដូចម្តេច ទើបខ្លួនខ្ញុំរួចខ្លួនដោយសារសតិបញ្ញារបស់ទ្រង់ ?

— ខ្ញុំមិនដឹងថាអ្នកឯណា អាចជួយកំចាត់សេចក្តីព្រួយចិត្តរបស់ខ្ញុំបានទេ បើទុកជាខ្ញុំមានជ័យជំនះ បានសម្បត្តិទ្រព្យទឹកដីសម្បត្តិក៏ដោយ ។

— កាលអដ្ឋិនៈពោលដូច្នេះហើយក៏ប្រកាសថា ខ្លួនលោកមិនព្រមបព្វជ្ជាទេ រួចអង្គុយស្ងៀមទៅ ។

(នៅមានត)

# ភូមិសាស្ត្រសង្ខេប

## នៃប្រទេសអង់គ្លេស

ពាក្យថា ប្រទេសអង់គ្លេសក្នុងទីនេះ ចំពោះកោះដែលហៅថា អង់គ្លីតែប្រេតង់ប្រីតាញប៉ុណ្ណោះ ។

**ទីតាំងនិងអាណាខេត្ត** – ប្រទេសអង់គ្លេសជាកោះតាំងនៅក្នុង មហាសមុទ្រអត្លង់ទិក នៅទិសខាងលិចទ្វីបអឺរ៉ុប ។ អាណាខេត្តទិសខាងជើងទល់នឹងសមុទ្រអត្លង់ទិក ទិសខាងលិចទល់នឹងច្រកសមុទ្រខាងជើង ជាចន្លោះកោះអង់គ្លេសនឹងកោះអៀរឡង់ ទិសខាងត្បូងទល់នឹងច្រកឡាម៉ង់ស៍នឹងប៉ាដឺកាឡេស៍ ទិសខាងកើតទល់នឹងសមុទ្រខាងជើង ។

**ខ្នាត** – បណ្ដោយវែងបំផុត វាស់ពីលើមកក្រោមប្រមាណ ៩៧៣ គីឡូម៉ែត្រ ។ ទទឹងត្រង់ដែលទូលាយបំផុតប្រមាណ ៥៧២ គីឡូម៉ែត្រ ។ ទំហំដី ២៣០.៦១៦ គីឡូម៉ែត្រក្រឡា ។

**ច្រាំងសមុទ្រ** – ល័ក្ខខ័ណ្ឌដ៏សំខាន់របស់ច្រាំងសមុទ្រអង់គ្លេសមាន ឈូងតូច-ធំលូកចូលទៅកាន់ដីគោកដោយជុំវិញ ធ្វើឲ្យកើតជាកំពង់ទឹកដ៏ ចតកប៉ាល់ទូកនាវាបានដោយស្រួល ធ្វើឲ្យតំបន់ផ្សេងៗនៅមិនឃ្លាតឆ្ងាយពីសមុទ្រហួសពី ១១២ គីឡូម៉ែត្រឡើយ ។

កោះ – ប្រទេសអង់គ្លេសប្រកបដោយកោះធំៗពីរគឺ ក្រង់ប្រ៊ីតាញ និងអៀរឡង់ ហើយមានកោះតូចៗទៀតជាចំនួនច្រើនប្រមាណ ៥.០០០ កោះ ។

ភ្នំ – ក្នុងអេកូស្ស៍មានភ្នំជាច្រើនស្រពាប់ជាប់គ្នាយ៉ាងក្រាស់នៅត្រង់ភាគកណ្ដាលរបស់ប្រទេស នៅភាគខាងជើងនិងខាងត្បូងមានភ្នំតូចៗហើយច្រើនតែទាបៗជាងនៅភាគកណ្ដាល ។ ភ្នំសឺវីយ៉ុតទាំងប្រវែងដែនអង់គ្លេសនៅភាគខាងក្រោម ភ្នំក្រាមពៀនជាភ្នំធំនៅភាគកណ្ដាល នៅភាគខាងជើងមានភ្នំហៃឡែនដ៍ជាដងភ្នំធំសំបើម ។

ក្នុងអង់គ្លេសមានភ្នំធំៗ តាំងនៅទិសខាងលិចទាំងអស់ ដែលសំខាន់គឺដងភ្នំប៉េននីន ជាដងភ្នំវែងបំផុតក្នុងអង់គ្លេស ភ្នំកាមប្រៀននៅទិសខាងលិចឆៀងខាងជើង ភ្នំនៅទិសខាងលិចឆៀងខាងត្បូង និងភ្នំនៅទិសខាងកើត ។

ក្នុងប៉េអ៊ីសដឺកល្ល៍មានភ្នំដេរដាសទូទៅគ្រប់ទិសតំបន់ ។

ទន្លេ – ទន្លេក្នុងកោះអេកូស្ស៍ជាទន្លេខ្លីៗ ហើយហូរខ្លាំង ។ ទន្លេដែលសំខាន់ គឺ ទន្លេតៃយ៍ (១៦០ គីឡូ) ដែលជាទន្លេវែងបំផុតក្នុងកោះអេកូស ហូរធ្លាក់ទៅមាត់សមុទ្រទិសខាងកើត និងទន្លេក្លីត (១៥៧ គីឡូម៉ែត្រ) ហូរធ្លាក់ទៅក្នុងសមុទ្រទិសខាងលិច ។ ក្នុងប្រទេសអង់គ្លេសមានទន្លេតាមីស៍ (៣៤៤ គីឡូម៉ែត្រ) ជាទន្លេវែងបំផុតនិងសំខាន់បំផុត

ខាងពាណិជ្ជកម្ម បន្ទាប់មកទន្លេសេវែន ( ៣៣៦ ) ទន្លេត្រេនត៍ ( ២៨៨ ) អ៊ូស្វ ( ២៩០ ) ទីន ( ១១៧ ) វ៉ៃអើយ ( ១០៩ ) ។ ក្នុងប៉េអ៊ីដឹកល្ង មានទន្លេសំខាន់ៗ ពីរ ។

ខ្យល់អាកាស – ដោយហេតុប្រទេសអង់គ្លេសជាកោះមានសមុទ្រ ព័ទ្ធជុំវិញ ទើបធ្វើឲ្យអាកាសមិនសូវក្តៅពេកមិនសូវត្រជាក់ពេក មាន ឧណ្ហភូមិយ៉ាងមធ្យម បើនឹងធៀបរហូតឆ្នាំ នៅភាគខាងជើងយ៉ាងទាបត្រឹម ៤៦ ភាគ ខាងត្បូងត្រឹម ៥២ បើធៀបនឹងប្រទេសឯទៀតដែលនៅក្នុងរយៈ ជាមួយគ្នា ដូចជាកាណាដា ជាទីងស៊ីបេរី នឹងឃើញខុសគ្នាច្រើន ។

ភ្លៀង – ខ្យល់ដែលបក់កាត់ប្រទេសអង់គ្លេស ជាខ្យល់បក់ពីទិសខាង លិចនៀងខាងត្បូង ខ្យល់នេះជាខ្យល់បក់កាត់ខ្សែទឹកអ៊ុនគុលហ្វ៍ស្ត្រីម មុន មកដល់ប្រទេសអង់គ្លេស ជាខ្យល់បក់យកចំហាយទឹកមកជង់ជាច្រើន ក្នុង អង់គ្លេសនិងអេកូស្ស៍មានភ្នំខ្ពស់ៗ តាំងនៅទិសខាងលិចទាំងអស់ ទើប បានភ្លៀងធ្លាក់នៅតាមភ្នំនិងតាមសមុទ្រទិសខាងកើតជាច្រើន ។ ចំនួន ទឹកភ្លៀងដែលធ្លាក់នៅទិសខាងកើតរបស់អង់គ្លេស ប្រមាណ ១ ឆ្នាំ៦៣៥ ដល់ ៧៦២ មិល្លីម៉ែត្រ ។ ឯទឹកភ្លៀងដែលធ្លាក់នៅទិសខាងលិចនោះ បានប្រមាណច្រើនជាងទិសខាងកើតដល់ពីរភាគ ។

( នៅមានត )

(តទៅ)

# អំពីអាមិលការទៅអេស្ប៉ាញ

អាមិលការជាអ្នកជួយជីវិតស្រុកការថាស៍ក្នុងគ្រានោះ លុះតមកបែរជាមិនជាទីគាប់ចិត្តនៃពួកមន្ត្រីដែលមានអំណាចត្រួតត្រាស្រុកក្នុងសម័យនោះ ព្រោះអាមិលការបានតាំងសមាគមថ្មីមួយហៅថា "សមាគមស្រឡាញ់ជាតិ" ដោយបំណងចង់រៀបចំស្រុកទេសតាមបែបប្រជាធិបតេយ្យដូចជាក្រុងរោម ។ ហេតុនេះហើយបានជាពួកមន្ត្រីក៏បាយបណ្ដេញអាមិលការឲ្យចេញទៅពីស្រុកការថាស៍ ដោយបង្គាប់ឲ្យអាមិលការ ឃុំកងទ័ពទៅវាយការផ្សាយអាណាខេត្តនៅខាងប្រទេសអេស្ប៉ាញ ។

កាលអាមិលការឃើញថាស្រុកការថាស៍មិនត្រូវការខ្លួនហើយ ទើបនាំកងទ័ពចូលទៅច្បាំងលុកលុយប្រទេសអេស្ប៉ាញ រហូតដល់ទន្លេអែប្រ៍ (Èbre) ហើយរៀបចំតាំងអាណាចក្រមួយយ៉ាងមាំមួនឡើងឲ្យឈ្មោះថាស្រុកការថាស៍ថ្មី ឬការថាសែន (Nouvelle Carthage ou Carthagène) ហើយតាំងខ្លួនជានាយកឡើង មានកងទ័ពដែលបានហ្វឹកហាត់ទាំងការច្បាប់វិន័យទាហានយ៉ាងម៉ឺងម៉ាត់ ដែលអាចប្រើការធ្វើអ្វីបានតាមចិត្ត លុះអាមិលការអនិច្ចកម្មទៅ ទើបអនិបាល (Annibal) ជាកូនប្រុសរបស់

កលិគារមានអាយុ២៧ឆ្នាំបានទទួលមត៌កជាមេទ័ពជាកំណត់មក កាល ពី ព.ស. ៣៦៣ (មុន គ.ស. ៦៦០) ។

**អំពីអន្និបាល** — កងទ័ពនេះជាកងទ័ពដែលអន្និបាលតាំងខ្លួនជាគូសត្រូវសំខាន់នឹងក្រុងរ៉ូម ដែលក្រុងរ៉ូមមិនធ្លាប់ជួបប្រទះមកអំពីដើម ។ អន្និបាលនេះស្អប់ខ្ពើមពួករ៉ូម៉ាំងណាស់ ដល់ទៅណាខ់មាត់ស្បថថាយខ្លួនឯងជាទីដឹកយក្រុងរ៉ូមឲ្យទាល់តែមានជ័យជំនះ ហើយនឹងរៀបចំស្រុកការថាសុំឲ្យបានជំពំរើនឡើង អន្និបាលមានសេចក្ដីតាំងចិត្តដ៏ខ្ជាប់ខ្ជួនយ៉ាងមុឺងម៉ាត់ ។ មួយវិញទៀតអន្និបាលនេះមានចំណេះខាងវិជ្ជាទាហានបាត់ចត់ល្អណាស់ ទុកជាព្រះចៅណាប៉ូលេយ៉ុងក៏មានសេចក្ដីសរសើរហើយនាំយកបែបផែនទ្វះមកប្រើការ ទុកជាពួករ៉ូម៉ាំងដែលជាគូសត្រូវក៏គេរាប់តែព្រមទទួលថា អន្និបាលជាមនុស្សមានលក្ខណៈដ៏សំខាន់ ។ មានអ្នកប្រាជ្ញពង្សាវតាររ៉ូមម្នាក់ឈ្មោះទិតលីវ បានពោលទុកថា អន្និបាលជាមេទ័ពដែលពួកទាហានមានជំនឿនឹងគោរពល្អណាស់ ជាអ្នកក្លាហានអង់អាចក្នុងការលើកទ័ពទៅវាយសត្រូវ នឹងប្រយ័ត្នល្អណាស់ ក្នុងវេលាច្បាំងតាញ់ ជាមនុស្សមិនចេះអស់កំឡាំង ហើយមានសេចក្ដីអត់ធន់ក្ដៅ-ត្រជាក់មិនរួញក ការបរិភោគនឹងប្រើប្រាស់របស់ផ្សេងៗមិនជាការចំឡែកនឹងកូនទាហានឡើយ វេលា ដេកយប់ក៏មិនត្រូវការពូកខ្នើយសម្រាប់ប្រើផ្ទាល់ខ្លួន. មានគេឃើញជារឿយៗអន្និបាល

យកភួយដណ្ដប់ឃ្លុំខ្លួនដេកទឹងដីនៅមុខបន្ទាយជាច្រើនដងមកហើយតាំង សំលៀកបំពាក់របស់មេទ័ពនេះ គឺមិនចំឡែកប្លែកពីពាហានឯទៀតៗ ដែរ តែការុធទីងសេះប៉ុណ្ណោះ ដែលធ្វើឲ្យដឹងថាជាមេទ័ពធំ ៗ វេលា ចេញច្បាំង អន្ទិបាលចេញនាំមុខពាហានទាំងពួងហើយថយរត់អន្ទិបាល ថយរត់ក្រោយគេបង្អស់ ៗ អន្ទិបាលជាមនុស្សមានលក្ខណៈក្លាហានទីង ណាស់ពៃយ៉ាងវិសេស កិច្ចការដែលអន្ទិបាលបានធ្វើមកហើយនោះ ដោយ អាស្រ័យចេះស្ទូនការពារមុខទីងត្រៀមខ្លួនបានត្រឹមត្រូវល្អណាស់ ៗ

## អំពីចម្បាំងពុយនិកលើកទីពីរ

អន្ទិបាលចាប់កេរ្តើងឈ្មោះទីងក្រុងរ៉ូមមុន គឺចាប់ផ្ដើមវាយស្រុក មួយក្នុងដែនអេស្ប៉ាញ ដែលនៅក្នុងអាណាព្យាបាលរបស់ពួករ៉ូម៉ាំង ទើប ក្រុងរ៉ូមចាត់កជទូតទៅស្នើដល់ស្រុកការថាស ថាការថាស់ត្រូវទទួល លក់ពិន័យជាច្រើនសំរេចហើយឲ្យរើសពីរផ្លូវ គឺទីងទទួលធ្វើសន្តិភាព ឬធ្វើចម្បាំង ៗ ពួកការថាស់បានឆ្លើយតបទៅក្រុងរ៉ូមវិញថា ត្រូវក្រុង រ៉ូមរើសយកតាមចិត្តចុះ នៅទីបំផុត ក្រុងរ៉ូមរើសយកខាងសង្គ្រាម ៗ

ឱកាសនេះ អន្ទិបាលមានចិត្តត្រេកអរណាស់ ដោយខ្លួនបានទទួល ធ្វើជាមេទ័ពលើកទ័ពទៅវាយសងសឹកក្រុងរ៉ូម ឲ្យសមទីងចិត្តចង់គំនុំស្អប់ ខ្ពើមរ៉ូម ទើបប្រុងប្រៀបត្រៀមខ្លួនលុកលុយក្រុងរ៉ូមតាមផ្លូវដើរគោក

ដោយមានបំណងថា កាលបើលើកទ័ពទៅដល់ស្រុកណា នឹងចាប់យកមនុស្សក្នុងស្រុកនោះធ្វើជាទាហានលើកទៅក្រោយក្រឯកេម ។ ការដែលរៀបចំធ្វើឲ្យបានសម្រេចតាមបំណងនេះ ទើបអន្និបាលលើកទ័ពឆ្លងទន្លេអែប្រ៉ និងឆ្លងភ្នំពីរ៉េណេ (Pyrénées) ទន្លេរ៉ូន (Rhone) និងភ្នំអាល់ប៍ (Alpes) ការដើរទ័ពតាមផ្លូវនេះប្រកបដោយសេចក្ដីលំបាកពន់ពេក ហើយដែលធ្វើបានផ្លូវនេះ មានតែកងទ័ពដែលជឿទុកចិត្តនាយទៅហ្វាយ (មេទ័ព) ហើយនាយទៅហ្វាយក៏ជឿទុកចិត្តកងទ័ពរបស់ខ្លួនផង ។ អន្និបាលមានទាហានដែលស្ម័គ្រចិត្តនឹងស្មោះត្រង់នឹងខ្លួនចំនួន ៥០.០០០ នាក់ សុទ្ធតែជាប់ចិត្តជាស្រេចក្នុងការច្បាំងឈ្នះប្ដូរស្លាប់ជាមួយគ្នា ។

ការលើកទ័ពដើរកាត់ផែនដីនៃពួកគោល្វា មិនជាលំបាកទេ ការឆ្លងទន្លេរ៉ូនបានរៀបចំធ្វើផែចម្លងពួកទាហានទៅបានដែរ តែការឆ្លងភ្នំអាល់ប៍នោះ ជាការលំបាកពន់ពេកហើយវេលាក៏ពុំនឹងរាំង មានតែទឹកកកដេរដាសពេញទៅ អន្និបាលត្រូវតែនាំទ័ពដើរកាត់ទឹកកក ព្រមទាំងដំរីនិងយានជំនិះសម្រាប់ដឹកស្បៀងអាហារផង ក្នុងរវាង ១៥ ថ្ងៃទើបឆ្លងផុត ។ ក្នុងគ្រានេះឯង អន្និបាលខូចខាតទាហានអស់ចំនួនពាក់កណ្ដាល (ព.ស. ៣២៥ មុន គ.ស. ២១៨) ។

(នៅមានត)

# ប្រស្នាចំរើនសតិបញ្ញា

(តទៅ)

## សេចក្តីឆ្លើយទី ២

ឯរដូវទាំង ៣ នេះ ខ្ញុំពោលថារដូវណា ស្រួលសប្បាយជាងរដូវណា ក៏ពិបាកថាដែរ ព្រោះក្នុងរដូវនីមួយ ៗ មានអាការស្រួលសប្បាយផ្សេង ៗ គ្នា ប៉ុន្តែបើលើកដាក់ថ្លឹងនឹងផ្ទឹមនឹងឃើញថា រដូវភ្លៀងមានទម្ងន់ជាងរដូវឯទៀត ដូច្នោះខ្ញុំបាទយល់ថា រដូវភ្លៀងស្រួលសប្បាយជាង ២ រដូវ ដូចមានសេចក្តីអធិប្បាយតទៅនេះ :

ក្នុងរដូវភ្លៀង អាកាសធាតុលើនឹងធាតុក្រោម ដែលមានសម្ផស្សមកប៉ះពាល់កាយ យើងក៏ដឹងខ្លួនថាជាធម្មតាប្រក្រតី គឺមិនក្តៅពេក មិនរងាពេក ទុកជាមានភ្លៀងធ្លាក់ចុះមកច្រើនក៏គ្រាន់តែរងាបន្តិចបន្តួច មិនបាច់ដណ្តប់ភួយជាប់នឹងខ្លួនដូចរដូវរងាទេ ទុកជាឥតភ្លៀងក៏មិនសូវក្តៅពេក ដល់ទៅលាបស្រឡាបប្លុងគឺតក់ហើយ ព្រោះព្រំមេឃទឹកអប់ដូចរដូវក្តៅឡើយ កំដៅនឹងរងាមិនខ្លាំងពេកទេ ទើបយល់ថារដូវភ្លៀងស្រួលសប្បាយជាង ព្រោះគាប់ធ្វើការងារដោយកំឡាំងកាយឬកំឡាំងគំនិតបាន ហើយហាក់ដូចជាបានប្រយោជន៍ច្រើនផងក្នុងរដូវនេះ ព្រោះកាលកាយស្រួលសប្បាយនាំចិត្តរីករាយជានិច្ច ល្មមឲ្យមានកំឡាំងធ្វើការ-

ឆាប់បាន ទឹងមានគំនិតគិតការអ្វីៗបានស្រួល មិនស្មុគស្មាញដូចរដូវក្តៅ មិនទាន់ដូចរដូវរងា សូម្បីតែដេកឬអង្គុយឥតធ្វើអ្វីក៏ស្រួលជាងរដូវឯទៀតៗដែរ មានសេចក្តីលំបាកបន្តិចបន្តួចខ្លះក្នុងខណៈដែលមានភ្លៀងធ្លាក់នោះ ទឹងទៅណាមកណាឬធ្វើការអ្វីមិនសូវស្រួល ដ្បិតមានទឹកភក់ជោកជាំឬមានភ្លៀងធ្លាក់រយ៉ៈៗមិនឈប់ឈរក៏នាំឲ្យរំខានចិត្តខ្លះដែរ តែមិនមែនជាហេតុធំប៉ុន្មានទេ មិនមែនមានភ្លៀងមកហាមឃាត់មិនឲ្យយើងទៅ មិនឲ្យធ្វើការកើតកាលណា បើក្រែងខ្លួនខាតពេលវេលាទឹងហោប្រពន្ធកូន បើងឲ្យយកអាវភ្លៀងមកពាក់ ឬគាំងយូប៉ាំងទៅក៏បានឥតខាតសល់ឡើយ ។ ប្រសិនបើមានការប្រញាប់ក្នុងមួយផងមួយកាលដែលជាការខានមិនបាន ដូចកិច្ចកដការជាដើម ទុកជាត្រូវធ្វើក្នុងវេលាកំពុងភ្លៀងខ្លាំងឬរងាខ្លាំង ឬក៏ក្តៅខ្លាំង ក្នុងរដូវទាំង ៣ នេះក៏ត្រូវតែធ្វើឲ្យស្របដូចគ្នា តែរដូវភ្លៀងគង់មានដរៀបជាងរដូវឯទៀត ព្រោះរដូវភ្លៀងទឹងធ្វើអ្វីហាក់ដូចស្រួលត្រជាក់ចិត្តផង បើក្តៅខ្លាំងច្រើនតែងាប់ទៀយហត់អស់កម្លាំង ហើយឈឺក្បាលវិលមុខក៏មាន បើរងាខ្លាំង កាយចិត្តច្រើនរួលប្រមូលសរសៃសណ្តាញ់មិនស្រួលខ្លួន ត្រឹមប៉ុណ្ណោះក៏ឃើញថា រដូវភ្លៀងល្អជាងរដូវឯទៀតៗ ទឹងប្រៀបសេចក្តីម្យ៉ាងទៀតឲ្យមើលឃើញច្បាស់ ដូចជាយើងត្រូវការប្រើក្មេងឬមនុស្សព្រសថាឲ្យទៅអង្គុយហាលភ្លៀងខណៈភ្លៀងកំពុងធ្លាក់ ដូចជាទុកតាំងភ្លៀង ១ ម៉ោង កំពុងក្តៅដូចឈរហាលថ្ងៃ

៣ ម៉ោង ឬកំពុងក្តៅខ្លាំងឡើង ១ ម៉ោង ៗ ឯចាស់ឬក្មេងនេះគង់តែយកខាងរដូវទឹកភ្លៀងវិញស្រួលសប្បាយជាង អញ្ជើញចាំមើលចុះ វេលាមានភ្លៀងធ្លាក់ៗ ក្មេងជាច្រើនចូលចិត្តរដូវទឹកភ្លៀងលេងសប្បាយជាវេលាយូរៗ មួយវិញទៀត ស្រុកយើងនេះជាប្រទេសក្តៅស្រាប់ហើយ ដល់រដូវក្តៅទើបមានអាកាសអន្ទះអន្ទែង ដល់រដូវរងាក៏ត្រជាក់ហួសពេក យើងដឹងខ្លួនថាមិនស្រួលទាំង ២ រដូវ ៗ តែដល់មករដូវភ្លៀងវិញ អាកាសក្តៅត្រជាក់នៅជាកណ្តាលៗ មិនសូវក្តៅមិនសូវរងា ល្មមសមនឹងប្រទេសដែលយើងនៅ ៗ

ហេតុដូច្នោះហើយ ទើបខ្ញុំបានយល់ថា រដូវភ្លៀងស្រួលសប្បាយក្រៃលែងជាងរដូវដទៃទាំងអស់ ៗ

នាយវិស្សាគរដ្ឋ

# រឿងព្រះរាជវិនិច្ឆ័យក្តីទាំង ៤

មាននិទានមួយដំណាលថា មានបុរសពីរនាក់ជាអ្នកម្រាក់នឹងគ្នា ។ ថ្ងៃមួយ អ្នកម្នាក់ទៅខ្ចីគោរបស់អ្នកម្នាក់ដើម្បីទឹមរទេះទៅលក់ទំនិញ គ្រាន់វេលាដែលខ្ចីនោះ បុរសអ្នកម្ចាស់គោទាំងប្តីទាំងប្រពន្ធនៅជួបជុំគ្នា ។ លុះអ្នកខ្ចីគោនោះលក់ទំនិញរួចហើយ ក៏នាំយកគោមកជូនវិញតែពុំឃើញអ្នក ឃើញតែប្រាក់[១] ក៏ជូនគោទៅប្រាក់ៗទទួលយកគោនោះ ។ តមកក្រោយ គោនោះក៏ងាប់ទៅ ។

លុះអ្នកម្ចាស់គោត្រឡប់មកផ្ទះវិញស្រាប់តែឃើញគោនោះងាប់ក៏ទឹកចិត្ត ហើយទៅប្រាប់ឲ្យអ្នកខ្ចីគោសងគោនោះវិញ ។ ឯអ្នកខ្ចីគោឆ្លើយថា កាលអញយកគោទៅសងពុំឃើញអ្នកទេ ឃើញតែប្រាក់ៗក៏ទទួលយកគោនោះដែរស្រឡះឥតតក់ស្លុតឡើយ ហេតុអ្វីក៏អ្នកបង្គាប់អញឲ្យសងដូច្នេះ ។ អ្នកម្ចាស់គោថា ហេតុដូចម្តេចក៏អ្នកមិនរង់ចាំអញមកដល់ផ្ទះសិន ម្តេចក៏យកគោទៅជូនឯប្រពន្ធអញវិញ ហេតុដូច្នេះត្រូវតែអ្នកសងគោអញវិញ ។ អ្នកខ្ចីគោឆ្លើយថា អញបានយកគោទៅជូនប្រពន្ធឯងស្រឡះហើយ បើអ្នកបង្ខំអញឲ្យសង ចាំអញទៅសូមព្រះរាជទានព្រះរាជទ្រព្យឲ្យបានសិន ។ បុរសទាំងពីរនាក់ពុំសុខចិត្តនឹងខ្លួន ក៏បណ្តើរគ្នាទៅប្តឹង

---

១ ពាក្យថា "ប្រាក់" ក្នុងទីនេះសំដៅយកកិរិយាជាប្រពន្ធរបស់អ្នកម្ចាស់គោ ។

ទៅក្រម លុះដើរបន្តិចទៅត្រូវថ្ងៃក្ដៅណាស់ ក៏នាំគ្នាចូលទៅជ្រកម្លប់ឈើមួយ ។

គាប់ជួនវេលានោះមានបុរសជាម្ចាស់នឹងខ្ញុំបណ្ដើរសេះមក ខ្ញុំដឹកសេះដើរមុន ម្ចាស់ដើរពីក្រោយឆ្ងាយ អាដឹកសេះបានជួបនឹងបុរសពីរនាក់ ដែលកើតក្ដីនឹងគ្នាអង្គុយនៅក្រោមម្លប់ឈើនោះ ក៏និយាយទៅថា ចូរទៅបរ ( ដេញ ) សេះឲ្យអញផង ។ បុរសនោះបរហើយសេះនៅតែមិនព្រមដើរក៏និយាយតបថា ទៅអើយ សេះទៅឯងមិនព្រមដើរទេ ។ ទើបអាដឹកសេះនោះថា ចូរទៅវាយមក ។ បុរសកើតក្ដីថា អញមិនហ៊ានវាយទេ ខ្លាចក្រែងបាក់បែកសេះទៅឯង ។ អាដឹកសេះថា វាយចុះមិនអីទេ ។ បុរសខ្ចីគោក៏វាយទៅ ត្រូវជើងសេះនោះបាក់ ។ ឯចៅម្ចាស់សេះដើរមកដល់ក៏ស្រែកថា ហេតុអ្វីក៏ទៅវាយសេះអញឲ្យបាក់ជើង ត្រូវទៅសងសេះឲ្យអញវិញ ។ បុរសខ្ចីគោឆ្លើយថា ចាំអញទៅសូមព្រះកដតានព្រះកដទ្រព្យបានសិនសឹមអញសងទៅ ហើយក៏នាំគ្នាដើរទៅរហូតដល់ផ្ទះមួយដែលជាផ្ទះរបស់សំឡាញ់នៃបុរសខ្ចីគោ ។

បុរសខ្ចីគោក៏ដើរចូលទៅផ្ទះសំឡាញ់ តែថ្ងៃនោះបុរសសំឡាញ់មិននៅ ។ តែប្រពន្ធនោះមានផ្ទៃពោះជាង ៧ ខែ ហើយនិយាយសុំទឹកផឹកថា ប្អាក់អើយអញសុំទឹកផឹកផង ។ នាងនោះក៏ស៊ិតទឹករួចចុះជណ្ដើរមកនឹងហុចឲ្យ ស្រាប់តែភាំជណ្ដើររបាក់ធ្លាក់ដល់ដីរលូតកូនទៅ ។ ឯប្ដីមកដល់

ឃើញហើយស្រដីថា ហេតុអ្វីក៏ក្មេងប្រើប្រពន្ធអញឲ្យសែកទឹកផឹកទាល់តែ ធ្លាក់ពីដណ្ដើរល្បែងកូនដូច្នេះ ក្មេងឯងតោងសងកូនអញ ។ បុរសខ្វីតោឆ្លើយថា ចាំអញទៅសូមព្រះរាជទានព្រះរាជទ្រព្យបានសមអញសងទៅឯងវិញ ហើយក៏នាំគ្នាបណ្ដើរទៅ លុះទៅដល់ទីមានដើមឈើច្រើន ទើបបុរសខ្វីតោនោះស្រដីថា អ្នកអើយ អ្នកនៅនេះចាំអញបន្តិចសិន ហើយគេចទៅឡើងដើមឈើមួយដោយទឹកក្នាញ់ថា ខ្លួននេះអភ័ព្វណាស់ នឹងលោតទំលាក់សម្លាប់ខ្លួនបង់ទៅ ។ ដួនជានៅខាងក្រោមដើមឈើនោះមានបុរសពីរនាក់អាពុកនឹងកូនកំពុងត្បាញកន្ទេល បុរសនោះលោតទៅក៏ធ្លាក់ទៅលើអាពុកដែលកំពុងត្បាញកន្ទេលនោះស្លាប់ទៅ ឯខ្លួនអ្នកលោតមិនស្លាប់ ។ បុរសជាកូនឃើញអាពុកស្លាប់ក៏ខឹងខ្លាំងណាស់ ស្រដីថា ត្រូវតែឯងសងអាពុកឲ្យអញវិញ ។ បុរសលោតពីចុងឈើឆ្លើយថា បើទៅឲ្យអញសងអាពុកអញក៏សង តែចាំអញទៅសូមព្រះរាជទានព្រះរាជទ្រព្យបានសិន ។ បុរសទាំង ៤ នាក់ជាគូវិវាទក៏បណ្ដើរគ្នាទៅរកចៅក្រមហើយប្ដឹងដោយនូវដំណើររៀងៗពីគ្នា ។

(នៅមានត)

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

## ឆ្នាំគំរប់ ១៤ ភាគទី ៣

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ


ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨៥

គ. ស. ១៩៤២

# បញ្ជីរឿង


ទំព័រ

១ — វិទ្យុទេសនា កណ្ឌទី ១ ព្រះតេជព្រះគុណ ព្រះសាក្យវង្ស គ្រូបង្រៀនសំស្ក្រឹតនៅសាលាបាលីជាន់ខ្ពស់សំរែក . . . . . . . . . . . . . . . . . ៣

២ — មហាភារត សង្ខេប (តមកនឹងចប់) . . . . . . . . . . . . . . . . ១២

៣ — រឿងព្រះបាទអសោកមហារាជ អ្នកអាចារ្យ គិម-អាន ប្រែពីភាសាបារាំងសែស មកជាខេមរភាសា (តមក) . . . . . . . . . . . . . . . . . ១៦

៤ — ភូមិសាស្ត្រសង្ខេបនៃនានាប្រទេស: អំពីភូមិសាស្ត្រប្រទេសអង់គ្លេស (តមក) . ២០

៥ — ពង្សាវតារក្រុងរោម ស្រង់និងប្រែអំពីគោលបារាំងផ្សេងៗក្នុងពង្សាវតារលោក (តមក) . . . . . . . . . . . . . . . . . . . . . . ២៣

៦ — ប្រស្នាចំរើនសតិបញ្ញា: ១១ និយាយពីវត្ថុទាំង ៣ ជាសេចក្ដីពោះថ្ងៃ (តមកនឹងចប់) . . . . . . . . . . . . . . . . . . . . . . ២៧

៧ — រឿងព្រេងខ្មែរ: "រឿងព្រះរាជវិនិច្ឆ័យក្ដីទាំង ៤ (តមកនឹងចប់) . . . . . . . . . ៣០


## រូបក្រៅរឿង


រូបក្បាលយក្ស នៅទ្វារបញ្ចោតប្រាសាទបាគង ការរចនាសម័យប្រាសាទព្រះគោ សតវត្សរ៍ទី ១៥ នៃពុទ្ធសករាជ . . . . . . . . . . . . . . . . . ១

# TABLE DES MATIÈRES

Pages

1. VIDYUDESANĀ (prédication faite à la Radio Phnôm-Penh) par le Vénérable Préas SAKYAVONG TATH, professeur à l'École Supérieure de Pāli .................................... 3

2. MAHĀBHĀRATA (sommaire) (suite et fin)..................... 12

3. Légende de l'Empereur Açoka de l'Inde antique, traduit du français en cambodgien par feu l'Achar KIM-ANN (suite) ............................................ 16

4. Géographie sommaire de divers pays: l'Angleterre (suite) ......................................... 20

5. Histoire de Rome. Extraits de divers documents de l'histoire universelle (suite) ...................................... 23

6. Réflexions sur les phénomènes naturels: I. Dialogue sur les trois saisons (suite et fin)............................ 27

7. Conte populaire Cambodgien inédit : "La procédure d'un roi au cours de quatre procès" (suite et fin)............................................ 30

HORS TEXTE

Tête de yaksa. Fausse-porte du groupe de Bakong.............. 1



រូបក្បាលយក្ខនៅទ្វារបញ្ជោតប្រាសាទបាគង ការរចនាសម័យប្រាសាទព្រះគោ សតវត្សរ៍ទី ១៥ នៃពុទ្ធសករាជ

# ធម៌ទេសនា តាមវិទ្យុ

នៅថ្ងៃអាទិត្យ ១៤ កើតខែផល្គុនឆ្នាំម្សាញ់ត្រីស័ក ព. ស. ២៤៩៥ (១-៣-៥២)

របស់

## ព្រះសាក្យវង្ស ហ-តាត

*សេចក្តីបរិយាយខាងដើមនៃធម៌ទេសនា*

*អស់លោក-អ្នក ជាពុទ្ធសាសនិកជនទាំងឡាយ,*

*ថ្ងៃនេះជាថ្ងៃ ១៤ កើត, តាមរបៀបថ្ងៃក្នុងពុទ្ធសាសនា ចាត់ជាថ្ងៃឧបោសថសីល គឺថ្ងៃដែលពុទ្ធសាសនិកជនត្រូវដកខ្លួនចេញពីការរវល់ ហើយចូលមកសង្រួមខ្លួនធ្វើចិត្តឲ្យអប់រំនៅក្នុងសីល ដើម្បីនឹងបង្ហាត់ចិត្តកុំឲ្យត្រាំនៅក្នុងកាមារម្មណ៍ជោកពេក ឲ្យចិត្តនោះងាកបែរទៅជាប់នៅក្នុងអារម្មណ៍ដ៏ស្អាតបរិសុទ្ធ ជាហេតុនឹងធ្វើខ្លួនឲ្យផុតចេញពីសេចក្តីទុក្ខព្រួយ ម្យ៉ាងទៀតចាត់ជាថ្ងៃធម្មស្សវនកាល គឺកាលត្រូវស្តាប់ធម៌ទេសនា ឯកាលដែលត្រូវស្តាប់ធម៌ទេសនានោះ តាមក្នុងសម័យបច្ចុប្បន្ននេះ ក្នុង ១ ខែមាន ៤ ដង គឺថ្ងៃ ៨ កើត, ១៤ កើត, ៨ រោច, ១៤ ឬ ១៥ រោច ។ ឯការស្តាប់ធម៌ជាកិច្ច ១ ដ៏ប្រសើរក្នុងព្រះពុទ្ធសាសនា ព្រោះព្រះបរមសាស្តាព្រះអង្គបានត្រាស់សំដែងថា ការស្តាប់ធម៌នាំឲ្យមានប្រយោជន៍ធំណាស់ដល់អ្នកស្តាប់ តែចំពោះអ្នកស្តាប់ដោយយកចិត្តទុកដាក់ ។*

ហេតុដូច្នេះ បានជាក្រសួងឃោសនាការ បានរៀបចំចាត់ការបង្កើត ឲ្យមានព្រះសង្ឃសំដែងធម៌ទេសនាតាមវិទ្យុគ្រប់១ខែ ៤ដង តាមកំណត់ ថ្ងៃឧបោសថសីល ឬថ្ងៃធម្មស្សវនកាល ដើម្បីត្រូវទៅសមតាមអធ្យា-ស្រ័យនៃពួកពុទ្ធសាសនិកជនទាំងឡាយក្នុងកម្ពុជរដ្ឋ ។

ថ្ងៃនេះជាថ្ងៃផ្ដើមសំដែងធម៌ទេសនាជាដំបូង គេទៅនឹងមានសំដែង រាល់ថ្ងៃសីល សូមអស់លោក-អ្នកពុទ្ធបរិស័ទទាំងឡាយ ដែលត្រូវការ នឹងស្ដាប់ធម៌ទេសនា ប្រឹងតាំងស្ដាប់ដោយយកចិត្តទុកដាក់ចុះ ដើម្បីឲ្យ កើតផលកើតប្រយោជន៍សមតាមប្រាថ្នាគ្រប់គ្នា ។

## អំពីធម៌ទេសនា

ក្នុងនេះ នឹងសំដែងធម៌ទេសនាជាសេចក្ដីសង្ខេបអំពីរឿងព្រះពុទ្ធ-សាសនានឹងផលប្រយោជន៍ដែលកើតឡើងពីព្រះពុទ្ធសាសនា ដូចសេច-ក្ដីតទៅនេះ ។

កោ សាសនោ បពិត្រសាធុសប្បុរសទាំងឡាយ អ្វីហៅថាព្រះ ពុទ្ធសាសនា ?

ពាក្យប្រៀនប្រដៅរបស់ព្រះអរហំសម្មាសម្ពុទ្ធឬធម៌ដែលព្រះសម្ពុទ្ធ ទ្រង់បានត្រាស់សំដែងប្រោសសត្វអស់ចំនួន ៤៥ ឆ្នាំ ហៅថា ព្រះពុទ្ធ-សាសនា ។

ព្រះសម្ពុទ្ធទ្រង់ជ្រាបហេតុដូចម្តេចបានជាព្រះអង្គខំសំដែងធម៌ទេសនាទុកឲ្យមានជាច្បាប់ព្រះពុទ្ធសាសនាតមក ?

ព្រះអង្គទ្រង់ជ្រាបច្បាស់លាស់អំពីចិត្តគំនិតនិងអជ្ឈាស្រ័យរបស់សត្វនិករទាំងអស់ ក្នុងវេលាដែលព្រះអង្គបានត្រាស់ពេញទីជាព្រះពុទ្ធប្រាកដក្នុងលោក ឃើញថា ពពួកសត្វគ្រប់ប្រភេទ សឹងមានបំណងត្រូវគ្នា គឺចង់បានសេចក្តីសុខ, សេចក្តីចំរើនរុងរឿង ប៉ុន្តែក្នុងចំណោមពួកសត្វទាំងនោះ មានសត្វនិករមានចំនួនជាច្រើន សឹងមានគំនិតឆេងឆាំងភ័ន្តច្រឡំដោយអាប់ឥតប្រាជ្ញាស្វែងរកសេចក្តីសុខមិនសម្រេច ត្រឡប់ទៅជាបានសេចក្តីទុក្ខព្រួយ សេចក្តីអាប់ឱនទៅវិញ ដោយហេតុធ្វើខុសឲ្យមានដំណើរពានទៅលើផ្លូវខុស ៗ ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបដូច្នេះហើយ ទើបទ្រង់មានព្រះទ័យករុណា ខំប្រឹងសំដែងធម៌ទេសនាប្រោសសត្វឥតមានគិតដល់សេចក្តីលំបាកព្រះកាយពល ដរាបដល់ពេលចូលព្រះបរម-និព្វាន ៗ ធម៌ទេសនាដែលព្រះអង្គសំដែងក្នុងសម័យនោះមានអាការដូចប្រទីបភ្លើងដែលព្រះអង្គអុជឲ្យមានពន្លឺខ្លាំង ហើយត្រោលបំភ្លឺដល់ពពួកសត្វដែលមានចក្ខុប្បសាទអាចឃើញរូបផ្សេង ៗ បានច្បាស់លាស់ ៗ ព្រះធម៌ទាំងប៉ុន្មានដែលទ្រង់បានសំដែង, លុះដល់ឥតអំពីព្រះអង្គទ្រង់ចូលបរិនិព្វានទៅ សឹងសល់នៅគង់នៅទាំងអស់ឥតមានខ្វះខាតដរាបដល់សព្វថ្ងៃនេះ ព្រះធម៌ទាំងនោះហើយ ដែលហៅថា ព្រះពុទ្ធសាសនា ៗ

ព្រះពុទ្ធសាសនាបើពោលដោយសង្ខេបតើអ្វីខ្លះ?

បើពោលដោយសង្ខេបមានត្រឹម ៣ យ៉ាង

១- សព្វបាបស្ស អករណំ ព្រះអង្គប្រដៅមិនឲ្យធ្វើបាប គឺសេចក្ដីអាក្រក់ សេចក្ដីខុសគ្រប់យ៉ាង ។

២- កុសលស្សូបសម្បទា ទ្រង់ប្រដៅឲ្យបំពេញកុសល គឺធ្វើសេចក្ដីល្អ សេចក្ដីត្រូវគ្រប់យ៉ាង ។

៣- សចិត្តបរិយោទបនំ ទ្រង់ប្រដៅឲ្យជំរះជុសខាត់ចិត្តរបស់ខ្លួនឲ្យស្អាតផូរផង់ កុំឲ្យប្រឡាក់ដោយគ្រឿងសៅហ្មង ។

ទាំង ៣ យ៉ាងនេះ ជាពាក្យទុកចំ, ពាក្យប្រៀនប្រដៅនៃព្រះពុទ្ធគ្រប់ព្រះអង្គ ។ ព្រះពុទ្ធសាសនាទាំង ៣ យ៉ាងនេះ បើនឹងអធិប្បាយពង្រីកឲ្យពិស្ដារទៅ សឹងមានចំនួនច្រើនលើសលុប ហេតុចប់ព្រះត្រៃ-បិដកទាំងមូល ឬក៏ចប់ធម៌ទាំង ៨ ហ្មឺន ៤ ពាន់ធម្មក្ខន្ធ ។

ហេតុនេះ សូមពួកពុទ្ធបរិស័ទ្យទាំងឡាយតាំងចិត្តឲ្យដាច់ខាត ត្រង់ណាដែលអាក្រក់កុំធ្វើ ធ្វើតែត្រង់ល្អ កិច្ចត្រង់ណាដែលខុសត្រូវបោះលាស់ចោលចេញកុំស្ដាយ ហើយប្រកាន់យកតែត្រង់កិច្ចដែលត្រូវល្អ ព្រមទាំងធ្វើចិត្តរបស់ខ្លួនកុំឲ្យសេមសោមង៉ុមតាមទំនងបក្កិលេសធម៌ណាមួយឡើយ ដើម្បីឲ្យសមតាមពុទ្ធសាសនាទាំង ៣ យ៉ាងខាងលើនេះ ។

ពួកជនទាំងឡាយ ដែលជាអ្នកប្រតិបត្តិកាន់តាមព្រះពុទ្ធសាសនា ហៅថា ពុទ្ធសាសនិកជន ។

ចុះពុទ្ធសាសនិកជននោះ គឺជនជាតិអ្វីខ្លះ?

ពុទ្ធសាសនិកជន ឥតមានកំណត់ជាតិណាទេ, តាមតែជនជាតិណាក៏ដោយ តែមានចិត្តជ្រះថ្លាស្រឡាញ់ព្រះពុទ្ធសាសនាថាជាពាក្យប្រៀនប្រដៅ គួរគោរពកាន់តាម ហើយប្រតិបត្តិធ្វើតាម ក៏ហៅថា ពុទ្ធសាសនិកជនទាំងអស់ ។ ជនណាមួយ មិនជឿមិនកាន់តាម ក៏មិនមែនបានឈ្មោះថាជាអ្នកកាន់ព្រះពុទ្ធសាសនាឡើយ ទោះបីជនជាតិខ្មែរយើងក្នុងកម្ពុជរដ្ឋទាំងមូលនេះ ដែលពួកជននានាប្រទេសគេធ្លាប់ដឹងធ្លាប់យល់ថាជាអ្នកកាន់ព្រះពុទ្ធសាសនាទាំងអស់គ្នានោះក៏ដោយ បើតាមសេចក្ដីពិតមិនប្រាកដដូច្នោះទេ តាមសេចក្ដីពិតគឺក្នុងចំណោមជនជាតិខ្មែរយើងទាំងអស់, អ្នកណាជឿកាន់តាមច្បាប់ពុទ្ធសាសនា អ្នកនោះឈ្មោះថាពុទ្ធសាសនិកជនបាន អ្នកណាមិនជឿមិនកាន់តាម អ្នកនោះមិនមែនជាពុទ្ធសាសនិកជនទេ ។

## អំពីផលប្រយោជន៍

ព្រះពុទ្ធសាសនា មានប្រយោជន៍ដូចម្ដេចខ្លះ?

ព្រះពុទ្ធសាសនា មានប្រយោជន៍ច្រើនយ៉ាង តែបើពោលដោយសង្ខេបមាន ៣ យ៉ាង:

១ – ទិដ្ឋធម្មិកត្ថ មានប្រយោជន៍ក្នុងបច្ចុប្បន្ន គឺអ្នកដែលកាន់ព្រះពុទ្ធសាសនា តាមទំនងពិតនោះ នឹងត្រូវបានទទួលប្រយោជន៍ក្នុងសម័យបច្ចុប្បន្នទាន់ភ្នែកឃើញ ។

២ – សម្បរាយិកត្ថ មានប្រយោជន៍ក្នុងបរលោក គឺអ្នកកាន់ព្រះពុទ្ធសាសនាដោយត្រឹមត្រូវនោះ នឹងត្រូវទទួលប្រយោជន៍ក្នុងពេលដែលខ្លួនឃ្លាតចេញអំពីលោកនេះ ហើយទៅកើតក្នុងលោកថ្មីទៀត ។

៣ – បរមត្ថៈ មានប្រយោជន៍យ៉ាងឧត្តមក្រៃលែង គឺអ្នកកាន់ព្រះពុទ្ធសាសនាដោយស៊ប់សួន បានប្រដៅខ្លួនឲ្យលុះក្នុងគន្លងនៃសីលធម៌បានហើយ នឹងត្រូវទទួលប្រយោជន៍យ៉ាងឧត្តមបំផុតពោលគឺព្រះនិព្វាន ។

ព្រះសម្មាសម្ពុទ្ធទ្រង់ប្រដៅពុទ្ធសាសនិកជនឲ្យធ្វើដូចម្តេចខ្លះ ទើបនាំឲ្យបានទទួលផលប្រយោជន៍ក្នុងបច្ចុប្បន្ននេះ?

ព្រះអង្គប្រដៅច្រើនយ៉ាងៈ

១ – ទ្រង់ប្រដៅថាកុំឲ្យខ្ជិលច្រអូស ត្រូវខំប្រឹងរៀនសូត្រឲ្យបានចេះដឹងឡើង ដើម្បីបំបាត់សេចក្តីល្ងង់ខ្លៅ, ត្រូវខំប្រឹងធ្វើការងាររកស៊ីចិញ្ចឹមជីវិតតាមផ្លូវដែលប្រាសចាកទោស ឲ្យមានទ្រព្យសម្បត្តិឡើង ដើម្បីបំបាត់សេចក្តីទាល់ក្រលំបាក ។

២ – ទ្រង់ប្រដៅឲ្យចេះថែរក្សាទ្រព្យសម្បត្តិដែលគេបានមកហើយ ឲ្យបានគង់ កុំឲ្យវិនាសអន្តរាយ ទៅដោយអបាយមុខទាំង ៤ យ៉ាង គឺ លេងល្បែងស្រី, ផឹកស្រា, លេងល្បែងភ្នាល់មានបៀបៅជាដើម និង ការសេពគប់រួមគំនិតជាមួយនឹងមនុស្សខូច ។

៣ – ទ្រង់ប្រដៅថាឲ្យមានកល្យាណមិត្ត គឺមិត្តសំឡាញ់ដែល ជាមនុស្សត្រឹមត្រូវល្អ អាចជួយរំពុកដាស់តឿនខ្លួនបាន ក្នុងវេលាដែល ខ្លួនធ្វេសប្រហែសមួយដងមួយកាល មិនត្រូវទៅសេពគប់ស្និទ្ធស្នាល នឹងមនុស្សពាលខូចអាក្រក់នោះឡើយ ។

៤ – ទ្រង់ប្រដៅថា ពេលដែលនឹងចាយវាយទ្រព្យសម្បត្តិចិញ្ចឹម ជីវិតរបស់ខ្លួននឹងបុត្រាបុត្រីរបស់ខ្លួន ត្រូវចាយឲ្យសមរម្យតាមទ្រព្យ ដែលគេបានមក កុំចាយឲ្យហួសមានហួសបាន ។

៥ – ទ្រង់ប្រដៅឲ្យមាតាបិតា នឹងបុត្រាបុត្រីចេះសង្គ្រោះនឹងគោរព ប្រតិបត្តិគ្នាទៅវិញទៅមក ជាហេតុនឹងឲ្យបានសុខស្រួលក្នុងបច្ចុប្បន្ននេះ គឺមាតាបិតាបើមានបុត្រាបុត្រី មិនត្រូវបណ្ដែតបណ្ដោយតាមអំពើចិត្តរបស់ កូននោះឡើយ ត្រូវមាតាបិតាតាំងចិត្តសង្គ្រោះរំពុកដាស់តឿនប្រដៅកូន របស់ខ្លួន កុំឲ្យធ្វើអំពើអាក្រក់ដែលជាចំនងនាំឲ្យមានទុក្ខទោសក្នុងបច្ចុប្បន្ន

និងបរលោក ឲ្យកូនចេះធ្វើអំពើល្អ ឲ្យកូនខំប្រឹងរៀនចំណេះវិជ្ជាតាមផ្លូវលោកនិងផ្លូវធម៌ ឲ្យបានចេះដឹងកុំឲ្យកូនធ្លាក់ខ្លួនទៅជាមនុស្សល្ងង់ខ្លៅជាដើម ។ ចំណែកបុត្រាបុត្រីត្រូវធ្វើខ្លួនជាមនុស្សស្គាល់គុណមាតាបិតា ហើយចេះគោរពមាតាបិតា មានកិច្ចថែរក្សាចិញ្ចឹមមាតាបិតាជាដើម ដើម្បីឲ្យមាតាបិតាបានសេចក្ដីសុខស្រួលដោយសារខ្លួន ក្រៅពីនេះព្រះអង្គបានប្រដៅប្រាប់អំពីស្វាមី-ភរិយាត្រូវរក្សាគ្នាទៅវិញទៅមកដោយអាការដូច្នេះៗ មិត្រសំឡាញ់ត្រូវតាំងចិត្តឲ្យល្អរកគ្នាទៅវិញទៅមកដូច្នេះៗ គ្រូនិងសិស្សត្រូវសង្គ្រោះ ត្រូវប្រតិបត្តិទៅវិញទៅមកដូច្នេះៗ ទើបបានសេចក្ដីសុខ-ចំរើន ។

ច្បាប់ប្រដៅដែលព្រះសម្ពុទ្ធទ្រង់ត្រាស់ទុក ដើម្បីឲ្យកើតប្រយោជន៍ជាសុខក្នុងបច្ចុប្បន្ននេះ មានច្រើនលើសលុបពេក ដែលនាំយកមកពណ៌នាក្នុងទីនេះ ជាសេចក្ដីសង្ខេបត្រឹមប៉ុណ្ណោះ ។

សូមអស់លោក-អ្នកជាពុទ្ធបរិស័ទ្យទាំងឡាយ សង្កេតមើលចុះ ច្បាប់ព្រះពុទ្ធសាសនាដែលប្រដៅមនុស្សឲ្យធ្វើតាម គ្រាន់តែជាសេចក្ដីសង្ខេបប៉ុណ្ណោះ គង់ឃើញថា ប្រសិនបើជនណាមួយអាចធ្វើតាមបាន នឹងនាំផលនោះឲ្យបានសម្រេចប្រយោជន៍ច្រើនយ៉ាង:

១ – នឹងបានជាមនុស្សចេះដឹង

២ – នឹងបានជាមនុស្សមានទ្រព្យសម្បត្តិ

៣ – នឹងបានជាមនុស្សថ្កុំថ្កើងមានមុខមាត់គួរគេរាប់រក

៤ – នឹងបានសេចក្តីសុខស្រួលក្នុងវង្សត្រកូលរបស់ខ្លួន ។

ឯផលប្រយោជន៍ក្នុងបរលោកនឹងប្រយោជន៍ជាន់ខ្ពស់គឺព្រះនិព្វាន ដែលកើតឡើងដោយអំណាចប្រតិបត្តិតាមច្បាប់ព្រះពុទ្ធសាសនានោះ មានច្រើនជាអនេក មិនអាចនឹងស្រង់យកមកសំដែងក្នុងពេលនេះបានឡើយ ព្រោះពេលនេះខ្វះពេក ទុកឱកាសដល់ទៅថ្ងៃសីលតទៅ លោកជាធម្មកថិកនឹងស្រង់យកមកសំដែងជាលំដាប់តទៅទៀត ។

ក្នុងពេលនេះ សូមបញ្ចប់ត្រឹមតែប៉ុណ្ណោះ ។

មហាភារតៈ

(តមកពីលេខមុន)

ព្រះបាទក្រិស្ណៈមានព្រះបន្ទូលដូច្នេះថា :

— ម្នាលអជ៌ុនៈ កាលបើមនុស្សណាមួយផ្តាច់ផ្តិលតណ្ហាទាំងពួង ដែលតែងតែកកួនដល់ចិត្តរបស់ខ្លួន ហើយដែលចូលទៅជាប់នៅក្នុងហទយ-វត្ថុក៏ កាលបើមានចិត្តរីករាយនឹងខ្លួនឯងហើយមានចិត្តសន្តោសផង មនុស្សនេះហើយដែលគេហៅថា ជាអ្នកមានធម៌សប្បុរសនៅក្នុងខ្លួន ។

— កាលបើមានសត្រូវមកដល់ក៏មិនតក់ស្លុត មិនញាប់ញ័រក្នុងពេលដែលមានទុក្ខសោក ផ្តាច់បំណងស្នេហាចេញ មិនមានអារម្មណ៍ខាងក្រៅនាំឲ្យកើតទោស, កោធនឹងភ័យភិត បុគ្គលនេះជាអ្នកមានតទ្រឹប្រាជ្ញាជាសម្បត្តិ ។

— កាលបើបានប្រតិបត្តិដោយធម៌សប្បុរសដូច្នេះហើយ បុគ្គលនេះមិនមានអគតិធម៌សោះឡើយ ជាអ្នកមិនមានមានះរឹងត្អឹង ជាអ្នកមិនហួងហែង មិនត្រេកអរ មិនផ្តួលទៅតាមអារម្មណ៍ ជាអ្នកស្គាល់ល្អស្គាល់អាក្រក់, មិនរីករាយនឹងអំពើមួយហើយត្រូវគិតដៀលអំពើមួយទៀត ។

— មានសេចក្តីប្រៀបដូចអណ្តើកដែលលៀនចេញនឹងលបចូលនូវក្បាល ទីងជើងដៃក្នុងស្នូករបស់វាយ៉ាងណា ឯសប្បុរសក៏ដកចិត្តចេញ

ពីអារម្មណ៍ផ្សេងៗខាងក្រៅមិនឲ្យជាប់ជាមដល់ចិត្ត ក៏មានឧបមេយ្យដូច្នោះដែរ ទើបសប្បុរិសធម៌របស់បុគ្គលនោះ ជាធម្មជាតិដ៏ចុងពិតប្រា-កដ ។

– បុគ្គលណាមួយបានលះបង់អស់ទាំងមានះ ឈ្លានពានដែលខ្លួនផ្តាច់ផ្តិលបានហើយនោះ បុគ្គលនេះក៏នៅតែត្រូវខំធ្វើកិច្ចការសព្វសារពើដើម្បីជីវិត ត្រូវបំពេញកិច្ចជាមុខក្រសួងរបស់ខ្លួន ដោយមិនបាច់ព្រួយបារម្ភនឹងហេតុគេខ្ញុំទាំងអស់ ទឹងព្យាយាមធ្វើទៅតាមរបៀបរបបផង ទើបមានមនុស្សរាប់អាន (ថាជាមនុស្សល្អ) ។ បើមិនប្រព្រឹត្តដូច្នេះទេ សូម្បីតែខ្លួនលោកក៏មិនអាចនឹងចិញ្ចឹមអាត្មាឲ្យរស់នៅបានផង ។

— អ្នកឯណាមួយនៅក្នុងលោកនេះ មិនគិតគូរធ្វើការងារទៅតាមសេចក្តីប្រែប្រួលនៃជីវិតសត្វលោក ហើយជាប់នៅក្នុងអំពើបាប សប្បាយនឹងបាប អ្នកនោះទុកជារស់នៅក៏ឥតប្រយោជន៍អ្វីឡើយ ។

— ហេតុនេះហើយទើបត្រូវផ្តាច់សេចក្តីកង្វល់ចេញឲ្យអស់ ហើយបំ-ពេញការកិច្ចដែលខ្លួនត្រូវធ្វើវិញ ក្នុងការធ្វើការកិច្ចនេះសោតទៀត ក៏ត្រូវបំពេញបរិច្ចាគដោយឥតស្តាយផង ការធ្វើដូច្នេះទើបមនុស្សបានលុះដល់ឋានៈដ៏រុងរឿងខ្ពង់ខ្ពស់មិនខាន ។

(១)សេចក្ដីទាំងនៃពាក្យភាសាដែលហៅថា ភគវទ្គីតា នេះ នឹងឃើញថាអជ៌ុនៈនឹងក្រឹស្ណៈនិយាយឆ្លើយឆ្លងគ្នាទៅវិញទៅមក ដើម្បីថ្លែងសេចក្ដីឲ្យឃើញហេតុផលដ៏ត្រឹមត្រូវតែរៀងខ្លួន តែនៅទីបំផុតនៃសេចក្ដីសន្ទនានេះ ក្រឹស្ណៈបានបំភ្លឺអជ៌ុនៈឲ្យយល់ច្បាស់ថា ធម្មតាកើតមកជាមនុស្សទុកជាយើងទំប្រតិបត្តិយ៉ាងម៉ឺងម៉ាត់មិនឲ្យមានលំអៀងឃ្លៀងឃ្លាតអំពីគន្លងធម៌យ៉ាងណាក៏ដោយ យើងត្រូវតែធ្វើការកិច្ចសម្រាប់ជីវិតរបស់យើងឲ្យប្រព្រឹត្តទៅបានស្រួលនឹងចំរើនជានិច្ច ទើបខ្លួនយើងនឹងសីលធម៌របស់យើងមានសេចក្ដីចំរើនដ៏ខ្ជាប់ខ្ជួន មិនងាយនឹងលំលោយដោយពេលចាប់បើស ៗ ឯអារ្យធម៌ វប្បធម៌ នឹងសីលធម៌របស់ប្រទេសនីមួយៗ ដែលនឹងបានចំរើនរឹងស្ថិតស្ថេរនៅបានដោយសារតែការប្រតិបត្តិតាម ទំនុកបំរុងនឹងការពារកុំឲ្យសត្រូវខាងក្នុងនឹងខាងក្រៅបំផ្លាញឲ្យហិនហោច ។

កម្ពុជរដ្ឋ ជាដែនពុទ្ធសាសនិកជនដែលបានយានប្ដូលទ្ធិថេរវាទប្រជាជនច្រើនតែស្លូតត្រង់នឹងប្រតិបត្តិតាមពុទ្ធសាសនាយ៉ាងម៉ឺងម៉ាត់នឹងច្រើនតែសន្ដោស ចូលចិត្តនៅស្ងប់ស្ងៀម មិនមានទស្សន័យរុះរើកែប្រែទៅតាមកាលសម័យ ទើបអ្នកប្រទេសក្រៅសំឡឹងឃើញថា ជនជាតិខ្មែរនៅប្រកាន់ទំនៀមទម្លាប់ជាប់ស្និទ្ធណាស់ បានជាមិនចំរើនរួសរាន់

---
១ ចាំងពីត្រឹមនេះទៅជាសេចក្ដីបន្ថែមរបស់អ្នកប្រែ ។

កាលសម័យទំនើប ៗ ការដែលខ្មែរជាចំនួនច្រើនមិនព្រមប្រែប្រួលនេះ ហើយ ដែលយើងមើលឃើញច្បាស់ថែងថា ខ្មែរគង់ទ្រង់នៅជាខ្មែរដដែល មិនក្លាយប្ដូរលាយជាតិចាល់តែមើលមិនស្គាល់ ដូចពួកចាមនៅក្នុងដែនអណ្ណាមជាដើម ៗ មួយវិញទៀត ជាតិខ្មែរដែលគង់ទ្រង់នៅជាជាតិខ្មែរសព្វថ្ងៃនេះ ដោយសារតែជាតិខ្មែរកាន់ព្រះពុទ្ធសាសនា យ៉ាងម៉ឺងម៉ាត់ អានុភាពរបស់សាសនានេះនាំឲ្យជាតិខ្មែរទីងសំដីភាសាខ្មែរ អក្សរសាស្ត្រខ្មែរ ទំនៀមទម្លាប់របស់ខ្មែរ ទើបគង់ទ្រង់នៅជានិច្ច ៗ

ចប់រឿងមហាការតដោយសង្ខេបតែប៉ុណ្ណេះ ៗ

ទេមរង្សី

# រឿងព្រះបាទអសោក

(តមក)

ព្រះបាទអសោកមិនគ្រាន់តែផ្សាយអំណាចចក្រពត្តិទៅលើអាណា-ខេត្តដែលជាកិត្តិយសរបស់ព្រះអង្គប៉ុណ្ណោះទេ ព្រមទាំងបានផ្សាយព្រះពុទ្ធសាសនាដោយសេចក្តីជ្រះថ្លាដែលជាកិត្តិគុណដល់ទ្វីបអាស៊ីទាំងមូលថែមទៀតផង ។ ក្នុងសៀវភៅបារាំងដែលប្រែមកពីសំស្ក្រឹតថា: ព្រះបាទអសោកបានជ្រះថ្លាក្នុងព្រះពុទ្ធសាសនាដោយឫទ្ធិរបស់សមុទ្រភិក្ខុ តែក្នុងមហាវង្ស៖ ព្រះបាទអសោកកាលដែលព្រះអង្គបានរាជាភិសេកជាស្តេចគ្រងក្រុងបាដលិបុត្រហើយ ព្រះអង្គមានឫទ្ធានុភាពផ្សាយទៅលើមួយយោជន៍ ទៅក្រោមមួយយោជន៍ មានពួកទេវតា, នាគ, យក្ស, មនុស្ស, បក្សី, សត្វចតុប្បាទនិងសត្វទ្វេបាទ ចូលគាល់បម្រើព្រះអង្គជានិច្ច ទ្រង់បានសោយរាជ្យជាស្តេចចក្រពត្តិ សម្បូណ៌ដោយសេចក្តីសុខ ដោយរាជបរិវារទាំងអស់នោះទំនុកបម្រុងមិនឲ្យខ្វល់ព្រះរាជហឫទ័យ[1] ។

ថ្ងៃមួយ ព្រះបាទអសោកប្រថាប់នៅទៀបសីហបញ្ជរទ្រង់ទស្សនា-ការនិគ្រោធសាមណេរជាព្រះអរហន្តដែលជាព្រះយោគាវចរសង្រួមឥន្ទ្រិយដ៏ស្រគត់ស្រគំនិមន្តរម្យទំទៅក្នុងព្រះលាន មានអាការកិរិយាគួរឲ្យជ្រះថ្លាពន់ពេក ក៏ព្រះអង្គមានទឹកព្រះហឫទ័យរីករាយដោយសមាធិ-

---

១ មើលសេចក្តីពិស្តារក្នុងមហាវង្ស ។

គុណរបស់និគ្រោធសាមណេរនោះ ៗ មានសេចក្ដីជំណាលក្នុងគម្ពីរនោះ
ថា និគ្រោធសាមណេរនោះជាឱរសរបស់សុមនរាជកុមារជាបុត្រនៃព្រះ
បាទពិន្ទុសារ: លោកអង្គនោះត្រូវជាក្មួយរបស់ព្រះបាទអសោកនោះ ៗ
លុះព្រះអង្គទតឃើញដូច្នោះហើយ ក៏មានសេចក្ដីជ្រះថ្លាពន់ពេក ដោយ
កុសលដែលបានធ្វើមកអំពីអតីតជាតិជួយដាស់តឿនព្រះរាជហឫទ័យ ព្រោះ
កាលបុព្វជាតិមុនក្សត្រទាំងបីព្រះអង្គ គឺព្រះបាទអសោក ១ ព្រះបាទទេវា-
នម្បិយតិស្ស ១ និគ្រោធសាមណេរ ១ ទាំងបីនេះត្រូវជាបងប្អូននឹងគ្នា ជា
ពាណិជទឹកឃ្មុំនៅក្នុងក្រុងពារាណសី គ្រានោះមានព្រះបច្ចេកពុទ្ធ ១ អង្គ
គង់នៅលើភ្នំគន្ធមាទន៍ កើតវណ្ណរោគ (រោគស្គមលឿង) ព្រះបច្ចេកពុទ្ធឯ
ទៀតត្រាច់ស្វែងរកទឹកឃ្មុំទៅដល់ក្រុងពារាណសីក៏បានជួបនឹងកុម្ភទាសី
ម្នាក់ហើយសួរថា " នែនាង, ស្រុកនេះអ្នកណាគេមានទឹកឃ្មុំ " នាងកុម្ភ-
ទាសីបានលើកដៃចង្អុលបង្ហាញផ្ទះពាណិជនោះហើយអង្គុយគិតថា "បើ
ព្រះបច្ចេកពុទ្ធអង្គនុះបានទឹកឃ្មុំអំពីសំណាក់មធុពាណិជហើយ អាត្មា
អញនេះក៏ជួយត្រេកអរនឹងកុសលរបស់គេនោះណាស់ តែបើលោកមិន
បានទេ អាត្មាអញនឹងយកក្រមាបង់កមួយនេះទៅចំណាយយកប្រាក់
មកទិញទឹកឃ្មុំថ្វាយព្រះបច្ចេកពុទ្ធម្ចាស់អង្គនោះពាល់តែបាន " ៗ ឯព្រះ
បច្ចេកពុទ្ធទៅរកទឹកឃ្មុំពាណិជ ទទួលពេលនោះ ពាណិជជាប្អូននៅផ្ទះតែ
ម្នាក់ឯង លុះឃើញដូច្នោះក៏មានសេចក្ដីជ្រះថ្លាស្ទុះទៅយកទឹកឃ្មុំមកប្រ-

គេនព្រះបច្ចេកពុទ្ធពេញហូរហៀរហួសកណ្ដាប់មាត់បាត្រ ហើយតាំងសេចក្ដីប្រាថ្នាថា: "ដោយអំណាចកុសលនៃបុណ្យម្ហូបបបរចេតនារបស់ខ្ញុំដ៏បរិសុទ្ធស្អាតក្នុងគ្រានេះ សូមឲ្យខ្ញុំបានជាស្ដេចឯករាជជាធំលើសកលជម្ពូទ្វីប សូមឲ្យរាជអាណាចក្ររបស់ខ្ញុំផ្សាយទៅលើផែនដី ១យោជន៍ ទៅក្រោមផែនដី ១ យោជន៍ កុំឲ្យអ្នកណាមួយមានសម្បត្តិសម្បូណ៌ស្មើនឹងសម្បត្តិរបស់ខ្ញុំព្រះអង្គឡើយ" ។ ព្រះបច្ចេកពុទ្ធបានធ្វើអនុមោទនាហើយ និមន្តត្រឡប់មកជួបនឹងនាងកុម្ភទាសីវិញ នាងសួរថា "បពិត្រព្រះអង្គដ៏ចំរើន ព្រះករុណាបានទឹកឃ្មុំសម្រេចដូចសេចក្ដីប្រាថ្នាហើយឬ?" ។ ព្រះបច្ចេកពុទ្ធត្រាស់តបថា "ម្នាលនាង ទឹកឃ្មុំនោះអាត្មាបានហើយ" នាងកុម្ភទាសីទូលសួរទៀតថា "កាលនាយពាណិជថ្វាយទឹកឃ្មុំនោះ គេប្រាថ្នាទៅអនាគតដូចម្ដេចខ្លះ ព្រះអង្គ?" ព្រះបច្ចេកពុទ្ធរៀបរាប់ប្រាប់សេចក្ដីប្រាថ្នាសព្វគ្រប់ នាងបានដឹងដូច្នោះ ទើបនិមន្តឲ្យព្រះបច្ចេកពុទ្ធនៅចាំសិន ឯខ្លួននាងត្រឡប់ម្នីម្នាទៅផ្ទះយកក្រមាចាស់មកផ្លាស់ យកក្រមាថ្មីទំពីខ្លួនទៅលាងទឹកឲ្យស្អាតល្អហើយ យកមកថ្វាយដល់ព្រះបច្ចេកពុទ្ធអង្គនោះ ទើបតាំងប្រណិធានថា "ដោយអំណាចកុសលដែលខ្ញុំម្ចាស់បានថ្វាយសំពត់សាដកនេះ អំណើះទៅអនាគត កាលបើនាយពាណិជទឹកឃ្មុំបានជាស្ដេចចុល្លចក្រពត្រាធិរាជជាធំក្នុងសកលជម្ពូទ្វីបពេលណា សូមឲ្យខ្ញុំម្ចាស់បានជាអគ្គមហេសីនៃស្ដេចអង្គនោះក្នុងពេល

នោះ, សូមឲ្យខ្ញុំម្ចាស់មានរូបឆោមដ៏ល្អគួរគេភឹតពិលរមិលមើលហើយ មានយសសក្តិនិងសម្បត្តិជាសិរីសួស្តី ជាទីពេញចិត្តនៃជនទាំងពួងក្នុងលោក ។ ព្រះបច្ចេកពុទ្ធបានធ្វើអនុមោទនារួចហើយលោកហោះទៅកាន់អាកាសហូតដល់ភ្នំគន្ធមាទន៍នោះ ។ ចំណែកបងទាំងពីរនាក់របស់ពាណិជត្រឡប់មកផ្ទះវិញក៏បានត្រេកអរនឹងកុសលដែលប្អូនធ្វើហើយនោះឯង ។

លុះពាណិជទាំង ៣ នាក់ធ្វើកាលកិរិយាទៅបានសោយសម្បត្តិមនុស្សនិងសម្បត្តិសួគ៌ជាច្រើនជាតិ ដល់មកក្នុងសាសនានៃព្រះពុទ្ធជាម្ចាស់យើងនេះ ខាងក្រោយបរិនិព្វានប្រមាណ ២០០ ឆ្នាំសេស ក៏ពាណិជប្អូនដែលបានថ្វាយទឹកឃ្មុំផ្ទាល់នឹងដៃខ្លួន បានមកជាស្តេចអសោក នាងកុម្ភទាសីដែលចង្អុលផ្លូវបង្ហាញកន្លែងលក់ទឹកឃ្មុំនឹងបានថ្វាយសំពត់សាដកនោះ បានជាអគ្គមហេសី ព្រះនាមនាងអសន្ធិមិត្តា ពាណិជជាបងច្បង បានជានិគ្រោធសាមណេរ ពាណិជជាកណ្តាលបានជាព្រះបាទទេវានម្បិយតិស្ស ។

(នៅមានត)

# ភូមិសាស្ត្រសង្ខេប
## នៃប្រទេសអង់គ្លេស (តមក)

ភ្លៀងធ្លាក់ក្នុងប្រទេសអង់គ្លេស មានចំនួនច្រើនជាងប្រទេសដទៃៗ ក្នុងទ្វីបអឺរ៉ុប ។ មានភ្លៀងធ្លាក់ច្រើនក្នុងរដូវរងា ច្រើនជាងរដូវក្តៅបន្តិចបន្តួច ។

ដី — ដីក្នុងប្រទេសអង់គ្លេសជាដីមានជីជាតិល្អ ជាទីគួរដាំដំណាំបានផលល្អជាជាងប្រទេសឯទៀតក្នុងទ្វីបអឺរ៉ុប ។ ដោយធម្មជាតិដីមានជីជាតិល្អ ហើយជនជាតិអង់គ្លេសមានចំណេះចេះធ្វើល្អក្នុងរបរក្សេត្រកម្ម ទើបធ្វើឲ្យរបរដំណាំមានផលចំរើនយ៉ាងវិសេស ។

ភាគផែនដីដែលប្រើដាំដំណាំក្នុងអង់គ្លេសប្រមាណជាង ៣ ក្នុង ៤ នៃភាគផែនដី ។ ក្នុងស្កុស្សប្រមាណ ១ ភាគក្នុង ៤ ភាគ ។

ដំណាំ — មានការដាំស្មៅ (សម្រាប់ចិញ្ចឹមសត្វ) និងស្រូវផ្សេងៗ ដំឡូងបារាំងនិងបែត្តរ៉ាវ, សណ្តែកផ្សេងៗមានដាំច្រើនខាងទិសខាងកើត ។ ទុកជាមានដាំស្រូវផ្សេងៗជាចំនួនច្រើនដល់ម្ល៉េះក៏នៅតែមិនល្មមបរិភោគឲ្យគ្រប់គ្រាន់តាមចំនួនមនុស្សក្នុងស្រុកទេ គេទិញស្រូវពីប្រទេសផ្សេងៗក្នុង ១ ឆ្នាំៗ ជាចំនួនច្រើន ។

សត្វ — មានកែះ, គោ, ជ្រូកនិងត្រីជាសំខាន់ ក្នុង ព.ស. ២៤៧៨ មានសត្វចិញ្ចឹមមានចំនួនដូច្នេះ គឺ :

| | អង់គ្លេសនឹងប៉េអ៊ីស៍ដឺកល៍ | អេកូស្ស៍ |
|---|---|---|
| ចៀម | ១៦.៤៧៧.០០០ | ៧.៧៦៦.៤១៥ |
| គោ | ៦.៥៤១.១៤៤ | ១.៣១៨.៤៩៤ |
| ជ្រូក | ៣.៨១៣.៣៧៣ | ២៦០.២១៣ |
| សេះ | ៨៧៣.៨៥២ | ១៤៦.៩៩៤ |

លោហធាតុ— លោហធាតុផ្សេងៗមានបរិបូណ៌ក្នុងអង់គ្លេសនឹងអេកូស្ស៍ មានលោហធាតុសំខាន់ៗតាមលំដាប់ដូច្នេះ គឺធ្យូងថ្ម, ដែក, ដីស្អិត, ថ្មខ្សាច់, ថ្មកំបោរ, ថ្មក្រាឆ្នែន, សំណប៉ាហាំង, អំបិល, សំណ, ទង់ដែង ។ អង់គ្លេសមានធ្យូងថ្មច្រើនលេខ ១ មានដែកជាទី ៣ ក្នុងប្រទេសអឺរុប ។ ក្នុង ព.ស. ២៤៧៣ ជីកបានធ្យូងថ្មចំនួន ២២៤ លានតោន ធាតុដែកបាន ១១ លានតោន សំណ ១៩.២៥៩ តោន សំណប៉ាហាំង ២.៤៨៨ តោន ។

របររបស់ប្រជាជន — របរហត្ថកម្មជារបរសំខាន់បំផុតរបស់អង់គ្លេស ក្សេត្រកម្មនឹងនេសាទកម្មជាទី ២ ជំនួញជាទី ៣ របរស៊ីឈ្នួលនឹងបម្រើគេជាទី ៤ ។ ឯហត្ថកម្មដែលសំខាន់ គឺការត្បាញសំពត់ ការធ្វើគ្រឿងដែក ការត្បាញសំពត់រោមសត្វ ការត្បាញសំពត់សូត្រ ការត្បាញសំពត់លិនិន ការធ្វើកញ្ចក់ ការធ្វើទូកនាវា ។

ពាណិជ្ជកម្ម— អង់គ្លេសជាប្រទេសដែលមានការលក់ដូរទំនិញនានា ប្រទេសយ៉ាងធំទូលាយបំផុត មិនមានប្រទេសណាស្មើបាននៅ គប៉ាល់ជំនួញមានចំនួន ៩.៧០៤ ប្រមាណ ២០.៣៨៥.១៣៨ តោន ។ ដំឡៃជំនួញលក់ចូលប្រទេស ក្នុង ព. ស. ២.៤៧៩. មានចំនួនដល់ ៧៣១.៤១៣.៧៨៣ លីវ្រស្ទែរឡាំង ជំនួញលក់ចេញមានចំនួន ៤៤៧.១៧៨.៨៦៨ លីវ្រស្ទែរឡាំង ។ ប្រទេសដែលអង់គ្លេសធ្វើការលក់ដូរច្រើនបំផុត គឺប្រទេសកូលនីរបស់អង់គ្លេស សហរដ្ឋអាមេរិក, អាល្លឺម៉ង់, បារាំងសែស, ដាណឺម៉ាក, អាសង់ទីន, រុស្ស៊ី, បែលហ្ស៊ិក, ហុល្លង់, ចិន, ជប៉ុន ។

ជំនួញលក់ចេញ — ជំនួញលក់ចេញរបស់អង់គ្លេសជាគ្រឿងស្លៀកពាក់, ដែក, គ្រឿងម៉ាស៊ីន សំពត់រោមសត្វនិងធ្យូងថ្មមានចំនួនច្រើនជាងយ៉ាងដទៃទៀត ។ ប្រទេសដែលទិញជំនួញរបស់អង់គ្លេសជាច្រើនបំផុតគឺ ឥណ្ឌា, អូស្ត្រាលី, អាមេរិក, កាណាដា, អាល្លឺម៉ង់, នគររដ្ឋអៀរឡង់ ។ ខាងក្រោមនេះគឺឈ្មោះជំនួញដែលលក់ចេញក្រៅៈ

សំពត់អំបោះនិងអំបោះ ផ្ញើទៅលក់ប្រទេសឥណ្ឌា, ទួរគី, ចិន, អេស៊ីប្ត, អាហ្វ្រិក ។ (នៅមានត)

## ពង្សាវតាររោម

(តមក)

ការដែលគិតចាប់មនុស្សតាមផ្លូវមកធ្វើជាទាហានបន្ថែមឡើងទៀតនោះ អន្និបាលកំណត់ទុកថា នឹងបានពួកគោល្វានៅខែត្រស៊ីស័លពីនមកបន្ថែម តែប្រជាជនអស់នេះនៅក្នុងអំណាចរោមអស់ទៅហើយ ទើបអន្និបាលសង្ឃឹមពឹងផ្អែកពុំបាន ។ លុះអន្និបាលលើកទ័ពមកដល់ខែត្រនេះ ក៏បានប្រទះនឹងកងទ័ពរោម ដែលកុងស៊ុលស៊ីព្យុង ជាមេទ័ពលើកមកចាំស្ទាក់ស្កាត់ផ្លូវ អន្និបាលក៏វាយពួកកងទ័ពនេះបែកបាក់ទៅបាន តាំងអំពីកាលនោះមកទើបពួកគោល្វាស្ម័គ្រចូលជាបក្សពួកនឹងអន្និបាល ហើយលើកទ័ពដើរចូលទៅក្នុងដែនដីអេទ្រូស្គី ក្នុងវេលាដែលទឹកកកចាប់ផ្តើមរលាយ ហើយមានទឹកលិចកលផាលទៅដោសសព្វអន្លើ គ្រានេះពួកទាហានរបស់អន្និបាលក៏ស្លាប់អស់ទៅចំនួនច្រើន តែពួកទាហានដែលនៅសេសសល់ ក៏អាចសម្លាប់ពួកទាហានរបស់រោម៉ាំងដែលកុងស៊ុលហ្វាមីនីយុសលើកមកច្បាំងតទល់ស្លាប់អស់ចំនួន ៣០.០០០ នាក់ ( ព . ស . ៣២៦ មុន គ . ស . ២១៧ ) ។

អន្និបាលមិនបានលើកទ័ពដើរចូលក្រុងរោម ព្រោះយល់ថាគ្រឿងប្រើប្រាស់មិនមានគ្រប់គ្រាន់ ហើយថែមទាំងមិនមានកំឡាំងល្មមនឹងវាយក្រុងរោមឲ្យបានផង ទើបលើកវង់ទៅវាយពួកឡាតាំងឯទៀតៗ តាម

ហើយពិត ក្នុងពេលនេះ ក្រុងរ៉ូមបានត្រៀមកងទ័ពខ្លួន មានមេទ័ពរបស់រ៉ូមម្នាក់ឈ្មោះហ្វាប៊ីយុស យល់ថាការច្បាំងតទល់នឹងអន្និបាលចំៗមុខនោះ កម្រនឹងយកជ័យជំនះបាន ទើបត្រូវគិតរកឧបាយផ្សេងទៀត គឺធ្វើឲ្យអន្និបាលអស់ស្បៀងអាហារទើបងាយមិនខាន តែរដ្ឋបុរសសំខាន់ៗរបស់ក្រុងរ៉ូមជាច្រើនមិនយល់ព្រមតាមគំនិតនេះ ហេតុនេះហើយទើបកើតចម្បាំងធំឡើងនៅស្រុកកាន កាលពីពុទ្ធសករាជ ៣២៧ (មុន គ.ស. ២១៦) ។

ស្រុកកាននេះជាស្រុកដែលអន្និបាលស្គាល់ច្បាស់លាស់ណាស់ ហើយបានបោះទ័ពនៅទីមានជ័យភូមិល្អ ការច្បាំងគ្នាគ្រានេះទៅជាពួករ៉ូម៉ាំងខ្លួនទប់ទល់ក្នុងទីដែលមានធូលីហុយ ហើយពន្លឺថ្ងៃចាំងចូលភ្នែកពួកទាហានៗ មួយវិញទៀតពួកទាហានរ៉ូម៉ាំងមិនចេះច្បាំងលើខ្នងសេះ ដល់វេលាច្បាំងមែនទែន រែងជាចុះពីខ្នងសេះច្បាំងតស៊ូគ្នានៅលើដីវិញ ហេតុនេះហើយបានជាត្រូវកងទ័ពរបស់អន្និបាល ដែលស្ទាត់ច្បាំងលើខ្នងសេះស្រាប់នោះកាប់កំទេចទ័ពរ៉ូម៉ាំងឲ្យហិនហោចអស់ទៅយ៉ាងធំ ។ ខណៈនោះអន្និបាលជិតបានជ័យជំនះយ៉ាងដាច់ស្រេចហើយ មាននាយទាហានសេះរបស់អន្និបាលម្នាក់ ឈ្មោះមហាបាល (Maharbal) សុំយកអាសាលើកទ័ពសេះចូលទៅវាយយកក្រុងរ៉ូមឲ្យបានក្នុងវេលានោះ តែ

អន្និបាលនៅតែយល់ថាកំឡាំងទ័ពមិនទាន់គ្រប់ទំរាំយកក្រុងរ៉ូមបាន ទើបលើកទ័ពសំដៅទៅទិសខាងត្បូងទៅ ។

## ហេតុដែលអន្និបាលមានជ័យជំនះ

ចម្បាំងរវាងរ៉ូម៉ាំងនឹងការថាសនេះ ពួករ៉ូម៉ាំងច្បាំងមានរបៀបល្អ នឹងមានសេចក្តីក្លាហានមុខគួរសរសើរ តែការដែលអន្និបាលមានជ័យជំនះគ្រានេះ ព្រោះបានហាត់មកយ៉ាងស្ទាត់ជំនាញ ហើយអន្និបាលជាមេទ័ពដែលពូកែជាងមេទ័ពរ៉ូមច្រើនណាស់ ។ ឯកងទ័ពរ៉ូមមិនបានហាត់បម្រុងទុក សម្រាប់ច្បាំងក្នុងគ្រាសំខាន់ដូច្នេះទេ គ្រាន់តែកេណ្ឌហៅទាហានមកប្រជាការយ៉ាងប្រញាប់ប្រញាល់ក្នុងពេលដែលត្រូវការ ហើយមិនមានពេលហាត់ឲ្យស្ទាត់ល្អ ។ មួយវិញទៀត ពួកមេទ័ពរ៉ូមក្រៅពីហ្វាប៊ីយុស មិនមានអ្នកណាបានទទួលការអប់រំវិជ្ជាការទាហានយ៉ាងម៉ឺងម៉ាត់ទេឡើយ ។ តាមធម្មតាពួកមេទ័ពរ៉ូម៉ាំងច្រើនតែជាពួកកុងស៊ុល មានវេលាធ្វើមេទ័ពត្រឹម ១ ឆ្នាំ ហើយមិនមានការត្រៀមខ្លួន ទាំងមិនស្គាល់ពួកទាហានខ្លួនយ៉ាងច្បាស់លាស់ផង ។ ចំណែកឯអន្និបាលជាមេទ័ពដែលស្ទាត់ជំនាញក្នុងការចម្បាំង និងចិញ្ចឹមជីវិតដោយរបរធ្វើទាហានរនេះធន់ ទើបមានដំឡៃជាងមេទ័ពខាងរ៉ូមជាអនេកប្រការ ។ លុះតមកពីថ្ងៃច្បាំងធំក្នុងគ្រានោះ កងទ័ពអន្និបាលក៏ដេញតាមកងទ័ព

កំលាំង ហើយចាប់បានឈ្លើយជាច្រើនពាន់ អន្និបាលពោលថា ទ័ពកំលាំងជាទ័ពខ្លាំង ដែលពោលដូច្នេះដោយហេតុអន្និបាលដឹងស្គាល់ កិច្ចការសព្វសពើ នៅប្រទេសរោមហូតដល់ផលានុផលភូមិប្រទេស ដែលខ្លួនត្រូវលើកទ័ពកាត់ទៅ សូម្បីតែចាត់ទ័ពកំលាំងអន្និបាលក៏ដឹងដែរ ហើយនៅដំបន់ណាខ្លះ គួរជាទីបោះទ័ពសាងបន្ទាយ មានចូនកាលខាង ក្រុងរោមមិនបានដឹងក៏មាន ។ មួយវិញទៀត អន្និបាលយកចិត្តទុកដាក់ ទ័ពទាហានរបស់ខ្លួនណាស់ បានរៀបចំត្រួតត្រាហូតដល់អាហារនឹង ចំណែក ចូនកាលសាងបន្ទាយដោយខ្លួនឯងក៏មាន ។

## អំពីចម្បាំងតមករវាងក្រុងរោមនឹងអន្និបាល

ក្រុងរោមនេះធ្លាក់ទៅនៅក្នុងឋានៈពិតវិនាសដូច្នេះ ទើបគេកេណ្ឌមនុស្ស ធ្វើទាហានគ្រប់ៗ គ្នាដែលមានរាងកាយមាំមួន សូម្បីពួកបាវក៏ត្រូវចូល ធ្វើទាហានដែរ ឯពួកមេទ័ពក៏ខំប្រឹងប្រែងរៀបចំកងទ័ពយ៉ាងម៉ឺងម៉ាត់ ធ្វើតាមប្លង់របស់ហ្វាប៊ីយុស ក្រុងរោមក៏ត្រឡប់ជាមានកងទ័ពរឹងប៉ឹងខ្លាំង ក្លាឡើងវិញម្តងទៀត ។ ចំណែកខាងអន្និបាលគោងរសាត់អណ្តែត នៅក្នុងប្រទេសរោមជាយូរ នៅទីបំផុតក៏អស់ស្បៀងហើយ កំឡាំង មនុស្សក៏ខ្សោយថយតិចទៅ សុំជំនួយពីអ្នកដទៃទៀតក៏ពុំសម្រេច ព្រោះ ពួកទាហានស្រឡាញ់ក្រុងរោមច្រើនជាង ទើបមិនព្រមចូលដៃនឹងអន្និបាល ។

(នៅមាន)

# ប្រស្នាចំរើនសតិបញ្ញា

## ប្រស្នាទី ១

## សេចក្ដីឆ្លើយទី ៣

រឿងរដូវទាំង ៣ នេះលំបាកនឹងវិនិច្ឆ័យណាស់ ដ្បិតអ្នកដែលគាប់ចិត្តនឹងរដូវក្ដៅ ក៏ពោលសរសើរគុណវិសេសរបស់រដូវក្ដៅថា វិសេសស្រួលជាងរដូវឯទៀត ឯអ្នកគាប់ចិត្តនឹងរដូវភ្លៀងក៏សរសើរថា ស្រួលជាងរដូវឯទៀតដែរ ៗ ចំណែកខាងខ្ញុំបាទយល់ឃើញដោយឡែកពីអ្នកទាំង ២ ដែលពោលមកហើយនោះ គឺយល់ថារដូវរងាស្រួលជាងគេទាំងអស់ ព្រោះរដូវរងារបស់ប្រទេសយើងមិនរងាខ្លាំងដល់ទៅទឹកក្នុងទន្លេ បឹង ត្រពាំងកកទេ ឬរងាជាហេតុនាំឲ្យខូចខាតការងារឬធ្វើដំណាំដាំដុះទាំងឡាយឲ្យវិនាសអន្តរាយទៅក៏ទេដែរ ៗ មួយវិញទៀត រដូវរងាមនុស្សច្រើនតែខ្ជិលច្រអូសស្ពឹកដៃជើងរួយស្រពន់មិនចង់ធ្វើការងារក៏ពិតមែន តែជាការទម្រន់ជាទីកានរបស់មនុស្សខ្ជិលច្រអូសទេតើ បើជាអ្នកស្រែខែស្រូវទុំហើយ តែមិនក្រោកពីព្រលឹមទៅដេញចាបទេ មុខជាចាបស៊ីស្រូវខូចមិនខាន ៗ រងាមិនហួសវិស័យដល់ទៅធ្វើការមិនកើតនុះទេ ៗ

ប៉ុន្តែនៅរដូវភ្លៀងមានខូចប្រយោជន៍ច្រើនជាង ព្រោះមានទឹកកក់ជោគជាំ ភ្លៀងជ្រាំមិនឈប់ ទាំងធ្វើការអ្វីក្រៅផ្ទះក៏លំបាកឬមិនបានសោះក៏មាន ដូចផ្ទះបោកខោអាវ ឬហាលស្រូវអង្ករក៏មិនបានដែរ ទុកជាទៅណាមកណា ក៏តោងកៗ រង៉ៗ បង្អន់តាំងភ្លៀងខូចខាតប្រយោជន៍ក៏មាន ហើយជាហេតុនាំឲ្យខ្ជិលច្រអូសជាងរដូវដទៃទៅទៀត ។ បើមានធុរៈទៅណាមកណា ក្នុងវេលាមានភ្លៀងមិនដែលស្រួលទេ ទុកជាពាក់អាវភ្លៀង ឬប្រើតាំងយូក៏ការពារបានតែកន្លះកាយខាងលើ ឯស្បែកជើងស្រោមជើងតែងតែទទឹកជោកជាំអស់ បើពាក់ស្បែកជើងស្បែកលុយទឹកក៏ច្រើននាំខូចខាតអន្តរាយ វេលាស្ងួតទៅវិញ ក្រៀមក្រពាំងពាក់មិនស្រួល បើស្បែកជើងសំពត់លាបថ្នាំសក៏អស់ល្អតែម្តង បើនៅតាមបាតបឹង ដូចភូមិបឹងកក់ បឹងកេងកង នៅក្រុងភ្នំពេញនេះ ក៏តែលំបាកវេទនាជាងនោះទៀត វេលាមានភ្លៀងធ្លាក់ជោកជាំ បើជិះកង់មុខជាកង់ជិះវិញហើយ បើពាក់ស្បែកជើងស្រោមជើងមុខជាដោះកាន់ដើរទៅជើងព្រួច ៗ មួយវិញទៀត រដូវភ្លៀងច្រើនតែនាំឲ្យកើតផ្តាសាយហៀរសំបោរ ព្រោះអាកាសក្តៅត្រជាក់ផ្លាស់ប្តូរដាច់ នាំឲ្យមិនស្រួលដល់រាងកាយ ។

ឯរដូវក្តៅសោតទៀតក៏នាំឲ្យខូចប្រយោជន៍ខ្លះដែរ តែគ្រាន់បើជាងរដូវភ្លៀងបន្តិច ព្រោះកំដៅដ៏ក្តៅរបស់ព្រះអាទិត្យ នាំចិត្តគំនិតឲ្យក្រវល់

ក្រោយឈឺក្បាលវិលមុខ នឹងធ្វើការដោយគំនិតមិនបានឡើយ ។ នឹងពោលថារដូវក្តៅស្រួលដូចម្តេចបាន របស់ស្បៀកពាក់ក៏ចាប់ខូចច្រើនជាងរដូវរងា អាវសម្រាប់ពាក់ក៏គេនឹងប្រើសំពត់ស្តើងៗ ទើបស្រួល ព្រោះមានញើសច្រើន គេនឹងបង់ខាតថ្លៃបោកលាងញឹកញយ ទោះគ្រឿងបរិភោគក៏ឆាប់ខូចឆាប់ផ្អូមជាងរដូវរងា ព្រោះអាកាសមិនល្អក្តៅពេក ម្ហូបអាហារទុកយូរមិនបានទេ តែចិត្តរបស់យើងក៏នៅតែអន្ទះអន្ទែងដោយអាកាសដ៏ក្តៅកេលកលនេះដែរ ។

ហេតុដូច្នេះ ទើបខ្ញុំបាទយល់យ៉ាងដាច់ស្រេចថា រដូវរងាមានទម្ងន់ជាងរដូវក្តៅនឹងរដូវភ្លៀង ព្រោះមិនសូវខូចខាតប្រយោជន៍ច្រើនពេក ទុកជាប្រើសំពត់ក្រាស់ៗបន្តិច ក៏មិនជាធ្ងន់ស្រាលប៉ុន្មានទេ ដ្បិតមិនសូវមានញើសក្អួល សំពត់អាវក៏ប្រើប្រាស់បានយូរក្រខូច ហើយមិនសូវបង់ខាតសោហ៊ុយបោកលាងផង ។ ចំណែកខាងសត្វជាអាហាររបស់យើង ដូចត្រី សត្វស្លាប មាន់ទាជាដើម មានខ្លាញ់ឆ្ងាញ់ពិសាជាងនៅក្នុងរដូវឯទៀតៗ ជាប្រាកដ ទាំងផលាផលផ្សេងៗ ក៏មានទុំជាល្អដែរក្នុងរដូវនេះ ហេតុនេះបានជាខ្ញុំបាទយល់ថា រដូវរងាស្រួលសប្បាយជាងទាំងអស់ ។

នាយរដ្ឋរង៉ា

# រឿងព្រះរាជវិនិច្ឆ័យក្តីទាំង ៤

(តមកនិងចប់)

ទើបចៅក្រមជំនុំជំរះកាត់សេចក្តីថា ត្រូវឲ្យបុរសខ្ចីគោគេនោះ សងគោគេវិញ ត្រូវឲ្យបុរសខ្ចីគោដែលបោលបាក់ជើងសេះគេនោះ សងសេះគេវិញ ត្រូវឲ្យបុរសខ្ចីគោដែលប្រើប្រពន្ធគេឲ្យលើកទឹកឲ្យផឹក ជាហេតុឲ្យរលូតកូនគេនោះ សងកូនគេវិញ ត្រូវឲ្យបុរសខ្ចីគោដែលលោតសម្លាប់ខ្លួន ជាហេតុឲ្យស្លាប់ឪពុកគេទៅនោះ ត្រូវសងឪពុកគេវិញ ។

ឯបុរសខ្ចីគោ ដែលជាប់ទោសទាំង ៤ រឿងនេះពុំសុខចិត្តក៏នាំគ្នាឡើងទៅគាល់សម្តេចព្រះមហាក្សត្រ ហើយក្រាបបង្គំទូលសូមព្រះរាជ-ទានទោស ។ សម្តេចព្រះមហាក្សត្រមានព្រះបន្ទូលដណ្តឹងថា ហេតុអ្វីក៏ប្រវែងមកសូមប្តឹងអញដូច្នេះ ។ បុរសខ្ចីគោក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ទូលព្រះបង្គំជាខ្ញុំបានខ្ចីគោក្មេងនេះនាំទំនិញទៅលក់រួចហើយនាំយកគោនោះទៅជូន តែគាប់ជួនជួបនឹងប្រាក់ពុំជួបនឹងក្មេង បានប្រគល់គោនោះទៅប្រាក់ៗ ក៏ទទួលយកគោនោះផ្ទះស្រឡះហើយៗ ទូលព្រះបង្គំជាខ្ញុំវិលមកផ្ទះវិញ តមកក្មេងនេះទៅប្រាប់ទូលព្រះបង្គំជាខ្ញុំថា គោនោះដាច់ទៅហើយៗ បន្ទោសទូលព្រះបង្គំជាខ្ញុំថា វេលាក្មេងទៅសងម្តេចក៏មិនផ្តាំអញសិន ម្តេចក៏យកគោទៅជូនប្រពន្ធអញវិញ ដូច្នេះក្មេង

គោឯងសងគោអញ ។ សូមទ្រង់ជ្រាប ដំណើរក្តីរបស់ទូលព្រះបង្គំជាខ្ញុំ ដូចក្រាបបង្គំទូលមកនេះ ។

សម្តេចព្រះមហាក្សត្រត្រាស់ដណ្តឹងទៅបុរសម្ចាស់គោនោះថា ដំណើរក្តីនេះតើដូច្នេះមែនឬពុំមែនទេ ។ បុរសម្ចាស់គោទូលថា សូមទ្រង់មេត្តាប្រោសដូច្នេះមែន ។ ទើបព្រះអង្គត្រាស់សួរទៀតថា តើប្រៃស្តងទឹងឲ្យគេសងឬអ្វី ។ ម្ចាស់គោក្រាបទូលថា ទូលព្រះបង្គំជាខ្ញុំខឹងឲ្យសង ។ ទើបព្រះអង្គត្រាស់ថា បើប្រៃស្តងឲ្យគេសងគោ គោឯងប្រៃស្តងឲ្យប្រពន្ធទៅក្តីប្រៃស្តង ទើបប្រៃស្តងបានគោ ដ្បិតប្រពន្ធប្រៃស្តងទទួលយកគោពីគេផ្ទះស្រឡះហើយ តើឥឡូវនេះប្រៃស្តងទឹងឲ្យប្រពន្ធទៅក្តីប្រៃស្តងឬទេ ។ បុរសនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ទូលព្រះបង្គំជាខ្ញុំពុំព្រមឲ្យទៀយ ។ ទើបព្រះអង្គមានព្រះបន្ទូលថា បើប្រៃស្តងមិនព្រមឲ្យប្រពន្ធទៅគេទេ ប្រៃស្តងក៏មិនត្រូវបានសំណងគោនោះដែរ ព្រោះប្រពន្ធប្រៃស្តងទទួលយកគោនោះផ្ទះស្រឡះហើយ ម្តេចក៏ប្រៃស្តងទារសំណងពីគេ ។

ព្រះមហាក្សត្រាធិរាជទ្រង់ព្រះរាជវិនិច្ឆ័យក្តីនេះរួចហើយ ទើបទ្រង់ដណ្តឹងសួររឿងសេះតទៅទៀត ។ ឯបុរសខ្ញុំគោជាដើមហេតុដែលបោលសេះឲ្យបាក់ជើងក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ទូលព្រះបង្គំជាខ្ញុំឈប់នៅក្រោមម្លប់ឈើមួយ គាប់ជួនបុរសនេះដឹកសេះមក

ដល់ទីនោះ បានប្រើទូលព្រះបង្គំជាខ្ញុំឲ្យបរសេះវាមិនព្រមដើរ ក៏បង្គាប់ទូលព្រះបង្គំជាខ្ញុំឲ្យវាយ ទូលព្រះបង្គំជាខ្ញុំប្រកែកថាមិនហ៊ានវាយទេ ក្រែងបាក់ជើងសេះ បុរសដឹកសេះថាវាយចុះ ទូលព្រះបង្គំជាខ្ញុំក៏វាយទៅត្រូវជើងសេះបាក់ ។ ទើបព្រះអង្គមានព្រះបន្ទូលនឹងអ្នកដឹកសេះថា ដំណើរក្តីនេះដូច្នោះមែនឬដូចម្តេច ។ បុរសនោះក្រាបទូលថា ពិតដូច្នោះមែន ។ ព្រះអង្គត្រាស់ថា បើប្រស្នូងឲ្យគេសងសេះ ត្រូវប្រស្នូងប្រគល់ខ្ញុំប្រស្នូងឲ្យទៅគេ ព្រោះខ្ញុំប្រស្នូងប្រើគេឲ្យវាយសេះទាល់តែសេះប្រស្នូងបាក់ជើង តើប្រស្នូងព្រមឬមិនព្រម ។ បុរសម្ចាស់សេះនោះក្រាបទូលថា ទូលព្រះបង្គំជាខ្ញុំពុំព្រមឡើយ ដ្បិតខ្ញុំទូលព្រះបង្គំជាខ្ញុំមានតែម្នាក់នេះឯង ព្រះអង្គត្រាស់ថា បើដូច្នោះមិនត្រូវឲ្យគេសងសេះប្រស្នូងដែរ ព្រោះប្រស្នូងមិនព្រមឲ្យខ្ញុំទៅគេ ។

ព្រះអង្គក៏ត្រាស់សួរដំណើរក្តីស្រីលូតកូនតទៅទៀត ទើបបុរសខ្ញុំនោះក្រាបបង្គំទូលថា នាកាលទូលព្រះបង្គំជាខ្ញុំដើរមកតាមផ្លូវនោះស្រេកទឹកខ្លាំងណាស់ បានចូលទៅសូមទឹកផឹកនៅផ្ទះស្ត្រីម្នាក់ ចួនជាថ្ងៃនោះស្ត្រីមិននៅ ។ តែប្រាក់ ។ ក៏សិតទឹកចុះជណ្តើរហូបមក ជណ្តើរបាក់ធ្លាក់ប្រាក់ទៅជាន់លូតកូនទៅ លុះប្តីមកដល់យល់ប្រាក់លូតកូនដូច្នោះ ក៏ខឹងខ្លាំងណាស់ បង្គាប់ឲ្យទូលព្រះបង្គំជាខ្ញុំសងកូនគេ ។ ទើបព្រះអង្គត្រាស់សួរទៅបុរសប្តីនោះថា ដំណើរក្តីនេះតើពិតដូច្នេះឬពុំមែនទេ ។

បុរសប្ដីក្រាបបង្គំទូលថា ពិតដូច្នោះមែន ។ ព្រះអង្គត្រាស់សួរថា តើប្រស្ដូននឹងឲ្យសងកូននោះម្ដេច ។ សូមទ្រង់ព្រះមេត្តាប្រោស សូមឲ្យគេសងកូននោះវិញ ។ ចុះប្រពន្ធប្រស្ដូនដើមបានប៉ុន្មានខែ ។ សូមទ្រង់ព្រះមេត្តាប្រោស ដើមបាន ៧ ខែហើយ ។ ព្រះមហាក្សត្រទ្រង់ព្រះរាជ-វិនិច្ឆ័យថា បើប្រស្ដូនឲ្យគេសងកូននោះ ត្រូវប្រស្ដូនឲ្យប្រពន្ធប្រស្ដូនទៅធ្វើជាប្រពន្ធគេទុកឲ្យដើមបាន ៧ ខែសិន សឹមប្រស្ដូនយកមកធ្វើជាប្រពន្ធប្រស្ដូនវិញ តើប្រស្ដូនព្រមទេ ។ បុរសប្ដីក្រាបទូលថា ទូលព្រះបង្គំជាខ្ញុំពុំព្រមទេ ។ ទ្រង់ត្រាស់ថា បើប្រស្ដូនមិនព្រមឲ្យប្រពន្ធទៅគេ ចុះឲ្យគេយកកូនពីណាមកសងប្រស្ដូនវិញបាន ៕

ព្រះមហាក្សត្រក៏ត្រាស់សួរដំណើរក្ដីស្លាប់អាពុកគេទៅទៀត ទើបបុរសខ្ចីគោក្រាបបង្គំទូលថា ដើមឡើយទូលព្រះបង្គំជាខ្ញុំស្រដីលាអ្នកដើមហោទាំង ៣ នាក់ថា សូមទៅបត់ជើងធំមួយភ្លែតសិន លុះចូលព្រៃយល់ដើមឈើមួយធំ ដោយទឹកអន់ចិត្តនឹងភ័ព្វសំណាងរបស់ខ្លួនខ្លាំងណាស់ ក៏ឡើងទៅលើចុងឈើនោះប្រុងនឹងលោតសម្លាប់ខ្លួនបង់ ដល់លោតចុះមកស្រាប់តែត្រូវលើអាពុកបុរសនេះស្លាប់ទៅ ឯទូលព្រះបង្គំជាខ្ញុំពុំស្លាប់ វេលាលោតចុះមកនោះ ទូលព្រះបង្គំជាខ្ញុំពុំបានឃើញបុរសអាពុកនឹងកូននោះខាងក្រោមដើមឈើនោះឡើយ ។ បុរសកូនឃើញអាពុកស្លាប់ក៏ចាប់ទូលព្រះបង្គំជាខ្ញុំថាត្រូវឲ្យសងអាពុកគេវិញ ដំណើរក្ដី

នេះតែប៉ុណ្ណោះ សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។ ហើយព្រះមហាក្សត្រត្រាស់សួរទៅបុរសកូននោះថា តើប្រែស្ដងទឹងឲ្យគេសងអាពុកប្រែស្ដងវិញឬអី ។ សូមទ្រង់ព្រះមេត្តាប្រោស សូមឲ្យគេសងអាពុកទូលព្រះបង្គំជាខ្ញុំវិញ ។ បើដូច្នោះត្រូវប្រែស្ដងឲ្យម្ដាយប្រែស្ដងទៅធ្វើជាប្រពន្ធគេដើម្បីឲ្យបានជាអាពុករបស់ប្រែស្ដង ជំនួសអាពុកដែលស្លាប់ទៅ តើប្រែស្ដងព្រមទេ ។ ទូលព្រះបង្គំជាខ្ញុំទឹងឲ្យម្ដាយទៅធ្វើជាប្រពន្ធបុរសនេះដូចម្ដេចបាន ឯម្ដាយទូលព្រះបង្គំជាខ្ញុំវេលានេះកំពុងកើតទុក្ខធ្ងន់ផង ទូលព្រះបង្គំជាខ្ញុំពុំព្រមទេ ។ ព្រះអង្គវិនិច្ឆ័យថា បើប្រែស្ដងពុំព្រម ទឹងឲ្យគេយកអាពុកពីណាមកជំនួសអាពុកប្រែស្ដងបាន អាពុកប្រែស្ដងស្លាប់ទៅដោយផលកម្មរបស់ខ្លួន ទឹងបន្ទោសនរណា ។

សម្ដេចព្រះមហាក្សត្រាធិរាជទ្រង់ព្រះរាជវិនិច្ឆ័យក្ដីទាំង ៤ បំពូកនេះដោយប្រការដូច្នេះហើយ បុរសទាំង ៥ នាក់ដែលកើតក្ដីនឹងគ្នាក៏ចូលចិត្តស្ដាប់បាន ហើយក្រាបថ្វាយបង្គំលាទៅកាន់លំនៅអាត្មាទៃ ៗ រៀងខ្លួនហោង ។

ចប់

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

## ឆ្នាំគំរប់ ១៤ ភាគទី ៨

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨៦

គ. ស. ១៩៤២

# បញ្ជីរឿង


ទំព័រ

១ — វិទ្យុទេសនា កណ្ឌទី ២ របស់ព្រះតេជព្រះគុណ ព្រះសិរីសម្មតិវង្ស ចាងហ្វាង សាលាបាលីជាន់ខ្ពស់ សំដែង . . . . . . . . . . . . . . . . . . ៣

២ — រឿងព្រះបាទអសោកមហារាជ អ្នកអាចារ្យឌឹម-អាន ប្រែពីភាសាបារាំងសែស មកជាខេមរភាសា (តមក) . . . . . . . . . . . . . . . . . . ១០

៣ — ប្រវត្តិពួកឧបាសក-ឧបាសិកា ជាសាវកសាវិកា របស់ព្រះពុទ្ធជាម្ចាស់ ទី ៧-៨ ប្រវត្តិរបស់ឧគ្គ-ហត្ថិគាមកនឹងអម្ពដ្ឋ . . . . . . . . . . . . ១៤

៤ — ភូមិសាស្ត្រសង្ខេបនៃនានាប្រទេស អំពីភូមិសាស្ត្រប្រទេសអង់គ្លេស (តមក).. ១៩

៥ — ពង្សាវតាររោម ស្រង់យកអំពីគោលតារាងផ្សេងៗក្នុងពង្សាវតារលោក (តមក) ២២

៦ — លោកវិទ្យ ពាក្យកាព្យ របស់អ្នកឧកញ៉ាវង្សាសារពេជ្ញ (នង) (តមក)... ២៩


## រូបក្រៅរឿង


ក្បាច់ហោជាងដែលលយចេញពីប្រាសាទកណ្ដាលនៃប្រាសាទបន្ទាយសំរែ ។ ការរចនាសម័យប្រាសាទនគរវត្ត សតវត្សរ៍ទី ១២ នៃពុទ្ធសករាជ . . . . . . . . . . ១

# TABLE DES MATIÈRES


Pages

1. VIDYUDESANĀ (Prédication faite à la Radio Phnôm-Penh) par le Vénérable Préas SIRISAMMATIVONG ÈM Directeur de l'École Supérieure de Pāli........................ 3

2. Légende de l'Empereur Açoka de l'Inde antique, traduit du français en Cambodgien par feu l'Achar KIM-ANN (suite).. 10

3. Vies des disciples laïcs du Bouddha: VII. Vie d'UGGA-HATTHIGĀMOKA. — VIII Vie de AMBATTHA.................. 14

4. Géographie sommaire de divers pays: l'Angleterre (suite).. 17

5. Histoire de Rome. Extraits de divers documents de l'histoire universelle (suite).............................. 22

6. Lokaneyya, poème par feu l'Oknha Vongsa Sarpejña (Nong) (suite)...................................... 29

HORS-TEXTE:

Fronton du sanctuaire central de Banteay-Samrè............. 1



ក្បាច់ទោយ៍ដែលលយចេញពីប្រាសាទកណ្តាលនៃប្រាសាទ
បន្ទាយសំរៃ ។ ការរចនាសម័យប្រាសាទអង្គរវត្ត សតវត្សរ៍
ទី ៧ នៃពុទ្ធសករាជ

# វិទ្យុទេសនាកាលទី ២

នៅថ្ងៃចន្ទ ៨ កើតខែផល្គុន ឆ្នាំម្សាញ់ត្រីស័ក ព. ស. ២៤៩៦

របស់

## ព្រះសិរីសម្មតិវង្ស អែម

ផ្សាយតាមវិទ្យុ ចំពោះពុទ្ធសាសនិកជនដែលកាន់ព្រះពុទ្ធសាសនា បានអញ្ជើញចូលមកប្រជុំស្តាប់ព្រះធម៌ទេសនាក្នុងឱកាសពេលនេះ, អាត្មាភាពនឹងសំដែងជាលំដាប់ភ្ជាប់អនុសន្ធិអំពីធម្មទេសនាទី ១ មក ដែលធម្មកថិកលោកបានសំដែងរឿងព្រះពុទ្ធសាសនាមាន ៣ ព្រមទាំងសេចក្តីអធិប្បាយដោយសង្ខេប ឲ្យល្មមនឹងឱកាសដែលមានវេលាតិច ។

ពេលនេះនឹងសំដែងរឿងព្រះពុទ្ធសាសនាតទៅទៀត ដែលសម្តេចព្រះមហាមុនីនាថព្រះអង្គទ្រង់ត្រាស់សំដែងឲ្យទាក់ទងដល់ពុទ្ធបរិស័ទទាំង ៤ ពួក មានភិក្ខុបរិស័ទជាដើម, ក្នុងគម្ពីរអង្គុត្តរនិកាយតិកនិបាត ពន្យល់អំពីព្រះពុទ្ធសាសនាមានអង្គបី ៗ ដូចគ្នា ដ៏ក្រៃលែងច្រើនលើក គឺព្រះអង្គទ្រង់សំដែងបន្ថែមរឿងព្រះពុទ្ធសាសនាមានអង្គបីៗផ្សេងៗគ្នាច្រើនជង, តែថាមានធម្មរសនឹងអត្ថរសផ្សេងៗគ្នា ជាគ្រឿងដាស់តឿនសតិបញ្ញាដល់ពុទ្ធបរិស័ទឲ្យបានចំរើនប្រាជ្ញាកាន់តែភ្លឺក្លាខ្លាំងឡើង, ដើម្បីនឹងបានសម្រេចប្រយោជន៍ក្នុងលោកនេះនឹងលោកខាងមុខ ដោយមេត្តាគុណរបស់ព្រះអង្គពិត ៗ

គោ សាធកោ បតិត្រូវសាធុសប្បុរសទាំងឡាយដ៏ចំរើន ព្រះពុទ្ធសាសនាមានអង្គ ៣ នោះគឺ សាមញ្ញសាសនា ព្រះសម្ពុទ្ធជាម្ចាស់ព្រះអង្គទ្រង់ប្រៀនប្រដៅថា សាធុជនត្រូវតែខំព្យាយាមរៀនសូត្រឲ្យចេះដឹងនូវវិជ្ជាដែលជាផ្លូវត្រង់មានអង្គ ៨ កំណត់ទុកក្នុងចិត្តឲ្យចាំស្គាល់ច្បាស់លាស់ដោយខ្លួនឯង ១, សាមញ្ញផលសាសនា ព្រះអង្គទ្រង់ប្រដៅប្រាប់ពន្យល់ថា សាធុជនដែលត្រូវបានផលប្រយោជន៍ទាំងពួង ក្នុងបច្ចុប្បន្ននេះក្តី បរលោកក្តី ព្រះនិព្វានក្តី ក៏បានមកតែពីការចេះដឹងនូវវិជ្ជាដែលជាផ្លូវត្រង់ច្បាស់លាស់ដោយខ្លួនឯង១, សាមញ្ញត្ថសាសនា ព្រះអង្គទ្រង់ប្រដៅពន្យល់ថា: សាធុជនដែលនឹងបានសម្រេចប្រយោជន៍ដ៏ជាទីមសារបរិសុទ្ធផុតចាកកង្វក់ទាំងពួងនោះ ក៏កើតមកតែអំពីការចេះដឹងនូវវិជ្ជាដែលជាផ្លូវត្រង់ច្បាស់លាស់ដោយខ្លួនឯង១, ត្រូវជាពុទ្ធ-សាសនាមានអង្គ ៣ ពិត ។

## សេចក្តីអធិប្បាយថា

ទី១ - សម្តេចព្រះមុនីទូនិធនស្រីជាម្ចាស់ ព្រះអង្គជាអង្គសព្វញ្ញូទ្រង់ជ្រាបច្បាស់នូវធម៌ជាលោកិយ និងលោកុត្តរទាំងអស់ដោយសព្វគ្រប់ ហើយព្រះអង្គប្រកបដោយព្រហ្មវិហារធម៌ទាំង៤ មានមេត្តាសេចក្តីស្រ-ឡាញ់រាប់អានស្វែងរកនូវប្រយោជន៍រំលែកចែកដល់សត្តនិករទាំងឡាយ

ឲ្យបានសេចក្ដីសុខ-ចំរើនបរិបូណ៌ដោយភោគសម្បត្តិ រូបសម្បត្តិ បញ្ញា-
សម្បត្តិ ស្មើៗគ្នាជាដើម, ហើយព្រះអង្គទ្រង់ប្រៀនប្រដៅសត្វនិកាយ
ទាំងឡាយដែលមានប្រាថ្នាចង់បានសំរេចសម្បត្តិទាំង ៣ យ៉ាងនេះ, ឲ្យ
ខំព្យាយាមប្រឹងប្រែងរៀនសូត្រនូវវិជ្ជាដែលជាផ្លូវត្រង់មានអង្គ ៨ ទើប
ដោះទៅកាន់សម្បត្តិទាំង ៣ យ៉ាងដូចបំណងប្រាថ្នាបាន បើសត្វទាំង-
ឡាយពុំបានព្យាយាមរៀនសូត្រឲ្យចេះដឹងនូវវិជ្ជាដែលជាផ្លូវត្រង់មានអង្គ
៨ នេះទេ មុខជាពុំបានសំរេចនូវសម្បត្តិទាំង ៣ យ៉ាងនេះឡើយ ឬជាបាន
ព្យាយាមរៀនសូត្រចេះដឹងហើយតែពុំបានប្រតិបត្តិតាម ក៏គង់ពុំបាន
សំរេចសម្បត្តិទាំង ៣ យ៉ាងនេះដែរ ។ ឯវិជ្ជាដែលជាផ្លូវត្រង់មានអង្គ ៨
នោះគឺ សម្មាទិដ្ឋិ ប្រាជ្ញាយល់ឃើញត្រង់ ១ សម្មាសង្កប្បៈ សេចក្ដីត្រិះរិះ
គិតត្រង់ ១ សម្មាវាចា សំដីនិយាយត្រង់ ១ សម្មាកម្មន្តៈ ធ្វើការងារត្រង់ ១
សម្មាអាជីវៈ រកស៊ីចិញ្ចឹមជីវិតត្រង់ ១ សម្មាវាយាមៈ ព្យាយាមសង្កាត់
ធ្វើត្រង់ ១ សម្មាសតិ ស្មារតីនឹកឃើញត្រង់ ១ សម្មាសមាធិ ដំកល់ចិត្ត
ស្មោះត្រង់ក្នុងធម៌ ១ ត្រូវជាវិជ្ជាមានអង្គ៨ ជាផ្លូវត្រង់ដ៏ប្រសើរ សម្រាប់
អ្នកប្រាជ្ញទាំងឡាយមានបច្ចេកពោធិសត្វនិងសព្វញ្ញូពោធិសត្វជាដើម
លោកតែងត្រាច់ទៅស្វែងរកសេចក្ដីសុខសេចក្ដីចំរើន បានជួបប្រទះនឹង
សម្បត្តិទាំង ៣ យ៉ាងគឺ សម្បត្តិមនុស្ស ១ សម្បត្តិទេព្តា ១ សម្បត្តិព្រះ
និព្វាន ១ ព្រោះតែលោកបានចេះដឹងវិជ្ជាដែលជាផ្លូវត្រង់មានអង្គ ៨ នេះ

៦៥ ។ ន័យមួយទៀត ព្រះអរហំសម្មាសម្ពុទ្ធព្រះអង្គបានបរមាភិសេកសម្ពោធិញាណជាអង្គព្រះសព្វញ្ញូសម្ពុទ្ធប្រាកដក្នុងលោកហើយ ទ្រង់ប្រកបដោយមហាករុណាគុណមានព្រះហឫទ័យអាណិតអាសូដល់សត្វនិករទាំងឡាយដែលដេកត្រាំនៅក្នុងសង្សារវដ្តទុក្ខឥតស្រាកស្រាន្ត, ទើបព្រះអង្គលើកយកផ្លូវត្រង់មានអង្គ៨មានក្នុងធម្មចក្កប្បវត្តនសូត្រមកសំដែងប្រកាសផ្សាយទៅក្នុងមួយម៉ឺនលោកធាតុ ហើយទ្រង់លើកយកអង្គទី ១-២ គឺ សម្មាទិដ្ឋិ សម្មាសង្កប្បៈ ឲ្យឈ្មោះថាបញ្ញាខន្ធ ជាពួកនៃបញ្ញាទាំងអស់ បានខាងបរមត្ថព្រះអភិធម្មបិដក ៧ គម្ពីរចំនួន ៤ ម៉ឺន ២ ពាន់ធម្មក្ខន្ធ, ទ្រង់លើកយកអង្គទី ៣-៤-៥ គឺ សម្មាវាចា - សម្មាកម្មន្តៈ សម្មាអាជីវៈ ឲ្យឈ្មោះថាសីលក្ខន្ធ ជាពួកនៃសីលទាំងអស់ បានខាងព្រះវិន័យបិដកចំនួន ២ ម៉ឺន ១ ពាន់ធម្មក្ខន្ធ, ទ្រង់លើកយកអង្គទី ៦-៧-៨ គឺសម្មាវាយាមៈ - សម្មាសតិ - សម្មាសមាធិ ឲ្យឈ្មោះថាសមាធិក្ខន្ធ ជាពួកនៃសមាធិទាំងអស់ បានខាងព្រះសុត្តន្តបិដកចំនួន ២ ម៉ឺន ១ ពាន់ធម្មក្ខន្ធ រួមទាំងអស់ត្រូវជា ៨ ម៉ឺន ៤ ពាន់ធម្មក្ខន្ធ ។ ឃើញថាផ្លូវត្រង់មានអង្គ ៨ នេះច្រើនជាអនេកហួសកំឡាំងប្រាជ្ញានឹងអធិប្បាយឲ្យពិស្តារសព្វគ្រប់ពុំបាន, នឹងលើកយកតែអង្គទី ១ គឺសម្មាទិដ្ឋិមកអធិប្បាយជាសេចក្តីពិស្តារបន្តិច ដើម្បីជាកិច្ចដល់លោកអ្នកជាសប្បុរសបានចូលមកប្រជុំស្តាប់ក្នុងវេលានេះ ក៏សម្មាទិដ្ឋិអង្គទី ១ នេះ ព្រះសយម្ភូញាណជា

ម្ចាស់ទ្រង់ត្រាស់សំដែងចែកជាពីរយ៉ាងគឺ សម្មាទិដ្ឋិជាលោកិយ ១ ជាលោកុត្តរ ១ ។

ឯសម្មាទិដ្ឋិជាលោកិយនោះ សេចក្ដីអធិប្បាយថា ប្រាជ្ញាយល់ឃើញត្រង់ គឺរៀនចេះដឹងជាក់ច្បាស់ដោយខ្លួនឯងថា អំពើដែលបុគ្គលបានធ្វើល្អនឹងបានទទួលផលល្អជាទ្រព្យមរដករបស់ខ្លួន ឲ្យផលល្អដល់ខ្លួនវិញ, អំពើដែលបុគ្គលបានធ្វើអាក្រក់ នឹងបានទទួលផលអាក្រក់ជាទ្រព្យមរដករបស់ខ្លួន ឲ្យផលអាក្រក់ដល់ខ្លួនវិញ, រៀនចេះដឹងជាក់ច្បាស់ស្គាល់ប្រយោជន៍ជាលោកិយថា មនុស្សកើតមកក្នុងបច្ចុប្បន្ននេះ មានវិជ្ជាជាទ្រព្យដ៏ប្រសើរ, ត្រូវតែខំព្យាយាមរៀនសូត្រនូវចំណេះវិជ្ជាគ្រប់យ៉ាង ដែលជាវិជ្ជាសម្រាប់លោក មិនត្រូវខ្ជិលច្រអូសទម្រន់ចុះឡើយ, ត្រូវតែខំរៀនសន្សំប្រាជ្ញាឲ្យកើតមកពីការស្ដាប់ខ្លះ ឲ្យកើតមកពីការទន្ទេញខ្លះ ឲ្យកើតមកពីការរំពឹងរិះគិតពិចារណាខ្លះ ឲ្យកើតមកពីការស្វាធ្យាយខ្លះ ឲ្យកើតមកពីការពិចារណាសំឡឹងមើលនូវហេតុនិងផលឲ្យសមគ្នាតាមសភាពពិតខ្លះ, ព្រោះវិជ្ជាគ្រប់យ៉ាងក្នុងលោកនេះ តាមតែវិជ្ជាអ្វីក៏ដោយ ដែលជាវិជ្ជាត្រង់មិនប្រកបដោយទោសមានវិជ្ជាកសិកម្មពាណិជ្ជកម្មជាដើម សឹងមានផលប្រយោជន៍កើតទ្រព្យសម្បត្តិយសស័ក្តិ បានសេចក្ដីសុខចំរើនក្នុងលោកនេះនិងលោកខាងមុខ តាមលំដាប់វិជ្ជាជាន់ទាប-កណ្ដាល-ខ្ពស់ ដោយពិត បានឈ្មោះថាសម្មាទិដ្ឋិជាលោកិយ ។

សម្មាទិដ្ឋិ ប្រាជ្ញាយល់ឃើញត្រង់ជាលោកុត្តរនោះ សេចក្តីថា សប្បុរសទាំងឡាយមានប្រាជ្ញាយល់ឃើញជាក់ច្បាស់ថា សេចក្តីសុខទាំង ៣ យ៉ាង គឺ សុខរបស់មនុស្ស ១ សុខរបស់ទេវតា ១ សុខក្នុងព្រះនិព្វាន ១ ជាផលកើតមកអំពីបរិច្ចាគទ្រព្យទាន ១ សមាទានរក្សាសីល ១ ចំរើនមេត្តាភាវនា ១ ហើយខំប្រឹងប្រែងធ្វើទានរក្សាសីលភាវនាពុំដាច់ៗ ន័យមួយទៀត គឺមានប្រាជ្ញាភ្លឺស្វាងវៃរៀងចាក់ធ្លុះទៅក្នុងគន់ព្រះអរិយ-សច្ចទាំង ៤ មានទុក្ខសច្ចជាដើម បានធ្វើសោឡសកិច្ចទាំង ១៦ ឲ្យហើយស្រេច បានសម្រេចមគ្គ ៤ ផល ៤ មានសោតាបត្តិមគ្គជាដើម បានឈ្មោះថាសម្មាទិដ្ឋិជាលោកុត្តរពិត ។

កិច្ចការទាំងអស់នេះ សម្តេចព្រះលោកុត្តមាចារ្យជាម្ចាស់ទ្រង់ឲ្យនាំទប្រដៅពុទ្ធបរិស័ទថា ត្រូវតែខំព្យាយាមរៀនសូត្រឲ្យចេះដឹងស្ទាត់ដោយខ្លួនឯង ហៅថា សាមញ្ញសាសនា ។

ទី ២– អធិប្បាយថា: ព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គទ្រង់ប្រៀនប្រដៅដល់ពុទ្ធបរិស័ទថា ផលប្រយោជន៍គឺមនុស្សសម្បត្តិទឹងយសស័ក្តិជាដើមក្នុងលោកនេះក្តី, ទេវសម្បត្តិជាទិព្វទឹងមនុស្សសម្បត្តិដែលនឹងត្រូវបានទៅក្នុងលោកខាងមុខក្តី, និព្វានសម្បត្តិដែលជាសម្បត្តិយ៉ាងខ្ពង់ខ្ពស់បំផុតក្តី, ក៏សម្បត្តិទាំងអស់នេះដែលនឹងកើតឡើង ក៏កើត

មកតែអំពីការរៀនសូត្របេះដឹងជាក់ច្បាស់នូវវិជ្ជាដែលជាផ្លូវត្រង់មានអង្គ
៨ មានសម្មាទិដ្ឋិប្រាជ្ញាយល់ឃើញត្រង់ជាដើម ហើយបដិបត្តិតាមផ្លូវ
ដោយខ្លួនឯង បានឈ្មោះថា សាមញ្ញផលសាសនាពិត ។

ទី ៣– អធិប្បាយថា: សម្តេចព្រះអនាវរញ្ញាណព្រះអង្គទ្រង់ប្រទាន
ទុកដល់ពួកពុទ្ធបរិស័ទថា សប្បុរសអ្នកកាន់ព្រះពុទ្ធសាសនា ដែល
មិនបានសម្រេចប្រយោជន៍ដ៏មានខ្លឹមសារបរិសុទ្ធផុតពាកកងកិលេសទាំង
អស់ ក៏បានសម្រេចមកតែអំពីការរៀនសូត្របេះដឹងច្បាស់លាស់នូវវិជ្ជា
ដែលជាផ្លូវត្រង់ហើយបានប្រតិបត្តិត្រូវដោយខ្លួនឯងពិត បានឈ្មោះថា
សាមញ្ញគសាសនា ។

សំដែងរឿងសាសនាមានអង្គ ៣ បញ្ចប់សេចក្តីជាសង្ខេបតែប៉ុណ្ណោះ
ឯង ។

សូមផ្សាយកុសលកសិតនៃកុសលផលបុណ្យដែលជាបច្ច័យកើតមក
អំពីធម្មទាននេះ ចំពោះដល់អស់លោក-អ្នកជាសប្បុរសទាំងឡាយ សូម
ទទួលអនុមោទនាកកាយត្រេកអរយកចំណែកផលបុណ្យធម្មទាននេះ
ដោយកុសលចេតនាស្មោះត្រង់ ហើយសូមឲ្យសាធុសប្បុរសទាំងឡាយ
បានសម្រេចសេចក្តីសុខគ្រប់ប្រការ កុំឲ្យឃ្លៀងឃ្លាតឡើយ ។

ចប់

# រឿងព្រះបាទអសោក

(តមក)

កាលព្រះបាទអសោកបានទស្សនាការឃើញនិគ្រោធសាមណេរកំពុងនិមន្តបិណ្ឌបាតដូច្នោះ ទើបចាត់រាជអមាត្យឲ្យទៅនិមន្តសាមណេរនោះមក ស្ដេចយាងចូលទៅជិតសាមណេរដែលមានឥន្ទ្រិយនិងឥរិយាបថដ៏ស្ងប់ស្ងៀមដូច្នោះ ក៏មានព្រះរាជឱង្ការត្រាស់ថា "លោកម្ចាស់ប្ដូរគង់លើអាសនៈដ៏សមគួរចុះ" ។ ពេលនោះ និគ្រោធសាមណេរងាកមើលក្នុងទិសផ្សេងៗ មិនឃើញមានភិក្ខុដទៃនៅក្នុងទីនោះ លោកក៏ចូលទៅជិតបល្ល័ង្ក ព្រះបាទអសោកជ្រាបដូច្នោះ ទើបទ្រង់ព្រះតម្រិះថា: "សាមណេរនេះនឹងជាម្ចាស់នៃព្រះរាជដំណាក់របស់អាត្មាអញក្នុងថ្ងៃនេះ" ។ សាមណេរបានហុចបាត្រដល់ព្រះហស្តព្រះបាទអសោកហើយ ទើបឡើងគង់លើបល្ល័ង្កនៅក្រោមស្វេតច្ឆត្រ ព្រះរាជាទ្រង់ទតឃើញដូច្នោះក៏មានព្រះរាជហឫទ័យជ្រះថ្លា ទ្រង់សរសើរនូវការសង្រួមឥន្ទ្រិយជាដើមហើយ ទើបព្រះរាជទានភោជនាហារដ៏ត្រកាល ដែលគេតាក់តែងដើម្បីព្រះអង្គ ប្រគេនដល់និគ្រោធសាមណេរ និមន្តឲ្យធ្វើភត្តកិច្ចរួចស្រេចហើយ ទើបត្រាស់សួរនូវពុទ្ធវចនៈនឹងនិគ្រោធសាមណេរ ។ បានសំដែងធម៌ទេសនាក្នុងធម្មបទអប្បមាទវគ្គថ្វាយព្រះរាជាថា:

អប្បមាទោ អមតំ បទំ បមាទោ មច្ចុនោ បទំ
អប្បមត្តា ន មីយន្តិ យេ បមត្តា យថា មតា

សេចក្តីមិនប្រហែសជាផ្លូវមិនស្លាប់ សេចក្តីប្រហែសជាផ្លូវស្លាប់
ពួកអ្នកមិនប្រហែសឈ្មោះថាមិនស្លាប់ ពួកអ្នកប្រហែសទុកដូចស្លាប់ ។

ព្រះបាទអសោកបានទ្រង់ព្រះសណ្តាប់នូវគាថាមួយប្រកបដោយបាទ ៤ នេះ ព្រះអង្គក៏កើតសេចក្តីជ្រះថ្លាក្នុងពុទ្ធសាសនា ទើបបរិច្ចាគនិច្ចភត្តដល់និគ្រោធសាមណេរ ៨ សម្រាប់ ។ សាមណេរថ្វាយព្រះពរថា "អាត្មាភាពបានទទួលព្រះរាជទានដោយត្រូវធម៌ហើយ អាត្មាភាពនឹងបូជាវត្ថុនេះដល់ព្រះឧបជ្ឈាយ៍ដែលលោកប្រដៅអាត្មាភាពឲ្យដឹងគុណទោសខុសត្រូវ" ។ ព្រះបាទអសោកបានប្រគេន ៨ សម្រាប់ទៀតនិគ្រោធសាមណេរថ្វាយព្រះពរថា "អាត្មាភាពនឹងបូជាដល់អាចារ្យដែលលោកលើកយកនូវធម៌ជាប្រយោជន៍មកប្រដៅអាត្មាភាព" ។ ព្រះរាជាប្រគេន ៨ សម្រាប់ទៀត សាមណេរក៏យកទៅបូជាដល់ព្រះសង្ឃអស់ទៅ ព្រះមហាក្សត្រិយ៍ប្រគេន ៨ សម្រាប់ទៀត ក្នុងគ្រាជាគំរប់ ៤ នេះ សាមណេរជាបណ្ឌិតមានប្រាជ្ញាមិនបានធ្វើសព្វាពាយកឲ្យធ្លាក់ចុះ ទើបលោកទទួលយកដោយខ្លួនឯង ។ ដល់ថ្ងៃទី ២ ព្រឹកឡើងនិគ្រោធសាមណេរបាននាំភិក្ខុសង្ឃ ៣២ រូបចូលទៅកាន់រាជស្ថាន ព្រះបាទអសោក

បានប្រគេនបង្គាន់ផ្ទាល់ដោយព្រះហស្តព្រះអង្គហើយនិមន្តព្រះសង្ឃឲ្យ ធ្វើភត្តកិច្ចក្នុងរាជដំណាក់នោះ ដល់ពេលខាងក្រោយភត្តកិច្ច និគ្រោធ-សាមណេរបានសំដែងធម៌ទេសនា ព្រះមហាក្សត្រិយ៍ព្រមទាំងសេនា-បតីនិងរាជបរិស័ទទាំងពួងក៏តាំងនៅក្នុងព្រះត្រៃសរណគមន៍និងសីល ៥ សីល ៨ក្នុងព្រះពុទ្ធសាសនាចាប់ផ្តើមតាំងតែអំពីថ្ងៃនោះមក ។

លំដាប់តពីនោះមក ព្រះបាទអសោកបានត្រាស់សួរព្រះសង្ឃថា «ព្រះបរិយត្តិធម៌ដែលព្រះបរមគ្រូទ្រង់ត្រាស់ទេសនានោះមានប៉ុន្មាន ?» ព្រះមោគ្គលីបុត្តតិស្សត្ថេរថ្វាយព្រះពរថា «បើរាប់ដោយអង្គមាន ៩ បើរាប់ដោយធម្មក្ខន្ធមាន ៨៤.០០០» ។ លុះព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យនោះហើយព្រះអង្គកំណត់ថានឹងបូជាព្រះធម្មក្ខន្ធ ដោយវិហារឲ្យគ្រប់ ៨៤.០០០ ទ្រង់ត្រាស់បង្គាប់ឲ្យបរិច្ចាគព្រះរាជទ្រព្យ ៩៦ កោដិ ត្រាស់បញ្ជាទៅលើក្សត្រិយ៍ទាំង ៨៤.០០០, ឯព្រះអង្គក៏ទ្រង់ផ្តើមសាងអសោការាមឡើងក្នុងពេលនោះ លុះតដល់ ៣ ឆ្នាំទើបសម្រេចវត្ថុនោះ ហើយព្រះអង្គបានព្រះរាជប្រកាសប្រាប់ដល់ស្តេចគ្រប់ប្រទេសឲ្យធ្វើវិហារទាំង ៨៤.០០០ នោះក្នុងថ្ងៃមួយព្រមគ្នា ប្រកាសឲ្យអ្នកនគរទាំងអស់សមាទានឧក្កដ្ឋង្គឧបោសថសីលក្នុងពេលនោះគ្រប់ៗគ្នា ។

ព្រះបាទអសោកមានវត្ថុ ២ ប្រការដែលមានឧបត្ថម្ភគាំពារយ៉ាងវិសេស គឺព្រះខាន់កែវ ១ ឈ្មោះបរន្តបៈអាចទៅកាត់ក្បាលសត្រូវបានចម្ងាយមួយ

រយៈយោជន៍យកមកថ្វាយព្រះអង្គដូចព្រះបំណង មានប្រាក់មាសមួយខ្សែ អាចទៅចាប់ចងក្រៀកមនុស្សប្ដូរក្ដាំងឲ្យយនាំយកមកបានដូចព្រះរាជ-ប្រាថ្នា ។

ថ្ងៃមួយ ព្រះបាទអសោកទ្រង់ព្រះសណ្ដាប់ថា កាឡនាគរាជមានអាយុមួយកល្ប ជាអ្នកបានទាន់ឃើញព្រះពុទ្ធទាំង ៤ ព្រះអង្គដែលទ្រង់ចូលកាន់ព្រះនិព្វានទៅហើយ ទើបស្ដេចប្រើប្រាក់មាសឲ្យទៅនាំយកកាឡនាគរាជនោះមក ព្រះអង្គបានអញ្ជើញកាឡនាគរាជឲ្យឡើងលើរតន-បល្ល័ង្ក បូជាដោយគ្រឿងសុគន្ធជាតិនិងផ្កានានា ហើយស្ដេចត្រាស់បង្គាប់ឲ្យកាឡនាគរាជនិម្មិតធ្វើជារូបព្រះពុទ្ធម្ចាស់ ស្ដេចនាគក៏បានធ្វើតាមព្រះរាជបំណង បាននិម្មិតខ្លួនធ្វើជាព្រះពុទ្ធឡើង មានរូបភាពដូចជាព្រះពុទ្ធសុទ្ធសាត ជាទីនាំមកនូវសេចក្ដីជ្រះថ្លាពន់ពេក ព្រះបាទអសោកបានទតមើលព្រះពុទ្ធនិម្មិតនោះដោយបីតិរីករាយផ្សព្វផ្សាយសព្វសព៌ាង្គ ឲ្យកើតមានសេចក្ដីជ្រះថ្លារឹងរឹតតែកំរើនខ្លាំងឡើង ព្រះអង្គទតសំឡឹងឆ្ពោះទៅព្រះពុទ្ធនោះមិនប៉ព្រិចនេត្រាហាក់ដូចជាទីងរជកព្រះនេត្រាពីព្រះអង្គទៅជាប់ទីងព្រះពុទ្ធនិម្មិតនោះ ដោយទ្រង់អត់ព្រះក្រយាស្ងោយរហូតដល់ ៧ ថ្ងៃ កិច្ចនោះឈ្មោះថា អក្ខិបូជា (បូជាភ្នែក) ។ (៣៩៩)

១

# ប្រវត្តិពួកឧបាសកឧបាសិកា

## ជាសាវកសាវិការបស់ព្រះពុទ្ធជាម្ចាស់

៧ — ឧគ្គត-ហត្ថិគាមក — កើតក្នុងត្រកូលសេដ្ឋី ក្នុងហត្ថិគ្រាម ឈ្មោះថា ឧគ្គតកុមារ កាលមានវ័យចំរើនឡើងហើយ ក៏បានទទួលដំណែងសេដ្ឋីជាជំនួសបិតា ។ សម័យនោះ សម្តេចព្រះបរមសាស្តា ស្តេចត្រាច់ចារិកទៅកាន់ហត្ថិគ្រាម ទ្រង់គង់នៅឧទ្យាន ។ វេលានោះ ឧគ្គតសេដ្ឋីកំពុងផឹកសុរាស្រវឹងជួបជុំដោយស្រីបំរើ លុះបានជួបព្រះបរមសាស្តា ក៏បាត់ស្រវឹងស្រា កើតហិរិឩត្តប្បៈឡើង ទើបចូលទៅគាល់ព្រះបរមសាស្តា ស្តាប់ព្រះធម្មទេសនា បានសម្រេចមគ្គផលដល់ថ្នាក់អនាគាមីផល ។ តំណើរតពីមក លោកជាអ្នកត្រេកអរក្នុងការបរិច្ចាគទានទំនុកបំរុងព្រះសង្ឃ មានចិត្តស្មើៗ ក្នុងភិក្ខុទូទៅ អាស្រ័យហេតុនេះ កាលព្រះបរមសាស្តាប្រថាប់នៅព្រះជេតវ័នមហាវិហារ ទើបទ្រង់តាំងក្នុងដំណែងឯតទគ្គដ្ឋានជាកំពូលនៃបណ្តាពួកឧបាសកដែលជាអ្នកឧបដ្ឋាកភិក្ខុសង្ឃ ។

ចប់ប្រវត្តិសង្ខេបរបស់ឧគ្គត-គហបតីតែប៉ុណ្ណេះ ។

៨ — អម្ពដ្ឋ ឬសូរ-អម្ពដ្ឋ — លោកនេះមានឈ្មោះជា ២ គឺឈ្មោះបុរាណ ១ ឈ្មោះសូរ-អម្ពដ្ឋ ១ កើតក្នុងត្រកូលសេដ្ឋីជាអ្នកស្រុកសាវត្ថី លុះ

ចំណើរវៃយបានត្រៀបត្រើយកកាស ដាក់ក្នុងបដ្ឋាកក្នុងគព្រែយ ។ លុះវេលាជិតភ្លឺព្រះបរមសាស្តាទ្រង់ទតឃើញឧបនិស្ស័យធម៌របស់លោក ទើបស្តេចត្រាច់ចារិកទៅកិច្ចាចារនៅមាត់ទ្វារផ្ទះ ។ អម្ពដ្ឋមាណពគ្រាន់តែបានឃើញព្រះបរមសាស្តាក៏គិតថា ព្រះសមណគោតមនេះកើតក្នុងត្រកូលខ្ពស់ ហើយនៅវេលានេះក៏កំពុងរុងរឿងដោយគុណសម្បត្តិដែលគួរអញនិមន្តអាកធនា ទើបចុះទៅទទួលបាត្រនិមន្តឲ្យចូលទៅក្នុងផ្ទះ ហើយអង្គាសដោយចង្ហាន់បិណ្ឌបាត លុះស្រេចភត្តកិច្ចហើយព្រះបរមសាស្តាក៏ទ្រង់សំដែងធម៌ឲ្យសមទីងបរិយារបស់លោក នៅទីបំផុតចប់ព្រះធម្មទេសនា សេដ្ឋីបានសម្រេចសោតាបត្តិផល ឯសម្តេចព្រះបរមសាស្តាស្តេចត្រឡប់វិលមកវិញ ។

ត្រង់នេះ មានសេចក្តីពណ៌នារបស់ព្រះគន្ថរចនាចារ្យប្លែកទៅទៀតថា មារមានចិត្តបាបគិតថា អំពីដើម អម្ពដ្ឋកុមារនេះនៅក្នុងអំណាចវិស័យរបស់អញ តែឥឡូវនេះបានស្តាប់ធម៌របស់ព្រះសមណគោតមទីងសម្រេចមគ្គផលកន្លងហួសវិស័យរបស់អញឬនៅឡើយហ្ន៎? គិតដូច្នោះហើយ ក៏និម្មិតរូបខ្លួនឲ្យដូចព្រះបរមសាស្តា: ហើយចូលទៅកាន់ផ្ទះអម្ពដ្ឋសេដ្ឋី ។ បានឃើញក៏ចេញមកទទួល ហើយក្រាបទូលសួរអំពីហេតុដែលស្តេចយាងមក ដោយស្មានថាជាព្រះពុទ្ធជាម្ចាស់ ។ ខណៈនោះ មារពោលពាក្យតបទៅថា ម្នាលអម្ពដ្ឋ: តថាគតមិនបានជា

ពិចារណា សំដែងធម៌ដល់អ្នកក្លាត់ក្លាំងទៅខ្លះ ត្រង់ដែលតថាគតពោលថា បញ្ចក្ខន្ធទាំងពួងមិនទៀង ជាទុក្ខ ជាអនត្តា ការពិត មិនមែនដូច្នេះទាំងអស់ទេ មានខន្ធបំពួកខ្លះដែលទៀងទាត់ឋិតថេរក៏មាន ។

គ្រាន់តែបានស្តាប់ពាក្យនេះ អម្ពដ្ឋមាណពនឹកសង្ស័យ ទើបរំពឹងពិចារណាទៅយល់ថា ធម្មតាព្រះពុទ្ធដីកាមិនដែលមានពីរទេ នេះប្រហែលជាមារនិម្មិតមកទេដឹង ទើបសួរទៅថា អ្នកឯងជាមារមែនឬទេ ? ឯមារមានចិត្តបាបលុះដឹងថាគេស្គាល់ខ្លួនហើយ ក៏អន្តរធានបាត់ទៅនៅទីនុះឯង ។

អាស្រ័យហេតុនេះ ទើបព្រះបរមសាស្តាតាំងក្ខនិងដំណែងឯតទគ្គៈប្រសើរលើសលែងជាងពួកឧបាសកដែលមានចិត្តជ្រះថ្លាមិនរំភើបញ្ញយ ។

ចប់ប្រវត្តិសង្ខេបរបស់អម្ពដ្ឋតែប៉ុណ្ណោះ ។

# ភូមិសាស្ត្រសង្ខេប

## នៃប្រទេសអង់គ្លេស (តមក)

គ្រឿងដែក – ផ្ញើទៅលក់ប្រទេសផ្សេងៗទូទៅក្នុងលោក ។

ធ្យូងថ្ម — ផ្ញើទៅលក់ប្រទេសបារាំងសែស ឥតាលី, អល្លឺម៉ង់, អេស្ប៉ាញ, ស៊ុយអែត ។

សំពត់រោមសត្វ — ផ្ញើទៅលក់ប្រទេសផ្សេងៗក្នុងអាមេរិក, អូស្ត្រាលី, ចិន ។

កប៉ាល់ជំនួញនិងកប៉ាល់ចម្បាំង – ផ្ញើទៅលក់ទូទៅ ។

គ្រឿងយន្ត – ផ្ញើទៅលក់ប្រទេសអល្លឺម៉ាញ, រុស្ស៊ី, អហ្វ្រិកខាងត្បូង, ចិន, អូស្ត្រាលី, កាណាដា ។

គ្រឿងចាន – ផ្ញើទៅលក់សហរដ្ឋអាមេរិកនិងកាណាដា ។

ទង់ដែង – ផ្ញើទៅលក់ឥណ្ឌា, បារាំងសែស, អល្លឺម៉ាញ និងហូល្ល៉ង់ ។

គ្រឿងស៊ីមី – ផ្ញើទៅអាមេរិក, ជប៉ុន ។

**ជំនួញលក់ចូល** — ជំនួញដែលលក់ចូលមកក្នុងប្រទេសអង់គ្លេសដោយច្រើនជាគ្រឿងអាហារនិងធម្មជាតិវត្ថុ ។

ប្រទេសដែលនាំជំនួញចូលមកលក់ប្រទេសអង់គ្លេសជាច្រើនបំផុតគឺអាមេរិក, អាសង់ទីន, អល្លឺម៉ាញ, ដាណឺម៉ាក, បារាំងសែស, ឥណ្ឌា,

កាណាដា, សហរដ្ឋអាមេរិកខាងត្បូង, ផ្ដេអៀឡេង់, ហុល្លង់ដ៍នឹង បែលស៊ិក ។ ឯជំនួញអស់នោះមានស្រូវនឹងម្សៅស្រូវប៉ូ, កប្បាស កេមកែះ សាច់កែះ, ស្ករ, ស្បែកសត្វ, ស្រាទំពាំងបាយជូរ, កាហ្វេ កាកាវ, ស៊ុតសត្វ, ថ្នាំជក់ ទឹកលោហធាតុផ្សេងៗ ។

ស្រុកកំពង់ ១ — កោះអេក្លូស្ស៍ មានស្រុកក្លាសកាវនឹងស្រុក ដង់ឌីជាស្រុកកំពង់ ។ ក្លាស្កាវជាស្រុកកំពង់ធំបំផុតក្នុងកោះអេក្លូស្ស៍ ធ្វើជំនួញនឹងអាមេរិកច្រើនជាងស្រុកដទៃ ។

២ — ប៉េអ៊ីសដឹកល្វ - មានស្រុកការឌីហ្វជាកំពង់ធំបំផុត ចំណាយធ្យូងថ្មទៅកាន់ទ្វីបផ្សេងៗ ។

៣ — អង់គ្លេស - មានស្រុកឡុងដ៍ជាទីក្រុង (មានចំនួនមនុស្ស ៨ លាន) ជាស្រុកកំពង់ធំបំផុត ។ ក្នុងព. ស. ២៤៧៨ មានកប៉ាល់ជំនួញចូលមកក្នុងស្រុកនេះ ១៤.០១៩ កប៉ាល់ ។ ឯជំនួញដែលនាំចេញចូលតាមកំពង់ឡុងដ៍តែមួយប៉ុណ្ណោះប្រមាណ ៣០% នៃជំនួញក្នុងប្រទេសអង់គ្លេសទាំងអស់ ។ ស្រុកលីវើពុលជាស្រុកកំពង់ធំទី ២ ធ្វើការលក់ដូរនឹងទ្វីបអាមេរិកដោយច្រើន ជាស្រុកដែលលក់ជំនួញកប្បាសច្រើនបំផុតក្នុងលោក ។ ស្រុកកំពង់ដែលសំខាន់ៗបន្ទាប់មកគឺ ស៊ូតាំតុង, ហុល, សូខស៊ី, មិតផ្ទេសប៊ួរក៍, ព្លីមូទ្រ ជាដើម ។

គមនាគមន៍ — អង់គ្លេសមានផ្លូវរថភ្លើងប្រវែង ១២.២៤០ គីឡូម៉ែត្រ ផ្លូវថៃអ ១.៧១៧ គីឡូម៉ែត្រ ថ្នល់ ២៨២.៥១៥ គីឡូម៉ែត្រ ព្រែកក្នុងអង់គ្លេសនិងប៉េអ៊ីដឹកល្ប្រវែង ៥៨.២៥៦ គីឡូម៉ែត្រ ក្នុងអេកូស្ស៍ ២.៩៤៤ គីឡូម៉ែត្រ ។ មានមន្ទីរធ្វើការប្រៃសណីយ៍ ២២.៧១០ អន្ទើ មន្ទីរធ្វើការទូរលេខ ១២.៥៦៤ អន្ទើ ខ្សែទូរលេខនិងទូរស័ព្ទមានខ្នាតវែងជិត ១៣ លានគីឡូម៉ែត្រ ។

ប្រជាជន — ក្នុងអេកូស្ស៍មានចំនួនមនុស្សប្រមាណ ៤.៨៤២.៥៥៤ នាក់ ក្នុងអង់គ្លេសមានមនុស្ស ៣៧.៧៨៩.៧៣៨ នាក់ ក្នុងប៉េអ៊ីដឹកល្ មាន ២.១៥៨.៣៩២ នាក់ ក្នុងកោះម៉ង់និងកោះសារណែលមាន ១៤២.២៩៩ នាក់ រួមទាំងអស់មានចំនួន ៤៤.៩៣២.៧៥៣ នាក់ កាលពីក្នុងពុទ្ធសករាជ ២៤៧៤ ។

សាសនា — ប្រជាជនអង់គ្លេសកាន់សាសនាគ្រិស្តនិកាយប្រូតេស្តង់ស្ទើរតែទាំងអស់ ។

ស្រុកសំខាន់ៗ — ក្រៅពីដែលពោលរួចមកហើយនៅមានស្រុកសំខាន់ៗ ផ្សេងទៀតដូចមានឈ្មោះខាងក្រោមនេះគឺ :

អេឌិមបួក — ជាទីក្រុងនិងជាស្រុកធំទី ២ របស់កោះអេកូស្ស៍ ។

ប៉័រតស:មុទ ឬប៉័រតស៍ម៉ូទ ជាស្ថានទីពាដើងទឹករបស់អង់គ្លេស ។

ពុម្ពេ – ជាទីប្រជុំនៃសាទកម្ម ។

ឌូវ្រ៍ – ជាកំពង់កប៉ាល់ទទួលចម្លងមនុស្សចេញចូលទៅស្រុកប៉ាដឺ-កាលេស៍របស់បារាំងសែស ។

**ស្រុកចំណុះរបស់អង់គ្លេស** — មិនមានប្រទេសណាក្នុងលោកមានស្រុកចំណុះច្រើនប្រហែលនឹងប្រទេសអង់គ្លេសឡើយ គឺមានទូទៅគ្រប់ទ្វីបទាំងអស់ ប្រមាណទំហំផែនដីដែលជាចំណុះរបស់អង់គ្លេស ៣០.០០០០.០០ គីឡូម៉ែត្រក្រឡា (ច្រើនជាង ១ ភាគក្នុង ៥ ភាគរបស់ផ្ទៃលោកទាំងមូល) ។ ឯចំនួនមនុស្សជាចំណុះអង់គ្លេសមានប្រមាណ ៤៦២ លាន (ប្រមាណ ១ ភាគក្នុង ៤ ភាគនៃចំនួនមនុស្សក្នុងលោក) ។ ស្រុកចំណុះរបស់អង់គ្លេសចែកចេញជា ៥ ប្រភេទគឺ

១ **ស្រុកចំណុះដែលត្រួតត្រាខ្លួនឯង** — គឺពួកប្រទេសដែលអង់គ្លេសបានទៅនៅត្រួតត្រាយូរហើយ ឯក្រោយរដ្ឋបាលអង់គ្លេសអនុញ្ញាតឲ្យត្រួតត្រាស្រុកទេសដោយខ្លួនឯងបាន តែច្បាប់ដែលប្រកាសចេញក្នុងស្រុក តោងបានទទួលព្រះបរមានុញ្ញាតរបស់ព្រះមហាក្សត្រជាមុនសិន ហើយមានមន្ត្រីជាដំណាងអង្គព្រះមហាក្សត្រអង់គ្លេសនៅត្រួតត្រាកាន់កាប់ជាជំនួសព្រះអង្គ ។ ស្រុកចំណុះពួកនេះ គឺទ្វីបអូស្ត្រាលី, កាណាដា, នូវ៉ែលសេឡង់, តែរេនើវ, សហរដ្ឋអាហ្វ្រិកខាងត្បូង និងឥស្សរដ្ឋអៀរឡង់ជាដើម ។

**២ – ស្រុកចំណុះដែលអង់គ្លេសកាន់កាប់ត្រួតត្រា** – ស្រុកទេសដំពូកខ្លះជាស្រុកដែលអង់គ្លេសទៅនៅត្រួតត្រាដូចពួកមុននេះដែរ តែដោយហេតុជាស្រុកតូច ឬមិនទាន់មានសេចក្ដីចំរើនគ្រប់គ្រាន់ ទើបរដ្ឋបាលអង់គ្លេសមិនទាន់ព្រមបណ្ដោយឲ្យត្រួតត្រាខ្លួនឯង ៗ ស្រុកចំណុះចំពួកនេះ គឺឥណ្ឌៀ, លង្កា, ម៉ាឡាយូ, ភូមា ហុងកុង ជាដើម ៗ

**៣ – ស្រុកចំណុះដែលសុំចូលក្នុងការគ្រប់គ្រង** – ស្រុកចំណុះចំពួកនេះ មានការត្រួតត្រាខាងក្នុងស្រុកដោយឥស្សរៈ តែប្រសាសនោបាយរបស់ការបរទេស រដ្ឋបាលអង់គ្លេសកាន់កាប់ត្រួតត្រា គឺដែនខ្លះក្នុងឥណ្ឌៀ, បេលូជិស្ថាន, សហរដ្ឋម៉ាឡាយូ, ណាយ៉ាសាឡង់, កែនយ៉ា, អូកង់ដា, សូម៉ាលីឡង់ជាដើម ៗ

៤ – ពួកស្រុកចំណុះដែលរាជការអង់គ្លេសមិនបានកាន់កាប់ត្រួតត្រាផ្ទាល់ខ្លួនទេ តែបានប្រគល់អំណាចឲ្យអ្នកសម្រេចរាជការស្រុកចំណុះត្រួតត្រាជំនួស មានស្រុកអាដែននឹងកោះផ្សេងៗ ជាដើម ៗ

៥ – ស្រុកចំណុះដែលសន្និបាតនានាជាតិប្រគល់ឲ្យទំនុកបំរុង បានដល់ស្រុកប៉ាលេស្ទីន នឹងស្រុកដំពូកខ្លះដែលចំណុះអល្លឺម៉ង់នៅទ្វីបអហ្វ្រិក ៗ

(មានត)

# ៣ ជ័ក្ខាតការពេម

( តមក )

ឯស្រុកការថាស៍ កាលបើបានឃើញអន្ទិបាលខ្លាំងពូកែច្រើន ដូច្នោះ គួរតែមានសេចក្តីត្រេកអរទីដ៍ជ័យជំនះរបស់មនុស្សជាតិជាមួយគ្នា ត្រឡប់ជាមានចិត្តប្រស្យាមិនព្រមបាត់បញ្ជូនទ័ពទៅជួយអន្ទិបាល ទើបអន្ទិបាលអង្វរសុំកំឡាំងពីប្អូនខ្លួននៅប្រទេសអេស្ប៉ាញឲ្យបញ្ជូនទ័ពមកជួយ ហើយធ្វើស្ពានមេត្រីនឹងព្រះបាទហ្វីលីប ក្សត្រប្រទេសម៉ាសេ-ដូន នឹងពួកស៊ីកុស តែឃើរពេកមិនទាន់ការ ខាងពួករ៉ូម៉ាំងបានបាត់ទ័ពទៅចាំស្ទាក់ត្រង់ច្រក ហើយក្រុងរ៉ូមបានបាត់ទ័ពឲ្យលើកទៅវាយដល់ប្រទេសអេស្ប៉ាញ ដិតចូលទៅវាយដល់ស្រុកការថាស៍របស់អន្ទិបាលហើយ ទើបអន្ទិបាលខំប្រូតមកស្រុកវិញយ៉ាងប្រញាប់ ទាហានណា មិនព្រមត្រឡប់ទៅវិញ អន្ទិបាលក៏សម្លាប់ចោលទាំងអស់ ៗ អន្ទិបាលបានបាត់តាំងកងទ័ពច្បាំងនឹងពួករ៉ូម៉ាំងតាំងពីពេលត្រឡប់មកវិញ ជាវេលាដល់ ១៨ ឆ្នាំ ហើយហេតុដែលក្រុងរ៉ូមមិនដល់នូវសេចក្តីវិនាសក្នុងគ្រានោះ ព្រោះអន្ទិបាលមានតែខ្លួនម្នាក់ឯង ៗ

## អំពីចម្បាំងនៅសាម៉ា (Zama)

លុះអន្និបាលត្រឡប់ទៅដល់ស្រុកខ្លួនហើយក៏បះចម្បាំងនឹងស៊ីប្យ៉ុង (Scipion) នៅស្រុកសាម៉ា កាលពីពុទ្ធសករាជ ៣៤១ (មុនគ.ស. ២០២) តែចម្បាំងក្នុងគ្រានេះ អន្និបាលមិនមានពួកទាហានជាន់ចាស់ទើបចាញ់ប្រៀបស៊ីប្យ៉ុងដោយប្រការទាំងពួង ការថាស៍ទើបសុំស្ងប់សង្គ្រាម នឹងត្រូវពិន័យឲ្យរ៉ូមជាចំនួនច្រើន ។ ខ្លួនអន្និបាលគេចថយចេញពីការថាស៍ទៅប្រទេសស៊ីរី ហើយញុះញង់ក្សត្រប្រទេសស៊ីរីឲ្យធ្វើសង្គ្រាមនឹងរ៉ូមឡើង តែនៅទីបំផុតប្រទេសស៊ីរីក៏ចាញ់រ៉ូម ទើបអន្និបាលរត់ចេញពីស៊ីរីទៅទៀត តែគ្រានេះកងទ័ពរ៉ូមដេញតាមចាប់អន្និបាល ឯអន្និបាលឃើញថាចួនខ្លួនណាស់ហើយក៏ផឹកថ្នាំពុលស្លាប់ទៅ ដើម្បីមិនឲ្យទ័ពរ៉ូម៉ាំងចាប់បានទាំងរស់ (រវាងមុន គ.ស. ១៨៣ ព.ស. ៣៦០) ។

លុះអស់បុណ្យអន្និបាលហើយ ដល់រវាង ៥០ ឆ្នាំតមក ក្រោយដែលបានធ្វើសន្យាស្ងប់សឹក ស្រុកការថាស៍ចាស់ក៏ត្រឡប់ជាស្រុកស្ដុកស្ដម្ភឡើងវិញទៀត ធ្វើឲ្យក្រុងរ៉ូមស្ញើបរកើបជាច្រើន ក្រែងដូចកាលអន្និបាលទៀត ទើបត្រូវតែក្រុងរ៉ូមរកឧបាយរំលាយកំទេចស្រុកការថាស៍ឲ្យបាន តាំងអំពីនោះគេមកពាក្យថា "ត្រូវរំលាយការថាស៍ចេញ" ជាពាក្យបន្ថែមនៅចុងសុន្ទរកថាខ្លួនទៅ ដែលពួកអ្នកមានសំដីវោហារលើកឡើងនិយាយ ។

ការកកើងច្បាំងនោះមិនជាការក្រទេ នៅក្នុងពុទ្ធសករាជ ៣៩៤ (មុនគ.ស. ១៤៩) ឯពួកការថាស៍ត្រូវតែរៀបចំសាងកងទ័ពជើងទឹកឲ្យមាំមួនការពារខ្លាំងស្រដៀងគ្នា តែការដែលប្រទេសការថាស៍រៀបចំនេះ ខាងក្រុងរ៉ូមប្រកាន់ថា ការថាស៍ធ្វើខុសខសន្យា ទើបក្រុងរ៉ូមបង្ខំឲ្យគិតគួរកែខៃ ខាងការថាស៍ក៏ព្រមកែខៃតាម តែបង្គាប់ទៅថាត្រូវឲ្យការថាស៍បញ្ជូនគ្រឿងសាស្ត្រាវុធទាំងទូកចម្បាំងទៅឲ្យរ៉ូមឲ្យអស់ ពួកការថាស៍ក៏ព្រមធ្វើតាម ៗ ខាងពួកក្រុងរ៉ូមក៏នៅតែត្រូវការកកើងច្បាំងឲ្យទាល់តែបាន ក៏បង្គាប់ឲ្យថយចេញទៅចម្ងាយ ១៥ គីឡូម៉ែត្រពីមាត់សមុទ្រ គឺថារ៉ូមត្រូវការត្រួតត្រាមាត់សមុទ្រការថាស៍ទាំងមូល ៗ តាមដោយពិតនោះការថាស៍មានជីវិតគង់វង់នៅបានដោយសារជំនួញខាងផ្លូវសមុទ្រ ការដែលក្រុងរ៉ូមបង្គាប់ឲ្យធ្វើដូច្នេះ ដើម្បីផ្តាច់ជីវិតប្រទេសការថាស៍នេះឯង ហេតុនេះនាំឲ្យពួកការថាស៍មានសេចក្តីអាឃាតក្តៅក្រហាយពន់ពេក ហើយព្រមចិត្តលះបង់គ្រប់ៗយ៉ាង សម្រាប់ជាប្រយោជន៍ក្នុងការច្បាំងតទល់នឹងក្រុងរ៉ូម ៗ ពួកប្រុសៗ ក៏រុះរើផ្ទះរបស់ខ្លួនយកឈើដែកគ្រឿងលោហៈផ្សេង ៗ ទៅធ្វើទូកចម្បាំងឲ្យកងការ ឯពួកស្រីៗ ក៏កាត់សក់វែងរបស់ខ្លួនសម្រាប់យកទៅប្រើជាខ្សែក្នុងកងទ័ពជើងទឹក នេះសំដែងឲ្យឃើញចិត្តស្រឡាញ់ជាតិប្រទេសយ៉ាងខ្លាំងបំផុត ៗ តែទុកជាធ្វើដូច្នេះក៏ដោយ ក៏នៅតែមិនមានកំឡាំងល្មមទប់ទល់នឹងកំឡាំងរបស់ក្រុងរ៉ូមបាន ៗ ពួក

កាថាស៍អត់បាយស្លាប់អស់ទៅជាច្រើន គ្រានេះជាគ្រាដែលជាតិកាថាស៍ដល់នូវសេចក្ដីវិនាសហិនហោចខ្ទេចខ្ទី មានជនជាតិស្រុកកាថាស៍ជាច្រើនរាប់ពាន់នាក់ ព្រមទាំងប្រពន្ធកូនរបស់មេទ័ពកាថាស៍នាំគ្នាលោតចូលគំនរភ្លើងស្លាប់ទៅ តាំងអំពីនោះមកស្រុកកាថាស៍ក៏ទៅជាស្រុកចំណុះរបស់ក្រុងរោម ពុទ្ធសករាជ ៣៩៧(មុន គ.ស. ១៤៦) ។

កាលបើជាតិកាថាស៍វិនាសហើយ ទើបធ្វើឲ្យក្រុងរោមចាប់ធ្វើចម្បាំងនឹងស្រុកឯទៀតៗ បានដោយងាយៗ ដំបូងពួករោមរាំងប្រាបប្រាមពួកគោល៉ូនៅក្នុងស៊ីស័ល្ពីនឲ្យរាបទាបហើយទើបលើកទ័ពទៅប្រាបប្រាមប្រទេសអេស្ប៉ាញ បានលុកលុយប្រទេសនេះជាវេលាយូរ ហើយអាណាខេត្តរបស់រោមនៅទ្វីបឪរុបក៏រីកធំទូលាយចេញទៅទៀតជាច្រើន ។

## អំពីជ័យជំនះរបស់រោមទៅទិសខាងកើត

ក្រុងរោមបានចម្បាំងឈ្នះនឹងពួកកាថាស៍ ដើម្បីរក្សាឥស្សរភាពរបស់ខ្លួនឯង លុះមានជ័យជំនះហើយ តមកក៏ធ្វើសង្គ្រាមដោយចិត្តលោភនឹងស្វែងរកអំណាច ។ អាណាចក្រទាំងឡាយនៅទិសខាងកើតដែលជាសម្បត្តិរបស់ព្រះបាទអាឡេក្សង់ដ៏មហារាជ អំណាចដើមនោះក៏សាបសូន្យចុះទៅជាច្រើន ដោយហេតុអ្នកទទួលមត៌កបន្ទាប់ពីព្រះបាទអាឡេក្សង់ដ៏គិតស្វែងរកសេចក្ដីសុខផ្ទាល់ខ្លួន មិនគិតប្រយោជន៍ស្រុកទេស ថែមទាំងមានការបែកខ្ញែកគ្នាមិនបានរួបរួមបូលគ្នា

កំឡាំងក៏ចុះទន់ខ្សោយចុះទៅ ទើបជាហេតុឲ្យពួករ៉ូម៉ាំងផ្សាយអំណាចចូលមក ក្នុងផែនដីចំណែកនេះបានដោយស្រួល ៗ ឯការផ្សាយឫទ្ធិអំណាចនេះ ច្រើនតែរៀបចំធ្វើតាមផ្លូវការទូតច្រើនជាងធ្វើដោយចម្បាំង ព្រោះកងទ័ពរ៉ូម៉ាំងយកទៅប្រើនៅទីដទៃ មិនមានចំនួនគ្រប់គ្រាន់ទីងាត់បញ្ជូនទៅចំណែកទិសខាងកើតបាន ទើបរ៉ូម៉ាំងរង់ចាំឱ-កាសបន្ទោះ កាលបើអាណាចក្រអស់នោះកើតវិវាទទាស់ទែងគ្នាឡើង ក៏លូកដៃទៅគ្រប់គ្រងយកជាស្រុកចំណុះតែម្តង ៗ នៅចំណែកទិសខាងកើតនេះ បើមានប្រទេសណាត្រូវការបណ្តេញពួករ៉ូម៉ាំងដែលទៅនៅមុនហើយ ក៏កើតជាចម្បាំងឡើង ហេតុនេះទើបឃើញថាជ័យជំនះរបស់រ៉ូមនៅទិសខាងកើតនោះ ទើបមានការបង់ខាតទ្រព្យសម្បត្តិទាំងខូចខាតសាច់ឈាមពលជាចំនួនតិចបំផុត ។

សត្រូវដែលក្រុងរ៉ូមត្រូវតែសប់ស្រែងញញើតនោះគឺម៉ាសេដូនីដែលព្រះបាទហ្វីលិប (អង្គក្រោយតពីព្រះបាទអាឡេក្សង់ដ្រ៍មហារាជមក) មានសម្ពន្ធមិត្តនឹងអន្និបាល (ទ្រង់មានព្រះទ័យប៉ងពង្រីកអាណាចក្ររបស់ព្រះបាទអាឡេក្សង់ដ្រ៍ ៗ ខាងក្រុងរ៉ូមបានដឹងរឿងនេះ ទើបចេញប្រកាសយ៉ាងនាប់ថា ជាអ្នកទំនុកបំរុងគ្រប់គ្រងប្រទេសក្រិកនិងអេស៊ីទាំងអស់ ទើបនាំឲ្យកើតសង្គ្រាមនឹងប្រទេសម៉ាសេដូនឡើង ចម្បាំងគ្រានេះធ្វើឲ្យព្រះបាទហ្វីលិបបរាជ័យ ក្នុងពុទ្ធសករាជ ៣៤៦ (មុន

គ.ស.១៩៧) ។ ប្រទេសក្រិកឯទៀត ៗ ក៏ផុតរបូតពីអំណាចប្រទេសម៉ាសេដ្វាន សូម្បីប្រទេសម៉ាសេដ្វានក៏តោងនៅក្នុងអាណាព្យាបាលរបស់រ៉ូមដែរ ។

តមកមានក្សត្រប្រទេសម៉ាសេដ្វាន ១ អង្គទៀត ទ្រង់មានព្យាយាមចង់ដោះខ្លួនឲ្យរួចពីកណ្តាប់ដៃរ៉ូម ចង់ធ្វើការសងសឹកវិញ តែនៅតែបរាជ័យទៀត ក្នុងពុទ្ធសករាជ ៣៧៩ (មុន គ.ស. ១៦៨) ហើយកងទ័ពរ៉ូមក៏ប្រាបប្រាមអស់ទាំងប្រទេសទាំងមូល មានស្រុកខ្លះទ័ពរ៉ូមធ្វើការយ៉ាំងសាហាវ ដូចជាចាប់មនុស្សសម្លាប់អស់ទាំង ៥០.០០០ នាក់ហើយបំផ្លាញស្រុកភូមិអស់ទៅទាំងស្រុក ហើយនៅទីបំផុតប្រទេសក្រិកទាំងមូលក៏ទៅជាស្រុកចំណុះរបស់រ៉ូម ក្នុងពុទ្ធសករាជ ៣៩៧ (មុន គ.ស. ១៤៦) ។

ក្រៅពីនេះ ពួករ៉ូមតោងទៅប្រាបប្រាមប្រទេសស៊ីរីដែលជាសម្ពន្ធមិត្តនឹងអន្ទិបាលនោះទៀតផង ។ ក្នុងគ្រានោះមិនមានប្រទេសណាហ៊ានរឹងទទឹងច្បាំងតទល់នឹងរ៉ូមបានឡើយ រ៉ូមបានបំពេញអាណាខេត្តផ្សេងៗ រហូតដល់ឈូងសមុទ្រទាំង ៣ នៃសមុទ្រមេឌីតេរ៉ាណេ ។

(មានត)

# សេចក្ដីប្រារព្ធ

គម្ពីរលោកនេយ្យ ពាក្យកាព្យនេះ យើងបានចុះផ្សាយក្នុងទស្សនា-វដ្ដីនេះកាលពីឆ្នាំមុនៗមកជាច្រើនហើយដែរ តែមិនទាន់ចប់សព្វគ្រប់ ដោយមានហេតុអាក់ខានមកជាវេលាយូរ តាំងពីឆ្នាំ ១៩៣៩ រហូតមក គួរឲ្យនឹកស្ដាយណាស់ ។

ដល់មកក្នុងកាលនេះ មានឱកាសល្មមនឹងចុះផ្សាយក្នុងឆ្នាំនេះបាន ហើយយើងនាំយករឿងនេះមកចុះបន្តពីសេចក្ដីដែលបានចុះពីខាងចុងឆ្នាំ ១៩៣៨ នោះ ។ អស់លោក-អ្នកដែលធ្លាប់បានជាវទស្សនាវដ្ដីរៀងរាល់ឆ្នាំមកគង់មានសេចក្ដីត្រេកអរ ដោយបានដឹងរឿងពីខាងដើមរហូតមកទល់រឿងក៏ជាលំដាប់តទៅ ។

ពាក្យកាព្យលោកនេយ្យនេះ មានសេចក្ដីវែងឆ្ងាយណាស់ យើងមិនអាចចុះផ្សាយឲ្យចប់តាំងអស់ក្នុងកំណត់ ១ ឆ្នាំបានទេ តែយើងនឹងចុះផ្សាយបន្តិចៗ ត្រាតែចប់សព្វគ្រប់ ។

លោកអ្នកឧកញ៉ាវង្សាសារពេជ្ញ (នង) ជាកវីជាតិខ្មែរម្នាក់ មានឈ្មោះជាអ្នកតែងពាក្យកាព្យជាច្រើនរឿងទុកជាកេរ្ដិ៍តមក ដូចជាប្រជុំពាក្យកាព្យនិងច្បាប់សុភាសិតជាដើម ដែលយើងបានចុះផ្សាយក្នុងទស្ស-នាវដ្ដី ឆ្នាំ ១៩៣៩ – ១៩៤០ – ១៩៤១ រួចមកហើយ ។

ទេពរង្សី

# លោកនេយ្យ ពាក្យកាព្យ

របស់អ្នកឧកញ៉ាវង្សាសរពេជ្ញ (នង)

មួយទៀតលោកថា បើញាតិឯណា មានចិត្តអស់អញ ចិញ្ចឹមរក្សា ព្យាបាលស្រឡាញ់ ទុកញាតិនោះមិញ ស្មើម្តាយអាពុក ។ មួយស្រីឯណា បើបានស្នេហា នូវលេតទុក្ខ ស្រីនោះហៅថា ភរិយាឲ្យសុខ បើស្និទ្ធទំនុក នឹងអ្នកឯណា ។ អ្នកនោះហៅមិត្រ សំឡាញ់ស្នេហ៍ស្និទ្ធ មួយសោតលោកថា ឲ្យរៀរចៀសស្រី ក្បត់ប្តីអាត្មា មិត្រកាចទ្រុស្តគ្នា ខ្ញុំជំនឹងម្ចាស់ ។ បើពុំរៀរឡើយ ខំគប់នៅហើយ នឹងកើតទុក្ខណាស់ លោកថាស្មើយក ពស់មកជាម្ចាស់ ក្របើផ្គាប់ណាស់ នឹងវិនាសប្រាណ ។ មួយគឺមហាមិត្រ គាប់គួរចូលចិត្ត បំរើនោះមាន ទាំងដប់ប្រការ អាចារ្យទិទាន គឺព្រះទ្រង់ញាណ ត្រាស់ធម៌ទេសនា ។ នូវព្រះបច្ចេក- ពោធិឯនឯក អគ្គអរហន្តា ភិក្ខុភិក្ខុនី ជននីបិតា រៀមច្បងអនុជា នូវក្សត្រធិបតី ។ នូវអ្នកប្រាជ្ញប្រាយ ចែងធម៌ទាំងឡាយ នោះគួរគប្បី បំរើផ្តេកផ្តិត ជាមិត្រមេត្រី ធ្វើគតវេទី នូវបានសុខសល់ ។ ពុំបាច់ព្រួយរៀន សិល្បសាស្ត្ររៀន ចំណេះខ្វាយខ្វល់ ដូចគល់ស្រមណ៍ព្រាហ្មណ៍ ដោយតាមយោបល់ ប្រាជ្ញាលុះដល់ សុខសួគ៌និព្វាន ។ ហេតុនោះលោកថា អ្នកមានប្រាជ្ញា សប្បុរសប្រធាន ឲ្យគេអ្នកដប់ ចូរគប់ឲ្យបាន ជាមិត្រកុំខាន តាមដោយធម៌ថា ។

មួយសោតអ្នកទាល់ ទុគ៌តស្រើបស្រាល កាចឥតសង្ខា ហើយចូល
ទៅគប់ ប្រសព្វនៅនា ទីអ្នកដប់ត្រា-ការទាំងនោះហើយ ៗ
កុំបានជាគុណ ផលប្រយោជន៍បុណ្យ ខ្លួនដល់តិចឡើយ ដូចកញ្ចាញ់
ចេក ដែកនៅគៀកកើយ លើផ្កាឈូកហើយ ពុំយកសេផ្កា ៗ អ្នក
ណាមាន សប្បុរសញេយ្យញាណ ចិត្តថ្លាសាធារណ៍ បើទៅសំណាក់
ទីអ្នកដប់ត្រា-ការនោះមាត្រា តែពេចក្តី ៗ បានប្រាជ្ញអស់អាថ៌
គ្រង់គ្រស់សេធម៌ គាថាបាឡី ប្រយោជន៍អាត្មា ក្នុងនាលោកិយ ដល់
បរលោកក្តី សោយសុខសួគ៌ា ៗ ដូចកល់គន្ធ ហនន្តាយគ្រាប់គ្រង់
គ្រឹបរកសផ្កា បានហើយយកទៅ លំនៅអាត្មា លោកដូចខ្ញុំកថា
ដូចសប្បុរសធម៌ ៗ

ស្តេចស្តាប់ព្រះពោ-ធិសត្វសេដ្ឋា ទូលដូច្នោះហោង ទើបក្សត្រ
ឥស្សរ បន្ទូលសារសង់ ត្រេកត្រាស់ទៅផង អាចារ្យចាំងប៉ ៗ ថាហៃ
អាចារ្យ ធនញ្ជយកុមារ សព្វថ្ងៃប្រក្រតី នេះតើបួលចិត្ត ជាមិត្រ
មេត្រី នឹងអ្នកចាំងប៉ ឬកុំជាមិត្រ ៗ អាចារ្យចាំងប៉ ក្រញូក្រាបទូ
ទូលថាបពិត្រ យើងខ្ញុំចាំងប៉ មេត្រីជាមិត្រ នឹងធនញ្ជយឥត សទ្ធិះ
សង្កា ៗ ឯធនញ្ជយនោះ មិនជាមិត្រស្មោះ នឹងខ្ញុំឡើយណា ស្តេច
ត្រាស់ថាហៃ ធនញ្ជយគេថា ដូច្នោះតើបា មែនពិតឬអ្វី ៗ ពោធិ-

សត្វទូល បពិត្រឥស្សូរ ជាម្ចាស់សិរសី មែនដូច្នោះពិត ពុំទិត្យសេចក្តី ដ្បិតមានបាលី ទុកជាច្បាប់ថា ៗ

សកិំទុដ្ឋំ បិយមិត្តំ បុនសន្ធា-តុមិច្ឆតិ គព្ភំអស្ស- តរីយថា មរណ- ភវេ ៗ

បពិត្រចក្រី ធម៌លោកស្រដី តាមថែងបន្ទូ ជាអាថ៌បាលី ថាមិត្រឯ- ណាមួយបើគេ គិតទ្រុស្តម្តងហើយ ៗ គួរកុំបង់ចូល មកជាមិត្រមូល វិញទៀតជាត្រើយ កុំឲ្យយកវា មកជាមិត្រឡើយ ខំយកមកហើយ ជាទុក្ខអាត្មា ៗ ស្មើទូបទូរម៉ែ-ត្បូវផ្តេកផ្តួលផ្តិត តែងតែ មរណា ដូចគិកិអស្សតរ បរិបូណ៌ហើយណា តែងតែមរណា ពុំដែល រស់ឡើយ ៗ ស្តេចស្តាប់ពាក្យពី ព្រះពន្សូរោធ ទូលដូច្នោះហើយ ពុំមានព្រះសូរ បន្ទូលទៀតឡើយ ស្តេចដោះឡើងហើយ ចូលក្នុង ប្រាសាទ ៗ ឯកដំបណ្ឌិត ទូលព្រាហ្មណ៍បុរោហិត សេនាអមាត្យ បន្តិ លុតលា ក្សត្រានរនាថ វិលមកឋានអា- ត្មាទៅដោយរៀ ៗ

អសិនាគ: បញ្ហាវណ្ណ: នាទីងស្រដី កាលស្តេចសង្កា ចិន្តាភូមិ ទីងពន្សូរោធ- សត្វសូរប្រហោង ៗ

(នៅមានទៀត)

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

## ឆ្នាំគំរប់ ១៤ ភាគទី ៩

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

BIBLIOTHÈQUE ROYALE DU CAMBODGE

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៥

គ.ស. ១៩៤២

# បញ្ជីរឿង


ទំព័រ

១ — វិទ្យុធម្មទេសនា កណ្ឌទី ៣ ព្រះតេជព្រះគុណ ព្រះពុទ្ធឃោសាចារ្យ (ជ. ណាត) ចាងហ្វាងនៃសាលាបាលីជាន់ខ្ពស់សំរេច . . . . . . . . . . . . . . ៣

២ — អភិនវភាសិត លោកគ្រូអាចារ្យ អ៊ុក-ជា ក្រុមជំនុំព្រះត្រៃបិដក ជាអ្នកតែង និងរៀបរៀង . . . . . . . . . . . . . . . . . . . . . ១២

៣ — ពង្សាវតារភេទ ស្រង់យកអំពីគោលជាតកផ្សេងៗក្នុងពង្សាវតារលោក (តមក) ២១

៤ — ភូមិសាស្ត្រសង្ខេបនៃតាតាប្រទេសៈ អំពីប្រទេសអង់គ្លេស (តមកនិងចប់) . . . ២៧


## រូបក្រៅរឿង


រូបក្បាច់សិលានៅក្រោមហោជាងខាងលើមាត់ទ្វារប្រាសាទសម្បូរ (ព. ស. ១១៤៣) . . . . . . . . . . . . . . . . . . . . . ១

# TABLE DES MATIÈRES

Pages

1. Vidyudesanā (Prédication faite à la Radio Phnôm-Penh), par le Vénérable Préas Buddhaghosāchar (Ch. Nath) Sous-directeur de l'École Supérieure de Pâli.................. 3

2. Abhinavabhāsita. Pāli et traduction par le Vénérable Ouk-Chéa, membre de la Commission du Tripitaka........... 12

3. Histoire de Rome. Extraits de divers documents de l'histoire universelle (suite)........................... 21

4. Géographie sommaire de divers pays: l'Angleterre (suite et fin)........................................ 27

## HORS-TEXTE :

Linteau d'un sanctuaire de Sambor (1143 E. B.)............... 1



រូបក្បាច់សិលានៅក្រោមហោជាងខាងលើមាត់ទ្វារប្រាសាទសម្បូរ ( ព. ស. ១១៤៣ )

ធម្មទេសនាផ្សាយក្នុងវិទ្យុភ្នំពេញ

កណ្ឌទី ៣

# ព្រះពុទ្ធឃោសាចារ្យ ជួន-ណាត ចាងហ្វាងរង

# សាលាបាលីជាន់ខ្ពស់ សំដែង

នៅថ្ងៃចន្ទ ១៤ រោចខែផល្គុនឆ្នាំម្សាញ់ត្រីស័ក ព.ស. ២៤៨៤ ត្រូវនឹងថ្ងៃ ១៦ ម៉ារ្ស ១៩៤២

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស!

សូមនមស្ការចំពោះព្រះអរហំសម្មាសម្ពុទ្ធគតវន្តមុនី ព្រមទាំងព្រះសទ្ធម្មនិងព្រះអរិយសង្ឃ!

## សូមសំដែងអំពីបុគ្គលដែលកម្រមានក្នុងលោក

ពិតជាក្នុងសកលលោកមានមនុស្សច្រើនមែន, ប៉ុន្តែបើនិយាយឲ្យឃើញជាក់ច្បាស់, ព្រះសព្វញ្ញូសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងប្រាប់ថា បុគ្គល ២ ចំពួកកម្រមានក្នុងលោក ។ បុគ្គលពីរចំពួកនោះគឺ បុព្វការី ១ កតញ្ញូ កតវេទី ១ ។

បុគ្គលណាបានទំនុកបំរុងផ្គងផ្គើមគេមុន នាំគេឲ្យបានលូតលាស់ចំរើន ឲ្យគេបានសេចក្ដីសុខ, បុគ្គលនោះឈ្មោះថា បុព្វការី ។ បុគ្គលណាបានទទួលសេចក្ដីទំនុកបំរុងនោះ ហើយដឹងគុណ បានតបឧបការ-គុណវិញ, បុគ្គលនោះឈ្មោះថា កតញ្ញូ កតវេទី ។

បើសំដែងដោយសាធារណៈ, តាមតែអ្នកណាក៏ដោយ ដែលបានទំនុកបំរុងគេ, អ្នកនោះហៅថា បុព្វការី; អ្នកដែលដឹងគុណ ហើយបានតបគុណវិញ តុំគោះតើយព្រះអើយ, អ្នកនោះឈ្មោះថា កតញ្ញូ កតវេទី ។ ប៉ុន្តែបើសំដែងឲ្យឃើញតាមលំអានដែលតែងតែមានចំពោះដែលវាននោះ, មាតាបិតាឈ្មោះថា បុព្វការី របស់បុត្រធីតា ព្រោះជាអ្នកចិញ្ចឹមបីបាច់ថ្នមទំនុកបំរុងផ្គង់ផ្គើមបុត្រប្រុសស្រី; បុត្រធីតាណា ជាអ្នកដឹងគុណ ហើយបានតបឧបការគុណចំពោះមាតាបិតា, បុត្រធីតានោះឈ្មោះថា កតញ្ញូ កតវេទី ។ លោកអ្នកប្រាជ្ញណាដែលជាសាស្តា បានប្រកាសសាសនាដ៏ល្អបរិសុទ្ធ ឬដែលបានតែងតាំងគម្ពីរក្បួនច្បាប់គម្រោងគម្រាដ៏ត្រឹមត្រូវ ប្រាប់ផលប្រយោជន៍ពិត ៗ ទុកឲ្យអ្នកខាងក្រោយតៗមក (ដូចយ៉ាងព្រះសម្មាសម្ពុទ្ធជាដើម), លោកអ្នកប្រាជ្ញនោះឈ្មោះថា បុព្វការី របស់សាសនិកជនឬរបស់អ្នកដែលជឿស្តាប់; សាសនិកជន (ដូចយ៉ាងពុទ្ធសាសនិកជាដើម) ទាំងអ្នកដែលជឿស្តាប់ បានរៀនសូត្រប្រតិបត្តិកាន់តាម ឲ្យកើតផលប្រយោជន៍ បានជួបប្រទះសេចក្តីសុខចំរើនតាមជាន់តាមថ្នាក់ ដោយសារសាសនាឬគម្ពីរក្បួនច្បាប់គម្រោងគម្រាដ៏ល្អបរិសុទ្ធត្រឹមត្រូវនោះ ហើយជាអ្នកដឹងគុណ បានតបឧបការគុណតាមដំណើរដែលគួរគេ, អ្នកទាំងនោះឈ្មោះថា កតញ្ញូ កតវេទី ។ គ្រូអាចារ្យហៅថា

បុព្វការី របស់សិស្ស ព្រោះជាអ្នកបង្ហាត់បង្រៀនសិស្សឲ្យមានចំណេះវិជ្ជា; សិស្សដែលដឹងគុណហើយតបគុណគ្រូអាចារ្យវិញ ហៅថា កតញ្ញូកតវេទី ។ ព្រះមហាក្សត្រជា បុព្វការី របស់ប្រជាជនក្នុងអាណាចក្រនៃព្រះអង្គ; ប្រជាជនណាជាអ្នកស្លូតត្រង់មានស្វាមីភក្តិគោរពចំពោះព្រះរាជារបស់ខ្លួន ហើយដឹងគុណ ដោយយល់ជាក់ថា ខ្លួនបានសេចក្ដីសុខចំរើនព្រោះការគ្រប់គ្រងផែនដីដែលមានព្រះមហាក្សត្រជាប្រមុខ ក៏ពេញចិត្តព្រមប្រព្រឹត្តតាមគន្លងច្បាប់សម្រាប់ផែនដី, ប្រជាជននោះឈ្មោះថា កតញ្ញូ កតវេទី ។

សូមអធិប្បាយដោយសង្ខេប:

## អំពីមាតាបិតានិងបុត្រធីតា

ក្នុងសកលលោក, បើរាប់តែចំនួនមនុស្ស, មានមាតាបិតានិងបុត្របុរសស្ត្រីច្រើនជាអនេក មិនមែនក្រទេ ព្រោះមនុស្សក្នុងលោកដែលកើតតៗគ្នាមកនោះមានច្រើនណាស់, ដែលថា កម្រមាននោះគឺ មិនសូវមានមាតាបិតានិងបុត្រធីតាដែលចេះទំនុកបំរុងសង្គ្រោះគ្នាឲ្យបានត្រឹមត្រូវតាមបែបបទ, ច្រើនតែលើសៗខ្វះៗ ត្រូវត្រង់ណោះខុសត្រង់ណោះ, បានត្រង់ណេះខ្វះត្រង់ណោះ មិនសព្វគ្រប់, ព្រោះហេតុនោះបានជាថា

កម្រមានក្នុងលោក ។ ឯបែបបទដែលមាតាបិតាត្រូវទំនុកបំរុងបុត្រធីតា នោះមាន ៤ យ៉ាងគឺ:

១ – ចិញ្ចឹមបីបាច់រក្សាកូនដោយប្រពៃ មិនទំរើសកូនឲ្យធំចិត្ត ឲ្យឡើងចាង, កាលណាឃើញកូនធ្វើអំពើអាក្រក់ ប្រញាប់ប្រញាល់ហាត់ហាមយ៉ាងម៉ឺងម៉ាត់ មិនបណ្តែតបណ្តោយ, ប្រាប់ប្រដៅឲ្យស្គាល់ទោសទុច្ចរិតដោយជាក់ស្តែង ឲ្យកូនខ្លាចរអាកងចាលរួញចិត្តគំនិតលែងហ៊ានប្រព្រឹត្តធ្វើអំពើអាក្រក់នោះតទៅទៀត ។

២– ប្រៀនប្រដៅកូនឲ្យរៀនកាន់សុចរិតប្រព្រឹត្តល្អតាមគន្លងធម៌ច្បាប់, ប្រាប់ពន្យល់អំពីផលសុចរិតដោយច្បាស់លាស់ ឲ្យកូនជឿស្តាប់សិប់គំនិតពេញចិត្តស្រឡាញ់ផ្លូវត្រូវផ្លូវល្អ, បង្វឹកកូនឲ្យថ្នឹកសិប់ស៊ាំក្នុងផ្លូវសុចរិត តាំងពីតូចមក ។

៣– ប្រដៅកូនឲ្យថ្នឹកក្នុងការចេះដឹង គឺបង្វឹកកូនឲ្យរៀនរាប់, ឲ្យរៀនគិត, រៀនបូក, រៀនចែក, រៀនសង, រៀនវាល់, រៀនថ្លឹង, រៀនវាស់, រៀនគ្នេរ, រៀនស្ទង់ស្មានការជាដើម ឲ្យថ្នឹកតាំងពីតូចមក មិនបណ្តែតបណ្តោយឲ្យកូនអាស់តាំងគំនិតប្រាជ្ញាក្នុងការចេះដឹង; លុះដល់កូនមានអាយុចំរើនធំល្មមឲ្យរៀនចំណេះវិជ្ជាហើយ បានទំនុកបំរុងឲ្យកូនរៀនអក្សរសាស្ត្រនិងវិជ្ជាផ្សេងៗតាមគួរដល់កាលៈទេសៈនិងសម័យនិយម

មិនបណ្តោយឲ្យកូនល្ងង់ខ្លៅ (កូនទាំងប្រុសទាំងស្រីត្រូវឲ្យរៀនអក្សរជាមុន រួចសឹមឲ្យរៀនចំណេះវិជ្ជាឯទៀតៗតទៅ) ។

៤ – ត្រូវរៀបចំកូនឲ្យបានផ្ទះសំបែង តាមសមគួរដល់ពូជវង្សជាតិត្រកូលទីងទ្រព្យធនជាដើម, ត្រូវប្រយ័ត្នកុំបាត់ការរៀបចំឲ្យហួសហេតុហួសទំនង, បើខ្លួនក្រកុំយកតម្រាប់អ្នកមាន កុំប្រណាំងប្រជែងនឹងអ្នកមានទ្រព្យ, ប្រយ័ត្នកុំឲ្យដាច់បង់ទ្រព្យធនទាល់តែដល់ថ្នាក់លក់ដីបញ្ចាំកេរ្តិ៍ ឬចំពាក់បំណុលគេរុំកោះត្រាំត្រែងយូរ, ត្រូវរៀបចំកូនឲ្យសមល្មមដល់ការគួរ កុំឲ្យហួសទំនង ។

៥ – ត្រូវលៃលកចំណាយប្រាក់ឲ្យកូនរៀនចំណេះវិជ្ជា, ត្រូវទិញគ្រឿងប្រដាប់ឲ្យកូនប្រើប្រាស់តាក់តែងខ្លួនខ្លះ, ឲ្យកូនមានសម្លៀកបំពាក់គ្រប់គ្រាន់, ឲ្យប្រាក់កាសចាយវាយខ្លះ មិនកំបុតកំបួញហួសប្រមាណ; ក្នុងវេលាដែលចែកទ្រព្យសម្រាប់ឲ្យ ត្រូវចែកឲ្យហើយស្រេច ឲ្យត្រឹមត្រូវតាមលក្ខណៈច្បាប់, កុំទុកឱកាសឲ្យកូនឈ្លោះប្រកែកដណ្តើមរើមគ្នាជាខាងក្រោយ ។

បែបបទដែលបុត្រធីតាត្រូវគោរពត្រូវទំនុកបំរុងមាតាបិតាវិញមាន ៥ យ៉ាងគឺ:

១ – ចិញ្ចឹមរក្សាមាតាបិតាដោយពេញលេញឲ្យដូចកាលមាតាបិតាចិញ្ចឹមរក្សាខ្លួន, ឬបើបានលើសជាងនោះទៅទៀតក៏រឹតតែប្រសើរណាស់ ។

២ – ធ្វើកិច្ចការជំនួសមាតាបិតា, មិនគោរពតែយសោះអង្គុយបណ្តែតបណ្តោយឲ្យមាតាបិតាទៀតហត់ចាល់ចាស់; ទោះបីខ្លួនមានស្វាមីភរិយាបែកមុខការរបរពេញឃ្លាតពីមាតាបិតាហើយ ក៏ត្រូវតែជួយធ្វើកិច្ចការរបស់មាតាបិតាតាមកាលវេលាម្តងៗ ដែលគួរនឹងខានពុំបាន ។

៣ – តាំងវង្សត្រកូលល្អរបស់មាតាបិតាឲ្យគង់នៅ គឺមិនបំបាត់សណ្តាប់ធ្នាប់ល្អរបស់មាតាបិតាឲ្យវិនាស, មិនប្រព្រឹត្តល្មើសរំលងទំនៀមល្អរបស់មាតាបិតា, មិនធ្វើឲ្យអ្នកមានគុណកើតទុក្ខព្រួយចិត្តព្រោះខ្លួន ។

៤ – គោរពប្រតិបត្តិឲ្យល្មមមាតាបិតាពេញចិត្តឲ្យទ្រព្យសម្បត្តិកេរ្តិ៍សម្រាប់, ប្រយ័ត្នរក្សាទ្រព្យសម្បត្តិកេរ្តិ៍អាករដែលមាតាបិតាចែកឲ្យ មិនបំផ្លាញឲ្យវិនាសអសារឥតការ ។

៥ – លុះឥតអំពីមាតាបិតាទៅ, បានលើកសពសំស្ការដោយគោរព, បានធ្វើទក្ខិណានុប្បទានឧទ្ទិសផលបុណ្យជូនរឿយៗ ។

មាតាបិតានឹងបុត្រធីតាដែលបានបំពេញកិច្ចរបស់ខ្លួនតាមបែបបទដូចសំដែងមកនេះ ទើបពេញជាបុគ្គលកតញ្ញូ កតវេទី ត្រឹមត្រូវ;

ប៉ុន្តែច្រើនតែមិនសូវបានប្រតិបត្តិគ្រប់គ្រាន់, បានត្រង់ណោះខ្លះត្រង់ណោះ ព្រោះហេតុនោះបានជាព្រះបរមសាស្តាទ្រង់ត្រាស់សំដែងប្រាប់ថាកម្រមានក្នុងលោក ។

លំដាប់តពីនេះទៅ សូមអធិប្បាយដោយសង្ខេបខ្លីៗជាងខាងលើ បន្ទាន់តាមវេលាខ្លី ព្រោះវិទ្យុបើកឲ្យការផ្សាយត្រឹមតែ ១៥ នាទី ។

## អំពីសាស្តានិងសាសនិកជន

សាស្តាអស្ចារ្យដែលហៅថាអច្ឆរិយមនុស្សឬអស្ចារ្យមនុស្សដូចយ៉ាងព្រះសព្វញ្ញូសម្មាសម្ពុទ្ធ មិនមែនមានគ្រប់កាលសម័យទេ យូរៗមានម្តង, ព្រោះហេតុនោះបានជាថាកម្រមានក្នុងលោក ។ ព្រះសក្យមុនីសម្ពុទ្ធជាបរមគ្រូដើមរបស់យើង ទ្រង់មានព្រះទ័យពេញព្រៀបដោយសេចក្តីអាណិត ទ្រង់ចង់ឲ្យសត្វលោករួចរំដោះចាកទុក្ខ; កាលព្រះអង្គជិតចូលបរិនិព្វាន ទ្រង់ខំប្រឹងផ្ទៀតប្រដៅទុកជាផ្តាំថា "អ្នកទាំងឡាយចូរកុំប្រហែសធ្វេស!"; ដោយហេតុនេះ យើងជាពុទ្ធបរិស័ទ គួរប្រតិបត្តិកាន់តាមលំអានធម៌វិន័យពុទ្ធសាសនាដែលជាផ្លូវនាំឲ្យយើងបានប្រទះសេចក្តីសុខស្ងប់ព្រមទាំងសេចក្តីចំរើន, យើងនឹងបានឈ្មោះថា កតញ្ញូ កតវេទី ចំពោះព្រះអង្គ ។

## អំពីគ្រូអាចារ្យនិងសិស្ស

កុំបាច់និយាយដល់គ្រូអាចារ្យដែលបង្ហាត់បង្រៀនប្រៀនប្រដៅពិត ៗ, សូម្បីតែលោកអ្នកឯណាក៏ដោយកំពុងប្រៀនប្រដៅសិស្សឬប្រៀនប្រដៅកូនចៅចំពោះផ្លូវធម៌និងច្បាប់ដ៏ត្រឹមត្រូវដែលជាពាក្យមានប្រយោជន៍គួររៀនគួរស្តាប់, យើងបានស្តាប់ពាក្យនោះចាំបានហើយយកមកត្រិះរិះប្រតិបត្តិតាមទៅ កើតសេចក្តីសុខចំរើន, លោកអ្នកនោះក៏ឈ្មោះថា បុព្វការី របស់យើងដែរ, យើងត្រូវដឹងគុណហើយតបគុណកុំបំភ្លេចឲ្យសោះ យើងឈ្មោះថា កតញ្ញូ កតវេទី ។

## អំពីមហាក្សត្រនិងប្រជាជន

ព្រះមហាក្សត្រដែលទ្រង់គ្រប់គ្រងប្រទេសនីមួយ ៗ ព្រះអង្គជាព្រះសម្មតិទេព "ទេពតាដោយសន្មត", ទ្រង់ព្រះនាមថា "ព្រះរាជា" ព្រោះទ្រង់ប្រកបដោយការសង្គ្រោះប្រជាជនដោយសង្គហវត្ថុ ៤ យ៉ាងគឺ ១ – ប្រទានទេយ្យវត្ថុ; ២ – មានព្រះវាចាគួរឲ្យចង់ស្តាប់; ៣ – ទ្រង់ប្រព្រឹត្តអំពើជាប្រយោជន៍; ៤ – ទ្រង់តាំងព្រះអង្គស្មើ ៗ គឺប្រើប្រុកតាឲ្យល្មមពេញចិត្តប្រជាជន ។ ទ្រង់តម្រង់ប្រជាជនដោយទសពិធរាជធម៌ "ធម៌សម្រាប់ព្រះរាជាមាន ១០ យ៉ាង" គឺ ១ – អំណោយទាន; ២ – រក្សា

សីល ៥ ជានិច្ច; ៣– បំណាយព្រះរាជទ្រព្យទំនុកបំរុងប្រទេស; ៤– មានសេចក្ដីទៀងត្រង់; ៥ ទន់ភ្លន់សុភាព; ៦– រក្សាឧបោសថសីលតាមកាលកំណត់មួយ ៗ; ៧– មិនកំហែងគ្រហាយប្រជាជន; ៨– មិនបៀតបៀនអ្នកដទៃ; ៩ មានសេចក្ដីអត់ធន់; ១០– មិនបំពានលើធម៌លើច្បាប់ ។ ដោយហេតុនេះទើបទ្រង់ព្រះនាមថា បុត្តការី របស់ប្រជាជន ។ ប្រជាជនដែលបានសេចក្ដីសុខដោយសារការគ្រប់គ្រងរបស់ព្រះរាជានោះហើយ ជាអ្នកដឹងឧបការគុណ ក៏តាំងចិត្តស្មោះត្រង់ចំពោះរាជការផែនដី, ជួយយកអាសាការផែនដីដោយស្មោះស្ម័គ្រ មានស្វាមីភក្ដិចំពោះព្រះរាជា ចំពោះរាជការផែនដី ឥតមានរឹងទទឹងឲ្យខាតផ្លូវរាជការ, យ៉ាងនេះហៅថា កតញ្ញូ កតវេទី ចំពោះព្រះរាជាជាម្ចាស់ជីវិតរបស់ខ្លួន ។

សំដែងអំពីបុត្តការីនិងកតញ្ញូ កតវេទី ដោយសង្ខេបតាមគួរដល់វេលាខ្លី, សន្មតថាចប់ត្រឹមប៉ុណ្ណេះ ។

សុខសួស្ដីសិរីវឌ្ឍិភាពចូរមានដល់អស់លោកអ្នកស្ដាប់!

ព្រះពុទ្ធឃោសាចារ្យ ជំ. ណា.

# អភិធម៌ភាសិត

## ភាគទី ១

### លោកគ្រូអាចារ្យ អ៊ុក-ជា ក្រុមជំនុំប្រែព្រះត្រៃបិដក

ជាអ្នកតែងនិងរៀបរៀង

# នមស្សការ

សុសារថោ មហិទ្ធិកោ មហាតេជី
សុធានច- ក្កលក្ខណី វរហារី វរន្ធនា;
សុសីលសេ- ដ្ឋលោកជេ- ដ្ឋគោរវា
កិលេសលោ- ភទោសមា- នមោហកា វិមុត្តិកោ.
អនន្តតា- រសេដ្ឋញ្ញា- ណសំយុត្តោ
អនេកបុ- ញ្ញសុដ្ឋកេ អសាធិសោ ជិតត្តយេ;
សរីតិលា- សម្ពុណ្ណតា- ឧបដ្ឋជេ
គុណាធិក- ស្ស តស្ស ឋ ធមាធិ :ច- តសា សនា.
តិលោកជេ- ដ្ឋកោបសេ- ដ្ឋគាត្យា
អនោមសិ- ទ្ធិ កិត្តិមា កិលេសុឃា- តិៈយោ ពុរំ;
កាវាធិប- ស្ស សារធ- ស្សឿនោត្តមំ
ធមាមិ ស- ដ្ឋុ តស្ស រំ- សិថាទបំ- សុមោធមិ.

ព្រះបមវិជិត កបរូបកបបុទ្ធិ ស្វែងរកសីលា
លះបង់លោភៈ ទោសៈ មោហា មានៈមុស្សា ត្រៀនហ្មងបងសត្វ;
ត្រៃលោកគត្តី បង់ពីងបារមី នៃព្រះពុទ្ធរ័ត្ន
យើងខ្ញុំអភិ- វន្ទ័យលើកហត្ថ បង្គំប្រតិបត្តិ បាទបង្សុព្រះអង្គ.
អង្គណាសម្ពុទ្ធ កបញាណវិសុទ្ធ នាំសត្វកាត់ត្រង់
ឆ្លងត្រើយសាគរ បើកបរកម្រង់ និព្វានភិរម- ន្ទលគាប់សុខា;

យើងខ្ញុំជាជាន់ កើតក្រោយពុំទាន់ ព្រះបរមសាស្តា
ទាន់តែបញ្ញត្តិ ដែលតាត់ទេសនា ទុកឲ្យអស់មហា- ជនក្រោយត្រង់ត្រាប់.
ព្រះធម៌សែនគ- ម្ភីរភាពសុខុម យើងខ្ញុំអ្នកស្តាប់
យោគយកមិនផល់ប្រាជ្ញខ្វល់ខ្វាល់សព្ទពាក្យស្តែងឯងស្តាប់តាប់យកពុំបាន;
អត្ថប្រែកែខ យោគយកតាមន័យ ដំណើរនិទាន
បរមត្ថសុខុម ត្រិះពុំយល់ដាន ព្រោះប្រាជ្ញញាណ កើតចុងសាសនា.
ពាក្យឆ័ន្ទកាព្យឃ្លោង ប្រាជ្ញប្រែយោគយោង ខុសពុទ្ធដីកា
គណៈឃ្លាឃ្លៀង លំអៀងសាព ចំណែកការ កត់ត្រាពុំត្រូវ;
ស្តាយណាស់ស្តាយជាតិ កើតក្នុងពុទ្ធបាទ មកប្រែជាខ្លៅ
អត្ថបញ្ញត្តិ សូន្យបាត់អស់ទៅ ទីនិរទ្យត្រូវ ឥតផ្លូវយាត្រា.
ប្រាជ្ញព្រេងតែងប្រែ ប្រាជ្ញក្រោយមកកែ ឲ្យខុសដីកា
គេនឹងកើតជាន់ក្រោយ ត្រូវសិក្សា តែក្បួនសាស្ត្រា អត្ថវិបត្តិ;
ធម៌អាថ៌បាលី សារៈវិជ្ជា ភាពខ្ពស់ខុសខាត
បទរើសរើសខ្លាត ខុចបាទបញ្ញត្តិ ព្រោះខ្លៅមកពាត់ វិបត្តិអន្តរាយ.

# អភិធរភាសិត

ភូបាលោ បណ្ឌិតោ និច្ចំ នេវ តុល្យា កុទាចនំ
សទេសេ បូជិតោ រាជា ពុទ្ធោ សព្វត្ថ បូជិតោ.

ស្តេចនឹងបណ្ឌិត ធ្លឹមគ្នានៅនិត្យ គ្រប់កាលមិនបាន
ព្រោះស្តេចមានមនុស្ស បូជាកប់អាន តែក្នុងទីស្ថានរបស់ទ្រង់ណា ;
ឯអ្នកប្រាជ្ញ មានមនុស្សកោតខ្លាច គោរពបូជា
គ្រប់ទីតំបន់ មិនថាស្ថានណា សឹងស្ងើមគ្រប់គ្នា ដោយការបេះដូង.

"បាក - ធម្មនីតិ - រាជនីតិ"

បណ្ឌិតេ ច គុណា សព្វេ មូឡ្ហេ ទោសា ហិ កេវលំ
តស្មា មូឡ្ហសហស្សេសុ វិញ្ញូ ឯកោ វិសេសិតេ.

គុណគ្រប់យ៉ាងមានតែក្នុងបណ្ឌិត មនុស្សល្ងង់ខ្លៅនឹងគមានតែទោសពៃរ៍
ដូច្នោះប្រាជ្ញម្នាក់វិសេសថ្លាថ្លៃ ជាងពាលចៃ្រល្ងង់ខ្លៅតាំងពាន់.

កឹ កុលេន វិសាលេន គុណហីនោ តុ យោ នរោ
អកុលីនោបិ សត្ថញ្ញោ ទេវតាបិ ច បូជយេ.

មនុស្សប្រាសចាកគុណ ទុកជាមានបុណ្យ ត្រកូលខ្ពស់ធំ
ក៏គ្មានប្រយោជន៍ ដល់អ្នកសេពសម គ្រាន់តែខ្ពស់ធំ ធំមិនឧត្តម ;
អ្នកត្រកូលទាបថោក តែស្ទាត់ផ្លូវលោក សិល្បសាស្ត្រគម
បេះដូងសត្វគ្រប់ ចំណោះតូចធំ ទេពតាឥន្ទ្រព្រហ្ម គង់បូជាដែរ.

តារកនំ ភូសនំ ចន្ទោ នារីនំ ភូសនំ បតិ
បថព្យា ភូសនំ រាជា វិជ្ជា សព្វស្ស ភូសនំ.

ព្រះចន្ទជាទីលំអពួកផ្កាយ ស្វាមីកើតឆាយនៃពួកនារី
ស្តេចជាលំអរបស់ប្រឹថពី វិជ្ជាជាទីលំអសព្វមនុស្ស.

" ចាក - ចាណក្យសតកម្ម "

វរមេកោ គុណីបុត្តោ ន ច មូឡ្ហសតម្បិ ច
ឯកោ ចន្ទោ តមោ ហន្តិ ន ច តារាគណោបិ ច.

កូនគបគុណម្នាក់ប្រសើរថ្លៃថ្លា ល្ងង់រយនាក់ណាមិនប្រសើរខ្ពស់
ព្រះចន្ទមួយកំចាត់ងងឹតបាត់អស់ ពួកផ្កាយច្រើនខ្ពស់កំចាត់មិនបាន.

" ចាក - ចាណក្យសតកម្ម "

លាលយេ បញ្ចវស្សានិ ទសវស្សានិ តាឡយេ
បត្តេ តុ សោឡសេ វស្សេ បុត្តំ មិត្តមិវាចរេ.

ត្រូវថ្នមកូនអាយុប្រាំវស្សា ត្រូវវាយជេរថា ទៅត្រឹមដប់ឆ្នាំ
ដល់អាយុដប់-ប្រាំមួយខួបចាំ ពាក្យអ្នកប្រាជ្ញផ្តាំថាកូនជាមិត្រ.

" ចាក - ចាណក្យសតកម្ម "

លាលនេ ពហវោ ទោសា តាឡនេ ពហវោ គុណា
តស្មា បុត្តញ្ច សិស្សញ្ច តាឡយេ ន តុ លាលយេ.

*ថ្នមឲ្យឡើងតាំងទោសច្រើនប្រការ វាយល្មមកំបាលមានគុណអនេក*
*ដូច្នោះកុំថ្នមកូនទាំងសិស្សពេក ត្រូវវាយដំផ្ដុកផ្ដួលពត់ឲ្យហើយ.*

ឯកេនាបិ សុរុក្ខេន បុប្ផិតេន សុគន្ធិនា
វាសិតស្ស វនំ សព្វំ សុបុត្តេន កុលំ យថា.

*ឈើល្អផ្កាក្រអូបស្អូមមួយដើម អាចស្រង់ក្លិនផ្សើមល្ហួយល្ហប់សព្វព្រៃ*
*ដូចត្រកូលដែលមានកូនប្រពៃ បានជាសិរីនៃវង្សញាតិផៅ.*

“ បាក - ពណាក្យសតកម្ម ”

ឯកស្សាបិ កុរុក្ខស្ស កោដរគ្គេន ឈាយិតា
ឌយ្ហតេ ហិ វនំ សព្វំ កុបុត្តេន កុលំ យថា.

*ដើមឈើពុកមានព្រង់ជាពូជភ្លើង កាលបើឆាបឆេះឡើងក្នុងកាលណា*
*អាចបណ្ដាលឆេះសព្វព្រៃព្រឹក្សា ដូចវង្សមានបុត្រាអាក្រក់ដែរ.*

ទូរតោ សោភតេ មូឡ្ហោ លម្ពមានបដាវុតោ
តាវ ច សោភតេ មូឡ្ហោ យាវ កិញ្ចិ ន ភាសតេ.

មនុស្សល្ងង់តែងខ្លួន បិទបាំងបំពួន ដោយសំពត់ស្បៃ
មើលពីចម្ងាយ សមល្អប្រពៃ ដោយសារអាស្រ័យ សំពត់ការពារនោះ;
បើមិនពោលហា មាត់ស្តីត្រឹមណា ក៏ល្អត្រឹមនោះ
លុះកាលណាហា មាត់ស្តីក៏ដុះ ឲ្យឃើញដល់គ្រោះ អាក្រក់ល្ងង់ខ្លៅ.

វិសារទប្បមត្តំ តាវ- បរេឍ្យានបិ កោញ្ចិ
គិ ចានបុត្តមំ វិដ្ឋិ ជីវក្ខំ ឧត្តុលានបិ.

ទឹកវិញទោះនៅ ក្នុងថ្នាំពិសក្តៅ គួរយកកុំខាន
មាសទោះនៅក្នុង ទីស្មោកគ្រោកស្អាន គួរយកឲ្យបាន កុំខានឡើយណា;
វិជ្ជាឧត្តម ទោះភ្ជាក់នៅចំ មនុស្សទាបសក្តិ
គួររៀនគ្រប់ចប់ ស្រីត្នុកជា វង្សទាបយ៉ាងណា ក៏គួរចិញ្ចឹម.

ជានេយ្យ បេសនេ ភិច្ចំ ពន្ធុំ ច ព្យសនាគមេ
មិត្តញ្ញាបទិ កាលេ ច ភរិយញ្ច វិភវក្ខយេ.

ចង់ដឹងខ្ញុំឲ្យមើលពេលធ្វើការ ចង់ដឹងវង្សក្នុងកាលដែលទាល់ទុក្ខ
ចង់ដឹងមិត្រក្នុងកាលភ័យមកដុក ចង់ដឹងប្រពន្ធកាលទុក្ខអស់សម្បត្តិ.

ទុព្ពលារក្ខំ បរេន សព្វានា សត្តុមុទ្ទំ
ទានលក្ខំ ការដ្ឋេន កណ្ហាកោដេ កណ្ហាកាំ.

ត្រូវកំចាត់សត្រូវដោយសត្រូវ ដោយឲ្យទ្រព្យត្រូវផលចិត្ត

ដូចបន្លាដែលមុតក្នុងបាត យកបន្លាដូចគ្នាដោះទើបបាន.

ន កោចិ កស្សចិ មិត្តោ ន កោចិ កស្សចិ រិបុ

ការណេន ហិ ជាយន្តិ មិត្តា ចាបិ រិបុ តថា.

នៅស្ងៀមព្រងើយ គ្មានអ្នកណាឡើយ ជាមិត្រអ្នកណា

អ្នកជាសត្រូវ ក៏គ្មានដូចគ្នា ដឹងមិនបានថា អ្នកណាដូចម្តេច;

កាលណាបើមាន ហេតុកើតឡើងបាន ទើបដឹងម៉េចៗ

អ្នកណាជាមិត្រ មានលេហកុលកិច្ច អ្នកណាសម្រេច ជាគូសត្រូវ.

នោ ន្នា នុ ន្នោ ន ន នុ នោ ន ន នុ ន្នុ ន នុ នុ ន្នោ

ន នុ ន ន្នោ ន នុ ន្នោ ន ន នេ នោ នុ ន នូ ន ន.

អ្នកដែលឈ្នះមនុស្សដោតចយមិនបានរៀបរយ ឈ្មោះថាឈ្នះល្អឡើយណា

ឈ្នះមនុស្សកំឡាំងច្រើនសោះសាទើបបានឈ្មោះថាជាប្រុសពិសេសថ្លៃថ្លៃ;

ខ្ញុំដែលម្ចាស់ឈ្នះនោះនៃឈ្នះមិនប្រពៃមិនបានឈ្មោះថាឈ្នះល្អ.

អ្នកបៀតបៀនមនុស្សស្រស្លូ មិនឈ្មោះថាល្អ ទុកជាអាក្រក់ពេកក្រៃ.

“ បាក - ភគីតិ ”

អនាយកា វិនស្សន្តិ នស្សន្តិ ពហុនាយកា
ថីនាយកា វិនស្សន្តិ នស្សន្តិ សុសុនាយកា.

ផងមិនមាននាយកក៏វិនាស នាយកច្រើនពេកវិនាសដូចគ្នា
ស្រីអាក្រក់ជានាយកខូចអាសា កំឡោះយង់ឃ្នងជានាយកវិនាស.

"ចាក - រាជនីតិ - ធម្មនីតិ"

កោត្ថោ បុត្តេន ជាតេន យោ ន វិទ្វា ន ធម្មិកោ
កាណេន ចក្ខុនា កឹ វា ចក្ខុបីឡាវ កេវលំ.

កូនគ្មានវិជ្ជាមិនដឹងច្បាប់ កូនណោះដូចស្លាប់ឥតប្រយោជន៍
ដូចភ្នែកដែលខ្វាក់ខ្លួនរោះសោះ នាំឲ្យចាំនូវរោគឈឺតែម្យ៉ាង.

"ចាក - ចាណក្យសតកម្ពុ"

អជាតមតមូឡ្ហានំ វរមាទោ ន ចន្តិមោ
សកឹ ទុក្ខករា អាទោ អន្តិមោ តុ បទេ បទេ.

កូនមានបីពួកតាមកំណើត មួយមិនទាន់កើតកូនមួយក្ស័យ
កូនពីរនេះនោះឲ្យទុក្ខភ័យ ក៏តែសម័យម្ដងមួយគ្រា.
ទីបីនោះគឺកូនល្ងង់ខ្លៅ កូននេះនោះនៅពេកណាស់សា
ក៏ឲ្យទុក្ខទោសកល់រាល់គ្រា ឲ្យឈឺទៅទាល់ជំហាន.

"ចាក - កថាកុសុមមញ្ជរី"

(មានត)

(ភទក)

វគ្គទី ៤

# អំពីភោគៈប្រជាជនជាតិខេមរ

ជ័យជំនះផ្សេងៗរបស់ក្រុងខេមរ ជាហេតុផ្លាស់ប្រែសភាពក្រុងខេមរឲ្យខុសប្លែកទៅជាច្រើន តាំងខាងរបៀបចំនៀមទម្លាប់ព្រមទាំងរបៀបគ្រប់គ្រងស្រុកទេស ។ ពួកមន្ត្រីទីពួកអ្នកមានត្រកូលក៏កាន់តែមានសម្បត្តិស្តុកស្តម្ភឡើងជានិច្ច តែប្រជាជនធម្មតាបែរជាក្រីក្រចុះទៅជានិច្ច គឺថាក្រុងខេមរមកដល់សម័យនេះ មានមនុស្សតែ២ជាន់ គឺពួកអ្នកមានទីពួកអ្នកទីទ័លក្រ ឯជនជាន់កណ្តាល ស្ទើរតែគ្មានឡើយ ។ ក្រុងខេមរធ្វើសង្គ្រាមតែរៀងរាល់ឆ្នាំ ស្ទើរតែមិនមានខានឆ្នាំណាឡើយ សង្គ្រាមនេះបានបំផ្លាញជីវិតប្រជាជនអស់ទៅដល់ ៣ ភាគក្នុង ៨ ភាគក្នុង ១ ឆ្នាំៗ ជួនកាលត្រូវទៅធ្វើសង្គ្រាមក្នុងរយៈផ្លូវឆ្ងាយៗដែលពួកទាហានតោងបោះបង់គ្រួសារពេលជាយូរ ហើយថែមទាំងគ្រួសារនោះឯកាយខ្ចីបុលប្រាក់កាសគេ នាំឲ្យមានបំណុលឡើងជាច្រើន ។ តាមធម្មតា ប្រទេសខេមរដាំដំណាំ ហើយដំរៀងដាំដំណាំនៅរណៈនេះក៏កាន់តែចុះថោកទៅជាលំដាប់ ព្រោះពួកអ្នកមានតែងមានទីដីក្នុងម្នាក់ៗជាចំនួនច្រើន ហើយអាចប្រើខ្ញុំគំ-

ផលទៅធ្វើការដាំដំណាំ មិនបាច់ជួលឈ្នួលប្រើ ទើបអាចលក់ផលានុផលអស់នេះដោយដំរៃថ្លៃយ៉ាងថោកៗ ទាល់តែពួកជនជាន់កណ្ដាលលក់ដូរគេចំណេញពុំបាន ជាហេតុឲ្យមានបំណុលស្អេកស្កះក៏តោងតែចាត់ការលក់ទីដីរបស់ខ្លួនឲ្យទៅម្ចាស់បំណុលយ៉ាងថោកៗ ឬដល់ពួកជនតាំងប្រទេសដែលចូលមកនៅក្រុងរ៉ូម ។ តាមទំនងដែលពោលមកនេះ នាំឲ្យពួកជនជាន់កណ្ដាលគ្មានរបរធ្វើការជាចំនួនច្រើន កាលបើមិនមានដីធ្វើការកសិ ទើបត្រូវតែរត់ចូលជ្រកកោនពួកអ្នកមានសម្បត្តិ ទទួលធ្វើការបំរើគេឲ្យតែល្មមមានអាហារចំណីចំអែតពោះ ។ សេចក្ដីប្រកាន់ខ្លួនរវាងពួកជនជាន់អ្នកមានអ្នកក្រ ក៏កាន់តែមានក្រាស់ក្រែលឡើង ពួកអាមាត្យមន្ត្រីក្រុងរ៉ូម ក៏ព្យាយាមគិតគូរកែខៃ តែពួករដ្ឋបុរសត្រឡប់ទៅជាបែកខ្ញែកគ្នាជា ២ ចំណែក គឺ ១ ពួកមានក្រាកស៊ុស (Gracchus) ជាដើម ជាពួកព្យាយាមជួយអ្នកទីទ័លក្រ មានពួក ១ ទៀតជាពួកមន្ត្រីដែលមិនព្រមលះបង់សិទ្ធិរបស់ខ្លួន ហេតុនេះទើបមានការប្រណាំងប្រជែងដណ្ដើមធ្វើការឲ្យបានសម្រេចតាមបំណងតែរៀងខ្លួន មានទំនងដូចជាសម័យប៉ាទ្រីស្យាង នឹងពួកប្លេបេអ៊ីយ៉ាងក្នុងគ្រានោះ ។

ក្រាកស៊ុសមានបងប្អូនពីរនាក់ ម្នាក់ឈ្មោះទីបេរីយុស (Tibérius) ម្នាក់ទៀតឈ្មោះកៃយុស (Caius) ទាំងពីរនាក់បានសិក្សារៀនសូត្រមកម៉ាំមួន មានអធ្យាស្រ័យរួសរាយល្អ ទុកជាខ្លួនកើតក្នុងត្រកូលមន្ត្រី ក៏នៅ

តែមានមេត្រីចិត្ត អាណិតបណ្ដាជនឯម្នាទូទៅ ។ ទីបេរីយុសជាមនុស្ស ទៀងត្រង់យុត្តិធម៌ មិនមានចិត្តគិតឆបោកបញ្ឆោតពួករាស្ត្រ ឬជាអ្នកនាំបំបះបំបោរឲ្យរាស្ត្រចលាចលនឹងកផការក៏ទៅដែរ ហើយជាអ្នកទទួល-ទាន សំដីទន់ភ្លន់ពីរោះ អាចធ្វើឲ្យមនុស្សនៅក្រុងរោមទាំងមូលមានមេត្តាចិត្តដល់បណ្ដាជនអ្នកទីទ័លក្រ មិនមានរបររកស៊ីនឹងគេ នៅត្រង់វគ្គ ១ ក្នុងសុន្ទរកថារបស់ទីបេរីយុស មានសេចក្ដីថា "សូម្បីតែសត្វព្រៃក៏នៅតែមានលំនៅ ចុះបើទេះជាមនុស្សត្រម្យ៉ាំង ម្ដេចក៏នៅតែរកទីសម្រាប់កប់ខ្មោចខ្លួននឹងគ្រួសារខ្លួនពុំបាន មនុស្សទាំងឡាយតែងពោលសរសើរជនជាតិរ៉ូម៉ាំងថាជាម្ចាស់លោក តែនឹងរកដី ១ ដុំជារបស់ខ្លួនពុំបាន" ។ ក្នុងពុទ្ធសករាជ ៤០៩ (មុនគ.ស. ១៣៤) ទីបេរីយុសបានទទួលមុខក្រសួងជាតំណាងរាស្ត្រ បានព្យាយាមស្នើសុំឲ្យរដ្ឋបាលចេញច្បាប់បញ្ញត្តិ ១ ដើម្បីចែកទីដីដល់បណ្ដារាស្ត្រទាំងអស់ ។

តាមដោយពិត ការចេញច្បាប់នេះ គួរតែធ្វើបានស្រួលដោយងាយ ព្រោះក្រុងរោមមានអាណាខេត្តយ៉ាងធំទូលាយ ដែលវាយយកបានពីជនជាតិឯទៀតៗ ហើយធ្លាក់មកជាសម្បត្តិរបស់ផែនដី ប៉ុន្តែផែនដីអស់នេះ ពួកមន្ត្រីបានជួលផ្ដាច់មកពីរដ្ឋបាលជាយូរ ច្រើនតំណមនុស្សមកហើយ សម្រាប់ឲ្យពួកខ្ញុំកំដរធ្វើការដាំដំណាំ និងចិញ្ចឹមសត្វយកផលប្រយោជន៍ផ្ទាល់ខ្លួន ។ លុះតមកទៀត ពួកនេះតោងយកដីអស់នោះពីរដ្ឋបាល

ដែលឲ្យឈ្នួលដីទៅរដ្ឋបាល ។ ទឹកប្រាក់ចំណាយជំនួសពួកនេះ មិនហ៊ានស្ដីថា ប្ដូរនូវការយកពន្ធដី ហើយតមកដីអស់នេះក៏ទៅជាសម្បត្តិផ្ទាល់ខ្លួនទៅ អាចបែងចែកប្ដូរប្រគល់ឲ្យកូនចៅទទួលជាមរតកតមក ។ ឯទីបេរិយុស មិនបានតាំងចិត្តឲ្យរដ្ឋបាលបង្គាប់ឲ្យមន្ត្រីអស់នោះប្រគល់ដីរដ្ឋបាលវិញទេ ប៉ុន្តែបើទីនេះធ្វើដោយវិធីបង្គាប់បង្ខំគង់តែសម្រេចបានដែរ តែទីបេរិយុសត្រូវការរិះស្រួបស្រួម គឺសុំឲ្យរដ្ឋបាលសុំបែងដី ១ ភាគ ៗ ហើយឲ្យរដ្ឋបាលសងសោហ៊ុយបង់ទាតទៅម្ចាស់ដីវិញ ។ ដីដែលរដ្ឋបាលទារយកបាន ១ ដុំ ៗ នេះ គេនឹងយកមកបែងជាភាគតូច ៗ ហើយចែកចាយដល់អ្នកទីទល់ក្រ ១ គ្រួបន្តិច ៗ ។ ការដែលរៀបចំតាមទំនងនេះ ដោយមានគោលយោបល់ម្នាថា ពួកអ្នកធ្វើការដាំដំណាំអស់នោះ ទុកជាកំឡាំងយ៉ាងសំខាន់របស់ប្រទេស ព្រោះតាមធម្មតា មនុស្សដែលមានកងកាយខែងរឹងជាទាហានដ៏ក្លាហាន មានសីលធម៌ល្អមិនចេះបៀតបៀនគេនោះ ច្រើនតែជាពួកអ្នកធ្វើស្រែចម្ការដាំដំណាំអស់នេះ ទើបត្រូវតែរដ្ឋបាលជួយទំនុកបម្រុងជនពួកនេះ ។

ប៉ុន្តែច្បាប់នេះមិនទាន់ចេញប្រើឲ្យបានទាន់ក្ដីឃើញរបស់ទីបេរិយុសឡើយ ព្រោះពួកអ្នកមានពូជអំបូរខ្ពង់ខ្ពស់មានទ្រព្យធន ច្រើនទាំគ្នាពាក់ព័ន្ធរារាំងមិនឲ្យរដ្ឋបាលចេញច្បាប់នេះបាន ។ លុះដល់ពេលបោះឆ្នោត

សម្រេចពីច្បាប់នេះ ខាងពួកទីបេរិយុសក៏នៅតែឈ្នះ ពោលគឺដំណាង ក្រសួយល់ព្រមឲ្យចេញជាច្បាប់បាន តែក្នុងខណៈនោះឯង ពួកអ្នកមាន នាំគ្នាញុះញង់ប្រជាជនឲ្យជឿថា ទីបេរិយុសមានចិត្តលោភចង់តាំងខ្លួនជា មហាក្សត្រ ហេតុនេះហើយបានជាត្រូវគេលួចសម្លាប់ក្នុងទីប្រជុំដំណាង ក្រសួមុខគួរឲ្យអាណោចអាធម្មណាស់ កាលពីពុទ្ធសករាជ ៤១០ (មុន គ.ស. ១៣៣)។

កាលទីបេរិយុសត្រូវគេសម្លាប់ដោយខំព្យាយាមទំនុកបំរុងគេឲ្យបាន ស្រួលបានចំរើន តែត្រឡប់ទៅជាទោសដល់ស្លាប់ខ្លួន ដូចជាពាក្យ ថា "ធ្វើគុណបូជាទោស" ឬ ខ្លះ ។ លុះអំណើះតមកទៀតជាវេលា ១០ ឆ្នាំ ទើបកៃយុសជាប្អូន ដែលមានគុណសម្បត្តិទីងគំនិតគិតគូរដូចជាបងដែរ ក៏ខំប្រឹងប្រែងធ្វើតាមលំអានដែលបងខ្លួនបានផ្តើមធ្វើមកហើយ ទើបធ្វើការនេះបានសម្រេចខ្លះ ពោលគឺផ្តុបាលបានបែងទីដីដោយអន្ទេវចែក ប្រជាជនតាមសមគួរ ដូចជាស្រុកកាថាស៍ទីងកូរិន្ធជាដើម ។ អំពើ ដែលកៃយុសបានរៀបចំធ្វើមកនេះ រាប់ថាជាសេចក្តីល្អយ៉ាងក្រៃលែង តែ កៃយុសធ្វើល្អជ្រុលហួសពេកទៅ ពោលគឺជួយពួកឡាតាំងទាំងមូលឲ្យ បានទទួលសិទ្ធិស្មើភាគគ្នានឹងពួករ៉ូម៉ាំង ហើយដកអំណាចពួកសេណាត មិនឲ្យធ្វើជាតុលាការផង ហេតុនេះនាំឲ្យពួករ៉ូម៉ាំងស្អប់ខ្ពើមកៃយុស

យ៉ាងខ្លាំង ហើយត្រូវបណ្តេញឲ្យចេញទៅនៅស្រុកកាថាស៍ លុះត្រឡប់មកក្រុងរ៉ូមវិញ គឺមិនត្រូវរើសឲ្យធ្វើជាដំណាងរាស្ត្រទៀត ថែមទាំងពួកសេណាត៍ដែលធ្លាប់ស្អប់មកពីមុនស្រាប់ ក៏ប្រកាសថា កៃយុសជាមនុស្សនៅក្រៅច្បាប់ពេម ទើបកៃយុសគេចរត់ចេញពីក្រុងរ៉ូមទៅទៀត ហើយត្រូវពួនខ្លួនម្នាក់សម្ងាត់បង់ទៅ ។ ឯប្រជាជនដែលជាបក្សពួករបស់កៃ-យុសចំនួន ៣.០០០ នាក់ ក៏ត្រូវចាប់ខ្លួនយកទៅសម្លាប់អស់ដែរ កាលពីពុទ្ធសករាជ ៤២០ (មុនគ. ស. ១២៣) ។ កៃយុសបានទទួលសេចក្តីសោកសៅជាងដើម ហើយត្រឡប់ជាមានពាក្យដំរៀលយ៉ាងខ្លាំងមកចុងក្រោយ ។ ណោ កៃយុសអនិច្ចកម្ម...! គណៈសេណាត៍ដល់ជាហាមប្រាមម្តាយកៃយុសមិនឲ្យកាន់ទុក្ខកូន ។

(មានត)

# ភូមិសាស្ត្រសង្ខេបនៃនានាប្រទេស

## ភូមិសាស្ត្រប្រទេសអង់គ្លេស (តមកនឹងចប់)

**ព្រះក្រមធម្មរដ្ឋរបស់ស្រុក** — អំណាចទាំងពួងចេញមកអំពីប្រជាជនជាតិអង់គ្លេសទាំងពួង ព្រះមហាក្សត្រទ្រង់ប្រើអំណាចអធិបតី គឺអំណាចបញ្ញត្តច្បាប់, អំណាចរដ្ឋបាល និងអំណាចតុលាការ ទ្រង់ប្រើអំណាចបញ្ញត្តច្បាប់ ដោយសេចក្តីណែនាំនិងការយល់ព្រមនៃរដ្ឋសភា (ប៉ាលេម៉ង់) ទ្រង់ប្រើអំណាចរដ្ឋបាល ដោយសេចក្តីយល់ព្រមនៃគណៈរដ្ឋមន្ត្រី ទ្រង់ប្រើអំណាចតុលាការ ដោយសេចក្តីយល់ព្រមខាងសាលាតុលាការ ប៉ុន្តែដោយន័យនៃទំនៀមបញ្ញត្តិនោះ ព្រះមហាក្សត្រនៅទ្រង់មានព្រះរាជអំណាចដែលមានមកពីបុរាណកាល ឧ៍ទ្រង់បញ្ញត្តច្បាប់, តាំងរដ្ឋមន្ត្រី, ព្រះរាជទានយសស័ក្តិ ប្រកាសសង្គ្រាមដល់ប្រទេសដទៃ ៗ តែតាមធម្មតា ព្រះរាជាទ្រង់ជាបម្រើរបស់ប្រទេសជាតិ ដោយទ្រង់អនុញ្ញាតឲ្យច្បាប់ផ្សេងៗ ដែលរដ្ឋសភាស្នើឡើងមកនោះ ប្រកាសប្រើបានជាដរាបទៅ ហើយទ្រង់នឹងបណ្តាប់កិច្ចរាជការអ្វីដោយសេចក្តីណែនាំនៃនាយករដ្ឋមន្ត្រីអង់គ្លេស ។

រដ្ឋបាលអង់គ្លេសប្រកបដោយរដ្ឋសភា ២ គឺសភាជាន់ខ្ពស់និងសភាតំណាងរាស្ត្រ ។ ឯសមាជិកក្នុងសភាជាន់ខ្ពស់នោះបានដល់បុគ្គល ៤ ចំពួក គឺពួកអ្នកមានយសស័ក្តិខ្ពស់ដោយតំណតវង្សត្រកូលមក ១ អ្នកមាន

យសស័ក្តិដោយព្រះរាជាទ្រង់តាំងឡើង ១ អ្នកមានដំណែងខ្ពង់ខ្ពស់ក្នុង គុណការងារខាងសាសនា ១ អ្នកមានយសស័ក្តិខ្ពស់ខាងគោះអគ្គស្ស័រ ១៦ នាក់ ១ អ្នកមានយសស័ក្តិខ្ពស់ខាងគៀវឡៀរ៍ចំនួន ២៨ នាក់ ១ រួមទាំងអស់មានចំនួន ៧៤០ នាក់ សមាជិកអស់នេះនៅក្នុងដំណែងអស់ ១ ជីវិតដោយច្រើន ដែលណាចេញប្រែតែចេញពីដំណែងមានតិច ៗ ឯសមាជិកសភាដំណាងរាស្ត្រមានចំនួន ៦១៨ នាក់ ជាអ្នកដំណាងគោះអគ្គស្ស័រ ៧៤ នាក់ ជាអ្នកដំណាងរបស់គោះគៀវឡៀរ៍ខាងជើងចំនួន ១៣ នាក់ ក្រៅអំពីនេះជាអ្នកដំណាងអង់គ្លេសនឹងប៉េអ៊ីដឺកល្ ៗ កំណត់នៅក្នុងដំណែង៥ ឆ្នាំ គេតែងមានការរើសតាំងសមាជិកសភាដំណាងរាស្ត្រជាថ្មី ៗ

ឯបណ្ដារាស្ត្រមិនថាប្រុសស្រី ដែលមានអាយុ ២១ ឆ្នាំហើយមានគុណសម្បត្តិតាមច្បាប់ដែលនិយាយពីការរើសតាំង រមែងមានអំណាចបោះឆ្នោតរើសតាំង ឬស្ម័គ្រចិត្តជាអ្នកឲ្យគេបោះឆ្នោតរើសខ្លួនធ្វើជាដំណាងរាស្ត្រក៏បាន ៗ ចំនួនអ្នកដំណាងរាស្ត្រក្នុងអង់គ្លេសនឹងអគ្គស្ស័រកំណត់ថា ដំណាងរាស្ត្រម្នាក់ជាដំណាងនៃចំនួនមនុស្ស ៧០.០០០ នាក់ ៗ ឯក្នុងគៀវឡៀរ៍មានកំណត់សមាជិកម្នាក់ ជាដំណាងប្រជាជនចំនួន៤៣.០០០ នាក់ ក្រៅអំពីនេះនៅមានអ្នកដំណាងរាស្ត្ររបស់ក្រុមម៉ឺនខេត្តក្រៅ និងក្រុមម៉ឺនទីក្រុងនិងរបស់មហាវិទ្យាល័យទៀតផង ៗ

សភាជាន់ខ្ពស់របស់អង់គ្លេសមានមុខក្រសួងត្រឹមអនុញ្ញាតឬតវ៉ាទប់ទល់ដែលសភាជំណាន់ក្រោមស្នើឡើងមកប៉ុណ្ណោះ មុខក្រសួងម្យ៉ាងទៀត គឺការពិចារណាពិភាក្សារឿងក្ដីដែលគេបានធ្វើបុតហ្មាយថ្វាយដីកាដល់ព្រះមហាក្សត្រ ។

ឯសភាដែលមានអំណាចក្នុងការចេញច្បាប់ ការថែរក្សាប្រាក់កាសរបស់ប្រទេសនិងឃុំរក្សារដ្ឋបាលយ៉ាងពិតប្រាកដនោះ គឺសភាជំណាន់ក្រោម ។ ច្បាប់ដែលសភានេះស្នើឡើងទៅ សភាជាន់ខ្ពស់អាចមិនទទួលយល់ព្រម ហើយធ្វើត្រឡប់មកឲ្យកែខ្លះ ឬវិនិច្ឆ័យជាថ្មីវិញ ឬមិនទទួលយល់ព្រមក៏បាន ប៉ុន្តែបើសភាជំណាន់ក្រោមនៅតែរឹងតាមយោបល់ដើម ហើយបានស្នើច្បាប់នោះឡើងទៅដល់ ៣ ដងហើយ សភាជំណាន់ក្រោមមានអំណាចនាំច្បាប់នោះថ្វាយស្នើព្រះមហាក្សត្រ ដើម្បីឲ្យទ្រង់ព្រះរាជទានព្រះរាជានុម័តតែម្ដង ។ ឯព្រះមហាក្សត្រ តាមធម្មតា តែងទ្រង់អនុម័តជាដរាប ។ ខនេះសំដែងឲ្យឃើញថាសភាជំណាន់ក្រោមមានមុខក្រសួងនិងអំណាចសំខាន់ជាងសភាជាន់ខ្ពស់ និងសំដែងឲ្យឃើញថាព្រះមហាក្សត្រទ្រង់គ្រប់គ្រងប្រទេសតាមបំណងរបស់បណ្ដារាស្ត្រទូទៅ ។

ព្រះមហាក្សត្រទ្រង់ប្រើអំណាចត្រួតត្រាស្រុកដោយគណៈរដ្ឋមន្ត្រី ព្រះអង្គទ្រង់ចាត់តាំងនាយករដ្ឋមន្ត្រីដោយរើសយកមកពីសភាជំណាន់

ក្សត្រ ហើយនាយករដ្ឋមន្ត្រីរើសតាំងគណៈរដ្ឋមន្ត្រីចេញអំពីសភាទាំងពីរ តាមធម្មតា ច្រើនតែរើសយកមនុស្សក្នុងបក្សពួករបស់ខ្លួនដែលមានយោ-បល់យល់ត្រូវគ្នាក្នុងកិច្ចការស្រុកទេសរួមគ្នា ។ គណៈរដ្ឋមន្ត្រី មានមុខក្រសួងត្រួតត្រាស្រុកទេស បើនាយករដ្ឋមន្ត្រីលាចេញ គណៈរដ្ឋមន្ត្រីក៏ត្រូវលាចេញទាំងអស់គ្នា ហើយគេទៅជាមុខក្រសួងរបស់នាយករដ្ឋមន្ត្រីថ្មីនឹងរៀបចំតាំងគណៈរដ្ឋបាលថ្មីឡើង ។

ឯរបៀបដ៏សំខាន់នៃលទ្ធិរាជាធិបតេយ្យអំណាចនៅក្រោមច្បាប់ ព្រះមហាក្សត្រគ្រាន់តែជាអ្នកគ្រងរាជ្យ មិនមែនជាអ្នកគ្រប់គ្រងប្រទេសទេ ។ អ្នកគ្រប់គ្រងប្រទេសគឺគណៈរដ្ឋមន្ត្រី ហេតុនេះ បើរដ្ឋបាលធ្វើការខ្លាំងក្លានាំឲ្យខូចខាតដល់ប្រទេសជាតិ ទើបមិនមានអ្នកណាហ៊ានតិះដៀលឬធ្វើទោសដល់មហាក្សត្រឡើយ ព្រះក្រមធម្មរដ្ឋអង់គ្លេសបញ្ញត្តច្បាប់ថា គណៈរដ្ឋមន្ត្រីត្រូវទទួលខុស-ត្រូវផ្ទាល់ខ្លួនក្នុងកំហុសដែលខ្លួនធ្វើខុស ហើយទាំងទទួលខុស-ត្រូវជាមួយនឹងរដ្ឋមន្ត្រីឯទៀតរួមគ្នាផង រដ្ឋមន្ត្រីដែលត្រូវរដ្ឋសភាតិះដៀលឬមិនទុកចិត្ត ត្រូវតែលាចេញពីដំណែង បើកំហុសនោះធំសំខាន់ផង អាចត្រូវប្តឹងឲ្យតុលាការធ្វើទោសទៀតផង ។

**អៀរឡង់ខាងជើង** — ជាចំណែកមួយរបស់រាជអាណាចក្រអង់-គ្លេស ជាដែនដីនៅភាគខាងជើងរបស់កោះអៀរឡង់ ទិសខាងត្បូងទល់

ទីនប្រទេសឥស្សរជ្ជអៀរឡង់ ។ ទំហំដីប្រមាណ ១៣.៥៦១គីឡូ-ម៉ែត្រក្រឡា មានចំនួនមនុស្ស ១៣ លាននាក់ ស្រុកបេលហ្វាស្ដជាទីក្រុងធំជាទីប្រជុំកេងគម្បាញសំពត់លីនិននឹងធ្វើកប៉ាល់នានា សំពត់លីនិនដែលគម្បាញនៅទីស្រុកនេះច្រើនជាងស្រុកដទៃ ។ ទាំងអស់ក្នុងរាជ-អាណាចក្រអង់គ្លេស ។ អៀរឡង់ខាងជើងនេះមានរដ្ឋសភានិងរដ្ឋបាលញែកដាច់ពីប្រទេសអង់គ្លេស តែនៅត្រូវបញ្ជូនដំណាងរាស្ត្រ ១៣ នាក់ ទៅចូលប្រជុំក្នុងសភាដំណាងរាស្ត្ររបស់អង់គ្លេស ។

ចប់ភូមិសាស្ត្រសង្ខេបនៃប្រទេសអង់គ្លេសតែប៉ុណ្ណេះ ។

# ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

## ឆ្នាំគំរប់ ១៤ ភាគទី ១០

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៥

គ.ស. ១៩៤២

# សេចក្ដីជូនដំណឹង

ព្រះរាជបណ្ណាល័យសូមជូនដំណឹងដល់អស់លោក-អ្នកជាវទស្សនាវដ្ដីកម្ពុជសុរិយាទាំងឡាយៈ

ក្នុងសម័យឥឡូវនេះ អស់លោក-អ្នកគង់បានជ្រាបច្បាស់ហើយថា ទំនិញសព្វសារពើទាំងពួង សឹងឡើងថ្លៃជាអនេកគុណពីឆ្នាំមុនៗ មកច្រើនណាស់ ។ ឯក្រដាសសម្រាប់បោះពុម្ពសៀវភៅ និងគ្រឿងប្រដាប់កេនពុម្ពក៏ឡើងថ្លៃច្រើនណាស់ដែរ ថែមទាំងរកទិញបានដោយកម្រផង ហេតុនេះព្រះរាជបណ្ណាល័យនឹងចេញផ្សាយទស្សនាវដ្ដីកម្ពុជសុរិយា ក្នុងកំណត់ ១ ខែពីរដងនោះឃើញថាខាតទុនជាច្រើន ដោយចង់ខាតទៅលើក្របសៀវភៅ បញ្ជីរឿង និងរូបជាដើម ទើបសុំជូនដំណឹងថា ចាប់តាំងពីខែយុកំនឹងឆ្នាំ ១៩៥២ នេះជាដើមទៅ នឹងកែប្រែរបៀបចេញផ្សាយ ក្នុងកំណត់ ១ខែ ១ ដងវិញ ប៉ុន្តែចំនួនទំព័រនឹងសេចក្ដីផ្ទៃរឿង ប្រហែលក្នុង ១ ខែពីរក្បាលដដែល គឺថាយករឿងក្នុងពីរក្បាលមករួមគ្នាជាមួយក្បាលវិញ ឯលេខរៀងនឹងដាក់តាមលំដាប់លំដោយពីលេខមុនរៀងមកដរាបដល់ដាច់ឆ្នាំនេះ ។

ដូច្នេះ សូមចិត្តអស់លោក-អ្នកជាវទស្សនាវដ្ដីកម្ពុជសុរិយា កុំបីត្អូញត្អែរ ឬបន្ទោសថាអ្វីឡើយ ការចេញផ្សាយក្នុងកំណត់ ១ ខែ ១ ក្បាល ពិតមែនតែយឺតយូរបន្តិច ប៉ុន្តែវេលាបានមើលម្ដងៗ នាំឲ្យបានមើលសេចក្ដីវែងៗ ច្រើនៗ ជាប់ទាក់ទងគ្នាល្អស្ដាប់ជាងមើលសេចក្ដីខ្លីៗ ឆាប់អស់ មិនសាយបានចប់រឿងនិមួយៗនោះ ។

# បញ្ជីរឿង

ទំព័រ

១ — វិន័យធម្មទេសនា កណ្ឌទី ៤ ព្រះបាទឡាត់ឃោសនាគ ហ. ចៀវ អាចារ្យបង្រៀន
សាលាបាលីជាន់ខ្ពស់សំដែង ................ ៣

២ — លោកនេយ្យ ពាក្យកាព្យ របស់អ្នកឧកញ៉ាវង្សាសារពេជ្ញ (នង) (តមក) .. ១៣

៣ — អភិនវភាសិត ភាគទី ១ របស់លោកគ្រូអាចារ្យ អ៊ុក-ជា ក្រុមជំនុំព្រះត្រៃបិដក
(តមកនិងចប់) ..................... ១៦

៤ — ពង្សាវតារភូមា ស្រង់យកពីពោលពារិកផ្សេងៗក្នុងពង្សាវតារលោក (តមក) ២៥

៥ — ភូមិសាស្ត្រសង្ខេបនៃនានាប្រទេស: អំពីប្រទេសអារ៉ុប .......... ២៩

## រូបក្រៅរឿង

រូបព្រះពោធិសត្វអវលោកិតេស្វរៈ ថែបរបនាប្រាសាទបាយ័ន (ព. ស. ១៧៤៣) ១

# TABLE DES MATIÈRES


Pages

1. Vidyudesanā (Prédication faite à la Radio Phnôm-Penh), par le Vénérable Achar H. Chieu, Professeur à l'École supérieure de Pāli ........ 3

2. Lokaneyya, poème par feu l'Oknha Vongsā Sarpejñā (Nong) (suite) ........ 13

3. Abhinavabhāsita, pāli et traduction par le Vénérable Achar Ouk-Chéa, membre de la Commission du Tripitaka (suite et fin) ........ 16

4. Histoire de Rome. Extraits de divers documents de l'histoire universelle (suite) ........ 25

5° Géographie sommaire de divers pays: l'Arabie ........ 29


## HORS-TEXTE


Portrait du Bodhisattva Avalokiteçvara — Style de Bayon (1743 E. B.) ........ 1



រូបព្រះពោធិសត្វអវលោកិតេស្វរៈ បែបរចនាប្រាសាទបាយ័ន (ព. ស. ១៧៤៣)

# វិទ្យុធម្មទេសនាកណ្ឌទី ៤

## ព្រះបាឡាត់ឃោសគាគ អាចារ្យសាលាបាលីជាន់ខ្ពស់ សំដែង

ថ្ងៃអង្គារ ៨ កើតខែចេត្រឆ្នាំម្សាញ់ត្រីស័ក ព. ស. ២៤៩៥ (៤-៣-៥២)

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការព្រះអរហំសម្មាសម្ពុទ្ធភគវន្តមុនីព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃដោយសេចក្ដីគោរព ។

លំដាប់នេះនឹងសំដែងអំពីកំណើតនៃសេចក្ដីសុខជាសង្ខេបតាមកាលវេលា ដូចតទៅនេះ ។

សុខោ ពុទ្ធានមុប្បាទោ ការបានត្រាស់ដឹងឡើងនៃព្រះពុទ្ធគ្រប់ព្រះអង្គជាហេតុនាំឲ្យកើតសេចក្ដីសុខ (ជាច្រើនប្រការដល់សព្វសត្វក្នុងត្រៃលោក) ។

អធិប្បាយថា ក្នុងកាលណាមួយៗ, ដែលមានព្រះអរហន្តសម្មាសម្ពុទ្ធបានត្រាស់ដឹងឡើង, កាលនោះសត្វមានចំនួនច្រើនទីងគណនារាប់មិនអស់ តែងបានប្រទះនឹងប្រយោជន៍ សេចក្ដីសុខស្ងប់ដ៏ក្រៃលែង ។ ព្រោះព្រះអង្គឧប្បត្តិកើតឡើងទ្រង់ប្រកបដោយសិរីសម្បត្តិដ៏ខ្ពង់ខ្ពស់គួរស្ងើច ជាទីបូជារបស់ពួកជនជាមនុស្ស ហើយបរិបូរដោយចំណេះវិជ្ជាគ្រប់យ៉ាង ព្រមទាំងមានព្រះទ័យពេញព្រៀបដោយសេចក្ដីករុណា អាណិត

អាសូរទៅកេពួកសត្វទៅក្នុងត្រៃភពឥតកើសមុខ ។ ព្រះពិជិតមារបរមត្រៃ ដែលទ្រង់បានបួសប្រេះនឹងសេចក្តីសុខក្សេមក្សាន្តខ្ពស់ផុតចំណោមមនុស្ស ដោយៈគោត្រត្រកូល កេរសម្បត្តិជាដើម ក៏ព្រោះតែកម្មបុណ្យ សេចក្តីល្អដែលទ្រង់បានកសាងសន្សំទុកជាលំដាប់ជាតិតទៅមកដោយពិត ។

មហាការុណិកោ នាថោ ព្រះលោកនាថប្រកបដោយមហាករុណាគុណ ទោះព្រះអង្គបានសេចក្តីសុខស្រួលដូចម្តេច ក៏មិនទម្រន់ឲ្យលក់ដក់ងប់ជាប់ព្រះទ័យឲ្យទាល់តែលង់គាំងគំនិតដល់ភ្លេចទឹក មិនឃើញការសុខទុក្ខរបស់ពួកសត្វដែលលិចលង់ក្នុងលោកសន្និវាសនេះទេ, ព្រះអង្គមិនព្រមសុខព្រះទ័យទទួលសោយសេចក្តីសុខថ្កុំថ្កើងជាផលសំណាងដែលបានមកតាំងនៅសិបក្នុងកណ្តាប់ព្រះហស្តរបស់ព្រះអង្គ តែមួយព្រះអង្គប៉ុណ្ណោះ ទ្រង់ស៊ូលះបង់ប្រយោជន៍ទាំងនោះចោលស្រឡះមិននឹកនា ទ្រង់ប្រឹងបំពេញព្យាយាមទាល់តែបានសម្រេចព្រះពោធិញ្ញាណលើកឧបល័ក្ខ ព្រះអង្គបានទាំជាសត្ថនាយកៈ អ្នកដឹកនាំស្រោចស្រង់សត្វទាំងឡាយទូទៅក្នុងលោកឲ្យផុតពីសេចក្តីទុក្ខលំបាកមាន កើត, ចាស់, ឈឺ, ស្លាប់ជាដើម (ដូចជាសំពៅធំធេង) ។

ចាប់ដើមតាំងពីត្រឹមថ្ងៃដែលទ្រង់បានត្រាស់ដឹងមកដល់ថ្ងៃដែលទ្រង់យាងត្រឡប់ពីដើមកែសខាងក្បែងដើមពោធិព្រឹក្ស មកគង់នៅក្រោមម្លប់ដើមជ្រៃ ជាខាងកើតដើមពោធិព្រឹក្សវិញ នៅក្នុងរវាងពី ៤១ ទៅ

ទល់នឹង ៤៦ ថ្ងៃ ។ តពីនោះមក ព្រះអរហំសម្ពុទ្ធ ស្ដេចយាងប្រកាស សាសនា ប្រទានទុកទំពាក្យប្រៀនប្រដៅណែនាំពួកសត្វមានមនុស្សនិង ទេវតាជាដើម, ខំប្រឹងព្យាយាមសំដែងធម៌បំភ្លឺពន្យល់ប្រាប់គុណ, ទោស, ខុស, ត្រូវ ឲ្យសត្វយល់ឃើញពិតៗ ឥតរួញរានឹងសេចក្ដីនឿយព្រួយព្រះ កាយពលក្នុងការប្រកាសប្រាប់ប្រយោជន៍ដល់សត្វទាំងនោះឡើយ ។ ព្រះអង្គទ្រង់ប្រឹងបំពេញពុទ្ធកិច្ចគប់គ្រាន់មិនមានចន្លោះ សមស័ក្ដិព្រះអង្គ ជាសត្ថានាយក អ្នកដឹកនាំស្រោចស្រង់ជាទីពឹងពំនាក់អាស្រ័យនៃសត្វក្នុង ត្រៃលោកនែនៗ ទាំងមានព្រះឥរិយាបថស្រគត់ស្រគំសមរម្យ, មានព្រះ អធ្យាស្រ័យក៏ទន់ភ្លន់ស្មោះស្មើ ស្លូតត្រង់ទៅកេសត្វទូទៅ, គួរជាប់ចិត្ត លួមឲ្យមនុស្សទេវតានិងសត្វគ្រប់ថ្នាក់ទាំងទាប - ខ្ពស់មានសេចក្ដីសង្ឃឹម កក់ក្ដៅចូលទៅជ្រកកោនក្រោមម្លប់ពោធិសម្ភារបានសម្រេចសន្តិសុខតាម ប្រាថ្នា; ព្រះអង្គមានទំនងគួរឲ្យសត្វក្នុងសាកលលោកគោរពក្រាបសំពះ យកតម្រាប់តាមដោយសេចក្ដីពេញចិត្តមិនបាច់បង្ខំ ។

ព្រះពុទ្ធគុណដែលរៀបរាប់ដោយសង្ខេបមកខាងលើនេះ បើពោល បំព្រួញឲ្យខ្លីងាយចំណាំជាងនោះមកទៀតថា: ព្រះអរហំសម្មាសម្ពុទ្ធជា បរមគ្រូ ទ្រង់មានព្រះទ័យស្អាត មិនប្រឡាក់ដោយបាបសេចក្ដីអាក្រក់ ណាមួយ ហៅថា វិសុទ្ធិគុណ, ទ្រង់ខំប្រឹងបំពេញប្រយោជន៍ឲ្យសត្វបាន ទទួលសេចក្ដីសុខតាមគតិលោកគតិធម៌ស្មើៗគ្នា សមគួរដល់កំពូលសំណាង

សត្វ  មិនលាក់បាំងប្រយោជន៍ទុកសម្រាប់សោយសេចក្ដីសុខស្រួលតែមួយព្រះអង្គឡើយ  ហៅថា  ករុណាគុណ,  ទ្រង់មានឧបាយដ៏ប្រពៃក្នុងការទូន្មានសត្វ  ធ្វើសេចក្ដីជ្រៅឲ្យរាក់  កំបាំងឲ្យងាយយល់ងាយគិតជាដើម ហៅថា បញ្ញាគុណ ។ ដោយហេតុនេះទើបប្រាកដថាព្រះពុទ្ធគ្រប់ព្រះអង្គបានត្រាស់ដឹងឡើងក្នុងលោក  ជាហេតុនាំឲ្យបានសេចក្ដីសុខ (ដល់ពួកសត្វក្នុងត្រៃភព) ។

សេចក្ដីដែលសំដែងមកនេះ  ជាគុណដែលមានក្នុងព្រះអង្គ ។

ស្វាក្ខាតោ  ភគវតា  ធម្មោ  ធម៌ដែលព្រះភគវន្តសម្ពុទ្ធសំដែងដោយប្រពៃ  មានគុណគាប់ស្រោចស្រង់ពួកសត្វលោកដែលពេញចិត្តកាន់តាមឲ្យផុតអំពីទុក្ខទោស  បានសេចក្ដីសុខស្រួលឃើញជាក់ច្បាស់ចំពោះមុខភ្លាមៗតាមថ្នាក់តាមជាន់ឥតបង្អង់ចាំកាលវេលា ។ ធម្មោ សុចិណ្ណោ  សុខមាវហាតិ  ធម៌ដែលសត្វបានគោរពទុកត្រឹមត្រូវទើបផ្ដល់សេចក្ដីសុខមកឲ្យវិញពុំខាន ។

អធិប្បាយថា: អំពើល្អហៅថាធម៌, អ្នកប្រព្រឹត្តត្រូវតាមធម៌ ឈ្មោះថាបានគោរពធម៌ទុកដោយប្រពៃ  ទើបត្រូវបានផលជាសុខ;  អំពើអាក្រក់ហៅថាអធម៌  គឺមិនមែនធម៌;  អ្នកមិនកាន់តាមធម៌  ឈ្មោះថាមិនគោរពធម៌បែរទៅប្រព្រឹត្តអាក្រក់  ដែលមិនមែនជាធម៌  ទើបត្រូវបានផលជាទុក្ខ ។

រួមព្រះធម៌ទាំង ៨៤០០០ ធម្មក្ខន្ធ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែង ហៅថា ពុទ្ធសាសនា ។

អស់លោក-អ្នកជាសាធុជនទាំងឡាយ ដែលពេញចិត្តគាប់អធ្យាស្រ័យ ចង់បានប្រយោជន៍ សេចក្ដីសុខចំរើនត្រឹមតែក្នុងលោកនេះក្ដី ឬក៏ចង់ប្រាថ្នាដល់ទៅលោកខាងនាយទៀតផងក្ដី គួរតែប្រឹងទៀតបង្អោនចិត្តចូលមកកាន់ព្រះពុទ្ធសាសនាខ្ពុះកុំខាន ព្រោះព្រះពុទ្ធសាសនានេះ អ្នកប្រាជ្ញជាន់ខ្ពស់ក្នុងលោកឃើញពិតថាជាសាសនាមានអានុភាព អាចធ្វើលោកឲ្យស្ងប់, ទាំងញ៉ាំងមនុស្សសត្វដែលទន់ទាបថោកថយឲ្យខ្ពង់ខ្ពស់ថ្លៃថ្នូរ, បើថ្លៃថ្នូរស្រាប់ ឲ្យរឹងរឹតតែវិសេសក្រៃលែងឡើងទៀត ។ សេចក្ដីដែលពណ៌នាមកនេះ ត្រង់តាមគោលដើមនៃពុទ្ធបំណងពិត; ព្រោះព្រះអង្គដែលខំប្រឹងព្យាយាមសំដែងច្បាប់ប្រាប់ពន្យល់ មិនគិតនឿយហត់ទាំងម៉្លេះ ដោយទ្រង់មានព្រះទ័យករុណាចង់ស្រាយដោះពួកសត្វដែលជាប់ចំណងនៃសេចក្ដីទុក្ខលំបាកមានជាតិ, ជរ, ព្យាធិ, មរណជាដើមឲ្យរួចចាកទុក្ខបានសេចក្ដីសុខស្កប់ស្កល់ប៉ុណ្ណោះ ។ សូមអស់លោក-អ្នកស្ដាប់ៗហើយកំណត់ទុកក្នុងចិត្តចុះ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ថា ពួកមនុស្សសត្វកើតមកពេញទាំងសាកលលោក សុទ្ធសឹងតែប្រាថ្នាសេចក្ដីសុខខ្ពង់ខ្ពស់ថ្លៃថ្នូរគ្រប់ៗរូប, ដែលបែរជាបានសេចក្ដីអាប់ឱនទន់ទាប មិនសមដូចបំណងស្មើគ្នា

ទៅវិញនោះ បណ្ដាលមកពីហេតុច្រើនយ៉ាងណាស់, ខ្លះកើតឡើងដោយសេចក្ដីទន់ទាបក្រីក្រល្ងង់ខ្លៅស្រាប់មកពីកំណើតក៏មាន ព្រោះផលបុញ្ញតិច, ខ្លះកើតមកបានជួបប្រទះនឹងសេចក្ដីចំរើនសម្បូណ៌សម្បត្តិគ្រប់គ្រាន់ស្រាប់ពីកំណើត តែធ្វេសភ្លេចគិត ទំរើសខ្លួនបណ្ដោយចិត្តឲ្យទៅប្រព្រឹត្តអាក្រក់ទាស់ទំនង ពានទៅលើអំពើមិនមែនជាធម៌ បានសេចក្ដីថ្លស់ធ្លាយធ្លាក់ខ្លួនជាអ្នកទន់ទាបអាប់ឱនខ្លួនទៅវិញក៏មាន, ខ្លះទប់ខ្លួនឲ្យនៅត្រឹមតែស្មើៗមិនទាបមិនខ្ពស់ក៏មាន តាមសមគួរដល់អំពើដែលសត្វបានធ្វើរៀងខ្លួន ; ដូចពុទ្ធភាសិតថា សត្តេ កម្មំ វិភជ្ជតិ កម្មគឺអំពើដែលសត្វធ្វើទុកមកពីជាតិមុន ឬជាតិនេះ, ជាមេចំណែកចែកឲ្យសត្វបានសុខបានទុក្ខផ្សេងៗគ្នា មិនមែនអ្វីផ្សេងក្រៅពីអំពើរបស់ខ្លួននោះចែកឲ្យឡើយ ។

ឯអំពើអាក្រក់មិនត្រូវតាមផ្លូវធម៌ នាំមនុស្សឲ្យវិនាសបានសេចក្ដីទុក្ខលំបាកទាំងលោកនេះនឹងលោកខាងមុខនោះដូច្នេះ ។

អបាយមុខ ហេតុនាំឲ្យវិនាសបាត់សេចក្ដីចំរើន ៤ យ៉ាងគឺ:

១ – ឥត្ថីធុត្តោ: អ្នកលោភចិត្តជក់នឹងមាតុគ្រាម មិនមានចិត្តសន្តោសត្រឹមតែភរិយា - ស្វាមីរបស់ផងខ្លួន ។

២ – សុរាធុត្តោ: អ្នកសេពគ្រឿងស្រវឹង

៣ – អក្ខធុត្តោ: អ្នកលេងល្បែងភ្នាល់

៤ – បាបមិត្តៈ អ្នកគប់គេមនុស្សអន្ធពាលអាក្រក់ជាមិត្ត ។

ហេតុទាំង ៤ នេះសុទ្ធសឹងតែជាអំពើអាក្រក់អាចនាំឲ្យប្រទេសជាតិ ភោគសម្បទ បំណោះវិជ្ជាចរិយាស្រុកស្រុតចុះថោកទាប, នាំឲ្យវិនាសថ្លស់ ក្លាយខ្លួនបង់ប្រយោជន៍សេចក្ដីសុខចំរើនរបស់មនុស្សក្នុងសាកលលោក ជាក់ស្ដែងក្រាមៗ; មិនបាច់ពោលថ្មីដល់ទៅលោកខាងមុខនោះឡើយ ។ មែនពិត, អំពើទាំងនេះ, បើសត្វខំប្រឹងប្រព្រឹត្តជាប់មិនលែង, លោក ពោលថា ទុកដូចជាយកគប់ភ្លើងយ៉ាងធំមកដុតកេលកំទេចបំផ្លាញភោគ-សម្បទ បំណោះវិជ្ជា ចរិយា មារយាទ ជាតិកំណើតទីងសន្តិសុខដ៏រុងរឿង របស់ខ្លួនឲ្យខ្ទេចខ្ទីខ្លួនលែងល្អតលាស់ដុះចំរើនឡើងទៀតរួច បេះតែ រេចរិលចុះទៅជានិច្ច ឈ្មោះថាជាមនុស្សជួញទុក្ខ ។

សាធុជនជាសប្បុរសត្រូវកុំប្រព្រឹត្តអំពើទាំងនេះឲ្យសោះ, កាលបើ សាធុជនបានវៀរចាកអំពើទាំងនេះរួចស្រឡះហើយ ឈ្មោះថាបានប្រ-ព្រឹត្តធម៌រក្សាធម៌ទុកដោយប្រពៃ នឹងបានផលជាសុខច្រើនប្រការ; បើ ពោលដោយសង្ខេបវិញគឺៈ ១ – សុខព្រោះមានចិត្តស្រស់ស្រួលស្មោះស្មើ ទៅរកភរិយា-ស្វាមី ដោយមិនជាប់ចិត្តនឹងស្ត្រីបុរសឯទៀត; ២ – សុខ ព្រោះមានសំដីពេសាជាប្រក្រតី, មិននិយាយឡេះឡោះកកែកករករឿង ឈ្លោះមិនខ្ចបបង់ប្រាក់កាសដោយហេតុមិនសេពសុក; ៣ – សុខព្រោះ បានគ្រឿងការងាររបរចំរើន រៀនវិជ្ជាបេះចាំមិនភ័យនឹងអ្នកពជការពាប់ចង់យុំខាំង

លក់ថ្លៃដោយហេតុមិនលេងល្បែងភ្នាល់; ៤ – សុខព្រោះមានចិត្តស្លូតត្រង់ មិនចេះធ្វើអំពើអាក្រក់ដោយហេតុមិនសេពគប់កេជនពាល ។

ឯការគេចកេជនពាលអាក្រក់ នាំឲ្យរួចចំណោះអាក្រក់ ព្រោះមនុស្សពាលមិនដែលនាំឲ្យប្រព្រឹត្តល្អទេ មិនស្គាល់ហេតុនាំឲ្យបានសុខ ស្តាប់ពាក្យគ្រូមិនសូវបាន, បើអ្នកដែលទៅសេពគប់ជននោះ មិនចេះលេងស្រី នាំឲ្យចេះលេង, មិនចេះសេពសុរា នាំឲ្យចេះ, មិនចេះលេងល្បែងភ្នាល់ នាំឲ្យចេះលេង, ហួសពេលទៅនាំឲ្យចេះដើរលេងយប់, ទោះក្រោយបំផុតប្រព្រឹត្តគេ ខ្លះក៏ដល់ចេះលួចប្លន់កាប់សម្លាប់គេក៏សឹងមាន; ត្រូវនឹងពុទ្ធភាសិតថា "អសេវនា ច ពាលានំ ការមិនគប់រកពួកជនពាល ជាមង្គលដ៏ប្រសើរ" ។ អ្នកដែលបានវៀរចាកអំពើអាក្រក់ដូចពោលមកហើយនេះ ទុកដូចជាអ្នកបានបណ្ដុះប្រយោជន៍ដ៏ធំទូលាយចំពោះខ្លួនផង ទុកសម្រាប់ប្រទេសជាតិឲ្យបានចំរើនទៅខាងអនាគតផង ។ សេចក្ដីសុខទុក្ខទាំងនេះកើតមកអំពីកម្មផ្ទាល់ខ្លួនពិត ៗ ។ ការលះបង់អបាយមុខមានប្រយោជន៍ធំទូលាយក្រៃពេក ដែលពោលមកនេះជាសេចក្ដីសង្ខេប ។ អ្នកប្រាជ្ញជាន់ខ្ពស់ដែលមានឈ្មោះចុះទុកជាប់គង់ប្រវត្តិសាស្ត្រនៃលោកតរៀងមកដរាបដល់សព្វថ្ងៃនេះក្ដី ដែលកំពុងមានសព្វថ្ងៃនេះក្ដី កាលបើលោកគិតប្រកបការណាមួយជា

ប្រយោជន៍ខ្លួនឯងប្រទេសជាតិជាដើម សុទ្ធតែលោកលះអបាយមុខទាំង ៤ នេះចោលចេញស្រឡះ ទើបធ្វើការនោះបានសម្រេចដូចបំណង ។

មិនត្រឹមតែប៉ុណ្ណេះដែលហៅថាសាសនាបរិសុទ្ធនោះ គឺជាសាសនាអាចញ៉ាំងលោកឱ្យលឿនទៅកាន់សេចក្ដីចំរើន ចប់សត្វមិនឱ្យធ្លាក់ទៅកាន់ទីថោកទាបមាននរកជាដើម ឱ្យលោកបានសេចក្ដីសុខស្ងប់ ទាំងធ្វើឱ្យអ្នកជឿស្ដាប់កាន់តាម បានប្រទះប្រយោជន៍សេចក្ដីចំរើនដោយគោត-សម្ប័ទ បញ្ញាសម្ប័ទ កេរ្តិ៍ឈ្មោះយសស័ក្តិតាមសមគួរ មិនមែនសំដែងប្រាប់ឱ្យមនុស្សសត្វដេកចាំសំណាងពីព្រេងនាយតែម្យ៉ាងទេ ដូចពុទ្ធភាសិតមានដើមថា សុស្សូសំ លភតេ បញ្ញំ អ្នកមានប្រាជ្ញចេះចំណេះវិជ្ជាគ្រប់យ៉ាងបានមកពីប្រឹងរៀនស្ដាប់ទន្ទេញ មិនធ្វេសប្រ-ហែសក្នុងការរៀនសូត្រ; ឧដ្ឋាតា វិន្ទតេ ធនំ អ្នកមានទ្រព្យធនគ្រប់គ្រាន់ មកពីរៀសរៃប្រឹងរកប្រឹងធ្វើមិនខ្ជិល ។ សេចក្ដីដែលសំដែងមកប៉ុណ្ណេះតាមលំអានព្រះពុទ្ធសាសនា ជាសាសនាប្រាប់ផ្លូវប្រតិបត្តិយ៉ាងកណ្ដាល មិនឱ្យសត្វកាន់អាកធ្លាក់ទៅលើផ្លូវប្រតិបត្តិខ្វេង ដែលហៅថា អន្តាបដិបទា សេចក្ដីប្រតិបត្តិដ៏លាមក ឬអមខាងនោះឡើយ មានទំនងឱ្យពួកពុទ្ធបរិស័ទនាំគ្នាកាន់តាមសេចក្ដីពេញចិត្តឥតបង្ខិតបង្ខំ ។ ព្រោះហេតុនោះ ទើបអធិប្បាយថាជាសាសនាស្អាងលោកឱ្យរុងរឿង ចប់សត្វមិនឱ្យធ្លាក់ទៅកាន់ទីទាប ។

សូមអស់លោក-អ្នកជាសប្បុរសទាំងឡាយ កំណត់ចាំទុក ហើយប្រតិបត្តិយកប្រយោជន៍ តាមគួរដល់អធ្យាស្រ័យចុះ ។ សំដែងមកដោយសង្ខេបតាមគួរដល់វេលា សន្មតជាចប់ត្រឹមប៉ុណ្ណេះ ឯវំ ។

សូមឲ្យជោគជ័យសិរីសុខគ្រប់ប្រការមានដល់អស់លោកអ្នកស្តាប់ទាំងឡាយ អស់កាលជានិច្ចតរៀងទៅ កុំបីឃ្លាតឡើយ! ។

ព្រះបាឡាត់ឃោសនាគ អាចារ្យសាលាបាលីជាន់ខ្ពស់ ។

## លោកនេយ្យ

### ពាក្យកាព្យ (តមក)

បទពំនោលនូវសាសន៍ ថ្លែងពីទំនង ដំណើរព្រះពង្សពោធិ ។ នូវកថបណ្ឌិតចាំងបី ដូចចូលកសី ប្រាំដណ្តប់ឆ្នាំហើយណា ។ ឯអង្គព្រះមហាក្សត្រា ស្តេចពិចារណា គិតថាឥឡូវធនញ្ជ័យ ។ ប្រយ័ត្នខ្លួនក់ពេកក្រៃ ពុំឲ្យឃល់នៃ កំហុសកំដល់គិចឡើយ ។ បើកលែងតាល់អញហើយ ឥតអ្នកណាឡើយ ទឹងអាចយកទោសកំបាន ។ គួរអញរកកលគិតឆ្ងាន ស្រដីឲ្យបាន ញ៉ីកៗទឹងជាប្រក្រតី ។ មានកាលមួយថ្ងៃពោធិទឹងអ្នកចាំងបី ឡើងទៅគាល់មហាក្សត្រា ។ ទើបស្តេចបន្ទូលទៅថា ម្នាលអស់អាចារ្យ នាចិត្តព្រះស្តែងសព្វថ្ងៃ ។ ចង់ប្រយោជន៍ឲ្យអញក្រៃ ឬចង់ឲ្យនៃ អាត្មាឯងចូរថាចោ ។ អាចារ្យចាំងបីអង្គ ទូលព្រមឡើងថាបពិត្រព្រះមហាក្សត្រក្បាន្ត ។ យើងខ្ញុំចាំងបីនេះមាន ចិត្តចង់ឲ្យបានប្រយោជន៍អម្ចាស់ពេកក្រៃ ។ ឯប្រយោជន៍ខ្លួនឯងនៃ ពុំគិតសង្ស័យពុំមានដល់គិចឡើយណា ។ ព្រះពោធិសត្វសោភា ស្តាប់ពាក្យនោះណាអ្នកសើចហើយអ្នកស្ងៀមនៅ ។ ទើបស្តេចបើកបន្ទូលទៅ ត្រាស់ថាហៃចៅ ធនញ្ជ័យចិត្តបាតើម្តេច ។ ពង្សពុទ្ធង្កួលសរពេជ្ញ ទូលថាសម្តេចមហាកដឥស្សូរសិរសោ ។ សព្វថ្ងៃប្រយោជន៍អាត្មា ខ្ញុំសឹងប្រាថ្នាប្រយោជន៍អម្ចាស់ថ្ងៃក្តី ។ សឹងគិតបំពេញចក្រិ ចាំងបទអ្ហ៊ីៗ អញខ្ញុំទឹងទូលឡើយណា ។ ក្សត្រណានោះឯសុទ្ធក- លៃយទូលកិច្ចការ បពិត្រ

ព្រះបាទក្សត្រថៃ ៗ យើងខ្ញុំយល់ចិត្តធនញ្ជ័យ បណ្ឌិតសព្វថ្ងៃ ចង់
តែប្រយោជន៍ខ្លួនពិត ៗ ប្រយោជន៍អម្ចាស់ពុំគិត សព្វថ្ងៃជីវិត រស់
ដោយព្រះរាជទាន ៗ គាត់ពុំគិតគុណក្សត្រក្សាន្ត សព្វថ្ងៃនេះមាន ចិត្ត
ចង់ចម្រាសក្សត្រា ៗ ស្តេចស្តាប់ពាក្យសុន្ទក- លៃយក្រាបទូលថា ព្នោះ
គួរសព្វព្រះហឫទ័យ ៗ ទើបស្តេចបន្ទូលថាហៃ សុន្ទកលៃយ បទអ្វីទៅ
ថាដូច្នោះ ៗ សុន្ទកលៃយទូលស្នោះ នាខ្ញុំទូលនោះ ដ្បិតខ្ញុំយល់ទៅ
ធនញ្ជ័យ ៗ ធ្វើធ្មឹងអំនួតធំក្រៃ លទ់ពទ់សព្វថ្ងៃ ខុសទំនងក្នុងអ្នក
ផង ៗ មានក្មេងប្រាំយជាម្តង កើតថ្ងៃព្រមផង ឲ្យគាល់ឲ្យហៃប្រក្រតី ៗ
បពិត្រអម្ចាស់សិរី យល់ហេតុសេចក្តី ដូច្នោះទើបខ្ញុំទូលថា ៗ ចង់តែ
ប្រយោជន៍អាត្មា ប្រយោជន៍ក្សត្រា ពុំធ្វើជល់គិតឡើយនៃ ៗ ឥដ្ឋា-
រម្មណ៍ទូរកភ័យ បណ្ឌិតនោះនៃ ទូលថាបពិត្រក្សត្រា ៗ ពាក្យសុន្ទក-
លៃយថា ទូលព្រះរាជា មែនពិតដូច្នោះឯងហោង ៗ ស្តេចស្តាប់ហើយ
ស្តេចត្រាស់ផង ធនញ្ជ័យនេះម្តង គេថាដូច្នោះឬអ្វី ៗ កាលនោះព្រះ
ពន្ស្រះតាធិ ស្តាប់ហើយទ្រី បង្គំប្រណម្យទូលថា ៗ បពិត្រសម្តេចរាជា
ពិតដូចគេថា ទឹងបន្ទោសទណោឡើយ ៗ ទោសដ្បិតកុសលខ្ញុំហើយ
បានសាងជាត្រើយ អំពីបុរាណនាយណា ៗ នាំមកឲ្យកើតនៅនា
ត្រកូលនៃមហា- សេដ្ឋីប្រសើរមានទ្រព្យ ៗ ទើបមានបរិពារសំរាប់ ទាំង
ប្រាំយស្រាប់ តែងគាល់តែងហែសព្វថ្ងៃ ៗ ហើយមានប្រាជ្ញាវាងវៃ

ដោះទុក្ខក្សត្រថៃ ព្រះអង្គទ្រង់ព្រះមេត្តា ៗ ឲ្យជូនជំនូនគោត្តា ច្រើនក្រៃ
មហិមា មួយសែនខ្ទាសព្វថៃ ៗ ទើបឲ្យគេខឹងស្អប់ក្រៃ មកទូលក្សត្រ
ថៃ កាច់ឲ្យព្រះអង្គខ្វល់ផង ៗ បើកើតដូចគេនោះហោង ជាកូនដកខង
ម្ដាយដើរទៅគេប្រុសវិញ ៗ សមបានជាមិត្រសំឡាញ់ ពុំនោះសោត
មិញ កើតជាកូនអ្នកសសន ៗ ដើរលេងដេកលេងតំបន់ គេពុំដឹងខ្ពង់
សមបានជាមិត្រផងគ្នា ៗ ពុំនោះបើទៅកើតជា កូនអ្នកលេងរ៉ា តែងសូម
គេទីសព្វស្រុក ៗ ដូចគេនោះសមបានសុខ ជាមិត្រឥតទុក្ខ គិតគេខឹង
ផងឡើយណា ៗ បពិត្រសម្ដេចក្សត្រា សព្វថៃនេះណា ឈើផ្អាលព្រះ
បាទចក្រី ៗ ពុំឈើផ្អាលអម្ចាស់ក្តី ពោះធ្វើស្វាមី- ភក្តីស្វាមីភក្តិនោះ ៗ
នរណាមួយចិត្តចង់ស្មោះ ប្រយោជន៍ថ្វាយគ្នោះ មិនចង់ឲ្យប្រយោជន៍ក្តី ៗ
ខ្ញុំដឹងខ្ញុំពុំប្រណី ពុំបាច់ចក្រី ស្ដេចជ្រាបក្នុងព្រះទ័យ ៗ កជបណ្ឌិត
ទាំងបីនាក់ ខឹងហើយទូលថា បពិត្រក្សត្រថៃច្បាស់ច្បង ៗ ធនញ្ជ័យដឹង
មែនពិតហោង ដ្បិតគាត់ប៉ុនប៉ង ដណ្ដើមរាជ្យទីនព្រះអង្គ ៗ ស្ដែង
ស្ដេចស្ដាប់ហើយពុំលង់ បន្ទូលត្រាស់ត្រង់ ថាហៃធនញ្ជ័យបណ្ឌិត ៗ
ព្រះស្ដែងប៉ុនប៉ងគំនិត ទីងក្សត់អញពិត ឬស្ដេចចូរចៅចរចា ៗ ព្រះ
ពោធិសត្វទូលថា ខ្ញុំទេតែក ទាំងបីនឹងក្សត់ព្រះអង្គ ៗ កាលត្រាស់
ឲ្យហៅទៅក្នុង ប្រាសាទកំឡុង ព្រះរាជមន្ទីរក្សត្រថៃ ៗ រីឯសុន្ទរ-
ហៃយ យល់ប្រសើរស្រី ព្រះសុំអម្ចាស់ថៃថ្លា ៗ (នៅមានត)

## អភិជាកាសិក

### ភាគទី ១

(គមកនិងឲប់)

ញុំ វត្ថុំ បរិចន្ទ្ទ   យោ'ញុំ វត្ថុំ សេវតេ
ញុកញុក ខុគោ តស្ស វិនស្សន្តិ ន សំសយោ.

នរអ្នកណា មានចិត្តសាក់ ទៅលះបោលបង់
វត្ថុដែលទៀង ហើយទៅត្រេកត្រង់ សេពវត្ថុផូវផង់ មិនទៀងវិញណា;
វត្ថុទៀងមិនទៀង ទាំងពីរគង់ឃ្លៀង ឃ្លាតមិនជាវក
ផននោះឧិនបង់ ខាតខូចអាសា ឥតបានត្រង់ណា កុំសង្ស័យឡើយ.

ចក្ខុមា'ស្ស 'បថា អន្ធោ ...

នរអ្នកណា មាននយនេត្រា ល្អិតល្អក្ដីថា
តែបើមិនចេះ អក្សរសាស្ត្រា អ្នកនោះលោកថា មានភ្នែកខ្វាក់;
ធម្មជាតិតាក់តែង បង្កើតភ្នែកឯង ឲ្យមើលជ្រាកក់
មិនឲ្យទើសទាល់ ឲ្យសល់ដំពាក់ មិនឲ្យធ្វើខ្វាក់ មើលអ្វីមិនបាន.

“ចាក-ចៅរាជា”

គតិលោកថា:

“អ្នកចេះអក្សរ លោកឲ្យនាមករណ៍ ថាមានភ្នែកទិព្វ...”

ភាសិតខ្ញុំ[១]ថា៖

"អ្នកមិនចេះអក្សរ លោកឲ្យនាមថា ជាមនុស្សខ្វាក់"

សជាតិ សាសនំ បិយ! អត្តនោ បវរំ រក្ខ!
នានាសិប្បំ ពហុំ គណ្ហ! រដ្ឋំ នោ ឧបលោកតិ!
ចូរស្រឡាញ់ជាតិនិងសាសនា! និងផែនពសុធាដីទឹកយើង
ចូរនាំគ្នាខំរៀនសូត្រឡើង! ទើបដែនយើងចំរើនទាន់សម័យ!

"ចាក-ភាសិតខ្ញុំ"

សជាតិ សាសនំ បិយ! បវរំ ជីវិតសមំ!
មតំ ជីវំ ន ចិន្តេតិ តេស'ត្ថាយ ជីវំ ជហេ!
ចូរស្រឡាញ់ជាតិនិងសាសនា និងផែនពសុធាស្មើជីវិត
ទោះស្លាប់ទោះរស់មិនត្រូវគិត ត្រូវលះជីវិតជួសការវិញ!
សព្វេ បុរិសា ឥត្ថិយោ សព្វវិជ្ជំ ឧគ្គណ្ហយ្យុំ!
សព្វេ បណ្ឌិតា ហោន្តុ! រដ្ឋ'ម្ហាកំ វិរោចតិ!
ជាតិមនុស្សប្រុសស្រីគប្បីរៀន ចំណេះរបៀនសព្វវិជ្ជា!
ឲ្យបានចេះដឹងដូចៗគ្នា ទើបបានថ្លៃថ្លាដល់ជាតិស្រុក!

"ចាក - បញ្ញាសុមាលី"

---

១ ពាក្យថា៖ "ភាសិតខ្ញុំ" នេះ មិនមែនជាភាសិតរបស់អ្នកសរសេរសៀវភៅនេះទេ គឺជាឈ្មោះគម្ពីររបស់អ្នកប្រាជ្ញពីបុរាណមក ។

សព្វធនេសុ វិជ្ជា វ ធនំ មហារហុត្តមំ
អហារិយា អនគ្ឃា អក្ខយា ច សព្វទា.

*វិជ្ជាវិសេសលើសទ្រព្យធន ចោរមិនអាចប្លន់ឆក់លួចបាន*
*វិជ្ជាគ្មានថ្លៃនឹងប្រមាណ ប្រើចេះតែបានគ្រប់វេលា !*

“ ចាក - បញ្ញាសុមាលី ”

សក្កា សិប្បវិជ្ជាយោ វីរិយេន នោ'ប្បជ្ជតិ
សព្វានិ ធនជាតានិ បសយ្ហ នោ លព្ភន្តិ?

*សិល្បសាស្ត្រវិជ្ជានឹងកើតឡើងដោយព្យាយាមយើងរាល់ៗគ្នា*
*ទ្រព្យធនទនឹងកើតនឹងវឡ្បនាដោយយើងរាល់គ្នាប្រឹងរកណា .*

“ ចាក - ភាសិតខ្ញុំ ”

ន សយំ វិជ្ជា បសយ្ហ- បត្តេនេន ឧប្បជ្ជតិ
ន ធនជាតានិ យស្សា'- នុស្សហិតស្សុប្បជ្ជតិ.

*វិជ្ជាមិនដែលកើតឡើងឯង ដោយឥតគេស្វែងគេប្រាថ្នា*
*ទ្រព្យធនមិនកើតដល់អ្នកណា ដែលគ្មានឧស្សាហ៍ប្រឹងរក.*

“ ចាក - ភាសិតខ្ញុំ ”

ពាលោ និវត្តតំ ធីរំ តស្សេវ មរណំ សេយ្យោ
ឯតា ហិ តំ ន ភេចន្តិ បិហាយន្តិ វ ទាណុកា.

មនុស្សល្ងង់រស់នៅឥតអំពើ ស្លាប់វិញគ្រាន់បើប្រសើរជាង
រស់នៅឲ្យគេឃើញរូបកង ប្រឆេងប្រឆាំងទទឹងទាស់.

"បាក - ភាសិតខ្ញុំ"

មនុស្សជាតិ ជាតេយ្យ - សន្តានេ ច សិប្បវិជ្ជំ
តិរច្ឆានំ ន ការេយ្យ ឧត្តិ ចោទកំ សាហេ សកេ.
កើតមកជាមនុស្សត្រូវតែចេះ វិជ្ជាចំណេះក្នុងសន្តាន
មិនត្រូវធ្វើខ្លួនដូចតិរច្ឆាន គ្មានខ្វីមក្នុងប្រាណបន្តិចសោះ.

"បាក - ភាសិតខ្ញុំ"

មតា'ហំ មណ្ឌាគាជីវេ ធរ សេវេ សិប្បវិជ្ជំ
យថាកម្មំ ន សេវេយ្យ ន អាគមេយ្យ ភាសនំ.
កុំស្លាប់ដូចពស់រស់ដូចកង្កែប គួរប្រឹងតប់សេពសិប្បវិជ្ជា
កុំបណ្តោយតាមយថាកម្ម កុំចាំភ័សនាលើកបាយបញ្ចុក.

"បាក - ភាសិតខ្ញុំ"

ន សិយា លោកវឌ្ឍនោ.

កើតមកជាមនុស្ស គោរស្គាល់ត្រូវខុស គុណទោសនានា
ត្រូវគេរៀនសូត្រ សិប្បវិជ្ជា ទុកក្នុងអាត្មា ឲ្យបានច្រើនឡើង;
មិនត្រូវកើតមក មិនចេះលៃលក រកការថ្កុំថ្កើង
ធ្វើខ្លួនឲ្យល្ងង់ គេកែមិនឡើង ហើយប្រឹងបើងថាខ្លួនគ្រាន់បើ.

ជាតិមនុស្សបែបនេះ អ្នកប្រាជ្ញដែលចេះ ថាឥតអំពើ
កើតមកជាមនុស្ស មកធ្វើក្អើៗ ស្លាប់វិញត្រាន់បើ មិនបង្អៀតលោក;
មនុស្សនេះលោកថា ចង្រៃបង្ខា ស្អុតស្អាញក្អិលោក
នាំឲ្យបង្អៀត គេឯងតរគោក នាំសោកមមោក អាក្រក់ពេកក្រៃ.

"បាលី - ធម្មបទ"

អសន្តំ យោ បគ្គណ្ហាតិ អសន្តូបសេវតិ
តមេវ ឃាសំ កុរុតេ ព្យគ្ឃោ សជីវកោ យថា.

នរអ្នកណា ក្រស្តុកជា មុខមន្ត្រីផង
បានលើកដំកើង មនុស្សពាលយង់ឃ្នង គប់ប្រសព្វផងទឹងរនោះឯង;
នរអ្នកនោះ តែងនឹងបានលុះ ផលកាចជាក់ស្តែង
ដែលពាលរក្សង សំណាងនោះឯង ដូចសញ្ជីវៈថ្លែង ព្រោះខ្លាឲ្យរស់.

"បាលី - មង្គលត្ថទីបនី"

អត្តានំ ន ទទេ បោសោ
កើតមកជាមនុស្ស ទោះបីស្រីប្រុស ចាស់ក្មេងក៏ដោយ
គួរគេរក្សាខ្លួនកុំឲ្យថ្លស់ធ្លោយ កុំបីបណ្តោយឲ្យជាខ្ញុំគេ;
ឈ្មោះថាខ្ញុំគេ លំបាកឥតល្ហែ គ្មានទំនេរទេ
ធ្វើការមួយរួច ត្រូវតែកវែករ ទឹងនៅទេ ពុំបានឡើយណា.

"បាលី - សំយុត្តនិកាយ"

យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ អសមាហិតោ

ឯកាហំ ជីវិតំ សេយ្យោ បញ្ញវន្តស្ស ឈាយិនោ.

អ្នកដែលរស់នៅអស់រយវស្សា តែគ្មានប្រាជ្ញាដឹងការពក់ជ្រៅ

ចិត្តតាំងមិនទឹងបេះតែសៅជៅ អ្នកនោះលោកហៅរស់ឥតអំពើ.

អ្នកមានប្រាជ្ញាបេះសព្វអន្ទើ ស្ងឹងស្ងាត់នៅស្ងៀតគិតពិចារណា

អ្នកនោះរស់នៅថ្ងៃមួយគង់ជា បានឈ្មោះហៅថារស់នៅប្រសើរ.

“ បាលី - ធម្មបទ ”

យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ

ឯកាហំ ជីវិតំ សេយ្យោ វីរិយំ អារភតោ ទឡ្ហំ

អ្នកដែលរស់នៅអស់តាំងរយឆ្នាំ តែខ្ជិលច្រអាំព្យាយាមរកយមាយ

ស៊ីដេកៗមិនគិតខ្វល់ខ្វាយ អ្នកនោះលោកម៉ាយរស់ឥតសំខូន.

អ្នកមានព្យាយាមប្រពូមាំមួន បានបេះតាំក្បួនសិល្បសាស្ត្រវិជ្ជា

អ្នកនោះរស់តែមួយថ្ងៃឈ្មោះថា រស់នៅថ្ងៃថ្លាវិសេសលើសលន់.

“ បាលី - ធម្មបទ ”

អត្តាភិយេន បុរិសោ សេវតេ មិត្តពន្ធហិ

អត្ថហីនោ តុ បុរិសោ ជីវេបិច មតោបមា!

អ្នកមានទ្រព្យញាតិមិត្រតែងរកបាន អ្នកឥតទ្រព្យទោះមានជីវិតនៅ
ក៏លោកប្រៀបទុកដូចជាស្លាប់ទៅ ព្រោះរស់នៅក៏ឥតអំពើដែរ.

" ជាត - កថាកុសុមមញ្ជរី "

សន្តិ ពុទ្ធិរ- លស្មា សក្កម- តាលបតាលំ
ឧទ្ធក្កុលេ រវេជាតំ និរជំ ន បស្សតិ.

ទោះអ្នកឯណា ទំហំអង្គ ប្រាំពីរដម្រី
កំពស់បើលេ ប្រាំពីរត្នោតក្តី ប្រហែលឥន្ទ្រិយ ណាក់ធំមហិមា
សន្តានអម្បូរ ជាមួយព្រះសូរ្យ នឹងព្រះចន្ទ្រា
ថាបើពុំមាន ធនធានទ្រព្យ អង្គឥតអ្នកណា មួយនឹងយល់ឡើយ;
រហេតិយប្រពាន ប្រសើរសោតមាន តែទ្រព្យជាត្រើយ
ជាញាតិជាមិត្រ ស្នេហ៍ស្និទ្ធឯងហើយ ឥតអ្វីទៀតឡើយទ្រព្យជានាថ.

តិលមត្តំ បកាយមំ ពហុជនោ
បកាសេន្តិ ហានិទូរតោ មិត្តំពេ ចសព្វជា.

បើកបទបាលី នេះលោកស្រដី អាថ៌ឧបមា
អ្នកមួយតូចលន់ ខ្លួនប៉ុនល្ងណា ទោះមានទ្រព្យ មានប្រាក់ធនធាន;
មានពាក្យប្រពៃ ចូលចិត្តនរនៃ អ្នកផងសព្វហាន
ឆ្ងាយជិតក្តីណា យាត្រាមកហ៊ាន រិះរកបាន នៃអ្នកនោះហោង;

សួរសាករកកៅ សឹងជាញាតិផៅ សន្តានពាក់ទង
សឹងស្គាល់ជាមិត្រ ស្នេហ៍ស្និទ្ធស្នាលស្នួន ឥតឯឲ្យហួន នៃអ្នកនោះណា.

“ដក - ច្បាប់សុភាសិត”

យស្ស អត្ថោ តស្ស មិត្តា យស្ស អត្ថោ តស្ស ពន្ធុ
យស្សត្ថោ សោ បុមា លោកេ យស្ស អត្ថោ សោ បណ្ឌិតោ.
មានទ្រព្យគង់ទឹងមានមិត្រភក្ដិ មានទ្រព្យមុខជាមានផៅពង្ស
មានទ្រព្យរាប់ថាប្រុសខ្ពស់ខ្ពង់ មានទ្រព្យជាវង្សបណ្ឌិតជាតិ.

“ដក - បាកុសុមមញ្ជរី”

មា ចិន្តាបសុតំ តាត! បរតោ ជយំ តណ្ហាយ?
ចេលន្តោ មា តុណ្ហី ករ! បរសមការំ តណ្ហា!
កើតមកជាមនុស្សកុំរវល់តែលេង ចូរខំប្រឹងប្រែងឲ្យបានឈ្មោះគេ
បើមិនបានឈ្មោះចូរខំរិះរេ! ឲ្យបានស្មើគេក៏ល្អដោយយ៉ាង!

មា ភាសធំ បច្ចាសីស! ទុរមជាតិភារិតំ!
យា ជាតិ បរលទ្ធិកា សរដ្ឋ ធាសំ តកេតិ!
កុំដេកស្ងៀមចាំព្រេងសំណាង ដែលខ្លួនកសាងពីជាតិមុនណា
សាសន៍ណាដូច្នោះសាសន៍នោះឈ្មោះថា នាំដែនអាត្មាឲ្យជាខ្ញុំគេ!!!

“ដក - ភាសិតខ្ញុំ”

ឆាត្រសរោ សុរសោ ឃោ –
ពួកទាហាន សេនាថ្មើរថ្កាន សាហ័សក្លៀវក្លា
បើគ្មានថ្វីដៃ ឥតជ័យចេស្ដា ពុំគប្បីហៅថា ទាហានឡើយនៃ.

" ពាក-ច្បាប់សុភាសិត "

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

សង្គាមេ មេ មតំ សេយ្យោ! យញ្ចេ ជីវេ បរាជិតោ!!

. . . . . . . . . . . . . . . . . . . . . . . . . . . . . .

ស្លាប់ក្នុងសង្គ្រាមប្រសើរថ្លៃថ្លា! គ្មានខ្មាសអ្នកណា បាត់បង់តែម្ដង
រស់នៅចាញ់គេនាំឲ្យអួហ្មង! ខ្មាសទេវតាផងនឹងគង់មនុស្ស!

" ពាក - ធម្មប្រទីបលោ "

បក្ខិ មយុរោ  ពាលសិង្គោ មរណាវំ
ភិក្ខុ មរសីលំ  រាជា មរសង្គាមា

លោកថាសត្វបក្សី សោកព្រោះបីទីមរណា
លុះលើមែកក្ដា ទើបប្រសើរជាបក្សី;
ឈ្លើញសោកមរណា លើកែត្រាត្រាប់ផលធី
ភិក្ខុទ្រង់សីលា- សេសះសោកមរក្នុងសីលសង្ឃ;
ព្រះមហាក្សត្រឆិកផ ទ្រង់អំណាចមរណាក្នុង
សង្គ្រាមជ័យទ្រើសទ្រង់ កេរ្តិ៍ប្រសើរជាក្សត្រា.

" ពាក - ច្បាប់សុភាសិត "

## ពង្សាវតាររោម

(តទៅ)

# អំពីវីរបុរស ៤ នាក់

តាំងអំពីកាលនោះមក ប្រជាជនក៏បែកខ្ញែកគ្នាជា ២ ពួក គឺពួកអ្នកមានទីងអ្នកក្រ តាំងតស៊ូគ្នាទៅវិញទៅមកមិនសូវស្រាក ទាំងពីរពួកសឹងមាននាយកតែរៀងៗខ្លួន សុទ្ធតែជាមនុស្សសំខាន់ៗ គឺខាងពួកអ្នកមានមានស៊ីល្លានឹងប៉ុមប៉េ (Sylla et Poumpée) ជាអធិបតី ចំណែកខាងសាមញ្ញជនធម្មតា មានម៉ារីយុសនឹងហ្ស៊ូលសេសារ (Marius et Jules César) ជាអធិបតី ទាំង ៤ នាក់ បានប្រណាំងប្រជែងគ្នារៀមជាគូៗ គឺស៊ីល្លានឹងម៉ារីយុស ប៉ុមប៉េហើយនឹងសេសារ ។

ម៉ារីយុសជាមេទាហាន១ដ៏ល្បីឈ្មោះ ធ្លាប់ធ្វើជាមេទ័ពទៅច្បាំងឈ្នះស៊ុគុរថា (Jugurtha) ដែលធ្លាប់ជាចំណុះរោម បង្កការចលាចលជាក្បត់ឡើង ។ ម៉ារីយុសជាទាហានដ៏អង់អាច ១ មានបំណងចង់បានដំណែងជាកុងស៊ុល ទើបចូលមកក្រុងរោម ប្រើសំដីជាគ្រឿងជួយខ្លួន ទើបបានទទួលនាទីជាកុងស៊ុល មានមុខក្រសួងជាមេទ័ពធំ ដើម្បីធ្វើសង្គ្រាមនឹងស៊ុគុរថាតទៅទៀត ។

កិច្ចការដំបូងដែលម៉ារីយុសចាប់ធ្វើឡើងនោះ គឺការកែប្រែរបៀបកេណ្ឌមនុស្សធ្វើទាហាន គឺបញ្ញត្តឲ្យកេណ្ឌអ្នកទីទ័លក្រណាស់នោះចូលធ្វើជាទាហានបានផង ។ វិធីនេះជាវិធីល្អមួយយ៉ាងដែរ ដើម្បីជួយឲ្យក្រុងរ៉ូមមានទាហានថែមច្រើនឡើងទៀត តែនាំឲ្យខូចកេរ្តិ៍ឈ្មោះជាច្រើន គឺពួកនេះស្ម័គ្រចិត្តចូលធ្វើទាហាន ដើម្បីទៅប្លន់យកទ្រព្យសម្បត្តិខាងសឹកសត្រូវ ក្នុងវេលាមានជ័យជំនះ ។ ទាហានអស់នេះមិនសូវគោរពកោតក្រែងច្បាប់ទេ គោរពខ្លាចតែមេទ័ពម្នាក់ប៉ុណ្ណោះ ទើបជាឱកាសល្អដល់មេទ័ពបង្គាប់ឲ្យទៅប្លន់ទ្រព្យសម្បត្តិអ្នកស្រុកជារឿយៗ ហេតុនេះហើយបានជាមុខក្រសួងបញ្ជាការកងទ័ព ទើបគេត្រូវការប្រាថ្នាចង់បានណាស់ កាលណាមានសង្គ្រាមកើតឡើង ពួកមេទ័ពច្រើនតែដណ្ដើមគ្នាធ្វើជាមេទ័ពនាំទ័ពចេញច្បាំង ព្រោះជាផ្លូវហូរចូលមកនៃទ្រព្យសម្បត្តិជាចំនួនច្រើន ។

កាលម៉ារីយុសបានចាត់ការប្រែប្រួលដូចបានពោលមកនេះហើយ ក៏លើកកងទ័ពចេញទៅប្រាបប្រាមស៊ុគុរថា ចាប់ខ្លួនស៊ុគុរថាចូលមកក្រុងរ៉ូម ហើយដាក់គុកទាល់តែស្លាប់ទៅ (មុនគ.ស.១០៤) ។ កាលម៉ារីយុសមានជ័យជំនះគ្រានេះ ក៏បានទទួលដំណែងជាកុងស៊ុលតទៅទៀតជាច្រើនឆ្នាំ ព្រោះបានទទួលដំណែងជាអ្នកប្រាបប្រាមពួកស៊ីមប្រ៍និងពួកតឺតុង៍ (Cimbres et Teutons) ដែលចូលមកលុកលុយប្រទេស

ឥតាលី ។ មនុស្ស ២ ពួកនេះ ជាជនជាតិអល្លឺម៉ង់ (ពួកក្រិកនិងពួករ៉ូម៉ាំង ច្រើនហៅថាមនុស្សព្រៃទាំងអស់ ប៉ុន្តែបើពោលតាមពិតនោះ មិនមែនជាមនុស្សព្រៃឡើយ ) ដែលលើកទ័ពមកពីខាងសមុទ្របាល់ទិក (Baltique) ហើយចេញដំណើរដើរកាត់ផែនដីដ៏ធំទូលាយក្នុងទ្វីបអឺរ៉ុប ព្រមទាំងប្រពន្ធកូន សត្វពាហនៈនិងយានជំនិះ ដើម្បីរកទីកន្លែងតាំងស្រុកទេសថ្មីឡើង ។ ពួកនេះបានកាត់និងទំលាយស្ពានផ្សេងៗតាមផ្លូវដែលខ្លួនលើកទ័ពទៅ ហើយបានសម្លាប់ពួកទាហានរ៉ូម៉ាំងអស់ជាចំនួនច្រើន ។ ក្នុងវេលានោះ ពួកទាហានរ៉ូម៉ាំងដែលតាំងស្អាកច្បាំងនឹងមនុស្សព្រៃអស់នោះ មិនមែនជាពួកទាហានដែលមានថ្វីដៃ ថែមទាំងកងកាយនិងកំឡាំងមិនសូវរឹងប៉ឹង ក៏ស៊ូពួកអល្លឺម៉ង់មិនបាន តែចួនជាគ្រាគ្រោះល្អនៃក្រុងរ៉ូម ព្រោះពួកមនុស្សព្រៃនេះមិនបានលើកទ័ពតំហុកហួសចូលទៅក្នុងក្រុងរ៉ូមវេលានោះទេ បែរជាវិលទៅកាយប៉ូទខាងប្រទេសអេស្ប៉ាញវិញ ទើបធ្វើឲ្យម៉ារីយុសមានឱកាសល្មមហ្វឹកហាត់ពួកទាហានរ៉ូម៉ាំងឲ្យបានខ្លាំងពូកែឡើង ។ លុះពួកមនុស្សព្រៃអស់នោះត្រឡប់វិលមកក្រុងរ៉ូមទៀត ទើបត្រូវកងទ័ពម៉ារីយុសច្បាំងទប់ទល់និងសម្លាប់មនុស្សព្រៃអស់នោះបានជាចំនួនច្រើនដល់ ១២០.០០០ នាក់ ។

កាលម៉ារីយុសបានធ្វើកិច្ចសំខាន់ៗសម្រេចបានជាច្រើនលើកដូច្នេះ ទើបធ្វើឲ្យម៉ារីយុសកាន់តែមានអំណាចក្នុងដែនដីរ៉ូមច្រើនឡើងទៀត

បានធ្វើការជួយទំនុកបំរុងជនអ្នកទ័លក្រ ដោយវិធីបែងចែកដីឲ្យយកទៅធ្វើការរកស៊ី នឹងចំណាយចំណីអាហារឲ្យដោយដៃខ្លួនគេៗ ។ ក្រៅពីនេះ សេណាត់ដែលជាសភាខ្ពង់ខ្ពស់បំផុតរបស់ក្រុងរោមតាំងអំពីដើមមកនោះ ក៏ត្រូវម៉ារីយុសបន្ថយអំណាចឲ្យមកនៅក្រោមច្បាប់វិញ ហើយបន្ថែមអំណាចរបស់ប្រជាជនអ្នកស្រុកឲ្យមានច្រើនឡើង បានចេញប្រកាសបញ្ញត្តផ្តល់ទោសប្រហារជីវិតចំពោះឈ្មោះណាមួយដែលព្យាយាមផ្តាច់ផ្តិលសិទ្ធិអំណាចរបស់រាស្ត្រប្រជា ។ វិធីនេះក៏ល្អណាស់ដែរ តែម៉ារីយុសអាងផ្តល់បញ្ញត្តិនេះ ហើយកាប់សម្លាប់មនុស្សលេងតាមអំពើចិត្ត ហេតុការណ៍ទាំងនេះធ្វើឲ្យប្រជាជនអាក់ប្រចិត្តគំនិតលែងស្រឡាញ់ម៉ារីយុស ។ ឯពួកជនជាន់អ្នកមានត្រកូលនិងអ្នកមានសម្បត្តិ ជាពួកដែលស្អប់ម៉ារីយុសស្រាប់តាំងពីដើមមកហើយ ក៏បែរជាមានអំណាចឡើងវិញដោយមានមនុស្សសំខាន់ម្នាក់ជាប្រមុខឈ្មោះស៊ីល្ល៉ា ។

ស៊ីល្ល៉ាជានាយទាហានម្នាក់របស់ម៉ារីយុស តាំងអំពីកាលម៉ារីយុសលើកទ័ពទៅច្បាំងច្បាមយុគុរថា ជាអ្នកកើតក្នុងត្រកូលខ្ពង់ខ្ពស់ មានសតិបញ្ញាឆ្លៀវឆ្លាត អធ្យាស្រ័យល្អ បានធ្វើការសំខាន់ ១ ជាថ្នាក់ដំបូង គឺច្បាប់ច្បាមពួកឥតាលីដែលបង្កការចលាចលបានសម្រេច ទើបពួកជនជាន់ខ្ពស់ព្រមទាំងសភាសេណាត់ក៏ជឿទុកចិត្ត

(មានត)

# ភូមិសាស្ត្រសង្ខេបនៃនានាប្រទេស

## អំពីភូមិសាស្ត្រសង្ខេបនៃប្រទេសអារ៉ាប់

**ទីតាំងនិងអាណាខេត្ត** នៅទិសខាងជើងនៅក្នុងរយៈទេង អង្សា ១២ ទីង ៣២ ហើយទិសខាងកើតនៅក្នុងរេងអង្សា ៣៥ ទីង ៦០ ។ អាណាខេត្តទិសខាងជើងទល់នឹងប្រទេសអ៊ីរ៉ាក់ ស៊ីរីនិងត្រង់ស្សូរដានី ទិសខាងលិចទល់នឹងសមុទ្រក្រហម ទិសខាងកើតទល់នឹងឈូងសមុទ្រពែរ្ស៊ិក ទិសខាងត្បូងទល់នឹងសមុទ្រអារ៉ាប់ ។

**ទំហំដី** — ប្រមាណ ២.៥៩០.០០០ គីឡូម៉ែត្រក្រឡា ជាជ្រោយសមុទ្រធំបំផុតមួយ ។

**ផ្ទៃផែនដី** — ផ្ទៃផែនដីនៃជ្រោយសមុទ្រអារ៉ាប់ មានលក្ខណៈជាទីរាបខ្ពស់ទូទៅ មានកំពស់តាំងពី ៧៥០ ដល់ ២.១០០ ម៉ែត្រ នៅតំបន់ទិសខាងលិចខ្ពស់ជាងទិសខាងកើត ទីដីទំនាបមានតែតាមជាយមាត់សមុទ្រ ផ្ទៃផែនដីមានតែក្រួសនិងខ្សាច់ទូទៅ វៀរលែងតែក្នុងប្រទេសអូម៉ង់និងយេមេន សមុទ្រខ្សាច់នៅទិសខាងជើង សមុទ្រខ្សាច់នេហ្វូតនៅកណ្ដាល សមុទ្រខ្សាច់រេប៉ល-ខាលីនៅទិសខាងត្បូង សឹងមិនមានព្រៃព្រឹក្សានិងទន្លេធំៗទេ មានតែជ្រោះជ្រលងដងអូរដែលហូរតៗគ្នាចុះទៅក្នុងបឹងត្រពាំង នៅកណ្ដាលសមុទ្រខ្សាច់ ៗ នៅតាមតំបន់បរិវេណដែលមានបឹងត្រពាំង

ដងក្សា ច្រើនមានដីដ៏ជាតិល្អ ដំណាំដុះល្អគួរណាស់ល្អ តំបន់ដូច្នេះហៅថា អូអាស៊ីស មានមនុស្សទៅតាំងភូមិលំនៅៗជាច្រើន ។

ភ្នំ — ជួរភ្នំដែលវែងបំផុតនៅជ្រោយសមុទ្រនេះ គឺភ្នំទីហាម៉ា ដែលលាតសន្ធឹងទៅតាមមាត់ច្រាំងសមុទ្រទិសខាងលិច កំពូលភ្នំដែលខ្ពស់ៗនៅទិសខាងត្បូង កំពូលមានកំពស់ពី ២.៧០០ដល់ ៣០០០ម៉ែត្រក៏មាន ជួរភ្នំធំ១ផ្នែកទៀតនៅទិសខាងកើតឆៀងខាងត្បូងក្នុងប្រទេសអូម៉ង់ គឺភ្នំជេបេលអក្តារ កំពស់ពី ២.៧០០ ដល់ ៣០០០ ម៉ែត្រដែរ ។

ខ្យល់អាកាស — ក្នុងប្រទេសអូម៉ង់, យេមេន និងដែនអាស៊ីរ មានអាកាសល្អជាងប្រទេសដទៃៗទាំងអស់ គឺមានក្តៅត្រជាក់យ៉ាងកណ្តាល ក្នុងប្រទេសដទៃៗនៅជ្រោយសមុទ្រអារ៉ាប់ច្រើនតែមានអាកាសក្តៅខ្លាំងក្នុងរដូវក្តៅ រងាខ្លាំងក្នុងរដូវរងា ដូចជាប្រទេសនេជ៌ត ក្នុងរដូវរងា ត្រជាក់អាកាសចុះទាបដល់ ០៦ ក្នុងរដូវក្តៅឡើងដល់ ១១៦ ក៏មាន ។

ភ្លៀងធ្លាក់នៅប្រទេសអូម៉ង់, យេមេន, និងដែនអាស៊ីរប្រមាណ ៣០៥ មិល្លីម៉ែត្រក្នុង ១ ឆ្នាំ ។ ឯប្រទេសឯទៀតៗមិនសូវមានភ្លៀងឡើយ ។

ដំណាំ — ដីដែលដាំដំណាំមានផលល្អមានតិចទេ ការធ្វើស្រែចំការច្បារដំណាំមានតែនៅតាមតំបន់ជាយសមុទ្រ និងអូអាស៊ីស នៅ

កណ្តាលសមុទ្រខ្សាច់ ។ ដំណាំដែលដាំច្រើន គឺ កាហ្វេ, ល្ង, ស្រូវផ្សេងៗ, ថ្នាំជក់, ឪឡឹក, ល្ពៅ, អំពៅ, គរ, កប្បាស, ដូងជាដើម ។

សត្វ — មានសេះ, លា, ចចក, ទន្សាយ, ឆ្កែព្រៃ, ខ្លា, ឆ្មាព្រៃ, សត្វអូទ្រីស, រមាំង, ក្តាន់, ពពែ, កែះ, ឱដ្ឋ ។

លោហធាតុ — មានដែក, សំណ, ទង់ដែង, ធ្យូងថ្ម, និងពេជ្រ ត្បូងផ្សេងៗ ។

ជ្រោយសមុទ្រអារ៉ាប់នេះគេស៊ីលក់ដូរនឹងប្រទេសអង់គ្លេស, ឥណ្ឌា, អៀរ៉ង់, និងអ៊ីរ៉ាក់ដោយច្រើន ។ ដំនូញដែលវិញចូលមកមាន ស្រូវ, ម្សៅ, ស្ករ, តែ, គ្រឿងសំលៀកបំពាក់, គ្រឿងដែក, និងរថយន្តជាដើម ។

ប្រជាជន — មានប្រមាណ ១០.០០០.០០០ នាក់ នៅក្នុងប្រទេសនេត់សេក ប្រមាណ៥លាន, ក្នុងប្រទេសយេមេន ៣.៥០០.០០០, ក្នុងប្រទេសអូម៉ង់, ៥០០.០០០ ក្នុងតំបន់ផ្សេងៗ ក្រៅពីនេះប្រមាណ ១ លាន ។

សាសនា — ពួកអារ៉ាប់កាន់សាសនាអ៊ិស្លាមនិកាយស៊ុនី ។

ស្រុកកំពង់ — សេដ្ឋា ជាស្រុកកំពង់សំខាន់បំផុតរបស់ប្រទេសនេត់សេក ។

ហូដេដា – ជាស្រុកកំពង់របស់ប្រទេសយេម៉ុន លក់កាហ្វេជាជំនួញចេញជាច្រើន ។

មុកាល្លា – ជាទីក្រុងរបស់ប្រទេស ហ័ដ្រាម៉ាអូត ហើយជាស្រុកកំពង់ធ្វើការលក់ដូរនឹងប្រទេសឥណ្ឌា ។

**ស្រុកសំខាន់ៗ** — អែរីយ៉ាត-ជាទីក្រុងរបស់ប្រទេសនេត៍សេត

មេក្កា – ជាទីក្រុងរបស់ប្រទេសហេត៍សាស ពួកជនអ៊ិស្លាមតែងនាំគ្នាទៅនមស្សការព្រះនៅស្រុកនេះ ក្នុងឆ្នាំៗជាច្រើនសែននាក់ ស្រុកនេះជាស្រុកកំណើតរបស់ព្រះមហាម៉ាត់ ។

មះឌីន - ជាស្រុកមានជំនួញលក់ដូរច្រើន សពព្រះមហាម៉ាត់កប់នៅស្រុកនេះ ។

ហៃហល់ – ជាទីក្រុងរបស់ដែនផាំម៉ា

សាប៊ីយ៉ា - ជាទីក្រុងរបស់ដែនអាស៊ីរ

សាណា – ជាទីក្រុងប្រទេសយេមេន

ម៉ស្កាត – ជាទីក្រុងប្រទេសអូម៉ង់ ។

**របៀបរាជការ** — ក្នុងសម័យនេះ អាណាចក្រផ្សេងៗរបស់ពួកអារ៉ាប់ស៊ើរតែរួបរួមគ្នាតែមួយ ក្រោមអំណាចព្រះមហាក្សត្រប្រទេសនេត៍សេត អំណាចអធិបតីទាំងពួងជារបស់ព្រះមហាក្សត្រតែមួយ ព្រះអង្គៗ

ក្រៅពីនេះ អ្នកគ្រប់គ្រងអាណាចក្រទាំងពួងស្ទើគ្រប់លនៅក្នុងអាណាព្យាបាលរបស់អង់គ្លេសទាំងអស់ មានស្រុកចំណុះអង់គ្លេសតូចៗពីរស្រុក គឺអាដែននិងកោះប៉េរីម ដែលនៅចំត្រង់ច្រកសមុទ្រក្រហម ។ ស្រុកអាដែន (ជាចំណុះអង់គ្លេសតាំងពី ព.ស.២៣៨២) ជាស្រុកកំពង់សំខាន់បំផុតនៅភាគខាងលិចឆៀងខាងត្បូងនៃទ្វីបអាស៊ី ។

ប្រទេសយេមែន— មានទំហំដីប្រមាណ ១៩៤.២៤០ គីឡូម៉ែត្រក្រឡា ចំនួនមនុស្ស ៣.៥០០.០១០ នាក់ ប្រទេសនេះតាំងនៅលើទីដីកម្ពស់ ដែលជាទីល្អបំផុតនៅជ្រោយសមុទ្រអារ៉ាប់ ទើបមានការដាំដំណាំជាច្រើន គឺ កាហ្វេ, ស្រូវផ្សេងៗ ។ ដំនួញលក់ចេញដែលសំខាន់ គឺកាហ្វេ, ស្បែកសត្វនិងក្លក ។

ប្រទេសអូម៉ង់ — ទំហំដី ២១២.៣៨០ គីឡូម៉ែត្រក្រឡា ចំនួនមនុស្ស ៥០០.០០០ នាក់, ស្រុកម៉ាស្កាតជាទីក្រុង, ស្រុកស្ហូរជាស្រុកកំពង់ធំបំផុត ដំនួញលក់ចេញមានផ្លែល្មើ, ផ្លែទទឹម, ក្រូចឆ្មានិងត្រីទៀត ។

ហ៍ដ្រាម៉ាអ៊ូត — ទំហំដី ២២០.៦៦៥ គីឡូម៉ែត្រក្រឡា ចំនួនមនុស្ស ១២០.០០០ នាក់ មានស្រូវនិងស្ករជាដំនួញលក់ចេញ ។

ចប់

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែ ១ ក្បាល

ឆ្នាំគំរប់ ១៤ ភាគទី ១១-១២

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ


ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៩៥

គ.ស. ១៩៥២

# បញ្ជីរឿង


ទំព័រ

១ — វិទ្យុធម្មទេសនា កណ្ឌទី ៥ លោកគ្រូអាចារ្យ ម៉ុញ-ឆាត្រី ក្រុមជំនុំព្រះត្រៃបិដក នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ សំដែង . . . . . . . . . . . . . . . . ១

២ — សេចក្ដីផ្សេងៗ . . . . . . . . . . . . . . . . . . . . . . ១២

៣ — លោកនេយ្យ ពាក្យកាព្យ របស់ឧកញ៉ាវង្សាសពេជ្ញ នង (តមក) . . . . . ២០

៤ — រឿងព្រះបាទអសោកមហារាជ អ្នកអាចារ្យ គឹម-អាន ប្រែពីបារាំងសេសមក-ជាខេមរភាសា (តមក) . . . . . . . . . . . . . . . . . . . ២៧

៥ — ពង្សាវតារក្រុងទេព ស្រង់យកពីពោលចារិកផ្សេងៗ ក្នុងពង្សាវតារលោក (តមក) . . . . . . . . . . . . . . . . . . . . . . . . ៣៣

៦ — ភូមិសាស្ត្រសង្ខេបនៃប្រទេសនានា: អំពីភូមិសាស្ត្រទ្វីបអាមេរិកខាងជើង. . . . ៤១

៧ — ប្រវត្តិពួកឧបាសក-ឧបាសិកា ជាសាវក-សាវិការបស់ព្រះពុទ្ធជាម្ចាស់ : ទី ៩ ប្រវត្តិជីវកកោមារភច្ច ទី ១០ ប្រវត្តិនកុលបិតាគហបតិ . . . . . . . . . . ៤៨

៨ — ប្រស្នាចំរើនសតិបញ្ញា: ប្រស្នាទី ២ សួរនិងឆ្លើយអំពីខ្វាក់នឹងខ្វិន . . . . . . ៥១

៩ — រឿងព្រេងខ្មែរ: « រឿងចៅម្ចាស់ផ្ទះនិងចៅសុំសំបត» . . . . . . . . . . ៥៤

# TABLE DES MATIÈRES

Pages

1. VIDYUDESANĀ (prédication faite à la Radio Phnôm-Penh), par le Vénérable MINH-NAGHI, membre de la Commission du Tripitaka .................................... 1

2. Notes variées .................................... 12

3. LOKANEYYA, poème par feu l'OKNHA VONGSASARPEJÑA NONG (suite) .................................... 20

4. Légende de l'Empereur Açoka de l'Inde antique, traduit par feu l'Achar KIM-ANN (suite) .................................... 27

5. Histoire de Rome. Extraits de divers documents de l'histoire universelle (suite) .................................... 33

6. Géographie sommaire de divers pays : l'Amérique du Nord .. 41

7. Vies des disciples laïcs du Bouddha. IX : Vie de JIVAKA. X : Vie de NAKULAPITA .................................... 48

8. Réflexions sur les phénomènes naturels : Dialogue sur l'aveugle et le paralytique .................................... 51

9. Conte populaire cambodgien inédit : " Un maître de maison et son hôte " .................................... 54

វិទ្យុធម្មទេសនា ទាណ្ឌាទី ៥

# លោកគ្រូអាចារ្យ មុិញ-ឆ៉ាគ្រី

ក្រុមជំនុំព្រះត្រៃបិដក ក្រសួងពុទ្ធសាសនបណ្ឌិត្យ សំដែង

នៅថ្ងៃ ១៥ កើត ខែចេត្រ ឆ្នាំម្សាញ់ត្រីស័ក ព.ស. ២៤៨៥ (៣១ ម៉ារ្ស ឆ្នាំ ១៩៤២) ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

វេលានេះត្រូវវេនអាត្មាភាពសំដែងធម្មទេសនា ចែកជូនដល់អស់លោក-អ្នកទាំងឡាយ ដើម្បីជាសណ្ដាប់ដូចសេចក្ដីតទៅនេះ:

"មត្តញ្ញុតា សទា សាធុ"

"បុគ្គលអ្នកស្គាល់ប្រមាណរមែងញុំាងប្រយោជន៍ឲ្យសំរេចគ្រប់កាល"

ធម្មភាសិតនេះ សរសើរបុគ្គលអ្នកស្គាល់ប្រមាណថា អាចធ្វើប្រយោជន៍ឲ្យសំរេចបានគ្រប់កាល គ្រប់សម័យ ដូចសេចក្ដីតទៅនេះ:

មត្តញ្ញុតា ភាពជាអ្នកស្គាល់ប្រមាណ គឺស្គាល់ថា ការធ្វើយ៉ាងនេះសម យ៉ាងនេះល្អ យ៉ាងនេះត្រូវទំនងចុះរបៀប ធ្វើយ៉ាងនេះសំរេចប្រយោជន៍ ។

ការស្គាល់ប្រមាណនេះ មានន័យទូ ពណ៌នាបានដោយពិស្ដារជាអនេក តែបើរើសស្រង់ប្រមូលមកទុកជាគោលមាន ៥ ប្រការគឺ:

១– ការដឹងប្រមាណក្នុងទ្រព្យសម្បត្តិ

២– ការដឹងប្រមាណក្នុងកិច្ចការ

៣– ការដឹងប្រមាណក្នុងការរក្សាកាយ

៤– ការដឹងប្រមាណក្នុងបុគ្គល

៥– ការដឹងប្រមាណក្នុងធម៌

## ទី ១ — ការដឹងប្រមាណក្នុងទ្រព្យសម្បត្តិ

ការដឹងប្រមាណក្នុងទ្រព្យសម្បត្តិ ចែកចេញដោយប្រភេទជា ៣ ប្រការ គឺ ស្គាល់ប្រមាណក្នុងការស្វែងរក ១, ស្គាល់ប្រមាណក្នុងការរក្សា ១ ស្គាល់ប្រមាណក្នុងការបរិភោគប្រើប្រាស់ ១ ។

ស្គាល់ប្រមាណក្នុងការស្វែងរក គឺចេះលៃលករកទ្រព្យក្នុងការស្វែងរកដែលត្រូវតាមគន្លងធម៌ មិនស្វែងរកដោយអាការកុហកករកូតបញ្ឆោត បោកប្រាស់បំបាត់ប្រវញ្ចន៍ លួចប្លន់ដណ្តើមអ្នកដទៃ ដោយកិច្ចកលចោរកម្ម មិនបន្លំដោយក្លែងថ្លឹង តែកៀសបំផ្លាញដោយរង្វាល់នាឡិ តៅ-កន្ទាំង បំបិទបំបាំងបន្លាតបន្លួចទ្រព្យអ្នកដទៃ លៃយកចំណេញដោយទុច្ចរិត ដែលចាត់ចូលក្នុងជំនួញប្រាំប្រការ ឬមន្ត្រីដែលលុះអំណាចអគតិធម៌ ស៊ីសំណូកសូកអង្វរសង្កត់សង្កិនប្រជា ក៏ហៅថា ការស្វែងរកមិនត្រូវគន្លងធម៌ដោយពិត ។

ការស្វែងរកដោយឧបាយទុច្ចរិត ព្រះពុទ្ធទ្រង់ហាម ព្រោះជាហេតុធ្វើឲ្យអ្នកដទៃមានសេចក្ដីក្ដៅក្រហាយនិងនាំឲ្យជួបប្រទះទៅលើទុក្ខទោសគ្រោះថ្នាក់ច្រើនប្រការ ឈ្មោះថាស្វែងរកសេចក្ដីទុក្ខមកដាក់ខ្លួននិងអ្នកដទៃ និងបានសេចក្ដីវិនាសក្នុងលោកទាំងពីរ; ឯការស្វែងរកដោយឧបាយសុចរិត ជាហេតុនាំឲ្យត្រជាក់ចិត្តរបស់ខ្លួននិងអ្នកដទៃ នាំឲ្យទ្រព្យសម្បត្តិឋិតនៅចំរុងចំរើនឡើងតាមលំដាប់ ។

ទ្រព្យសម្បត្តិដែលគេបានមកដោយយុត្តិធម៌យ៉ាងនេះ ត្រូវស្គាល់ប្រមាណក្នុងការរក្សាទ្រព្យថែមទៀត ព្រោះថាទ្រព្យសម្បត្តិដែលគេបានមកនោះ បើបុគ្គលបណ្ដែតបណ្ដោយប្រហែសធ្វេស និងវិនាសបាត់បង់ទៅវិញដោយភ័យផ្សេងៗ មានចោរភ័យជាដើម នាំឲ្យបង់កម្លាំងខ្ជះពេលវេលាដែលខំរកខំធ្វើមកហើយ ជួនកាលនាំឲ្យបង់ទ្រព្យដើមតាមរករបស់ដែលបាត់ទៅទ្វេភាគឡើងទៀត ហេតុនោះបុគ្គលម្ចាស់ទ្រព្យគួរតែប្រយ័ត្នក្នុងការថែរក្សាទ្រព្យសម្បត្តិឲ្យម៉ឺងម៉ាត់ ទើបបានថាជាអ្នកស្គាល់ប្រមាណក្នុងការថែរក្សា ។

បុគ្គលដែលមានទ្រព្យសម្បត្តិ ឈ្មោះថាជាអ្នកមានសេចក្ដីសុខច្រើនប្រការ ព្រោះទ្រព្យសម្បត្តិអាចឲ្យសំរេចប្រយោជន៍ ៥ យ៉ាងគឺ:

១- ចិញ្ចឹមខ្លួន មាតាបិតា បុត្រភរិយា ទាសកម្មករឲ្យជាសុខ

២- ចងមិត្រសម្លាញ់ឲ្យជាសុខ

៣- សម្រាប់បំបាត់ភយន្តរាយដែលកើតអំពីហេតុផ្សេងៗ

៤- សម្រាប់ធ្វើពលិកម្ម ៥ ប្រការគឺ:

ក) ញាតិពលី ការសង្គ្រោះញាតិ

ខ) អតិថិពលី ការទទួលភ្ញៀវ

គ) បុព្វបេតពលី ការធ្វើបុណ្យឧទ្ទិសផលដល់អ្នកស្លាប់

ឃ) រាជពលី ការបង់ពន្ធសួយសារអាករថ្វាយម្ចាស់ផែនដី

ង) ទេវតាពលី ការធ្វើបុណ្យឧទ្ទិសផលថ្វាយទេវតា

៥- បរិច្ចាគទានក្នុងសមណព្រាហ្មណ៍អ្នកប្រព្រឹត្តត្រូវ ។

ការបរិច្ចាគតាមដំណើរនេះ ចាត់ថាស្គាល់ប្រមាណក្នុងការបរិភោគប្រើប្រាស់ ។

មួយទៀត បុគ្គលដែលស្គាល់ប្រមាណក្នុងការប្រើប្រាស់ ចាយវាយទ្រព្យសម្បត្តិតាមកម្លាំងធនធានរបស់ខ្លួន ដឹងអស់ដឹងគង់ដឹងបង់ដឹងបាត់ មិនខ្ជះខ្ជាយគោកាកែតបទឥតសណ្ដាប់ មិនបណ្ដោយឲ្យទ្រព្យធនធ្លាក់ជ្រុះកយកយទៅដោយល្បែងនានាគឺ: ល្បែងស្រី ល្បែងស្រា កញ្ឆា កាតៀន ល្បែងភ្នាល់ផ្សេងៗ មានបៀ-ប៉ោ-ឆូ-អាប៉ោងជាដើម ក៏ចាត់ថាជាអ្នកស្គាល់ប្រមាណក្នុងការប្រើប្រាស់ចាយវាយ ។

មួយវិញទៀត បុគ្គលដែលចេះលៃលកប្រើតាមដំណើរទ្រព្យសម្បត្តិដែលតិចច្រើន មានសណ្ឋានតូចធំក្រាស់ស្ដើង ច្រៀកក់

វែងខ្លី ដាច់ស្រួយ រឹងទន់ ដែលគួរប្រើបានយ៉ាងណា សមរម្យ មិនមានខ្ជង ប្រើយ៉ាងនោះ ក៏ចាត់ថាជាអ្នកស្គាល់ប្រមាណក្នុងការប្រើប្រាស់ ។

រួមការដឹងប្រមាណក្នុងការស្វែងរក ការរក្សាទុកការប្រើប្រាស់ ឈ្មោះថាការដឹងប្រមាណក្នុងទ្រព្យសម្បត្តិ ។

## ទី ២ ការដឹងប្រមាណក្នុងកិច្ចការ

ធម្មតាកិច្ចការក្នុងលោក តែងមានសភាពផ្សេងៗគ្នា កិច្ចការខ្លះលំបាក ខ្លះស្រួលងាយ ខ្លះតូច ខ្លះធំ ខ្លះយូរ ខ្លះឆាប់ តែកិច្ចការទាំងនោះ ទោះបីមានសភាពផ្សេងគ្នាជាអនេកប្បការយ៉ាងណាក៏ដោយ បើប្រមូលមកពណ៌នាដោយសង្ខេបមាន ២ យ៉ាងគឺ: កិច្ចការដែលត្រូវធ្វើដោយកំឡាំងប្រាជ្ញា ១ កិច្ចការដែលត្រូវធ្វើដោយកម្លាំងកាយ ១ ។

វិជ្ជាអក្សរសាស្ត្រ លេខនព្វន្តគុណហារ ហោរាសាស្ត្រ បរមត្ថវិជ្ជា ធម៌វិន័យត្រៃសិក្ខា ហៅថាកិច្ចការដែលត្រូវធ្វើដោយប្រាជ្ញា ។ កិច្ចការហត្ថកម្មសម្រាប់ជាងឈើ ជាងស៊ីម៉ងត៍ អ្នកស្រែអ្នកចម្ការ ដែលជាការត្រូវលើកលីពូនផ្ទួនសែងរែកជាដើម ឈ្មោះថាកិច្ចការត្រូវធ្វើដោយកម្លាំងកាយ ។

និសម្មករណំ សេយ្យោ

កិច្ចការទាំងនោះ បុគ្គលត្រូវពិចារណាឲ្យឃើញជាក់លាក់ហើយ ទើបធ្វើល្អជាង ព្រោះថាអំពើដែលបុគ្គលធ្វើហើយ រមែងតាំងនៅប្រាកដ អស់កល្បាវសាន ដូចជាគំនូសថ្មមិនងាយលុបទៅវិញបាន ។

កតស្ស នត្ថិ បដិការំ

អំពើដែលបុគ្គលធ្វើផ្ដុលហួសដោយកាយក៏ដោ ចិត្តមិនងាយកែប្រែបានទេ ប្រៀបដូចជាផ្ទាំងជាវិការនៃដី ដែលបែកហើយមិនដែលផ្សាភ្ជាប់វិញបានឡើយ ទុកណាជាផ្សាប៉ះប៉ុនបាន ក៏មិនមានរូបសណ្ឋានល្អដូចដើម ។

ន តំ កម្មំ កតំ សាធុ យំ កត្វា អនុតប្បតិ

អំពើណាដែលបុគ្គលធ្វើទៅហើយ ក្ដៅក្រហាយតាមក្រោយ អំពើដែលបុគ្គលធ្វើហើយនោះមិនប្រពៃឡើយ ។

អកតំ ទុក្កដំ សេយ្យោ

អំពើអាក្រក់បុគ្គលកុំធ្វើល្អជាង ។

ន ហិ តំ សុលភំ ហោតិ សុខំ ទុក្កដការិនា

បុគ្គលធ្វើអំពើអាក្រក់ មិនងាយបានសេចក្ដីសុខឡើយ ។

បុគ្គលអ្នកស្គាល់ប្រមាណគុណអំពើដែលខ្លួនធ្វើ ឈ្មោះថាដឹងប្រមាណគុណកិច្ចការ ។

## ទី ៣ ការដឹងប្រមាណក្នុងការរក្សារាងកាយ

រូបរាងកាយរមែងជាទីស្រឡាញ់របស់ជនគ្រប់គ្នា ប៉ុន្តែខ្លះក៏ថែរក្សារូបកាយឲ្យបានសេចក្តីសុខគ្រាន់បើ ខ្លះក៏ត្រឡប់ស្វែងរកសេចក្តីទុក្ខមកបំពេញរាងកាយវិញ ។ ព្រះឈ្មោះមានទ្រង់ត្រាស់ប្រដៅឲ្យរក្សារាងកាយ ដោយវិធីសំអាតភូមិភាគផ្ទះដី គេហដ្ឋាន គ្រឿងសំលៀកបំពាក់ អាហារសម្រាប់បរិភោគ ឲ្យជំរះមន្ទិល កោរសក់ពុកមាត់ កាត់ក្រចក សំអាតធ្មេញជាដើម ឲ្យលលក់ប្រើឥរិយាបថឲ្យស្មើ បរិភោគអាហារល្មមប្រមាណមិនឲ្យឃ្លានពានតាមចំណង់ តមអាហារដែលនាំឲ្យស្វែងដល់រាងកាយ មិនបរិភោគគ្រឿងស្រវឹងគ្រឿងពុល ដែលជាហេតុបណ្តាលឲ្យកើតរោគដល់រាងកាយ ពីព្រោះរោគទាំងអស់មិនមែនសុទ្ធតែកើតមកអំពីផលកម្មទេ មានរោគខ្លះកើតឡើងព្រោះអាស្រ័យហេតុបច្ចុប្បន្ន ព្រះកតវុទ្ធមុនីទ្រង់ត្រាស់សរសើរអំពីគុណនៃការរក្សារាងកាយថានាំឲ្យបានសេចក្តីសុខ មានអាយុវែង ទើបទ្រង់សំដែងថា: . . .

សណិតំ ជីវតិ អាយុំ ចាលំ

អាយុដែលបុគ្គលរក្សា រមែងគ្រាំគ្រាទៅបន្តិចម្តងៗ ។ រួមមកហៅថា ការដឹងប្រមាណក្នុងការរក្សារាងកាយ ។

## ទី ៤ ការដឹងប្រមាណក្នុងបុគ្គល

មនុស្សយើងដែលកើតឡើងក្នុងលោក សុទ្ធតែលែលកឲ្យមានសភាពផ្សេងៗគ្នា: មានរូបរាងខុសគ្នា មានសន្តានចិត្តមិនត្រូវគ្នា មាននាទីមុខក្រសួងកិច្ចការប្លែកគ្នា មានបុណ្យស័ក្តិខ្ពស់ទាបជាងគ្នា មានទ្រព្យធនធានតិចច្រើនជាងគ្នា ព្រមទាំងមានលទ្ធិសាសនាទំនៀមទម្លាប់ផ្សេងគ្នាទៀត; កាលបើមនុស្សមានសភាពផ្សេងៗគ្នាដូច្នេះហើយ ជាហេតុនាំឲ្យមានផ្ទៃគិតជាអនេក ដល់បុគ្គលអ្នកនៅរួមគ្នា អ្នកអាស្រ័យទាក់ទងគ្នា; ហេតុនោះបុគ្គលត្រូវតែចេះវៃឆលាតក្នុងអធ្យាស្រ័យគ្នាទៅវិញទៅមក ដើម្បីរក្សាសេចក្តីសុខឲ្យកើតមានសព្វខ្លួន, បានជាព្រះបរមសាស្តាទ្រង់ប្រដៅគ្រហស្ថឲ្យតាំងនៅក្នុងឃរាវាសធម៌ ៤ ប្រការគឺ:

ទី ១ សច្ចៈ ឲ្យមានសេចក្តីស្មោះត្រង់ចំពោះគ្នានឹងគ្នា ដើម្បីជាទីទុកចិត្តទៅវិញទៅមក គឺៈ មាតាបិតា បុត្រធីតា ត្រូវសំដែងទឹកចិត្តស្មោះសរគ្នា ស្វាមីភរិយាត្រូវសំដែងសេចក្តីស្មោះស្ម័គ្រទៅវិញទៅមក មិនប្រព្រឹត្តក្បត់ចិត្តគ្នា, ចៅហ្វាយនាយបាវព្រាវទៀតសោត ក៏ចេះសំដែងសេចក្តីស្មោះត្រង់ដល់គ្នា ។

២ ទមៈ ចេះទប់ចិត្តរបស់ខ្លួន ចេះទប់សំដីរបស់ខ្លួន ចេះបន្ទន់ចិត្តគ្នា មិនឲ្យកើតសេចក្តីក្រោធបាន ចេះទូន្មានខ្លួននៅវេលាដែលមានឧបសគ្គចូលមកញាំញី ។

៣ ខន្តិ ឬ ធិតិ បើមានសេចក្តីក្រោធឡើងហើយ ចេះបង្ក្រាប ចេះបន្ទយកំហឹងនោះនៅវិញ ចេះលុបលាងកំហុសមិនទទួលរំលឹកឡើង ខុសមកពោលដដែលៗ ចេះលៃលករកឧបាយឲ្យស្ងប់សេចក្តីក្រោធ មិនព្យាបាទអាឃាតចងពៀរគេទៅ ។

៤ ចាគៈ ចេះចែកចាយអាហារចំណីគ្រឿងឧបភោគបរិភោគដល់ គ័ត្តា ។

យស្សេតេ ចតុរោ ធម្មា សទ្ធស្ស ឃរមេសិនោ
សច្ចំ ធមោ ធិតិ ចាគោ ស វេ បេច្ច ន សោចតិ ។

ធម៌ ៤ ប្រការគឺៈ សច្ចៈ ធម្មៈ ធិតិៈ ចាគៈ នេះ បើគ្រហស្ថឯណាមានជំនឿកាន់ប្រព្រឹត្ត គ្រហស្ថនោះនឹងមិនមានសេចក្តីទុក្ខព្រួយក្នុងលោកខាងមុខថែមទៀត ។ រួមមកហៅថា ការដឹងប្រមាណក្នុងបុគ្គល ។

## ទី ៥ ការដឹងប្រមាណក្នុងធម៌

ការដឹងប្រមាណក្នុងធម៌នេះ មានន័យត្រូវញែកអធិប្បាយជា ៣ យ៉ាងគឺៈ ដឹងប្រមាណក្នុងការរៀនសូត្រស្វាធ្យាយធម៌ ១ ដឹងប្រមាណក្នុងការសំដែងនិយាយពន្យល់ធម៌ ១ ដឹងប្រមាណក្នុងការប្រតិបត្តិធម៌ ១ ។

ការចេះលៃលកទន្ទេញស្វាធ្យាយពិនិត្យពិចារណាឲ្យបានចូលចិត្ត ជាក់លាក់ ចេះចាំច្បាស់ស្ទាត់ជំនាញ ចាត់ជាស្គាល់ប្រមាណក្នុងការរៀនសូត្រ ។

សេចក្ដីឈ្លាសវៃក្នុងការសំដែងធម៌តាមដំណើរបរិស័ទដែលចេះដឹងតិចច្រើន តាមឧកាសពេលវេលា ចាត់ជាស្គាល់ប្រមាណក្នុងការសំដែងធម៌ ។

សេចក្ដីឈ្លាសវៃយល់ទំនងក្នុងការប្រព្រឹត្តការកាន់កាម ដូចដឹងថា ការធ្វើបរិច្ចាគយ៉ាងនេះ ទើបមានផលច្រើន, ឲ្យយ៉ាងនេះមានផលតិច; សីលត្រូវរក្សាដូច្នេះ ទើបបរិសុទ្ធ, កាន់ដូច្នេះសៅហ្មងពពាលពព្រុះ ដាច់ធ្លុះធ្លាយ; ភាវនាត្រូវចំរើនតាមរបៀបនេះ ទើបងាយសំរេចគុណតាមថ្នាក់ដែលគួរសំរេច ដូច្នេះជាដើមឈ្មោះថាស្គាល់ប្រមាណក្នុងការប្រតិបត្តិធម៌ ។

បុគ្គលអ្នកស្គាល់ប្រមាណក្នុងការប្រតិបត្តិធម៌ នឹងបានទទួលផលអំពីព្រះធម៌វិញ សមដូចព្រះលោកនាថទ្រង់ត្រាស់ថា:

ធម្មោ ហវេ រក្ខតិ ធម្មចារឹ ។

ព្រះធម៌រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ (អ្នករក្សាធម៌) រួមការដឹងប្រមាណក្នុងមាតិកាទាំង ៤ ដែលបានពណ៌នាដោយសង្ខេបមកនេះ ឈ្មោះថា "មត្តញ្ញុតា អ្នកស្គាល់ប្រមាណ" ។

បុគ្គលអ្នកដឹងប្រមាណ បាននាមថាជាសប្បុរស, បណ្ឌិត, អ្នកប្រាជ្ញ ខ្ពស់ទៅក្នុងលោក ។

ការដឹងប្រមាណ ចាត់ជាគុណធម៌មួយយ៉ាងវិសេសដែលគួរប្រាថ្នា ខានពុំបាន ព្រោះជាគុណញុំាងប្រយោជន៍ឱ្យសំរេចគ្រប់កាលគ្រប់សម័យ សមដូចពុទ្ធភាសិតដែលបានអានទុកខាងដើមថា:

មត្តញ្ញុតា សទា សាធុ ។

អាចារ្យ ម៉ុញ-ត៉ាត្រី

## សេចក្តីផ្សេងៗ

### អំពីមុខក្រសួងគ្រួសារក្នុងព្រះពុទ្ធសាសនា

កាលព្រះពុទ្ធសាសនាផុសប្រាកដឡើងក្នុងដែនទេសឥណ្ឌានោះ ឯរបៀបគ្រួសារក្នុងប្រទេសឥណ្ឌាគង់មានយូរណាស់មកហើយ ទើបគេមិនឃើញស្នាមលំអានក្នុងគម្ពីរពុទ្ធសាសនា ដើម្បីសើរើរៀបចំច្បាប់សម្រាប់គ្រួសារដូចជារបៀបដែលមាននៅក្នុងសព្វថ្ងៃនេះ សូម្បីក្នុងវេលាក្រោយៗ សង្គាយនាមកទៀតក៏មិនឃើញមានដែរ ។ តែទុកជាយ៉ាងណាក៏ដោយ ធម្មៈបានចូលជ្រែកនៅក្នុងគ្រួសារ ព្រមទាំងឱវាទរបស់ព្រះពុទ្ធជាម្ចាស់ ដែលបានកែប្រែទំនៀមទម្លាប់ខ្លះដោយពិតពុំខាន ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ទូន្មានឱវាទដ៏សំខាន់មួយ ដើម្បីឲ្យយើងសំដែងសេចក្តីគោរពគួរសមដល់ចាស់ព្រឹទ្ធាចារ្យ សឹងមានសំដែងក្នុងរឿងផ្សេងៗជាច្រើន ដូចមានសំដែងក្នុងគាថាធម្មបទទី ១០៩ ថា "អ្នកឯណាមួយសំដែងសេចក្តីគោរពនិងឱនលំទោនដល់ចាស់ព្រឹទ្ធាចារ្យក្នុងត្រកូលជានិច្ច អ្នកនោះនឹងបានចំរើនដោយធម៌ ៤ ប្រការ គឺ អាយុយឺន, ពណ៌សម្បុរផង, សេចក្តីសុខនឹងកំឡាំង" ។

ក្នុងសិង្គាលោវាទសូត្រ ព្រះពុទ្ធទ្រង់ទូន្មានអំពីកិច្ចដែលត្រូវប្រព្រឹត្តចំពោះមាតាបិតា ភរិយា, កូនប្រុសស្រី, គ្រូ, មិត្រសំឡាញ់និងពួកខ្ញុំ

ប្រុសស្រី ។ កិច្ចប្រតិបត្តិអស់នេះទុកជាចំណែកមួយរបស់ព្រះពុទ្ធសាស-
នាដោយពិត ។ តែព្រះពុទ្ធសាសនាបានបៀសវាងលះបង់នូវសេចក្ដី
ប្រតិបត្តិដែលជឿប្រកាន់ផ្ដេសផ្ដាសទំនងពិធីផ្សេងៗ ដែលជាកិច្ចការខាង
ត្រៃសារ ។ អាពាហ៍ពិពាហ៍ជាកិច្ចមួយរបស់បណ្ដាជន គណៈសង្ឃក៏
មិនចូលទៅប្រជុំជាមួយផងទេ ។ នៅក្នុងប្រទេសដែលប្រកាន់លទ្ធិ
ថេរវាទ ការលះលែងប្ដីប្រពន្ធមានទំនងដូចគ្នា ទោះបីប្ដីក្ដីប្រពន្ធក្ដី
ខាងណាមួយមិនស្មោះត្រង់នឹងមួយទៀតហើយ ត្រូវតែចុះចេញពីផ្ទះទៅ
ឬទាំងពីរនាក់មិនស្រុះស្រួលគ្នា ។ ប្រពន្ធមិនបាច់មានឈ្មោះតាមប្ដីទេ
គឺប្រកាន់តាមឈ្មោះរបស់ខ្លួនពីដើមមក ហើយការធ្វើអាពាហ៍ពិពាហ៍ត្រូវ
មានប្រពន្ធតែមួយប៉ុណ្ណោះ វៀរលែងតែពួកក្សត្រនិងមន្ត្រីធំៗ ។ ក្នុង
ព្រះពុទ្ធសាសនា ស្ត្រីមិនត្រូវបណ្ដែតបណ្ដោយឲ្យទៅកាន់ឋានៈដ៏ថោក
ទាបទេ ស្ត្រីអាចនឹងរៀនសូត្រឲ្យចេះដឹងហើយកាន់កាប់ការសំខាន់ៗ
បាន ។ ទំនងនេះហើយដែលនាំឲ្យប្រទេសដែលកាន់ព្រះពុទ្ធសាសនា
ថេរវាទខ្លះ ដូចជាលង្កា ភូមា និងសៀមឥឡូវនេះ គេបានទំនុកបំរុង
ឲ្យមានចំណេះចេះដឹងស្មើនឹងចំណេះខាងប្រុសហើយ ៗ បានគេរក្សាសេចក្ដី
ប្រតិបត្តិតាមព្រះពុទ្ធសាសនាទុកដោយល្អផង ។ ហេតុនេះហើយ
បានជាយើងមានសេចក្ដីងឿងឆ្ងល់ដែលបានប្រុសស្រីៗក្នុងប្រទេសឥណ្ឌូ-
ស៊ីននេះណាស់ មាតាបិតាជាពុទ្ធសាសនិកជន មិនទំនុកបំរុងកូន

ស្រីឲ្យរៀនសូត្រឲ្យចេះដឹងខ្លួនគេឲ្យនៅល្ងង់ខ្លៅ? ដូច្នេះ ត្រូវតែមាតាបិតា ខំបំពេញមុខក្រសួងរបស់ខ្លួនឲ្យពេញលេញឡើង គឺ

១– ត្រូវធ្វើជាពុទ្ធសាសនិកជនដ៏ល្អ ព្រោះព្រះពុទ្ធជាម្ចាស់ទ្រង់ទូន្មានឲ្យខំរៀនសូត្រឲ្យចេះដឹង ទំនងត្រូវចៀសវាងចាកសេចក្ដីល្ងង់ខ្លៅ ។

២– ត្រូវធ្វើជាជាតិខ្មែរដ៏ល្អ មិនត្រូវភ្លេចថាខ្លួនត្រូវបណ្ដុះបណ្ដាលកូនស្រីៗឲ្យមានចំណេះចេះដឹងច្រើនឡើង ដល់បានធ្វើជាភរិយារបស់បុរសដែលចេះដឹង នឹងបានជាកំឡាំងយ៉ាងធំ ជាម្ដាយដែលប៉ិនប្រសព្វចេះចិញ្ចឹមកូនចៅឲ្យបានសេចក្ដីសុខនិងឲ្យចេះដឹងច្បាប់ធំៗ តាំងអំពីកូននៅក្មេង នឹងឲ្យមានសីលធម៌យ៉ាងល្អឡើងតាមធម្មជាតិផង ។

## អំពីអ្នកធុតង្គធំៗជាតិចិន

### ខាងព្រះពុទ្ធសាសនា

លោកហ្យួន-ឆាង ជាអ្នកធុតង្គជាតិចិនដ៏ល្បីល្បាញបំផុត ដែលបានធ្វើដំណើរទៅប្រទេសឥណ្ឌាកាលពីពុទ្ធសករាជ១១៧២ដល់១១៨៨ ហើយជាគ្រូធម្មទូតពុទ្ធសាសនា ១ រូប ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងប្រទេសចិន ។ មុនលោកនេះ នៅមានអ្នកធុតង្គជាតិចិន ៣ រូបទៀត ដែលទៅកាន់ប្រទេសឥណ្ឌា ក្នុងចំនួននេះ លោក ហ្វា-ហៀន ជាអ្នកធ្វើដំណើរទៅទស្សនាបូជនីយស្ថាននៅប្រទេសឥណ្ឌាជាដំបូង កាលពី

ពុទ្ធសករាជ ៩៤២ ដល់ ៩៥៦ ។ ដល់លោកត្រឡប់មកស្រុកចិនបាន ផ្តើមពិនិត្យមើលគម្ពីរដីកាក្នុងពុទ្ធសាសនា ។ អ្នកធុតង្គ ២ រូបទៀត ឈ្មោះ ស៊ុន-យុន នឹងហៀន-សេង ធ្វើដំណើរទៅក្នុង ព.ស. ៩៦១ តែ មិនសូវមានរឿងរ៉ាវ ឯការដើរធុតង្គរបស់អ្នកធុតង្គជាតិចិនគ្រប់ៗរូបនោះ គេបានរៀបរៀងជាភាសាចិន ហើយគម្ពីរដីកាខាងពុទ្ធសាសនាចំនួន ១៧០ គម្ពីរដែលគេបាននាំយកមកពីប្រទេសឥណ្ឌា ។ តអំពីលោក ហ្វូន-ឆាង មក ទើបមានអ្នកធុតង្គជាតិចិនជាច្រើន នាំគ្នាទៅប្រទេស ឥណ្ឌា ។ ក្នុងចំនួនអ្នកធុតង្គធំៗអស់នេះ លោកអ៊ី-ឈិង ជាអ្នកធុតង្គ ចិនដ៏ល្បីឈ្មោះ១រូបទៀតក្នុងចំនួន៥៦រូប ដែលលោកបានចេញដំណើរ មិនមែនត្រឹមតែប្រទេសឥណ្ឌា១ទេ គឺបានចូលទៅក្នុងប្រទេសមលេស៊ី មួយទៀតផង ជាវេលាតាំងអំពី ព. ស. ១២១៤ ហូត ១២៣៨ ។

លោកហ្វា-ហៀង— មានរឿងដែលបានកត់ត្រាទុកថា លោក នេះបានចេញពីក្រុងចិននៅទិសខាងលិចទៅនៅក្នុង ព.ស. ៩៤២ ហើយ ជាវេលា ៦ ឆ្នាំទើបបានដល់ទៅប្រទេសឥណ្ឌា ហើយសំណាក់ក្នុង ស្រុកនេះជាវេលា ៦ ឆ្នាំទៀត ទើបត្រឡប់ចូលមកក្នុងប្រទេសរបស់ លោកវិញ ក្នុង ព. ស. ៩៥៦ ជាវេលាដើរផ្សំចំនួន ៣ ឆ្នាំ ។ រឿងរ៉ាវ នៃការធ្វើដំណើររបស់លោកមកចប់ចុះក្នុង ព. ស. ៩៥៧ ដែលហៅថា "អំពីប្រទេសកាន់ពុទ្ធសាសនា" ហើយឈ្មោះរបស់លោកនេះគេហៅថា

"មហាសមណៈ" ។ ឯរឿងរ៉ាវរបស់លោក គេបានប្រែចេញពីភាសាចិន មកជាភាសាបារាំងសែសនិងភាសាអង់គ្លេស ។ ក៏កាលដែលលោកហ្វា-ហៀន ចេញដំណើរទៅប្រទេសឥណ្ឌានោះទៅតាមជើងគោក ហើយត្រឡប់មកស្រុកចិនវិញតាមផ្លូវជើងទឹក គឺទៅកាន់កោះលង្កា រួចកោះជ្វា ហើយចូលមកស្រុកចិនខាងត្បូង កាលចេញពីស្រុកចិនទៅនោះ មានសមណៈជាតិចិនរួមដំណើរជាមួយគ្នា ១០ រូប តែដោយហេតុផលផ្សេងៗ ទើបលោកហ្វា-ហៀន មានតែអ្នករួមផ្លូវ ១ រូបដែលបានដល់ទៅប្រទេសឥណ្ឌាជាមួយគ្នា ។ លោកហ្វា-ហៀន បានទៅមើលទីក្រុងជាចំនួនច្រើន ជាទីក្រុងដែលលោកបានទៅមើល ទីក្រុងដែលគួរនាំយកមករៀបរាប់គឺ ក្រុងសាវត្ថី, កបិលវត្ថុ, វេសាលី, កុសិនគរ, បាតលីបុត្រ, រាជគ្រឹះ, គយា, ពារាណសី ។ អ្នកធុតង្គចិនទៅតាំងទីសំណាក់នៅក្រុងបាតលីបុត្រ ដើម្បីប្រមូលនិងចម្លងយកច្បាប់គម្ពីរដីកាពុទ្ធ-សាសនាដែលមាននៅក្នុងនិកាយផ្សេងៗ ឯអ្នកធុតង្គ ១ រូបទៀតដែលជាមិត្តដើរផ្លូវជាមួយនឹងលោកហ្វា-ហៀន នោះ បានពេញចិត្តគំនិតទៅតាមវិធីដែលខ្នាន់ចិត្តឲ្យផ្ទួរផង់នឹងចំណោះវិជ្ជារបស់គណៈសង្ឃពុទ្ធសាសនា នៅប្រទេសឥណ្ឌា ក៏ដាច់ចិត្តនៅនឹងប្រទេសឥណ្ឌានោះទៅ ។ ឯលោកហ្វា-ហៀនយល់ថា ខ្លួនលោកត្រូវតែត្រឡប់ទៅប្រទេសចិនវិញ ដើម្បីបំភ្លឺប្រជាជនអ្នកស្រុក និងបំភ្លឺសេចក្តីប្រតិបត្តិដ៏ត្រឹមត្រូវដល់

លោកសង្ឃចិនផង ។ លោកនេះចេញពេលមិត្តរួមផ្លូវរបស់លោកចុះទៅតាមទន្លេគង្គា ហើយដើរកាត់ប្រទេសឥណ្ឌូស៊ីនទាំងផង ។ លោកនេះបានពោលអំពីនិកាយពុទ្ធសាសនាបែបហីនយានទាំងបែបមហាយានដែរ តែមិនបាននិយាយអំពីការប្រណាំងប្រជែងគ្នាក្នុងរវាងនិកាយទាំង ២នេះឡើយ គឺបានសេចក្ដីថា ក្នុងសម័យនោះនិកាយទាំងពីរមានសេចក្ដីស្រុះស្រួលមូលគ្នាល្អ ។

ឯការធ្វើដំណើររបស់អ្នកធុតង្គឈ្មោះហៀន-ឆាំង ជារឿងរ៉ាវសំខាន់មួយដែរ សម្រាប់សិក្សាឲ្យដឹងពង្សាវតារនិងភូមិសាស្ត្ររបស់ប្រទេសឥណ្ឌាផ្នែកខាងពុទ្ធសាសនា ។ លោកបានរៀបរៀងរឿងរ៉ាវរបស់លោកជាភាសាសំស្ក្រឹត រួចគេជាភាសាចិនហើយបែងចេញជាផ្នែកៗជាច្រើនផ្នែកគឺ: ១ – ពណ៌នាអំពីផ្លូវថ្នល់ដែលមាននៅក្នុងលោក រួចពណ៌នាអំពីប្រទេសឥណ្ឌា ២ – អំពីការពិនិត្យសិក្សាយ៉ាងជ្រៅជ្រះ អំពីឈ្មោះ, ភូមិសាស្ត្រ, ថ្ងៃខែឆ្នាំ, កិច្ចការរបររកស៊ី, ភាសា, ទំនៀមទម្លាប់, សាសនា, ពួកវណ្ណ, ផលាផល, ៣ – អំពីសេចក្ដីពណ៌នាយ៉ាងពិស្ដារអំពីស្រុកមគធៈនិងនាឡន្ទា, ៤ – អំពីប្រទេសឥណ្ឌាខាងត្បូង; ៥ – អំពីផ្លូវដែលត្រឡប់មកវិញ ។

ក្នុងការដើរផ្លូវទៅប្រទេសឥណ្ឌានោះ មានស្ដេច ៤ អង្គទ្រង់ជួយទំនុកបំរុងលោក ចាត់ឲ្យសាមណេរ៤រូបធ្វើដំណើរទៅជាមួយនឹងលោកផង

ហើយទ្រង់តាក់តែងឲ្យការធ្វើដំណើររបស់លោកបានស្រួលផង ។ នៅប្រទេសឥណ្ឌាក៏មានក្សត្រ ១ អង្គដែរ ទ្រង់យកព្រះទ័យទុកដាក់នឹងលោក ហើយបានតាក់តែងឲ្យលោកបានជួបនឹងពួកអ្នកប្រាជ្ញជាចំនួនច្រើន ។ ឯស្រុកនាឡន្ទាជាទីប្រជុំធំ ១ នៃពុទ្ធសាសនាបែបមហាយាន នៅក្នុងទីនោះមានលោកសីល-ភទ្រ ជាចាងហ្វាងធំនៃមហាវិទ្យាល័យ ជាគ្រូមួយដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញណាស់ ។ លោកនៅក្នុងមហាវិទ្យាល័យនេះជាច្រើនឆ្នាំដើម្បីរៀនភាសាសំស្ក្រឹតនឹងលទ្ធិព្រះពុទ្ធសាសនា ហើយជ-ជែកដេញដោលគ្នាជាមួយនឹងប្រមុខនៃនិកាយផ្សេងៗ ព្រោះ(ក្នុងសម័យនោះ) ពុទ្ធសាសនាបែបហីនយានក៏មាននៅក្នុងមហាវិទ្យាល័យនេះដែរ ។

លោកអ៊ី-ឈឹង បានកត់ត្រាអំពីរឿងរ៉ាវនៃការធ្វើដំណើររបស់លោកមួយដែលបានចាត់ផ្ញើទៅស្រុកចិន ទើបលោកចេញដំណើរទៅប្រទេសជ្វា បាលី ស៊ុមាត្រាដែលនៅក្នុងសមុទ្រខាងត្បូង ហើយលោកបានប្រមូលនឹងចម្លងអស់ទាំងគម្ពីរដីកាច្បាប់ពុទ្ធសាសនា ជាភាសាសំស្ក្រឹតអំពីប្រទេសអស់នោះ ៗ ឯចំណែករឿងរ៉ាវនៅកោះអស់នេះ លោកនិយាយពន្យល់អំពីកិច្ចការចិញ្ចឹមជីវិត និងសេចក្ដីប្រតិបត្តិតាមផ្លូវសាសនាក្នុងស្រុកហើយលោកបានពិនិត្យមើលគម្ពីរផ្សេងៗខាងច្បាប់វិន័យ នេះជាសៀវភៅសំខាន់មួយសម្រាប់ការសិក្សាអក្សរសាស្ត្រដែលនិយាយអំពីវិន័យ ។ ក្នុងសៀវ-ភៅ ១ ទៀត លោកអ៊ី-ឈឹងបានកត់ត្រាទុកអំពីប្រវត្តិរបស់អ្នកធុតគ្គជាតិ

ចិនចំនួន ៥៦ នាក់ដែលធ្វើដំណើរទៅប្រទេសឥណ្ឌា ។ ក្នុងសៀវភៅនេះ លោកអ៊ី-ឈិង៍បានពោលអធិប្បាយអំពីប្រទេសដែលលោកដើរត្រឡប់មកស្រុកចិនវិញ ហើយបានមកសំចតនៅក្នុងស៊ុមាត្រាជាគំរប់ពីរដង ដើម្បីចម្លងក្បួនច្បាប់គម្ពីរដីកាអំពីស្រុកនេះម្តងទៀត ។

លោកអ៊ី-ឈិង៍នេះ កាលលោកចេញពីប្រទេសរបស់លោកទៅ អាយុលោក ២៥ ឆ្នាំ ដើរកាត់ប្រទេសផ្សេងៗច្រើនជាង ៣០ ប្រទេស ក្នុងការធ្វើដំណើរទៅនមស្សការបូជនីយស្ថានក្នុងប្រទេសឥណ្ឌានោះ ។ លោកនៅសិក្សាគាំង៍អំពីវិន័យជាដើមក្នុងមហាវិទ្យាល័យនាឡន្ទាជាវេលា ១០ ឆ្នាំ លុះលោកត្រឡប់មកស៊ុមាត្រាវិញក្នុងអាយុ ៥០ ឆ្នាំ ក្នុងពុទ្ធសករាជ ១២៣២ ហើយតមកជាវេលា ៦ ឆ្នាំទៀត ទើបលោកត្រឡប់ទៅប្រទេសចិនវិញ ។

មានចិត្តៈហាប់ចង់ប្រាថ្នា ការស៊ីខ្ទង់ ជាកូនជនទង់នោះមិញ ។ ពុំគួរទើង ចង់ស្រឡាញ់ ពុតម្ដាយម្ដេចមិញ ធ្វើតាមដូចម្ដាយនោះណា ។ បពិត្រ រីឯឥដ្ឋា- រម្មណ៍បណ្ឌិតថា យល់ព្រះពស្ត្រកម្ពល ។ មានចិត្តចង់ស្លៀក សោតសល់ ប្រមាទទសពល ពុំគួរពុំស្មើទីងកាណ ។ គួរតែទីងសំពត់ បាន មួយបង់កប្រាណ ដើរប្រោតដោយសព្វតំបន់ ។ រកស៊ីជាអ្នក សសន់ គូរសមពេកពន់ តាមដោយសណ្ដាប់នោះនៃ ។ បពិត្ររីឯ អភ័យ បណ្ឌិតកាចកៃ ក៏យល់ព្រះខាន់ក្សត្រា ។ ជង់ដាំសឹងរ័តន៍វេទា មានចិត្តប្រាថ្នា ចង់យកមកជាកំណាន់ ។ ដៃពុំគួរទើងព្រះខាន់ រ័តន៍គួរតែ កាន់ ស្រៃឡូអន្ទង់ពាទ្យផង ។ ស្ដេចស្ដាប់ពោធិ៍ទូលស្នង ដូច្នោះហើយ ហោង ព្រះអង្គទ្រង់ព្រះក្រោធកៃក្រៃ ។ ត្រាស់ថាអស់អ្នកនេះនៃ មែន ដូចធនញ្ជ័យ ទូលអញ្ជៈនះពិតប្រាកដ ។ ឯអង្គអាចារ្យទាំងបី កិតឥត ស្មារតី បង្គំប្រណម្យទូលថា ។ បពិត្រសម្ដេចក្សត្រា មែនពិតក្ដាត់ ណា សូមទានតែជីវិតហោង ។ ស្ដេចទ្រង់ព្រះក្រោធក្រោធទ្រង់ ត្រាស់ ឲ្យចាប់ចង ដាក់ប្រួលអាចារ្យទាំងបី ។ ឲ្យនាំទៅទុកនៅទី ក្នុងព្រោះ រង្គី ជាទុក្ខពន្ធ័គមហិមា ។ ទើបពោធិសត្វទូលថា បពិត្រព្រះមហា- កដ ក្សត្រឥស្សរាធិបតី ។ រីកដបណ្ឌិតទាំងបី ហីនជាតិអប្រិយ ពុំគួរប្រាថ្នា

ចង់បាន ។ សឹងកើតទុក្ខអន្តរាយប្រាណ ដូចកល់និទាន បក្សីទាំងប្រាំ
នោះណា ។ ចង់ដណ្តើមកជ្សទីគ្នា កើតជាទោសា ពីព្រេងដល់ឥឡូវ
នេះ ។ ស្តេចស្តាប់ហើយត្រាស់សំណេះ ថាបាងឯងបេះ និទានចូរ
បានិយាយ ។

ព្រះពោធិសត្វប្រាជ្ញប្រាយ អ្នកនាំនិយាយ ដោយនូវជាតិស-
ញ្ញាណ ។ បពិត្រព្រះមហាក្សត្រក្សាន្ត កាលព្រេងមុនមាន បក្សីទាំង
ប្រាំប្រាកដ ។ គឺហង្សស្រេកក្អែកមៀមត្រែង និត្យនៅចំហុត លំនៅនៃ
ព្រៃហិមពាន្ត ។ លុះជាអំឡុងពេលបាន បក្សីហៅហាន ទាំងឡាយសឹង
បៀតបៀនគ្នា ។ មានកាលថ្ងៃមួយនោះណា អស់សត្វបក្សា បក្សីទាំងប្រាំ
ជាធំ ។ នូវអស់បក្សីតាស់ទុំ ហើយទៅជំនុំ លើថ្មមនោសិលា ។ ឥតសត្វ
បក្សីឯណា គតាំងឲ្យជា ស្តេចឲ្យរក្សាសត្វផង ។ មានខ្វែងមួយនោះ
ឆ្លើយស្នង ថាមៀមនោះហោង ដ្បិតគាត់ជាបក្សីធំ ។ គាត់កើតមុនពី
ប្រថម- កល្បគាត់មានកំ- ឡាំងលើសអស់សត្វនានា ។ គួរយើងតាំង
គាត់ឲ្យជា ស្តេចឲ្យរក្សា រំងាប់ភ័យយើងបានហោង ។ អស់ទាំងសត្វ
បក្សីផង សឹងព្រមឥតហ្មង តាមដោយពាក្យសត្វខ្វែងនោះ ។ កាលនោះ
ក្អែកឆ្លើយពាស់ថា មៀមធំនេះណា មានកំឡាំងតិចហើយហាន ។ គឺ
មោះកើតក្នុងសន្តាន កោលីគោត្រប្រាណ ជាបក្សីថោកអប្រិយ ។ មួយ
ទោះសន្តានថោកថ្វៃ អស់សត្វបក្សី ទាំងអស់ព្រមហើយសឹងបាន ។

អញនឹងឆ្លើយពាក្យមួយថ្កាន អ្នកទាំងឡាយមាន អនុញ្ញាតទើបអញ
ធ្លាស់ឆ្លើយ ។ អស់សត្វចាស់ទុំធ្លាស់ឆ្លើយ ថាម្ចាស់ថៅអើយ ទៅមាន
គំនិតនោះជ្រៅ ។ អស់យើងទាំងឡាយនេះក្តី អនុញ្ញាតឲ្យទៅ ចូរទៅ
ឆ្លើយមកនេះម្តង ។ ក្អែកថាហៃអស់អ្នកផង ឲ្យមៀមនេះហោង ជា
ស្តេចពុំចូលចិត្តអញ ។ ដ្បិតមុខនឹងក្អែកមៀមមិញ គេពុំស្រឡាញ់ ពោះ
គាត់ទីងពុំទីងក្តី ។ ដូចគេខមនៅប្រក្រតី ធ្វើជាស្តេចអ្វី តែងខមឲ្យ
គេដូច្នោះ ។ អស់សត្វបក្សីទាំងនោះ ត្រូវចិត្តស្មានស្មោះ ថាមែនពិត
ដូច្នោះហោង ។ មានត្មាតធំមួយឆ្លើយសួង ថាក្អែកនេះហោង គាត់មាន
កំឡាំងមហិមា ។ គួរយើងដំកល់គាត់ជា ស្តេចស្នងគេគ្រា ព្យាបាលនៃ
យើងបានហោង ។ ឯមៀមទឹងហើយឆ្លើយសួង ថាក្អែកនេះហោង
កើតលើសន្តានចណ្ឌាល ។ ជាអ្នកសាហាវអន្ធពាល គំនិតស្រើប
ស្រាល ឥតមានករុណាប្រណី ។ តែនឹងលួចកូនគេធំ ជាពោរ
អប្រិយ នឹងឲ្យជាស្តេចម្តេចបាន ។ ក្អែកឮពាក្យមៀមឆ្លើយថ្កាន
ដូច្នោះហើយមាន ចិត្តខឹងកំហឹងពេកក្រៃ ។ ស្រែកថាម្នាលមៀមចង្រៃ
រកជ្យនេះនៃ នឹងបានមកអញហើយណា ។ ម្តេចឡើយព្រះស្នងបាវា
ស្រដីតាស់ថា ឲ្យអន្តរាយបង់វិញ ។ មៀមថាម្នាលមហាក្អែកមិញ កដ្យនឹង
បានអញ ព្រះស្នងស្រដីឲ្យខាន ។ បក្សីទាំងពីរសោមាន្យ អត់គ្នាពុំបាន
លោតហោរប្រចឹកផងគ្នា ។ កណ្តាលជំនុំនោះណា ចង់ជាហេក ពីកាល

នោះដល់ឥឡូវ ។ មានបក្សីតាស់មួយគូ ឆ្លើយថាឥឡូវ គួរអភិសេក
ក្រុងគ្រុឌ ។ ឲ្យគាត់ជាស្តេចប្រាកដ កំឡាំងចំហុត ក្រៃលែងបក្សី
នានា ។ អណ្តាប់នោះទើបសេកជា អ្នកប្រាជ្ញឆ្លើយថា រីឯក្រុងគ្រុឌនោះ
នៃ ។ ពុំជាអំបូរក្សត្រថ្ងៃ គួរយើងទីទៃ ឲ្យហង្សជាស្តេចគួរបាន ។ ដ្បិត
គាត់មានពូជសន្តាន ជាស្តេចហើយមាន រូបល្អប្រកបប្រាជ្ញា ។ មាន
ចិត្តមុទុករុណា ហើយចេះធម្មា គួរឲ្យជាស្តេចគាប់ហោង ។ រីអស់
សត្វបក្សីផង នូវគ្រុឌឯងហោង សឹងព្រមដូចពាក្យសេកថា ។ ទើបមក
អភិសេកមហា- ហង្សហើយឲ្យជា ស្តេចប្រាកដកាលនោះហោង ។
ពោធិសត្វនាំទំនង និយាយសត្វផង ស្រេចទើបបង្គំទូលថា ។ បពិត្រ
សម្តេចក្សត្រា អ្នកហិនប្រាជ្ញា ចង់ធំនោះពុំដែលបាន ។ ដូចក្អែកនឹងមៀម
សាមាន្យ សឹងអន្តរាយប្រាណ អសារអន្តងឯងអប្រិយ ។ ឥឡូវសូមស្តេច
ប្រណី ដោះទោសអ្នកបី ទុកស្ថិតស្ថាននោះហោង ។ ស្តេចស្តាប់ហើយ
បន្ទូលស្នង ទោសវាច្រើនផង អញមិនដោះលែងក៏ឡើយ ។ ព្រះពោធិ-
សត្វស្តាប់ហើយ បង្គំទូលឆ្លើយ បពិត្រសម្តេចចក្រី ។ បើអម្ចាស់ពុំ
ប្រណី ទោសអ្នកទាំងបី នូវកើតដំនៀលជាមុន ។ ថាស្តេចយកកូន
ដកខ្លួន នូវកូនអ្នកផង សសេទនូវកូនអ្នកលេង ។ មកជាអ្នកប្រាជ្ញស្តេច
ស្តែង ខុសហើយពុំលែង ស្តេចឲ្យសម្លាប់បាតបង់ ។ ហើយគេនឹងដៀល
មកត្រង់ ខ្លួនខ្ញុំជាបង់ មកទូលសំដែងភាសា ។ ឲ្យអ្នកទាំងបីមរណា

ហាក់ឥតមេត្តា ឥតសប្បុរសពេកក្រៃ ៗ ស្តេចស្តាប់ពោធិសត្វថ្លៃ។ ព្រមព្រះហឫទ័យ ថាមែនពិតដូចពៅថា ៗ ទើបស្តេចឲ្យដោះទោសា អ្នកតាំងនោះណា នឹងឲ្យបំបរបង់សៀត ៗ ព្រះពោធិសត្វឆ្លើយឆ្មៀត ទូលទាស់ទៅទៀត បពិត្រព្រះបាទចក្រ ៗ បើម្ចាស់បរអ្នកតាំងបី កាត់ទៅទីប្រទេសឯទៀតហើយណ៎ា ៗ នឹងនាំសត្រូវពាធា មកទ្រុស្តក្សត្រាប្រាកដពុំលែងឡើយហោង ៗ ស្តេចស្តាប់ហើយបន្ទូលស្នង ថាបើច្នោះហោង អញឲ្យទៅជាខ្ញុំពៅ ៗ ទើបពោធិសត្វឆ្លើយទៅ ថាខ្ញុំខ្លាចត្រូវដំនៀលគេជៀលនិន្ទា ៗ ថាខ្ញុំមកទូលក្សត្រា សំដែងទោសា តាំងនេះចង់បានជាខ្ញុំ ៗ ហេតុនោះគួរព្រះអង្គអំ- ម្ចាស់ថ្លៃស្តេចដំ- កល់ជាអ្នកប្រាជ្ញវិញណា ៗ មហាកជខ្ញុំពុំប្រាថ្នា យកអ្នកពាលា តាំងបីនេះជាខ្ញុំឡើយ ៗ ដ្បិតមានច្បាប់ធម៌ជាត្រើយ ថាអ្នកណាហើយ ពុំមានចិត្តសប្បុរសផង ៗ លោកពុំឲ្យគប់ស្នេហ៍ស្នង នឹងអ្នកពាលផង ឥតសប្បុរសនោះណា ៗ មួយទីកុំយកអាគា ចូលទៅធ្វើជា មិត្រនឹងសត្រូវនោះឡើយ ៗ បើខំចូលជាមិត្រហើយ មានទុក្ខពុំស្បើយ នូវកើតវិនាសពេកក្រៃ ៗ គួរនាដូចភ្លើងនេះព្រៃ នាកាលសម័យ រដូវខចេត្រនោះហោង ៗ ទើបពោធិសត្វសាសង ទូលក្សត្រច្បាស់ប្រាជ្ញសំដែងជាបវគាថា ៗ បញ្ចោមហាផ្លូ ឃ្លៃចេញថា សត្រូវបីកាចតាំងឡាយ ៗ លោកប្រើឲ្យចៀសចម្ងាយ ប្រាំហត្ថគត់ឆ្ងាយ កុំចូល

ទៅទៀតឡើយណា ៗ អស្សសភហត្ថា ឲ្យចៀសសេះសា-ហារ
បានមួយរយហត្ថ ៗ សហស្សស្សុហត្ថិ ប្រើចៀសដំរី សាហារ
មួយពាន់ហត្ថ ៗ ចៀសសត្វសឹងមានកំណាត់ កំណាន់ដោយបទ
បាលីដ្ឋះបុះឯងហោង ៗ រីចៀសអ្នកទុជ៌នផង ឲ្យឆ្ងាយជាម្លង ទៅប្រ-
ទេសឯទៀតវិញ ៗ ស្តេចស្តាប់ពោធិសត្វមិញ សោមនស្សពេញ
ព្រះទ័យថាគាប់មែនពិត ៗ ស្តេចដកលាក់ផបណ្ឌិត តាំងបីនោះឋិត
ឲ្យជាអ្នកប្រាជ្ញវិញខ្ញី ៗ ហិតបណ្ហាទិដ្ឋ- តាយេងថ្ងៃពី ប្រយោជន៍
នេះស្រេចម៉្ញះណា ៗ

បន្ទាកាគតិ ដំណាលដំណ ដំណើរអស់អាថ៌ ចាប់ផង់ចិត្តចាំ
រកឃ្លាំពោសា នៃព្រះអគ្គមហា- បុរសរតន៍ថ្ងៃ ៗ ប្រដូចស្រមោល តែង
តាមអន្ទោល ដោយខ្លួនប្រក្រតី មានមួយទេក អាចារ្យតាំងបី ទូរពង្ស
ពោធិ ឡើងតាល់មហាក្សត្រ ៗ លង់ល្បុះស៊ុរិយា ចាបទៅចុំមា
ពង្សពោធិសត្វ ថ្វាត់ថ្វាយបង្គំ ប្រណម្យប្រណិប័តន៍ លុតលាមហា-
ក្សត្រ ចុះចាកចេញចរ ៗ អាចារ្យតាំងបី ទូនអគ្គសិរីសិ កង្វេញកាយករ
ប្រញប្រាំណស្រពាប ក្រញក្រាបបាទបរ ចុះចាកចេញចរ ដើរដល់ផ្លូវ
ផ្កា ៗ ផ្ដួចចូនពើបពង្ស ពោធិសត្វគង់ លេងលើសាលា អស់អគ្គអាចារ្យ
ត្រអាលម្ចា ឡើងទៅចរពា ក្រសាលសុខសាន្ត ៗ ទើបស្ទាក-
លែយល្ហុងចរពា បន្ថិចទៅថ្កាន ថាហៃធនញ្ជ័យ សព្វថ្ងៃគេមាន

ក៏ជាប្រពន្ធ អស្ចារ្យផងចិត្ត ។ ព្រះពង្សពោធិ៍ ស្ដេចស្ដាប់សំដី
ពាក្យពផបណ្ឌិត អ្នកសឹងសរសើរ ទៅគេគន់គិត បានអ៊ីចូលចិត្ត ជា
អស្ចារ្យស់ ។ ឯស្រុទ្ធក- រៃយព្ទហើយថា ខ្ញុំគិតយល់យល់ មានតែ
ខ្លួន សក្ករស្សមិត្រផល ក្នុងកើតសុខសល់ ជាអស្ចារ្យក្លាត់ ។ ឥដ្ឋារម្មណ៍
ឡើយ ថាហៃទៅអើយ ទានតែគន់គិត សរសើរគុណគេ នោះឯគំនិត
អន្ធអញចូលចិត្ត ថាប់ជាអស្ចារ្យ ។ អភ័យបណ្ឌិត ឆ្លើយដោយ
គំនិត កំណាចក្រោធការ ប្រើប្រណីប័តន៍គេ នោះឯងអស្ចារ្យ
ខ្ញុំគិតយល់អាថ៌ ជាក់ហើយចូលចិត្ត ។ កាលនោះពោធិ- សត្វស្ដាប់សំដី
ពាក្យពផបណ្ឌិត ទាំងពីរអង្គ ចរចាតាមចិត្ត អ្នកជាបណ្ឌិត ដំណឹងទៅ
នោះ ។ សឹងតែផគការ ឥតខ្ញុំអសារ អរសោចស្ទុរសោះ អាចារ្យ
ទាំងពីរ ស្រដីងីរស្មោះ ដំណឹងអ្នកនោះ មានខ្ញុំតើម្ដេច ។ សូមអ្នក
សំដែង និទានថាយថែង ឲ្យជាក់សេចក្រេច ព្រាប់ដោយបានដឹង
ដំណឹងគល់កិច្ច ខ្ញុំនោះដូចម្ដេច សូមអ្នកចរចា ។ អ្នកឆ្លើយថាឯ
អញដឹងមានតែ កតញ្ញូតា កតវេទី ឯងក្ដីកើតព្រា- កដមុតសល់ជា
អស្ចារ្យពេកពន់ ។ លើសទីនដំណឹង ព្រះស្ដេចឯងដឹង ជារយសៃនគុណ
អ្នកណាកាន់គាប់ កំណាចពេកពន់ ភ្លាំងភ្លេចល្មើសគុណ ដោយកាប
ឯងណា ។

# រឿងព្រះបាទអសោកមហារាជ

(តមក)

ព្រះបាទអសោកបានបំបួសព្រះមហិន្ទរាជបុត្រាជាភិក្ខុ និងនាងសង្ឃមិត្តារាជបុត្រីជាភិក្ខុនី ក្នុងព្រះពុទ្ធសាសនា ។

ប្រវត្តិសាស្ត្រសាកលរបស់ហ្វូនវិចិត្រពង្សការថា ដែនមគធៈនោះជាទីដែលព្រះពុទ្ធសាសនាបានប្រតិស្ឋានជាដំបូង ហើយនាំគ្នាកាន់កាប់តរៀងមក តែកាលចន្ទ្រគុប្តៈចូលមកគ្រប់គ្រងដែនដីនោះហើយ សាសនាព្រាហ្មណ៍ក៏មានអំណាចរុងរឿងឡើងក្នុងអាណាចក្រមគធៈ ព្រោះហេតុតែមួយយ៉ាងគឺចន្ទ្រគុប្តៈមានអាចារ្យជាព្រាហ្មណ៍ ហើយការដែលចន្ទ្រគុប្តៈតាំងខ្លួនជាស្តេចផែនដីបាន ក៏ដោយវិធីប្រើប្រាស់របស់ព្រាហ្មណ៍ជាអាចារ្យនោះ ។

មួយយ៉ាងទៀត ក្នុងពុទ្ធកាលក្តី ខាងក្រោយពុទ្ធកាលយូរមកក្តី ក៏ពួកព្រាហ្មណ៍តែងមានតួនាទីជាបុរោហិត (ជាទីប្រឹក្សារាជការផែនដី) ហើយគេតែងប្រកាន់ថាព្រាហ្មណ៍ជាបុគ្គលចំពូកមួយ ដែលជាអ្នកចេះដឹងក្នុងវេទសាស្ត្រ (វេទប្រសាសន៍ ឬទំនាយទាយផ្សេងៗ ថាវិជ្ជាគ្រប់គ្រង ឬវិជ្ជាការពារនគរ) ។ ព្រះបាទពិន្ទុសារៈជាព្រះបិតារបស់ព្រះបាទអសោក ក៏តង់ជ្រះថ្លាក្នុងសាសនាព្រាហ្មណ៍ដែរ ដោយការធ្លាប់បានអញ្ជើញពួកព្រាហ្មណ៍មកលៀងអាហារក្នុងមួយលើកៗ មួយម៉ឺនប្រាំមួយពាន់នាក់ ។ ឯព្រះបាទអសោកសោត កាលព្រះអង្គនៅជាកុមារនៅឡើយ ក៏ទ្រង់

បានទទួលការសិក្សាក្នុងស្នាដៃរបស់ពួកព្រាហ្មណ៍ដែរ តែដល់ពុទ្ធ-សករាជ ២៧៨ ទើបបានទ្រង់ប្រកាសព្រះអង្គថាជាពុទ្ធមាមកៈ ដោយសេចក្តីណែនាំនៃមន្ត្រីរបស់ព្រះអង្គម្នាក់ឈ្មោះឧបគុប្តៈ ។ ព្រះមហា-ក្សត្រិយ៍ទ្រង់កាន់ព្រះពុទ្ធសាសនានោះព្រោះទ្រង់ជ្រាបថា ព្រះអង្គបានធ្វើសង្គ្រាមជាកម្មដ៏អាក្រក់ច្រើនលើសលុបពេក ទឹងទ្រង់ជ្រាបច្បាស់ថាគ្រាកាលដែលព្រះអង្គវាយដណ្តើមយកបានដែនកលិង្គៈ ទ្រង់បានធ្វើដោយអំណាច បំផ្លាញជីវិតមនុស្សច្រើនជាអនេក ។

កាលពុទ្ធសករាជ ២៩៤ ស្តេចបានទៅនមស្សការទូទៅប្រសូតរបស់ព្រះពុទ្ធជាម្ចាស់ លុះដល់ពុទ្ធសករាជ ៣០៣ បានទ្រង់ឧបសម្បទាជាភិក្ខុក្នុងព្រះពុទ្ធសាសនា ។

ការសង្គ្រាមដែលព្រះបាទអសោកធ្វើក្នុងខេត្តកលិង្គៈនោះ ជាសង្គ្រាមធំបំផុត ដែលជាហេតុនាំឲ្យផ្លាស់ព្រះរាជហឫទ័យរបស់ព្រះអង្គពីភាពជាអ្នកធ្វើចម្បាំង មកជាអ្នកប្រព្រឹត្តធម៌វិញ សិលាចារឹកដែលបញ្ចុះពាក្យប្រកាសរបស់ព្រះបាទអសោកនោះឯង សំដែងឲ្យឃើញថាព្រះអង្គទ្រង់ស្តុតព្រះរាជហឫទ័យយ៉ាងណា ។ មានសេចក្តីប្រែដូចតទៅនេះ:

"ព្រះករុណាជាម្ចាស់ជីវិតជាអ្នកស័ក្តិសិទ្ធិ បានជ័យជំនះដល់ខេត្តកលិង្គៈ កាលទ្រង់បានរាជសម្បត្តិហើយ ៨ ឆ្នាំ ។ ទ្រង់បានចាប់មនុស្សមកជាឈ្លើយមួយសែនប្រាំម៉ឺន ទឹងបានសម្លាប់អស់មួយសែន" ។

« កាលដែលបានរួមខេត្តកលិង្គៈចូលមកហើយ ទើបព្រះករុណាជាម្ចាស់ជីវិត ជាអ្នកស័ក្តិសិទ្ធិ បានតាំងខ្លួនជាអ្នកគ្រប់គ្រងរក្សាព្រះធម៌ ទ្រង់ស្រឡាញ់ក្នុងព្រះធម៌ និងទ្រង់ស្រឡាញ់ការរៀនប្រដៅព្រះធម៌ ហើយរឿងនេះឯងដែលធ្វើឲ្យព្រះករុណាម្ចាស់ជីវិត ជាអ្នកស័ក្តិសិទ្ធិទ្រង់តូចព្រះហឫទ័យក្នុងការដែលទ្រង់ទៅវាយដណ្តើមយកក្រុងកលិង្គៈ ព្រោះការវាយក្រុងនោះត្រូវតែប្រទូសរ៉ាយពិឃាដមនុស្សឬចាប់យកជាឈ្លើយ ជារឿងដែលព្រះករុណាម្ចាស់ជីវិតទ្រង់មានព្រះទោមនស្សយ៉ាងក្រៃលែង» ។

តាំងអំពីបានទ្រង់ប្រកាសព្រះអង្គជាពុទ្ធមាមកៈហើយ ក៏លោកទាំងមូលបានដឹងច្បាស់ថា ព្រះអង្គជាពុទ្ធសាសនូបត្ថម្ភកៈពិតប្រាកដ ទ្រង់បានសាងព្រះស្តូបប្រាំបីម៉ឺនបួនពាន់[១] ឡើងក្នុងក្រុងកជគ្រឹះ ហើយតាំងអំពីនោះមក ក្រុងកជគ្រឹះផ្លាស់នាមថា "វិហារ" ដោយទីនោះជាទីតាំងនៅនៃព្រះស្តូប ដល់មកសម័យនេះហៅថា "បិហារ" ។

---

១ មានសៀវភៅបារាំងប្រាប់ចំនួនខុសៗគ្នាច្រើន ខ្លះថាប្រាំបីម៉ឺន ខ្លះថាប្រាំមួយម៉ឺនបួនពាន់ ខ្លះប្រាំបីពាន់បួនរយ ការដែលពិតនោះ បើនឹកដល់អាណាចក្រនិងសេចក្តីជ្រះថ្លាខ្លាំងក្លាក្រៃលែងរបស់ព្រះបាទអសោកហើយ ការកសាងព្រះស្តូបប្រាំបីម៉ឺនបួនពាន់អង្គនោះ ជារបស់ដែលគួរជឿ មិនជាការលើសវិស័យដែលទ្រង់កសាងបាន ។

ក្នុងសម័យរបស់ព្រះបាទអសោកនេះ ពួកព្រាហ្មណ៍អាប់រស្មីចុះទៅ ពួកព្រាហ្មណ៍ដែលធ្លាប់បានទទួលប្រាក់ទំនុកបំរុងរបស់រដ្ឋបាលពីមុនមកនោះ ក៏ត្រូវកាត់ចេញអស់ ផ្លាស់យកប្រាក់នោះទៅទំនុកបំរុងព្រះសង្ឃវិញ ។

តែទុកជាព្រះបាទអសោកយកព្រះរាជហឫទ័យទុកដាក់ក្នុងការប្រកាសព្រះពុទ្ធសាសនាដូច្នេះហើយក៏ដោយ ក្នុងអាណាចក្ររបស់ព្រះអង្គក៏គង់នៅមានសាសនាដទៃ ៗ ទៀតជាច្រើន ។ ព្រះបាទអសោកទ្រង់ទំនុកបំរុងព្រះពុទ្ធសាសនា តែទ្រង់មិនប្រទូសរ៉ាយសាសនាដទៃទេ សូម្បីទ្រង់ដកសាសនាព្រាហ្មណ៍ ដែលធ្លាប់ជាសាសនាសម្រាប់អាណាចក្រចេញហើយ ក៏គង់នៅប្រើព្រាហ្មណ៍ធ្វើពិធីផ្សេង ៗ នៅឡើយ រឿងនេះក៏ព្រោះថាជាកិច្ចខានសោះមិនបាន ដោយពួកដែលជឿសាសនាព្រាហ្មណ៍ក្នុងវេលានោះមិនមែនតិចជាងពួកពុទ្ធសាសនិកជនទេ ម្យ៉ាងទៀត តាំងអំពីបុរាណកាលយូរមកហើយក្តី ក្នុងសម័យនេះក្តី ចិត្តរបស់ជនជាតិឥណ្ឌានៅជាប់តែនឹងសាសនា បើព្រះបាទអសោកបដិសេធបោលសាសនាព្រាហ្មណ៍ចេញហើយ ក៏ប្រាកដជានឹងកើតការក្បត់កាប់សម្លាប់គ្នាកែរយ៉ាងធំ បើទុកជាទ្រង់លះបង់បោលសោះមិនបានដូច្នេះ ក៏គង់ទ្រង់មិនទំនុកបំរុងព្រាហ្មណ៍ជាការធំដុំប៉ុន្មានឡើយ ។

មិនមែនតែសាសនាព្រាហ្មណ៍ប៉ុណ្ណោះទេ សូម្បីសាសនាដទៃៗ ដែលមានគណាចារ្យតាំងការប្រៀនប្រដៅនៅឡើយ ព្រះបាទអសោក ក៏មិនបានលុបលាងចោលដែរ គ្រាន់តែទ្រង់សំដែងព្រះរាជប្រាថ្នាឲ្យម្ចាស់នៃសាសនានុ៎ះៗ ជួយទំនុកបំរុងសីលធម៌របស់ប្រជាជនប៉ុណ្ណោះ សេចក្តីប្រាថ្នានេះ ទ្រង់បានចារឹកនៅលើផែនសិលា ហើយនាំទៅប្រតិស្ឋានទុកក្នុងទីផ្សេងៗ សិលាចារឹកនោះតាំងនៅរហូតដល់សម័យនេះ មានផែនថ្មួយផ្ទាំងដែលសំដែងឲ្យឃើញចរិយាវត្តដ៏ល្អរបស់ព្រះបាទអសោក ដូចសេចក្តីប្រែតទៅនេះ

« ប្រជាកស្ត្រគ្រប់គ្នាសុទ្ធតែជាបុត្ររបស់ខ្ញុំ ខ្ញុំត្រូវការឲ្យបុត្រក្នុងទ្រូងរបស់ខ្ញុំមានសេចក្តីសុខសួស្តីក្នុងលោកនេះយ៉ាងណា ខ្ញុំក៏មានប្រាថ្នាឲ្យពួកប្រជាជនមានសេចក្តីសុខសួស្តីយ៉ាងនោះៗ ខ្ញុំឲ្យដាំដើមជ្រៃនៅប្របខាងផ្លូវដើរដើម្បីឲ្យជាម្លប់ដល់មនុស្សនិងសត្វៗ ខ្ញុំបានឲ្យដាំសួនស្វាយ ជីកស្រះនិងសាងសាលា ឲ្យជាទីសំណាក់អាស្រ័យនៃមនុស្សនិងសត្វៗ ខ្ញុំបានតាំងអ្នកមើលការខាងផ្លូវសាសនាសម្រាប់ធ្វើការកុសលគ្រប់ប្រភេទ និងប្រតិបត្តិនាទីរបស់សាសនាគ្រប់និកាយៗ ខ្ញុំយកចិត្តទុកដាក់ចំពោះព្រះសង្ឃរបស់ព្រះពុទ្ធសាសនា សូម្បីពួកព្រាហ្មណ៍ដែលជាសាសនារបស់ពួកសូមតាន ហើយនិងម្ចាស់លទ្ធិដទៃៗ ខ្ញុំក៏យកចិត្តទុកដាក់ផង » ៗ

កាលក្នុងពុទ្ធសករាជ ៣០១ ព្រះបាទអសោកបានតាំងឲ្យមានសង្គាយនា[១] ជាគ្រាទី ៣ ក្នុងក្រុងបាដលីបុត្រដែលជាក្រុងរបស់ព្រះអគ្គគង់នៅ ។ ក្នុងកាលសង្គាយនាជាន់នេះ មានភិក្ខុមកប្រជុំមួយពាន់អង្គ ហើយក្នុងគ្រានេះឯងដែលបានបញ្ជូនពួកព្រះថេរជាអ្នកអង់អាចទៅប្រកាសព្រះពុទ្ធសាសនាក្នុងមួយទិសមួយរូបគ្រប់ផ្លូវ គឺព្រះមហារក្ខិតត្ថេរ ទៅប្រកាសដល់ពួកក្រិកខាងខែត្របាក់ត្រីយ៉ាន (Bactriane) ព្រះមជ្ឈិយន្តិកៈ (មជ្ឈន្តិក?) ទៅប្រកាសខាងកស្មីរៈនឹងដែនគន្ធារៈ, ព្រះមហាដម្មៈ(?)នឹងព្រះសហទេវៈ ទៅប្រកាសក្នុងអាណាចក្រតូចៗផ្សេងៗ ខាងភ្នំហិមាល័យ, ព្រះមហាធម្មៈ ទៅប្រកាសខាងខេត្តមហាព្រស្ត, ព្រះមហាទេវៈ ទៅប្រកាសខាងម៉ៃសរ, ព្រះសោណៈនឹងព្រះឧត្តរៈ ទៅប្រកាសខាងប្រទេសភូមា-មន, ព្រះឱរសនឹងព្រះធីតារបស់ព្រះបាទអសោកបានទទួលនាទីទៅប្រកាសខាងកោះលង្កា ។

---

១ មើលសេចក្តីសង្ខេប តែងាយយល់ ក្នុងសៀវភៅ "Les religions du monde" par C. Clément

# ពង្សាវតារពេម

(តមក)

ប្រគល់អំណាចឲ្យធ្វើជាអ្នកបញ្ជាការកងទ័ព លើកទ័ពទៅច្បាំងនឹងព្រះបាទមិត្រជាត ក្នុងទ្វីបកាស៊ី ដំណែងបញ្ជាការទ័ពនេះគេត្រូវការណាស់ ព្រោះដល់ពេលត្រឡប់មកដល់ស្រុកវិញនឹងបានធ្វើជាមហាសេដ្ឋី ព្រមទាំងមានអំណាចយ៉ាងធំថែមទៀតផង ព្រោះមានកំឡាំងទាហាននៅក្នុងកណ្តាប់ដៃខ្លួន ។

ដំបូង ដំណែងនេះម៉ារិយុសត្រូវការចង់បានណាស់ ហើយគិតថាគង់នឹងបានមកខ្លួន លុះមិនបានសម្រេចដូចបំណង ទើបម៉ារិយុសបបួលក្រុ ប្រជាឲ្យបោះឆ្នោតទម្លាក់សេចក្តីវិច្ឆ័យសម្រេចនៃសភាសេណាត៍ ក្នុងការតាំងឲ្យស៊ីល្លាធ្វើជាមេទ័ពធំក្នុងគ្រានេះ ។ ឯស៊ីល្លាបានដឹង ក៏រួបរួមកងទាហានរបស់ខ្លួនលើកចូលក្រុងកេម តាមធម្មតាមានខហាមផ្តាច់មិនឲ្យពួកទាហានកាន់អាវុធដើរចូលក្រុងកេម គ្រានេះជាគ្រាដំបូងដែលកុងទាហានព្រមទាំងអាវុធដើរចូលក្រុងកេម ។ ឯម៉ារិយុសមិនទាន់បានត្រៀមកំឡាំងទប់ទល់ ក៏គេចរត់ចេញពីក្រុងកេមនោះទៅ ឆ្លងទៅទ្វីបអាហ្វ្រិក ។ ស៊ីល្លាមានជ័យជំនះក្នុងគ្រានេះ ទើបប្រកាសលើកលែងប្រើច្បាប់ដែលម៉ារិយុសបានធ្វើទុកមកនោះទាំងអស់ នឹងលើកអំណាចសភាសេណាត៍

ឲ្យខ្ពង់ខ្ពស់ឡើងដូចកាលដាន់ដើមវិញទៀត ទើបលើកទ័ពចេញទៅទ្វីបអាស៊ី ។

ក្នុងពេលដែលស៊ីល្លាមិននៅក្នុងក្រុងរោមនោះ ម៉ារីយុសក៏ត្រឡប់ចូលមកក្នុងប្រទេសអ៊ីតាលី ហើយបានបក្សពួកសំខាន់ម្នាក់ធ្វើជាកុងស៊ុល ម៉ារីយុសបានប្រមូលពួកអ៊ីតាលីនិងពួកខ្ញុំបានជាចំនួនច្រើនហើយ ក៏លើកទ័ពចូលក្រុងរោម បានបំផ្លាញជីវិតពួកនាម៉ឺនមន្ត្រីអស់ចំនួនច្រើន និងប្រកាសថា ស៊ីល្លាជាសត្រូវនឹងប្រជាជន ហើយតាំងខ្លួនឯងជាអ្នកបញ្ជាការទ័ពទ្វីបអាស៊ី តែកាលចេញដំណើរទៅ ក៏ស្រាប់តែអនិច្ចកម្មពាក់កណ្តាលផ្លូវ ក្នុងពុទ្ធសករាជ ៤៥៧ (មុន គ.ស. ៨៦) ។ ទុកក្រុងរោមនៅក្រោមកណ្តាប់ដៃរបស់ស៊ីល្លា និងកូនប្រុសរបស់ខ្លួនម្នាក់ គ្រប់គ្រងក្រុងរោមតមកទៀតជាវេលា ៣ ឆ្នាំ ។

កាលស៊ីល្លាលើកទ័ពទៅច្បាំងឈ្នះព្រះបាទមិទ្រីដាតនោះ បានប្រមូលយកទ្រព្យសម្បត្តិចូលមកក្រុងរោមជាចំនួនច្រើន ទើបសភាសេណាត តាំងស៊ីល្លាឲ្យមានដំណែងខ្ពស់ឡើងទៀតជា ឌិកតាទ័រ (Dictateur) នៃក្រុងរោម ដរាបដល់អស់ជីវិត ។ ក្នុងគ្រានេះ ស៊ីល្លាបានធ្វើការសងសឹកពួកជាសត្រូវនឹងខ្លួនដោយវិធីប្រហារជីវិតនឹងរឹបជាន់យកទ្រព្យសម្បត្តិលក់ឲ្យរាស្ត្រយ៉ាងថោកៗ មានសេចក្តីដំណាលថា ដី ១ កន្លែងនោះជារបស់អ្នកដែលជាសត្រូវនឹងស៊ីល្លា ដីនេះមានដំឡៃដល់ ២០.០០០.០០០

ហ្វ្រាន់ ស៊ីល្លាបែរយកមកលក់ឡាយឡុងឲ្យពួកខ្លួនគិតជាដំឡៃ ៤៧០ ហ្វ្រាន់ ប៉ុណ្ណោះ (ប្រហែល ២.០០០.០០០ រៀល លក់ត្រឹម ៤៧ រៀល) ។ តាំងអំពីនោះមក ស៊ីល្លាក៏កែប្រែរបៀបត្រួតត្រាក្រុងរោមជាច្រើនយ៉ាង ដូចជាកុងស៊ុលពីដើម មានដំណែងជាអ្នកបញ្ជាការកងទ័ពផង ក៏ត្រូវស៊ីល្លាផ្តាច់អំណាចនេះចេញដែរ ស៊ីល្លាបានលាចេញពីដំណែងឌិកតាទ័រ កាលពីពុទ្ធសករាជ ៤៦២ (មុនគ.ស. ៧៩) ហើយតមកទៀត ១ ឆ្នាំក៏អនិច្ចកម្មទៅ ។ ការរៀបធ្វើបុណ្យសពស៊ីល្លានេះ គេរៀបធ្វើជាពិធីធំឱឡារិកសំបើមណាស់ ទីងសំខាន់យ៉ាងក្រៃលែងមួយគ្រាទៀត ក្នុងប្រវត្តិសាស្ត្ររបស់រោម ។

កិច្ចការរបស់ស៊ីល្លានោះ ឲ្យផលអាក្រក់ដល់ក្រុងរោមច្រើនជាងផលល្អ ព្រោះតាំងអំពីនោះតមក អ្នកណាបានធ្វើជាអ្នកបញ្ជាការទ័ព ក៏គិតតែប៉ុនប៉ងចង់ធ្វើជានាយចៅហ្វាយធំនៅក្រុងរោម បើអ្នកឯណាមានកំឡាំងទាហាននៅក្នុងកណ្តាប់ដៃ ហើយរដ្ឋបាលធ្វើការមិនជាទីគាប់ចិត្ត ក៏លើកទាហានចូលក្រុងរោម ។ កិច្ចការនៅក្រុងរោមមានទំនងដូច្នេះរហូតមកដល់មនុស្សសំខាន់ ២ នាក់ គឺ ប៉ុមប៉េនិងសេសារ (Pompée et césar) ។

ប៉ុមប៉េកើតក្នុងត្រកូលខ្ពស់ មានសម្បត្តិស្តុកស្តម្ភហើយក្លាហាន ជាមិត្តជំនិតរបស់ស៊ីល្លា ជាអ្នកធ្លាប់ចេញច្បាំងមកជាមួយគ្នា ។ លុះស៊ីល្លា

អនិច្ចកម្មទៅ ហើយតាំងខ្លួនជាអ្នកគ្រប់គ្រងសភាសេណាត៍តមក ៗ តាម ដោយពិត ប៉ុមប៉េជាមនុស្សកើតក្នុងត្រកូលខ្ពស់ ជាមេទ័ពមានគុណសម្បត្តិយ៉ាងកណ្ដាល ជាជើងប្រសើរតិចតួច មាននិស្ស័យត្រឡប់ត្រឡប់មិនទៀងទាត់ ជាមនុស្សក្បាលពីរ មួយចូលខាងពួកអ្នកមាន មួយទៅចូលខាងពួកអ្នកក្រ ស្រេចតែពួកខាងណាធ្វើប្រយោជន៍ឲ្យខ្លួនបានច្រើន តែប៉ុមប៉េនេះជាមនុស្សមានជោគល្អចំឡែក បានធ្វើការសម្រេចដោយគ្រោះល្អរបស់ខ្លួន ៗ ជាន់ដំបូង សភាសេណាត៍តាំងឲ្យធ្វើជាមេទ័ព ទៅច្បាំងស្រុកអេស្ប៉ាញក៏បានជ័យជំនះ លុះតមក ប៉ុមប៉េផ្លាស់ចិត្តគំនិតចេញពីពួកអ្នកមានត្រកូលខ្ពស់ មកចូលនឹងពួកក្រវិញ ហើយប្រកាសឲ្យលើកច្បាប់ដែលស៊ីល្លាបានបញ្ញត្តទុកនោះចោលទាំងអស់ សភាសេណាត៍ក៏តាំងតែយល់ព្រមតាម ព្រោះខ្លាចកំឡាំងទាហានរបស់ប៉ុមប៉េ ៗ តអំពីនោះមក ប៉ុមប៉េលើកទ័ពទៅច្បាំងនឹងព្រះបាទមីទ្រីដាតក្សត្រនៃអាណាចក្រប៉ុងត៍ (Pont) ជាប្រទេសតូច ៗ នៅឆ្នេរសមុទ្រខ្មៅ (Mer noire) ដែលជាសត្រូវនឹងក្រុងរ៉ូមយ៉ាងសំបើមដូចកាលអន្និបាល ប៉ុមប៉េក៏ច្បាំងប្រាបប្រាមកបគាបទៅបានដែរ ហើយពង្រីកអាណាខេត្តឲ្យរីកចេញទៅទៀត រហូតដល់ទន្លេអឺប្រាត (Euphrate) ឲ្យរួមនៅក្នុងមហាអាណាចក្ររ៉ូម តាំងអំពីពុទ្ធសករាជ ៤៨០ (មុន គ.ស. ៦៣) ៗ

នៅឱកាសដែលប៉ុមប៉េចេញទៅធ្វើសង្គ្រាមនៅខាងណោះ ចំណែកខាងក្រុងរោមក៏កើតចលាចលឡើង ដោយមានមនុស្សម្នាក់ឈ្មោះកាទីលី-ណា (Catilina) បានរួបរួមកំឡាំងមនុស្សបក្សឡើង ដ្បិតក្រុងរោមសម័យនោះ អ្នកណាមានកំឡាំងទាហាន ក៏អាចនឹងបានធ្វើជានាយចៅហ្វាយធំនៅក្រុងរោមបាន តែវេលានោះបួនជាគ្រោះល្អរបស់ក្រុងរោមដោយមានកុងស៊ុលម្នាក់ឈ្មោះស៊ីសេរ៉ុង (Cicéron) ជាអ្នកជួយរបៀបរពុយពួករបស់រោមឲ្យបានផុតពីគ្រោះថ្នាក់ ។ ឯប្រវត្តិរបស់ស៊ីសេរ៉ុងដូច្នេះ :

ស៊ីសេរ៉ុងកើតក្នុងត្រកូលមិនមានកេរ្តិ៍ឈ្មោះអ្វីទេ បានចេញទៅសិក្សាអក្សរសាស្ត្រវិជ្ជាការនៅក្រុងរោមនិងក្រុងអាថែន បានចូលធ្វើរាជការតាំងពីអាយុ ៣០ ឆ្នាំ ។ មានសេចក្ដីដំណាលថា មានមនុស្សស្រឡាញ់ពេញចិត្តច្រើនដោយសំដីវោហារថ្លៃមាត់ ឆ្លាត, ស្មោះត្រង់ ជាគុណសម្បត្តិ ៣ ប្រការមានរួមនៅក្នុងមនុស្សម្នាក់ លុះអាយុ ៤៤ ឆ្នាំទើបបានទទួលដំណែងជាកុងស៊ុល ហើយបានធ្វើការយ៉ាងម៉ឺងម៉ាត់ ក្នុងសម័យដែលពួកមេទ័ពកំពុងដណ្ដើមអំណាចគ្នានៅក្រុងរោម ។ ស៊ីសេរ៉ុងមានចិត្តគំនិតទន់បន្តិច តែស្មោះត្រង់សុចរិតនឹងមិត្តសំឡាញ់ ប៉ិននិយាយយ៉ាងឯកក្នុងសម័យនោះ លោកនេះបានតែងរឿងកវីទុកជាច្រើន ដែលមានមនុស្សនិយមរាប់អានរហូតមកដល់ឥឡូវនេះ ។

ការចលាចលផ្សេង ៗ ដូចបានពោលមកនោះបានស្ងប់ស្ងាត់ទៅវិញ ក្នុងកាលដែលប៉ុំប៉េត្រឡប់មកពីទ្វីបអាស៊ី ព្រោះក្នុងគ្រានោះប៉ុំប៉េមានជ័យជំនះយ៉ាងសំខាន់ ទើបជឿទុកចិត្តខ្លួនថា ខ្លួនឯងមានអំណាចបុណ្យស័ក្តិធំក្នុងគ្រានេះ លុះចូលមកដល់ក្រុងរោម ក៏លែងទាហានចេញអស់ទៅ តែគ្រាក្រោយទើបដឹងខ្លួនថាខ្លួនគិតខុស ព្រោះប៉ុំប៉េមិនបានមានអំណាចអ្វីឡើយ សុំអ្វីពីរដ្ឋបាល ៗ ក៏មិនព្រមអនុញ្ញាតឲ្យ ថែមទាំងមិនទទួលដឹងឮថាកិច្ចការដែលប៉ុំប៉េបានធ្វើមកហើយទុកជាត្រឹមត្រូវផង ។ កាលបើរដ្ឋបាលមិនបានទទួលដឹងអំពីកិច្ចការដ៏សំខាន់ ៗ ដែលប៉ុំប៉េបានធ្វើមកនោះ ប៉ុំប៉េក៏មានសេចក្តីតូចចិត្តជាពន្លឹក ប្រសិនបើមានកងទ័ពនៅក្នុងដៃគង់នឹងលើកទ័ពចូលក្រុងរោម ដូចជាមេទ័ពមុនៗធ្លាប់ធ្វើមកនោះជាមិនខាន តែគ្រានេះប៉ុំប៉េលែងទាហានចេញអស់ទៅហើយ ទើបត្រូវតែរត់ទៅរកក្រាស៊ុស (Crassus) ដែលជាសំឡាញ់របស់ខ្លួន ហើយថែមទាំងបានសេសារម្នាក់ទៀតយកជាបក្ខពួកផង ទើបរៀបចំតាំងគណៈរបស់ខ្លួនឡើង ហៅថា ត្រីយុមវីរ៉ាត់ (Triumvirat) ប្រែថា ក្រុម ៣ នាក់ ដោយមានគោលបំណងនឹងអូសទាញយកអំណាចស្រុកទេសមកនៅក្នុងកណ្តាប់ដៃ ។

សេសារជាក្មួយរបស់ម៉ារីយុស ជាកូនប្រសារបស់ស៊ីណ្ណា (Cinna) កើតក្នុងត្រកូលខ្ពង់ខ្ពស់មួយនៅក្រុងរោម ។ សេសារជាអ្នកប្រាថ្នាអំណាច

យ៉ាងខ្ពង់ខ្ពស់បំផុតក្នុងស្រុកទេស ទីងមានសេចក្ដីប្រកាន់ទុកក្នុងចិត្តថា ធ្វើជាមនុស្សលេខ ១ ក្នុងភូមិប្រសើរជាងលេខ ២ នៅក្រុងរោម ជាមនុស្សមានលក្ខណៈបើងរើងស្រូ ទីងមានសេចក្ដីឈ្លាសវៃជាងអ្នកទាំងពីរនេះ ។

សេចក្ដីប្រាថ្នានៃបុរសទាំង ៣ នាក់ ដែលមានបំណងចង់ធ្វើជានាយទៅហ្វាយធំនៅក្រុងរោមក៏ប្រាកដឡើង ព្រោះក្នុងពុទ្ធសករាជ ៤៨៤ (មុន គ.ស. ៥៩) សេសារបានទទួលដំណែងជាកុងស៊ុល ហើយជាអ្នកបញ្ជាការគង់ទ័ពប្រចាំស្រុកបំណកុះរបស់រោម ។ កិច្ចការដែលប៉ុមប៉េធ្វើមកក៏បានទទួលការរ៉ប់រងពីពឹកជការទាំងអស់ ។ ឯក្រាស្ស៊ុសនោះ បានទទួលនាទីឲ្យឃុំគង់ទ័ពទៅច្បាំងនឹងពួកប៉ារថ៍ស៍ (Parthes) ក្នុងទ្វីបដែលជាផ្លូវនាំមកនូវកោតសម្បូរ យ៉ាងស្ដុកស្ដម្ភ ។ កាលបើបុរសទាំង ៣ នាក់មានអំ-ណាចក្នុងក្រុងរោមហើយ ឯពួកកស្ត្រប្រជាក៏បានទទួលប្រយោជន៍ខ្លះដែរ គឺពីមុនមកដែលមានច្បាប់ហួងហែងទីដីកជការនោះ ក៏លើកលែងប្រើក្នុងគ្រានេះម្ដងទៀត ទើបទីដីកជការត្រូវកាត់បែងចែកឲ្យរាស្ត្រប្រជាដែលមានកូន តាំងពីចំនួន ៣ នាក់ឡើងទៅ ។ សភាសេណាត៍ទំកំងកវិធីបែងចែកទីដីនេះ តែអ្នកទាំង ៣ នាក់មានអំណាចខ្ពស់ជាងសភានេះទាំងមូល ឯស៊ីសេរ៉ុងដែលជាអ្នកទំប្រឹងរក្សាការពារសភានេះ ក៏ត្រូវអ្នកទាំង ៣នាក់និរទេសឲ្យចេញទៅនៅក្រៅក្រុងរោម ។ កាលសេសារបានលាចេញពី

ដំណែងកុងស៊ុលហើយ ក៏បានចេញទៅធ្វើជាអ្នកសម្រេចរាជការក្នុងប្រ-ទេសគោលស៊ីសាល់ពីន (Gaule Cisalpine) មានកំណត់ ៥ ឆ្នាំ ។ នៅឱកាសនោះ សេសារបានបង្ក្រាបក្នុងប្រទេសគោលទាំងមូលឲ្យរាបសារ ហើយ ទើបឆ្លងសមុទ្រទៅបង្ក្រាបដល់កោះអង់គ្លេសផង ។

តែក្រាស៊ុសដែលចេញទៅច្បាំងនឹងពួកប៉ាថេនោះ មានគ្រោះថ្នាក់ច្រើន ព្រោះបរាជ័យដល់ស្លាប់ខ្លួនផង ។ ឯប៉ុមប៉េបានទទួលនាទីជាអ្នកបញ្ជាការកងទ័ព ក្នុងប្រទេសអេស្ប៉ាញនោះនៅជាប់ចិត្តចង់បានអំណាចនៅក្រុងរោម ទើបមិនបានចេញទៅប្រចាំនាទីរបស់ខ្លួន ។

តមកនៅក្រុងរោមនោះ មានបុរសម្នាក់ឈ្មោះ ក្លូឌិយុស (Clodius) បានបបួលដឹកនាំឲ្យបណ្ដារាស្ត្របង្កការចលាចលឡើង កាលបើស្រុកទេសត្រូវការមនុស្សពូកែខាងការព្រាបព្រាម ទើបសភាសេណាត់បែរទៅពឹងប៉ុមប៉េជាកុងស៊ុល ដែលមានអំណាចពេញតែម្នាក់ ។ លុះសេសារត្រឡប់មកដល់ ត្រូវការឲ្យរាជការទទួលដឹងពីជ័យជំនះរបស់ខ្លួនដើម្បីទទួលដំណែងជាកុងស៊ុលផង តែប៉ុមប៉េមិនយល់ព្រម ទើបសេសារនិយាយថា បើដូច្នេះសុំឲ្យប៉ុមប៉េលាចេញពីដំណែងចុះ ខាងសេសារក៏លែងរវល់នឹងស្រុកទេសគោលទៀតដែរ តែប៉ុមប៉េក៏នៅតែមិនព្រមទទួលទៀត ហើយសំនិយាយនេះ នាំឲ្យរាជការបោះឆ្នោតបង្គាប់ឲ្យសេសារដោះលែងទាហានឲ្យអស់ទៅ ។ (មានត)

# ភូមិសាស្ត្រសង្ខេប

### នៃទ្វីបអាមេរិក

## ប្រទេសអាមេរិកខាងជើង

**អាណាខេត្ត**— ប្រទេសអាមេរិកខាងជើងនោះមានអាណាខេត្ត ទល់នឹងមហាសមុទ្រអាកទិកខាងជើង ទិសខាងលិចទល់នឹងមហាសមុទ្រប៉ាស៊ីហ្វិក ទិសខាងកើតទល់នឹងមហាសមុទ្រអាត្លង់ទិក ទិសខាងត្បូងទល់នឹងទ្វីបអាមេរិកខាងត្បូង (ប្រទេសកូឡុមប៊ី) ។

**ឃ្លាតនិងទំហំដី** — ឃ្លាតទទឹងដែលទូលាយបំផុត ប្រមាណ ៤.៩៦០ គីឡូម៉ែត្រ ។ ឃ្លាតបណ្ដោយដែលវែងបំផុត រាប់អំពីច្រោយបា-រៅ ក្នុងអាឡាស្កា រហូតដល់ប្រទេសប៉ាណាម៉ា ប្រមាណ ៦.៨៨០ គីឡូ-ម៉ែត្រ មានទំហំដីប្រមាណ ២៣.៩៥៧.៥០០ គីឡូម៉ែត្រក្រឡា តែជាចំណែកផែនដីរបស់អង់គ្លេសនៅក្នុងទ្វីបអាមេរិកខាងជើង ដល់ទៅប្រ-មាណ ៩.៧៦៦.៨៩០ គីឡូម៉ែត្រក្រឡា សហរដ្ឋអាមេរិកប្រមាណ ៧.៧០២.០៨០ គីឡូម៉ែត្រក្រឡា អាឡាស្កា ១.៥១៨.៧៧៦ គីឡូ-ម៉ែត្រក្រឡា កោះគ្រីនឡង់របស់ដាណឺម៉ាក ២.១៨៦.៥៨១ គីឡូម៉ែត្រក្រឡា, មេកស៊ិក ១.៩៨៦.៥៣០ គីឡូម៉ែត្រក្រឡា, អាមេរិកកណ្ដាល ៥៤៣.៩០០ គីឡូម៉ែត្រក្រឡា ពួកកោះផ្សេងៗ ២៤៣.៤៦០ គីឡូ-ម៉ែត្រក្រឡា ។

មាត់ច្រាំងសមុទ្រ — មាត់ច្រាំងសមុទ្រទិសខាងលិច ច្រើនមានកំពស់ខ្ពស់ៗ ក្បែរៗមាត់ច្រាំងមានទឹកជ្រៅ កប៉ាល់នាវាទាំងតូចធំចូលចតទីកំពង់បានដោយស្រួល ។ ឯមាត់ច្រាំងសមុទ្រទិសខាងកើតច្រើនរាក់ៗ មានដីខ្សាច់លយចូលទៅក្នុងសមុទ្រ ជាហេតុឲ្យនាវាសមុទ្រចតនៅឆ្ងាយពីមាត់ច្រាំង ហើយមាត់ច្រាំងទិសខាងកើតនេះច្រើនតែមានឈូងលូកចូលបត់បែន មានភ្នាគតូចធំមានចំនួនច្រើនជាងមាត់ច្រាំងទិសខាងលិច ។

ឈូងសមុទ្រ — ឈូងធំៗ គឺឈូងហ៊ុតសុន ខាងជើង, សាំង-ឡូរ៉ង់, អាឡាស្កា, មេក្ស៊ិក បេរ៉ែត្រស និងហុងឌូរ៉ស ទិសខាងកើត និងឈូងកាលីហ្វរនី, ឈូងប៉ាណាម៉ា ទិសខាងលិច ។

ជ្រោយ — ជ្រោយបារ៉ៅ ជាជ្រោយដែលលយចេញឆ្ងាយបំផុតនៅទ្វីបអាមេរិកទិសខាងជើង, ជ្រោយអាឡាស្កាជាជ្រោយលយចេញវែងបំផុតនៅទិសខាងលិច, ជ្រោយគុត ជាជ្រោយលយវែងបំផុតនៅសហ-រដ្ឋអាមេរិកទិសខាងកើត, ជ្រោយសាប៊ឺ ជាជ្រោយលយចេញវែងបំផុតនៅទ្វីបសហរដ្ឋអាមេរិកខាងត្បូង ។

សមុទ្រ — សមុទ្រប៊េរិង នៅចន្លោះអាឡាស្កា និងស៊ីប៊េរី, សមុទ្រអង់ទីយ៍ នៅចន្លោះពពួកកោះ និងអាមេរិកកណ្ដាល និងអាមេរិកខាងត្បូង សមុទ្រប៊ែបហ្វីននៅខាងជើងឆៀងខាងកើត ។

**ច្រកសមុទ្រ** — ទិសខាងលិចច្រកបេរ៉ិង ទិសខាងជើងមានឡាំងកាស្ទ័រ, ហ៊ុតសុននិងដាវិស, ទិសខាងកើតមានច្រកសាប៊្វ័លនៅចន្លោះប្រ៉ាដរ័ននិងហាវ៉ែ និងច្រកហ្វ្លរីត ៗ

**កោះ** — ទិសខាងជើងមានកោះគ្រីនឡង់ និងពពួកកោះអាទិក, ទិសខាងកើតមានកោះតែរ៉េនើវ, ប្រ៉ាំងឥតក៏ត, កាប់ព្រឺតុង, ឡុង, ទិសខាងលិចមានកោះវ៉ែនគូវ៉ែ, វ៉ែនសាឡុត ៗ

**លក្ខណៈផែនដី** — ផ្ទៃផែនដីនៃទ្វីបអាមេរិកខាងជើង មានលក្ខណៈជាដីកបខ្ពស់ ១ ចំណែក មានផ្ទៃដីជាដីកបទំនាប ១ ចំណែក តំបន់ដែលជាដីកបខ្ពស់ ច្រើនប្រកបដោយជង្គង់ភ្នំខ្ពស់ៗ និងច្រកភ្នំជ្រៅៗជាចំនួនច្រើន ក្នុងតំបន់ដូច្នេះ ប្រជាជនច្រើនរកបរបចិញ្ចឹមជីវិតដោយការចិញ្ចឹមសត្វ, កាប់ឈើនិងជីករ៉ែ ៗ ចំណែកខាងផែនដីនៅតំបន់ទិសខាងកើតដែលជាទីទំនាប មានភ្នំខ្លះនៅជាយអន្លើជិតមាត់ច្រាំងសមុទ្រ តែជាភ្នំមិនធំខ្ពស់ដូចភាគផែនដីទិសខាងលិចទេ ហើយនៅតាមបរិវេណភ្នំអស់នោះជាទីទួលខ្លះដែរបន្តិចបន្តួច ភាគផែនដីទិសខាងកើតនេះ ជាទីដីមានដីជាតិល្អ ព្រោះជាដីទំនាបមានផ្លូវទឹកបរិបូណ៌ផង ៗ ការធ្វើស្រែចំការ ច្បារដំណាំ មាននៅតាមតំបន់អស់នោះជាច្រើន ៗ

ភ្នំ — ១ ជួរភ្នំវែងបំផុតនៅទ្វីបអាមេរិកខាងជើង គឺជួរភ្នំរ៉ុកគីស៍ ភ្នំនេះខ្ពុកជួបជាច្រើនជួរនិងខ្ពង់រាបខ្ពស់ទិសខាងលិច លាតចេញមកពីប្រទេសអាឡាស្កា ចុះមកតាមដងកខ្ពស់ កាត់ប្រទេសកាណាដា និងសហរដ្ឋអាមេរិក រហូតដល់ប្រទេសមេក្សិក ជារយៈវែងប្រមាណ ៦.៤០០ គីឡូម៉ែត្រ បណ្តាជ្រោះទឹកសំខាន់ៗ នៅទ្វីបអាមេរិកខាងជើង មានកំណើតចេញមកអំពីជួរភ្នំដ៏ធំមហិមានេះស្ទើរតែទាំងអស់ ។ មួយវិញទៀត ជួរភ្នំនេះបរិបូណ៌ដោយលោហធាតុដ៏មានដំឡៃជាច្រើនយ៉ាង គឺមាស, ប្រាក់, សំណ, ទង់ដែង, ត្បូង ។

២-ភ្នំនៅក្បែរសមុទ្រទិសខាងលិច គឺភ្នំស៊ីយែរ៉ាណេវ៉ាដា ដែលជាជួរភ្នំលាតចេញមកពីទិសខាងជើងនៃប្រទេសកាណាដា រហូតដល់ទិសខាងត្បូងនៃទ្វីបសហរដ្ឋអាមេរិក និងភ្នំស៊ីយែរ៉ាម៉ាដ្រេក្នុងប្រទេសមេក្សិក ។

៣ — ភ្នំអាល្ល៉េយានី ជាជួរភ្នំវែងប្រមាណ ២.៤០០ គីឡូម៉ែត្រ តែមិនសូវខ្ពស់ទេ (កំពូលដែលខ្ពស់បំផុតមានកំពស់ត្រឹម ២.០១៣ម៉ែត្រ) តាំងនៅស្ទើរមាត់សមុទ្រទិសខាងកើតនៃសហរដ្ឋអាមេរិក ។ ជួរភ្នំនេះជាកំណើតមានជ្រោះទឹកសំខាន់ៗ ជាច្រើន ហើយបរិបូណ៌ដោយលោហធាតុ គឺត្បូង, ប្រេងនិងកាសធូនេះ ។

៤ – ភ្នំនៅអាមេរិកកណ្ដាល មានភ្នំភ្លើងជាច្រើន ។ ឯកំពូលភ្នំដែលខ្ពស់បំផុតនៅទ្វីបអាមេរិកខាងជើងក្នុងដែនអាឡាស្កា មានកំពស់ ៦.១៣៩ ម៉ែត្រ ។

ទន្លេ – ទន្លេចែកចេញជា ៥ ពួក គឺ

១ – ពួកទន្លេដែលហូរធ្លាក់ទៅក្នុងមហាសមុទ្រអត្លង់ទិក ។

២ – ពួកទន្លេដែលហូរធ្លាក់ទៅក្នុងឈូងសមុទ្រមេក្សិក ។

៣ – ពួកស្ទឹង, ទន្លេដែលហូរធ្លាក់ទៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ។

៤ – ទន្លេ, ស្ទឹងដែលហូរធ្លាក់ទៅក្នុងមហាសមុទ្រអាទិក ។

៥ – ទន្លេ, ស្ទឹងដែលហូរធ្លាក់ទៅក្នុងឈូងសមុទ្រហ៊ុតសុង ។

ទន្លេដែលវែងបំផុតនោះ នៅក្នុងប្រទេសសហរដ្ឋអាមេរិក ហៅថា មិស្សិស្សិពី មានបណ្ដោយប្រមាណ ៦.៧២០ កិឡូម៉ែត្រ ចាត់ជាទន្លេវែងបំផុតក្នុងលោក ។

ទន្លេសាប – ១ – ទន្លេសាបក្នុងប្រទេសកាណាដា គឺទន្លេសាបគ្រង់អួស៍, អាថាបាស្កា, វិន្នីប៉ែក, ម៉ានីតូបាជាដើម ។

២ – ទន្លេសាបនៅចន្លោះកាណាដា និងសហរដ្ឋអាមេរិក គឺទន្លេសាបស៊ុប៉េរីយើរ (ជាទន្លេទឹកសាបដែលធំបំផុតក្នុងលោក មានទំហំប្រមាណ ៨២.៨៨០ កិឡូម៉ែត្រក្រឡា) ។

៣-ទន្លេសាបក្នុងសហរដ្ឋអាមេរិក គឺទន្លេសាបក្រង់ឡក់សាលេ ។

៤-ទន្លេសាបក្នុងប្រទេសមេក្សិក និងអាមេរិកកណ្តាល មានតិចដែលសំខាន់ជាងគេ គឺទន្លេសាបនិការ៉ាក្ហ ។

ខ្យល់អាកាស — ១ - អាមេរិកកណ្តាលនិងពួកកោះនៅទិសខាងលិច និងខាងត្បូងស្រុកមេក្សិក មានអាកាសក្តៅ និងមានទឹកភ្លៀងច្រើន ប្រហែល ៗ និងឥណ្ឌូស៊ិននេះដែរ ។

២-សហរដ្ឋអាមេរិក មានអាកាសយ៉ាងមធ្យម តាំងនៅក្នុងតំបន់មានអាកាសអ៊ុន ។

៣ កាណាដា និងអាឡាស្កា មានអាកាសត្រជាក់រងាខ្លាំងក្នុងរដូវរងា ព្រោះផែនដីតំបន់អស់នោះ ចូលទៅក្នុងដែនរងាខ្លាំង ហើយមានខ្យល់ត្រជាក់បក់មកពីឯជើងផង ។

ទឹកភ្លៀង — ភ្លៀងមានធ្លាក់ច្រើននៅតំបន់មាត់ព្រំសមុទ្រ ចំណែកខាងមហាសមុទ្រប៉ាស៊ីហ្វិក និងតំបន់មាត់ព្រំសមុទ្រខាងមហាសមុទ្រអត្លង់ទិក ។

១ — ផលាផលផែនដី មានដាំដំណាំស្រុកត្រជាក់ ដំណាំស្រុកក្តៅ ដែលសំខាន់ គឺស្រូវសាលី, ពោត, ថ្នាំជក់ ដំឡូងបារាំង កប្បាស, ទំពាំងបាយជូរ, អំពៅ, កាហ្វេ, ស្រល់ ជាដើម ។ ល ។

២ - លោហធាតុ - ទ្វីបអាមេរិកខាងជើងបរិបូណ៌ដោយលោហធាតុច្រើនយ៉ាង នៅតំបន់ជីកបន្ទស់ទឹងតាមភ្នំនៅទិសខាងលិចនោះ មាន មាស, ប្រាក់, អំបិល, ទង់ដែង ។ល។ នៅតំបន់ជីកបទិសខាងកើត មានធ្យូងថ្ម, ដែក, ប្រេង ទឹងទីកែលជាច្រើន ក្រៅអំពីនេះមានបារ៉ែត, សំណ, និលជាដើម ។

សត្វ - ពួកសត្វព្រៃមានប្រមា, ក្របី, ខ្លាឃ្មុំ, សុនខព្រៃ, ឆ្កែចចក, ក្ដាន់, ខ្លាខ្មៅ សត្វស្លាបផ្សេងៗ, ស្វា ។ល។ សត្វចិញ្ចឹមដែលសំខាន់ គឺគោ, សេះ កែះ ជ្រូក, មាន់, ទា ។

ត្រីផ្សេងៗមានច្រើនក្នុងសមុទ្រទឹងក្នុងទន្លេភាគខាងលិច ទឹងភាគខាងកើត ។

ប្រជាជន — មានច្រើនជាតិច្រើនភាសា ឯជាតិអ្នកស្រុកនោះ គឺពួកអេស្គីមោ ដែលអាស្រ័យនៅតាមត្រើយមហាសមុទ្រអាទិកទឹង ផងជាតិឥណ្ឌៀក្រហម ដែលអាស្រ័យនៅតាមទីតំបន់ទូទៅ, ឯពួកជាតិដែលមកនៅថ្មី ជាពួកឥរុបដោយច្រើន មានជាតិអង់គ្លេស អល្លឺម៉ង់ បារាំងសែស អេស្ប៉ាញ៉ុលជាដើម ពួកជាតិទ្វីបឯទៀតមកនៅក្នុងទ្វីបនេះក៏ច្រើន គឺណែគ្រ៍, ចិនទឹងជប៉ុនជាដើម រួមប្រជាជនទាំងអស់មាន ប្រមាណ ១៨០.០០០.០០០ នាក់ ។ ចប់

# ប្រវត្តិឧបាសក-ឧបាសិកា

ជាសាវកសាវិការបស់ព្រះពុទ្ធជាម្ចាស់

(តមក)

៩ — ជីវក-កោមារភច្ចៈ ជាអ្នកស្រុកក្រុងរាជគ្រឹះ ជាបុត្រនាងសាលវតីនិងអភយរាជកុមារ មានរឿងដំណាលថា នាងសាលវតីជាស្រីពេស្យា លុះនាងមានផ្ទៃពោះជិតស្រាលក៏គិតថា បើកូនដែលស្រាលមកជាប្រុសនឹងយកទៅបោះចោល បើជាកូនស្រីនាងនឹងចិញ្ចឹមទុក ។ លុះដល់នាងស្រាលកូនមកជាប្រុស ទើបបង្គាប់ទាសីឲ្យលើកកូនដាក់កន្ទ្រកហើយឲ្យនាំយកទៅចោលឯគំនរសម្រាម ។ វេលានោះ អភយរាជកុមារទៅគាល់ស្តេច បានឃើញក្អែកនិងសុនខចោមរោមនៅទីនោះ ទ្រង់ស៊ើបសួរទៅបានសេចក្តីថា មានកូនប្រុសម្នាក់នៅរស់នៅឡើយដេកនៅត្រង់កន្ទ្រកនោះ ទើបមានបន្ទូលឲ្យយកទៅចិញ្ចឹមក្នុងដំណាក់របស់ទ្រង់ ទ្រង់ប្រទានឈ្មោះថា ជីវកៈ ព្រោះហេតុតែព្រះអភ័យរាជកុមារទ្រង់រើសទៅចិញ្ចឹម ទើបមានថែមពាក្យថាកោមារភច្ចៈ ជា ជីវក-កោមារភច្ចៈ ។ លុះបានអាយុ ១៦ ឆ្នាំក៏ចេញទៅសិក្សាវិជ្ជាពេទ្យនៅក្រុងតក្កសិលា ដល់រៀនសម្រេចត្រឡប់មក ទើបត្រូវគេលើកដំកើងជាគ្រូពេទ្យដ៏ខ្ពង់ខ្ពស់បំផុតក្នុងដំណាក់ព្រះបាទពិម្ពិសារ ធ្លាប់បានទៅរក្សាអង្គព្រះបាទចណ្ឌប្បជ្ជោត ដែលគ្រូពេទ្យឯទៀតៗមិនអាចថែរក្សាឲ្យសះជាបាន មានកេរ្តិ៍

ឈ្មោះល្បីល្បាញ បានលាភសក្ការៈជាច្រើនក្នុងគ្រានោះ ។ កាលសម្តេចព្រះបរមសាស្តាស្តេចគង់នៅក្នុគិជ្ឈកូដ ក្រុងរាជគ្រឹះ គ្រូពេទ្យជីវក-កោមារភច្ចៈ បានផ្សំថ្នាំថ្វាយព្រះអង្គ ទាំងបាននិមន្តឲ្យព្រះបរមសាស្តាប្រថាប់នៅវិហាររបស់ខ្លួនផង បានទំនុកបំរុងព្រះភិក្ខុសង្ឃដោយល្អ ។ គេអាចពោលបានថា បណ្តាបុថុជ្ជនសាមញ្ញធម្មតាដែលមានចិត្តជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ជីវក-កោមារភច្ចៈ ទុកជាអ្នកជ្រះថ្លាយ៉ាងក្រៃលែង គ្មានអ្នកដទៃស្មើទេ អាស្រ័យហេតុនេះ ទើបព្រះបរមសាស្តាទ្រង់តាំងលោកក្នុងឯតទគ្គដ្ឋាន ប្រសើរលើសលែងជាងពួកឧបាសកបុថុជ្ជនដែលជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។

ចប់ប្រវត្តិសង្ខេបរបស់ជីវក- កោមារភច្ចៈតែប៉ុណ្ណេះ ។

**១០– នកុលបិតា·គហបតី** កើតក្នុងត្រកូលសេដ្ឋី ជាអ្នកស្រុកសុង្សុមារគិរៈ ក្នុងដែនភគ្គៈ ។ សម្តេចព្រះបរមសាស្តាព្រមដោយភិក្ខុសង្ឃ ស្តេចយាងដល់នគរនោះ ស្តេចប្រថាប់នៅភេសកឡាវ័ន ។ ឯនកុលបិតា-គហបតីព្រមដោយអ្នកស្រុកសុង្សុមារគិរៈនាំគ្នាទៅកាន់សំណាក់ព្រះបរមសាស្តា គ្រាន់តែបានឃើញព្រះបរមសាស្តាគ្រាដំបូង ក៏រត់ទៅឱបព្រះបាទទាំងពីរទាំងប្រពន្ធ ហើយនាំគ្នាស្រែកហៅថា កូនៗ ម្តេចក៏កូនទៅណាបាត់ចោលឪពុកម្តាយយូរម្ល៉េះ ។ ហេតុដែលគាត់ពក់ហៅព្រះប-

មេសាស្តាថា កូនៗ ដូច្នោះ ព្រោះស្វាមីភរិយាទាំងពីរនោះធ្លាប់ធ្វើជាមាតាបិតារបស់ព្រះពោធិសត្វមកជាច្រើនជាតិ សេចក្តីស្រឡាញ់ស្នេហាពីជាតិមុនៗនោះជាប់តាក់ទងហូតមកដល់ជាតិជាបច្ចុប្បន្ននេះ ។ សម្តេចព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែងព្រះធម្មទេសនា ស្វាមីភរិយាទាំងពីរនាក់ក៏បានសម្រេចសោតាបត្តិផល ។

លុះចំណេរកាលតមក ស្វាមីភរិយាទាំងគូមានអាយុច្រើនហើយ សម្តេចព្រះបរមសាស្តាស្តេចយាងទៅកាន់គន្ធនគរម្តងទៀត ជនទាំងពីរបានដឹងដំណឹង ក៏ចូលទៅគាល់ព្រះបរមសាស្តា ហើយបានដុបលៀងព្រះភិក្ខុសង្ឃជាច្រើន បានសំដែងអាការស្និទ្ធស្នាលនឹងព្រះភិក្ខុសង្ឃ ពោលពាសំណេះសំណាលនាំឲ្យកើតសេចក្តីស្និទ្ធស្នាលជាយ៉ាងក្រៃពេក ។ អាស្រ័យហេតុនេះ ទើបព្រះបរមសាស្តាទ្រង់តាំងក្នុងដំណែងឯតទគ្គដ្ឋានប្រសើរលើសលែងជាងបណ្តាឧបាសកដែលជាអ្នកពោលពាសំណេះសំណាលនាំឲ្យកើតសេចក្តីស្និទ្ធស្នាល ។

ចប់ប្រវត្តិសង្ខេបរបស់នកុលបិតា-គហបតីតែប៉ុណ្ណេះ ។

# ប្រស្នាចំរើនសតិបញ្ញា

## ប្រស្នាទី ២

សួរថា ខ្វាក់និងខ្វិន តើខាងណាគ្រាន់បើជាងខាងណា?

## សេចក្ដីឆ្លើយទី ១

មានពាក្យចោទសួរថា ខ្វាក់ហើយនិងខ្វិន តើខាងណាគ្រាន់បើជាងខាងណា?— ខ្ញុំបាទបានត្រិះរិះដោយសព្វគ្រប់ទៅ យល់ថាខ្វិនដូចជាគ្រាន់បើជាងខ្វាក់បន្តិច ដែលថាខ្វាក់ៗនេះ សំដៅយកខ្វាក់តាំងសងខាងតាំងពីកំណើតមក, ឯខ្វិនដើរមិនរួចនោះសោតទៀត ក៏សំដៅយកខ្វិនតាំងពីកំណើតមកដែរ ។ កាលបើប្រៀបធៀបសេចក្ដីទុក្ខ-លំបាកក្នុងការចិញ្ចឹមជីវិត ដែលជាប្រយោជន៍ខ្លួននិងប្រយោជន៍អ្នកដទៃ ល្បងមើលទៅខ្ញុំបាទយល់ថា ខ្វិនមានជាងខ្វាក់ ព្រោះខ្វាក់មើលមិនឃើញអ្វីសោះនោះ ទិងអង្គុយ ឬនិងឈរ តោងប្រើដៃស្ទាបនេះស្ទាបនោះ បើមិនស្ទាបក្រែងប៉ះទង្គិចនេះនោះ ម្យ៉ាងហើយរំលោភផ្លាស់ប្ដូរឥរិយាបថម្ដងៗតែងតែប្រយ័ត្នជានិច្ច មើលទៅក៏លំបាកសែនលំបាកពេក បើនឹងក្រោកដើរទៅណាមកណា ក៏គោងតិប គុបទ្ទីមទាម គ្មានអ្នកដឹកដៃគ្មានបានឈានដើរដើរទេ តាំងមិនស្គាល់ទិសខាងលិច ខាងកើត ខាងជើង ខាងត្បូងផង ។ បើទុកជាអ្នកក្រែកខ្វាក់នោះ ចេះសង្កេតចំណាំពូកែយ៉ាងណាក៏ដោយ បើដើរចេញទៅកាន់ទីប្រ-ជុំជន មុខជាមិនផុតពីគ្រោះថ្នាក់ឡើយ ដូចជាផ្លូវឡូហ៊ីយោ ក្រែងក្នុងពេញ

ដែលមានមនុស្សដើរមើរដើរដាស ទាំងរថត្រីចក្រយាន រថយន្ត ទោចក្រ យានបរបើកចុះឡើងជាប្រចាំ មនុស្សម្នាក់ក្នុងទាំងសងខាង មុខជាប៉ះ ទង្គិចឬត្រូវបុកនឹងស្លាប់ ឬបាក់ដៃបាក់ជើងជាមិនខាន ៗ បើដើរទៅតាមផ្លូវ ដើរផ្លូវប្រែក តែងតែប៉ះនេះប៉ះនោះ ឬដើរជាន់កូនឆ្កែកូនឆ្មាដែលរត់ដេកនឹង ផ្លូវស្លាប់ក៏មាន ឬចំពប់ដួលដល់បែកមុខមាត់ក៏មាន បើទុកជាមានព្យាយាម ឧស្សាហ៍រៀនសូត្រវិជ្ជាសម្រាប់ចិញ្ចឹមជីវិត ក៏រៀនបានតែត្រឹមកូតទ្រ, ផ្លុំខ្លុយ, ដេញចាប៉ី, ផ្លុំស្រឡៃ, វាយសំភោរ, ស្គរ, រនាត, គងប៉ុណ្ណោះ នឹង រៀនសូត្រវិជ្ជាដែលថ្លៃថ្លាជាងនេះទៅទៀតពុំបានឡើយ សេចក្ដីលំបាក របស់មនុស្សម្នាក់នឹងពណ៌នាតទៅទៀតវែងឆ្ងាយណាស់ ទើបខ្ញុំបាទស្នើត្រឹម ពិត្តចូលខាងពួកមនុស្សខ្វិន ៗ

ឥឡូវនេះ ខ្ញុំបាទនឹងសូមអធិប្បាយពីយោបល់ដែលយល់ថា ខ្វិន គ្រាន់បើជាងខាងខ្វាក់ឲ្យស្ដាប់គេទៅ ពិតមែនតែខ្វិនដើរទៅណាមកណាមិន រួច គេនឹងទទួលនូវទុក្ខវេទនាដែរ តែមានភ្នែកមើលឃើញអ្វីនឹងចាំអ្វីៗបាន គ្រប់ជំពូក ៗ បើមានព្យាយាមរៀនវិជ្ជាអក្សរសាស្ត្រ ឬរៀនវេទនានឹងគំ-នូរគូរក់សាផ្សេងៗ ឬរៀនដេរប៉ាក់ត្បាញជាដើម ក៏ល្មមជាប្រយោជន៍ស-ម្រាប់ចិញ្ចឹមជីវិតបានដោយងាយ មិនបាច់ដើរសាត់អណ្ដែតទៅសុំទានគេ ចិញ្ចឹមជីវិតដូចមនុស្សខ្វាក់ទេ ដោយហោចទៅគ្រាន់តែបង្រៀនអក្សរ ក្មេងៗរបស់អ្នកស្រុកដែលនៅផ្ទះជិតខាងគ្នាក៏បាន មាតាបិតារបស់ក្មេង

អស់នោះគង់ជួយចិញ្ចឹមបាយទឹក ឬសំពត់អាវប្រាក់កាស់សម្រាប់ចាយវាយមិនឲ្យលំបាកវេទនាពេកដែរ ប្រសិនបើគ្មានវិជ្ជាអ្វីសោះ ដោយហោចទៅ គ្រាន់តែនៅចាំផ្ទះឲ្យគេ ៗ ក៏ឲ្យទានអាហារព្រឹកល្ងាចមិនឲ្យអត់ឃ្លានដែរ ជាប្រយោជន៍ខ្លួននឹងប្រយោជន៍អ្នកដទៃផង ។ នេះពោលចំពោះតែមនុស្សខ្វាក់ឬខ្វិន ដែលជាអ្នកទីទ័លក្រឬជាមនុស្សអនាថា ។ បើពោលដល់មនុស្សខ្វាក់ដែលមានសម្បត្តិស្តុកស្តម្ភ ប្រៀបធៀបនឹងមនុស្សខ្វិនដែលមានសម្បត្តិដូចគ្នា អ្នកខ្វិនក៏នៅតែគ្រាន់បើជាងអ្នកខ្វាក់ដែរ ។ ធម្មតាអ្នកខ្វាក់ដែលមានសម្បត្តិនោះ ទោះជានៅតែនឹងផ្ទះក៏មិនសូវមានប្រយោជន៍អ្វីឡើយ គ្រាន់តែហាមាត់ហៅបាវព្រាវថា មកណេះវ៉ើយ ទៅណោះបន្តិច យកនេះមកឲ្យបន្តិច នឹងបង្គាប់ការងារអ្វីមិនបានឡើយ ព្រោះភ្នែកមើលមិនឃើញ បានតែនិយាយត្អូញត្អែរអែតអត់ប៉ុណ្ណោះឯង ។ ចំណែកឯអ្នកខ្វិន ដែលមានសម្បត្តិនោះមានប្រយោជន៍ច្រើនយ៉ាងណាស់ គឺបង្គាប់បញ្ជាការងារបានគ្រប់ជំពូក បង្គាប់អ្នកនោះធ្វើការនេះ អ្នកនេះធ្វើការនោះ បាវព្រាវធ្វើការល្អអាក្រក់ដឹងទាំងអស់ និងស្តីប្រដៅមនុស្សម្នាបានទាំងអស់ បាវព្រាវក៏មានសេចក្តីកោតខ្លាច មិនអាចប្រមាថមើលងាយទេ ទុកជាដើរទៅណាមិនបាន តែភ្នែកអាចមើលឃើញអ្វីៗគ្រប់យ៉ាងបានជារបស់សំខាន់ណាស់ ហេតុដូច្នោះបានជាខ្ញុំបាទសូមវិនិច្ឆ័យដាច់ស្រេចថា ខ្វិនគ្រាន់បើជាងខ្វាក់ ដោយប្រការដូច្នេះឯង ។ ឆាយខ្វិន

# រឿងចៅម្ចាស់ផ្ទះនិងចៅសុំសំចត

មានទិតានមួយដំណាលថា មានបុរសម្នាក់ទើបនឹងសង់ផ្ទះហើយថ្មីៗ គាប់ជួនមានបុរសម្នាក់ទៀត ចូលមកសុំសំណាក់នឹងផ្ទះនោះ ។ ឯចៅម្ចាស់ផ្ទះក៏ព្រមឲ្យសំចតៈហើយរួបរួមជាមួយគ្នាក្នុងផ្ទះនោះទៅ ។ ចៅសុំសំចតលុះនៅបានយូរបន្តិច ក៏គាំងរកបអស់គ្រឿងផ្ទះ ទូរទូតនោប, ពោប, បន្ទំ, ផ្តៅង, ផ្ទាន, ឆៃពណង, មានតំណឥតតំណ, ទូស្ទីកប្រក់ខ្មួចសព្វគ្រប់ ក៏កត់សំគាល់ទុកជាចំណាំ ។ លុះនៅជាអម្ចុង បាន ១ ខែទៅ ចៅម្ចាស់ផ្ទះក៏ស្រដីថា ចៅមកនៅសំចតនឹងអញនេះយូរអង្វែងហើយ ចូរចៅទៅស្រុកចៅវិញចុះ ។ ឯចៅសុំសំចតឆ្លើយថា ផ្ទះនេះជាផ្ទះរបស់អញ ម្តេចក៏ចៅថាជាផ្ទះរបស់ចៅវិញ ។ ចៅទាំងពីរក៏កើតទៅជាឈ្លោះតាស់ទែងដណ្តើមផ្ទះគ្នា ទើបនាំគ្នាឡើងទៅប្តឹងចៅក្រមឲ្យជំនុំជំរះ ។

ចៅម្ចាស់ផ្ទះប្តឹងថា ផ្ទះនោះជាផ្ទះរបស់ខ្ញុំប្របាទទើបសង់ថ្មី ចៅនេះចូលមកសុំសំចតអស់អម្ចុង ១ ខែពុំព្រមចេញឡើយ ហើយខ្ញុំប្របាទប្រាប់ឲ្យចេញ ក៏នៅតែពុំព្រមចេញ ហើយចៅនេះប្រកាន់យកផ្ទះរបស់ខ្ញុំប្របាទថាជារបស់ខ្លួន ។

ចៅសុំសំចតប្តឹងថា ផ្ទះនោះខ្ញុំប្របាទទើបសង់ថ្មី ចៅនេះមកសុំសំ-ចតអស់អម្ចុងខែ ១ ហើយដណ្តើមយកផ្ទះនោះអំពីខ្ញុំប្របាទ សូមគាន

ះមក្កាព្រាស បើចៅនេះប្រកាន់ថាជាផ្ទះរបស់ខ្លួន តើចៅនេះដឹងទេ អស់ទាំងគ្រឿងផ្ទះប៉ុន្មានតំណ រនូតរនាប បង្គន់ ខ្លប ស្លឹកក្នុងផ្ទះនោះមានប៉ុន្មាន ។

ចៅម្ចាស់ផ្ទះឆ្លើយតបទៅចៅក្រមថា ខ្ញុំប្របាទពុំបានកប់ទេ តែផ្ទះនោះពិតជារបស់ខ្ញុំប្របាទប្រាកដមែន ។ ចៅក្រមក៏ដណ្ដឹងសួរទៅចៅសុំសំបកថា បើចៅប្រកាន់ថាជាផ្ទះរបស់ចៅ តើចៅដឹងទេ អស់គ្រឿងផ្ទះនោះមានប៉ុន្មាន? ឯចៅសុំសំបក ហេតុតែខ្លួនបានកត់សំគាល់ចំណាំទុកពីមុនមកស្រេច ក៏ឆ្លើយត្រូវទាំងអស់ ។ ឯចៅក្រមយល់ថា ប្រហែលជាចៅនេះជាម្ចាស់ផ្ទះមែន ទើបចាំបានសព្វគ្រប់អស់ទាំងគ្រឿងផ្ទះ ទើបកាត់សេចក្ដីឱ្យបានទៅចៅសុំសំបកនោះ ។ ឯចៅម្ចាស់ផ្ទះពុំសុខចិត្តឡើយ ទើបនាំរឿងនោះក្រាបបង្គំទូលដល់សម្ដេចព្រះមហាក្សត្រ ។

ទើបសម្ដេចព្រះមហាក្សត្រទ្រង់ព្រះចិន្ដាថា ហេតុអ្វីក៏ចៅមួយនេះចាំអស់គ្រឿងផ្ទះសព្វគ្រប់ម៉្លេះ ហើយទ្រង់ត្រាស់សួរថា អើ ចៅចាំគ្រឿងផ្ទះបានហ្មត់ចត់ល្អណាស់ តែឯជើងសសរខាងក្នុងរណ្ដៅនោះតើមានអ្វីខ្លះឬទេ ។ ចៅសុំសំបកក្រាបបង្គំទូលថា គ្មានអ្វីនៅក្នុងរណ្ដៅទេ ។ ទើបទ្រង់ត្រាស់សួរទៅចៅម្នាក់ទៀតថា ចៅថាផ្ទះនោះជារបស់ចៅ តើចៅបានដាក់អ្វីនៅជើងសសរខ្លះដែរឬទេ ។ ចៅម្ចាស់ផ្ទះក្រាបបង្គំទូលថា ក្នុងរណ្ដៅខាងជើងទិសអគ្នេយ៍នោះជាទីខាងកក់ដែកទន់ព្រាយ ទើបទូល

ព្រះបន្ទំជាខ្ញុំយកឈើ ១ កំណាត់ដាក់នៅបាតសសរ ដើម្បីកុំឲ្យរេកស្រុត ។ ទ្រង់ត្រាស់ថា បើមានកំណល់នៅដើមសសរដូច្នោះមែនត្រូវទៅដកដើមសសរនោះមើល តើជាមានមែនឬគ្មានទេ ។ លុះដកទៅក៏បានឃើញកំណល់គល់ដើមនោះមែន ទើបត្រាស់វិនិច្ឆ័យថា ហេតុតែផ្ទះនោះជារបស់ចៅនេះមែនបានជាចាំបានដល់ក្នុងដី ឯចៅមួយនោះពិតជាមិនមែនជាម្ចាស់ទេ ទើបចាំបានតែគ្រឿងខាងលើពុំដឹងដល់ខាងក្នុងដី ហេតុនេះត្រូវបានផ្ទះទៅចៅដែលដឹងដល់គ្រឿងផ្ទះដែលនៅក្នុងដី ឯចៅមួយនោះជាអ្នកឆបោកគេ ត្រូវមានទោសទាំងត្រូវពិន័យតាមច្បាប់ ។

ចៅទាំង ២ នាក់ក៏សុខចិត្ត ហើយក្រាបថ្វាយបង្គំលាទៅលំនៅរបស់ខ្លួនហោង ។

ចប់និទាននេះតែប៉ុណ្ណេះ ។